# ព្រះត្រៃបិដក

## ប្រែរួមនឹង

# ព្រះអដ្ឋកថា

## ភាគ៤៤

បាលីប្រែ ៥៧

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# ថេរគាថា ឆដ្ឋមភាគ

# ៤៤

# បាលីប្រែ ៥៧



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤៤

# សុត្តន្តបិដក

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ខុទ្ទកនិកាយ ថេរីគាថា ឯកនិបាត

## អញ្ញតរាថេរីគាថា

*[ ២៦៦ ] ម្នាលថេរី នាងចូរដេកលក់ស្រួល នាងចូរធ្វើ ( ចីវរថេរី ) ដោយសំពត់ ( បង្សុកូល ) ហើយស្លៀកដណ្តប់ចុះ ព្រោះរាគៈរបស់នាងស្ងប់រម្ងាប់ហើយ ដូចជាបន្លែស្ងួតក្នុងឆ្នាំង ។*

*ឮថា ភិក្ខុនីមួយរូបជាថេរី មិនប្រាកដ ( ដោយនាមនិងគោត្តជាដើម ) បានពោលគាថា មានបការៈដូច្នេះ ។*

# ខុទ្ទកនិកាយ បរមត្ថទីបនី អដ្ឋកថា

# ថេរីគាថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## ឯកនិបាត

## អញ្ញតរាថេរីគាថា

[ ២៦៦ ] ក្នុងឯកនិបាត មានវិនិច្ឆ័យដូចតទៅនេះថា

ឥឡូវនេះ ដល់ឱកាសដែលនឹងពណ៌នាអត្ថថេរីគាថា តាមលំដាប់ហើយ ព្រោះក្នុងថេរីគាថានោះ កាលប្រាប់ខាងដើមថា ភិក្ខុនីក្នុងសាសនានោះ បានទទួលបព្វជ្ជា និងឧបសម្បទាដូចម្តេច ការអធិប្បាយអត្ថុប្បត្តិហេតុ ក្នុងគាថានោះៗ ក៏ធ្វើបានងាយនឹងធ្វើឲ្យយល់ងាយ ព្រោះហេតុនោះ ដើម្បីឲ្យយល់រឿងនោះ គប្បីជ្រាបលំដាប់ហេតុដែលកើតមកដូចតទៅនេះថា

សេចក្តីសង្ខេបថា ព្រះលោកនាថសាស្តាអង្គនេះ ទ្រង់ប្រជុំដោយអង្គ ៨ ដែលត្រាស់ដោយន័យថា **មនុស្សត្តំ លិង្គសម្បត្តិ** ប្រែថា ភាពជាមនុស្ស ១ ដល់ព្រមដោយភេទ ១ ជាដើម សាងមហាភិនីហារ ទុកទៀបបាទមូលរបស់ព្រះមានព្រះភាគព្រះនាមថាទីបង្ករ ទ្រង់បំពេញបារមី ៣០ បានទទួលព្យាករណ៍ ក្នុងសម្នាក់របស់ព្រះពុទ្ធទាំងឡាយ ២៤ អង្គ ទ្រង់បំពេញបារមីដោយលំដាប់ កាន់យកកំពូលនៃញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា កើតក្នុងស្ថានតុសិតតាំងនៅក្នុងស្ថានតុសិតនោះដរាបដល់អស់អាយុ

ទេវតាក្នុងម៉ឺនចក្រវាឡអារាធនាឲ្យមកកើតជាមនុស្ស ដើម្បីត្រាស់ជាព្រះពុទ្ធ ដោយពាក្យ ( ក្នុងខុទ្ទកនិកាយពុទ្ធវំស: ) ថា

**កាលោយំ តេ មហាវីរ ឧប្បជ្ជ មាតុកុច្ឆិយំ**
**សទេវកំ តារយន្តោ ពុជ្ឈស្សុ អមតំ បទំ។**

បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះគួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះ អមតៈ ដូច្នេះ ។

ទ្រង់ប្រទានបេ្តជ្ញាដល់ទេវតាទាំងនោះ ហើយទ្រង់ធ្វើបញ្ចមហាវិលោកនៈ ( ការជ្រើសរើសធំ ៥ យ៉ាង ) ទ្រង់មានព្រះសតិសម្បជញ្ញៈយាងចុះកាន់ព្រះឧទរព្រះមាតា ក្នុងព្រះដំណាក់របស់ព្រះបាទសុទ្ធោទនមហារាជ ក្នុងសក្យរាជត្រកូល ទ្រង់មានព្រះសតិសម្បជញ្ញៈនៅក្នុងព្រះឧទរនោះ ១០ ខែ ទ្រង់មានសតិសម្បជញ្ញៈយាងចេញចាកព្រះឧទរ បាននូវព្រះអភិជាតិ ត្រង់លុម្ពិនីវ័ន បានទទួលការថែរក្សាយ៉ាងល្អ ដោយការបរិហារធំ ដោយកីលៀងយ៉ាងច្រើនសន្ធឹកសន្ធាប់ ទ្រង់ចម្រើនវ័យដោយលំដាប់ ចោមរោមដោយអ្នករបាំជាច្រើនក្នុងប្រាសាទ ៣ សោយសម្បត្តិដូចទេវតា ទ្រង់សង្វេគព្រោះឃើញមនុស្សចាស់ មនុស្សឈឺនិងមនុស្សស្លាប់ ទ្រង់ឃើញទោសក្នុងកាមនិងអានិសង្សក្នុងនេក្ខម្មៈ ព្រោះញាណចាស់ក្លា ក្នុងថ្ងៃដែលរាហុលកុមារប្រសូតទ្រង់មាននាយឆន្នជាសម្លាញ់ ទ្រង់គង់លើកណ្ឋកអស្សរាជចេញមហាភិនេស្ក្រមណ៍

ក្នុងកណ្ដាលរាត្រី តាមទ្វារដែលទេវតាបើកថ្វាយ ទ្រង់ឆ្លងកាត់នគរ ៣ ដែលមានព្រះរាជាគ្រប់គ្រង ក្នុងរាត្រីនោះឯង ទ្រង់ដល់នូវត្រើយអនោមានទី ទ្រង់ទទួលទង់ជ័យអរហត្តដែលឃដិការមហាព្រហ្មនាំមកថ្វាយ ទ្រង់ព្រះផ្នួស ជាអ្នក ដល់ព្រមដោយអាកប្បកិរិយាដូចព្រះថេរៈមានវស្សា ៦០ ក្នុងខណៈនោះឯងទ្រង់យាងដល់នគររាជគ្រឹះដោយលំដាប់ ដោយឥរិយាបថដែលគួរជ្រះថ្លា ទ្រង់ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះហើយ គង់សោយបិណ្ឌបាតត្រង់ញកភ្នំបណ្ឌវៈ ។ ព្រះបាទពិម្ពិសាររាជ ជាស្ដេចនៃអ្នកមគធៈ ទ្រង់អារាធនាឲ្យគ្រប់គ្រងរាជសម្បត្តិជាមួយព្រះអង្គ ព្រះមហាសត្វបដិសេធរឿងនោះ យាងទៅកាន់អារាមនៃកាឡាមព្រាហ្មណ៍ ទ្រង់សិក្សាលទ្ធិរបស់កាឡាមព្រាហ្មណ៍ ។ បន្ទាប់អំពីនោះ ទ្រង់សិក្សាលទ្ធិរបស់អាឡារតាបសនិងឧទកតាបស ទ្រង់មិនពេញព្រះទ័យក្នុងលទ្ធិទាំងអស់ យាងទៅកាន់ឧរុវេលាតាមលំដាប់ ទ្រង់បំពេញទុក្ករកិរិយា ៦ ឆ្នាំ ត្រង់តំបន់ឧរុវេលានោះ ទ្រង់ជ្រាបថា ទុក្ករកិរិយានោះមិនធ្វើឲ្យត្រាស់ដឹងអរិយធម៌បាន មានព្រះតម្រិះថា នេះមិនមែនផ្លូវត្រាស់ដឹង ទ្រង់សោយអាហារគ្រោតគ្រាត មានកម្លាំងក្នុងកាល ២-៣ ថ្ងៃ ក្នុងថ្ងៃវិសាខបុណ្ណមី សោយភោជនដ៏ប្រសើរដែលនាងសុជាតាថ្វាយ ហើយទ្រង់បណ្ដែតភាជន៍មាស ភាជន៍មាសអណ្ដែតច្រាសទឹកស្ទឹងនេរញ្ជរា ទ្រង់សម្រេចក្នុងព្រះទ័យថា អាត្មាអញនឹងត្រាស់ដឹងក្នុងថ្ងៃនេះ ពេលល្ងាចស្ដេចកាឡនាគសរសើរគុណ ទ្រង់ឡើងកាន់ពោធិមណ្ឌល បែរព្រះភក្ត្រទៅកាន់ទិសខាងកើតនៃលោកធាតុ គង់លើអបរាជិតបល្ល័ង្ក ដែលជាទីមិនញាប់ញ័រ ទ្រង់អធិដ្ឋានព្យាយាម

ប្រកបដោយអង្គ ៤ ទ្រង់កម្ចាត់ទ័ពមារបាន ក្នុងកាលព្រះអាទិត្យមិនទាន់-អស្តង្គត ក្នុងបឋមយាមទ្រង់សម្រេចបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងមជ្ឈិម-យាម ទ្រង់សម្រេចទិព្វចក្ខុញ្ញាណ ( ចុតូបបាតិញ្ញាណ ) ក្នុងបច្ឆិមយាម ទ្រង់ញ៉ាំងញាណឲ្យឈមចុះក្នុងបដិច្ចសមុប្បាទ ពិចារណាបច្ចយាការ ទាំងអនុលោមនិងបដិលោម ចម្រើនវិបស្សនាសម្រេចសម្មាសម្ពោធិញ្ញាណដែលមិនជាសាធារណៈដល់ជនដទៃ ដែលព្រះពុទ្ធទាំងពួងសម្រេចហើយ ទ្រង់ចូលផលសមាបត្តិ មានព្រះនិព្វានជាអារម្មណ៍អស់កាល ៧ ថ្ងៃ ត្រង់ពោធិមណ្ឌលនោះឯង ទ្រង់ឲ្យពេលវេលាកន្លងទៅត្រង់ពោធិមណ្ឌលនោះជាច្រើនសប្តាហ៍ដោយន័យនោះឯង សោយទូវកោជនដែលលាយដោយទឹកឃ្មុំ ត្រង់គល់រាជាយតនៈ ( គល់កែស ) គង់ត្រង់គល់អជបាលនិគ្រោធ ទ្រង់ពិចារណាធម៌ដ៏ជ្រាលជ្រៅតាមធម្មតា មហាព្រហ្មមកអារាធនា ក្នុងកាលព្រះអង្គមានព្រះទ័យបង្អោនទៅដើម្បីការខ្វល់ខ្វាយតិច គឺមិនចង់ទូន្មានសត្វលោកទ្រង់ប្រមើលមើលទ្វីបលោក ដោយពុទ្ធចក្ខុ ទ្រង់ឃើញពួកសត្វមានឥន្ទ្រិយចាស់ក្លាក៏មាន មានឥន្ទ្រិយទន់ខ្ចីក៏មាន ទ្រង់ធ្វើបដិញ្ញាជាមួយមហាព្រហ្មថា នឹងសម្តែងធម៌ ទ្រង់អាវជ្ជនៈថា តថាគតគួរសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបសនិងឧទកតាបសស្លាប់ហើយ មានព្រះតម្រិះថា បញ្ចវគ្គិយដែលបម្រើតថាគតកំពុងបំពេញព្យាយាមយ៉ាងដាច់ខាត ជាអ្នកមានឧប-ការៈច្រើនដល់តថាគត ណ្ហើយចុះ តថាគតគប្បីសម្តែងធម៌ដល់ពួកបញ្ចវគ្គិយនោះមុន ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ទ្រង់យាងអំពីមហាពោធិ៍ បែរព្រះភក្ត្រទៅ

កាន់ក្រុងពារាណសី អស់ចម្ងាយផ្លូវ ១៨ យោជន៍ ទ្រង់ជួបឧបកាជីវក កណ្តាលផ្លូវ ដល់ព្រៃឥសិបតនៈតាមលំដាប់ ទ្រង់ធ្វើបញ្ចវគ្គិយក្នុងព្រៃឥសិ-បតនៈឲ្យត្រាស់ដឹង មួយអន្លើដោយព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោ-ណ្ឌញ្ញៈជាប្រធានឲ្យផឹកនូវអមតធម៌ដោយធម្មចក្កប្បវត្តនសូត្រ ដោយន័យជា ដើមថា ម្នាលភិក្ខុទាំងឡាយ ធម៌អមខាងទាំងពីរប្រការនេះ គឺបព្វជិតមិនគួរ សេពគប់ឡើយ ដូច្នេះ ។

ក្នុងថ្ងៃ ១ រោច ទ្រង់ឲ្យព្រះភទ្ទិយត្ថេរ តាំងនៅក្នុងសោតាបត្តិផល ក្នុង ថ្ងៃ ២ រោច ទ្រង់ឲ្យព្រះវប្បត្ថេរតាំងនៅក្នុងសោតាបត្តិផល ថ្ងៃ ៣ រោច ទ្រង់ឲ្យព្រះមហានាមត្ថេរតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃ ៤ រោច ទ្រង់ឲ្យ ព្រះអស្សជិត្ថេរតាំងនៅក្នុងសោតាបត្តិផល ។

ម្យ៉ាងទៀត ក្នុងថ្ងៃ ៥ រោច ទ្រង់ឲ្យបញ្ចវគ្គិយទាំងអស់ តាំងនៅក្នុង អរហត្ត ដោយអនត្តលក្ខណសូត្រ ។

បន្ទាប់អំពីនោះ ទ្រង់ឲ្យមហាជនចុះកាន់អរិយភូមិយ៉ាងនេះ គឺបុរស ៥៥ នាក់ មានយសកុលបុត្តជាប្រធាន ភទ្ទវគ្គិយកុមារប្រមាណ ៣០ រូប ត្រង់ចម្ការ កប្បាស បុរាណជដិលប្រមាណ ១០០០ រូប ត្រង់ផ្ទាំងថ្មដែលរាបស្មើ នា គយាសីសប្បទេស ទ្រង់ឲ្យមហាជន ១១ ម៉ឺន មានព្រះបាទពិម្ពិសារជាប្រធាន តាំងនៅក្នុងសោតាបត្តិផល ឲ្យមហាជន ១ ម៉ឺននាក់តាំងនៅក្នុងសរណៈ ៣ ទ្រង់ទទួលវត្តវេឡុវ័នហើយ គង់ក្នុងវត្តវេឡុវ័ននោះ ទ្រង់តាំងព្រះសារីបុត្ត និងព្រះមោគ្គល្លានដែលសម្រេចបឋមមគ្គ ដោយអំណាចព្រះអស្សជិត្ថេរ លា

អាអាចារ្យសញ្ជ័យ ចូលមកកាន់សម្នាក់របស់ព្រះអង្គ ព្រមដោយបរិវារ ទុកក្នុងតំណែងអគ្គសាវកដែលជាទីបំផុតនៃសាវកបារមីញាណ ហើយទ្រង់យាងទៅកាន់នគរកបិលពស្តុ តាមពាក្យអារាធនារបស់កាឡុទាយិត្ថេរ ទ្រង់ទូន្មានពួកញាតិដែលរឹងត្អឹងព្រោះមានះ ដោយយមកប្បាដិហារ្យ ទ្រង់ឲ្យព្រះជនកតាំងនៅក្នុងអនាគាមិផល ឲ្យព្រះមហាបជាបតីតាំងនៅក្នុងសោតាបត្តិផល ឲ្យនន្ទកុមារនិងរាហុលកុមារបួស ហើយយាងត្រឡប់មកកាន់នគររាជគ្រឹះវិញ ។

សម័យតមក កាលព្រះសាស្តាទ្រង់ចូលអាស្រ័យក្រុងវេសាលី គង់នៅត្រង់កូដាគារសាលា ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បរិនិព្វានក្រោមស្វេតច្ឆត្រនោះឯង ។ កាលនោះព្រះមហាបជាបតិគោតមីមានបំណងនឹងបួស ។ លំដាប់នោះ ពួកស្រីដែលជាបាទបរិចារិការបស់ព្រះរាជកុមារ ៥០០ ដែលចេញបួស ក្រោយពីបានស្តាប់ទេសនាកលហវិវាទសូត្រ ត្រង់ឆ្នេរស្ទឹងរោហិណី បានស្រុះស្រួលគ្នាចូលទៅគាល់ព្រះនាងមហាបជាបតី គ្រប់គ្នាទូលថានឹងបួសក្នុងសម្នាក់របស់ព្រះសាស្តា ឲ្យព្រះនាងមហាបជាបតីជាប្រធាន តាំងចិត្តនឹងទៅគាល់ព្រះសាស្តា ព្រះមហាបជាបតីនោះ កាលមុន បានទូលសូមបព្វជ្ជានឹងព្រះសាស្តាម្តងហើយ តែមិនបានហេតុនោះ ទើបឲ្យហៅជាងកោរកាត់មក ដាក់ព្រះកេសា ហើយគ្រងសំពត់កាសាវៈ នាំសាកិយានីទាំងនោះទៅកាន់នគរវេសាលី សូមឲ្យព្រះអានន្ទត្ថេរអង្វរព្រះទសពល ក៏បានបួសជាសាមណេរីនិងឧបសម្បទា ដោយការទទួលគរុធម៌ ៨ ប្រការ សូម្បីសាកិយានីក្រៅអំពីនេះ ក៏បានឧបសម្បទាព្រមគ្នា

ទាំងអស់ ។

នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ឯរឿងដោយពិស្តារមកហើយក្នុងបាលីក្នុងទីផ្សេងៗ ។

ព្រះមហាបជាបតី ឧបសម្បទាយ៉ាងនេះហើយ ចូលគាល់ព្រះសាស្តាថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង គ្រានោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះមហាបជាបតីនោះ ព្រះនាងរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាបានសម្រេចអរហត្ត ភិក្ខុនី ៥០០ ដ៏សេសបានសម្រេចអរហត្តក្នុងកាលចប់នន្ទកោវាទសូត្រ កាលភិក្ខុសង្ឃតាំងមាំល្អជាបែបផែនយ៉ាងនេះហើយ ពួកស្រីមានត្រកូល កូនប្រសារបស់ត្រកូល និងកុមារិកាក្នុងត្រកូលទាំងឡាយ ក្នុងគាមនិគម ជនបទនិងរាជធានីនោះៗ បានស្តាប់ភាពដែលព្រះពុទ្ធជាអ្នកត្រាស់ដឹងល្អហើយ ភាពដែលព្រះធម៌ជាធម៌ដែលព្រះពុទ្ធត្រាស់ល្អហើយ និងភាពដែលព្រះសង្ឃបដិបត្តិល្អហើយ មានសេចក្តីជ្រះថ្លាក្នុងសា-សនា និងសេចក្តីសង្វេគក្នុងសង្សារវដ្ត ទើបសូមអនុញ្ញាតស្វាមី មាតាបិតានិងញាតិរៀងៗខ្លួន បួសថ្វាយជីវិតក្នុងសាសនា កាលបួសហើយជាអ្នកដល់ព្រមដោយសីលនិងអាចារៈ បានទទួលឱវាទក្នុងសម្នាក់របស់ព្រះសាស្តាផងរបស់ព្រះថេរៈទាំងនោះផង ធ្វើនូវសេចក្តីព្យាយាម មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត គាថាទាំងឡាយដែលព្រះថេរីភាសិតក្នុងទីនោះៗ ដោយអំណាចនៃការបន្លឺឧទានជាដើម ក្រោយមកព្រះសង្គីតិកាចារ្យទាំងឡាយរួមគ្នាលើកឡើងកាន់សង្គីតិ ចាត់ជាឯកនិបាតជាដើម គាថាទាំងនេះ ឈ្មោះថេរី

គាថា ការចែកគាថាទាំងនោះជានិបាតជាដើម បានពោលទុកហើយខាងដើម នោះឯង បណ្តានិបាត ទាំងនោះ ឯកនិបាត ជានិបាតដំបូង ក្នុងឯកនិបាតនោះ មានគាថាថា

ម្នាលថេរី នាងចូរដេកលក់ស្រួល នាងចូរធ្វើ ( ចីវរបី )
ដោយសំពត់ ( បង្សុកូល ) ហើយស្លៀកដណ្តប់ចុះ ព្រោះ
រាគៈរបស់នាងស្ងប់រម្ងាប់ហើយដូចជាបន្លែស្ងួតក្នុងឆ្នាំង ដូច្នេះ
ជាគាថាដំបូង ។

ព្រះថេរីអង្គនោះ មានការប្រព្រឹត្តមកដូចម្តេច បានឮថា ក្នុងអតីតកាល ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា កោនាគមនៈ កុលធីតាម្នាក់ជ្រះថ្លា ក្រៃលែងក្នុងសាសនា និមន្តព្រះសាស្តា ក្នុងថ្ងៃទី ២ ឲ្យសាងមណ្ឌបមែកឈើ រោយនូវខ្សាច់ ចងពិតានខាងលើ បូជាគ្រឿងក្រអូបនិងផ្កាជាដើម ហើយឲ្យ មនុស្សទៅក្រាបទូលដល់ព្រះសាស្តា ព្រះសាស្តា យាងទៅត្រង់មណ្ឌបនោះ គង់លើអាសនៈដែលគេក្រាលទុក កុលធីតានោះ ថ្វាយបង្គំព្រះមានព្រះភាគ ហើយ អង្គាសដោយរបស់ទំពា របស់បរិភោគយ៉ាងប្រណីត ឲ្យព្រះមានព្រះ ភាគសោយស្រេច ដកព្រះហស្តចេញអំពីបាត្រ គ្រងត្រៃចីវរ ព្រះមានព្រះ ភាគទ្រង់អនុមោទនាដល់នាងហើយ ទ្រង់ចៀសចេញទៅ កុលធីតានោះ ធ្វើ បុណ្យដរាបដល់អស់អាយុ កាលអស់អាយុកើតក្នុងទេវលោក អន្ទោលទៅ ក្នុងសុគតិភូមិប៉ុណ្ណោះ អស់មួយពុទ្ធន្តរ ក្នុងសាសនាព្រះមានព្រះភាគ ព្រះ នាមថាកស្សបៈ កើតក្នុងត្រកូលគហបតី លុះដឹងក្តីហើយ កើតនូវសេចក្តី

សង្វេគក្នុងសង្សារវដ្ត ទើបបព្វជ្ជាឧបសម្បទាក្នុងសាសនា បួសជាភិក្ខុនី បំពេញសីលអស់ ២ ម៉ឺនឆ្នាំ ស្លាប់ទាំងនៅជាបុថុជ្ជន កើតក្នុងស្ថានសួគ៌សោយនូវសម្បត្តិក្នុងស្ថានសួគ៌អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កើតនៅក្នុងត្រកូលខត្តិយមហាសាលក្នុងក្រុងវេសាលី មនុស្សទាំងឡាយហៅនាងថា ថេរិកា ព្រោះមានរូបរាងទាប នាងចម្រើនវ័យ មាតាបិតាឲ្យដល់ខត្តិយកុមារដែលមានជាតិស្មើគ្នា ដោយត្រកូលនិងប្រទេសជាដើម បូជាស្វាមីដូចទេវតា បាននូវសទ្ធាក្នុងព្រះសាស្តា គ្រាព្រះសាស្តាយាងទៅកាន់ក្រុងវេសាលី មានសទ្ធាក្នុងសាសនានាងក៏ថ្វាយខ្លួនជាឧបាសិកា តមកបានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះមហាបជាបតិគោតមីថេរី កើតនូវការពេញចិត្តក្នុងបព្វជ្ជា ប្រាប់ដល់ស្វាមីថានឹងបួស ស្វាមីមិនអនុញ្ញាត តែព្រោះនាងសាងបុញ្ញបារមីមក នាងពិចារណាធម៌ តាមដែលបានស្តាប់ កំណត់រូបធម៌និងអរូបធម៌ ប្រកបវិបស្សនារឿយៗ ។

ថ្ងៃមួយ កាលនាងចម្អិនអាហារក្នុងរោងចុងភៅ អណ្តាតភ្លើងធំបានតាំងឡើង អណ្តាតភ្លើងនោះ ធ្វើឲ្យភាជនៈកើតនូវសំឡេងប្រេះៗនាងឃើញដូច្នោះ ទើបកាន់យកសេចក្តីនោះធ្វើឲ្យជាអារម្មណ៍ ពិចារណានូវការមិនទៀង ដែលប្រាកដឡើងយ៉ាងក្រៃលែង បន្ទាប់អំពីនោះ បានលើកនូវអនិច្ចំ ទុក្ខំ អនត្តាក្នុងគ្រានោះ ចម្រើនវិបស្សនា ខ្មីឃ្មាតដោយលំដាប់ បានតាំងនៅក្នុងអនាគាមិផលតាមលំដាប់នៃមគ្គ ។ តាំងអំពីនោះមក នាងមិនប្រើសំពត់ដែលស្អាតឬគ្រឿងប្រដាប់ កាលស្វាមីសួរថា ហេតុអ្វីទើបនាងមិនប្រើប្រាស់សំពត់ដែល

ស្អាតឬគ្រឿងប្រដាប់ដូចកាលមុន ទើបនាងប្រាប់ភាពដែលនាងមិនគួរនៅជាគ្រហស្ថ ហើយសូមអនុញ្ញាតបួស ស្វាមីនាំនាងទៅកាន់ សម្នាក់របស់ព្រះនាងមហាបជាបតិគោតមីដោយបរិវារធំ ដូចវិសាខឧបាសក នាំនាងធម្មទិន្នាទៅដូច្នោះ បានពោលថា បពិត្រព្រះនាង សូមព្រះនាង ឲ្យនាងបួសចុះ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ឲ្យនាងបព្វជ្ជាឧបសម្បទាហើយ នាំទៅវិហារ ទូលដល់ព្រះសាស្តា ព្រះសាស្តាកាលទ្រង់ធ្វើអារម្មណ៍ដែលនាងឃើញតាមប្រក្រតីនោះឯងឲ្យជាក់ច្បាស់ឡើង ទើបត្រាស់គាថានេះថា

ម្នាលថេរី នាងចូរដេកលក់ស្រួល នាងចូរធ្វើ ( ចីវរបើ )
ដោយសំពត់ ( បង្សុកូល ) ហើយស្លៀកដណ្តប់ចុះ ព្រោះ
រាគៈរបស់នាង ស្ងប់រម្ងាប់ហើយ ដូចជាបន្លែស្ងួតក្នុង ឆ្នាំង
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខំ** ជាពាក្យដែលប្រើជានបុំសកលិង្គ ។ បទថា **សុបាហិ** ជាពាក្យប្រាប់ ។ បទថា **ថេរិកេ** ជាពាក្យហៅ ។ បទថា **កត្វា ចោឡេន បារុតា** ជាពាក្យពោលបន្ថែមឲ្យកើតការប្រាថ្នាតិច ។ បទថា **ឧបសន្តោ ហិ តេ រាគោ** ជាពាក្យប្រាប់វត្ថុដែលបដិបត្តិ ។ បទថា **សុក្ខឌាកំវ** ជាពាក្យសម្តែងថា កិលេសដែលរម្ងាប់មិនសំខាន់ ។ បទថា **កុម្ភិយំ** ជាពាក្យសម្តែងឆ្នាំងដែលដាក់បន្លែត្រាំនោះ មានភាពទទេព្រោះមិនទៀង ម្យ៉ាងទៀត បទថា **សុខំ** នេះ ជាឈ្មោះរបស់វត្ថុដែលប្រាថ្នា សេចក្តីថា មានសុខប្រាសចាកទុក្ខ ។ បទថា **សុបាហិ** នេះ ជាពាក្យសម្តែងការ

ផ្លាស់ប្តូរឥរិយាបថទាំង ៤ អធិប្បាយថា ព្រោះហេតុនោះ ចូរនាងសម្រេចឥរិយាបថទាំង ៤ តាមសប្បាយចុះ គឺចូរនៅយ៉ាងសប្បាយ ។ បទថា **ថេរិកេ** នេះ ជាបទប្រកាសឈ្មោះរបស់ព្រះថេរីនោះក៏ពិត តែដោយច្រើនសំដៅដល់បុគ្គលដែលជាអ្នកមាំទាំ ក្នុងសាសនាដែលមាំទាំ ព្រោះភាវៈដែលដឹងតាមអត្ថដែលស្តាប់មក គឺប្រកបដោយធម៌មានសីលជាដើមដែលមាំទាំ ។ បទថា **កត្វា ចោឡេន ចារុតា** សេចក្តីថា ចូរកាន់យកកំណាត់សំពត់បង្សុកូលធ្វើចីវរបិទបាំងសរីរៈ គឺស្លៀកដណ្តប់សំពត់នោះ ។ **ហិ** សព្ទ ក្នុងបទថា **ឧបសន្តោ ហិ តេ រាគោ** មានអត្ថប្រាប់ថា ហេតុ អធិប្បាយថា ព្រោះកាមរាគៈដែលកើតក្នុងសន្តានរបស់នាងស្ងប់ហើយ គឺត្រូវដុតដោយភ្លើង គឺអនាគាមិមគ្គញ្ញាណ ឥឡូវនេះ ចូរនាងដុតរាគៈដែលនៅសេសសល់នោះដោយភ្លើង គឺអរហត្តមគ្គញ្ញាណ សម្រាកឲ្យសប្បាយចុះ ។ បទថា **សុក្ខ-ឌាកំវ កុម្ភិយំ** សេចក្តីថា រមែងស្ងប់ ដូចបន្លែបន្តិចបន្តួចក្នុងភាជនៈក្តៅនោះដែលគេរម្ងាស់ដោយអណ្តាតភ្លើងដ៏ក្តៅ ក្រៀមស្ងួតទៅ ។

ម្យ៉ាងទៀត កាលយកបន្លែលាយទឹកដាក់រម្ងាស់លើជើងក្រាន កាលទឹកនៅមាន បន្លែនោះរមែងក្តៅ តែកាលអស់ទឹក រមែងស្ងប់ យ៉ាងណា កាមរាគៈក្នុងសន្តានរបស់នាងស្ងប់ហើយ ចូរនាងធ្វើកិលេសដ៏សេសឲ្យស្ងប់ រួចសម្រាកឲ្យសុខសាន្តចុះ ដូច្នេះ ។

ព្រោះព្រះថេរីមានឥន្ទ្រិយចាស់ក្លា ១ ព្រោះលម្អនៃព្រះគាថារបស់ព្រះសាស្តា ១ កាលចប់គាថា ព្រះថេរីសម្រេចអរហត្ត មួយអន្លើដោយបដិ-

សម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានកសាងមណ្ឌបថ្វាយព្រះពុទ្ធព្រះនាមកោនាគមនៈ ហើយ
ថ្វាយព្រះស្តូបដ៏ប្រសើរ ដល់ព្រះពុទ្ធជាផៅពង្សនៃលោកថែម
ទៀត ។ ខ្ញុំទៅកាន់ជនបទ និគម រាជធានីណាៗ ជាស្រីត្រូវ
គេបូជាក្នុងទីទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ កិលេសទាំង
ឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជា
ស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់
ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ
របស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ
ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ នឹងអភិញ្ញា ៦ នេះ
ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំ
ក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលបានសម្រេចអរហត្តហើយ ព្រះថេរីកាលបន្លឺឧទាន បានភាសិតគាថានោះទៀត ព្រោះហេតុនោះ ទើបគាថានេះ បានជាគាថារបស់ព្រះថេរីអង្គនេះ ។

បន្ទាប់អំពីគាថាដែលត្រាស់ដល់ព្រះថេរី ក្នុងនោះឈ្មោះថា គ្រប់ដណ្តប់ដល់រាគៈគ្រប់យ៉ាង មិនមានសេសសល់ ព្រោះការស្ងប់របស់រាគៈនោះសម្រេចបានដោយអគ្គមគ្គ ។ គប្បីជ្រាបការស្ងប់កិលេសទាំងអស់ក្នុងទីនេះ

១-ក្នុងអបទានជា មណ្ឌបទាយិកាថេរី ។

ត្រាស់ទុកដោយការស្ងប់រាគៈនោះឯង ព្រោះកិលេសធម៌ទាំងអស់ស្ងប់បាន អាស្រ័យការតាំងនៅរួមគ្នា សមដូចលោកពោលទុកថា

មោហៈណាកើតរួមជាមួយឧទ្ធច្ចៈនិងវិចិកិច្ឆា ដែលខ្ញុំដឹងហើយ

មោហៈនោះ ក៏សង្រ្គោះចូលជាមួយរាគៈ ព្រោះតាំងនៅរួមគ្នា

ដោយការលះ ដូច្នេះ ។

ការស្ងប់នៃសង្កិលេសទាំងពួង ទ្រង់ត្រាស់ទុកក្នុងទីនេះ យ៉ាងណាសូម្បីក្នុងទីគ្រប់អន្លើក៏គប្បីជ្រាបថា លោកពោលសំដៅយកការស្ងប់នៃសង្កិលេសទាំងនោះទុកក៏យ៉ាងនោះ ព្រោះការស្ងប់កិលេសសម្រេចក្នុងខាងដើម ដោយតទង្គប្បហាន ក្នុងខណៈនៃសមថៈនិងវិបស្សនាដោយវិក្ខម្ភនប្បហាន ក្នុងខណៈនៃមគ្គដោយសមុច្ឆេទប្បហាន ក្នុងខណៈនៃផលដោយបដិបស្សទ្ធិប្បហាន ។ ព្រោះហេតុនោះ គប្បីជ្រាបថា ធ្វើឲ្យសម្រេចនូវបហានៈទាំង ៤ យ៉ាង ។ បណ្តាបហានៈទាំង ៤ នោះ សេចក្តីសម្រេចនៃសីលសម្បទា លោកសម្តែងដោយតទង្គប្បហាន ការសម្រេចនៃសមាធិសម្បទា លោកសម្តែងដោយវិក្ខម្ភនប្បហាន ការសម្រេចនៃបញ្ញាសម្បទា លោកសម្តែងដោយបហានៈក្រៅអំពីនេះ ព្រោះធ្វើឲ្យបានសម្រេចបហានៈ ។ ព្រះយោគាវចរញ៉ាំងការសម្រេចសច្ឆិកិរិយានិងការសម្រេចបរិញ្ញាឲ្យសម្រេច ដូចញ៉ាំងការសម្រេចភាវនាឲ្យសម្រេចនោះឯង ព្រោះកាលភាវនាមិនមាន ក៏មិនមានសច្ឆិកិរិយា ។ បណ្ឌិតគប្បីជ្រាបថា ដោយគាថានេះ ឈ្មោះថាប្រកាសនូវការបរិបូរនៃសិក្ខា ៣ ដោយការសម្រេចគឺការសម្រេចសច្ចៈ ៤ ( ប្រកាស )

លម្អ ៣ ដោយការបដិបត្តិ ។ ព្រះថេរីមួយអង្គ មិនប្រាកដឈ្មោះនិងគោត្ត ដល់ព្រមដោយលក្ខណៈ បានភាសិតគាថានេះទុក ។

## អដ្ឋកថាអញ្ញតរាថេរីគាថា ចប់

# មុត្តាថេរីគាថា

[ ២៦៧ ] ម្នាលនាងមុត្តា នាងចូររួចចាកយោគៈទាំងឡាយ ដូចជាព្រះចន្ទ ដែលរាហូចាប់ ( ហើយរួចអំពីដៃ ) នាងមានចិត្តរួចស្រឡះ មិនមានបំណុលទេ ចូរបរិភោគដុំបាយចុះ ។

ឮថា ព្រះមានព្រះភាគទ្រង់ទូន្មានរឿយៗនូវសិក្ខមានា ឈ្មោះមុត្តាដោយគាថា មានបការៈដូច្នេះ ។

# អដ្ឋកថា

# មុត្តាថេរីគាថា

[ ២៦៧ ] គាថាតទៅនេះជាគាថារបស់សិក្ខមានាឈ្មោះមុត្តា

ម្នាលនាងមុត្តា នាងចូររួចចាកយោគៈទាំងឡាយ ដូចជាព្រះ
ចន្ទដែលរាហូចាប់ ( ហើយរួចអំពីដៃ ) នាងមានចិត្តរួចស្រឡះ
មិនមានបំណុលទេ ចូរបរិភោគដុំបាយចុះ ដូច្នេះ ។

ព្រះថេរីរូបនេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូលជាអ្នកដឹងក្តីហើយ ថ្ងៃមួយឃើញព្រះសាស្តាយាងតាមវិថី មានចិត្តជ្រះថ្លា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយក្រាបទៀបព្រះយុគលបាទរបស់ព្រះសាស្តា ដោយកម្លាំងបីតិ ។ ដោយបុញ្ញកម្មនោះ ទៅកើតក្នុងទេវលោក អន្ទោលទៅមកតែក្នុង

សុគតិភូមិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងសាវត្ថី មានឈ្មោះថា មុត្តា ព្រោះជាស្រីដល់ព្រមដោយឧបនិស្ស័យ ក្នុងកាលអាយុ ២០ ឆ្នាំ នាងក៏បួសជាសិក្ខមានា ក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមី ឲ្យព្រះនាងបជាបតិគោតមីប្រាប់កម្មដ្ឋានហើយ ចម្រើនវិបស្សនា ។ ថ្ងៃមួយ ត្រឡប់អំពីបិណ្ឌបាត ធ្វើភត្តកិច្ចស្រេចហើយ សម្តែងវត្តដល់ភិក្ខុនីដែលជាថេរីទាំងឡាយ ហើយទៅកាន់ទីសម្រាកពេលថ្ងៃ អង្គុយក្នុងទីកំបាំង ផ្តើមមនសិការវិបស្សនាកម្មដ្ឋាន ព្រះសាស្តាគង់នៅត្រង់ព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញរស្មីសម្តែងព្រះអង្គ ដូចនៅក្នុងទីចំពោះមុខរបស់នាង ត្រាស់គាថានេះថា

ម្នាលនាងមុត្តា នាងចូររួចចាកយោគៈទាំងឡាយ ដូចជាព្រះ
ចន្ទដែលរាហូចាប់ ( ហើយរួចអំពីដៃ ) នាងមានចិត្តរួចស្រឡះ
មិនមានបំណុលទេ ចូរបរិភោគដុំបាយចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មុត្តេ** ជាពាក្យហៅសិក្ខមានានោះ ។ បទថា **មុញ្ចស្សុ យោគេហិ** សេចក្តីថា ចូរផុតចាកយោគៈ ៤ មានកាមរាគៈជាដើម ដោយមគ្គប្បដិបត្តិ គឺចូរជាអ្នកមានចិត្តផុតចាកយោគៈទាំងនោះ ដូចអ្វី ដូចជាព្រះចន្ទដែលរាហូចាប់ ( ហើយរួចអំពីដៃ ) សេចក្តីថា ដូចព្រះចន្ទផុតចាករាហូ ឬផុតចាកគ្រឿងសៅហ្មង ។ បទថា **វិប្បមុត្តេន ចិត្តេន** បានដល់មានចិត្តផុតដោយល្អ ដោយសមុច្ឆេទវិមុត្តិ និងដោយអរិយមគ្គ ។ បទថា **វិប្បមុត្តេន ចិត្តេន** នេះ ជាតតិយាវិភត្តិ ចុះក្នុងលក្ខណឥត្ថម្ភូត ។ បទថា

**អនណា ភុញ្ជ បិណ្ឌកំ** សេចក្ដីថា ចូរជាបុគ្គលដែលមិនមានបំណុលព្រោះលះបំណុលគឺកិលេសបាន បរិភោគដុំបាយរបស់អ្នកដែន ដ្បិតថាបុគ្គលណាមិនទាន់លះកិលេសទាំងឡាយបាន បរិភោគបច្ច័យ ដែលព្រះសាស្ដាទ្រង់អនុញ្ញាត បុគ្គលនោះឈ្មោះថាជាអ្នកមានទនូវបំណុលបរិភោគដូចព្រះពាកុលៈពោល ( ក្នុងពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ ) ថា ម្នាលអាវុសោ អាត្មាប្រកបដោយកិលេស ឆាន់បិណ្ឌបាត របស់អ្នកដែនតែ ៧ ថ្ងៃ ដូច្នេះ ហេតុនោះបព្វជិតក្នុងសាសនា គប្បីលះបំណុល គឺកាមច្ឆន្ទៈជាដើម ជាអ្នកមិនមានបំណុល បរិភោគរបស់ដែលគេឲ្យដោយសទ្ធាចុះ ។ បទថា **បិណ្ឌកំ** ជាមាតិកានៃទេសនាប៉ុណ្ណោះ ដោយអត្ថគឺបច្ច័យ ៤ ។ បទថា **អភិណ្ហំ ឱវទតិ** សេចក្ដីថា ព្រះមានព្រះភាគ កាលឲ្យជម្រះឧបក្កិលេសដោយការបដិបត្តិតាមអរិយមគ្គ បានប្រទានឱវាទរឿយៗ ។

សិក្ខមានាមុត្តានោះ តាំងនៅក្នុងឱវាទនោះ មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈ ជាធំជាងលោក
ជាតាទិបុគ្គល ទ្រង់ស្ដេចទៅក្នុងប្រកទ្រង់ញុំាងសត្វទាំងឡាយ
ឲ្យឆ្លង ខ្ញុំចេញអំពីផ្ទះ ហើយឱនក្រាបចុះ កាលនោះ ព្រះពុទ្ធ
ជាធំជាងលោកព្រះអង្គជាអ្នកអនុគ្រោះបានជាន់លើក្បាលខ្ញុំ ។
លុះព្រះលោកនាយក ទ្រង់ជាន់លើក្បាលខ្ញុំហើយស្ដេចហួស
ទៅ ខ្ញុំក៏បានទៅកើតក្នុងឋានតុសិត ដោយសេចក្ដីជ្រះថ្លាក្នុង

ចិត្តនោះ កិលេសទាំងឡាយខ្ញុំផុតបំផ្លាញហើយ ។បេ។ ទាំង

សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលសម្រេចអរហត្តហើយ សិក្ខមានាមុត្តានោះបានបន្លឺឧទានដោយ គាថានោះឯង ។ បទថា **សិក្ខមានំ** បានដល់ ជាអ្នកមានសិក្ខាបរិបូណ៌ ។ តមក គឺក្នុងកាលបរិនិព្វាន ព្រះថេរីពោលគាថានោះឯងទៀត ។

## អដ្ឋកថាមុត្តាថេរីគាថា ចប់

១-ក្នុងអបទានជា សង្គមនទាថេរី ។

# បុណ្ណាថេរីគាថា

[ ២៦៨ ] ម្នាលនាងបុណ្ណា នាងចូរពេញដោយពោធិបក្ខិយធម៌ទាំងឡាយ ដូចជាព្រះចន្ទក្នុងថ្ងៃ ១៥ កើត នាងចូរទម្លាយនូវគំនរងងឹត គឺមោហៈ ដោយបញ្ញាដ៏បរិបូណ៌ ។

បុណ្ណាថេរី ។

# អដ្ឋកថា

## បុណ្ណាថេរីគាថា

[ ២៦៨ ] គាថារបស់សិក្ខមានាមានពាក្យផ្ដើមថា **បុណ្ណេ បូរស្សុ ធម្មេហិ** ដូច្នេះ ជាដើម ។

បានឮថា កុលធីតានេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗកាលចក្កវាឡមិនមានព្រះពុទ្ធ កើតក្នុងកំណើតកិន្នរត្រង់ឆ្នេរស្ទឹងចន្ទភាគា ។ ថ្ងៃមួយ ឃើញព្រះបច្ចេកពុទ្ធមួយអង្គត្រង់ឆ្នេរស្ទឹងនោះ មានចិត្តជ្រះថ្លា បូជាព្រះបច្ចេកពុទ្ធដោយផ្កាបបុស ឈរផ្គងអញ្ជលី ដោយបុញ្ញកម្មនោះ កុលធីតានោះអន្ទោលទៅក្នុងសុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតិមហាសាលក្នុងនគរសាវត្ថី មានឈ្មោះថាបុណ្ណា ព្រោះជាស្រីដល់ព្រមដោយឧបនិស្ស័យ លុះដល់អាយុ ២០ ឆ្នាំ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះនាងគោតមីបាននូវសទ្ធាសូមបព្វជ្ជាជាសិក្ខមានា ផ្ដើមវិបស្សនា ។

ព្រះសាស្តា គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញព្រះរស្មី ត្រាស់ព្រះគាថានេះដល់កុលធីតានោះថា

ម្នាលនាងបុណ្ណា នាងចូរពេញដោយពោធិបក្ខិយធម៌ទាំងឡាយ ដូចជាព្រះចន្ទក្នុងថ្ងៃ ១៥ កើត នាងចូរទម្លាយនូវគំនរងងឹត គឺ មោហៈ ដោយបញ្ញាដ៏បរិបូណ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ណេ** ជាពាក្យហៅសិក្ខមានានោះ ។ បទថា **បូរស្សុ ធម្មេហិ** សេចក្តីថា ចូរបរិបូណ៌ដោយពោធិបក្ខិយធម៌ ៣៧ ប្រការ ។ រ អក្ខរៈ ក្នុងបទថា **ចន្ទោ បណ្ណរសេរិវ** គ្រាន់តែធ្វើកិច្ចភ្ជាប់បទ សេចក្តីថា ដូចព្រះចន្ទពេញវង់ក្នុងថ្ងៃ ១៥ កើត គឺក្នុងថ្ងៃពេញបូណ៌មី ។ បទថា **បរិបុណ្ណាយ បញ្ញាយ** បានដល់ ដោយបញ្ញាដែលសម្បយុត្តដោយអរហត្តមគ្គ ឈ្មោះថា **បរិបុណ្ណាយ** ព្រោះធ្វើកិច្ច ១៦ ឲ្យបរិបូណ៌ ។ បទថា **តមោក្ខន្ធំ បទាលយ** សេចក្តីថា ចូរទម្លាយ គឺចូរដកនូវគំនរមោហៈ ដោយឲ្យមិនសេសសល់ ដោយការទម្លាយគំនរមោហៈនោះឯង កិលេសទាំងអស់ឈ្មោះថាទម្លាយហើយ ។

សិក្ខមានាបុណ្ណានោះ ស្តាប់គាថានោះហើយចម្រើនវិបស្សនាបានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះ ខ្ញុំជាកិន្នរញី នៅជិតឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេសហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ កើត

សេចក្ដីរីករាយ ធ្វើអញ្ជលីហើយ យកកម្រងផ្កាបបុសបូជា ព្រះសយម្ភូ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជាកិន្នរញីហើយ ក៏បានទៅកើត ក្នុងឋានត្រៃត្រឹង្ស ។ ខ្ញុំបានទទួលភាពជាមហេសីនៃទេវរាជ ៣៦ ដង បានទទួលភាពជាមហេសីនៃស្ដេចចក្រពត្តិ ១០ ដង ។ ខ្ញុំទទួលវង្គកុសល បានចូលទៅកាន់ផ្នួស កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរីនោះសម្រេចអរហត្តហើយ បានបន្លឺឧទានគាថានោះ គាថានោះបានជាគាថាព្យាករណ៍អរហត្តរបស់ព្រះថេរីនោះឯង ។

**អដ្ឋកថា បុណ្ណាថេរីគាថា ចប់**

១-ក្នុងអបទានជា នឡមាលិកាថេរី ។

# តិស្សាថេរីគាថា

[ ២៦៩ ] ម្នាលនាងតិស្សា ចូរនាងសិក្សាតាមសិក្ខា កុំឲ្យយោគៈទាំងឡាយគ្របសង្កត់នាងបាន នាងចូរជាស្រីប្រាសចាកយោគៈទាំង អស់ មិនមានអាសវៈ ប្រព្រឹត្តនៅក្នុងលោក ។

តិស្សាថេរី ។

# អដ្ឋកថា

## តិស្សាថេរីគាថា

[ ២៦៩ ] គាថារបស់ភិក្ខុមានាឈ្មោះថា តិស្សា មានពាក្យផ្តើមថា **តិស្សេ សិក្ខស្សុ សិក្ខាយ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ក៏មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងសក្យរាជត្រកូល ក្នុងនគរកបិលពស្តុ ចម្រើនវ័យហើយ បានជាស្នំរបស់ព្រះពោធិសត្វ ក្រោយមក បានចេញបួសមួយអន្លើដោយព្រះមហាបជាបតិគោតមី ចម្រើនវិបស្សនា ព្រះសាស្តាទ្រង់បញ្ចេញព្រះរស្មី តាមន័យដែលពោលហើយខាងដើមនោះឯង បានភាសិតគាថាដល់ព្រះថេរីនោះថា

ម្នាលនាងតិស្សា ចូរនាងសិក្សាតាមសិក្ខា កុំឲ្យយោគៈទាំង
ឡាយ គ្របសង្កត់នាងបាន នាងចូរជាស្រីប្រាសចាកយោគៈ

ទាំងអស់ មិនមានអាសវៈ ប្រព្រឹត្តនៅក្នុងលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តិស្ស** ជាពាក្យហៅព្រះថេរនោះ ។ បទថា **សិក្ខស្សុ សិក្ខាយ** សេចក្ដីថា ចូរសិក្សាក្នុងសិក្ខា ៣ មានអធិសីលសិក្ខាជាដើម គឺចូរញ៉ាំងសិក្ខា ៣ ដែលសម្បយុត្តដោយមគ្គឲ្យដល់ព្រម ព្រះមានព្រះភាគត្រាស់ហេតុក្នុងការញ៉ាំងសិក្ខា ៣ នោះ ឲ្យដល់ព្រមទុកថា នាងចូរជាស្រីប្រាសចាកយោគៈទាំងអស់ សេចក្ដីថា សម័យដែលគួរប្រកបទាំងនេះ គឺភាពជាមនុស្ស ១ ការមិនខ្វះខាតនៃឥន្ទ្រិយ ១ ការកើតឡើងនៃព្រះពុទ្ធ ១ ការមាននូវសទ្ធា ១ ជាខណៈដែលរកបានដោយក្រកុំកន្លងនាងទៅឡើយ ម្យ៉ាងទៀត យោគៈ ៤ មានកាមយោគៈជាដើមនោះឯង កុំចូលជិត គឺកុំគ្របសង្កត់នាងឡើយ ។ បទថា **សព្វយោគវិសំយុត្តា** សេចក្ដីថា ចូរផុតចាកយោគៈទាំងអស់ មានកាមយោគៈជាដើម បន្ទាប់អំពីនោះ ចូរជាអ្នកមិនមានអាសវៈត្រាច់ទៅក្នុងលោក គឺចូរនៅដោយធម៌ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ។

ន័យជាដើមថា ព្រះថេរីស្ដាប់គាថានេះហើយ ចម្រើនវិបស្សនា សម្រេចអរហត្ត ដូច្នេះ គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនោះឯង ។

## អដ្ឋកថាតិស្សាថេរីគាថា ចប់

# អញ្ញតរាតិស្សាថេរីគាថា

[ ២៧០ ] ម្នាលនាងតិស្សា ចូរនាងប្រកបដោយធម៌ទាំងឡាយ ខណៈកុំកន្លងនាងឡើយ ព្រោះពួកជនដែលខណៈកន្លងហើយ រមែងសោកស្តាយពេញប្រៀបក្នុងនរក ។

**តិស្សាថេរីមួយរូប ។**

# ធីរាថេរីគាថា

[ ២៧១ ] ម្នាលនាងធីរា នាងចូរពាល់ត្រូវនូវនិរោធជាសុខ ជាទីរម្ងាប់នូវសញ្ញា នាងចូរត្រេកអរនឹងព្រះនិព្វានដ៏ក្សេមចាកយោគៈ ប្រសើរបំផុត ។

**ធីរាថេរី ។**

# អញ្ញតរាធីរាថេរីគាថា

[ ២៧២ ] ធីរាភិក្ខុនី មានឥន្ទ្រិយអប់រំហើយ ដោយធម៌ទាំងឡាយជាប្រធាននៃព្យាយាម នាងចូរផ្ចាញ់នូវមារព្រមទាំងវាហនៈ ហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ។

**ធីរាថេរីមួយរូប ។**

## មិត្តាថេរីគាថា

[ ២៧៣ ] ម្នាលនាងមិត្តា នាងបួសដោយសទ្ធាហើយ ចូរជាអ្នកត្រេកអរក្នុងកល្យាណមិត្ត ចូរចម្រើននូវកុសលធម៌ទាំងឡាយ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ។

**មិត្តាថេរី ។**

## ភទ្រាថេរីគាថា

[ ២៧៤ ] ម្នាលនាងភទ្រា នាងបួសដោយសទ្ធាហើយ ចូរជាអ្នកត្រេកអរក្នុងធម៌ដ៏ចម្រើន ( មានសីលជាដើម ) នាងចូរចម្រើននូវកុសលធម៌ទាំងឡាយ ( ដើម្បីដល់ ) នូវព្រះនិព្វានជាទីក្សេមចាកយោគៈ ដ៏ប្រសើរបំផុត ។

**ភទ្រាថេរី ។**

## ឧបសមាថេរីគាថា

[ ២៧៥ ] ម្នាលនាងឧបសមា នាងគប្បីឆ្លងអន្លង់គឺសង្សារ ជាទីនៅនៃមច្ចុ ដែលពួកសត្វឆ្លងបានដោយកម្រក្រៃពេក ចូរនាងផ្ចាញ់នូវមារព្រមទាំងវាហនៈ ហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ។

**ឧបសមាថេរី ។**

# អដ្ឋកថា

## អញ្ញតរាតិស្សាថេរីគាថាជាដើម

[ ២៧០-២៧៥ ] គាថារបស់តិស្សាថេរីជាដើមមានពាក្យផ្ដើមថា **តិស្សេ យុញ្ជស្សុ ធម្មេហិ** ដូច្នេះជាដើម ។

រឿងរបស់ព្រះថេរីអង្គនេះ ក៏ដូចគ្នានិងរឿងរបស់សិក្ខមានាឈ្មោះ តិស្សា តែព្រះថេរីអង្គនេះ បួសហើយបានសម្រេចព្រះអរហត្ត ។ ព្រះថេរីអង្គនេះ យ៉ាងណា រឿងរបស់ព្រះថេរី ៥ អង្គ បន្ទាប់អំពីនេះ គឺធីរាថេរី អញ្ញតរាធីរាថេរី មិត្តាថេរី ភទ្រាថេរី ឧបសមាថេរី ក៏យ៉ាងនោះ គឺដូចគ្នានោះឯង ព្រះថេរីទាំងអស់ ជាអ្នកកបិលពស្តុ ជាស្នំរបស់ព្រះពោធិសត្វ ចេញបួសជាមួយព្រះនាងមហាបជាបតិគោតមី សម្រេចអរហត្តដោយគាថាកើតអំពីឱកាសរៀរអង្គទី ៧ ឯអង្គទី ៧ នោះ រៀរគាថាដែលកើតអំពីឱកាស អាស្រ័យឱវាទ ដែលបានក្នុងសម្នាក់ព្រះសាស្ដាដោយត្រង់ ខ្វល់ខ្វាយចម្រើនវិបស្សនាសម្រេចអរហត្ត បានពោលគាថាជាឧទានថា **ធីរា ធីរេហិ** ជាដើម ព្រះថេរីអង្គដទៃៗ សម្រេចអរហត្តហើយ បានពោលគាថាទាំងនេះថា

( ព្រះនាងអញ្ញតរាតិស្សាថេរីពោលថា )

ម្នាលនាងតិស្សា ចូរនាងប្រកបដោយធម៌ទាំងឡាយ ខណៈកុំកន្លងនាងឡើយ ព្រោះពួកជនដែលខណៈកន្លងហើយ រមែងសោកស្ដាយពេញប្រៀបក្នុងនរក ដូច្នេះ ។

( ព្រះនាងធីរាថេរីពោលថា )

ម្នាលនាងធីរា នាងចូរពាល់ត្រូវនូវនិរោធជាសុខ ជាទីរម្ងាប់នូវសញ្ញា នាងចូរត្រេកអរនឹងព្រះនិព្វាន ដ៏ក្សេមចាកយោគៈប្រសើរបំផុត ដូច្នេះ ។

( ព្រះនាងអញ្ញតរាធីរាថេរីពោលថា )

ធីរាភិក្ខុនី មានឥន្ទ្រិយអប់រំហើយ ដោយធម៌ទាំងឡាយ ជាប្រធាននៃព្យាយាម នាងចូរផ្ចាញ់នូវមារព្រមទាំងវាហនៈហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ដូច្នេះ ។

( ព្រះនាងមិត្តាថេរីពោលថា )

ម្នាលនាងមិត្តា នាងបួសដោយសទ្ធាហើយ ចូរជាអ្នកត្រេកអរក្នុងកល្យាណមិត្ត ចូរចម្រើននូវកុសលធម៌ទាំងឡាយដើម្បីដល់នូវព្រះនិព្វានជាទីក្សេមចាកយោគៈ ដូច្នេះ ។

( ព្រះនាងភទ្រាថេរីពោលថា )

ម្នាលនាងភទ្រា នាងបួសដោយសទ្ធាហើយ ចូរជាអ្នកត្រេកអរក្នុងធម៌ដ៏ចម្រើន ( មានសីលជាដើម ) នាងចូរចម្រើននូវកុសលធម៌ទាំងឡាយ ( ដើម្បីដល់ ) នូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរបំផុត ដូច្នេះ ។

( ព្រះនាងឧបសមាថេរីពោលថា )

ម្នាលនាងឧបសមា នាងគប្បីឆ្លងអន្លង់គឺសង្សារ ជាទីនៅនៃមច្ចុ ដែលពួកសត្វឆ្លងបានដោយកម្រក្រៃពេក ចូរនាងផ្ចាញ់

នូវមារព្រមទាំងវាហនៈ ហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យុញ្ជស្សុ ធម្មេហិ** សេចក្ដីថា ចូរប្រកប គឺចូរធ្វើការប្រកបដោយធម៌ គឺសមថៈ និងវិបស្សនាទាំងឡាយ និងដោយពោធិបក្ខិយធម៌ទាំងឡាយដ៏ប្រសើរ ។ បទថា **ខណោ តំ មា ឧបច្ចគា** សេចក្ដីថា បុគ្គលណា មិនធ្វើនូវការចម្រើននូវវត្ថុដែលគួរប្រកបយ៉ាងនេះ ខណៈទាំងអស់នេះ គឺខណៈដែលកើតក្នុងបទេសដ៏សមគួរ ១ ខណៈដែល មានអាយតនៈ ៦ គ្រប់បរិបូណ៌ ១ ខណៈដែលមានព្រះពុទ្ធកើតឡើង ១ ខណៈដែលបាននូវសទ្ធា ១ ឈ្មោះថាឈានកន្លងនូវបុគ្គលនោះទៅ ។ ខណៈនោះកុំបីកន្លងនាងឡើយ ។ បទថា **ខណាតីតា** សេចក្ដីថា ព្រោះបុគ្គលពួកណាធ្វើឲ្យខណៈកន្លងទៅ ខណៈនោះកន្លងបុគ្គលណាទៅ បុគ្គលនោះរមែងចង្អៀតក្នុងនរក សោយសោក គឺកើតក្នុងនរកនោះ សោយនូវទុក្ខធំ ។

បទថា **និរោធំ ផុសេហិ** សេចក្ដីថា ចូរពាល់ត្រូវ គឺចូរបាននូវការរំលត់កិលេស ។ បទថា **សញ្ញាវូបសមំ សុខំ អារាធយាហិ និព្វានំ** សេចក្ដីថា ចូរត្រេកអរក្នុងព្រះនិព្វានដែលជាហេតុឲ្យស្ងប់រម្ងាប់បាបសញ្ញាមានកាមសញ្ញាជាដើម ជាសុខយ៉ាងក្រៃលែង ។

បទថា **ធីរា ធីរេហិ ធម្មេហិ** សេចក្ដីថា អញ្ញតរាធីរាភិក្ខុនីដែលមានឥន្ទ្រិយអប់រំហើយ គឺមានឥន្ទ្រិយ មានសទ្ធាជាដើម ដែលខ្លួនឲ្យចម្រើនហើយដោយធីរធម៌ទាំងឡាយ គឺដោយអរិយមគ្គធម៌ដែលសម្បូរដោយតេជះ ដោយ

ភាពជាអ្នកមានូវបធានគឺសេចក្ដីព្យាយាម ឈ្នះនូវកិលេសមារមួយអន្លើដោយពាហនៈ និងដោយវត្ថុកាមទាំងឡាយ ទ្រទ្រង់ទុកនូវកាយដែលមានក្នុងទីបំផុត ព្រោះមិនកើតតទៅទៀត ព្រះថេរីសម្ដែងឲ្យខ្លួនធ្វើដូចជាអ្នកដទៃ ដោយប្រការដូច្នេះ ។

ព្រះសាស្ដាហៅព្រះថេរី ដោយបទថា **មិត្តេ** ។ បទថា **មិត្តរតា** សេចក្ដីថា ចូរត្រេកអរក្នុងកល្យាណមិត្តទាំងឡាយ គឺចូរធ្វើសក្ការៈ និងសមានក្នុងកល្យាណមិត្តទាំងនោះ ។ បទថា **ភាវេហិ កុសលេ ធម្មេ** សេចក្ដីថា ចូរចម្រើនធម៌ គឺអរិយមគ្គ ។ បទថា **យោគក្ខេមស្ស** បានដល់ ដើម្បីដល់ គឺសម្រេចនូវអរហត្តផង នូវព្រះនិព្វានផង ។

ព្រះសាស្ដាហៅព្រះថេរីនោះដោយបទថា **ភទ្រេ** ។ បទថា **ភទ្ររតា** សេចក្ដីថា ជាអ្នកត្រេកអរហើយ ត្រេកអរក្រៃលែងហើយ ក្នុងធម៌ មានសីលជាដើមដ៏ចម្រើន ។ បទថា **យោគក្ខេមំ អនុត្តរំ** បានដល់ ព្រះនិព្វានដែលក្សេមចាកយោគៈ គឺមិនមានអន្តរាយ សេចក្ដីថា ចូរចម្រើនពោធិបក្ខិយធម៌ដែលជាកុសល ដើម្បីសម្រេចព្រះនិព្វាននោះ ។

ព្រះសាស្ដាហៅព្រះថេរីនោះដោយបទថា **ឧបសមេ** ។ បទថា **តរេ ឱឃំ មច្ចុធេយ្យំ សុទុត្តរំ** សេចក្ដីថា ឈ្មោះថា **មច្ចុធេយ្យំ** ព្រោះជាអន្ទាក់របស់មច្ចុ ឈ្មោះថា **សុទុត្តរំ** ព្រោះបុគ្គលដែលមិនបានសន្សំកុសលសម្ភារទុក ឆ្លងបានដោយលំបាកពន់ពេក ។ ចូរឆ្លងគឺគប្បីប្រើអរិយមគ្គនាវាឆ្លងមហាឱឃៈ គឺសង្សារវដ្ដ ។ បទថា **ធារេហិ អន្តិមំ ទេហំ** សេចក្ដីថា ចូរជាអ្នកទ្រទ្រង់

នូវកាយដែលមានក្នុងភពចុងក្រោយដោយរាងកាយដែលនៅក្មេងនោះឯង ។

## អដ្ឋកថា អញ្ញតរាតិស្សាថេរីគាថាជាដើម ចប់

## មុត្តាថេរីគាថា

[ ២៧៦ ] ខ្ញុំជាអ្នករួចដោយល្អ រួចដោយប្រពៃ ព្រោះការរួចចាក អាការគមបីយ៉ាង គឺត្បាល់ ១ អង្រែ ១ ប្តីគម ១ ខ្ញុំជាអ្នករួចចាក ជាតិនិងមរណៈហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភពខ្ញុំដកចេញហើយ ។

មុត្តាថេរី ។

## អដ្ឋកថា

## មុត្តាថេរីគាថា

[ ២៧៦ ] គាថារបស់មុត្តាថេរីមានពាក្យផ្តើមថា **សុមុត្តា សាធុ មុត្តាម្ហិ** ដូច្នេះជាដើម ។

ព្រះថេរីឈ្មោះមុត្តានេះ មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុន ៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះ ៗ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនស្រីរបស់ព្រាហ្មណ៍ក្រីក្រ ក្នុងកោសលជនបទ កាលចម្រើនវ័យហើយ មាតាបានលើកឲ្យដល់ព្រាហ្មណ៍គមម្នាក់ នាងមិនពេញចិត្តក្នុងការនៅគ្រប់គ្រងផ្ទះជាមួយព្រាហ្មណ៍គមនោះ សូមអនុញ្ញាតបួស ចម្រើនវិបស្សនា ចិត្តរបស់នាងស្ទុះទៅក្នុងអារម្មណ៍ខាងក្រៅ កាលសង្កត់ចិត្តនោះ បានពោលគាថាថា ខ្ញុំជាអ្នករួចដោយល្អ រួចដោយប្រពៃជាដើម ម្តងហើយម្តងទៀត ខ្វល់ខ្វាយក្នុងវិបស្សនា សម្រេចអរហត្តមួយអន្លើដោយ បដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមថា បទុមុត្តរៈ ទ្រង់មានចក្ខុក្នុងធម៌ទាំងពួង ទ្រង់អនុគ្រោះពួកសត្វ យាងចូលកាន់បុរីដើម្បីបិណ្ឌបាត ។ កាលព្រះសាស្តាអង្គនោះយាងមក អ្នកនគរទាំងអស់នោះត្រេកអររីករាយ រួមគ្នាកៀរខ្សាច់ ប្រោសសំអាតផ្លូវ លើកដើមចេកតម្កល់ក្អមដែលមានទឹកពេញ និងលើកទង់ឡើង យកផ្សែងក្រអូប លម្អិតនិងកម្រងផ្កា ធ្វើសក្ការៈព្រះសាស្តា ។ ខ្ញុំចាត់ចែងកសាងមណ្ឌប និមន្តព្រះលោកនាយក ថ្វាយមហាទាន ហើយប្រាថ្នានូវការត្រាស់ដឹង ព្រះមហាវីរៈព្រះនាមថាបទុមុត្តរៈ ទ្រង់ជញ្ជូនសព្វសត្វ ( ឆ្លងសង្សារ ) ជាអគ្គបុគ្គល ទ្រង់អនុមោទនាហើយព្យាករថា

កាលកន្លងទៅ ១០០០០០ កប្ប នឹងមានភទ្ទកប្ប នាងនឹងបានសេចក្តីសុខក្នុងភពតូចធំទាំងឡាយ ហើយសម្រេចពោធិញ្ញាណ ។ បុរសនិងស្ត្រីពួកណា ដែលធ្វើការកសាង ជនទាំងអស់នឹងជួបគ្នាក្នុងអនាគតកាល ។ ដោយវិបាកកម្មនោះ និងដោយចេតនាដែលតាំងមាំ ជនទាំងនោះ នឹងជាអ្នកបម្រើរបស់នាងក្នុងទេវពិភពដែលទៅកើត ។ សោយទិព្វសុខនិងមនុស្សសុខដែលរាប់មិនបាន ពួកយើងត្រាច់ទៅក្នុងភពតូចធំអស់កាលយូរ ។ ក្នុងកប្បទី ១០០០០០ អំពីកប្បនេះ ខ្ញុំបានធ្វើកម្មណាទុក ក្នុងកាលនោះ ដោយកម្មនោះ ខ្ញុំជាអ្នក

សុខុមាលជាតិក្នុងមនុស្សលោកផង ទេវលោកផង ។ ខ្ញុំបាន រូប ភោគៈ យស អាយុ កិត្តិយសនិងសុខដែលគួរត្រេកអរ នេះជាការដល់ព្រមនៃកុសលកម្មដែលធ្វើជាប់តគ្នា ។ កាល ដល់ភពចុងក្រោយ ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនិវេសន៍ ដែលគួរជាទីត្រេកអរ មានដៃនិងជើងប្រកបដោយសុខុមាល ជាតិ ។

ក្នុងកាលទាំងពួង ខ្ញុំមិនឃើញវត្ថុដែលមិនស្អាតលើផែនដី ខ្ញុំមិនឃើញផែនដី ដែលប្រកបដោយភក់មិនស្អាត ក្នុងកាល ណាឡើយ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ដូច្នេះ[១]។

ព្រះថេរីកាលសម្រេចអរហត្តហើយ កាលបន្លឺឧទាន ទើបពោលគាថា នេះថា

ខ្ញុំជាអ្នករួចដោយល្អ រួចដោយប្រពៃ ព្រោះការរួចចាកអាការ គមបីយ៉ាង គឺត្បាល់ ១ អង្រែ ១ ប្ដីគម ១ ខ្ញុំជាអ្នករួចចាក ជាតិនិងមរណៈហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំដក ចេញហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុមុត្តា** បានដល់ ផុតហើយដោយល្អ ។ បទថា **សាធុ មុត្តាម្ហិ** សេចក្ដីថា ជាអ្នករួចផុតដោយល្អ គឺដោយប្រពៃនោះ

---

១-អបទាននេះ មានក្នុងអដ្ឋកថានេះប៉ុណ្ណោះ មិនប្រាកដក្នុងអបទាន ។

ឯង ជាអ្នករួចផុតដោយល្អ ជាអ្នករួចផុតដោយប្រពៃចាកអ្វី ដើម្បីឆ្លើយទើបព្រះថេរីពោលថា **តីហិ ខុជ្ជេហិ មុត្តិយា** អធិប្បាយថា ដោយការរួចផុតចាកការគម ៣ យ៉ាង ។ ឥឡូវនេះ កាលសម្តែងការគម ទាំងនោះដោយសង្ខេប ទើបព្រះថេរីពោលថា ព្រោះការរួចចាកអាការគមបីយ៉ាង គឺត្បាល់ ១ អង្រែ ១ ប្តីគម ១ ដូច្នេះជាដើម ព្រោះថា កាលដាក់អង្ករក្នុងត្បាល់ត្រឡប់អង្ករទៅមក និងបុកដោយអង្រែ ត្រូវធ្វើខ្នងកោង ដូច្នេះ ទើបព្រះថេរីពោលហេតុទាំង ២ ថា គម ព្រោះជាហេតុឲ្យធ្វើនូវការគម ម្យ៉ាងទៀតប្តីរបស់ព្រះថេរីនោះ ជាបុរសគមនោះឯង ។

ឥឡូវនេះ កាលសម្តែងឲ្យជ្រាបថា ព្រោះរួចផុតចាកអ្វី ទើបផុតចាកការគម ៣ យ៉ាង ក៏ពោលថា ខ្ញុំជាអ្នករួចចាកជាតិនិងមរណៈហើយ ដូច្នេះ ។

ពាក្យនោះមានអត្ថថា ខ្ញុំមិនមែនបានរួចផុតត្រឹមតែចាកការគម ៣ យ៉ាងប៉ុណ្ណោះទេ ដែលពិត ខ្ញុំរួចផុតចាកការកើត និងការស្លាប់ទាំងអស់ផងដែរ ព្រោះតណ្ហាដែលនាំទៅកាន់កពទាំងអស់ខ្ញុំដកចោលហើយដោយអរហត្តមគ្គ។

## អដ្ឋកថា មុត្តាថេរីគាថា ចប់

## ធម្មទិន្នាថេរីគាថា

[ ២៧៧ ] នាងថេរីណា មានចំណង់កើតហើយ ( ដើម្បីផលដ៏ប្រសើរ ) ញ៉ាំងសមណកិច្ចឲ្យសម្រេចហើយ គប្បីជាអ្នកពាល់ត្រូវ ( នូវព្រះនិព្វាន ) ដោយមគ្គចិត្ត ( បីខាងក្រោម ) មានចិត្តមិនជាប់ទាក់ទងក្នុងកាមទាំងឡាយ ( នាងថេរីនោះ ) បណ្ឌិតតែងហៅថា ឧទ្ធំសោតា ( អ្នកមានខ្សែគឺមគ្គនិងខ្សែគឺសង្សារក្នុងខាងលើ ) ។

ធម្មទិន្នាថេរី ។

# អដ្ឋកថា

## ធម្មទិន្នាថេរីគាថា

[ ២៧៧ ] គាថារបស់ព្រះថេរីឈ្មោះ ធម្មទិន្នាមានពាក្យផ្ដើមថា **ឆន្ទជាតា អវសាយី** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ក្នុងសាសនាព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ ជាអ្នកអាស្រ័យអ្នកដទៃចិញ្ចឹមជីវិតក្នុងនគរហង្សវតី ថ្វាយទាន បូជាសក្ការៈជាខាងដើម ដល់អគ្គសាវកដែលចេញអំពីនិរោធ កើតនៅក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាផុស្សៈ កុលធីតានេះ នៅក្នុងផ្ទះ ( ជាអ្នកបម្រើ ) នៃបងប្រុសមាតាដទៃនៃព្រះសាស្ដា កាលចៅហ្វាយនាយពោលដល់ទានថា ចូរនាងឲ្យមួយចំណែក ដូច្នេះ នាងក៏ឲ្យ ២ ចំណែក ធ្វើ

បុណ្យដ៏ច្រើន ក្នុងសាសនារបស់ព្រះកស្សបសម្ពុទ្ធ បដិសន្ធិក្នុងព្រះរាជវាំងរបស់ព្រះបាទកាសីព្រះនាមថាកិកិ ជាទារិកាម្នាក់ ក្នុងចំណោមបងប្អូនស្រី ៧ អង្គ ប្រព្រឹត្តព្រហ្មចរិយៈ ២ ម៉ឺនឆ្នាំ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងនគររាជគ្រឹះ ចម្រើនវ័យហើយ ទៅកាន់ផ្ទះរបស់វិសាខសេដ្ឋី ។

ថ្ងៃមួយ វិសាខសេដ្ឋីស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បានជា អនាគាមី ទៅកាន់ផ្ទះ កាលឡើងប្រាសាទ មិនចាប់ដៃនាងធម្មទិន្នាដែលឈរត្រង់ក្បាលជណ្តើរហុចដៃឲ្យ កាលបរិភោគអាហារ ក៏បរិភោគព្រងើយៗ ។ នាងធម្មទិន្នាពិចារណាសេដ្ឋីនោះហើយពោលថា អយ្យបុត្ត ថ្ងៃនេះហេតុអ្វីក៏លោកមិនចាប់ដៃខ្ញុំ កាលបរិភោគអាហារ ក៏មិនពោលពាក្យណាមួយ ខ្ញុំខុសអ្វីឬ ។ វិសាខសេដ្ឋីពោលថា ធម្មទិន្នា នាងមិនខុសអ្វីឡើយ តាំងពីថ្ងៃនេះទៅ ខ្ញុំមិនគួរពាល់កាយស្រី មិនគួរធ្វើសេចក្តីឡេះឡោះក្នុងអាហារ ខ្ញុំចាក់ផ្ទះនូវធម៌ហើយ បើនាងប្រាថ្នា ក៏ចូរនៅក្នុងផ្ទះនេះឯង បើមិនប្រាថ្នា ក៏ចូរកាន់យកទ្រព្យតាមដែលនាងត្រូវការ ទៅកាន់ផ្ទះនៃត្រកូលចុះ ។ នាងធម្មទិន្នា ពោលថា អយ្យបុត្ត ខ្ញុំមិនបរិភោគកន្អុតដែលលោកខ្ជាក់ សូមលោកអនុញ្ញាតឲ្យខ្ញុំបួសចុះ ។ វិសាខសេដ្ឋីពោលថា សាធុ ធម្មទិន្នា ហើយយកវមាសនាំនាងទៅកាន់សម្នាក់ភិក្ខុនី ។

នាងធម្មទិន្នាបួសហើយ រៀនកម្មដ្ឋានក្នុងសម្នាក់ភិក្ខុនី ២-៣ ថ្ងៃ បំណងនៅដោយវិវេក ទើបចូលទៅរកឧបជ្ឈាយ៍ និងអាចារ្យពោលថា បពិត្រអ្នក

នាងម្ចាស់ទាំងឡាយ ចិត្តរបស់ខ្ញុំមិនពេញចិត្តក្នុងទីអ៊ីអ ខ្ញុំនឹងទៅកាន់អាវាស ក្បែរស្រុក ពួកភិក្ខុនីនាំនាងទៅកាន់អាវាសក្បែរស្រុក នាងនៅក្នុងទីនោះ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ព្រោះញុំាញើសន្ធារក្នុងអតីតបានហើយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ជាអ្នកដឹកនាំសត្វលោក ទ្រង់កើតឡើងក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូល ១ ក្នុងក្រុងហង្សវតី ជាអ្នកធ្វើនូវការងារនៃជនដទៃ ខ្ញុំមានប្រាជ្ញាចាស់សង្រួមក្នុងសីល ។ ព្រះថេរៈឈ្មោះសុជាតិ ជាអគ្គសាវកនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ចេញអំពីវត្តទៅដើម្បីបិណ្ឌបាត ។ កាលនោះខ្ញុំចេញទៅដងទឹក កាន់ក្អមដើរទៅ បានឃើញព្រះថេរៈនោះ ក៏មានសេចក្ដីជ្រះថ្លា បានប្រគេននំដោយដៃរបស់ខ្លួន ។ ព្រះថេរៈនោះ ទទួលនំហើយ ក៏គង់ឆាន់ក្នុងទីនោះលំដាប់នោះ ម្ចាស់របស់ខ្ញុំមានចិត្តត្រេកអរនឹងខ្ញុំ បានយកខ្ញុំធ្វើជាកូនប្រសាររបស់ខ្លួន ខ្ញុំទៅជាមួយនឹងម្ដាយក្មេក ថ្វាយបង្គំព្រះសម្ពុទ្ធ ។ គ្រានោះ ព្រះអង្គទ្រង់តាំងភិក្ខុនី ១ រូបជាធម្មកថិកា អ្នកសម្ដែងធម៌ដល់បរិស័ទ ក្នុងទីជាឯតទគ្គ ខ្ញុំបានស្ដាប់ពុទ្ធតម្រាស់នោះហើយ ក៏មានចិត្តរីករាយខ្លាំង ។ ខ្ញុំ

និមន្តព្រះសុគត ជាលោកនាយក ព្រមទាំងភិក្ខុសង្ឃ ថ្វាយមហាទានហើយ ប្រាថ្នានូវតំណែងនោះ ។ លំដាប់នោះ ព្រះសុគត ព្រះអង្គមានសំឡេងណែនរំពងពីរោះ ត្រាស់នឹងខ្ញុំថា នាងជាស្រីត្រេកអរក្នុងការបម្រើតថាគត ជាអ្នកអង្គាសតថាគត ព្រមទាំងភិក្ខុសង្ឃ ។ នាងជាអ្នកប្រកបក្នុងការស្តាប់នូវព្រះសទ្ធម្ម មានចិត្តចម្រើនដោយគុណ ម្នាលនាងដ៏ចម្រើន នាងចូររីករាយចុះ នាងនឹងបាន ផលដែលនាងតាំងប្រាថ្នាទុំ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលក្សត្រឱក្កាកនឹងត្រាស់ឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌នៃព្រះពុទ្ធអង្គនោះ ជាឱរសជាធម្មនិម្មិត បានជាសាវិកានៃព្រះសាស្តា មានឈ្មោះថាធម្មទិន្នា ។ ខ្ញុំបានស្តាប់ព្យាករនោះ ក៏រីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះមហាមុនីជានាយក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធមានផៅពង្សដ៏ប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ព្រះនាមកស្សបៈ កើតឡើងហើយក្នុងភទ្ទកប្បនេះ ។ កាលនោះព្រះរាជាក្នុងដែនកាសី ព្រះនាមកិកី

ជាឥស្សរៈនៃនរៈក្នុងពារាណសីដ៏ឧត្តម ជាឧបដ្ឋាកនៃព្រះពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ ។ ខ្ញុំជាធីតាទី ៦ នៃព្រះរាជាអង្គនោះ មានឈ្មោះប្រាកដជានាងសុធម្មា បានស្តាប់ធម៌នៃព្រះជិនស្រី ដ៏ប្រសើរ ហើយពេញចិត្តនឹងផ្នួស ។ ព្រះបិតារបស់យើងទ្រង់ មិនអនុញ្ញាត កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បាន ប្រព្រឹត្តព្រហ្មចរិយធម៌សម្រាប់កុមារីអស់ ២ ម៉ឺនឆ្នាំក្នុងផ្ទះ ។ ធីតា ៧ អង្គ ជាកញ្ញានៃស្តេចតាំងនៅក្នុងសេចក្តីសុខ ត្រេកអរ រីករាយក្នុងការបម្រើព្រះពុទ្ធ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃ ទាសិកាជាគម្រប់ ៧ ។ ( ធីតា ៧ អង្គនោះ ចេរវិលវិញ មកបានជា ) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលា ១ គោតមី ១ ខ្ជនខ្ញុំ ១ វិសាខា ជាគម្រប់ ៧ ។ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវ ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តឹង្ស ។ ឥឡូវនេះ ដល់មកបច្ឆិម ភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដ៏ស្តុកស្តម្ភ ក្នុងក្រុងគិរិព្វជៈដ៏ ឧត្តម អាចសម្រេចសេចក្តីប្រាថ្នាទាំងពួងបាន ។ កាលណា ខ្ញុំប្រកបដោយគុណគឺរូបសម្បត្តិ តាំងនៅក្នុងបឋមវ័យហើយ កាលនោះឯង ខ្ញុំបានទៅកាន់ត្រកូលនៃបុរសដទៃ ( មានប្តី )

ហើយនៅស្កប់ស្កល់ដោយសេចក្តីសុខ ។ ឯស្វាមីរបស់ខ្ញុំនោះ មានប្រាជ្ញាល្អ បានចូលទៅគាល់ព្រះពុទ្ធជាទីពឹងនៃសត្វលោក ស្តាប់ធម៌ទេសនាហើយក៏បានដល់នូវ អនាគាមិផល ។ កាលនោះខ្ញុំបានញ៉ាំងស្វាមីនោះឲ្យអនុញ្ញាតហើយ ចូលទៅកាន់ផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានដល់ព្រះអរហត្ត ។ កាលនោះ ឧបាសកនោះ ចូលមករកខ្ញុំ ហើយសួរនូវប្រស្នាទាំងឡាយដ៏ជ្រាលជ្រៅ ខ្ញុំក៏បានព្យាករប្រស្នាទាំងអស់នោះ ។ ព្រះជិនស្រីត្រេកអរក្នុងគុណនោះហើយ បានតាំងខ្ញុំក្នុងទីជាឯតទគ្គថា តថាគតមិនឃើញភិក្ខុនីជាធម្មកថិកាដទៃ ប្រាកដដូចភិក្ខុនីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះថា នាងធម្មទិន្នាជាអ្នកប្រាជ្ញ ។

ខ្ញុំឈ្មោះថាជាស្រីបណ្ឌិត ដែលព្រះលោកនាយកអនុគ្រោះដោយប្រការយ៉ាងនេះឯង ។ ព្រះសាស្តា ខ្ញុំបានបម្រើដោយគោរពហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានរំលើងចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណាប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួងខ្ញុំបានសម្រេចហើយ ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមពុទ្ធសាសនា ដឹងនូវចិត្តនៃបុគ្គលដទៃ

ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វ-
ចក្ខុ ខ្ញុំបានជម្រះហើយ ខ្ញុំញ៉ាំងអាសវៈទាំងពួងឲ្យអស់ហើយ
ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលសោះឡើយ ។ កិលេស
ទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះ
ពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ព្រះនាងធម្មទិន្នាថេរីគិតថា ចិត្តរបស់អញ អស់កិលេសហើយ ឥឡូវនេះ អញនឹងនៅធ្វើអ្វីក្នុងទីនេះអញនឹងទៅកាន់ក្រុងរាជគ្រឹះថ្វាយបង្គំព្រះសាស្តា ពួកញាតិរបស់អញជាច្រើននឹងធ្វើបុណ្យ ទើបត្រឡប់មកកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយភិក្ខុនីទាំងឡាយ ។

វិសាខឧបាសកដឹងថា ព្រះនាងធម្មទិន្នាថេរីត្រឡប់មក កាលនឹងពិសោធការត្រាស់ដឹងរបស់ព្រះថេរីនោះ បានសួរបញ្ហាអំពីបញ្ចក្ខន្ធជាដើម ព្រះនាងធម្មទិន្នាថេរី បានវិសជ្ជនាបញ្ហា ដែលសួរហើយ ដូចកាត់ដើមឈូកដោយសស្ត្រាដ៏មុត ដូច្នោះ ។ វិសាខឧបាសក ក្រាបទូលន័យរបស់សំណួរនិងចម្លើយទាំងអស់ដល់ព្រះសាស្តា ព្រះសាស្តាទ្រង់សរសើរព្រះថេរីនោះដោយព្រះពុទ្ធវចនៈថា ម្នាលវិសាខ ធម្មទិន្នាភិក្ខុនីជាបណ្ឌិតជាដើម ទ្រង់ប្រកាសការព្យាករបញ្ហាដែលប្រៀបធៀបជាមួយនឹងសព្វញ្ញុតញ្ញាណ ទ្រង់ធ្វើចូឡវេ-ទល្លសូត្រនោះឯងឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់តាំងនាងធម្មទិន្នាថេរីនោះទុកក្នុងតំណែងឯតទគ្គៈជាងភិក្ខុនីទាំងឡាយខាងធម្មកថិក ព្រះថេរីនៅក្នុងអាវាសក្បែរស្រុកនោះ សម្រេចមគ្គខាងដើមហើយ ផ្ដើមចម្រើនវិបស្សនាដើម្បីមគ្គខាង

លើក្នុងកាលណា ក្នុងកាលនោះ បានពោលគាថានេះថា

នាងថេរីណាមានចំណង់កើតហើយ ( ដើម្បីផលដ៏ប្រសើរ ) ញុំាងសមណកិច្ចឲ្យសម្រេចហើយ គប្បីជាអ្នកពាល់ត្រូវ ( នូវព្រះនិព្វាន ) ដោយមគ្គចិត្ត ( បីខាងក្រោម ) មានចិត្តមិនជាប់ទាក់ទងក្នុងកាមទាំងឡាយ ( នាងថេរីនោះ ) បណ្ឌិតតែងហៅថា ឧទ្ធំសោតា ( អ្នកមានខ្សែគឺមគ្គ និងខ្សែគឺសង្សារក្នុងខាងលើ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆន្ទជាតា** បានដល់ កើតនូវឆន្ទៈដើម្បីអរហត្តផល ការអស់ គឺការបញ្ចប់ លោកហៅថា **អវសាយី** ។ ក្នុងបទថា **អវសាយី** នោះ គប្បីជ្រាបថា ការបញ្ចប់នៃសមណកិច្ចនោះឯង មិនមែនកិច្ចដទៃឡើយ ព្រោះព្រះថេរីពោលទុកថា មានចិត្តមិនជាប់ទាក់ទងក្នុងកាមទាំងឡាយ ( នាងថេរីនោះ ) បណ្ឌិតតែងហៅថា ឧទ្ធំសោតា ព្រោះហេតុនោះទើបបទទាំង ២ ( **ឆន្ទជាតា អវសាយី** ) មានអត្ថថា បុគ្គលមានចិត្តមិនទាន់សមបំណង គឺបុគ្គលត្រូវការសេចក្ដីក្សេមចាកយោគៈដ៏កំពូល ។ បទថា **មនសា ច ផុដ្ឋា សិយា** សេចក្ដីថា គប្បីជាអ្នកពាល់ត្រូវ គឺប៉ះនូវព្រះនិព្វានដោយមគ្គចិត្ត ៣ ខាងក្រោម ។ បទថា **កាមេសុ អប្បដិពទ្ធចិត្តា** បានដល់ជាអ្នកមានចិត្តមិនប្រតិព័ទ្ធក្នុងកាមទាំងឡាយ ដោយអំណាចអនាគាមិមគ្គ ។ បទថា **ឧទ្ធំសោតា** សេចក្ដីថា ឈ្មោះថា **ឧទ្ធំសោតា** ព្រោះព្រះថេរីនោះមានខ្សែមគ្គនិងខ្សែសង្សារវដ្តខាងលើនោះឯង អធិប្បាយថា អរហត្ត-

មគ្គ រមែងកើតឡើងដល់ព្រះអនាគាមី មគ្គដទៃរមែងមិនកើតយ៉ាងណា ព្រះអនាគាមី ដែលកើតក្នុងសុទ្ធាវាសកព មានអវិហាជាដើម រមែងមានការកើតក្នុងជាន់ខាងលើរហូតដល់អកនិដ្ឋកព ក៏យ៉ាងនោះ ។

## អដ្ឋកថាធម្មទិន្នាថេរីគាថា ចប់

## វិសាខាថេរីគាថា

[ ២៧៨ ] អ្នកទាំងឡាយ ចូរធ្វើតាមព្រះពុទ្ធសាសនាដែលគេធ្វើហើយ មិនក្តៅក្រហាយតាមក្រោយ ចូរលាងជើងទាំងឡាយឲ្យឆាប់ ហើយអង្គុយក្នុងទីសមគួរ ។

វិសាខាថេរី ។

## អដ្ឋកថា
## វិសាខាថេរីគាថា

[ ២៧៨ ] គាថារបស់ព្រះថេរីឈ្មោះ វិសាខា មានពាក្យផ្តើមថា **ករោថ ពុទ្ធសាសនំ** ដូច្នេះជាដើម ។

រឿងរបស់ព្រះថេរីឈ្មោះវិសាខានោះ ដូចគ្នានឹងរឿងរបស់ព្រះថេរីឈ្មោះធីរានោះឯង ។ ព្រះថេរីឈ្មោះវិសាខានោះ សម្រេចអរហត្តហើយ ញុំាងកាលវេលាឲ្យកន្លងទៅដោយវិមុត្តិសុខ បានព្យាករអរហត្តផល ដោយគាថានេះថា

អ្នកទាំងឡាយ ចូរធ្វើតាមព្រះពុទ្ធសាសនា ដែលគេធ្វើហើយ
មិនក្តៅក្រហាយតាមក្រោយ ចូរលាងជើងទាំងឡាយឲ្យឆាប់
ហើយអង្គុយក្នុងទីសមគួរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ករោថ ពុទ្ធសាសនំ** សេចក្តីថា ចូរធ្វើតាមពាក្យប្រៀនប្រដៅ គឺពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺចូរ

បដិបត្តិតាមពាក្យប្រៀនប្រដៅ ។ បទថា **យំ កត្វា នានុតប្បតិ** សេចក្ដីថា ព្រោះធ្វើឲ្យអ្នកធ្វើតាមពាក្យប្រៀនប្រដៅដែលធ្វើហើយ មិនក្ដៅក្រហាយក្នុងកាលជាក្រោយសម្រេចបំណងបានដោយប្រពៃពិត ។ បទថា **ខិប្បំ បាទានិ ធោវិត្វា ឯកមន្តេ និសីទថ** សេចក្ដីថា ព្រោះខ្លួនឯងត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្ត សម្ដែងវត្តដល់អាចារ្យនិងឧបជ្ឈាយ៍ហើយ លាងជើងទាំង ២ អង្គុយក្នុងទីស្ងាត់ ក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន ហើយញ៉ាំងប្រយោជន៍របស់ខ្លួនឲ្យដល់ទីបំផុត ហេតុនោះ ព្រះនាងវិសាខាថេរី កាលបបួលអ្នកដទៃឲ្យធ្វើប្រយោជន៍នោះដែរ ទើបពោលបទនេះ ។

អដ្ឋកថា វិសាខាថេរីគាថា ចប់

# សុមនាថេរីគាថា

[ ២៧៩ ] នាងឃើញធាតុទាំងឡាយថាជាទុក្ខ កុំមកកាន់កំណើតថ្មីទៀតឡើយ នាងរំសាយចំណង់ក្នុងភពចេញ ទើបស្ងប់រម្ងាប់បាន ។

សុមនាថេរី ។

# អដ្ឋកថា

## សុមនាថេរីគាថា

[ ២៧៩ ] គាថារបស់ព្រះថេរីឈ្មោះសុមនាមានពាក្យផ្ដើមថា **ធាតុយោ ទុក្ខតោ ទិស្វា** ដូច្នេះជាជាដើម ។

រឿងរបស់ព្រះថេរីឈ្មោះសុមនានោះ ដូចគ្នានឹងរឿងរបស់ព្រះថេរីឈ្មោះតិស្សា ។ មានសេចក្ដីសង្ខេបថា ព្រះសាស្ដាទ្រង់បញ្ចេញព្រះរស្មី បង្ហាញព្រះកាយដូចគង់ក្នុងទីចំពោះមុខ ត្រាស់ព្រះគាថានេះថា

នាងឃើញធាតុទាំងឡាយថាជាទុក្ខ កុំមកកាន់កំណើតថ្មីទៀត
ឡើយ នាងរំសាយចំណង់ ក្នុងភពចេញ ទើបស្ងប់រម្ងាប់បាន
ដូច្នេះ ។

ក្នុងកាលចប់គាថា ព្រះថេរីនោះបានសម្រេចអរហត្ត ។

បណ្ដាបទទាំងនោះបទថា **ធាតុយោ ទុក្ខតោ ទិស្វា** សេចក្ដីថា ឃើញធាតុ មានចក្ខុជាដើមដែលទាក់ទងដោយសន្តតិ និងធាតុដទៃដោយញាណចក្ខុថាជាទុក្ខ ព្រោះកើតឡើង វិនាសទៅ និងបៀតបៀនជាដើម ។ បទថា **មា**

**ជាតឹ បុនរាគមិ** សេចក្ដីថា កុំចូលដល់ជាតិ គឺភពថ្មីតទៅទៀត ឡើយ ។ បទថា **ភវេ ឆន្ទំ វិរាជេត្វា** សេចក្ដីថា លះនូវឆន្ទៈ គឺតណ្ហាក្នុងភពទាំងពួង មានកាមភពជាដើម ដោយមគ្គ ពោលគឺវិរាគៈ ។ បទថា **ឧបសន្តោ ចរិ-ស្សសិ** សេចក្ដីថា នឹងជាអ្នករំលត់ ព្រោះលះកិលេសបានទាំងអស់ ។

ម្យ៉ាងទៀត ក្នុងគាថានេះ គប្បីជ្រាបថា លោកសម្ដែងវិបស្សនាដោយមាតិការបស់ទុក្ខានុបស្សនា ដោយបទថា **ធាតុយោ ទុក្ខតោ ទិស្វា** ដូច្នេះ ។ សម្ដែងមគ្គដោយបទថា **ភវេ ឆន្ទំ វិរាជេត្វា** ដូច្នេះ ។ សម្ដែងឧបាទិសេសនិព្វានធាតុដោយបទថា **ឧបសន្តោ ចរិស្សសិ** ដូច្នេះ ។ សម្ដែងអនុបាទិសេសនិព្វានធាតុ ដោយបទថា **មា ជាតឹ បុនរាគមិ** ដូច្នេះ ។

អដ្ឋកថា សុមនាថេរីគាថា ចប់

## ឧត្តរាថេរីគាថា

[ ២៨០ ] ខ្ញុំជាអ្នកសង្រួមដោយកាយ ដោយវាចា ដោយចិត្ត បានដក តណ្ហាព្រមទាំងឫស ( ឬព្រមទាំងអវិជ្ជា ) ជាអ្នកមានចិត្តត្រជាក់ សម្រេច អនុបាទិសេសនិព្វានធាតុ ។

ឧត្តរាថេរី ។

## អដ្ឋកថា
## ឧត្តរាថេរីគាថា

[ ២៨០ ] គាថារបស់ព្រះថេរីឈ្មោះឧត្តរា មានពាក្យផ្ដើមថា **កាយេន សំវុតា អាសឹ** ដូច្នេះជាដើម ។

រឿងរបស់ព្រះថេរីឈ្មោះឧត្តរានោះ ក៏ដូចគ្នានឹងរឿងរបស់ព្រះថេរីឈ្មោះ តិស្សា ។ មានសេចក្ដីសង្ខេបថា ព្រះថេរីឈ្មោះឧត្តរានោះប្រសូតក្នុងសក្យ-ត្រកូល ជាស្នំរបស់ព្រះពោធិសត្វ ចេញបួសជាមួយព្រះនាងមហាបជាបតិ គោតមី សម្រេចអរហត្តដោយឱភាសគាថា បានពោលគាថានេះ ជាឧទាន ដោយខ្លួនឯងថា

ខ្ញុំជាអ្នកសង្រួមដោយកាយ ដោយវាចា ដោយចិត្ត បានដក
តណ្ហាព្រមទាំងឫស ( ឬព្រមទាំងអវិជ្ជា ) ជាអ្នកមានចិត្ត
ត្រជាក់ សម្រេចអនុបាទិសេសនិព្វានធាតុ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាយេន សំវុតា អាសឹ** សេចក្ដីថា ជាអ្នក

សង្រួមហើយដោយការសង្រួមតាមកាយ ។ បទថា **វាចាយ** ប្រែកបសេចក្ដីថា ជាអ្នកសង្រួមហើយដោយការសង្រួមផ្លូវវាចា ។ ដោយបទទាំង ២ ព្រះមានព្រះភាគពោលដល់សីលសំវរៈ ។ បទថា **ឧទ** ប្រែថា និង ។ បទថា **ចេតសា** សេចក្ដីថា ដោយសមាធិចិត្ត ។ ព្រះមានព្រះភាគត្រាស់ការចម្រើនវិបស្សនាដោយពាក្យនេះ ។ បទថា **សមូលំ តណ្ហំ អព្ពុយ្ហ** សេចក្ដីថា ដកឡើងនូវតណ្ហា មួយអន្លើដោយឫស ឬមួយអន្លើដោយអវិជ្ជា ។ ដ្បិតថា តណ្ហារមែងកើតឡើងក្នុងភព ៣ ដែលត្រូវអវិជ្ជាបិទបាំងទុក ។

ន័យម្យ៉ាងទៀត បទថា **កាយេន សំវុតា** សេចក្ដីថា ជាអ្នកសង្រួមតាមកាយ ដោយការសង្រួមដោយមគ្គនោះឯង ព្រោះលះនូវមិច្ឆាកម្មន្តៈទាំងអស់ដោយសម្មាកម្មន្តៈ ។ បទថា **វាចាយ** សេចក្ដីថា ជាអ្នកសង្រួមតាមវាចា ដោយការសង្រួមដោយមគ្គនោះឯង ព្រោះលះនូវមិច្ឆាវាចាទាំងអស់ដោយសម្មាវាចា ។ បទថា **ចេតសា** បានដល់ ដោយសមាធិ ។ ក្នុងទីនេះព្រះមានព្រះភាគ ពោលដល់សមាធិដោយមាតិការបស់ចិត្ត អធិប្បាយថា មគ្គធម៌ទាំងឡាយ មានសម្មាទិដ្ឋិជាដើម មានលក្ខណៈតែមួយដូចគ្នានឹងមគ្គលក្ខណៈ ដែលទ្រង់កាន់យកដោយសព្ទ គឺសម្មាសមាធិនោះឯង ។ ការលះអសំវរៈ មានអភិជ្ឈាជាដើម ដោយមិនសេសសល់ ឈ្មោះថា លោកសម្ដែងហើយដោយមគ្គសំវរៈ ។ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា **សមូលំ តណ្ហំ អព្ពុយ្ហ** ដូច្នេះ ។ បទថា **សីតិភូតាម្ហិ និព្វុតា** សេចក្ដីថា ជាអ្នកដល់នូវការត្រជាក់ ព្រោះមិនមានការក្ដៅដោយអំណាចកិលេសដោយប្រការ

ទាំងពួង ជាអ្នករំលត់ឥតសេសសល់ដោយអនុបាទិសេសនិព្វានធាតុ ។

## អដ្ឋកថា ឧត្តរាថេរីគាថា ចប់

## សុមនា វុឌ្ឍបព្វជិតាថេរីគាថា

[ ២៨១ ] ម្នាលនាងចម្រើនដោយសីលាទិគុណ នាងចូរដេកស្រួល នាងចូរធ្វើ ( ចីវរ ) ដោយសំពត់ ( បង្សុកូល ) ស្លៀកដណ្តប់ ព្រោះថាបើរាគៈរបស់នាង ស្ងប់រម្ងាប់ហើយ នាងនឹងជាស្រ្តីមានចិត្តត្រជាក់ រលត់កិលេស ។

សុមនាថេរីបួសឯចាស់ ។

## អដ្ឋកថា

## សុមនា វុឌ្ឍបព្វជិតាថេរីគាថា

[ ២៨១ ] គាថារបស់ព្រះថេរីដែលបួសឯចាស់ ឈ្មោះសុមនា មានពាក្យផ្តើមថា **សុខំ ត្វំ វុឌ្ឍិកេ សេហិ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតជាព្រះភគិនីរបស់ព្រះបាទមហាកោសលក្នុងក្រុងសាវត្ថី ស្តាប់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងដល់ព្រះបាទបសេនទិកោសល ដោយន័យ ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា បពិត្រមហារាជ សភាវៈ ៤ ពួកនេះ បុគ្គលមិនគប្បីមើលងាយថា ក្មេង ដូច្នេះជាដើម កាលបានទូវសេចក្តីជ្រះថ្លា តាំងនៅក្នុងសរណៈនិងសីល ៥ សូម្បីបំណងនឹងបួស ក៏ត្រូវឲ្យពេលវេលាកន្លងទៅយូរ ព្រោះគិតថា ត្រូវបដិបត្តិមើលថែព្រះអយ្យកា តមក

កាលព្រះអយ្យកាអស់ព្រះជន្មហើយ ព្រះនាងឲ្យមនុស្សក្រាន់កម្រាល គ្រឿងស្មៀកដណ្តប់ដែលមានតម្លៃច្រើន ទៅកាន់វិហារជាមួយព្រះរាជា បានថ្វាយដល់សង្ឃ រួចស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា តាំងនៅក្នុងអនាគាមិផល ទើបសូមបួស ព្រះសាស្តា ទ្រង់ឃើញព្រះនាងមានញាណចាស់ក្លា បានភាសិតគាថានេះថា

ម្នាលនាងចម្រើនដោយសីលាទិគុណ នាងចូរដេកស្រួល នាងចូរធ្វើ ( ចីវរ ) ដោយសំពត់ ( បង្សុកូល ) ស្លៀកដណ្តប់ ព្រោះថា បើរាគៈរបស់នាងស្ងប់រម្ងាប់ហើយ នាងនឹងជាស្ត្រីមានចិត្តត្រជាក់រលត់កិលេស ដូច្នេះ ។

ក្នុងកាលចប់គាថា នាងបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ បានពោលគាថានោះឯងជាឧទាន ការពោលគាថាជាឧទាននោះឯង បានជាការព្យាករអរហត្តផលរបស់ព្រះថេរី ។ នាងបួសក្នុងខណៈនោះឯង ។ បទថា **វុឌ្ឍិកេ** ក្នុងគាថាមានអត្ថថា ជាអ្នកចម្រើន គឺចម្រើនដោយវ័យ តែព្រះថេរីចម្រើនដោយគុណមានសីលជាដើម ។ បទថា **សីតិភូតាសិ** ក្នុងបាទទី ៤ ជាពាក្យពន្រឹកសេចក្តីនៃគាថាដែលត្រាស់ដល់ព្រះថេរី ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា វុឌ្ឍបព្វជិតសុមនាថេរីគាថា ចប់

## ធម្មាថេរីគាថា

[ ២៨២ ] ខ្ញុំមានកម្លាំងថយ កាន់ឈើច្រត់ដើរទៅបិណ្ឌបាត មានខ្លួនញ័រញាក់ ដួលលើផែនដីក្នុងទីនោះឯង លំដាប់នោះចិត្តរបស់ខ្ញុំក៏រួច ស្រឡះ ( ចាកកិលេស ) ព្រោះឃើញទោសក្នុងកាយ ។

**ធម្មាថេរី ។**

## អដ្ឋកថា

## ធម្មាថេរីគាថា

[ ២៨២ ] គាថារបស់ព្រះថេរីឈ្មោះធម្មាមានពាក្យផ្តើមថា **បិណ្ឌចារំ ចរិត្វាន** ដូច្នេះជាដើម ។

បានឮថា កុលធីតាអង្គនេះ មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ បានរួបរួមបុញ្ញសម្ភារទុកហើយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងនគរសាវត្ថី ចម្រើនវ័យហើយ ទៅកាន់ផ្ទះរបស់ស្វាមីដែលមានឋានៈស្មើគ្នា បាននូវសទ្ធាក្នុងសាសនារបស់ព្រះសាស្ដា បំណងនឹងបួស តែស្វាមីមិនអនុញ្ញាត ក្រោយមក កាលប្តីអស់ជីវិតហើយក៏បួស ចម្រើនវិបស្សនា ។ ថ្ងៃមួយត្រាច់បិណ្ឌបាត កំពុងដើរមកកាន់វិហារ ក៏ដួល ទើបធ្វើរឿងនោះឯងឲ្យជាអារម្មណ៍ ចម្រើនវិបស្សនា សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ បានពោលគាថានេះជាឧទានថា

ខ្ញុំមានកម្លាំងថយ កាន់ឈើច្រត់ ដើរទៅបិណ្ឌបាត មានខ្លួនញ័រញ៉ោង ដួលលើផែនដីក្នុងទីនោះឯង លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួចស្រឡះ ( ចាកកិលេស ) ព្រោះឃើញទោសក្នុងកាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បិណ្ឌចារំ ចរិត្វាន ទណ្ឌមាទាយ ទុព្វលា** សេចក្ដីថា ប្រើឈើច្រត់ទប់ខ្លួនត្រាច់ទៅក្នុងនគរដើម្បីបិណ្ឌបាត គឺត្រាច់ភិក្ខាចារ ។ បទថា **ឆមា** បានដល់ លើផែនដី អធិប្បាយថា ដួលចុះលើផែនដីព្រោះជើងទាំង ២ មិនមានកម្លាំង ។ បទថា **ទិស្វា អាទីនវំ កាយេ** សេចក្ដីថា ឃើញទោសក្នុងសរីរៈដោយប្រការផ្សេងៗ មានមិនស្អាត មិនទៀងជាទុក្ខ និងជាអនត្តាជាដើម ដោយបញ្ញាចក្ខុ ។ បទថា **អថ ចិត្តំ វិមុច្ចិ មេ** សេចក្ដីថា ចិត្តរបស់ខ្ញុំ រួចផុតហើយចាកកិលេសទាំងឡាយ ព្រោះសង្កត់ដោយនិព្វិទានុបស្សនាជាដើម ដែលកើតឡើងមុនអាទីនវានុបស្សនា ឈ្មោះថា **វិមុច្ចិ** គឺផុតវិសេសហើយដោយប្រការទាំងពួងដោយសមុច្ឆេទវិមុត្តិតាមលំដាប់មគ្គផល និងដោយបដិបស្សទ្ធិវិមុត្តិទៀត អធិប្បាយថា ឥឡូវនេះវត្ថុដែលត្រូវរួចផុតមិនមានដល់ព្រះថេរីនោះ ម្យ៉ាងទៀត ការពោលគាថាជាឧទាននេះឯងជាការព្យាករអរហត្តផលព្រះថេរីនោះ ដូច្នេះ ។

**អដ្ឋកថា ធម្មាថេរីគាថា ចប់**

## សង្ឃាថេរីគាថា

[ ២៨៣ ] ខ្ញុំបានលះបង់ផ្ទះ លះកូនជាទីស្រឡាញ់និងសត្វចិញ្ចឹម ហើយមកបួស បានលះរាគៈនិងទោសៈ រំសាយអវិជ្ជា គឺមោហៈ បានដកតណ្ហាព្រមទាំងឫស ជាស្រីស្ងប់រម្ងាប់ ហើយបានសម្រេច អនុបាទិសេសនិព្វានធាតុ ។

សង្ឃាថេរី ។

ចប់ ឯកនិបាត ។

## អដ្ឋកថា

## សង្ឃាថេរីគាថា

[ ២៨៣ ] គាថារបស់ព្រះថេរីឈ្មោះ សង្ឃា មានពាក្យផ្តើមថា **ហិត្វា ឃរេ បព្ពជិត្វា** ដូច្នេះជាដើម ។

រឿងរបស់ព្រះថេរីឈ្មោះ សង្ឃា នោះ ដូចរឿងរបស់ព្រះថេរីឈ្មោះធីរា ព្រះថេរីឈ្មោះសង្ឃានោះ សម្រេចអរហត្តហើយ បានពោលគាថានេះថា

ខ្ញុំបានលះបង់ផ្ទះ លះកូនជាទីស្រឡាញ់ និងសត្វចិញ្ចឹមហើយ
មកបួស បានលះរាគៈនិងទោសៈ រំសាយអវិជ្ជា គឺមោហៈ
បានដកតណ្ហា ព្រមទាំងឫស ជាស្រីស្ងប់រម្ងាប់ ហើយបាន
សម្រេចអនុបាទិសេសនិព្វានធាតុ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិត្វា** បានដល់ លះហើយ ។ បទថា

**ឃរេ** បានដល់ នៅផ្ទះ ។ **ឃរ** សព្ទ សូម្បីនៅក្នុងរូបសព្ទឯកវចនៈ ជួនកាលក៏ប្រើក្នុងអត្ថពហុវចនៈ ព្រោះពង្រីកសេចក្ដីដូច **ពីដំ** ប្រើជាមួយពួជច្រើនយ៉ាង ។ បទថា **ហិត្វា បុត្តំ បសុំ បិយំ** សេចក្ដីថា លះបុត្ត និងសត្វចិញ្ចឹម មានគោក្របីជាដើម ដែលជាទីស្រឡាញ់ ដោយការលះឆន្ទរាគៈដែលទាក់ទងដោយកូននិងសត្វចិញ្ចឹមនោះ ។ បទថា **ហិត្វា រាគញ្ច ទោសញ្ច** សេចក្ដីថា ដកនូវរាគៈដែលមានសភាវៈត្រេកត្រអាល និងទោសៈដែលមានភាវៈអាក់អន់ដោយអរិយមគ្គ ។ បទថា **អវិជ្ជញ្ច វិរាជិយ** សេចក្ដីថា ខ្ទាក់នូវមោហៈដែលជាខាងដើមក្នុងអកុសលទាំងអស់ ដោយអត្ថថា ដកបានដោយមគ្គនោះឯង ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

អដ្ឋកថា សង្ឃាថេរីគាថា ចប់

ថេរីគាថា ឯកនិបាត ចប់

# ទុកនិបាត ថេរីគាថា

## នន្ទាថេរីគាថា

[ ២៨៤ ] ម្នាលនាងនន្ទា នាងចូរមើល ( រាងកាយនេះ ) មានជំងឺជានិច្ច មិនស្អាត ជារបស់ស្អុយ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំឡើងហើយ ចូរនាងអប់រំចិត្តដោយអសុភសញ្ញា ឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ ចូរនាងចម្រើននូវអនិមិត្ត ចូរលះបោលនូវមានានុស័យ នាងនឹងបានស្ងប់រម្ងាប់ ព្រោះបានលះនូវមានះនោះ ។

ឮថា ព្រះមានព្រះភាគ ទ្រង់ទូន្មានរឿយៗនូវសិក្ខមានាឈ្មោះ នន្ទាដោយគាថាទាំងនេះ ដោយប្រការដូច្នេះ ។

នន្ទាថេរី ។

# អដ្ឋកថា

## ទុកនិបាត ថេរីគាថា

## នន្ទាថេរីគាថា

ក្នុងទុកនិបាត ថេរីគាថា មានវិនិច្ឆ័យដូចតទៅនេះថា

[ ២៨៤ ] គាថារបស់សិក្ខមានា ឈ្មោះ អភិរូបនន្ទា មានពាក្យផ្ដើមថា **អាតុរំ អសុចឹ បូតឹ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាម វិបស្សី

កើតជាធីតារបស់គហបតីមហាសាល ក្នុងពន្ធុមតីនគរ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា តាំងនៅក្នុងសរណៈនិងសីល កាលព្រះសាស្ដាបរិនិព្វានហើយ បានបូជាព្រះធាតុចេតិយ ដោយឆត្រមាស ដែលប្រដាប់ដោយរតនៈ អស់ជីវិតហើយ ទៅកើតក្នុងស្ថានសួគ៌ អន្ទោលទៅមកក្នុងសុគតិភូមិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទៃអគ្គមហេសីរបស់ស្ដេចខេមកសក្យៈក្នុងនគរកបិលពស្ដុ មានឈ្មោះថា នន្ទា ព្រះនាងនន្ទានោះ មានរូបគួរមើល គួរជ្រះថ្លា គេស្គាល់ទូទៅថា អភិរូបនន្ទា ព្រោះអត្តភាពដល់នូវលម្អដ៏ក្រៃលែង លុះនាងចម្រើនវ័យហើយ សក្យកុមារដែលជាទីស្រឡាញ់ក្រៃលែងបានអស់ព្រះជន្មក្នុងថ្ងៃភ្ជាប់ពាក្យនោះឯង គ្រានោះព្រះជនកព្រះជននីក៏ឲ្យបួស ទាំងដែលនាងមិនចង់បួស ។

ភិក្ខុនីអភិរូបនន្ទានោះ សូម្បីបួសហើយ ក៏នៅមានការស្រវឹង ព្រោះអាស្រ័យរូប មិនទៅកាន់ទីបដិបត្តិព្រះសម្ពុទ្ធ ដោយយល់ថា ព្រះសាស្ដាទ្រង់តិះដៀលរូប ទ្រង់សម្ដែងទោសក្នុងរូបដោយអនេកបរិយាយ ។ ព្រះសាស្ដាទ្រង់ជ្រាបថា ភិក្ខុនីនោះមានបញ្ញាចាស់ក្លាហើយ ទ្រង់ត្រាស់នឹងនាងមហាបជាបតីថា ភិក្ខុនីទាំងអស់មកទទួលឱវាទតាមលំដាប់ កាលដល់វារៈរបស់ខ្លួន នាងបញ្ជូនភិក្ខុនីដទៃទៅ ព្រះសាស្ដាត្រាស់ថា កាលដល់វារៈ ( ទទួលឱវាទ ) ភិក្ខុនីគប្បីទៅដោយខ្លួនឯង មិនគប្បីបញ្ជូនភិក្ខុនីដទៃទៅជំនួសឡើយ ។ នាងមិនអាចបំពានព្រះតម្រាស់របស់ព្រះមុនីបាន ទើបទៅបដិបត្តិព្រះសម្ពុទ្ធ មួយអន្លើដោយភិក្ខុនីទាំងឡាយ ។ ព្រះមានព្រះភាគទ្រង់

និម្មិតរូបស្រីស្អាតម្នាក់ដោយឫទ្ធិ ហើយទ្រង់ធ្វើឲ្យរូបនោះចាស់ ឲ្យនាងកើតសេចក្ដីសង្វេគ ហើយត្រាស់គាថា ២ ថា

ម្នាលនាងនន្ទា នាងចូរមើល ( រាងកាយនេះ ) មានជំងឺ ជានិច្ច មិនស្អាត ជារបស់ស្អុយ ដែលធ្អឹង ៣០០ កំណាត់ផ្គុំឡើងហើយ ចូរនាងអប់រំចិត្តដោយអសុភសញ្ញាឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ ចូរនាងចម្រើននូវអនិមិត្ត ចូរលះបោលនូវមានានុស័យ នាងនឹងបានស្ងប់រម្ងាប់ ព្រោះបានលះនូវមានៈនោះ ដូច្នេះ ។

អត្ថនៃគាថានោះ មានន័យដូចពោលហើយខាងដើមនោះឯង ។ ក្នុងកាលចប់គាថា ភិក្ខុនីឈ្មោះអភិរូបនន្ទាសម្រេចអរហត្តសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងនគរអរុណវតី មានក្សត្រមួយព្រះអង្គ ព្រះនាមអរុណៈខ្ញុំជាអគ្គមហេសី របស់ស្ដេចនោះ ខ្ញុំបានញ៉ាំងជនពួកខ្លះ ឲ្យបម្រើ ។ ក្នុងកាលនោះ ខ្ញុំអង្គុយក្នុងទីស្ងាត់ហើយត្រិះរិះយ៉ាងនេះថា បើអាត្មាអញមិនបានធ្វើកុសល ដែលគប្បីកាន់យកទៅបានទេ អាត្មាអញនឹងទៅកាន់នរក មានសេចក្ដីក្ដៅក្រហាយធំខ្លាចផ្សា មានសភាពឃោរឃៅ អាក្រក់ក្រៃលែងដោយពិត សេចក្ដីសង្ស័យរបស់អាត្មាអញក្នុងរឿងនេះគ្មានទេ ។ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ញ៉ាំងចិត្តឲ្យរីករាយ ចូលទៅគាល់ព្រះ

រាជា ហើយក្រាបបង្គំទូលនូវពាក្យនេះថា បពិត្រព្រះសម្មតិទេព យើងខ្ញុំជាស្រី យើងខ្ញុំមិនមែនជាប្រុស បពិត្រព្រះមហាក្សត្រ សូមព្រះអង្គព្រះរាជទានសមណៈ ១ រូបដល់ខ្ញុំម្ចាស់ ៗ នឹងញុំាងសមណៈនោះឲ្យឆាន់ ។ គ្រានោះឯង ព្រះរាជាបានទ្រង់ប្រទានសមណៈ មានឥន្ទ្រិយអប់រំហើយដល់ខ្ញុំ ទាំងខ្ញុំបានកាន់យកបាត្ររបស់សមណៈនោះ ហើយញុំាងបាត្រឲ្យពេញដោយបាយដ៏ឧត្តម ។ លុះដាក់បាយដ៏ឧត្តម ព្រមទាំងគ្រឿងអប់និងគ្រឿងលាបហើយ ក៏មានចិត្តត្រេកអរបានយកសំពត់ផ្ទាំងធំគ្របបាត្រហើយ នាំយកទៅប្រគេន ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានធ្វើជាមហេសីនៃស្ដេចទេវតា ១ ពាន់ដង បានធ្វើជាមហេសីនៃស្ដេចចក្រពត្តិ ១ ពាន់ដង ។ ខ្ញុំបានធ្វើជាមហេសីនៃស្ដេចប្រទេសរាជដ៏ធំទូលាយរាប់ជាតិមិនអស់ ឯបុណ្យដទៃច្រើនមានប្រការផ្សេងៗ ផលនៃបុណ្យនោះច្រើនលើសនោះទៅទៀត ។ សម្បុររបស់ខ្ញុំដូចផ្កាឧប្បល ខ្ញុំជាស្រីមានរូបល្អល្អះគួររមិលមើល បរិបូណ៌ដោយអវយវៈទាំងអស់ កើតក្នុងត្រកូលខ្ពស់ ទ្រទ្រង់សេចក្ដីរុងរឿង ដល់មកក្នុងបច្ឆិមភព ខ្ញុំបានមកកើតក្នុងសក្យត្រកូល ជាប្រធាននៃស្រី ១ ពាន់

នៃព្រះរាជបុត្តរបស់ព្រះបាទសុទ្ធោទនៈ ។ ខ្ញុំនៀយណាយក្នុងផ្ទះ ហើយចូលទៅកាន់ផ្នួស លុះគ្រប់ ៧ រាត្រី ក៏បានយល់ច្បាស់នូវសច្ច ៤ ។ ខ្ញុំមិនអាចនឹងរាប់នូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យបានទេ នេះឯងជាផលនៃបិណ្ឌបាត ។ បពិត្រព្រះមុនីមានព្យាយាមធំ កុសលកម្មណាដែលខ្ញុំបានធ្វើហើយក្នុងកាលមុន សូមព្រះអង្គវញក នូវកម្មជាកុសលនោះចុះ ឯអំពើល្អមានច្រើន ដែលខ្ញុំបានលះបង់ហើយដើម្បីប្រយោជន៍នៃព្រះអង្គ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះព្រោះហេតុដែលខ្ញុំបានឲ្យបិណ្ឌបាតទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃបិណ្ឌបាត ។ ខ្ញុំស្គាល់តែគតិ ២ គឺទេវតានិងមនុស្ស ខ្ញុំមិនដែលស្គាល់គតិដទៃឡើយ នេះជាផល នៃបិណ្ឌបាត ។ ខ្ញុំស្គាល់តែត្រកូលខ្ពស់ជាមហាសាល មានទ្រព្យច្រើន មិនដែលស្គាល់ត្រកូលដទៃឡើយនេះជាផលនៃបិណ្ឌបាត ។ ខ្ញុំត្រាច់រង្គត់ទៅក្នុងភពតូចភពធំ ត្រូវកុសលមូលជាស់តឿន មិនដែលបានជួបប្រទះនឹងវត្ថុមិនពេញចិត្តឡើយ នេះជាផលនៃសេចក្តីត្រេកអរ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតហើយ អា-

សវៈទាំងពួងអស់ហើយឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។
បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា
ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទានិងបដិភាណប្បដិសម្ភិទានៃ
ខ្ញុំព្រះអង្គកើតឡើងក្នុងសំណាក់របស់ព្រះអង្គ ។ កិលេសទាំង
ឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ
ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១)។

ព្រះថេរីអង្គនោះ កាលសម្រេចអរហត្តហើយ បានពោលគាថានោះឯង ម្តងទៀតដោយពាក្យជាឧទាន ពាក្យជាឧទាននោះឯង ជាការព្យាករ អរហត្តផលរបស់ព្រះថេរីផងដែរ ។

## អដ្ឋកថា នន្ទាថេរីគាថា ចប់

---

១-ក្នុងអបទានជា ឧប្បលទាយិកាថេរី ។

## ជន្តាថេរីគាថា

[ ២៨៥ ] ពោជ្ឈង្គប្រាំពីរនេះណា ជាឧបាយ ដើម្បីដល់នូវព្រះនិព្វាន ពោជ្ឈង្គទាំងអស់នោះ ខ្ញុំបានចម្រើនតាមលំអាន ដែលព្រះពុទ្ធទ្រង់សំដែង ហើយ ។ ព្រោះថា ព្រះមានព្រះភាគអង្គនោះខ្ញុំបានឃើញហើយ រាងកាយ នេះ មានក្នុងទីបំផុត ជាតិសង្សារ ( នៃខ្ញុំ ) អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

ជន្តាថេរី ។

## អដ្ឋកថា
## ជន្តាថេរីគាថា

[ ២៨៥ ] គាថារបស់ព្រះថេរីឈ្មោះ ជន្តា មានពាក្យផ្ដើមថា **យេ ឥមេ សត្ត ពោជ្ឈង្គា** ដូច្នេះជាដើម ។

រឿងដែលជាអតីតនិងរឿងដែលជាបច្ចុប្បន្ន របស់ព្រះថេរីឈ្មោះ ជន្តា នោះ ដូចគ្នានឹងរឿងរបស់ព្រះថេរីឈ្មោះអភិរូបនន្ទា តែព្រះថេរីនេះ កើតក្នុង រាជត្រកូលលិច្ឆវីក្រុងវេសាលី សេចក្ដីប្លែកគ្នាមានប៉ុណ្ណេះឯង នាងស្ដាប់ធម៌ ដែលព្រះសាស្ដាទ្រង់សម្ដែង បានសម្រេចអរហត្តក្នុងកាលចប់ទេសនា ពិ-ចារណាគុណវិសេសដែលខ្លួនសម្រេច បានពោល ២ គាថា នេះ ដោយ អំណាចបីតិថា

ពោជ្ឈង្គប្រាំពីរនេះណា ជាឧបាយ ដើម្បីដល់នូវព្រះនិព្វាន

ពោជ្ឈង្គទាំងអស់នោះ ខ្ញុំបានចម្រើនតាមលំអានដែលព្រះពុទ្ធ
ទ្រង់សំដែងហើយ ។ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ខ្ញុំ
បានឃើញហើយ រាងកាយនេះមានក្នុងទីបំផុត ជាតិសង្សារ
( នៃខ្ញុំ ) អស់រលីងហើយ ឥឡូវនេះ ភពថ្មី មិនមានទៀត
ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ ឥមេ សត្ត ពោជ្ឈង្គា** សេចក្ដីថា ធម៌ ៧ ប្រការនេះ ពោលគឺ សតិ ធម្មវិចយៈ វិរិយៈ បីតិ បស្សទ្ធិ សមាធិ និង ឧបេក្ខា បានឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃការត្រាស់ដឹង គឺធម្មសាមគ្គី តាមដែលពោលហើយ ឬជាអង្គនៃបុគ្គលដែលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ ដឹង គឺជាអ្នកដល់ព្រមដោយពោជ្ឈង្គនោះ ។ បទថា **មគ្គា និព្វានបត្តិយា** បានដល់ ជាឧបាយឲ្យសម្រេចព្រះនិព្វាន ។ បទថា **ភាវិតា តេ មយា សព្វេ យថា ពុទ្ធេន ទេសិតា** សេចក្ដីថា ពោធិបក្ខិយធម៌ ៣៧ ប្រការ ទាំងអស់នោះ ខ្ញុំឲ្យកើតឡើងនិងឲ្យចម្រើន ដូចដែលព្រះពុទ្ធ គឺព្រះមានព្រះ ភាគទ្រង់សម្ដែងហើយ ។ **ហិ** សព្ទ ក្នុងបាទគាថាថា **ទិដ្ឋោ ហិ មេ សោ ភគវា** សេចក្ដីថា ហេតុ ប្រកបសេចក្ដីថា ព្រោះព្រះមានព្រះភាគ អង្គនោះ ជាធម្មកាយ ជាព្រះសម្ពុទ្ធដែលខ្ញុំឃើញហើយដោយធម្មទស្សនៈដ៏កំពូលដែល ខ្ញុំបានសម្រេចហើយ ដូច្នោះ ទើបសរីរៈនេះមានក្នុងទីបំផុតព្រោះថា ព្រះ មានព្រះភាគ និងព្រះអរិយៈដទៃៗរមែងឈ្មោះថា ខ្ញុំឃើញហើយដោយធម្ម- ទស្សនៈដ៏កំពូល មិនមែនឃើញត្រឹមតែរូបកាយដូចដែលត្រាស់ ( ទុកក្នុង

សំយុត្តនិកាយខន្ធវារវគ្គ ) ថា ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌បុគ្គល នោះឈ្មោះថាឃើញតថាគត និងត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ឯអរិយសាវកដែលជាអ្នកបានចេះដឹង បាន ឃើញនូវព្រះអរិយៈទាំងឡាយ ដូច្នេះជាដើម ។ ពាក្យដ៏សេសមានន័យដូច ពោលហើយនោះឯង ។

## អដ្ឋកថា ជន្តាថេរីគាថា ចប់

# អញ្ញតរាថេរីភិក្ខុនីអបញ្ញាតាគាថា

[ ២៨៦ ] អញរួចស្រឡះ ផុតស្រឡះ រួចល្អហើយចាកអង្រែ ( ប្ដីរបស់អញ ) មិនមានសេចក្ដីអៀនខ្មាស ( អញមិនគាប់ចិត្ត ) ទាំងឆត្រ ( ក៏មិនគាប់ចិត្ត ) អញដែរ អញ ( ផុតស្រឡះ ) ចាកឆ្នាំង ចាកភាពជាអ្នកកម្សត់ ។ អញបានផ្ដាច់ផ្ដិលរាគៈ និងទោសៈហើយ អញនោះចូលទៅរកគល់ឈើ ហើយចម្រើនឈានជាសុខថា ឱ សុខណាស់តើ ។

ថេរីភិក្ខុនីមួយរូប មាននាមនិងគោត្រមិនប្រាកដ ។

## អដ្ឋកថា

## សុមង្គលមាតុថេរីគាថា

[ ២៨៦ ] គាថាមាតារបស់ព្រះសុមង្គលត្ថេរមានពាក្យផ្ដើមថា **សុមុត្តិកា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលក្រីក្រ ក្នុងនគរសាវត្ថី ចម្រើនវ័យហើយ មាតាបិតាលើកឲ្យជាងផែងម្នាក់ បានកូនច្បង ដែលមានកពចុងក្រោយ កូនច្បងនោះបាន ឈ្មោះថា សុមង្គល តាំងអំពីនោះមក ស្ត្រីនោះ គេតែងស្គាល់ថា សុមង្គលមាតា តែព្រោះឈ្មោះ និងគោត្តរបស់នាងមិនប្រាកដ ដូច្នោះ ទើបលោកពោលក្នុងបាលីថា ភិក្ខុនីមួយអង្គ មិនប្រាកដឈ្មោះ ។ សូម្បីបុត្ត

របស់នាង កាលដឹងក្តីហើយក៏បួស បានជាព្រះអរហន្តមួយអន្លើដោយបដិ-សម្ភិទាទាំងឡាយ បានប្រាកដឈ្មោះថា ព្រះសុមង្គលត្ថេរ ។ មាតាព្រះថេរៈនោះ បួសក្នុងពួកភិក្ខុនីចម្រើនវិបស្សនា ថ្ងៃមួយពិចារណា សេចក្តីលំបាកដែលខ្លួនបានក្នុងពេលជាគ្រហស្ថ កើតនូវការសង្វេគ ចម្រើនវិបស្សនា បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ បានបន្លឺឧទាន ដោយគាថា ២ នេះថា

អញរួចស្រឡះ ផុតស្រឡះ រួចល្អហើយចាកអង្រែ ( ប្តីរបស់អញ ) មិនមានសេចក្តីអៀនខ្មាស ( អញមិនគាប់ចិត្ត ) ទាំងឆត្រ ( ក៏មិនគាប់ចិត្ត ) អញដែរ អញ ( ផុតស្រឡះ ) ចាកឆ្នាំង ចាកភាពជាអ្នកកម្សត់ ។ អញបានផ្តាច់ផ្តិលរាគៈនិងទោសៈហើយ អញនោះចូលទៅរកគល់ឈើហើយចម្រើនឈានជាសុខថា ឱ សុខណាស់តើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុមុត្តិកា** ប្រែថា ផុតល្អហើយ **ក** អក្ខរៈគ្រាន់តែធ្វើបទឲ្យពេញ សេចក្តីថា ផុតហើយដោយល្អហ្ន៎ ។ ព្រះថេរីនោះឃើញសម្បត្តិដែលខ្លួនបានក្នុងសាសនា ទើបពោលសរសើរដោយការជ្រះថ្លា ឬដោយការសរសើរវត្ថុដែលបានមកនោះថា ខ្ញុំរួចផុតល្អហើយ ខ្ញុំរួចផុតល្អហើយ តែកាលសម្តែងនូវការរួចផុត ចាកវត្ថុដែលខ្លួនរង្កៀស ជាពិសេសក្នុងកាលជាគ្រហស្ថ ទើបពោលពាក្យជាដើមថា **សាធុ មុត្តិកាម្ហិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាធុ មុត្តិកាម្ហិ** សេចក្តីថា ខ្ញុំជាអ្នកផុត

ដោយប្រពៃល្អហើយហ្ន៎ ។ បទថា **មុសលស្ស** ប្រែថា ចាកអង្រែ បានឮថា ព្រះថេរីនេះ កាលនៅជាគ្រហស្ថបុកអង្ករដោយខ្លួនឯង ព្រោះជាអ្នកក្រីក្រ ហេតុនោះទើបពោលយ៉ាងនេះ ។ បទថា **អហិរិកោ មេ** សេចក្តីថា ស្វាមីនៃខ្ញុំ ជាមនុស្សមិនមានហិរិ គឺប្រាសចាកការខ្មាស ។ គប្បីបន្ថែមនូវពាក្យថា ខ្ញុំមិនចូលចិត្ត ។ ព្រះថេរីពោលរង្កៀសការប្រព្រឹត្តទៅរបស់ពួកអ្នកវង្វេងក្នុងកាម ព្រោះតាមប្រក្រតី នាងមានចិត្តប្រាសចាកតម្រេក ក្នុងកាមទាំងឡាយហើយ ។ បទថា **ឆត្តកំ វាហិ** សេចក្តីថា សូម្បីឆត្រដែលធ្វើ ( លក់ ) ចិញ្ចឹមជីវិតខ្ញុំក៏មិនពេញចិត្ត ។ **វា** សព្ទ មានអត្ថរួមដល់វត្ថុដែលមិនបានពោល ដោយ **វា** សព្ទនោះ លោកសរុបយកប្រអប់និងស្នូកជាដើមផងដែរ ព្រះថេរី រង្កៀសក្នុងជីវិតក្រីក្រ ព្រោះត្រូវយកកំណាត់ឫស្សីជាដើមធ្វើឆត្រជាដើមរាល់ថ្ងៃ ទើបពោលដូច្នេះ ។

អាចារ្យពួកខ្លះសូធ្យថា **អហិតកោ មេ វាតោ វាតិ** ហើយពោលអត្ថទុកថាខ្យល់ដែលឥតប្រយោជន៍ មានតែនាំជរាមកឲ្យ បក់ទៅពេញសរីរៈរបស់ខ្ញុំ ក្នុងកាលដែលខ្ញុំនៅជាគ្រហស្ថ ។ តែអាចារ្យពួកដទៃពោលអត្ថថា ខ្យល់ដែលមិនមានប្រយោជន៍ និងមានក្លិនស្អុយជាងក្លិនរបស់មនុស្សដទៃបក់ចេញមកអំពីកាយខ្ញុំ ។ បទថា **ឧក្កលិកា មេ ទេឌ្ឌុភំ វាតិ** សេចក្តីថា កាជនៈដាំបាយរបស់ខ្ញុំ មានក្លិនពស់ទឹកផ្សាយទៅ ព្រោះត្រាំទុកយូរ ទើបមិនស្អាត ប្រកបសេចក្តីថា ខ្ញុំជាអ្នកផុតដោយប្រពៃចាកឆ្នាំងបាយនោះ ។ បទថា **រាគញ្ច អហំ ទោសញ្ច វិច្ឆិន្ទន្តី វិហរាមិ** សេចក្តីថា ខ្ញុំនឹងកាត់រាគៈ

ទោសៈដែលជាប្រធាននៃកិលេស បានដល់ នៅ គឺកម្ចាត់ បានដល់ លះនូវទោសៈ និងមោហៈដែលជាប្រធាននៃកិលេស មួយអន្លើដោយធ្វើសំឡេង **ចិច្ចិដិ ចិច្ចិដិ** បានឮថា ព្រះថេរីនោះ រង្កៀសស្វាមីរបស់ខ្លួន ដែលធ្វើសំឡេងរំខានដោយការពុះឫស្សីធ្លាប់ជាដើមរាល់ថ្ងៃ ទើបពោលថា ការលះស្វាមីបានស្មើគ្នានឹងការលះរាគៈនិងទោសៈ ។ បទថា **សារុក្ខមូលមុបគម្ម** សេចក្ដីថា ខ្ញុំ គឺសុមង្គលមាតានោះ ចូលទៅកាន់គល់ឈើដែលស្ងាត់ ។ បទថា **សុខ-តោឈាយាមិ** សេចក្ដីថា ខ្ញុំសម្លឹងថា ជាសុខ គឺខ្ញុំចូលសមាបត្តិតាមកាលដែលសមគួរ បានដល់ សម្លឹងផលជ្ឈានដោយផលសុខនិងនិព្វានសុខ ។ បទថា **អហោ សុខំ** នេះ ព្រះថេរីពោល ដោយអំណាចមនសិការដែលប្រព្រឹត្តទៅខាងក្រោយចូលសមាបត្តិ ទោះបីជាពោលថា ដោយអំណាចការចងចិត្តក៏ត្រូវដូចគ្នា ។

## អដ្ឋកថា សុមង្គលមាតុថេរីគាថា ចប់

## អឌ្ឍកាសីថេរីគាថា

[ ២៨៧ ] សួយក្នុងជនបទឈ្មោះកាសី មានចំនួនប៉ុន្មាន សួយរបស់ ខ្ញុំ ក៏មានចំនួនប៉ុណ្ណោះដែរ អ្នកនិគម បានធ្វើ ( ទ្រព្យចំនួន ៥០០ ) នោះឲ្យជាថ្លៃ ហើយតាំងទុកនូវខ្ញុំ ( ដោយឈ្មោះថាអឌ្ឍកាសី ) ដែលមានថ្លៃដោយថ្លៃ ។ ក្នុងកាលជាខាងក្រោយមកខ្ញុំក៏បាននឿយណាយក្នុងរូប កាលបើនឿយណាយ ក៏រសាយចិត្តថា សូមកុំឲ្យខ្ញុំអន្ទោលទៅកាន់ជាតិសង្សារវៀយៗទៀត វិជ្ជា ៣ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ សាសនាព្រះពុទ្ធខ្ញុំបានធ្វើហើយ ។

**អឌ្ឍកាសីថេរី ។**

## អដ្ឋកថា
## អឌ្ឍកាសីថេរីគាថា

[ ២៨៧ ] គាថារបស់ព្រះថេរីឈ្មោះអឌ្ឍកាសីមានពាក្យផ្ដើមថា **យាវ កាសិជនបទោ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ក្នុងសាសនាព្រះកស្សបទសពល កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ទៅកាន់សម្នាក់ភិក្ខុនី ស្ដាប់ធម៌ បាននូវសទ្ធា បួសហើយ ជេរព្រះថេរីខីណាស្រពដែលបានបដិសម្ភិទា មួយអង្គដែលតាំងនៅក្នុងសីលរបស់ភិក្ខុនីដោយពាក្យថា ស្រីពេស្យា ឃ្លាតចាកអត្តភាពនោះហើយ ឆេះក្នុងនរក ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសេដ្ឋីមានសម្បត្តិដ៏ឧឡារក្នុងដែនកាសី ចម្រើនវ័យហើយ វិនាសចាកឋានៈ ចុះកាន់

ភាពជាស្រីពេស្យា ព្រោះផលនៃវចីទុច្ចរិត ដែលបានធ្វើមកក្នុងកាលមុន នាង មានឈ្មោះថាអឌ្ឍកាសី ។ ការបួសជាសាមណេរី និងការឧបសម្បទាដោយ ទូតរបស់នាង មកហើយក្នុងខន្ធកៈនោះឯង សមដូចពាក្យដែលលោកពោល ទុក ( ក្នុងវិនយបិដកចុល្លវគ្គ ) ថា

សម័យនោះឯង មានស្រីផ្កាមាសឈ្មោះអឌ្ឍកាសី មកបួស ក្នុងសំណាក់ពួកភិក្ខុនី ។ នាងអឌ្ឍកាសីនោះ ចង់ទៅនគរ សាវត្ថីដោយគិតថាអាត្មាអញនឹងបានឧបសម្បទាក្នុងសំណាក់ នៃព្រះមានព្រះភាគ ។ ពួកអ្នកលេងបានឮដំណឹងថា នាង អឌ្ឍកាសីស្រីផ្កាមាស ចង់ទៅនគរសាវត្ថី ។ ពួកអ្នកលេង ទាំងនោះ ក៏ចាំស្កាត់ត្រង់កណ្តាលផ្លូវ ។ នាងអឌ្ឍកាសីស្រី ផ្កាមាស បានឮដំណឹងថា ពួកអ្នកលេងចាំស្កាត់ត្រង់កណ្តាល ផ្លូវដូច្នោះ ក៏បញ្ជូនទូត ទៅក្រាបបង្គំទូលព្រះមានព្រះភាគថា ដ្បិតខ្ញុំម្ចាស់ចង់ឧបសម្បទាតើខ្ញុំម្ចាស់នឹងប្រតិបត្តិយ៉ាងណា ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យឧបសម្បទាសូម្បីដោយទូតក៏បាន ដូច្នេះ ។

លុះបានឧបសម្បទាយ៉ាងនេះហើយ នាងចម្រើនវិបស្សនាមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមកស្សប មានផៅពង្សប្រសើរ មានយស ធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងក្នុងភទ្ទ-កប្បនេះ ។ កាលនោះ ខ្ញុំបានបួសក្នុងសាសនារបស់ព្រះពុទ្ធ អង្គនោះ បានសង្រួមក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ខ្ញុំជាអ្នកដឹងប្រមាណក្នុងអាសនៈដ៏ទាបផង ប្រកបក្នុងការភ្ញាក់ រឭកផង មានសេចក្តីព្យាយាមប្រកបហើយផង កាលនោះខ្ញុំ មានចិត្តប្រទូស្ត បានជេរភិក្ខុនីដែលប្រាសចាកអាសវៈ អស់ វារៈម្តងថា នៃស្រ្តីផ្កាមាស ខ្ញុំក៏ទៅឆេះក្នុងនរក ព្រោះបាបកម្ម នោះឯង ។ ដោយកម្មដ៏សេសនោះ ដល់មកក្នុងបច្ឆិមជាតិ ខ្ញុំ កើតក្នុងត្រកូល នៃស្រ្តីផ្កាមាស ជាអ្នកអាស្រ័យចិញ្ចឹមជីវិត ដោយបុគ្គលដទៃទៀតជាច្រើន ។ ខ្ញុំបានកើតក្នុងត្រកូលសេដ្ឋី នៅក្នុងដែនកាសី ដោយផលដែលបានប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកបរិបូណ៌ដោយរូប បីដូចជាស្រីអប្សរក្នុងទេវលោក ។ ជនទាំងឡាយ បានឃើញខ្ញុំដែលគួរមិលមើល ក្នុងគិរិព្វជ បុរីដ៏ឧត្តម ក៏ញ៉ាំងខ្ញុំឲ្យនៅក្នុងពួកនៃស្រ្តីផ្កាមាស ព្រោះផល នៃការជេររបស់ខ្ញុំនោះ ។ ខ្ញុំនោះបានស្តាប់នូវព្រះសទ្ធម្មដែល ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សម្តែងហើយ ក៏បរិបូណ៌ដោយបុព្វវា-សនា ហើយបានចូលទៅកាន់ផ្នួស ។ ខ្ញុំទៅកាន់សម្នាក់ព្រះ ជិនស្រី ដើម្បីប្រយោជន៍ដល់ឧបសម្បទានោះ បានឃើញពួក

អ្នកលេងឈរនៅក្បែរផ្លូវ ក៏បានឧបសម្បទាអំពីទូត ។ កម្មទាំងពួងរបស់ខ្ញុំអស់ហើយ បុណ្យនិងបាបអស់ហើយសង្សារវដ្តទាំងពួងខ្ញុំបានឆ្លងផុត ទាំងភាពជាស្រីផ្កាមាសខ្ញុំធ្វើឲ្យអស់ហើយ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយផង ស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ខ្ញុំដឹងច្បាស់បុព្វេនិវាស ទាំងទិព្វចក្ខុ ខ្ញុំបានជម្រះឲ្យស្អាតល្អហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវនេះភពថ្មីទៀតមិនមានឡើយ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃខ្ញុំកើតឡើង ក្នុងសំណាក់នៃព្រះអង្គ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ព្រះថេរីបានពោលគាថាទាំងនេះជាឧទានថា

សួយក្នុងជនបទឈ្មោះកាសី មានចំនួនប៉ុន្មាន សួយរបស់ខ្ញុំក៏មានចំនួនប៉ុណ្ណោះដែរ អ្នកនិគមបានធ្វើ ( ទ្រព្យចំនួន ៥០០ ) នោះឲ្យជាថ្លៃ ហើយតាំងទុកនូវខ្ញុំ ( ដោយឈ្មោះថា អឌ្ឍកាសី ) ដែលមានថ្លៃដោយថ្លៃ ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំក៏បាននឿយណាយក្នុងរូប កាលបើនឿយណាយ ក៏រសាយ

ចិត្តថា សូមកុំឲ្យខ្ញុំអន្ទោលទៅកាន់ជាតិសង្សាររឿយៗ ទៀត វិជ្ជា ៣ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ សាសនាព្រះពុទ្ធ ខ្ញុំបាន ធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវ កាសិជនបទោ សុង្កោ មេ តត្តកោ អហុ** សេចក្តីថា សួយមាននៅក្នុងជនបទកាសី ហៅថាកាសីជនបទ កាសីជនបទនោះមានសួយប្រមាណប៉ុនណា តម្លៃរបស់ខ្ញុំ ក៏មានប្រមាណប៉ុណ្ណោះ សួរថា សួយនោះប្រមាណប៉ុនណា ឆ្លើយថា ប្រមាណ ១០០០ បានឮថា ក្នុងដែនកាសីនោះ ចំណូលកើតឡើងដល់ព្រះរាជាក្នុងមួយថ្ងៃ ដោយអំណាចសួយប្រមាណ ១០០០ សូម្បីទ្រព្យដែលនាងអឌ្ឍកាសីបានក្នុងមួយថ្ងៃអំពីដៃបុរស ក៏ប្រមាណប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកពោលថា **យាវ កាសិជនបទោ សុង្កោ មេ តត្តកោ អហុ** ដូច្នេះ នាងបានឈ្មោះថា កាសី ព្រោះមានតម្លៃខ្លួនស្មើនឹងសួយក្នុងដែនកាសី ។ ពួកបុរសដោយច្រើន កាលមិនអាចឲ្យដល់ ១០០០ ទើបឲ្យពាក់កណ្តាលនៃចំណែកនោះ ហើយនៅរួមអភិរម្យអស់មួយថ្ងៃហើយចេញទៅ ។ ព្រោះបុរសទាំងនោះ ទើបគេស្គាល់នាងថា **អឌ្ឍកាសី** ( ពាក់កណ្តាលសួយដែនកាសី ) ព្រោះហេតុនោះ ទើបព្រះថេរីពោលថា **តំ កត្វា នេគមោ អគ្ឃំ អឌ្ឍេនគ្ឃំ ឋបេសិ មំ** ដែលមានសេចក្តីថា អ្នកនិគម គឺជនអ្នកនៅក្នុងនិគមកំណត់ ៥០០ កហាបណៈជាតម្លៃ ទើបដាក់ឈ្មោះខ្ញុំដែលជាស្រីកែវ ក្នុងឈ្មោះថ្មីថា អឌ្ឍកាសី ព្រោះបន្ថយតម្លៃខ្លួនចុះមកពាក់កណ្តាល គឺហៅឈ្មោះតាមនោះ ។

បទថា **អថ និព្វិន្ទហំ រូបេ** សេចក្ដីថា ខ្ញុំអាស្រ័យរូបចិញ្ចឹមជីវិតយ៉ាងនេះ តមកខាងក្រោយ បានអាស្រ័យសាសនា ទើបនឿយណាយក្នុងរូប គឺឃើញថា រូបមិនទៀង ដោយប្រការដូច្នេះ រូបនេះជាទុក្ខ មិនស្អាត ដោយប្រការនេះ ទើបមិនពេញចិត្តរូបនោះ ។ បទថា **និព្វិន្ទញ្ច វិរជ្ជហំ** សេចក្ដីថា កាលខ្ញុំនឿយណាយ ទើបដល់នូវភាពជាបុគ្គលដទៃ គឺប្រាសចាកតម្រេកក្នុងរូបនោះ ។ ដោយ **និព្វិន្ទ** សព្ទ ក្នុងគាថានេះ ព្រះថេរីសម្ដែងដល់ តរុណវិបស្សនា ដោយ **វិរាគ** សព្ទ សម្ដែងដល់ពលវវិបស្សនា មានពាក្យអធិប្បាយថា កាលនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក រមែងរួចផុត ដោយបទថា **មា បុន ជាតិសំសារំ សន្ធាវេយ្យំ បុនប្បុនំ** នេះ ព្រះថេរីសម្ដែងដល់អាការនៃការនឿយណាយ និងការប្រាសចាកតម្រេក ដោយបទថា **តិស្សោ វិជ្ជា** ជាដើម ព្រះថេរីសម្ដែងថា នាងបានសម្រេចវិជ្ជាទាំង ៣ នោះ ។ សេចក្ដីនោះ មានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា អឌ្ឍកាសីថេរីគាថា ចប់

## ចិត្តាថេរីគាថា

[ ២៨៨ ] ពិតមែនតែខ្ញុំជាស្រីស្គម មានជំងឺ មានកម្លាំងថយខ្លាំង ច្រត់ដំបងឡើងទៅលើភ្នំ ។ ដាក់នូវសង្ឃាដី ផ្កាប់នូវបាត្រទុក ( អង្គុយ ) លើភ្នំ អាចទម្លាយនូវគំនរងងឹត គឺមោហៈបាន ហើយសង្កត់សង្កិនទូវខ្លួន ( ដោយការទម្លាយនូវគំនរងងឹតគឺមោហៈនោះឯង ) ។

### ចិត្តាថេរី ។

## អដ្ឋកថា

## ចិត្តាថេរីគាថា

[ ២៨៨ ] គាថារបស់ព្រះថេរីឈ្មោះ ចិត្តា មានពាក្យផ្ដើមថា **កិញ្ចាបិ ខោម្ហិ កិសិកា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងកប្បទី ៩៤ អំពីកប្បនេះ កើតក្នុងកំណើតកិន្នរត្រង់ឆ្នេរស្ទឹងចន្ទភាគា ថ្ងៃមួយកិន្នរទាំងនោះឃើញព្រះបច្ចេកពុទ្ធមួយអង្គ គង់ត្រង់គល់ឈើ មានចិត្តជ្រះថ្លា យកផ្កាបបុសមកបូជា ថ្វាយបង្គំហើយ ផ្គងអញ្ជលី ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ដោយបុញ្ញកម្មនោះ កុលធីតានោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតី មហាសាល ក្នុងក្រុងរាជគ្រឹះ ដល់នូវភាពជាអ្នកដឹងក្ដីហើយ បាននូវសទ្ធា ក្នុងកាល

ព្រះសាស្តាយាងចូលនគររាជគ្រឹះ ក្រោយមកបួសក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមី ក្នុងកាលឯចាស់ បានឡើងកុំគិជ្ឈកូដ ធ្វើសមណធម៌ចម្រើនវិបស្សនា បានសម្រេចអរហត្តមួយ អន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះឯង ខ្ញុំកើតជាកិន្នរញី នៅទៀបឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានឃើញព្រះពុទ្ធជាព្រះសយម្ភូ ទ្រង់ប្រាសចាកធូលីទ្រង់ឈ្នះកិលេស ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយខ្លាំង មានចិត្តត្រេកអរ ធ្វើនូវអញ្ជលី ហើយកាន់យកនូវកម្រងផ្កាបុសទៅបូជាចំពោះព្រះសយម្ភូ ។ ខ្ញុំលះបង់រាងកាយ ជាកិន្នរញី បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផងដោយការតម្កល់ទុកនូវចេតនានោះផង ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៣៦ ដង សេចក្តីប្រាថ្នាដោយចិត្តរបស់ខ្ញុំ រមែងកើតឡើង តាមសមគួរដល់សេចក្តីប្រាថ្នា ។ ខ្ញុំបានជាអគ្គ-មហេសីនៃស្តេចចក្រពត្តិ ១០ ដង ព្រោះបានសន្សំកងកុសល ខ្ញុំតែងអន្ទោលទៅក្នុងភពទាំងឡាយ ។ កុសលរបស់ខ្ញុំរមែងមាន ខ្ញុំបានចូលទៅកាន់ផ្នួស ថ្ងៃនេះខ្ញុំជាស្រីគួរដល់ការបូជាក្នុងសាសនានៃព្រះសក្យបុត្ត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រងផ្កាបុស ។ ថ្ងៃនេះ

ខ្ញុំមានចិត្តស្អាត ប្រាសចាកចិត្តលាមក មានអាសវៈទាំងពួង
អស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេស
ទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោល
ហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ
ហើយ ដូច្នេះ[១] ។

ព្រះថេរីនោះ កាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន បានពោលគាថា ២ នេះថា

ពិតមែនតែខ្ញុំជាស្រីស្គម មានជំងឺ មានកម្លាំងថយខ្លាំង ច្រត់
ដំបង ឡើងទៅលើភ្នំ ។ ដាក់នូវសង្ឃាដី ផ្កាប់នូវបាត្រទុក
( អន្លើយ ) លើភ្នំ អាចទម្លាយនូវគំនរងងឹត គឺមោហៈបាន
ហើយសង្កត់សង្កិននូវខ្លួន ( ដោយការទម្លាយនូវគំនរងងឹត
គឺមោហៈនោះឯង ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិញ្ចាបិ ខោម្ហិ កិសិកា** សេចក្ដីថា ទោះខ្ញុំជាមនុស្សគ្រាំគ្រាព្រោះជរា មានរាងកាយស្គម ព្រោះមានសាច់និងឈាមតិចក៏ពិត ។ បទថា **គិលានា ពាឡ្ហទុព្វលា** សេចក្ដីថា ជាអ្នកឈឺ ព្រោះធាតុជាដើមកម្រើកទុព្វលភាពពន់ពេកព្រោះជំងឺនោះឯង ។ បទថា **ទណ្ឌ-ោលុព្ភា គច្ឆាមិ** សេចក្ដីថា កាលទៅក្នុងទីណាមួយ រមែងកាន់ឈើច្រត់ទៅ ។ បទថា **បព្វតំ អភិរូហិយ** សេចក្ដីថា ទោះជាយ៉ាងនេះ ក៏ឡើងកាន់

---

១-ក្នុងអបទានជា នឡមាលិកាថេរី ។

ភ្នំគិជ្ឈកូដ ព្រោះត្រូវការវិវេក ។ បទថា **សង្ឃាដឹ និក្ខិបិត្វាន** សេចក្តីថា ខ្ញុំដណ្តប់សំពត់ខាងក្រៅហើយ ទើបដាក់សំពត់សង្ឃាដីដែលបត់ ទុកត្រង់ចង្កួយស្មា ទុកក្នុងហត្ថបាស ។ បទថា **បត្តកញ្ចុ និកុជ្ជិយ** សេចក្តីថា ដាក់នូវបាត្រដីសម្រាប់ប្រើប្រាស់របស់ខ្ញុំ ផ្កាប់ទុកក្នុងទីសមគួរនាចំណែកម្ខាង ។ បទថា **សេលេ ខម្ភេសឹ អត្តានំ តមោក្ខន្ធំ បទាលិយ** សេចក្តីថា អង្គុយលើភ្នំទម្លាយនូវគំនរមោហៈដែលមិនធ្លាប់ទម្លាយអស់កាលយូរ សង្កត់ខ្លួន គឺអត្តភាពដោយការទម្លាយគំនរមោហៈនោះឯង គឺសង្កត់សន្តានរបស់ខ្លួនដោយការមិនឲ្យកើតឡើងតទៅទៀតជាជម្មតា ។

## អដ្ឋកថា ចិត្តាថេរីគាថា ចប់

## មេត្តិកាថេរីគាថា

[ ២៨៩ ] ពិតមែនហើយតែខ្ញុំជាអ្នកវេទនា មានកម្លាំងថមថយ មានវ័យកន្លងជ្រុលហើយ ច្រត់ដំបងឡើងទៅលើភ្នំ ។ ដាក់នូវសង្ឃាដី ផ្កាប់នូវបាត្រ អង្គុយលើភ្នំ លំដាប់នោះចិត្តរបស់ខ្ញុំរួចស្រឡះហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនាព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

**មេត្តិកាថេរី ។**

## អដ្ឋកថា

## មេត្តិកាថេរីគាថា

[ ២៨៩ ] គាថារបស់ព្រះថេរីឈ្មោះ មេត្តិកា មានពាក្យផ្ដើមថា **កិញ្ចាបិ ខោម្ហិ ទុក្ខិតា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ មានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិទ្ធត្ថ កើតក្នុងត្រកូលគហបតី ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានបូជាព្រះចេតិយ របស់ព្រះសាស្ដាដោយខ្សែក្រវាត់រំលេចដោយរតនៈ ដោយបុញ្ញកម្មនោះ កុលធីតានោះ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងនគររាជគ្រឹះ ។ រឿងដ៏សេសដូចគ្នានឹងរឿងបន្ទាប់មកដែលពោលហើយនោះឯង ព្រះថេរីនេះឡើងកំពូលភ្នំដូចគ្នាធ្វើសមណធម៌ចម្រើនវិបស្សនា បាន

សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានធ្វើព្រះស្តូបថ្វាយព្រះមានព្រះភាគព្រះនាមសិទ្ធត្ថៈហើយ
បានថ្វាយខ្សែក្រវាត់ចំពោះព្រះសាស្តា ដើម្បីនវកម្ម ។ កាល
មហាស្តូបសម្រេចហើយ ខ្ញុំមានចិត្តជ្រះថ្លា បានបូជាខ្សែក្រវាត់
ចំពោះព្រះមុនិលោកនាថដោយដៃរបស់ខ្លួនទៀត ។ ក្នុងកប្បទី
៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្សែក្រវាត់
ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើ
ស្តូប ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំង
សាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរីបានសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួនបានពោលគាថា ២ នេះជាឧទានថា

ពិតមែនហើយតែខ្ញុំជាអ្នកវេទនា មានកម្លាំងថមថយ មានវ័យ
កន្លងជ្រុលហើយច្រត់ដំបងឡើងទៅលើភ្នំ ។ ដាក់នូវសង្ឃាដី
ផ្កាប់នូវបាត្រអង្គុយលើភ្នំ លំដាប់នោះចិត្តរបស់ខ្ញុំរួចស្រឡះ
ហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនាព្រះពុទ្ធខ្ញុំក៏
បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុក្ខិតា** សេចក្តីថា មានទុក្ខ គឺដល់នូវ

---

១-ក្នុងអបទានជា មេខលទាយិកាថេរី ។

សេចក្តីទុក្ខដែលកើតឡើងឯង ព្រោះរោគជាដើម ។ បទថា **ឧបុព្វលា** សេចក្តីថា ព្រោះដល់នូវសេចក្តីទុក្ខនោះឯងផង ព្រោះមានអត្តភាពចាស់ផង ព្រោះអស់កម្លាំងផង ដោយហេតុនោះ ទើបលោកពោលថា **គតយោព្វនា** សេចក្តីថា ដល់នូវវ័យកណ្តាលមនុស្សហើយ ។

បទថា **អថ ចិត្តំ វិមុច្ចិ មេ** សេចក្តីថា ខ្ញុំជាអ្នកអង្គុយលើសិលា គឺលើដុំថ្មកាលនោះ គឺក្នុងលំដាប់នោះ ចិត្តរបស់ខ្ញុំរួចផុតហើយចាកអាសវៈទាំងអស់ តាមលំដាប់មគ្គ ព្រោះប្រកបដោយប្រពៃនោះឯង ដោយភាពជាអ្នកមានសេចក្តីព្យាយាមជានិច្ច ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

អដ្ឋកថា មេត្តិកាថេរីគាថា ចប់

## មិត្តាថេរីគាថា

[ ២៩០ ] ខ្ញុំជាអ្នកត្រេកអរនឹងពួកទេវតា ( ក្នុងឋានចាតុម្មហារាជិកា ) បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ តិថីទី ១៥ និងតិថីទី ៨ នៃបក្ខផង និងបាដិហារិកបក្ខៈផង ។ ថ្ងៃនេះ ខ្ញុំនោះ មានកត្តតែម្តង គោរសក់ ដណ្តប់សង្ឃាដី មិនគប្បីប្រាថ្នានូវពួកទេវតា ( ណាមួយ ) ទេ គប្បីបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យ ( តែប៉ុណ្ណោះ ) ។

មិត្តាថេរី ។

## អដ្ឋកថា
## មិត្តាថេរីគាថា

[ ២៩០ ] គាថារបស់ព្រះថេរីឈ្មោះ មិត្តា មានពាក្យផ្តើមថា **ចាតុទ្ទសឹ បញ្ចទសឹ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ មានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសល ដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី នាងកើតក្នុងត្រកូលក្សត្រ ដឹងក្តីហើយ ជាស្រីស្នំរបស់ព្រះបាទពន្ធុម ឃើញព្រះថេរីដែលជាខីណាស្រពមួយរូបដែលជាសាវិការបស់ព្រះមានព្រះភាគវិបស្សី មានចិត្តជ្រះថ្លា ទទួលបាត្រអំពីដៃរបស់ព្រះថេរីនោះ ហើយដាក់របស់ទំពាដ៏ប្រណីតរហូតពេញ យកទៅ

ប្រគេនមួយអន្ទើដោយសំពត់សាដកដែលមានតម្លៃច្រើន ២ ផ្ទាំង ដោយបុញ្ញកម្មនោះនាងអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងសក្យរាជត្រកូល ក្នុងនគរកបិលពស្តុ ដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា បានទូវសទ្ធាបានជាឧបាសិកា ក្នុងកាលក្រោយមក នាងបួស ក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិថេរី ចម្រើនវិបស្សនា មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ព្រះមហាក្សត្រព្រះនាម ពន្ធុមៈ ក្នុងក្រុងពន្ធុមវតី ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានពោលនូវពាក្យខ្វះ ( នឹងស្តេចនោះ ) ។ កាលនោះ ខ្ញុំអង្គុយក្នុងទីស្ងាត់ ហើយគិតយ៉ាងនេះថា កុសលដែលអញគួរយក ទៅបរលោក អញមិនបានធ្វើសោះ អញនឹងទៅកាន់នរកដែលជាឋានក្តៅខ្លាំង ខ្លាចផ្សាមានសភាពគួរខ្លាច អាក្រក់ក្រៃលែងដោយពិត អញមិនមានសេចក្តីសង្ស័យក្នុងដំណើរនេះឡើយ ។ ខ្ញុំចូលទៅគាល់ព្រះរាជាហើយ ក្រាបទូលដូច្នេះថា បពិត្រព្រះមហាក្សត្រ សូមព្រះអង្គប្រទាននូវសមណៈ ១ អង្គ ដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងនិមន្តលោកឲ្យឆាន់ ។ ព្រះមហារាជ ទ្រង់ប្រទាននូវសមណៈ១ អង្គ ដែលមានឥន្ទ្រិយអប់រំហើយដល់ខ្ញុំ ខ្ញុំទទួលនូវបាត្រ របស់លោកហើយ បំពេញដោយបាយដ៏ប្រសើរ ។

លុះខ្ញុំបំពេញហើយ ធ្វើនូវបាយដ៏ប្រសើរ ឲ្យជាបាយលាយ ដោយវត្ថុមានក្លិនក្រអូប បិទដោយសំណាញ់ ក្រង់ដោយសំពត់លឿង ។ កុសលនុ៎ះ ជាអារម្មណ៍របស់ខ្ញុំ ខ្ញុំរឭកដរាប ដល់អស់ជីវិត ខ្ញុំទៅកើតក្នុងឋានតាវត្តិង្ស ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងកុសលនោះ ។ ខ្ញុំបាននូវភាពនៃខ្លួនជាមហេសីនៃស្តេចទេវតាទាំងឡាយ ៣០ ដង សេចក្តីប្រាថ្នាដែលខ្ញុំប្រាថ្នា ហើយក្នុងចិត្តក៏កើតឡើងដល់ខ្ញុំដូចសេចក្តីប្រាថ្នា ។ ខ្ញុំបាននូវភាពជាមហេសីនៃស្តេចចក្រពត្តិ ២០ ដង ខ្ញុំជាស្រីមានកុសលសន្សំហើយ តែងអន្ទោលទៅក្នុងភពតូចនឹងភពធំ ។ ខ្ញុំរួចចាកចំណងទាំងអស់ហើយ ខ្ញុំជាអ្នកប្រាសចាកកំណើតហើយ អស់អាសវៈទាំងពួងរលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះ ជាផលនៃបិណ្ឌបាតទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន បានពោល ២ គាថានេះជាឧទានថា

---

១-ក្នុងអបទានជា ឯកបិណ្ឌបាតទាយិកាថេរី ។

ខ្ញុំជាអ្នកត្រេកអរនឹងពួកទេវតា ( ក្នុងឋានចាតុម្មហារាជិកា ) បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី ១៤ តិថីទី ១៥ និងតិថីទី ៨ នៃបក្ខផង និងបាដិហារិកបក្ខៈផង ។ ថ្ងៃនេះ ខ្ញុំនោះមានកត្តតែម្តងកោរសក់ដណ្តប់សង្ឃាដី មិនគប្បីប្រាថ្នានូវពួកទេវតា ( ណាមួយ ) ទេ គប្បីបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យ ( តែប៉ុណ្ណោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាតុទ្ទសី បញ្ចទសី** សេចក្តីថា តិថីថ្ងៃ ១៤ ឈ្មោះថា ចាតុទ្ទសី តិថីថ្ងៃ ១៥ ឈ្មោះថា បញ្ចទសី អស់ថ្ងៃចាតុទ្ទសី និងថ្ងៃបញ្ចទសីនោះ ភ្ជាប់សេចក្តីចូលគ្នាថា នៃបក្ខ ។ បទនេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថអច្ចន្តសំយោគ ប្រែថា រហូត ប្រកបសេចក្តីថា អស់តិថីទី ៨ នៃបក្ខនោះ ។ បទថា **បាដិហារិយបក្ខញ្ច** បានដល់ បក្ខសម្រាប់បុគ្គលរក្សានូវឧបោសថ និងបក្ខនៃឧបោសថសីលដែលគប្បីរក្សាក្នុងថ្ងៃ ១៣ រោច ថ្ងៃ ១ រោច ថ្ងៃ ៧ កើត ៧ រោច និងថ្ងៃ ៩ កើត ៩ រោច ក្នុងថ្ងៃដើមជាថ្ងៃចូល ថ្ងៃក្រោយជាថ្ងៃចេញ តាមលំដាប់របស់ថ្ងៃ ១៤ កើត ១៤ រោច ថ្ងៃ ១៥ កើត ១៥ រោច និងថ្ងៃ ៨ កើត ៨ រោច[១] ។ បទថា **អដ្ឋង្គសុសមាគតំ** សេចក្តីថា ប្រកបដោយល្អ ដោយអង្គ ៨ ប្រការ មានចេតនា

---

១-បាដិហារិយឧបោសថនេះ ក្នុងមួយខែមាន ១១ ថ្ងៃ ខាងខ្នើតមាន ៦ ថ្ងៃ ខាងរនោចមាន ៥ ថ្ងៃ គឺ ៧ កើត ៨ កើត ៩ កើត ១៤ កើត ១៥ កើតនិង ១ រោច ៧ រោច ៨ រោច ៩ រោច ១៤ រោច ១៥ រោច ( ឯថ្ងៃ ១ កើតមិនមាន ព្រោះជាខែថ្មី បើខែណាខាច់ ១៤ រោច ត្រូវបន្ថយមកជា ១៣ រោច ១៤ រោចវិញ ) ។

វៀរចាកបាណាតិបាតជាដើម ។ បទថា **ឧបោសថំ ឧបាគច្ឆិំ** ប្រែថា ចូលទៅរក្សា សេចក្តីថា ថែរក្សា ដែលលោកពោលសំដៅដល់ ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា

បុរសឬស្ត្រីមិនគប្បីសម្លាប់សត្វ ១ មិនគប្បីលួចយកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ១ មិនគប្បីនិយាយកុហក ១ មិនគប្បីក្រេបផឹកនូវទឹកស្រវឹង ១ គប្បីវៀរចាកមេថុនដែលមិនមែនជាសេចក្តីប្រព្រឹត្តដ៏ប្រសើរ ១ មិនគប្បីបរិភោគភោជនក្នុងវេលារាត្រីនិងភោជនក្នុងវេលាខុសកាល ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ ( ដែលត្រូវប្រមាណ ) ឬកម្រាលដែលក្រាលផ្ទាល់នឹងផែនដី ១ ។ ( បណ្ឌិតទាំងឡាយពោលសរសើរ ) ឧបោសថ: ប្រកបដោយអង្គ ៨ នុ៎ះ ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុតនៃទុក្ខទ្រង់ប្រកាសទុកហើយ ដូច្នេះ ។

បទថា **ទេវកាយាភិនន្ទិនី** ប្រកបសេចក្តីថា ខ្ញុំប្រាថ្នាយ៉ាងក្រៃលែងនូវទេវនិកាយ មានស្ថានចាតុម្មហារាជិកាជាដើម ទើបរក្សាឧបោសថ ព្រោះសង្ឃឹមកើតក្នុងទេវនិកាយនោះ ។ បទថា **សាជ្ជ ឯកេន ភត្តេន** សេចក្តីថា ខ្ញុំថ្ងៃនេះ គឺក្នុងថ្ងៃនេះឯង មានពេលបរិភោគភត្តាហារម្តង ។ បទថា **មុណ្ឌា សង្ឃាដិបារុតា** សេចក្តីថា កោរសក់ និងដណ្តប់រាងកាយ ដោយសំពត់សង្ឃាដី បួសហើយ ។ បទថា **ទេវកាយំ ន បត្ថេហំ** សេចក្តីថា ខ្ញុំមិន

ប្រាថ្នាទេវនិកាយណាមួយ ព្រោះមគ្គដ៏ប្រសើរ ខ្ញុំបានសម្រេចហើយ ព្រោះហេតុនោះឯង ទើបពោលថា **វិនេយ្យ ហទយេ ទរំ** សេចក្ដីថា កម្ចាត់នូវសេចក្ដីក្រវល់ក្រវាយ គឺកិលេសដែលនៅក្នុងចិត្តដោយការដកឡើង ពាក្យនេះឯងជាការព្យាករអរហត្តផលរបស់ព្រះថេរីនោះ ។

## អដ្ឋកថា មិត្តាថេរីគាថា ចប់

## អភយមាតាថេរីគាថា

[ ២៩១ ] បពិត្រមាតា សូមលោកពិចារណារាងកាយនេះ ជារបស់មិនស្អាត មានក្លិនស្អុយ ខាងលើអំពីបាតជើង ខាងក្រោមអំពីចុងសក់ ។ កាលខ្ញុំប្រព្រឹត្តយ៉ាងនេះ បានដករាគៈទាំងពួងហើយ បានផ្តាច់សេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកមានចិត្តត្រជាក់រលត់ទុក្ខហើយ ។

**អភយមាតាថេរី ។**

## អដ្ឋកថា

## អភយមាតាថេរីគាថា

[២៩១] គាថារបស់ព្រះថេរីដែលជាមាតារបស់ព្រះអភយត្ថេរ មានពាក្យផ្តើមថា **ឧទ្ធំ បាទតលា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុង ភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា តិស្សៈ កើតក្នុងផ្ទះមានត្រកូល ដឹងក្តីហើយថ្ងៃមួយឃើញព្រះសាស្តាត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា ទទួលបាត្រហើយថ្វាយកិក្ខាប្រមាណមួយវែក ដោយបុញ្ញកម្មនោះ នាងអន្ទោលទៅតែក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ បានជាស្រ្តីនគរសោភិនីឈ្មោះបទុមវតី ក្នុងនគរឧជ្ជេនីដោយវិបាកនៃកម្ម ( ណាមួយ ) ព្រះបាទពិម្ពិសារទ្រង់ស្តាប់នូវគុណមានរូបសម្បត្តិជាដើមរបស់នាង ទើបត្រាស់ប្រាប់

ដល់បុរោហិតថា បានឮថា ក្នុងនគរឧជ្ជេនី មានស្រីធ្វើឲ្យនគរស្អាតឈ្មោះ បទុមវតី យើងចង់ឃើញនាង បុរោហិតក្រាបទូលថា សាធុ នាំយក្ខឈ្មោះ កុម្ភីរមកដោយកម្លាំងមន្ត ហើយប្រើអានុភាពយក្ខ នាំព្រះរាជាទៅកាន់នគរ ឧជ្ជេនីក្នុងមួយរំពេចនោះឯង ។ ព្រះរាជា ទ្រង់សម្រេចការនៅរួមជាមួយស្រី នោះអស់រាត្រីមួយ នាងមានគភ៌ដោយព្រះរាជា ហើយបានក្រាបទូលព្រះរាជា ថា ខ្ញុំតាំងគភ៌ហើយ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ត្រាស់ថា បើជាឱរស ចូរ នាងចិញ្ចឹមឲ្យល្អ ហើយបង្ហាញដល់យើង បានប្រទានព្រះទម្រង់ ដែលធ្លាក់ ព្រះនាម ហើយយាងទៅ លុះកន្លងទៅ ១០ ខែ នាងក៏ប្រសូតបុត្ត ក្នុង ថ្ងៃដាក់ឈ្មោះបានដាក់ឈ្មោះថាអភ័យ ។ ក្នុងកាលដែលកុមារមានអាយុ ៧ ឆ្នាំ នាងបានបញ្ជូនទៅគាល់ព្រះរាជាបានប្រាប់ថា ព្រះបាទពិម្ពិសារមហារាជ ជាព្រះបិតារបស់អ្នក ព្រះបាទពិម្ពិសារ ទ្រង់ឃើញព្រះឱរសនោះហើយ មាន សេចក្តីស្រឡាញ់ក្នុងបុត្ត ទ្រង់ឲ្យកុមារធំធាត់ដោយគ្រឿងថែរក្សាកុមារ ។ រឿង ព្រះកុមារនោះបានទូវសទ្ធាក្តី ចេញបួសក្តី និងសម្រេចគុណវិសេសក្តី បាន ពោលទុកហើយខាងដើមនោះឯង ( ក្នុងថេរគាថាឯកនិបាត ) មាតារបស់ កុមារនោះ ក្នុងកាលតមក បានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះអភយត្ថេរជា បុត្តហើយ បានទូវសទ្ធាបួសក្នុងសម្នាក់ភិក្ខុនីចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

កាលព្រះសាស្តាព្រះនាម តិស្សៈ ទ្រង់ត្រាច់ទៅបិណ្ឌបាត ខ្ញុំ

បានយកចង្ហាន់មួយវែក ថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជាសាស្តាជានាយកដ៏លើសលុប ក្នុងលោកទ្រង់ទទួលហើយទ្រង់គង់នៅក្នុងផ្លូវ ទ្រង់ធ្វើអនុមោទនាដល់ខ្ញុំថា

នាងប្រគេនចង្ហាន់ ១ វែក នឹងបានទៅកើត ក្នុងឋានតាវត្តិង្ស នឹងបានជាអគ្គមហេសីនៃស្តេចទេវតា ៣៦ ដង ។ នឹងបានជាមហេសីនៃស្តេចចក្រពត្តិ ៥០ ដង នឹងបាននូវសម្បត្តិទាំងពួង ដែលនាងប្រាថ្នាហើយតាមចិត្តប្រាថ្នាក្នុង កាលទាំងពួង ។ នាងនឹងទទួលនូវសម្បត្តិជាស្ត្រីមិនមានសេចក្តីកង្វល់ នឹងបួសកំណាត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ ព្រះសម្ពុទ្ធព្រះនាមតិស្សៈជានាយក ដ៏លើសលុបក្នុងលោក ព្រះអង្គជាអ្នកប្រាជ្ញ លុះត្រាស់នូវពាក្យនេះហើយ ក៏ហោះទៅឯអាកាស ដូចជាស្តេចហង្សហើរទៅពួដ៏អាកាស ។

ទានដែលខ្ញុំបានថ្វាយល្អហើយ យាគសម្បទា ខ្ញុំបានបូជាល្អហើយ ខ្ញុំបានថ្វាយនូវចង្ហាន់ ១ វែក ហើយដល់នូវអចលបទ គឺព្រះនិព្វាន ។ ក្នុងកប្ប ទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការថ្វាយចង្ហាន់ កិលេសទាំងឡាយ

ខ្ញុំបានដុតបំផ្លាញហើយកពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិ ហើយ ដូច្នេះ(១) ។

កាលសម្រេចអរហត្តហើយ ព្រះថេរីបានអាងយកគាថាដែលព្រះអកយត្ថេរជាបុត្តសម្តែងធម៌ដើម្បីជាស់តឿន ធ្វើជាពាក្យឧទានរបស់ខ្លួនថា

បពិត្រមាតា សូមលោកពិចារណារាងកាយនេះ ជារបស់មិនស្អាត មានក្លិនស្អុយ ខាងលើអំពីបាតជើង ខាងក្រោមអំពីចុងសក់ ។ កាលខ្ញុំប្រព្រឹត្តយ៉ាងនេះ បានដករាគៈទាំងពួងហើយ បានផ្តាច់សេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកមានចិត្តត្រជាក់រលត់ទុក្ខហើយ ដូច្នេះ ។

បណ្តា ២ គាថានោះ គាថាដំបូងមានអត្ថសង្ខេបយ៉ាងនេះថា បពិត្រមាតាបទុមវតី សូមលោកពិចារណាសរីរៈនេះ ឈ្មោះថា **កាយំ** ព្រោះជាទីប្រជុំចុះនូវវត្ថុដែលគួរខ្ពើមទាំងឡាយ ឈ្មោះថា **អសុចឹ** ព្រោះពេញដោយរបស់មិនស្អាតមានប្រការផ្សេងៗ ឈ្មោះថា **បូតិគន្ធិកំ** ព្រោះមានក្លិនស្អុយ

---

១-ក្នុងអបទានជា កដច្ចុភិក្ខទាយិកាថេរី ។

ផ្សាយទៅសព្វកាល ខាងលើពីបាតជើងឡើងទៅ ខាងក្រោមពីចុងសក់ចុះមក ដោយញាណចក្ខុ ។ គាថានេះជាគាថាដែលបុត្តពោលឲ្យឱវាទ ដល់ព្រះថេរីនោះ ។ ព្រះថេរីស្តាប់គាថានោះហើយសម្រេចអរហត្តកាលបន្ទឹងឧទាន បានពោលគាថាដំបូងនោះឯង ជាការបូជាអាចារ្យ កាលពោលដល់ការបដិបត្តិរបស់ខ្លួន ទើបពោលគាថាទី ២ ថា **ឃរំ វិហរមានាយ** ដូច្នេះជាដើម ។

ក្នុងគាថាទី ២ នោះ បទថា **ឃរំ វិហរមានាយ** សេចក្តីថា កាលខ្ញុំតាំងនៅក្នុងឱវាទដែលព្រះអភយត្ថេរជាបុត្តឲ្យហើយ ដោយន័យថា **ឧទ្ធំ បាទ–តលា** ជាដើម បានឃើញកាយគ្រប់ចំណែកថាមិនស្អាត មានចិត្តចុះស៊ប់កំណត់រូបធម៌ មានមហាភូតរូបនិងឧបាទាយរូបក្នុងកាយនោះ និងអរូបធម៌មានវេទនាជាដើមដែលទាក់ទងដោយរូបធម៌នោះ លើកឡើងកាន់ត្រៃលក្ខណ៍ពិចារណាដោយអនិច្ចានុបស្សនាញាណជាដើមក្នុងកាយនោះ ។ បទថា **សព្វោ រាគោ សមូហតោ** សេចក្តីថា រាគៈទាំងឡាយ ខ្ញុំដក គឺជីកហើយដោយអរហត្តមគ្គតាមលំដាប់មគ្គដែលបន្តដោយមគ្គ ដោយវុដ្ឋានគាមិនីវិបស្សនា ។ បទថា **បរិឡាហោ សមុច្ឆិន្នោ** សេចក្តីថា បន្ទាប់អំពីនោះខ្ញុំកាត់សេចក្តីក្តៅក្រហាយ គឺកិលេសទាំងអស់ បានដោយប្រពៃនោះឯង ព្រោះកាត់នូវការក្តៅក្រហាយគឺកិលេសនោះបាន ទើបខ្ញុំជាបុគ្គលត្រជាក់ រំលត់ដោយឥតសេសសល់ដោយសឧបាទិសេសនិព្វានធាតុ ។

អដ្ឋកថា អភយមាតាថេរីគាថា ចប់

# អភយាថេរីគាថា

[ ២៩២ ] ម្នាលនាងអភយា ពួកបុថុជ្ជនជាប់ចំពាក់ក្នុងរាងកាយណា រាងកាយ ( នោះ ) ជាសភាពបែកធ្លាយ អាត្មាអញជាអ្នកដឹងខ្លួន មានស្មារតីតាំងស៊ប់នឹងដាក់ចុះនូវរាងកាយនេះចោលចេញ ។ អាត្មាអញត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ។

**អភយាថេរី ។**

## អដ្ឋកថា
## អភយាថេរីគាថា

[ ២៩២ ] គាថារបស់ព្រះថេរីឈ្មោះអភយាជាសម្លាញ់របស់អភយមាតាថេរី មានពាក្យផ្តើមថា **អភយេ ភិទុរោ កាយោ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាសិខី កើតក្នុងត្រកូលក្សត្រមហាសាល ដល់នូវភាពជាអ្នកដឹងក្តីហើយ បានជាអគ្គមហេសីរបស់ព្រះបាទអរុណរាជថ្ងៃមួយព្រះបាទអរុណរាជបានប្រទានផ្កាឧប្បលក្រអូប ៧ ទងដល់នាង នាងទទួលផ្កាឧប្បលទាំងនោះហើយ អង្គុយគិតថា អញប្រដាប់ផ្កាទាំងនេះ នឹងមានប្រយោជន៍អ្វី ណ្ហើយចុះ អញនឹងយកផ្កាឧប្បលទាំងនេះ បូជាព្រះមាន

ព្រះភាគ ។ ព្រះមានព្រះភាគយាងចូលកាន់ ព្រះរាជនិវេសន៍ក្នុងពេលកិច្ចាចារ ព្រះនាងឃើញព្រះមានព្រះភាគហើយ មានចិត្តជ្រះថ្លា ទើបទទួល ហើយយកផ្កាទាំងនោះ បូជាព្រះមានព្រះភាគ រួចថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានដោយបុញ្ញកម្មនោះ កុលធីតានោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលនានគរឧជ្ជេនី ដល់នូវភាពជាអ្នកដឹងក្តីហើយជាសម្លាញ់របស់នាងអភយមាតាថេរី កាលអភយមាតាថេរីបួស នាងក៏បួស ព្រោះការស្និទ្ធស្នាលជាមួយព្រះថេរីនោះ នៅក្នុងក្រុងរាជគ្រឹះជាមួយព្រះថេរីនោះ ។ ថ្ងៃមួយបានទៅកាន់ព្រៃសីតវនដើម្បីមើលអសុភ ព្រះសាស្តាទ្រង់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ធ្វើអារម្មណ៍ឲ្យប្រាកដដូចនៅក្នុងទីចំពោះមុខ ហើយឲ្យព្រះថេរីឃើញសាកសពហើមប៉ោងជាដើម តាមលំដាប់នៃអសុភ ។ នាងឃើញដូច្នោះ ឈរសង្វេគ ព្រះសាស្តាទ្រង់បញ្ចេញរស្មីបង្ហាញព្រះកាយដូចទ្រង់គង់ក្នុងទីចំពោះមុខបានត្រាស់គាថាទាំងនេះថា

ម្នាលនាងអភយា ពួកបុថុជ្ជនជាប់ចំពាក់ក្នុងរាងកាយណារាងកាយ ( នោះ ) ជាសភាពបែកធ្លាយ អាត្មាអញជាអ្នកដឹងខ្លួនមានស្មារតីតាំងស៊ប់នឹងដាក់ចុះនូវរាងកាយនេះចោលចេញ ។
អាត្មាអញត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅ នៃតណ្ហាសាសនា របស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ដូច្នេះ ។

ក្នុងកាលចប់គាថា ព្រះថេរីនោះបានសម្រេចអរហត្ត សមដូចគាថាព័ន្ធ

ដែលលោកពោលទុកក្នុងអបទានថា

ក្នុងក្រុងអរុណវតី មានក្សត្រ ១ ព្រះអង្គទ្រង់ព្រះនាមអរុណៈ ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានចាត់ចែងនូវផ្កាដែលមិនទាន់ក្រងទុក ។ ខ្ញុំកាន់យកនូវផ្កាឧប្បល ៧ កម្រង មានក្លិនដូចជាក្លិនទិព្វ អង្គុយលើប្រាសាទដ៏ប្រសើរ គិតយ៉ាងនេះក្នុងខណៈនោះថា អញមានប្រយោជន៍អ្វីដោយកម្រងផ្កានេះដែលអញពាក់លើក្បាលរបស់អញ បើអញបូជាចំពោះញាណព្រះពុទ្ធដ៏ប្រសើរ ប្រសើរជាង ។ ជនទាំងឡាយតែងរាប់អាននូវព្រះសម្ពុទ្ធ អញអង្គុយនៅជិតទ្វារកាលណាព្រះសម្ពុទ្ធទ្រង់ហៅថា នាងចូលមក អញនឹងបូជានូវព្រះមហាមុនី ក្នុងកាលនោះ ។ ព្រះជិនស្រីប្រកបដោយភិក្ខុសង្ឃ ស្តេចមកតាមផ្លូវថ្នល់ទ្រង់ល្វាសល្វន់ដូចជាដើមថ្នាំត្រូវខ្យល់ ឬដូចជាកេសររាជសីហ៍ជាស្តេចម្រឹគ ។ ខ្ញុំជាអ្នកមានចិត្តរីករាយលុះឃើញរស្មីព្រះពុទ្ធក៏មានចិត្តសង្វេគមិនទាន់ដល់ទ្វារ ក៏បូជាចំពោះព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំធ្វើផ្កាឧប្បល ៧ កម្រង ត្រដាងពួជដ៏អាកាស ផ្កាទាំងនោះក៏បាំងខាងលើព្រះសិរៈនៃព្រះពុទ្ធ ។ ខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តរីករាយ មានចិត្តត្រេកអរ ធ្វើអញ្ជលីហើយញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធនោះ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ផ្កាទាំងឡាយបាំងធ្វើជាដំបូលនៃរោងធំ ខាង

លើក្បាលខ្ញុំ ក្លិនជាទិព្វក៏ផ្សាយទៅ នេះជាផលនៃផ្កាឧប្បល ៧ កម្រង ។ កាលពួកញាតិនាំខ្ញុំទៅក្នុងកាលម្តងៗ បរិស័ទរបស់ខ្ញុំមានចំនួនត្រឹមណាផ្កាទាំងឡាយក៏បាំងជារោងមានចំនួនត្រឹមនោះ ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៧០ ជង ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំរមែងបានជាធំក្នុងទីទាំងពួង ។ ខ្ញុំបានជាមហេសីនៃស្តេចចក្រពត្តិ ៣៦ ជង ជនទាំងពួង តែងប្រព្រឹត្តតាមខ្ញុំខ្ញុំមានពាក្យត្រូវអ្នកផងជឿកាន់តាម ពណ៌នឹងក្លិនរបស់ខ្ញុំតែងផ្សាយទៅ ដូចក្លិននៃផ្កាឧប្បល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំជាស្រីឈ្លាសក្នុងឥទ្ធិបាទ ត្រេកអរក្នុងការចម្រើនពោជ្ឈង្គ ដល់នូវអភិញ្ញាបារមី នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំជាស្រីឈ្លាសក្នុងសតិប្បដ្ឋាន មានសមាធិជ្ឈានជាអារម្មណ៍ ប្រកបរឿយៗនូវសម្មប្បធាន នេះជាផលនៃពុទ្ធបូជា សេចក្តីព្យាយាមរបស់ខ្ញុំជាគ្រឿងនាំទៅនូវធុរៈ នាំមកនូវធម៌ដ៏ក្សេមចាកយោគខ្ញុំមានអាសវៈអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

---

១-ក្នុងអបទានជា សត្តឧប្បលមាលិកាថេរី ។

កាលសម្រេចអរហត្តហើយ ព្រះនាងអភយាថេរី បានដូវគាថានោះឯង ពោលជាឧទាន ។

បណ្តាបទទាំងនោះព្រះនាងអភយាថេរីហៅខ្លួនឯងដោយបទថា **អភយេ** ។ បទថា **ភិទុរោ** ប្រែថា មានសភាពបែកធ្លាយ សេចក្តីថា មិនទៀង ។ បទថា **យត្ថ សត្តា បុថុជ្ជនា** សេចក្តីថា អន្ធបុថុជ្ជនទាំងនោះជាប់ជំពាក់គឺជាប់ជំពាក់ហើយក្នុងកាយណាដែលមានប្រក្រតីបែកធ្លាយតាមកាល មានសភាវៈមិនស្អាត មានក្លិនស្អុយគួរខ្ពើមនិងបដិកូល ។ បទថា **និក្ខិបិស្សាមិមំ ទេហំ** សេចក្តីថា ខ្ញុំមិនសម្លឹង ព្រោះមិនប្រកាន់មាំ និងលះគឺនិងលះបង់រាងកាយស្អុយនេះ ។ ព្រះមានព្រះភាគត្រាស់ហេតុផលក្នុងសេចក្តីនោះទុកថា **សម្បជានា បតិស្សតា** អាត្មាអញជាអ្នកដឹងខ្លួន មានស្មារតី ដូច្នេះ ។

បទថា **ពហូហិ ទុក្ខធម្មេហិ** អធិប្បាយថា ដែលសេចក្តីទុក្ខមិនតិចមានជាតិនិងជរាជាដើមពាល់ត្រូវហើយ ។ បទថា **អប្បមាទរតាយ** សេចក្តីថា ត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ ពោលគឺការមិនទៅប្រាសចាកសតិព្រោះបាននូវការសង្វេគដោយភាពជាអ្នកឈមចុះកាន់សេចក្តីទុក្ខនោះឯង ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ក្នុងគាថានេះ មានបាឋៈដោយទំនង ( ប្រហែលគ្នា ) ដែលព្រះសាស្តាត្រាស់ហើយថា

> កាលនាងត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូរលះបង់រាងកាយ
> នេះចេញចូរដល់នូវការអស់តណ្ហា ចូរបដិបត្តិតាមពាក្យប្រៀន
> ប្រដៅរបស់ព្រះពុទ្ធ ដូច្នេះ ។

គាថានេះ ព្រះសង្គីតិកាចារ្យលើកឡើងកាន់សង្គីតិ តាមទំនងដែលព្រះថេរីពោលហើយនោះឯង ។ បទថា **អប្បមាទរតាយ តេ** សេចក្តីថា នាងគប្បីជាអ្នកត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ ។

## អដ្ឋកថា អភយាថេរីគាថា ចប់

## សាមាថេរីគាថា

[ ២៩៣ ] អាត្មាអញ មិនទាន់បានសេចក្តីស្ងប់រម្ងាប់នៃចិត្ត មិនលុះអំណាចក្នុងការទាចិត្ត បានចេញទៅខាងក្រៅអំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញនោះ ត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ បានដកតណ្ហាហើយក្នុងរាត្រីទី ៨ អាត្មាអញជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ។

សាមាថេរី ។

ចប់ ទុកនិបាត ។

## អដ្ឋកថា

## សាមាថេរីគាថា

[ ២៩៣ ] គាថារបស់ព្រះថេរីឈ្មោះសាមា មានពាក្យផ្តើមថា **ចតុក្ខត្តុំ បញ្ចក្ខត្តុំ** ដូច្នេះជាដើម ។

បានឮថាកុលធីតានេះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះ ៗ អន្ទោលទៅក្នុងសុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលគហបតិមហាសាលក្នុងក្រុងកោសម្ពីមានឈ្មោះថាសាមា ។ នាងសាមានោះដល់នូវភាពជាអ្នកដឹងក្តីហើយបានជាសម្លាញ់របស់ឧបាសិកាសាមាវតី កាលឧបាសិកាសាមាវតីស្លាប់កើតសេចក្តីសង្វេគបួស កាលបួសហើយ មិនអាចបន្ទោបង់សេចក្តី

សោកដែលកើតឡើងព្រោះនឹកដល់ឧបាសិកាសាមាវតី ទើបមិនអាចកាន់យកអរិយមគ្គបាន ។ ក្នុងកាលតមក នាងបានស្តាប់ឱវាទរបស់ព្រះអានន្ទត្ថេរ អន្តុយត្រង់រោងឆាន់ផ្តើមវិបស្សនា បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនោះ កាលសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កាលប្រកាសនូវការបដិបត្តិនោះ បានពោលគាថាជាឧទានថា

អាត្មាអញ មិនទាន់បានសេចក្តីស្ងប់រម្ងាប់នៃចិត្ត មិនលុះអំណាចក្នុងការនៃចិត្ត បានចេញទៅខាងក្រៅអំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញនោះត្រូវទុក្ខចម៌ជាច្រើនពាល់ត្រូវហើយ បានដកតណ្ហាហើយក្នុងរាត្រីទី ៨ អាត្មាអញជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅ នៃតណ្ហា សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុក្ខត្តុំ បញ្ចក្ខត្តុំ វិហារា ឧបនិក្ខមឹ** សេចក្តីថា ខ្ញុំអន្តុយមនសិការវិបស្សនាក្នុងវិហារដែលជាលំនៅរបស់ខ្ញុំ ខ្ញុំមិនអាចធ្វើសមណកិច្ចឲ្យដល់ទីបំផុតបានទើបគិតថា វិបស្សនារបស់ខ្ញុំបន្តជាមួយមគ្គមិនបាន ព្រោះមិនមានឧតុជាសប្បាយឬហ្ន៎ បានចេញអំពីលំនៅ គឺទីសម្រាក ៤-៥ ដង រួមជា ៩ ដង ព្រោះហេតុនោះ ទើបព្រះថេរីពោលថា **អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនិ** ដូច្នេះ ។ បទថា **ចេតសោ សន្តឹ** ក្នុងគាថានោះ លោកសំដៅយកអរិយមគ្គសមាធិ ។ បទថា **ចិត្តេ អវស-**

**វត្តិនិ** *សេចក្តីថា ធ្វើការនាចិត្តរបស់ខ្ញុំឲ្យប្រព្រឹត្តទៅក្នុងអំណាចមិនបានព្រោះមិនមានសេចក្តីព្យាយាមស្មើ ។*

*បានឮថា ព្រះថេរីនោះព្យាយាមខ្លាំងពេក ។ បទថា* **តស្សា មេ អដ្ឋមី រត្តិ** *សេចក្តីថា ព្រះថេរីមិនខ្ជិលច្រអូស ទាំងពេលយប់និងពេលថ្ងៃ ចម្រើនវិបស្សនា តាំងអំពីបានទទួលឱវាទក្នុងសម្នាក់ព្រះអានន្ទត្ថេរ ចេញអំពីវិហារមួយយប់ ៤-៥ ដង ញុំាំងមនសិការឲ្យប្រព្រឹត្តទៅមិនសម្រេចគុណវិសេសក្នុងរាត្រីទី ៨ ញុំាំងព្យាយាមឲ្យប្រព្រឹត្តទៅស្មើ ធ្វើកិលេសទាំងឡាយឲ្យអស់ទៅតាមលំដាប់មគ្គ ព្រោះហេតុនោះ ទើបព្រះថេរីពោលថា* **តស្សា មេ អដ្ឋមី រត្តិ យតោ តណ្ហា សមូហតា** *ដូច្នេះ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។*

*អដ្ឋកថា សាមាថេរីគាថា ចប់*

*ថេរីគាថា ទុកនិបាត ចប់*

# ថេរគាថា តិកនិបាត

## អញ្ញាតកោសាមាថេរគាថា

[ ២៩៤ ] តាំងពីកាលអាត្មាអញបួសមកបាន ២៥ ឆ្នាំហើយ អាត្មាអញមិនទាន់បានស្គាល់នូវសេចក្តីស្ងប់ចិត្តម្តងទេ ។ អាត្មាអញមិនបានសេចក្តីស្ងប់ចិត្តមិនលុះអំណាចក្នុងការនាចិត្តតែតមកអាត្មា អញរឭកដល់សាសនានៃព្រះជិនស្រី ក៏បានដល់នូវសេចក្តីសំវេគ ។ អាត្មាអញត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ថ្ងៃនេះជារាត្រីទី ៧ របស់អាត្មាអញ ជារាត្រីដែលតណ្ហារីងស្ងួត ។

សាមាថេរី ដទៃទៀត ។

# អដ្ឋកថា

# ថេរគាថា តិកនិបាត

## អញ្ញាតកោសាមាថេរគាថា

[ ២៩៤ ] ក្នុងតិកនិបាត មានវិនិច្ឆ័យដូចតទៅនេះថា

គាថារបស់ព្រះថេរីឈ្មោះអញ្ញាតកោសាមាមានពាក្យផ្តើមថា **បណ្ណវីសតិវស្សានិ** ដូច្នេះជាដើម ។

បានឮថា កុលធីតាអង្គនេះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុង

ព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភព នោះៗ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាវិបស្សី កើតក្នុងកំណើត កិន្នរត្រង់ឆ្នេរស្ទឹងចន្ទភាគា កិន្នរីនោះខ្មីឃ្មាតក្នុងការលេងជាមួយពួកកិន្នរ ក្នុង ទីនោះ ។ ថ្ងៃមួយព្រះសាស្តាយាងទៅក្នុងទីនោះដើម្បីបណ្តុះនូវពូជ គឺកុសល ដល់កិន្នរនោះ ទ្រង់ចង្ក្រមត្រង់ឆ្នេរស្ទឹង ។ កិន្នរនោះឃើញព្រះមានព្រះភាគ ហើយមានចិត្តត្រេកអរ កាន់យកផ្កាវរជព្រឹក្ស ចូលទៅគាល់ព្រះសាស្តាថ្វាយ បង្គំហើយបូជាព្រះមានព្រះភាគដោយផ្កាទាំងនោះ ដោយបុញ្ញកម្មនោះ កិន្នរី ទាំងនោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុង ផ្ទះមានត្រកូលក្នុងក្រុងកោសម្ពី ចម្រើនវ័យហើយ បានជាសម្លាញ់របស់នាង សាមាវតី កាលនាងសាមាវតីនោះស្លាប់ កើតនូវសេចក្តីសង្វេគ បួស ២៥ វស្សា មិនបាននូវចិត្តស្ងប់ ក្នុងពេលចាស់ បានឱវាទរបស់ព្រះសុគតហើយ ចម្រើនវិបស្សនា បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរញីនៅក្បែរឆ្នេរស្ទឹងចន្ទភាគា គ្រា
នោះខ្ញុំបានឃើញព្រះសម្ពុទ្ធទ្រង់ជាទេវតាប្រសើរជាងទេវតា
ព្រះអង្គប្រសើរជាងនរជន ទ្រង់កំពុងចង្ក្រម ។ ខ្ញុំបានបេះផ្កា
ស្រល់យកទៅថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ឯព្រះមហាវីរៈ ទ្រង់
ហិតនូវផ្កាស្រល់ដែលមានក្លិនដូចជាទិព្វ ។ ព្រះសម្ពុទ្ធព្រះនាម
វិបស្សីជាលោកនាយក មានព្យាយាមធំ ទ្រង់បានទទួលយក

ហើយកាលដែលខ្ញុំកំពុងតែសំឡឹងមើល ទ្រង់ក៏ហិតក្នុងកាល
នោះ ។ ខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសម្ពុទ្ធទ្រង់ប្រសើរជាងសត្វ
ជើងពីរ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លាឡើងទៅកាន់ភ្នំ ។ ក្នុង
កប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា
ក្នុងកាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។
កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ទាំងសាសនារបស់ព្រះ
ពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរីសម្រេចអរហត្តហើយ ពិចារណាដល់ការបដិបត្តិរបស់ខ្លួន បានពោលនូវគាថាទាំងនេះជាឧទានថា

តាំងពីកាលអាត្មាអញបួសមកបាន ២៥ ឆ្នាំហើយ អាត្មាអញ
មិនទាន់បានស្គាល់នូវសេចក្តីស្ងប់ចិត្តម្តងទេ ។ អាត្មាអញមិន
បានសេចក្តីស្ងប់ចិត្តមិនលុះអំណាចក្នុងភាវនាចិត្ត តែតមកអា-
ត្មាអញរឭកដល់សាសនា នៃព្រះជិនស្រី ក៏បានដល់នូវសេចក្តី
សំវេគ ។ អាត្មាអញត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ ជា
អ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់
ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយថ្ងៃ
នេះជារាត្រីទី ៧ របស់អាត្មាអញ ជារាត្រីដែលតណ្ហារីងស្ងួត
ដូច្នេះ ។

---

១-ក្នុងអបទានជា សលឡបុប្ផិកាថេរី ។

បណ្ដាបទទាំងនោះ បទថា **ចិត្តស្ស សមំ** បានដល់ ការចូលទៅស្ងប់ នៃចិត្ត សេចក្ដីថា មគ្គសមាធិ និងផលសមាបត្តិដែលកើតអំពីការស្ងប់ចិត្ត បទថា **តតោ** បានដល់ ចាកភាពជាអ្នកមិនអាចញុំាងអំណាចចិត្ត ឲ្យប្រព្រឹត្តទៅនោះ ។ បទថា **សំវេគមាគមឹ** សេចក្ដីថា កាលព្រះសាស្ដា គង់ព្រះជន្មនៅមិនអាចធ្វើកិច្ចរបស់បព្វជិតឲ្យដល់ទីបំផុតបានក្នុងកាល ក្រោយនឹងឲ្យដល់បានដូចម្ដេច ខ្ញុំដល់នូវសេចក្ដីសង្វេគ គឺការតក់ស្លុតព្រោះញាណដូចពោលមកនេះ ។ បទថា **សរិត្វា ជិនសាសនំ** បានដល់ រឭក ដល់ឱវាទរបស់ព្រះសាស្ដា ដែលមានឧបមាដោយអណ្ដើកខ្វាក់ជាដើម ពាក្យដ៏សេសមានន័យដូចបានពោលហើយនោះឯង ។

អដ្ឋកថា អញ្ញតរាសាមាថេរីគាថា ចប់

# ឧត្តមាថេរីគាថា

[ ២៩៥ ] អាត្មាអញមិនបានសេចក្តីស្ងប់រម្ងាប់ចិត្តមិនលុះក្នុងអំណាចការនាចិត្ត បានចេញទៅខាងក្រៅអំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញនោះ បានចូលទៅរកភិក្ខុនីដែលអាត្មាអញគួរជឿ ( បដាចារាថេរី ) ភិក្ខុនីនោះបានសំដែងធម៌ គឺខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ ។ លុះអាត្មាអញបានស្តាប់ធម៌របស់លោកតាមទំនងដែលលោកបានប្រៀនប្រដៅ អាត្មាអញក៏ឆ្អែតដោយបីតិនិងសុខៈ អង្គុយលើបល្ល័ង្កមួយអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៨ អាត្មាអញបានទម្លាយគំនរងងឹត គឺមោហៈ ហើយសណ្ដូកជើងទាំងគូ ។

ឧត្តមាថេរី ។

# អដ្ឋកថា

## ឧត្តមាថេរីគាថា

[ ២៩៥ ] គាថារបស់ឧត្តមាថេរី មានពាក្យផ្តើមថា **ចតុក្ខត្តុំ បញ្ចក្ខត្តុំ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សីកើតជាទាសីក្នុងផ្ទះក្នុងត្រកូលនៃកុដុម្ពិកៈម្នាក់ក្នុងនគរពន្ធុមតី ចម្រើនវ័យហើយ ធ្វើសេចក្តីខ្មីឃ្មាតសង្គ្រោះជីដូនជីតារបស់ខ្លួនចិញ្ចឹមជីវិត ។ សម័យនោះ ព្រះបាទពន្ធុមរាជ ទ្រង់រក្សា

ឧបោសថក្នុងថ្ងៃពេញបូណ៌មី មុនពេលអាហារ ទ្រង់ឲ្យទាន ក្រោយពេលអាហារទ្រង់យាងទៅស្តាប់ធម៌ ។ គ្រានោះ មហាជនប្រព្រឹត្តសមាទានអដ្ឋឧបោសថក្នុងថ្ងៃពេញបូណ៌មីដូចព្រះរាជាទ្រង់បដិបត្តិនោះឯង ។ គ្រានោះទាសីនោះមានគំនិតយ៉ាងនេះថា ឥឡូវនេះ ទាំងមហារាជនិងមហាជន សមាទានអដ្ឋឧបោសថ ណ្ហើយចុះ អាត្មាអញគប្បីសមាទានអដ្ឋឧបោសថក្នុងថ្ងៃឧបោសថទាំងឡាយ ទាសីនោះធ្វើយ៉ាងនោះរក្សានូវឧបោសថសីលបរិសុទ្ធល្អកើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្សអន្ទោលទៅមកតែក្នុងសុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលសេដ្ឋីក្រុងសាវត្ថីដឹងក្តីហើយ បានស្តាប់ធម៌ក្នុងសម្នាក់ព្រះនាងបដាចារាថេរី ចម្រើនវិបស្សនា មិនអាចឲ្យវិបស្សនានោះដល់ទីបំផុតបានបដាចារាថេរី ជ្រាបការប្រព្រឹត្តទៅនៃចិត្តរបស់នាងទើបបានឲ្យឱវាទ នាងតាំងនៅក្នុងឱវាទរបស់ព្រះថេរីនោះ បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមពន្ធុមៈ សោយរាជ្យ ក្នុងនគរពន្ធុមតី ព្រះអង្គរក្សាឧបោសថ ក្នុងថ្ងៃពេញបូណ៌មី ។ សម័យនោះខ្ញុំជាកុម្ភទាសីនៅក្នុងទីនោះ ខ្ញុំបានឃើញសេនាព្រមទាំងព្រះរាជា ហើយគិតយ៉ាងនេះថា សូម្បីស្តេចក៏ទ្រង់លះបង់រាជសម្បត្តិហើយរក្សាឧបោសថ កម្មនោះ ពិតជាប្រកបដោយផលបានជាពួកជនរីករាយហើយ ។ ខ្ញុំពិចារណានូវទុគ្គតិផង នូវសេចក្តីក្រីក្រផងដោយឧបាយនៃប្រាជ្ញាក៏ញុំាង

ចិត្តឲ្យរីករាយ ហើយរក្សាឧបោសថ ។ លុះខ្ញុំរក្សាឧបោសថក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធខ្ញុំក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះ ។ វិមានរបស់ខ្ញុំដែលកុសលធ្វើល្អហើយក្នុងទីនោះ មានកម្ពស់ទៅខាងលើ ១ យោជន៍ ប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈធំស្អិតស្អាងល្អហើយ ។ ស្រីអប្សរ ១ សែន តែងបម្រើខ្ញុំសព្វៗកាល ខ្ញុំរុងរឿងកន្លងលើសទេវតាទាំងឡាយជនៃសព្វៗកាល ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៦៤ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ៣៦ ដង ។ ខ្ញុំមានពណ៌ដូចជាមាស តែងអន្ទោលទៅក្នុងភពទាំងឡាយ ខ្ញុំជាស្រីប្រសើរក្នុងទីទាំងពួង នេះជាផលនៃឧបោសថ ។ ខ្ញុំតែងបាននូវវត្ថុទាំងពួងនេះ គឺយានដំរី យានសេះ យានរថទាំងអស់ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួង ជាវិការៈនៃមាស ជាវិការៈនៃប្រាក់ ជាវិការៈនៃកែវផលិក ជាវិការៈនៃកែវមានពណ៌ក្រហម ។ ខ្ញុំបាននូវវត្ថុទាំងពួង គឺសំពត់កោសេយ្យព័ស្រ្តនិងសំពត់កម្ពលផងសំពត់សម្បកឈើនិងសំពត់អម្បោះផង សំពត់មានថ្លៃដ៏ច្រើនផង ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺបាយ ទឹក ខាទនីយៈ សំពត់ និងសេនាសនៈ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺគ្រឿងប្រអប់ដ៏ប្រសើរ និងកម្រងផ្កា លំអិតសម្រាប់

លាប នេះជាផលនៃឧបោសថ ។ ខ្ញុំបានទូវវត្ថុទាំងនេះ គឺផ្ទះមានកំពូល ប្រាសាទ មណ្ឌប ប្រាសាទមានជំបូលរលីង និងគុហា នេះជាផលនៃឧបោសថ ។ ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើតបានចូលទៅកាន់ផ្នួសមិនទាន់បានកន្លះខែ ក៏បានសម្រេចព្រះអរហត្ត ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្មក្នុងកាលនោះខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧបោសថ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ(១)។

កាលព្រះថេរីសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន បានពោលគាថាទាំងនោះជាឧទានថា

អាត្មាអញ មិនបានសេចក្ដីស្ងប់រម្ងាប់ចិត្ត មិនលុះក្នុងអំណាចភាវនាចិត្តបានចេញទៅខាងក្រៅអំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញនោះ បានចូលទៅរកភិក្ខុនី ដែលអាត្មាអញគួរជឿ ( បដាចារាថេរី ) ភិក្ខុនីនោះបានសំដែងធម៌ គឺខន្ធ អាយតនៈ ធាតុដល់អាត្មាអញ ។ លុះអាត្មាអញបានស្ដាប់ធម៌របស់លោកតាមទំនងដែលលោកបានប្រៀនប្រដៅអាត្មាអញក៏ផ្គួតជោយ

---

១-ក្នុងអបទានជា ឯកុបោសថិកាថេរី ។

បីតិនិងសុខៈ អង្គុយលើបល្ល័ង្កមួយអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៨ អាត្មាអញបានទម្លាយគំនរងងឹត គឺមោហៈ ហើយសណ្ដូកជើងទាំងគូ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សា ភិក្ខុនី ឧចាគច្ឆឹ យា មេ សទ្ធាយិកា អហុ** សេចក្ដីថា ភិក្ខុនីណាជាបុគ្គលដែលខ្ញុំគប្បីជឿ គឺមានវាចាគួរជឿ ខ្ញុំនោះចូលទៅរក គឺចូលទៅជិតភិក្ខុនីនោះ ព្រះថេរីពោលសំដៅដល់ព្រះនាងបដាចារាថេរី ។ បាឋៈថា **សា ភិក្ខុនី ឧបគច្ឆិ យា មេ សាធយិកា** ដូច្នេះក៏មាន ។ សេចក្ដីថា ភិក្ខុនីណាធ្វើប្រយោជន៍របស់ខ្លួនឲ្យសម្រេចដល់ខ្ញុំភិក្ខុនីនោះ គឺបដាចារាថេរី បានចូលទៅរកខ្ញុំដើម្បីអនុគ្រោះ ។ បទថា **សា មេ ធម្មមទេសេសិ ខន្ធាយតនធាតុយោ** សេចក្ដីថា បដាចារាថេរីនោះ កាលសម្ដែងធម៌ដល់ខ្ញុំ ចែកខន្ធជាដើមថា នេះខន្ធ ៥ នេះអាយតនៈ ១២ នេះធាតុ ១៨ ។

បទថា **តស្សា ធម្មំ សុណិត្វាន** សេចក្ដីថា គប្បីស្ដាប់ធម៌អំពីវិបស្សនាដ៏ល្អិតសុខុមដែលសម្ដែងឲ្យដល់អរិយមគ្គ មានការចែកខន្ធជាដើម ជាខាងដើមក្នុងសម្នាក់របស់ព្រះថេរីដែលសម្រេចបដិសម្ភិទានោះ ។ បទថា **យថា មំ អនុសាសិ សា** សេចក្ដីថា តាមដែលព្រះថេរីនោះប្រៀនប្រដៅ គឺពោលប្រៀនប្រដៅខ្ញុំ កាលបដិបត្តិយ៉ាងនោះ ខ្ញុំបានញុំាងការបដិបត្តិឲ្យដល់ទីបំផុត អង្គុយដោយភ្នែនមួយអស់ ៧ ថ្ងៃ ។ សួរថា ដូចម្ដេច ឆ្លើយថា អាត្មាអញក៏ឆ្អែតដោយបីតិនិងសុខៈ បានដល់ ជាអ្នកដល់ព្រមដោយបីតិនិងសុខៈដែល

*សម្រេចដោយឈាន ។*

*បទថា* **អដ្ឋមិយា ចាគេ បសារេសឹ តមោក្ខន្ធំ បទាលិយ** *សេចក្តីថា ខ្ញុំទម្លាយនូវគំនរមោហៈមិនឲ្យសេសសល់ ដោយអរហត្តមគ្គ ទម្លាយក្អេន សណ្តូកជើងក្នុងថ្ងៃទី ៨ ។ ពាក្យនេះឯងជាការព្យាករអរហត្តផលនៃព្រះថេរី នោះ ។*

**អដ្ឋកថា ឧត្តមាថេរីគាថា ចប់**

## អញ្ញតរាឧត្តមាថេរីគាថា

[ ២៩៦ ] ពោជ្ឈង្គទាំង ៧ ណា ជាឧបាយដើម្បីដល់នូវព្រះនិព្វាន ពោជ្ឈង្គទាំងអស់នោះ អាត្មាអញបានចម្រើនហើយ តាមលំអានដែលព្រះពុទ្ធសំដែងហើយ ។ អាត្មាអញជាឱរសធីតារបស់ព្រះពុទ្ធ ជាអ្នកត្រេកអរចំពោះព្រះនិព្វានក្នុងកាលទាំងពួងជាអ្នកបានសុញ្ញតសមាបត្តិនិងអនិមិត្តសមាបត្តិតាមប្រាថ្នា ។ កាមទាំងអស់ទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបានកាត់ផ្តាច់ផ្តិលហើយ ជាតិសង្សាររបស់អាត្មាអញអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។

### ឧត្តមាថេរី មួយរូប ។

## អដ្ឋកថា

## អញ្ញតរាឧត្តមាថេរីគាថា

[ ២៩៦ ] គាថារបស់ព្រះថេរីឈ្មោះឧត្តមាមួយអង្គទៀត មានពាក្យផ្តើមថា **យេ ឥមេ សត្ត ពោជ្ឈង្គា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតជាកុលទាសីក្នុងនគរពន្ធុមតី ថ្ងៃមួយ កុលទាសីនោះ ឃើញព្រះថេរៈខីណាស្រពមួយអង្គដែលជាសាវករបស់ព្រះសាស្តាដែលកំពុងត្រាច់បិណ្ឌបាត មានចិត្តជ្រះថ្លា បានថ្វាយនំ ៣

ជុំ ។ ដោយបុញ្ញកម្មនោះ កុលធីតានោះអន្ទោលទៅក្នុងទេវតានិងមនុស្ស ទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងកោសលជនបទ ជាអ្នកដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ដែលទ្រង់ចារិកទៅក្នុងជនបទ បាននូវសទ្ធាបួស មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំជាកុម្ភទាសី នៅក្នុងនគរពន្ធុមតី បានកាន់យកនូវចំណែក ( នំអន្សម ) របស់ខ្ញុំ ហើយទៅកាន់កំពង់ទឹក ។ ខ្ញុំបានឃើញសមណៈ ១ រូប ក្នុងទីពាក់កណ្តាលផ្លូវ លោកមានចិត្តស្ងប់-ស្ងាត់ មានចិត្តតម្កល់មាំមួន ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានប្រគេននំអន្សម ៣ ។ ខ្ញុំមិនដែលទៅកាន់វិនិបាតអស់ ២៩ កប្ប ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ។ ខ្ញុំធ្វើកុសលហើយ ខ្ញុំបានទទួលសម្បត្តិទាំងអស់ ព្រោះបានធ្វើកុសលឲ្យជាសម្បត្តិ ខ្ញុំបានដល់នូវអ-ចលបទ គឺព្រះនិព្វាន ព្រោះប្រគេននំអន្សម ៣ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

កាលព្រះថេរីសម្រេចអរហត្តហើយ ពិចារណាការបដិបត្តិរបស់ខ្លួន បាន

---

១-ក្នុងអបទានជា មោទកទាយិកាថេរី ។

ពោលគាថាទាំងនេះជាឧទានថា

ពោជ្ឈង្គទាំង ៧ ណា ជាឧបាយដើម្បីដល់នូវព្រះនិព្វាន ពោជ្ឈង្គទាំងអស់នោះអាត្មាអញបានចម្រើនហើយ តាមលំអាន ដែលព្រះពុទ្ធសំដែងហើយ ។ អាត្មាអញជាឱរសធីតារបស់ ព្រះពុទ្ធ ជាអ្នកត្រេកអរចំពោះព្រះនិព្វានក្នុងកាលទាំងពួង ជា អ្នកបានសុញ្ញតសមាបត្តិ និងអនិមិត្តសមាបត្តិតាមប្រាថ្នា ។ កាមទាំងអស់ ទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបាន កាត់ផ្តាច់ផ្តិលហើយ ជាតិសង្សាររបស់អាត្មាអញ អស់រលីង ហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុញ្ញតស្សានិមិត្តស្ស លាភិនីហំ យទិច្ឆកំ** សេចក្តីថា ខ្ញុំបាននូវសុញ្ញតសមាបត្តិនិងអនិមិត្តសមាបត្តិដូចប្រាថ្នា ក្នុងសេចក្តីនោះ មានអធិប្បាយថា ខ្ញុំប្រាថ្នាចូលសមាបត្តិណាមួយក្នុងទីណាមួយ ខ្ញុំតែងចូលសមាបត្តិនោះៗក្នុងទីនោះៗក្នុងកាលនោះៗបានជានិច្ច សូម្បីមគ្គណាមួយដែលមានឈ្មោះថា សុញ្ញតនិងអប្បណិហិតជាដើម មានផលទាំង ៣ គឺសុញ្ញតជាដើមក៏ពិត តែព្រះថេរីអង្គនេះ ក៏ចូលសុញ្ញតសមាបត្តិនិងអនិមិត្តសមាបត្តិប៉ុណ្ណោះ ព្រោះហេតុនោះ ទើបព្រះថេរីពោលថា **សុញ្ញតស្សានិមិត្តស្ស លាភិនីហំ យទិច្ឆកំ** ដូច្នេះ ម្យ៉ាងទៀត ពាក្យនេះលោកពោលតាមដែលប្រព្រឹត្តទៅដោយច្រើន អាចារ្យពួកខ្លះពោលថា នុ៎ះត្រឹមតែជាគំរូ ។

បទថា **យេ ទិព្វា យេ ច មានុសា** សេចក្តីថា វត្ថុកាមទាំងដែលទាក់

ទងក្នុងទេវលោក និងទាក់ទងក្នុងមនុស្សលោកទាំងអស់នោះ ខ្ញុំនឹងកាត់ផ្តាច់ដោយប្រពៃនោះឯង ដោយលះឆន្ទរាគៈដែលទាក់ទងនឹងវត្ថុកាមនោះ គឺធ្វើឲ្យមិនគួរបរិភោគ ដូចព្រះតម្រាស់ ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា ភិក្ខុជាខីណាស្រព មិនគួរបរិភោគនូវរបស់ដែលខ្លួនធ្វើសេចក្តីសន្សំទុក និងកាមទាំងឡាយដូចកាលខ្លួននៅជាគ្រហស្ថក្នុងកាលពីដើម ដូច្នេះ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា អញ្ញតរាឧត្តមាថេរីគាថា ចប់

## ទន្តិកាថេរីគាថា

[ ២៩៧ ] អាត្មាអញ បានចេញទៅអំពីទីសម្រាកក្នុងវេលាថ្ងៃ លើភ្នំឈ្មោះគិជ្ឈកូដ ហើយបានឃើញដំរីដែលចុះឡើងក្បែរច្រាំងស្ទឹង ( ឈ្មោះចន្ទភាគា ) ។ បុរសកាន់កង្វេរបង្គាប់ថា ឯងចូរជូនជើងមក ដំរីដ៏ជូនជើង ហើយបុរសក៏ឡើងជិះដំរី ។ អាត្មាអញបានឃើញដំរីដែលគេមិនទាន់ទូន្មាន គេអាចទូន្មានឲ្យលុះក្នុងអំណាចរបស់ពួកមនុស្សបានហើយក៏ទៅកាន់ព្រៃតាមកិរិយារបស់ដំរីនោះក៏បានធ្វើចិត្តឲ្យនឹងធឹងព្រោះឃើញដំរីនោះ ។

**ទន្តិកាថេរី ។**

## អដ្ឋកថា
## ទន្តិកាថេរីគាថា

[ ២៩៧ ] គាថារបស់ព្រះនាងទន្តិកាថេរី មានពាក្យផ្តើមថា **ទិវា-វិហារា និក្ខម្ម** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងកាលដែលមិនមានព្រះពុទ្ធត្រាស់ដឹងក្នុងលោក កើតជាកិន្នរត្រង់ច្រាំងស្ទឹងចន្ទ-ភាគា ។ ថ្ងៃមួយកិន្នរីនោះត្រាច់លេងជាមួយពួកកិន្នរបានឃើញព្រះបច្ចេក-ពុទ្ធមួយអង្គអង្គុយត្រង់គល់ឈើមួយកន្លែង លុះបានឃើញ ក៏មានចិត្តជ្រះថ្លាចូលទៅរក បូជាដោយផ្កាសាលព្រឹក្សថ្វាយបង្គំហើយចៀសចេញទៅ ដោយ

បុញ្ញកម្មនោះ កុលធីតានោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះព្រាហ្មណ៍ ដែលជាបុរោហិតរបស់ព្រះបាទកោសល ក្នុងនគរសាវត្ថីដល់នូវភាពជាអ្នកដឹងក្ដីហើយបាននូវសទ្ធា ក្នុងកាលទទួលវត្តជេតពន ប្រកាសខ្លួនជាឧបាសិកា ក្រោយមកបួសក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមី នៅក្នុងក្រុងរាជគ្រឹះ ថ្ងៃមួយឆាន់អាហារហើយឡើងភ្នំគិជ្ឈកូដអង្គុយសម្រាកពេលថ្ងៃ ឃើញដំរីសណ្ដូកជើងដើម្បីឲ្យហ្មជាន់ឡើងធ្វើរឿងនោះឯងឲ្យជាអារម្មណ៍ ចម្រើនវិបស្សនា បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលនោះឯង ខ្ញុំកើតជាកិន្នរញីនៅទៀបច្រាំងស្ទឹងចន្ទភាគា ខ្ញុំបានឃើញព្រះពុទ្ធជាព្រះសយម្ភូទ្រង់ប្រាសចាកធូលី ទ្រង់ឈ្នះកិលេស ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយខ្លាំង មានចិត្តត្រេកអរធ្វើនូវអញ្ជលី ហើយកាន់យកនូវកម្រងផ្កាកំរងភ្នំ[១]ទៅបូជាចំពោះព្រះសយម្ភូ ។ ខ្ញុំលះបង់រាងកាយជាកិន្នរញី បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៣៦ ដង សេចក្ដីប្រាថ្នាដោយចិត្តរបស់ខ្ញុំ រមែង

---

១-អបទានរបស់ព្រះនាងទន្តិកាថេរីនេះដូចគ្នានឹងព្រះនាងចិត្តាថេរី តែអដ្ឋកថាចារ្យ លោកផ្លាស់បាលីពី នឡមាលំ មកជា សាលមាលំ ( កម្រងផ្កាបបុសមកជាកម្រងផ្កាកំរងភ្នំ ) វិញ ។

កើតឡើងតាមសមគួរដល់សេចក្តីប្រាថ្នា ។ ខ្ញុំបានជាអគ្គមហេ-
សីនៃស្តេចចក្រពត្តិ ១០ ជង ព្រោះបានសន្សំកងកុសល ខ្ញុំ
តែងអន្ទោលទៅក្នុងភពទាំងឡាយ ។ កុសលរបស់ខ្ញុំ រមែង
មាន ខ្ញុំបានចូលទៅកាន់ផ្នួស ថ្ងៃនេះ ខ្ញុំជាស្រីគួរដល់ការបូជា
ក្នុងសាសនានៃព្រះសក្យបុត្ត ។ ក្នុងកប្បទី ៩៤ អំពីកប្បកប្ប
នេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធក្នុងកាលនោះ ខ្ញុំមិន
ដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រងផ្កាកាំងក្នុំ ។ ថ្ងៃនេះ ខ្ញុំ
មានចិត្តស្អាត ប្រាសចាកចិត្តលាមក មានអាសវៈទាំងពួងអស់
ហើយឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំង-
ឡាយខ្ញុំបានដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា របស់ព្រះ
ពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលព្រះថេរីសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន កើតនូវ
បីតិសោមនស្សបានពោលគាថាទាំងនេះជាឧទានថា

អាត្មាអញបានចេញទៅអំពីទីសម្រាកក្នុងវេលាថ្ងៃលើភ្នំឈ្មោះ
គិជ្ឈកូដ ហើយបានឃើញដំរី ដែលចុះឡើង ក្បែរច្នេះស្ទឹង
( ឈ្មោះចន្ទភាគា ) ។ បុរសកាន់កង្វេរបង្គាប់ថា ឯងចូរជូន
ជើងមកដំរីដ៏ជូនជើងហើយបុរសក៏ឡើងជិះដំរី ។ អាត្មាអញ
បានឃើញដំរីដែលគេមិនទាន់ទូន្មាន គេអាចទូន្មានឲ្យលុះក្នុង
អំណាចរបស់ពួកមនុស្សបាន ហើយក៏ទៅកាន់ព្រៃ តាមគិរិ-

យារបស់ដីរនោះ ក៏បានធ្វើចិត្តឲ្យនឹងធឹង ព្រោះឃើញដីរនោះ

ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាតំ ឱគាហមុត្តិណ្ណំ** សេចក្តីថា ដីរដ៏ប្រសើរធ្វើនូវការឈានចុះ គឺចុះកាន់ស្ទឹង ហើយឡើងអំពីស្ទឹងនោះ ។ ម្យ៉ាងទៀតបាឋៈថា **ឱគយ្ហ ឧត្តិណ្ណំ** ប្រែថា ចុះហើយឡើង ដូច្នេះក៏មាន ។ **ម** អក្ខរៈ គ្រាន់តែធ្វើកិច្ចភ្ជាប់បទ ។ បទថា **នទីតីរម្ហិ អទ្ទសំ** សេចក្តីថា បានឃើញត្រង់ច្រាំងស្ទឹងចន្ទភាគា ។

ដើម្បីប្រាប់ឲ្យដឹងថា បុរសនោះធ្វើអ្វី ទើបព្រះថេរីពោលថា **បុរិសោ** ជាដើម ។ បាទគាថាថា **ធេហិ ទានន្តិ យាចតិ** ក្នុងគាថានោះ សេចក្តីថា ឲ្យសញ្ញាដើម្បីលាតជើង ហើយឡើងជិះលើខ្នងថា ចូរលាជើងចេញមក កាលឲ្យសញ្ញាតាមដែលបង្ហឹកហៅថា **យាចតិ** ( ប្រាប់ ) ក្នុងទីនេះ ។

បទថា **ទិស្វា អទន្តំ ទមិតំ** សេចក្តីថា តាមប្រក្រតី ដីរមិនធ្លាប់បង្ហឹកមកពីមុន ឥឡូវនេះ បានទទួលនូវការបង្ហឹកដែលហត្ថាចារ្យទូន្មានដោយវិជ្ជាដីរ ប្រកបសេចក្តីថា បង្ហឹកដូចម្តេចទើបនៅក្នុងអំណាចរបស់មនុស្ស មនុស្សបញ្ជាដីរប្រភេទណាបាន ខ្ញុំឃើញដីរប្រភេទនោះ ។ បទថា **ខលុ** ក្នុងបទថា **តតោ ចិត្តំ សមាធេសឹ ខលុ តាយ វនំ គតា** ជានិបាត ចុះក្នុងអត្ថហាមសេចក្តីដទៃ សេចក្តីថា ក្រោយអំពីនោះ គឺចាកទីឃើញដីរ ខ្ញុំទៅកាន់ព្រៃធ្វើចិត្តឲ្យជាសមាធិនោះឯង ដោយកិរិយារបស់ដីរនោះជាហេតុ យ៉ាងណា ខ្ញុំគិតថាដីរនេះឈ្មោះថាជាតិរច្ឆាន គង់ដល់នូវការទូន្មានដោយសមត្ថភាពរបស់

ហត្ថាចារ្យបាន ហេតុអ្វីទើបចិត្តរបស់អញដែលជាមនុស្សមិនដល់នូវការទូន្មាន ដោយអំណាចរបស់ព្រះសាស្តា ដែលជាអ្នកទូន្មាននូវបុរស ដូច្នេះ កើតនូវសេចក្តីសង្វេគ ចម្រើនវិបស្សនាធ្វើចិត្តរបស់ខ្ញុំឲ្យជាសមាធិ ដោយអរហត្តមគ្គសមាធិ គឺធ្វើកិលេសឲ្យអស់ទៅ ដោយប្រការទាំងពួងដោយសមាធិដែលពិតប្រាកដ ។

## អដ្ឋកថា ទន្តិកាថេរីគាថា ចប់

## ឧព្វិរីថេរីគាថា

[ ២៩៨ ] ម្នាលនាងឧព្វិរី នាងកន្ទក់កន្ទេញ ក្នុងព្រៃថា ម្នាលជីវៈមាសម្ដាយ ដូច្នេះ នាងចូរដឹងខ្លួន កូនស្រីរបស់នាងទាំងអស់ ៨៤០០០ មានឈ្មោះថាជីវៈ ដូចគ្នា ត្រូវគេដុតក្នុងឈាបនដ្ឋាននេះ បណ្ដាកូនស្រីទាំងនោះ តើនាងសោកចំពោះកូនស្រីណា ។

សរគឺសេចក្ដីសោក អាស្រ័យនូវហឫទ័យរបស់ខ្ញុំព្រះអង្គ ជារបស់ដែលគេឃើញបានដោយក្រ បានដកចេញហើយ ព្រះអង្គបានបន្ទោបង់នូវសេចក្ដីសោកព្រោះកូនស្រីរបស់ខ្ញុំព្រះអង្គ ដែលត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គនោះ មានសរដកហើយ ជាអ្នកមិនមានសេចក្ដីស្រេកឃ្លាន បានរំលត់ទុក្ខហើយ ខ្ញុំព្រះអង្គសូមដល់ព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ។

ឧព្វិរីថេរី ។

## អដ្ឋកថា

## ឧព្វិរីថេរីគាថា

[ ២៩៨ ] គាថារបស់ព្រះឧព្វិរីថេរី មានពាក្យផ្ដើមថា **អម្ម ជីវា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុង

សាសនានៃព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលក្នុង
នគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ កាលមាតាបិតាទៅផ្ទះ
ជនដទៃដើម្បីចូលរួមក្នុងមង្គល ខ្លួនឯងមិនមានសម្លាញ់ ត្រូវទុកចោលក្នុងផ្ទះ
តែម្នាក់ឯង ក្នុងកាលជិតភិក្ខាចារ ឃើញព្រះថេរៈខីណាស្រពមួយអង្គ ដែល
ជាសាវករបស់ព្រះមានព្រះភាគ ដើរចូលមកជិតទ្វារផ្ទះ បំណងនឹងប្រគេនភិក្ខា
ទើបពោលថា សូមនិមន្តលោកម្ចាស់ចូលមកក្នុងទីនេះ កាលព្រះថេរៈ ចូល
ផ្ទះហើយ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន បានក្រាលអាសនៈដែល
ធ្វើអំពីរោមសត្វជាដើមប្រគេន ព្រះថេរៈគង់លើអាសនៈដែលក្រាលនាងទទួល
បាត្រដាក់បិណ្ឌបាតពេញហើយដាក់ក្នុងដៃព្រះថេរៈ ព្រះថេរៈអនុមោទនាហើយ
ចៀសចេញទៅ ដោយបុញ្ញកម្មនោះ នាងកើតក្នុងស្ថានសួគ៌ ជាន់តាវត្តិង្ស
សោយទិព្វសម្បត្តិដ៏ឧឡារក្នុងតាវត្តិង្សនោះ ដរាបដល់អស់អាយុចុតិចាកតា-
វត្តិង្សនោះអន្ទោលទៅក្នុងសុគតិភូមិទាំងឡាយនោះឯង ក្នុងពុទ្ធុប្បាទនេះកើត
ក្នុងត្រកូលគហបតីមហាសាល ក្នុងនគរសាវត្ថី បានឈ្មោះថា ឧព្វិរី ជាស្រី
មានរូបស្អាត គួរទស្សនា គួរជ្រះថ្លា ចម្រើនវ័យហើយនាងត្រូវនាំទៅកាន់
ព្រះដំណាក់នៃព្រះបាទកោសល កន្លងទៅបាន ២ ឬ ៣ ឆ្នាំ បានព្រះរាជ-
ធីតា ១ អង្គ ញាតិបងប្អូនទាំងឡាយ ដាក់ឈ្មោះធីតានោះថា ជីវៈ ព្រះបាទ
កោសលទតឃើញធីតារបស់នាង មាននូវព្រះទ័យត្រេកអរបានប្រទានអភិ-
សេកដល់ព្រះនាងឧព្វិរី ( ឲ្យជាមហេសី ) ។ ក្រោយមក ធីតារបស់នាង
បានស្លាប់ក្នុងកាលដែលរត់ទៅមកបាន មាតាទៅកាន់ព្រៃខ្មោច ដែលគេយក

សាកសពរបស់ធីតាទៅចោល ខ្សឹកខ្សួលរាល់ថ្ងៃ ។

ថ្ងៃមួយ នាងទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយបន្តិច ក៏ទៅឈរត្រង់ច្រាំងស្ទឹងអចិរវតី ខ្សឹកខ្សួលដល់កូន ។ ព្រះសាស្តាទ្រង់ឃើញហេតុនោះ គង់ក្នុងព្រះគន្ធកុដិនោះឯងសម្តែងព្រះកាយត្រាស់សួរថា នាងរវើរវាយព្រោះហេតុអ្វី នាងក្រាបទូលថា សោកស្តាយដល់កូនស្រីរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ព្រៃនេះគេដុតកូនស្រីរបស់នាងប្រមាណ ៨ ម៉ឺន ៤ ពាន់នាក់ បណ្តាកូនស្រីទាំងនោះ នាងរវើរវាយដល់កូនស្រីមួយណា ដូច្នេះហើយទ្រង់សម្តែងទីដុតសពរបស់កូនស្រីទាំងនោះ ត្រង់ទីនោះ ហើយត្រាស់កន្ទុះគាថា[១]ថា

ម្នាលនាងឧព្វិរី នាងកន្ទក់កន្ទេញក្នុងព្រៃថា ម្នាលជីវៈ មាសម្តាយ ដូច្នេះ នាងចូរដឹងខ្លួន កូនស្រីរបស់នាង ទាំងអស់ ៨៤០០០ មានឈ្មោះថា ជីវៈ ដូចគ្នា ត្រូវគេដុតក្នុងឈាបនដ្ឋាននេះ បណ្តាកូនស្រីទាំងនោះ តើនាងសោកចំពោះកូនស្រីណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អម្ម ជីវា** ជាពាក្យហៅធីតាដែលជិតស្និទ្ធនឹងមាតា ពាក្យនេះជាពាក្យសម្តែងអាការកន្ទក់កន្ទេញរបស់នាង ។ បទថា **វនម្ហិ កន្ទសិ** ប្រែថា កន្ទក់កន្ទេញកណ្តាលព្រៃ ។ បទថា **អត្តានំ អធិគច្ឆ ឧព្វិរិ**

---

១-គាថានេះទំនងដូចជាមួយគាថាកន្ទុះ តែក្នុងទីនេះ លោកប្រាប់ថា កន្ទុះគាថា យើងក៏រក្សាទុកតាមពាក្យលោក ។

សេចក្តីថា ម្នាលនាងឧត្តិរី ចូរនាងស្គាល់ គឺចូរដឹងតាមសេចក្តីពិតនូវខ្លួនរបស់នាងនោះឯង ។ បទថា **ចតុរាសីតិសហស្សានិ** ប្រែថា ៨៤០០០ ។ បទថា **សព្វា ជីវសនាមិកា** សេចក្តីថា ជីតាទាំងអស់នោះ មានឈ្មោះដូចគ្នាថាជីវៈ ។ បទថា **ឯតម្ហាឡាហនេ ឧឌ្ឍា** ប្រែថា ត្រូវដុតក្នុងព្រៃខ្មោចនេះ ។ បទថា **តាសំ កមនុសោចសិ** សេចក្តីថា បណ្តា ជីតាប្រមាណ ៨៤០០០ ដែលមានឈ្មោះថាជីវៈនោះ នាងខ្សឹកខ្សួល គឺដល់នូវសេចក្តីសោកដល់អ្នកណា កាលព្រះមុនីទ្រង់សម្តែងធម៌យ៉ាងនេះ ដោយប្រការដូច្នេះ ហើយនាងបញ្ជូនញាណទៅតាមក្រសែព្រះធម៌ទេសនា ប្រារព្ធវិបស្សនាដោយការពីរោះនៃទេសនារបស់ព្រះសាស្តា និងដោយការសម្បូរនៃហេតុរបស់ខ្លួននាងឈរយ៉ាងនោះឯង ខ្វល់ខ្វាយក្នុងវិបស្សនា តាំងនៅក្នុងអរហត្ត ដែលជាអគ្គផលតាមលំដាប់មគ្គ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអបទានថា

ក្នុងកាលនោះ ខ្ញុំជាស្រីក្រងផ្កា នៅក្នុងនគរហង្សវតី មាតាបិតារបស់ខ្ញុំទាំងនោះ បានទៅធ្វើការងារ ។ កាលព្រះអាទិត្យកំពុងត្រង់ជាក់ ខ្ញុំឃើញព្រះសម្ពុទ្ធ[១]ជាសមណៈ កំពុងនិមន្តទៅតាមថ្នល់ ខ្ញុំក៏ក្រាលអាសនៈ ។ ខ្ញុំក្រាលអាសនៈ ដោយកម្រាល មានព្រំដែលមានរោមវែង ៤ ធ្នាប់ និងកម្រាល

---

១-បាលីក្នុងអបទានថា អទ្ទសំ សមណំ អហំ គួរប្រែថា ខ្ញុំឃើញសមណៈ ទើបត្រូវតាមន័យរបស់អដ្ឋកថា ព្រោះអដ្ឋកថា លោកប្រាប់ថា នាងបានធ្វើទានជាមួយភិក្ខុមួយរូប ។

ដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ ជាដើម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានពោលពាក្យនេះថា ផែនដីក្តៅណាស់ ឈរនៅពុំបានព្រះអាទិត្យកំពុងត្រង់ជាក់ ខ្យល់ក៏មិនបក់ ទាំងកត្តកាលក៏ជិតអស់ ។ បពិត្រព្រះមហាមុនី អាសនៈនេះ ខ្ញុំក្រាលហើយដើម្បីប្រយោជន៍ដល់ព្រះអង្គសូមព្រះអង្គអាស្រ័យនូវសេចក្តីអនុគ្រោះគង់លើអាសនៈរបស់ខ្ញុំ ។ ព្រះសមណៈមានព្រះទ័យទូន្មានហើយ មានព្រះទ័យបរិសុទ្ធគង់លើអាសនៈនោះ ខ្ញុំទទួលយកបាត្រនៃព្រះអង្គបានប្រគេនចង្ហាន់សមគួរដល់ការបម្អិន ។ ខ្ញុំលះបង់រាងកាយ ជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្សដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផងដោយការតម្កល់ទុកនូវចេតនានោះផង ។ វិមានរបស់ខ្ញុំល្អ ត្រូវផលនៃអាសនៈនិម្មិតហើយ ក្នុងឋានតាវត្តិង្សនោះ មានកំពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ បល្ល័ង្កផ្សេងៗ របស់ខ្ញុំជាវិការនៃមាស ជាវិការៈនៃកែវមណីជាវិការៈនៃកែវផលិក ជាវិការៈនៃមាសមានពណ៌ក្រហម ។ កម្រាលធ្វើដោយរោមសត្វ មានរោមប្រាងទាំងពីរខាង បល្ល័ង្ករបស់ខ្ញុំ តាំងនៅល្អហើយ ដោយកម្រាលដែលញាត់ដោយគរនិងកម្រាល ដែលធ្វើដោយរោមសត្វដ៏វិចិត្រដោយរូបសត្វមានសីហៈ និងខ្លាធំជាដើមផង ដោយកម្រាលដែលធ្វើដោយ

ឱនមាសនិងសូត្រ ហើយចាក់ស្រែះដោយរតនៈ និងកម្រាល
ដែលធ្វើដោយរោមសត្វ វិចិត្រដោយរោមសត្វសាហាវផង ។
ខ្ញុំស្កប់ស្កល់ដោយការសើចនិងការលេង កាលណាខ្ញុំចង់ទៅ
ខ្ញុំក៏ទៅកាន់ទីដែលខ្ញុំប្រាថ្នា មួយអន្លើដោយបល្ល័ង្ក ដ៏ប្រសើរ
( ក្នុងកាលនោះ ) ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង
បានជាមហេសីនៃស្តេចចក្រពត្តិ ៧០ ដង ។ ខ្ញុំអន្ទោលទៅ
ក្នុងភពតូច ភពធំ តែងបាននូវភោគៈដ៏ច្រើន ខ្ញុំមិនដែលខ្វះខាត
ភោគៈឡើយនេះជាផលនៃអាសនៈឯក ។ ខ្ញុំតែងអន្ទោលទៅ
ក្នុងភពពីរគឺទេវតានិងមនុស្ស ខ្ញុំមិនដែលស្គាល់ភពដទៃឡើយ
នេះជាផលនៃអាសនៈឯក ។ ខ្ញុំតែងកើតក្នុងត្រកូល ២ គឺ
ក្សត្រនិងព្រាហ្មណ៍ ប្រកបដោយត្រកូលខ្ពស់ក្នុងទីទាំងពួងនេះ
ជាផលនៃអាសនៈឯក ។ ខ្ញុំមិនស្គាល់ទោមនស្សដែលញុំាង
ចិត្តរបស់ខ្ញុំឲ្យក្តៅ ខ្ញុំមិនស្គាល់នូវភេទផ្សេងៗ នេះជាផលនៃ
អាសនៈឯក ។ មេនំ ស្រីគម ស្រីកំពុងពេញល្បែងច្រើននាក់
តែងបម្រើខ្ញុំ ខ្ញុំទៅពីចង្កេះ ១ ទៅចង្កេះ ១ គឺ គេពផ្លាស់ប្តូរ
គ្នាមិនដែលដើរដី នេះជាផលនៃអាសនៈឯក ។ ពួកស្រីដទៃ
ផ្លូតទឹកឲ្យខ្ញុំពួកស្រីដទៃឲ្យខ្ញុំបរិភោគភោជនពួកស្រីដទៃប្រដាប់
តាក់តែងឲ្យខ្ញុំពួកស្រីដទៃឲ្យខ្ញុំត្រេកអរសព្វៗកាល ។ ពួកស្រី
ដទៃលាបគ្រឿងក្រអូបឲ្យខ្ញុំ នេះជាផលនៃអាសនៈឯក។ កាល

ខ្ញុំនៅក្នុងមណ្ឌបក្តីនៅជិតគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី បល្ល័ង្ក តែងកើតឡើង ព្រោះដឹងនូវតម្រិះរបស់ខ្ញុំ នេះជាភពទីបំផុតរបស់ខ្ញុំ ភពជាទីបំផុតនេះកំពុងប្រព្រឹត្តទៅ ថ្ងៃនេះ ខ្ញុំទម្លាក់ចោលនូវភាជ ហើយចូលទៅកាន់ផ្នួស ។ ក្នុងកប្បទី ១ សែនអំពីកទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអាសនៈឯក ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

ព្រះថេរីតាំងនៅក្នុងអរហត្តហើយ កាលប្រកាសគុណវិសេស ដែលខ្លួនសម្រេច បានពោលគាថា ២ នេះថា

សរគឺសេចក្តីសោក អាស្រ័យនូវហឫទ័យរបស់ខ្ញុំព្រះអង្គ ជារបស់ដែលគេឃើញ បានដោយក្រ បានវេកចេញហើយព្រះអង្គបានបន្ទោបង់នូវសេចក្តីសោកព្រោះកូនស្រីរបស់ខ្ញុំព្រះអង្គដែលត្រូវសេចក្តីសោកគ្របសង្កត់ហើយ ។ ក្នុងថ្ងៃនេះខ្ញុំព្រះអង្គនោះមានសរវេកហើយ ជាអ្នកមិនមានសេចក្តីស្រេកឃ្លាន បានរំលត់ទុក្ខហើយ ខ្ញុំព្រះអង្គ សូមដល់ព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អព្ពុហិ វត មេ សល្លំ ទុទ្ទសំ ហទយ-**

---

១-ក្នុងអបទានជា ឯកាសនទាយិកាថេរី ។

**និស្សិតំ** សេចក្ដីថា ខ្ញុំម្ចាស់បានដកឡើងហើយ គឺបាននាំចេញហើយ នូវសេចក្ដីសោកនិងការចង់បានដែលបានឈ្មោះថា **សល្លំ** ព្រោះឲ្យកើតនូវការបៀតបៀនព្រោះដកបានដោយលំបាក និងព្រោះចាក់ចុះខាងក្នុង ព្រោះបុគ្គលមិនបានសន្សំកុសលសម្ភារ មើលឃើញបានដោយក្រនូវសរ ដែលដោតក្នុងចិត្តរបស់ខ្ញុំម្ចាស់ ។ បទថា **យំ មេ សោកបរេតាយ** ប្រកបសេចក្ដីថា ព្រោះទ្រង់បានបន្ទោបង់ គឺនាំចេញដោយមិនសេសសល់នូវសេចក្ដីសោកដល់ធីតារបស់ខ្ញុំម្ចាស់ ដែលត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ហេតុនោះទើបខ្ញុំម្ចាស់ដកនូវព្រួញ គឺសេចក្ដីសោកដែលចាក់ក្នុងហទយៈ របស់ខ្ញុំម្ចាស់បានហើយ ។

បទថា **សាជ្ជ អព្ពូឡ្ហសល្លាហំ** សេចក្ដីថា ថ្ងៃនេះ ខ្ញុំម្ចាស់នោះបានដកនូវព្រួញ គឺការចង់បានដោយប្រការទាំងពួង ដោយហេតុនោះឯង ទើបជាអ្នកអស់នូវការចង់បានដោយជុំវិញហើយ ។ បទថា **មុនឹ** សេចក្ដីថា ខ្ញុំម្ចាស់ចូលដល់ គឺចូលទៅជិតផង ដឹងផង សេពគប់ផងនូវព្រះពុទ្ធដែលជាសព្វញ្ញូដោយលោកុត្តរធម៌ ៩ យ៉ាង ចែកជាមគ្គ ផល និព្វាន ដែលព្រះពុទ្ធអង្គនោះទ្រង់សម្ដែងលម្អិតផង នូវព្រះសង្ឃ ពោលគឺពួកព្រះអរិយបុគ្គល ៨ ដែលតាំងនៅក្នុងលោកុត្តរធម៌នោះផង ថាជាសរណៈ គឺជាទីជ្រកកោន ជាទីពួន ជាទីពឹងព្រោះប្រកបដោយព្រះរតនត្រ័យដ៏កំពូលទាំងនោះ និងព្រោះធ្វើវដ្ដទុក្ខឲ្យវិនាសទៅ ។

**អដ្ឋកថាឧព្វិរីថេរីគាថាទី ចប់**

## សុត្តាថេរីគាថា

[ ២៩៩ ] ពួកមនុស្សក្នុងក្រុងរាជគ្រឹះនេះ សម្ងំធ្វើកិច្ចអ្វី ដូចជាបុគ្គលសម្ងំផឹកទឹកឃ្មុំ ក៏មិននាំគ្នាចូលទៅរកនាងសុក្កាថេរីដែលកំពុង ប្រកាសព្រះពុទ្ធសាសនា ។ ពួកបណ្ឌិតបុរសប្រកបដោយប្រាជ្ញាទំនងជាបានក្រេបផឹកនូវធម៌នោះ ជាធម៌មិនគប្បីដឹកនាំបុគ្គលឲ្យត្រឡប់ថយ ជាធម៌មិនលាយឡំ មានឱជារស ដូចជាពួកអ្នកដើរផ្លូវឆ្ងាយ បានក្រេបផឹកនូវទឹកភ្លៀង ។

ព្រះនាងសុក្កាថេរីមានលោកុត្តរធម៌ដ៏បរិសុទ្ធល្អ ជាស្រីប្រាស
ចាករាគៈហើយ ជាអ្នកនឹងធឹងឈ្នះមារព្រមទាំងវាហនៈហើយ
ទ្រទ្រង់រាងកាយមានក្នុងទីបំផុត ។

**សុក្កាថេរី ។**

---

## អដ្ឋកថា

## សុត្តាថេរីគាថា

[ ២៩៩ ] គាថារបស់ព្រះនាងសុក្កាថេរី មានពាក្យផ្ដើមថា **កឹ មេ កតា រាជគហេ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងផ្ទះមានត្រកូល ក្នុងនគរពន្ធុមតី ដឹងក្ដីហើយទៅកាន់វិហារជាមួយឧបាសិកាទាំងឡាយ ស្ដាប់ធម៌ក្នុង

សម្នាក់របស់ព្រះសាស្តា បានទូវសទ្ធាបួសហើយបានជាពហូសូត ទ្រទ្រង់នូវធម៌ មានបដិភាណ ប្រព្រឹត្តព្រហ្មចរិយៈក្នុងសាសនានោះច្រើនពាន់ឆ្នាំ ស្លាប់ទាំងបុថុជ្ជននោះឯង កើតក្នុងស្ថានសួគ៌ជាន់តុសិត ។

កុលធីតានេះរក្សាសីលក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ៣ អង្គយ៉ាងនេះ គឺក្នុងសាសនានៃព្រះមាន ព្រះភាគព្រះនាមថាវិបស្សី ព្រះមានព្រះភាគព្រះនាមថាសិខី និងព្រះមានព្រះភាគព្រះនាមថាវេស្សភូ បានជាពហូសូត ទ្រទ្រង់ព្រះធម៌ដូចគ្នា ។ បួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាកកុសន្ធៈ កោនាគមនៈនិងកស្សបៈ បានជាអ្នកមានសីលបរិសុទ្ធ ជាធម្មកថិកដូចគ្នា ។

កុលធីតានេះសន្សំបុណ្យជាច្រើនក្នុងភពនោះៗដោយប្រការដូច្នេះអន្ទោលទៅក្នុងសុគតិភូមិទាំងឡាយប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតិមហាសាលក្នុងនគររាជគ្រឹះ បាននាមថា សុក្កា ដល់នូវភាពជាអ្នកដឹងក្តីហើយ បានទូវសទ្ធាជាឧបាសិកា ក្នុងកាលព្រះសាស្តាយាងចូលនគររាជគ្រឹះតមកបានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះនាងធម្មទិន្នាថេរីកើតនូវសង្វេគ បួសក្នុងសម្នាក់របស់ព្រះនាងធម្មទិន្នាថេរីនោះឯង ចម្រើនវិបស្សនាមិនយូរប៉ុន្មានក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយកព្រះនាមវិបស្សីមាន
ព្រះនេត្រដូចមាស ពិចារណាឃើញធម៌ទាំងអស់ កើតឡើង

ហើយ ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលមួយក្នុងនគរពន្ធុមតី បាន ស្តាប់ធម៌របស់ព្រះមុនី ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំជាអ្នក ស្តាប់ច្រើន ចងចាំនូវធម៌ ជាអ្នកមានប្រាជ្ញា មួយទៀតជាអ្នក ពោលពាក្យវិចិត្រទាំងជាអ្នកធ្វើតាមសាសនានៃព្រះជិនស្រី ។ កាលនោះ ខ្ញុំបានធ្វើធម្មកថាដើម្បីប្រយោជន៍ដល់ប្រជុំជនគ្រប់ កាល លុះខ្ញុំច្យុតចាកអត្តភាពនោះ ក៏ចូលទៅកើត ក្នុងឋាន តុសិត ជាស្រីមានយស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះព្រះ ជិនស្រីព្រះនាមសិខី រុងរឿងដោយយសដូចជាភ្លើង ប្រសើរ ជាងអ្នកប្រាជ្ញទាំងឡាយ កើតឡើងក្នុងលោក ។ គ្រានោះខ្ញុំ បានបួស ជាស្រីវាងវៃក្នុងព្រះពុទ្ធសាសនា ញុំាងព្រះពុទ្ធដីកា ព្រះជិនស្រីឲ្យរុងរឿង លុះច្យុតចាកអត្តភាពនោះ ក៏បានទៅ កាន់ឋានតាវត្តិង្ស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះព្រះនាយក ព្រះនាមវេស្សភូទ្រង់កើតឡើង ( ក្នុងលោក ) ឯខ្ញុំក៏កើតឡើង តំណាលទឹងព្រះនាយកនោះក្នុងកាលនោះដែរ ជាអ្នកមានយាន ដ៏ធំ ។ ខ្ញុំបួសហើយ ជាអ្នកចងចាំនូវធម៌ ញុំាងសាសនាព្រះ ជិនស្រីឲ្យរុងរឿង ហើយទៅកើតក្នុងបុរីរបស់ទេវតា ដែលជា ទីរីករាយ ទទួលសេចក្តីសុខដ៏ច្រើន ។ ក្នុងភទ្ទកប្បនេះ ព្រះ ជិនស្រីដ៏ឧត្តម ព្រះនាមកកុសន្ធៈ ជានរៈដ៏ខ្ពង់ខ្ពស់កើតឡើង ក្នុងលោក កាលនោះ ខ្ញុំក៏បានកើតឡើងដែរ ។ ខ្ញុំបានបួស

រូបហើយញ៉ាំងសាសនានៃព្រះជិនស្រីឲ្យរុងរឿងតាមសប្បាយ ខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានទៅកើតក្នុងឋានត្រៃត្រឹង្ស ដូចជាភពរបស់ខ្លួនដដែល ។ ក្នុងកប្បនេះដដែល ព្រះនាយកព្រះនាមកោនាគមន ប្រសើរជាងអ្នកប្រាជ្ញ ឧត្តមជាងពួកសត្វទាំងពួង ទ្រង់កើតឡើង ។ គ្រានោះខ្ញុំ បានបួសក្នុងសាសនានៃព្រះកោនាគមនៈនោះ ព្រះអង្គប្រកបដោយតាទិគុណ ជាអ្នកបានស្តាប់ច្រើន ចងចាំនូវធម៌ ញ៉ាំងសាសនានៃព្រះជិនស្រីឲ្យរុងរឿង ។ ក្នុងកប្បនេះឯង ព្រះមុនីទី ៧ ព្រះនាមកស្សបជាទីពឹងនៃសត្វលោក មិនមានកិលេស ដល់នូវព្រះនិព្វានជាទីបំផុតនៃមរណៈកើតឡើង ។ ចំណែកខ្ញុំបានបួសក្នុងសាសនារបស់ព្រះពុទ្ធជាអ្នកប្រាជ្ញជាងពួកជននោះ មានព្រះសទ្ធម្មបែកសព្វគ្រប់ ដ៏ក្លៀវក្លាខាងការសាកសួរ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកមានសីលល្អ មានសេចក្តីអៀនខ្មាស វាងវៃក្នុងត្រៃសិក្ខា ហើយធ្វើនូវធម្មកថា មានប្រមាណច្រើន ដរាបដល់អស់ជីវិត ។ ដោយកម្មវិបាកនោះផង ដោយការតម្កល់នូវចេ-តនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដល់មកក្នុងបច្ឆិមភពឥឡូវនេះ ខ្ញុំបានកើតក្នុងត្រកូលនៃសេដ្ឋីដ៏ធំទូលាយ ដេរដាសដោយរតនៈច្រើនក្នុងគិរិព្វជបុរីដ៏ឧត្តម ។ កាលព្រះលោកនាយកមានភិក្ខុចំនួន

១ ពាន់រូបចោមរោម ទ្រង់ស្តេចទៅកាន់ក្រុងរាជគ្រឹះព្រះឥន្ទ្រ ក៏បានពោលសរសើរថា

ព្រះមានព្រះភាគ មានឥន្ទ្រិយទូន្មានហើយ មានព្រះហឫទ័យផុតចាក កិលេសហើយ ព្រមដោយបុរាណជដិលទាំងឡាយ ដែលមានឥន្ទ្រិយទូន្មាន មានចិត្តផុតស្រឡះហើយ ទ្រង់មានពណ៌បីដូចជាពណ៌នៃមាសផ្កាឈ្មោះសិង្គី ស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះ ។

ខ្ញុំបានឃើញអានុភាពនៃព្រះពុទ្ធនោះផង បានស្តាប់ការប្រជុំនូវគុណនោះផង ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងគុណរបស់ព្រះពុទ្ធ បានបូជាព្រះពុទ្ធនោះសមគួរតាមកម្លាំង ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួសក្នុងសំណាក់នៃនាងធម្មទិន្នាថេរី ។ កាលសក់កំពុងដាច់ចុះខ្ញុំបានជុតបំផ្លាញពួកកិលេសហើយ ខ្ញុំបួសមិនយូរប៉ុន្មាន ក៏បានរៀននូវព្រះពុទ្ធសាសនាចប់សព្វគ្រប់ ។ លំដាប់តពីនោះមក ខ្ញុំបានសម្តែងធម៌ក្នុងទីប្រជុំជនដ៏ច្រើនកាលដែលខ្ញុំកំពុងតែសម្តែងធម៌ធម្មាភិសម័យ ក៏កើតមាន ( ដល់ជនទាំងឡាយ ) ។ បណ្តាពួកសត្វជាច្រើនពាន់ មានយក្សមួយដឹងច្បាស់នូវធម៌នោះ ហើយសង្វេគ ជ្រះថ្លានឹងខ្ញុំ ហើយបានទៅកាន់ក្រុងគិរិព្វជៈ ដោយគិតថា មនុស្សណាមិនចូលទៅអង្គុយជិតនាងសុក្កាថេរីដែលកំពុង

សម្តែងនូវអមតបទគឺនិព្វាន អាត្មាអញធ្វើដូចម្តេចហ្ន៎ឲ្យមនុស្ស ទាំងនោះ ដែលនៅក្នុងក្រុងរាជគហៈមូលគ្នា ដូចពួកសត្វរោម ផឹកនូវទឹកផ្អែម ។ ចំណែកខាងពួកបុគ្គលអ្នកប្រកបដោយបញ្ញា ទំនងជាផឹកទឹកអម្រឹតនោះដែលកិលេសមិនគប្បីតស៊ូបានមាន ឱជា មិនបាច់ស្រោចថែម ដូចជាបុគ្គលដើរផ្លូវឆ្ងាយ ផឹកទឹក ភ្លៀង ។

បពិត្រព្រះពុទ្ធជាមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំង ឡាយផង ជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផងជាអ្នក ស្ទាត់ជំនាញក្នុងចេតោបរិញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេ-និវាស ទិព្វចក្ខុខ្ញុំជម្រះស្អាតល្អហើយ អាសវៈទាំងពួងអស់ ហើយ ឥឡូវនេះភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គ មានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា នៃខ្ញុំព្រះអង្គកើត ឡើង ក្នុងសំណាក់នៃព្រះអង្គ ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិ-បត្តិហើយ ដូច្នេះ ។

កាលព្រះថេរីសម្រេចអរហត្តហើយ បានជាមហាធម្មកថិក មានភិក្ខុនី ប្រមាណ ៥០០ ជាបរិវារ ។ ថ្ងៃមួយ ព្រះថេរីនោះត្រាច់បិណ្ឌបាត ក្នុងក្រុង រាជគ្រឹះ ឆាន់ស្រេចហើយចូលទៅកាន់សម្នាក់ភិក្ខុនីសម្តែងធម៌ដល់មហាបរិ-

ស័ទដែលអន្ធ័យប្រជុំគ្នា ដូចប្របាច់សម្បុកឃ្មុំឲ្យមហាជនផឹកនូវរសផ្អែម ដូចស្រោចដោយទឹកអម្រឹត បរិស័ទផ្ទៀងនូវសោតៈស្តាប់ធម្មកថា របស់ព្រះថេរីនោះ មានចិត្តមិនរាយមាយ ស្តាប់ដោយគោរព ខណៈនោះទេវតាដែលអាស្រ័យនៅលើដើមឈើ ខាងចុងទីចង្ក្រមរបស់ព្រះថេរី ជ្រះថ្លាក្នុងធម្មទេសនា ទើបចូលទៅកាន់ក្រុងរាជគ្រឹះ ប្រកាសគុណរបស់ព្រះថេរីនោះ ចេញពីថ្នល់នេះទៅកាន់ថ្នល់នោះ ចេញពីផ្លូវបែកជា ៤ នេះ ទៅកាន់ផ្លូវបែកជា ៤ នោះ បានពោលគាថា ២ ថា

ពួកមនុស្ស ក្នុងក្រុងរាជគ្រឹះនេះ សម្ងំធ្វើកិច្ចអ្វី ដូចជាបុគ្គល
សម្ងំផឹកទឹកឃ្មុំ ក៏មិនទាំគ្នាចូលទៅរកនាងសុក្កាថេរី ដែលកំពុង
ប្រកាសព្រះពុទ្ធសាសនា ។ ពួកបណ្ឌិតបុរស ប្រកបដោយ
ប្រាជ្ញា ទំនងជាបានក្រេបផឹកនូវធម៌នោះ ជាធម៌មិនគប្បីដឹកនាំ
បុគ្គលឲ្យត្រឡប់ថយ ជាធម៌មិនលាយឡំ មានឱជារស ដូច
ជាពួកអ្នកដើរផ្លូវឆ្ងាយ បានក្រេបផឹកនូវទឹកភ្លៀង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កឹ មេ កតា រាជគហេ មនុស្សា** សេចក្តីថា ពួកមនុស្សក្នុងក្រុងរាជគ្រឹះទាំងនេះធ្វើអ្វី គឺខ្វល់ខ្វាយក្នុងកិច្ចអ្វី ។ បទថា **មធុំ បីតាវ អច្ឆរេ** សេចក្តីថា មនុស្សទាំងឡាយកាន់យកសម្បុកឃ្មុំ ផឹកនូវទឹកឃ្មុំ ជាអ្នកប្រាសចាកសញ្ញា មិនអាចងើបក្បាលឡើងបានយ៉ាងណាសូម្បីពួកមនុស្សក្នុងក្រុងរាជគ្រឹះនេះក៏យ៉ាងនោះ ដូចជាបុគ្គលប្រាសចាកសញ្ញាក្នុងធម្មសញ្ញា រមែងមិនអាចងើបក្បាលឡើងបាន អធិប្បាយថា រវល់តែផ្ចាត់

ម្រាមដៃតែម្យ៉ាងប៉ុណ្ណោះ ។ បទថា **យេ សុត្វា ន ឧបាសន្តិ ទេសេន្តិ ពុទ្ធសាសនំ** សេចក្ដីថា មិនចូលទៅរក គឺមិនចូលទៅអង្គុយជិតព្រះនាងសុក្កាថេរី ជាអ្នកសម្ដែង គឺកំពុងប្រកាសនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺរបស់ព្រះមានព្រះភាគតាមសេចក្ដីពិត ប្រកបសេចក្ដីថា ពួកមនុស្សក្នុងក្រុងរាជគ្រឹះទាំងនោះវង្វេងធ្វើអ្វី ។

បទថា **តញ្ច អប្បដិវានីយំ** សេចក្ដីថា នូវធម៌នោះដែលជាធម៌មិនទាំត្រឡប់ ជាធម៌នាំសត្វចេញចាកទុក្ខ ជាធម៌ធ្វើឲ្យត្រជាក់ ឈ្មោះថា ជាធម៌ធ្វើអ្នកស្ដាប់ឲ្យត្រជាក់ ព្រោះជាធម៌ដែលមនុស្សចង់ស្ដាប់ ឬជាធម៌ដែលចាប់ចិត្តមិនបន្ថែមនូវគ្រឿងផ្សំអាហារ មានរសច្រើនតាមប្រក្រតីនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា មានឱជារស ។ បាលីថា **ឱសធំ** ក៏មាន សេចក្ដីថា ជាថ្នាំសម្រាប់ព្យាបាលព្យាធិ គឺវដ្ដទុក្ខទាំងឡាយ ។ បទថា **បិវន្តិ មញ្ញេ សប្បញ្ញា វលាហកមិវទ្ធគូ** សេចក្ដីថា អ្នកមានបញ្ញា គឺអ្នកជាបណ្ឌិតកំពុងផឹក គឺកំពុងស្ដាប់នូវធម៌នោះ ដូចអ្នកដើរក្នុងផ្លូវកន្តារមិនមានទឹក ផឹកនូវទឹកដែលហូរអំពីស្រទាប់ពពក ( ភ្លៀង ) ដូច្នោះ ។

មនុស្សទាំងឡាយ បានស្ដាប់ដូច្នោះហើយ មានចិត្តជ្រះថ្លា ចូលទៅកាន់សម្នាក់របស់ព្រះថេរី ស្ដាប់ធម៌ដោយគោរព ក្នុងកាលតមក គឺក្នុងកាលដែលបរិនិព្វានជាកាលទីបំផុតនៃអាយុរបស់ព្រះថេរី ព្រះថេរីដើម្បីប្រកាសថាពាក្យប្រៀនប្រដៅជាធម៌នាំសត្វចេញចាកទុក្ខ កាលព្យាករអរហត្តផល ព្រះថេរីបានពោលគាថានេះថា

ព្រះនាងសុក្កាថេរី មានលោកុត្តរធម៌ ដ៏បរិសុទ្ធល្អ ជាស្រី

ប្រាសចាករាគៈហើយ ជាអ្នកនឹងធឹង ឈ្នះមារព្រមទាំងវាហនៈ

ហើយទ្រទ្រង់រាងកាយ មានក្នុងទីបំផុត ដូច្នេះ ។

ក្នុងគាថានោះព្រះនាងសុក្កាថេរីសម្តែងខ្លួននោះឯងដូចអ្នកដទៃ ដោយបទថា **សុក្កា** ។ បទថា **សុក្កេហិ ធម្មេហិ** បានដល់ មានធម៌បរិសុទ្ធល្អ គឺលោកុត្តរធម៌ ។ បទថា **វីតរាគា សមាហិតា** សេចក្តីថា មានរាគៈ ទៅប្រាសហើយដោយប្រការទាំងពួងដោយអរហត្តមគ្គ មានចិត្តតាំងមាំដោយអរហត្តផលសមាធិ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

អដ្ឋកថាសុក្កាថេរីគាថា ចប់

## សេលាថេរីគាថា

[ ៣០០ ] ការរលាស់ខ្លួនចេញ ( ចាកភព ) ក្នុងលោករបស់នាង មិនមានទេ នាងនឹងធ្វើអ្វីដោយវិវេក នាងចូរបរិភោគនូវតម្រេកដែលអាស្រ័យនូវកាមទាំងឡាយ កុំឲ្យក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។

កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកសូលជាគ្រឿង
កាប់ចិញ្ច្រាំនូវឧបាទានក្ខន្ធទាំងឡាយអ្នកឯងពោល ( សំដៅ )
តម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះជាទីអផ្សុក
ដល់អាត្មាទេតើ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួងយើង
បានកម្ចាត់ចេញហើយ គំនរងងឹតយើងបានទម្លុះទម្លាយហើយ
ម្នាលមារមានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារ
ថោកទាប អ្នកឯងយើងកម្ចាត់ចេញបានហើយ ។

សេលាថេរី ។

## អដ្ឋកថា

## សេលាថេរីគាថា

[ ៣០០ ] គាថារបស់ព្រះថេរីឈ្មោះ សេលា មានពាក្យផ្តើមថា **នត្ថិ និស្សរណំ លោកេ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗកើត

ក្នុងផ្ទះមានត្រកូលក្នុងនគរហង្សវតីដល់នូវភាពជាអ្នកដឹងក្ដីហើយ មាតាបិតាលើកឲ្យកុលបុត្តដែលមានជាតិត្រកូលស្មើគ្នា នៅរួមជាមួយកុលបុត្តនោះយ៉ាងសុខសប្បាយច្រើនរយឆ្នាំ កាលកុលបុត្តនោះស្លាប់ខ្លួនឯងក៏មានវ័យកន្លងមកដោយលំដាប់ហើយ កើតនូវសេចក្ដីសង្វេគថា អ្វីជាកុសល ត្រាច់ទៅអំពីអារាមនេះទៅកាន់អារាមនោះ អំពីវិហារនេះទៅវិហារនោះ ម្ដងម្កាល ដើម្បីស្ដាប់ធម៌ក្នុងសម្នាក់របស់សមណព្រាហ្មណ៍ ថ្ងៃមួយ ចូលទៅកាន់ដើមឈើដែលជាទីត្រាស់ដឹងរបស់ព្រះសាស្ដា អង្គុយគិតថា បើព្រះមានព្រះភាគជាបុគ្គលមិនមានបុគ្គលស្មើ ជាបុគ្គលស្មើដោយបុគ្គលមិនមានបុគ្គលណាស្មើសូមពោធិព្រឹក្សនោះធ្វើនូវបាដិហារ្យដល់ខ្ញុំ ។ ដើមពោធិ៍ក៏មានពន្លឺក្នុងលំដាប់ចិត្តុប្បាទរបស់នាងនោះឯង ដូចពាក្យអធិដ្ឋាន មែកទាំងឡាយប្រាកដជា ( ពណ៌ ) មាសទាំងអស់ភ្លឺសព្វទិស នាងឃើញបាដិហារ្យដូច្នោះ មានចិត្តជ្រះថ្លាសម្ដែងសេចក្ដីគោរពរាបអាន អង្គុយផ្គងអញ្ជលីដាក់លើសិរសាក្នុងទីនោះឯងអស់ ៧ យប់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានបូជាសក្ការៈយ៉ាងឧឡារដោយបុញ្ញកម្មនោះ កុលធីតានោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតជារាជធីតារបស់ព្រះបាទអាឡវិក មាននាមថា សេលា តែមនុស្សទាំងឡាយហៅព្រះនាងថាអាឡវិកា ព្រោះជាបុត្រីរបស់ព្រះបាទអាឡវិក នាងដឹងក្ដីហើយ កាលព្រះសាស្ដាទូន្មានអាឡវកយក្ខ ប្រទានបាត្រនិងចីវរក្នុងដៃរបស់អាឡកយក្ខ ចូលទៅកាន់នគរអាឡវីជាមួយអាឡកយក្ខនោះ នាងនៅជាកុមារី ចូលទៅគាល់ព្រះសាស្ដាជាមួយព្រះរាជា ស្ដាប់ធម៌

ហើយ បានទូវសទ្ធា ( ប្រកាសខ្លួន ) ជាឧបាសិកា ។ ក្នុងកាលតមក នាង កើតនូវសេចក្ដីសង្វេគ បួសក្នុងពួកភិក្ខុនីធ្វើកិច្ចខាងដើមហើយ ផ្ដើមវិបស្សនា ពិចារណាសង្ខារទាំងឡាយមានញាណចាស់ក្លា ព្រោះសម្បូរដោយឧបនិស្ស័យ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុក ក្នុងអបទានថា

ក្នុងកាលនោះ ខ្ញុំជាស្រីអ្នកដំណើរនៅក្នុងនគរហង្សវតីខ្ញុំជាស្រី ត្រូវការដោយកុសល តែងដើរទៅរកអារាម ទៅរកវិហារ ។ ខ្ញុំបានឃើញដើមពោធិព្រឹក្សដ៏ឧត្ដម ក្នុងថ្ងៃកាឡប័ក្ខ ហើយ ញុំាងចិត្តឲ្យជ្រះថ្លា ចំពោះពោធិព្រឹក្សនោះ ក៏អង្គុយនៅក្បែរ គល់នៃពោធិព្រឹក្ស ។ ខ្ញុំតម្កល់ចិត្តគោរព ធ្វើនូវអញ្ជលីលើ សិរ្ស: ហើយរងនូវសោមនស្ស ក៏គិតយ៉ាងនេះក្នុងខណៈនោះ ថា បើព្រះពុទ្ធមានគុណរាប់មិនបានមិនមានបុគ្គលផ្ទឹមស្មើមែន សូមឲ្យពោធិព្រឹក្សនេះ សម្ដែងនូវបាដិហារ្យដល់អាត្មាអញ គឺ សូមឲ្យពោធិព្រឹក្សភ្លឺស្វាង ។ ដំណាលគ្នានឹងខ្ញុំកំពុងពិចារណា ពោធិព្រឹក្សក៏ភ្លឺស្វាងក្លាយទៅជាពណ៌មាសទាំងអស់ ទិសទាំង ពួងក៏រុងរឿងក្នុងខណៈនោះ ។ ខ្ញុំអង្គុយក្បែរគល់ពោធិព្រឹក្ស នោះអស់ ៧ ថ្ងៃ ៧ យប់ ដល់ថ្ងៃទី ៧ ខ្ញុំបានបូជាប្រទីប ។ ប្រទីបទាំង ៥ នោះ ក៏ភ្លឺរុងរឿងព័ទ្ធអាសនៈ កាលនោះប្រទីប ទាំងឡាយរបស់ខ្ញុំ ភ្លឺរុងរឿងដរាបដល់ព្រះអាទិត្យរះឡើង ។

លុះខ្ញុំលះបង់រាងកាយជារបស់មនុស្ស ក៏បានទៅកើតក្នុងឋាន តាវត្តិង្ស ដោយកុសលដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ប្រាសាទរបស់ខ្ញុំដែលបុញ្ញកម្មធ្វើល្អ ហើយក្នុងឋានតាវត្តិង្សនោះ លោកហៅថា បញ្ចទីបប្រាសាទ មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ប្រទីបទាំងឡាយរបស់ខ្ញុំមានចំនួនរាប់មិនអស់ តែងភ្លឺរុងរឿងជុំវិញ កពទេវតា ក៏ភ្លឺដោយពន្លឺប្រទីបនោះដែរ ។ ខ្ញុំអង្គុយបែរមុខទៅកាន់ទិសខាងកើត បើខ្ញុំប្រាថ្នាដើម្បីមើលខាងលើខាងក្រោម និងទិសទទឹង ខ្ញុំក៏ឃើញនូវវត្ថុទាំងអស់ដោយចក្ខុ ។ ខ្ញុំប្រាថ្នាដើម្បីឃើញនូវកម្ម ដែលខ្ញុំធ្វើល្អធ្វើអាក្រក់ជរាបណា គ្រឿងបិទបាំងក្នុងវត្ថុទាំងនោះទោះជាឈើឬភ្នំក៏មិនមានជរាបនោះ ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ១០០ ដង ។ ខ្ញុំទៅកាន់កំណើតណាៗ ជាទេវតាឬមនុស្ស ប្រទីបមានចំនួន ១ សែនភ្លឺជុំវិញខ្ញុំ ។ លុះខ្ញុំច្យុតចាកទេវលោកមកកើតក្នុងផ្ទៃមាតា កាលខ្ញុំនៅក្នុងផ្ទៃនៃមាតា ភ្នែករបស់ខ្ញុំមិនដែលធ្មេចឡើយ ។ ប្រទីបចំនួន ១ សែន ដែលប្រកបដោយបុញ្ញកម្ម រមែងភ្លឺក្នុងផ្ទះជាទីប្រសូតិ នេះជាផលនៃប្រទីប ៥ ។ កាលកពជាទីបំផុតដល់ព្រមហើយ ខ្ញុំញុំាងចិត្តឲ្យប្រព្រឹត្តទៅ ខ្ញុំឃើញព្រះនិព្វាន មិនមានជរានិងមរណៈ

មានសេចក្តីត្រជាក់ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើតក៏បាន
សម្រេចព្រះអរហត្ត ព្រះពុទ្ធទ្រង់ឲ្យឧបសម្បទាដល់ខ្ញុំ នេះជា
ផលនៃប្រទីប ៥ កាលខ្ញុំនៅក្នុងមណ្ឌបក្តី ជិតគល់ឈើក្តី ក្នុង
ផ្ទះស្ងាត់ក្តី ប្រទីបតែងភ្លឺរុងរឿងសព្វៗកាល នេះជាផលនៃ
ប្រទីប ៥ ។ ទិព្វចក្ខុរបស់ខ្ញុំស្អាតវិសេស ខ្ញុំជាស្រីឈ្លាសក្នុង
សមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃប្រទីប ៥ ។
បពិត្រព្រះអង្គមានព្យាយាមធំទ្រង់មានចក្ខុ ខ្ញុំមានការប្រព្រឹត្ត
ធម៌ចប់ស្រេចហើយ មានសោឡសកិច្ចធ្វើរួចហើយ មិនមាន
អាសវៈ ជាស្រីមានប្រទីប ៥ សូមថ្វាយបង្គំនូវព្រះបាទទាំង
គូ ។ ក្នុងកប្បទី ១ សែនអំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបាន
ឲ្យទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃ
ប្រទីប ៥ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១]។

កាលព្រះថេរីសម្រេចអរហត្តហើយ នៅក្នុងនគរសាវត្ថី ថ្ងៃមួយ ក្នុង
ពេលបច្ឆាភត្ត ចេញអំពីក្រុងសាវត្ថី ចូលទៅកាន់ព្រៃអន្ធវ័ន ដើម្បីសម្រាក

---

១-ក្នុងថេរិយាបទានត្រង់ទំព័រ ២៤៤ មានព្រះថេរីឈ្មោះ សោណា ដូចព្រះថេរីនេះដែរ តែលោកមិនលើកយកមកក្នុងទីនេះលោកលើកយកអបទានរបស់ព្រះថេរីឈ្មោះ បញ្ចទីបទាយិកា មកវិញ ឯអបទានរបស់ព្រះថេរីឈ្មោះ បញ្ចទីបទាយិកានេះ ដូចគ្នានឹងអបទានរបស់ព្រះថេរីឈ្មោះ បញ្ចទីបិកាដែរ បណ្ឌិតគាន់យកមួយណាក៏បាន ព្រោះមានសេចក្តីដូចគ្នាតែមួយ ។

ពេលថ្ងៃ អង្គុយត្រង់គល់ឈើមួយកន្លែង កាលនោះ មារបំណងនឹងរាំង ព្រះថេរីឲ្យផុតចាកវិវេក ទើបសម្តែងរូបចូលទៅរកពោលគាថានេះថា

ការរលាស់ខ្លួនចេញ ( ចាកភព ) ក្នុងលោករបស់នាងមិន
មានទេ នាងនឹងធ្វើអ្វីដោយវិវេក នាងចូរបរិភោគនូវតម្រេក
ដែលអាស្រ័យនូវកាមទាំងឡាយ កុំឲ្យក្តៅក្រហាយក្នុងកាល
ជាខាងក្រោយឡើយ ដូច្នេះ ។

គាថានោះមានសេចក្តីថា កាលពិចារណាមើលលទ្ធិទាំងពួង ឈ្មោះថា និព្វានដែលជាទីរលាស់ចេញមិនមានក្នុងលោក ។ ពាក្យថា និព្វាន នេះ ត្រឹមតែជាវោហារ ដែលសមណព្រាហ្មណ៍ទាំងនោះ ប្រឌិតតាមការពេញចិត្ត ប៉ុណ្ណោះ ព្រោះហេតុនោះនាងធ្វើប្រយោជន៍អ្វីដោយវិវេក គឺនាងតាំងនៅក្នុង បឋមវ័យបែបនេះនឹងធ្វើប្រយោជន៍អ្វីដោយកាយវិវេក កាលបើដូច្នេះចូរនាង ត្រេកអរក្នុងកាមទាំងឡាយ គឺចូរត្រឡប់សោយនូវការត្រេកអរក្នុងការលេង ដែលអាស្រ័យវត្ថុកាមនិងកិលេសកាម ព្រោះហេតុអ្វី ព្រោះកុំឲ្យក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ ។ អធិប្បាយថា នាងកុំមានការក្តៅក្រហាយ ស្តាយក្រោយថា អញប្រព្រឹត្តព្រហ្មចរិយៈដើម្បីនិព្វានណានិព្វាននោះមិនមាន ឡើយ ព្រោះហេតុនោះឯង ទើបអញមិនបានសម្រេចនូវនិព្វាននោះទាំងសាប សូន្យចាកការបរិភោគកាមផងដែរ អាត្មាអញវិនាសហើយហ្ន៎ ។

ព្រះថេរីបានស្តាប់ដូច្នោះ គិតថា មារនេះល្ងង់ខ្លៅពិត បដិសេធនិព្វាន ដែលអញឃើញប្រចក្សនិងអញ្ជើញអញក្នុងកាមទាំងឡាយ មិនដឹងថា អញ

ជាអ្នកមានអាសវៈអស់ហើយ ណ្ហើយចុះ អញនឹងឲ្យមារនេះ ដឹងរឿងនេះ ហើយគំរាមមារដោយគាថា ២ ថា

កាមទាំងឡាយ មានឧបមាដោយលំពែងនិងដែកស្ទូល ជាគ្រឿងកាប់ចិញ្ច្រាំនូវឧបាទានក្ខន្ធទាំងឡាយអ្នកឯងពោល ( សំដៅ ) តម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ ជាទីអផ្សុកដល់អាត្មាទេតើ ។ សេចក្តីរីករាយ ក្នុងអារម្មណ៍ទាំងពួង យើងបានកម្ចាត់ចេញហើយគំនរងងឹត យើងបានទម្លុះទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារថោកទាប អ្នកឯងយើងកម្ចាត់ចេញបានហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្តិសូលូបមា កាមា** សេចក្តីថា ឈ្មោះថា កាមទាំងឡាយ គប្បីឃើញថាដូចលំពែងនិងដែកស្ទូលដែលជាប់ ព្រោះចាក់នូវសត្វ ដែលជាប់ស្អិតក្នុងកាមនោះ ។ បទថា **ខន្ធ** បានដល់ ឧបាទានក្ខន្ធ ។ បទថា **អាសំ**[១] ស្មើគ្នានឹង **តេសំ** ប្រែថា ទាំងនោះ ។ បទថា **អធិកុដ្ដនា** បានដល់ ជាទីទ្រដើម្បីការកាត់ចិញ្ច្រាំ ( ជ្រញ់ ) សេចក្តីថា ជាទីប្រកាន់យ៉ាងក្រៃលែង ព្រោះសត្វទាំងឡាយប្រកាន់យ៉ាងក្រៃលែងនូវខន្ធទាំងឡាយហើយរមែងត្រូវប្រហារ ត្រូវកាមទាំងឡាយទម្លាយ ។ បទថា **យំ ត្វំ កាមរតឹ ព្រូសិ អរតី ទានិ សា មម** សេចក្តីថា នៃមារមានចិត្តបាបអ្នក

១-បាលីរបស់អដ្ឋកថាជា ខន្ធាសំ ទើបមានពាក្យថា អាសំ នេះ ។

ពោលការត្រេកអរក្នុងកាមណាថា គួរត្រេកអរ គួរសេព ឥឡូវនេះសម្រាប់ខ្ញុំកាមនោះដូចគ្នានឹងខច្ចារៈព្រោះខ្ញុំមិនត្រេកអរ គឺខ្ញុំមិនមាន សេចក្តីត្រូវការណាមួយក្នុងកាមនោះ ។

ដោយបទថា **សព្វត្ថ វិហតា នន្ទិ** ជាដើម ក្នុងគាថានោះ ព្រះថេរីប្រាប់ហេតុផលក្នុងសេចក្តីនោះទុក ។ បទថា **ឯវំ ជានាហិ** ក្នុងគាថានោះ សេចក្តីថា អ្នកចូរដឹងថា ខ្ញុំលះតណ្ហានិងអវិជ្ជាបានអស់ហើយ អធិប្បាយថា នែមារមានចិត្តបាបជាអ្នកប្រព្រឹត្តអាក្រក់ ព្រោះហេតុនោះ ទើបអ្នកត្រូវខ្ញុំកម្ចាត់ហើយ គឺត្រូវខ្ញុំញាំញីហើយដោយការទម្លាយកម្លាំងនិងឈានកន្លងវិស័យ តែអ្នកបៀតបៀនខ្ញុំមិនបានទេ ។

មារត្រូវព្រះថេរីគំរាមយ៉ាងនេះហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ។ សុម្បីព្រះថេរី ក៏សម្រាកអស់ថ្ងៃក្នុងព្រៃអន្ធវ័នដោយសេចក្តីសុខ ដែលកើតអំពីផលសមាបត្តិ វេលាល្ងាចក៏ទៅកាន់លំនៅនោះឯង ។

## អដ្ឋកថា សេលាថេរីគាថា ចប់

## សោមាថេរីគាថា

[ ៣០១ ] ពួកឥសី ( មានព្រះពុទ្ធជាដើម ) គប្បីដល់នូវឋានៈណា ដែលបុគ្គលដទៃ មិនងាយនឹងបានសម្រេច ស្ត្រីមិនអាចនឹងដល់នូវឋានៈនោះ ដោយប្រាជ្ញាប្រវែងពីរធ្នាប់បានទេ ។

កាលបើចិត្តរបស់បុគ្គលអ្នកឃើញច្បាស់នូវធម៌ដោយប្រពៃ បានតម្កល់មាំហើយ កាលបើញាណកំពុងតែប្រព្រឹត្តទៅ តើស្ត្រីភាពហេតុដូចម្តេចមិនគប្បីធ្វើនូវឋានៈនោះបាន ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង យើងបានកម្ចាត់ចេញហើយ គំនរងងឹតយើងបានទម្លុះទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារថោកទាបអ្នកឯងយើងកម្ចាត់ចេញបានហើយ ។

សោមាថេរី ។

**ចប់ តិកនិបាត ។**

## អដ្ឋកថា
## សោមាថេរីគាថា

[ ៣០១ ] គាថារបស់ព្រះសោមាថេរី មានពាក្យផ្តើមថា **យន្តំ ឥសីហិ បត្តព្វំ** ដូច្នេះជាដើម ។

បានឮថា កុលធីតាអង្គនេះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសល ដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងកព

នោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាសិខី កើតក្នុងត្រកូលក្សត្រមហាសាលដល់នូវភាពជាអ្នកដឹងក្តីហើយ បានជាអគ្គមហេសីរបស់ព្រះបាទអរុណរាជ រឿងអតីតទាំងអស់ដូចគ្នានឹងរឿងរបស់អភយាថេរី ឯរឿងបច្ចុប្បន្នដូច្នេះថា កុលធីតានោះអន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះកើតជាធីតាបុរោហិតរបស់ព្រះបាទពិម្ពិសារ ក្នុងក្រុងរាជគ្រឹះមានឈ្មោះថាសោមាដល់នូវភាពជាអ្នកដឹងក្តីហើយបាននូវសទ្ធាជាឧបាសិកា ក្នុងគ្រាព្រះសាស្តាយាងចូលនគររាជគ្រឹះ ក្នុងកាលតមក កើតនូវសេចក្តីសង្វេគបួសក្នុងពួកភិក្ខុនី ធ្វើកិច្ចខាងដើមហើយ ចម្រើនវិបស្សនាមិនយូរប៉ុន្មានក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងក្រុងអរុណវតីមានក្សត្រ ១ ព្រះអង្គ ទ្រង់ព្រះនាមអរុណៈ
ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានចាត់ចែងនូវផ្កាដែលមិន
ទាន់ក្រងទុក ។ ខ្ញុំកាន់យកនូវផ្កាឧប្បល ៧ កម្រង ។បេ។
ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ[១] ។

រឿងទាំងអស់ ដូចគ្នានឹងអបទានរបស់ព្រះនាងអភយាថេរី ។ ព្រះនាងសោមាថេរីនោះ កាលសម្រេចអរហត្តហើយ នៅក្នុងក្រុងសាវត្ថីដោយវិមុត្តិសុខ ។ ថ្ងៃមួយ ចូលកាន់ព្រៃអន្ធវនដើម្បីសម្រាកក្នុងពេលថ្ងៃ អង្គុយត្រង់

---

១-អបទានរបស់ព្រះថេរីអង្គនេះ ដូចគ្នានឹងអបទានរបស់ព្រះថេរីឈ្មោះ អភយា ក្នុងទុកនិបាត នោះឯង ។

គល់ឈើមួយដើម កាលនោះមារបំណងនឹងរារាំងព្រះថេរីអំពីវិវេក ទើបបាត់ខ្លួនទៅឈរក្នុងអាកាសពោលគាថានេះថា

ពួកឥសី ( មានព្រះពុទ្ធជាដើម ) គប្បីដល់នូវឋានៈណាដែល
បុគ្គលដទៃមិនងាយនឹងបានសម្ភពស្ត្រីមិនអាចនឹងដល់នូវឋានៈ
នោះដោយប្រាជ្ញាប្រវែងពីរធ្នាប់បានទេ ដូច្នេះ ។

គាថានោះ មានសេចក្តីថា ឋានៈនោះ គឺឋានៈដែលប្រសើរក្រៃលែងពោលគឺអរហត្ត បុគ្គលមានបញ្ញាច្រើន មានព្រះពុទ្ធជាដើមដែលបានឈ្មោះថា ឥសី ព្រោះអត្ថថា ស្វែងរកគុណមានសីលក្ខន្ធជាដើមទើបសម្រេចបាន តែបុគ្គលដទៃឲ្យចម្រើនបានលំបាក គឺឲ្យសម្រេចបានដោយលំបាក ស្ត្រីមានបញ្ញា ២ ធ្នាប់ គឺមានបញ្ញាថោកថយ មិនអាចសម្រេចឋានៈនោះបានជម្មតាស្រីទាំងឡាយដាំបាយរហូតទៅតាំងអំពីអាយុ ៧-៨ ឆ្នាំ យកអង្ករដាក់ក្នុងទឹកក្តៅ ក៏មិនដឹងថា ប៉ុណ្ណេះបាយឆ្អិនហើយ តែកាលយកវែកដួសអង្ករដែលក្តៅហើយឈ្ងីដោយម្រាមដៃ ២ រមែងដឹងបាន ដូច្នោះ ទើបមារពោលថាដោយប្រាជ្ញាប្រវែងពីរធ្នាប់ ដូច្នេះ ។

ព្រះថេរីបានស្តាប់ដូច្នោះហើយ កាលគំរាមមារ បានពោល ២ គាថាក្រោមអំពីនេះថា

កាលបើចិត្តរបស់បុគ្គលអ្នកឃើញច្បាស់នូវធម៌ដោយប្រពៃបានតម្កល់
មាំហើយ កាលបើញាណកំពុងតែប្រព្រឹត្តទៅតើស្ត្រីភាពហេតុដូចម្តេច
មិនគប្បីធ្វើនូវឋានៈនោះបាន ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង

យើងបានកម្ចាត់ចេញហើយ គំនរងងឹត យើងបានទម្លុះទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារថោកទាប អ្នកឯងយើងកម្ចាត់ចេញបានហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥត្ថិភាវោ នោ កឹ កយិរា** សេចក្ដីថា ភាពជាមាតុគ្រាមគប្បីធ្វើអ្វីដល់ពួកយើងបាន គឺគប្បីឲ្យកើតនូវការព្រាត់ប្រាសចាកការសម្រេចអរហត្តបានដូចម្ដេច ។ បទថា **ចិត្តម្ហិ សុសមាហិតេ** សេចក្ដីថា កាលចិត្តតាំងមាំដោយល្អដោយអរហត្តមគ្គសមាធិ ។ បទថា **ញាណម្ហិ វត្ត-មានម្ហិ** សេចក្ដីថា បន្ទាប់អំពីនោះ កាលអរហត្តមគ្គញាណប្រព្រឹត្តទៅ ។ បទថា **សម្មា ធម្មំ វិបស្សតោ** សេចក្ដីថា កាលខ្ញុំឃើញសច្ចៈ ៤ ដោយប្រពៃនោះឯង ដោយវិធីដែលកំណត់ដឹងជាដើម ក្នុងសេចក្ដីនេះមានសេចក្ដីសង្ខេបដូច្នេះថា នែមារមានចិត្តបាប ស្រីក្ដី ប្រុសក្ដី ចូរលើកទុក កាលបានសម្រេចអរហត្តមគ្គហើយ ភាពជាព្រះអរហន្តក៏នៅក្នុងកណ្ដាប់ដៃនោះឯង ។

ឥឡូវនេះ ព្រះថេរីកាលសម្ដែងថា ខ្ញុំនសម្រេចហើយត្រង់ៗនោះឯងដល់មារនោះ គប្បីជ្រាបគាថាថា **សព្វត្ថ វិហតា នន្ទិ** ជាដើម គាថានោះ មានអត្ថដូចពោលទុកហើយនោះឯង ។

អដ្ឋកថា សោមាថេរីគាថា ចប់

ថេរីគាថា តិកនិបាត ចប់

# ថេរីគាថា ចតុក្កនិបាត
## ភទ្ទកាបិលានីថេរីគាថា

[ ៣០២ ] ព្រះថេរៈឈ្មោះកស្សប ជាបុត្តព្ទទាយាទ មានចិត្តតម្កល់មាំល្អ លោកបានដឹងនូវបុព្វេនិវាស ទាំងឃើញឋានសួគ៌និងអបាយ លំដាប់អំពីនោះមក លោកបានដល់នូវធម៌ជាទីអស់ទៅនៃជាតិ បានសម្រេចនូវអភិញ្ញា ជាអ្នកប្រាជ្ញ ជាព្រាហ្មណ៍ បានសម្រេចវិជ្ជា ៣ ដោយវិជ្ជា ៣ នេះ ។ ព្រះថេរីឈ្មោះ ភទ្ទកាបិលានី ក៏យ៉ាងនោះដែរបានសម្រេចវិជ្ជា ៣ ញុំាងមច្ចុឲ្យសាបសូន្យឈ្នះមារព្រមទាំងវាហនៈហើយទ្រទ្រង់រាងកាយជាទីបំផុត ។ យើងទាំងពីររូបបានឃើញទោសក្នុងលោកហើយមកបួស យើងទាំងនោះ ជាព្រះខីណាស្រពបានទូន្មានខ្លួនហើយ ជាអ្នកមានចិត្តត្រជាក់បាននិព្វានហើយ ។

ភទ្ទកាបិលានីថេរី ។

ចប់ ចតុក្កនិបាត ។

# អដ្ឋកថា
# ថេរីគាថា ចតុក្កនិបាត
## ភទ្ទកាបិលានីថេរីគាថា

ក្នុងចតុក្កនិបាត មានវិនិច្ឆ័យដូចតទៅនេះថា

[ ៣០២ ]គាថារបស់ព្រះនាងភទ្ទកាបិលានីថេរី មានពាក្យផ្តើមថា **បុត្តោ**

**ពុទ្ធស្ស ធាយាគោ** ដូច្នេះជាដើម ។

បានឮថា ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ ព្រះថេរីនោះកើតក្នុងផ្ទះមានត្រកូល ក្នុងនគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុនីមួយអង្គក្នុងតំណែងឯតទគ្គៈខាងរឭកជាតិបាន ទើបធ្វើបុញ្ញាធិការ ប្រាថ្នាតំណែងនោះ ធ្វើបុណ្យជាបដល់អស់ជីវិត ឃ្លាតចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ កាលព្រះពុទ្ធមិនទាន់កើតឡើង កើតក្នុងផ្ទះមានត្រកូលក្នុងនគរពារាណសី ហើយទៅកាន់ក្រកូលស្វាមី ។ ថ្ងៃមួយឈ្មោះនឹងប្អូនថ្លៃស្រី កាលប្អូនថ្លៃស្រីប្រគេនបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ នាងគិតថាស្រីនេះ ថ្វាយទានដល់ព្រះបច្ចេកពុទ្ធអង្គនេះហើយ នឹងបានសម្បត្តិដ៏ឧឡារទើបកញ្ឆក់យកបាត្រអំពីដៃរបស់ព្រះបច្ចេកពុទ្ធ ហើយចាក់អាហារចោលយកភក់ដាក់ពេញ ហើយប្រគេន មហាជនតិះដៀលថា ស្រីនេះជាបុគ្គលពាលព្រះបច្ចេកពុទ្ធលោកធ្វើអ្វីខុសនឹងឯងឬ ។ ស្ត្រីនោះ ខ្មាសនឹងពាក្យរបស់មនុស្សទាំងនោះ ទទួលយកបាត្រមកវិញ ចាក់ភក់ចេញ លាងបាត្រដោយលម្អិតអប់ដោយគ្រឿងក្រអូបយករបស់មានរសឆ្ងាញ់ ៤ យ៉ាងដាក់រហូតពេញចាក់បំពេញដោយសប្បិដែលមានពណ៌ដូចផ្កាឈូក អំពីខាងលើ ហើយដាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ តាំងសេចក្តីប្រាថ្នាថា បិណ្ឌបាតនេះមានពន្លឺយ៉ាងណាសូមសរីរៈរបស់ខ្ញុំមានពន្លឺយ៉ាងនោះ ។ នាងឃ្លាតចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងសុគតិភូមិទាំងឡាយ ប៉ុណ្ណោះ ក្នុងសាសនាព្រះកស្សបសម្ពុទ្ធ

កើតជាសេដ្ឋីធីតាមានសម្បត្តិច្រើន ក្នុងនគរពារាណសី ដោយផលនៃបុព្វកម្ម ទើបមានរាងកាយស្អុយ ពួកមនុស្សរង្កៀស នាងកើតសេចក្តីសង្វេគ ទើបយកគ្រឿងអលង្ការរបស់ខ្លួនរម្លាយធ្វើឥដ្ឋមាស ប្រតិស្ឋានត្រង់ចេតិយនៃព្រះមានព្រះភាគនិងបូជាដោយផ្កាឧប្បលមួយក្តាប់ ។ ដោយបុញ្ញកម្មនោះ រាងកាយរបស់នាងមានក្លិនក្រអូបជាប់ចិត្តក្នុងកពនោះឯង នាងបានជាទីស្រឡាញ់ បានជាទីពេញចិត្តរបស់ប្តី ធ្វើកុសលជរាបដល់អស់ជីវិត ឃ្លាតចាកអត្តភាពនោះកើតក្នុងស្ថានសួគ៌ សូម្បីក្នុងស្ថានសួគ៌នោះ ក៏បានសោយទិព្វសុខជរាបដល់អស់ជីវិត ចុតិអំពីស្ថានសួគ៌នោះ មកកើតជារាជធីតានៃព្រះបាទពារាណសី សោយសម្បត្តិដូចគ្នានឹងសម្បត្តិទេវតា ក្នុងក្រុងពារាណសីនោះ បម្រើព្រះបច្ចេកពុទ្ធទាំងឡាយអស់កាលយូរ កាលព្រះបច្ចេកពុទ្ធទាំងនោះ បរិនិព្វានហើយកើតសេចក្តីសង្វេគ បួសជាតបស្វិនីក្នុងព្រះរាជឧទ្យាន ចម្រើនឈានទាំងឡាយ ហើយកើតក្នុងព្រហ្មលោក ចុតិអំពីព្រហ្មលោកនោះហើយ កើតត្រកូលព្រាហ្មណ៍កោសិយគោត្ត ក្នុងសាគលនគរ ធំចម្រើនឡើង ដោយបរិវារច្រើន ចម្រើនវ័យហើយមាតាបិតានាំទៅកាន់ផ្ទះរបស់បិប្ផលិកុមារ ក្នុងមហាតិត្ថគាម កាលបិប្ផលិកុមារចេញបួស នាងលះគំនរកោគៈធំនិងពួកញាតិចេញបួសដែរ ចូលទៅនៅក្នុងអារាមរបស់តិត្ថិយអស់ ៥ ឆ្នាំ ក្រោយមក នាងបានបព្វជ្ជា និងឧបសម្បទាក្នុងសម្នាក់ព្រះនាងមហាបជាបតិគោតមី ផ្តើមវិបស្សនា មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយកនៃសត្វលោក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ កាលនោះ សេដ្ឋីឈ្មោះវិទេហៈ មានកែវដ៏ច្រើននៅក្នុងក្រុងហង្សវតី ខ្ញុំជាប្រពន្ធនៃសេដ្ឋីនោះ ។ ក្នុងកាលមួយសេដ្ឋីនោះព្រមទាំងជន ជាបរិស័ទចូលទៅគាល់ព្រះពុទ្ធជាព្រះអាទិត្យរបស់នរជន ហើយស្តាប់ធម៌ របស់ព្រះពុទ្ធជាទីនាំមកនូវការអស់ទៅ នៃទុក្ខទាំងពួង ។ ព្រះពុទ្ធជានាយកទ្រង់សរសើរនូវសាវ័ក ថាជាអ្នកប្រសើរជាងភិក្ខុទាំងឡាយអ្នកពោលពាក្យជាគ្រឿងកម្ចាត់បង់នូវកិលេស ។ ខ្ញុំបានស្តាប់ហើយថ្វាយទានដល់ព្រះពុទ្ធជាតាទិបុគ្គលអស់ ៧ ថ្ងៃ ។ ខ្ញុំក្រាបទៀបព្រះបាទាដោយសិរ្សៈ ប្រាថ្នាតំណែងនោះគ្រានោះព្រះអង្គជាអ្នកធ្មើមជាងនរៈ ទ្រង់ញុំាងបរិស័ទឲ្យរីករាយហើយទ្រង់ត្រាស់គាថាទាំងនេះដើម្បីអនុគ្រោះសេដ្ឋីថា ម្នាលកូនអ្នកនឹងបានតំណែងដែលអ្នកប្រាថ្នាហើយអ្នកចូរបានរំលត់ទុក្ខចុះ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតមកើតក្នុងឱក្កាកៈត្រកូលនឹងត្រាស់ឡើងក្នុងលោក ។ សេដ្ឋីនោះនឹងបានជាញាតិក្នុងធម៌ទាំងឡាយនៃព្រះសាស្តានោះ ជាឱរសជាធម្មនិម្មិតជាសាវ័កនៃព្រះសាស្តា មានឈ្មោះថាកស្សបៈ ។ កាលនោះ ខ្ញុំបានស្តាប់ព្យាករណ៍នោះហើយ ក៏រីករាយ មាន

ចិត្តប្រកបដោយមេត្តា បម្រើព្រះជិនស្រី ព្រះអង្គជានាយកនៃសត្វលោកដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ព្រះពុទ្ធអង្គនោះញុំាងសាសនាឲ្យរុងរឿង ញុំាញីនូវតិរ្ថិយអាក្រក់ទាំងឡាយ ទូន្មាននូវវេនេយ្យសត្វ ព្រះអង្គព្រមទាំងសាវកបរិនិព្វានហើយ ។ កាលព្រះមានព្រះភាគជាកំពូលនៃសត្វនោះៗនិព្វានហើយ មហាជនបានប្រជុំញាតិនិងមិត្ត មួយអន្លើដោយសាវកទាំងឡាយនោះ បានញុំាងជនឲ្យធ្វើព្រះស្តូបជាវិការៈនៃកែវកម្ពស់ ៧ យោជន៍ ដ៏រុងរឿងដូចព្រះអាទិត្យ ឬដូចស្តេចឈើមានផ្ការីកដើម្បីបូជាព្រះសាស្តា ។ ខ្ញុំបានឲ្យគេសាងកាជន៍ ៧ អស់ ទ្រព្យ ៧ សែន កាជន៍ទាំងនោះរុងរឿងដោយកែវ ៧ ដូចភ្លើងឆេះបបុស ។ ខ្ញុំញុំាងប្រទីបទាំងនោះឲ្យពេញដោយប្រេងក្រអូប ហើយអុចបំភ្លឺក្នុងទីនោះ ដើម្បីបូជាព្រះពុទ្ធទ្រង់ស្វែងរកគុណធំ ទ្រង់អនុគ្រោះដល់សត្វទាំងពួង ។ ខ្ញុំសាងក្អមដ៏ពេញចំនួន ៧ សែន ដ៏ពេញដោយកែវ ៧ ដើម្បីបូជាដល់ព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ ។ គ្រឿងបូជា ជាវិការនៃមាសដែលបុគ្គលលើកឡើងហើយក្នុងកណ្តាលនៃក្អមប្រាំបី ៗ ដ៏រុងរឿងដោយសម្បុរ ដូចជាព្រះអាទិត្យក្នុងសារទសម័យ ។ ខ្លោងទ្វារជាវិការៈនៃកែវល្អក្នុងទ្វារទាំង ៤ ផែនក្តារជាវិការនៃកែវជាទីរីករាយដែលបុគ្គលលើកឡើងហើយក៏ល្អ ។ របងទាំង

ឡាយមានកំពូល ដែលបុគ្គលតាក់តែងល្អរុងរឿង ទង់ទាំងឡាយជាវិការៈនៃកែវដែលបុគ្គលលើកឡើងហើយ ក៏រុងរឿង ។ ចេតិយនេះជាវិការៈនៃកែវមានសម្បុរក្រហមល្អ ដែលបុគ្គលធ្វើហើយដោយប្រពៃ រុងរឿងដោយសម្បុរ ដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃល្ងាច ។ ខ្ញុំបានញុំាងទិសទាំង ៣ នៃព្រះស្តូបរបស់ខ្ញុំឲ្យពេញ គឺទិស ១ ពេញដោយថ្មហរិតាល ទិស ១ ពេញដោយថ្មមនោសិលា ទិស ១ ពេញដោយថ្មមានពណ៌ខៀវ ។ ខ្ញុំបានញុំាងជនឲ្យធ្វើនូវការបូជា ជាទីរីករាយប្រាកដដូចទុំះដល់ព្រះពុទ្ធមានវាទៈដ៏ប្រសើរ ហើយឲ្យទានដល់ព្រះសង្ឃ តាមសមគួរដល់កម្លាំង ដរាបដល់អស់ជីវិត ។ ខ្ញុំធ្វើបុណ្យទាំងនោះដោយសព្វគ្រប់ជាមួយនឹងសេដ្ឋីនោះ ដរាបដល់អស់ជីវិតហើយក៏បានទៅកាន់សុគតិជាមួយគ្នា ។ ខ្ញុំបានសោយសម្បត្តិទាំងឡាយក្នុងអត្តភាពជាទេវតានិងមនុស្ស អន្ទោលទៅជាមួយនឹងសេដ្ឋីនោះដូចជាស្រមោលអន្ទោលទៅតាមសរីរៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយកទ្រង់ព្រះនាមវិបស្សីមានព្រះនេត្រដូចមាស ពិចារណាឃើញច្បាស់នូវធម៌ទាំងពួងទ្រង់កើតឡើង ។ គ្រានោះមានព្រាហ្មណ៍ម្នាក់ក្នុងក្រុងពន្ធុមតីគេសន្មតិថាជាសប្បុរសជាអ្នកមាំមួន ស្ងប់ស្ងាត់ដោយគុណតែជាអ្នកខ្សត់ទ្រព្យក្រៃពេក ។ កាលនោះខ្ញុំជាព្រាហ្មណី

របស់ព្រាហ្មណ៍នោះមានចិត្តស្មើគ្នា ជួនកាលព្រាហ្មណ៍ប្រសើរ នោះបានគប់រកព្រះមហាមុនីដែលគង់សម្តែងអមតនិព្វាន ក្នុងពួកជន គាត់បានស្តាប់ធម៌ ក៏មានចិត្តរីករាយបានថ្វាយសំពត់សាដក ១ ហើយទៅកាន់ផ្ទះដោយសំពត់ ១ ហើយពោលពាក្យនេះនឹងខ្ញុំថា ម្នាលនាងមានបុណ្យធំ នាងចូររីករាយចំ-ពោះសំពត់សាដកដែលបងបានថ្វាយដល់ព្រះពុទ្ធចុះ ។ កាលនោះខ្ញុំដឹងច្បាស់បានធ្វើអញ្ជលីអនុមោទនាថា បពិត្រស្វាមី ខ្ញុំសូមអនុមោទនាសាដកដែលអ្នកថ្វាយហើយ ដោយប្រពៃដល់ព្រះពុទ្ធដ៏ប្រសើរទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ប្តីនៃខ្ញុំនោះដល់ហើយនូវសេចក្តីសុខ ត្រូវបុញ្ញកម្មចាត់ចែង កាលអន្ទោលទៅក្នុងភពតូច និងភពធំ បានកើតជាស្តេចម្ចាស់ផែនដីក្នុងក្រុងពារាណសីជាទីរីករាយ ។ កាលនោះ ខ្ញុំជាមហេសីនៃស្តេចនោះជាអ្នកខ្ពង់ខ្ពស់ជាងពួកស្រី ហើយជាអគ្គមហេសីដ៏ប្រសើរក្រៃលែង ជាងសេចក្តីស្រឡាញ់នៃស្តេចនោះ ដែលមានក្នុងភពមុន ។ ស្តេចនោះ ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គនិមន្តទៅដើម្បីបិណ្ឌបាតក៏មានចិត្តរីករាយ ប្រគេនចង្ហាន់បិណ្ឌបាតមានថ្លៃច្រើន ស្តេចនោះ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយហើយធ្វើបាំកែវជាវិការៈនៃមាស មានប្រមាណ ១០០ ហត្ថមានសណ្ឋានរលីង ដែលពួកជាងធ្វើហើយ ។ ព្រះរាជានោះ

ទ្រង់រាប់អានព្រះបច្ចេកពុទ្ធទាំងអស់នោះ មានសេចក្ដីជ្រះថ្លា ហើយបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធទាំងនោះដែលចូលទៅកាន់ទីសេនាសនៈដោយព្រះហស្ដនៃព្រះអង្គ ។ កាលនោះ ខ្ញុំបានឲ្យទាននោះ ជាមួយនឹងស្ដេចក្នុងដែនកាសី ខ្ញុំកើតក្នុងកាសិកគ្រាមជិតក្រុងពារាណសីម្ដងទៀត ។ ស្ដេចនោះកើតក្នុងត្រកូលកុដុម្ពិកៈដ៏ធំទូលាយ ដល់នូវសេចក្ដីសុខ ព្រមទាំងបងប្អូន ខ្ញុំជាប្រពន្ធនៃបងច្បង ជាស្រីមានវត្តដល់ប្ដីដោយប្រពៃ។ ប្អូនរបស់ប្ដីខ្ញុំបានឃើញព្រះបច្ចេកពុទ្ធហើយ ប្រគេនភត្តរបស់បងដល់ព្រះបច្ចេកពុទ្ធនោះ កាលបើបងនោះត្រឡប់មកខ្ញុំបាននិយាយប្រាប់សព្វគ្រប់ ។ បងនោះ មិនត្រេកអរចំពោះទានលំដាប់នោះ ខ្ញុំបានឲ្យភត្តដល់ប្ដីនោះប្ដីនោះនាំបាយនោះហើយថ្វាយដល់ព្រះពុទ្ធនោះទៀត ។ កាលនោះ ខ្ញុំចោលនូវទាននោះហើយប្រទូស្ដចំពោះព្រះពុទ្ធ ខ្ញុំបានឲ្យបាត្រដ៏ពេញដោយភក់ដល់ព្រះពុទ្ធនោះទ្រង់មិនញាប់ញ័រដោយលោកធម៌។ កាលនោះ ខ្ញុំឃើញព្រះពុទ្ធមានព្រះទ័យស្មើក្នុងការឲ្យទានផង ក្នុងការទទួលផងក្នុងសេចក្ដីកោតក្រែងផង ក្នុងសេចក្ដីប្រទូស្ដផង ហើយសង្វេគក្រៃលែង ។ ខ្ញុំកាន់យកបាត្រម្ដងទៀត ជម្រះដោយគ្រឿងក្រអូបមានចិត្តជ្រះថ្លា ញុំាងបាត្រឲ្យពេញ ហើយឲ្យស្ករព្រមទាំងទឹកដោះថ្លា ។ ខ្ញុំកើតក្នុងទីណាៗ ជាស្រីមាន

រូបល្អព្រោះទាននោះ ខ្ញុំជាស្រីមានក្លិនអាក្រក់ ព្រោះប្រទូស្ត ចំពោះព្រះពុទ្ធផងព្រោះសេចក្តីស្រវឹងផង ។ កាលចេតិយនៃ ព្រះពុទ្ធព្រះនាមកស្សបៈ ជាអ្នកប្រាជ្ញគេឲ្យសម្រេចហើយ ខ្ញុំ មានចិត្តរីករាយ បានឲ្យឥដ្ឋជាវិការៈនៃមាសដ៏ប្រសើរទៀត ។ ខ្ញុំជ្រលក់ឥដ្ឋនោះឲ្យទទឹកដោយគ្រឿងក្រអូបមានជាតិ ៤ យ៉ាង ក៏បានរួចស្រឡះចាកទោសមានក្លិនអាក្រក់ ប្រកបដោយអវ- យវៈទាំងពួងដ៏ល្អ ។ ខ្ញុំឲ្យធ្វើភាជន៍ ៧០០០ ដោយកែវ ៧ ប្រការផង ប្រទេះ ១០០០ ដ៏ពេញដោយខ្លាញ់ផង ។ ខ្ញុំ មានចិត្តជ្រះថ្លាបានចាក់ប្រេងអុជបំភ្លឺតម្កល់ទុក ៧ ជួរ ដើម្បី បូជាព្រះលោកនាថ ។ គ្រានោះខ្ញុំជាស្រីមានចំណែកក្នុងបុណ្យ នោះដោយវិសេស ( បុរសនោះ ) កើតក្នុងដែនកាសីទៀត ប្រាកដដោយឈ្មោះថាជា សមិត្តបុរស ។ កាលនោះ ខ្ញុំជា ភរិយាបុរសនោះ ជាអ្នកដល់នូវសេចក្តីសុខ មានគេជាប់ចិត្ត ជាទីស្រឡាញ់នៃជន ឯប្តីខ្ញុំបានប្រគេនឈ្នួតមានសាច់ក្រាស់ ដល់ព្រះបច្ចេកមុនី ។ មា្យ៉ាងទៀតខ្ញុំជាស្រីមានចំណែកដោយ បុណ្យត្រេកអរនូវទានដ៏ឧត្តម របស់ប្តីនោះ ឯបុរសនោះកើត ក្នុងជាតិកោលិយជនក្នុងដែនកាសីទៀត ។ កាលនោះ សមិត្ត បុរសនោះបម្រើព្រះបច្ចេកពុទ្ធ ៥០០ អង្គ មួយអន្លើដោយ កោលិយបុត្ត ៥០០ នាក់ ។ រួចហើយនិមន្តព្រះបច្ចេកពុទ្ធ

ទាំងឡាយឲ្យគង់នៅអស់ ៣ ខែហើយប្រគេនត្រៃចីវរ កាល នោះខ្ញុំជាប្រពន្ធនៃសមិត្តបុរសនោះជាអ្នកប្រព្រឹត្តទៅតាមគន្លង នៃបុញ្ញកម្ម ។ សមិត្តបុរសនោះច្យុតចាកអត្តភាពនោះ បាន កើតជាស្តេចព្រះនាមនន្ទះ មានយសធំ ខ្ញុំជាមហេសី នៃស្តេច នោះ ជាអ្នកសម្រេចនូវសេចក្តីប្រាថ្នាទាំងពួង ។ លុះច្យុតអំពី អត្តភាពនោះហើយបានកើតជាស្តេចព្រហ្មទត្ត ជាម្ចាស់ផែនដី កាលនោះ ខ្ញុំបម្រើព្រះបច្ចេកមុនីជាបុត្តនៃនាងបទុមាវតី ។ ខ្ញុំ បម្រើព្រះបច្ចេកមុនី ៥០០ អង្គ ដរាបដល់អស់ជីវិត ហើយ និមន្តព្រះបច្ចេកមុនីទាំងឡាយ ឲ្យនៅក្នុងឧទ្យាននៃស្តេចហើយ បូជានូវព្រះបច្ចេកមុនីទាំងឡាយ ដែលនិព្វានហើយ ។ យើង ទាំងពីរនាក់បានឲ្យជាងធ្វើចេតិយទាំងឡាយហើយបួសចម្រើន អប្បមញ្ញាទាំងឡាយ ក៏បានទៅកើតក្នុងព្រហ្មលោក ។ លុះ ច្យុតចាកព្រហ្មលោក ប្តីកើតក្នុងមហាតិត្ថ ជាកូនចៅនៃបិប្ផល គោត្ត ឯមាតាឈ្មោះ សុមនទេវី បិតាជាព្រាហ្មណ៍កោសិ គោត្ត ។ ខ្ញុំ ( កើត ) ក្នុងក្រុងសាកលា ជាបុរីដ៏ឧត្តម ក្នុង ជនបទឈ្មោះមទ្ទ ។ ខ្ញុំជាធីតានៃកបិលព្រាហ្មណ៍ មាតាឈ្មោះ សុចិមតី បិតាស្អិតស្អាងខ្ញុំដោយរូបកាពជាវិការៈនៃមាសតាន់ បានឲ្យខ្ញុំ ដល់កស្សបបណ្ឌិត ជាអ្នកវៀរចាកកាមទាំងឡាយ កាលដែលកស្សបបណ្ឌិតនោះនៅក្មេង បានទៅមើលការងារ

ឃើញសត្វតូច ៗ ត្រូវពួកសត្វ មានក្អែកជាដើមទំពាស៊ី ក៏សង្វេគ ។ ខ្ញុំឃើញគ្រាប់ល្ងទាំងឡាយដែលគេហាលក្នុងកម្ដៅថ្ងៃជិតផ្ទះ ត្រូវពួកជន្លេននិងក្អែកទំពាស៊ី បានទូវសេចក្ដីសង្វេគក្នុងកាលនោះ ។ កាលនោះ កស្សបបណ្ឌិតនោះបួសហើយ ខ្ញុំក៏បួសតាមកស្សបណ្ឌិតនោះដែរ ខ្ញុំនៅអាស្រ័យក្នុងគន្លងនៃបរិព្វាជកវត្តអស់ ៥ វស្សា ។ កាលណា នាងគោតមី ជាអ្នកចិញ្ចឹមព្រះជិនស្រីបួសហើយ កាលនោះ ខ្ញុំក៏ចូលទៅរកនាងគោតមីនោះដែលព្រះពុទ្ធប្រៀនប្រដៅហើយ ។ អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានដល់ព្រះអរហត្ត ឱហ្ន៎! ព្រះកស្សបមានសិរីជាមិត្តល្អ ។ ព្រះកស្សបជាកូន ជាញាតិនៃព្រះពុទ្ធ មានចិត្តតម្កល់ខ្ជាប់ហើយដោយប្រពៃ លោកដឹងនូវបុព្វេនិវាសផង ឃើញនូវឋានសួគ៌និងអបាយផង ។ មួយវិញទៀត ព្រះកស្សបនោះជាអ្នកប្រាជ្ញមានអភិញ្ញានៅរួចហើយ បានដល់នូវការអស់ទៅនៃជាតិ ជាខីណាសវព្រាហ្មណ៍ មានវិជ្ជា ៣ ដោយវិជ្ជាទាំង ៣ នេះ ។ ភទ្ទកាបិលានីមានវិជ្ជា ៣ លះបង់មច្ចុ ទ្រទ្រង់រាងកាយមានក្នុងទីបំផុត ឈ្នះមារព្រមទាំងវាហនៈដូចគ្នាដែរ ។ យើងទាំងពីរនាក់ឃើញទោសក្នុងលោក ហើយបួស យើងទាំងពីរនាក់នោះ មានអាសវៈអស់ហើយ មានខ្លួនទូន្មានហើយ មានសេចក្ដីត្រជាក់កើតហើយមានទុក្ខរំលត់ហើយ ។

កិលេសទាំងឡាយខ្ញុំផ្ចិតបំផ្លាញហើយ ។បេ។ ទាំងសាសនា
របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ព្រះថេរីភទ្ទកាបិលានី បានជាអ្នកមានការជំនាញក្នុងបុព្វេនិវាសញ្ញាណ ព្រោះបានសាងសន្សំបុណ្យបារមីយ៉ាងល្អ ក្នុងភពនោះៗ ។ ក្នុងកាលតមក ព្រះសាស្តាគង់កណ្តាលអរិយសង្ឃក្នុងវត្តជេតពនទ្រង់តាំងពួកភិក្ខុនីក្នុងតំណែងទាំងឡាយតាមលំដាប់ ទ្រង់បានស្ថាបនាព្រះថេរីនោះទុកក្នុងតំណែងឯតទគ្គៈ លើសភិក្ខុនីទាំងឡាយ ខាងរឭកជាតិបាន ។ ថ្ងៃមួយ ព្រះថេរីនោះកាលបន្លឺឧទានដែលផ្តើមដោយការសរសើរនូវ គុណរបស់ព្រះមហាកស្សបត្ថេរ ដោយបំណងប្រកាសកិច្ចដែលព្រះថេរៈធ្វើស្រេចហើយជាដើម ទើបពោលគាថាទាំងនេះថា

ព្រះថេរៈឈ្មោះកស្សប ជាបុត្តពុទ្ធទាយាទ មានចិត្តតម្កល់មាំល្អ លោកបានដឹងនូវបុព្វេនិវាសទាំងឃើញឋានសួគ៌និងអបាយលំដាប់អំពីនោះមក លោកបានដល់នូវធម៌ជាទីអស់ទៅនៃជាតិបានសម្រេចនូវអភិញ្ញាជាអ្នកប្រាជ្ញជាព្រាហ្មណ៍ បានសម្រេចវិជ្ជា ៣ ដោយវិជ្ជា ៣ នេះ ។ ព្រះថេរីឈ្មោះភទ្ទកាបិលានីក៏យ៉ាងនោះដែរ បានសម្រេចវិជ្ជា ៣ ញ៉ាំងមច្ចុឲ្យសាបសូន្យឈ្នះមារព្រមទាំងវាហនៈ ហើយទ្រទ្រង់រាងកាយជាទីបំផុត ។ យើងទាំងពីររូប បានឃើញទោសក្នុងលោក ហើយមកបួសយើងទាំងនោះ ជាព្រះខីណាស្រពបានទូន្មានខ្លួនហើយ ជាអ្នក

មានចិត្តត្រជាក់ បាននិព្វានហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុត្តោ ពុទ្ធស្ស ទាយាទោ** សេចក្ដីថា ព្រះកស្សបត្ថេរ ជាអនុជាតបុត្តរបស់ព្រះសម្មាសម្ពុទ្ធ ព្រោះជាអ្នកបានត្រាស់ដឹងតាមព្រះពុទ្ធ ឈ្មោះថា **ទាយាទោ** ព្រោះកាន់យកលោកុត្តរធម៌ ៩ ដែលជាសម្បត្តិរបស់ព្រះថេរៈនោះអំពីព្រះពុទ្ធនោះឯង ឈ្មោះថា **សុសមាហិតោ** ព្រោះជាអ្នកមានចិត្តតាំងមាំដោយល្អ ដោយសមាធិដែលជាលោកិយនិងលោកុត្តរ ។ បទថា **បុព្វេនិវាសំ សោ វេទិ** សេចក្ដីថា ព្រះមហាកស្សបត្ថេរនោះបានដឹងហើយ គឺដឹងទូទៅហើយ បានដល់ ចាក់ធ្លុះហើយនូវបុព្វេនិវាស គឺនូវខន្ធសន្តានដែលធ្លាប់នៅអាស្រ័យទាំងរបស់ខ្លួននិងរបស់អ្នកដទៃ ដោយធ្វើឲ្យប្រាកដ ដោយបុព្វេនិវាសានុស្សតិញ្ញាណ ។ បទថា **សគ្គាបាយញ្ច បស្សតិ** សេចក្ដីថា ឃើញស្ថានសួគ៌ដែលជាទេវលោក ២៦ ភូមិ និងអបាយភូមិ ៤ ដោយទិព្វចក្ខុ ដូចឃើញផ្លែកន្ទួតព្រៃក្នុងបាតដៃ ។

បទថា **អថោ ជាតិក្ខយំ បត្តោ** សេចក្ដីថា បន្ទាប់អំពីនោះ លោកសម្រេចអរហត្ត ពោលគឺការអស់ជាតិបានសម្រេចនូវអភិញ្ញា គឺដល់ហើយនូវការសម្រេច គឺជាអ្នកសម្រេចកិច្ចហើយ ព្រោះដឹងក្រៃលែង គឺព្រោះដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង ព្រោះកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ព្រោះលះនូវធម៌ដែលគួរលះ ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយញាណដែលគួរប្រាថ្នាក្រៃលែង គឺប្រសើរក្រៃលែង ឈ្មោះថា **មុនិ** ព្រោះសម្រេចមោនធម៌ពោល គឺបញ្ញាជាគ្រឿងធ្វើអាសវៈឲ្យ

អស់ទៅ ។

បទថា **តាថេវ ភទ្ទកាបិលានី** សេចក្តីថា ព្រះមហាកស្សបៈជាអ្នកបាន វិជ្ជា ៣ ដោយវិជ្ជា ៣ នេះ គឺតាមដែលពោលហើយ និងជាអ្នកលះមច្ចុរាជ បាន យ៉ាងណា ព្រះថេរីភទ្ទកាបិលានី ក៏បានវិជ្ជា ៣ និងលះមច្ចុបាន យ៉ាង នោះ ដូចគ្នា បន្ទាប់អំពីនោះ ព្រះថេរីសម្តែងខ្លួននោះឯងធ្វើឲ្យដូចជាអ្នកដទៃ ដោយបទថា **ធារេតិ អន្តិមំ ទេហំ ជេត្វា មារំ សវាហនំ** ឈ្នះមារព្រម ទាំងវាហនៈ ហើយទ្រទ្រង់រាងកាយជាទីបំផុត ដូច្នេះ ។

ឥឡូវនេះ ព្រះថេរីភទ្ទកាបិលានី កាលសម្តែងថា លម្អខាងដើម លម្អ កណ្តាល លម្អខាងចុងនៃការបដិបត្តិរបស់ព្រះថេរៈ យ៉ាងណា ឯរបស់ខ្ញុំក៏ យ៉ាងនោះ ទើបពោលគាថាចុងក្រោយថា **ទិស្វា អាទីនវំ** ជាដើម ។ បណ្តា បទទាំងនោះ បទថា **តេ្យម្ហ ខីណាសវា ទន្តា** សេចក្តីថា យើងទាំងឡាយ គឺព្រះមហាកស្សបត្ថេរនិងខ្ញុំ ជាអ្នកមានខ្លួនអប់រំហើយ ដោយការអប់រំដ៏ឧត្តម និងជាអ្នកមានអាសវៈអស់ហើយដោយប្រការទាំងពួង ។ បទថា **សីតិភូ- តាម្ហ និព្វុតា** សេចក្តីថា ជាអ្នកមានសេចក្តីត្រជាក់ ព្រោះមិនមាននូវកម្តៅ គឺកិលេសនោះឯង និងជាអ្នករលត់ដោយឥតសេសសល់ដោយសឧបាទិសេស និព្វានធាតុ ។

អដ្ឋកថាភទ្ទកាបិលានីថេរីគាថា ចប់

ថេរីគាថា ចតុក្កនិបាត ចប់

# ថេរីគាថា បញ្ចកនិបាត

## អញ្ញតរាភិក្ខុនីអប្បញ្ញាតាថេរីគាថា

[ ៣០៣ ] តាំងពីកាលអាត្មាអញបួសមកបាន ២៥ វស្សាហើយ មិនបានសេចក្ដីស្ងប់ចិត្តសូម្បីត្រឹមមួយផ្ទាត់ម្រាមដៃ ។ អាត្មាអញមានចិត្តទទឹកដោយកាមរាគមិនបានសេចក្ដីស្ងប់ចិត្ត ផ្គងដើមដៃកន្ទក់កន្ទេញ ហើយចូលទៅកាន់លំនៅ ។ អាត្មាអញនោះចូលទៅរកភិក្ខុនី ( ធម្មទិន្នាថេរី ) ជាស្ត្រីដែលអាត្មាអញគួរជឿ លោកបានសំដែងធម៌គឺ ខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ ។ លុះអាត្មាអញបានស្ដាប់ធម៌របស់លោកហើយ បានចូលទៅក្នុងទីសមគួរ ដឹងនូវបុព្វេនិវាសបានជម្រះទិព្វចក្ខុ ។ ចេតោបរិយញ្ញាណនិងសោតធាតុអាត្មាអញបានជម្រះហើយ ឫទ្ធិអាត្មាអញបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ទៅនៃអាសវៈអាត្មាអញបានសម្រេចហើយ អភិញ្ញា ៦ អាត្មាអញបានធ្វើឲ្យច្បាស់ហើយ ព្រះពុទ្ធសាសនាអាត្មាអញក៏បានធ្វើហើយ ។

**ភិក្ខុនីមួយរូប មាននាមនិងគោត្រមិនប្រាកដ ។**

# អដ្ឋកថា

# ថេរគាថា បញ្ចកនិបាត

## អញ្ញតរាថេរីគាថា

ក្នុងបញ្ចកនិបាតមានវិនិច្ឆ័យដូចតទៅនេះថា

[ ៣០៣ ] គាថារបស់ព្រះថេរីមួយអង្គ មានពាក្យផ្តើមថា **បណ្ណវីសតិ វស្សានិ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងពុទ្ធុប្បាទនេះបានជាមេដោះរបស់ព្រះនាងមហាបជាបតិគោតមី ក្នុងនគរទេវ-ទហៈតែមិនប្រាកដឈ្មោះនិងគោត្ត ព្រះថេរីនោះ ក្នុងកាលព្រះនាងមហាបជាបតិគោតមីបួស ខ្លួនឯងក៏បួស ត្រូវកាមរាគៈបៀតបៀនអស់ ២៥ ឆ្នាំ មិនបានឯកគ្គតាចិត្ត សូម្បីត្រឹមមួយផ្ទាត់ម្រាមដៃ ផ្គងដើមដៃកន្ទក់កន្ទេញ បានស្តាប់ធម៌ក្នុងសម្នាក់ របស់ព្រះនាងធម្មទិន្នាថេរី មានចិត្តប្រាសចាកកាមទាំងឡាយរៀននូវកម្មដ្ឋានប្រកបការនារឿយៗមិនយូរប៉ុន្មាន ក៏ជាអ្នកបានអភិញ្ញា ៦ ពិចារណាការបដិបត្តិរបស់ខ្លួន បានពោលនូវគាថាទាំងនេះជាពាក្យឧទានថា

តាំងពីកាលអាត្មាអញបួសមកបាន ២៥ វស្សាហើយ មិនបាន
សេចក្តីស្ងប់ចិត្តសូម្បីត្រឹមមួយផ្ទាត់ម្រាមដៃ ។ អាត្មាអញមាន
ចិត្តទទឹកដោយកាមរាគ មិនបានសេចក្តីស្ងប់ចិត្ត ផ្គងដើមដៃ

កន្ទក់កន្ទេញ ហើយចូលទៅកាន់លំនៅ ។ អាត្មាអញនោះចូលទៅរកភិក្ខុនី ( ធម្មទិន្នាថេរី ) ជាស្ត្រីដែលអាត្មាអញគួរជឿ លោកបានសំដែងធម៌គឺខន្ធ អាយតនៈ ធាតុដល់អាត្មាអញ។ លុះអាត្មាអញបានស្តាប់ធម៌របស់លោកហើយ បានចូលទៅក្នុងទីសមគួរដើងនូវបុព្វេនិវាស បានជម្រះទិព្វចក្ខុ ។ ចេតោបរិយញ្ញាណនិងសោតធាតុអាត្មាអញបានជម្រះហើយ ឫទ្ធិអាត្មាអញបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ទៅនៃអាសវៈ អាត្មាអញបានសម្រេចហើយ អភិញ្ញា ៦ អាត្មាអញបានធ្វើឲ្យច្បាស់ហើយ ព្រះពុទ្ធសាសនាអាត្មាអញក៏បានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាច្ឆរាសង្ឃាតមត្តម្បិ** បានដល់ មួយជួរខណៈ ត្រឹមតែមួយផ្ទាត់ម្រាមដៃ អធិប្បាយថា មួយជួរខណៈត្រឹមតែផ្ទាត់ម្រាមដៃ ។ បទថា **ចិត្តស្សុបសមជ្ឈគំ** ប្រកបសេចក្តីថា មិនសម្រេចនូវការស្ងប់ចិត្ត គឺឯកគ្គតាចិត្ត អធិប្បាយថា មិនទាន់បាន ។

បទថា **កាមរាគេន អដ្ដិតា** សេចក្តីថា មានចិត្តទទឹកដោយឆន្ទរាគៈដ៏ខ្លាំង ព្រោះកាន់យកយ៉ាងមាំក្នុងវត្ថុកាមទាំងឡាយ ពោលគឺកាមគុណទាំងឡាយ ។

ដោយបទថា **ភិក្ខុនឹ** លោកពោលសំដៅយកព្រះនាងធម្មទិន្នាថេរី ។

បទថា **ចេតោបរិច្ចញាណាញ្ច** ក្នុងបទសេចក្តីថា ចេតោបរិយញ្ញាណ ខ្ញុំក៏ជម្រះឲ្យបរិសុទ្ធិហើយ អធិប្បាយថា សម្រេចហើយ ។ ពាក្យដ៏សេស

មានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថាអញ្ញតរាថេរីគាថា ចប់

# វិមលាបុរាណគណិកាថេរីគាថា

[ ៣០៤ ] អាត្មាអញស្រវឹង រឹងត្អឹង ដោយការសរសើរគុណផងដោយរូបសម្បត្តិផង ដោយលំអដ៏លើសផង ដោយយសផង ដោយវ័យផង បានមើលងាយពួកស្រីដទៃ ។ អាត្មាអញស្អិតស្អាងរាងកាយនេះ ឲ្យវិចិត្រល្អ ឲ្យជាទីរាក់ទាក់នៃជនពាល ហើយឈរក្បែរទ្វារផ្ទះនៃស្រីពេស្យា ដូចជាព្រានម្រឹគដាក់អន្ទាក់ ។ អាត្មាអញសំដែងគ្រឿងប្រដាប់ និងអវយវៈដ៏កំបាំង ឲ្យជាក់ច្បាស់ជាច្រើន សើចក្អាកក្អាយ បានធ្វើមាយាច្រើនយ៉ាង ( ដើម្បី ) ញុំាងជនពាលជាច្រើន ( ឲ្យស្រើបស្រាល ) ។ ក្នុងថ្ងៃនេះ អាត្មាអញនោះបានកោរសក់ដណ្តប់សង្ឃាដីដើរទៅបិណ្ឌបាតរួចអង្គុយក្រោមម្លប់ឈើ ជាអ្នកបាននូវធម៌ដែលមិនមានវិតក្កៈ ។ គ្រឿងប្រកបទាំងពួងទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបានផ្តាច់ផ្តិលហើយ អាត្មាអញបានញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកមានចិត្តត្រជាក់រំលត់ទុក្ខហើយ ។

**វិមលាថេរី ជាស្រីពេស្យាពីដើម ។**

## អដ្ឋកថា

## វិមលាថេរីគាថា

[ ៣០៤ ] គាថារបស់ព្រះវិមលាថេរី មានពាក្យផ្តើមថា **មត្តា វណ្ណេន រូបេន** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធ

អន្តមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងពុទ្ធុប្បាទនេះ កើតជាកូនស្រីរបស់ស្ត្រីដែលអាស្រ័យរូបចិញ្ចឹមជីវិតម្នាក់ ក្នុងនគរវេសាលី មានឈ្មោះថាវិមលា ។ នាងវិមលានោះ កាលចម្រើនវ័យហើយ ក៏ចិញ្ចឹមជីវិតដូចមាតា ។ ថ្ងៃមួយ នាងឃើញព្រះមហាមោគ្គល្លានត្រាច់បិណ្ឌបាត ក្នុងក្រុងវេសាលីមានចិត្តប្រតិព័ទ្ធ ទើបទៅកាន់លំនៅរបស់ព្រះថេរៈធ្វើនូវការលួងលោមព្រះថេរៈ ។ អាចារ្យពួកខ្លះពោលថា ត្រូវតិត្ថិយបញ្ជូនទៅទើបធ្វើយ៉ាងនោះ ។ ព្រះថេរៈឲ្យនាងឃើញអសុភ គំរាមហើយបានឲ្យឱវាទដល់នាង រឿងនោះមានមកហើយ ក្នុងថេរគាថានោះឯង ។ កាលព្រះថេរៈឲ្យឱវាទយ៉ាងនោះហើយ នាងកើតនូវសេចក្តីសង្វេគកើតនូវហិរិឱត្តប្បៈបាននូវសទ្ធាក្នុងព្រះសាសនា ជាឧបាសិកា ។ ក្នុងកាលតមក បានបួសក្នុងសម្នាក់ពួកភិក្ខុនី ព្យាយាមមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ព្រោះជាអ្នកសម្បូរដោយហេតុ ពិចារណាការបដិបត្តិរបស់ខ្លួនបានពោលគាថាទាំងនេះជាឧទានថា

> អាត្មាអញស្រវឹងវង្វេងដោយការសរសើរគុណផង ដោយរូបសម្បត្តិផង ដោយលំអដ៏លើសផង ដោយយសផង ដោយវ័យផង បានមើលងាយពួកស្រីដទៃ ។ អាត្មាអញស្អិតស្អាងរាងកាយនេះឲ្យវិចិត្រល្អ ឲ្យជាទីរាក់ទាក់នៃជនពាល ហើយឈរក្បែរទ្វារផ្ទះនៃស្រីពេស្យា ដូចជាព្រានម្រឹគដាក់អន្ទាក់ ។ អាត្មាអញ សំដែងគ្រឿងប្រដាប់និងអវយវៈដ៏កំបាំង ឲ្យជាក់

ច្បាស់ជាច្រើន សើចក្អាកក្អាយ បានធ្វើមាយាច្រើនយ៉ាង ( ដើម្បី ) ញុំាងជនពាលជាច្រើន ( ឲ្យស្រើបស្រាល ) ។ ក្នុងថ្ងៃនេះ អាត្មាអញនោះបានកោរសក់ដណ្តប់សង្ឃាដីដើរទៅបិណ្ឌបាតរួចអង្គុយក្រោមម្លប់ឈើ ជាអ្នកបានទូវធម៌ដែលមិនមានវិតក្កៈ ។ គ្រឿងប្រកបទាំងពួង ទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបានផ្តាច់ផ្តិលហើយ អាត្មាអញបានញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកមានចិត្តត្រជាក់រំលត់ទុក្ខហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មត្តា វណ្ណេន រូបេន** បានដល់ ដោយវណ្ណៈ គឺគុណានិងដោយរូបសម្បត្តិ ។ បទថា **សោភគ្គេន** បានដល់ ដោយលម្អដ៏លើស ។ បទថា **យសេន** បានដល់ ដោយបរិវារសម្បត្តិ សេចក្តីថា ជាអ្នកស្រវឹង គឺដល់នូវការស្រវឹង បានដល់ស្រវឹងវណ្ណៈ ស្រវឹងរូប ស្រវឹងលម្អ ស្រវឹងបរិវារ ។ បទថា **យោព្វនេន ចុបត្ថទ្ធា** សេចក្តីថា រឹងត្អឹងក្រៃលែងដោយការស្រវឹងក្នុងភាពជាក្រមុំ គឺមានចិត្តរឹងត្អឹង បានដល់ មានចិត្តមិនស្ងប់ម្ញាប់ដោយអហង្ការមានភាពនៅក្មេងជាហេតុ ។ បទថា **អញ្ញាសមតិមញ្ញិហំ** សេចក្តីថា ខ្ញុំសម្គាល់ថាខ្លួនក្រៃលែងជាងស្រីដទៃៗ ដោយគុណមានពណ៌សម្បុរជាដើម ដោយប្រការទាំងពួង ។ ម្យ៉ាងទៀត ខ្ញុំមើលងាយ គឺយល់ថាក្រៃលែងជាង បានដល់ បានធ្វើនូវការមើលងាយនូវគុណដូចជាពណ៌សម្បុរជាដើមរបស់ស្រីដទៃ ។

បទថា **វិភូសិត្វា ឥមំ កាយំ សុចិត្តំ ពាលលាបនំ** សេចក្តីថា ខ្ញុំបាន ប្រដាប់គឺតាក់តែងឲ្យស្អាត គួរជ្រះថ្លានូវកាយរបស់ខ្ញុំនេះដែលពេញទៅដោយ របស់មិនស្អាតច្រើនយ៉ាង គួរខ្ពើម ឲ្យវិចិត្រល្អដោយការប្រោះព្រំស្បែក និង តាក់តែងសក់ជាដើម ដោយពស្ត្រាភរណៈទាំងឡាយ សម្រាប់បោកបញ្ឆោត បុរសល្ងង់ខ្លៅ ដោយបោកបញ្ឆោត គឺនិយាយនឹងពួកបុរសល្ងង់ថា ខ្ញុំ របស់ ខ្ញុំ ។ បទថា **អដ្ឋាសឹ វេសិទ្វារម្ហិ លុទ្ទោ បាសមិវោឌ្ឌិយ** សេចក្តីថា ខ្ញុំបាន យកកាយរបស់ខ្ញុំតាម ដែលពោលហើយដែលជាអន្ទាក់មារ បញ្ឆោតជានុយ ត្រង់ទ្វារផ្ទះរបស់ស្រីពេស្យាដូចព្រានម្រឹគដាក់អន្ទាក់ម្រឹគ មានសំណាញ់ដែល ចងដោយកំណាត់ឈើជាដើម ដើម្បីចាប់នូវម្រឹគទាំងឡាយ ។ បទថា **បិ-លន្ធនំ វិទស្សេន្តី គុយ្ហំ បកាសិកំ ពហុំ** សេចក្តីថា ប្រកាសអវយវៈដែល គួរបិទមានភ្លៅ ត្រគាកនិងដោះជាដើម និងអវយវៈដែលប្រាកដដូចជាជើង ក្បាលជង្គង់ និងក្បាលជាដើម គឺសម្តែងអវយវៈដែលគួរបិទបាំងឲ្យប្រាកដ និងគ្រឿងប្រដាប់ គឺអាភរណៈ មានប្រការផ្សេងៗជាច្រើន ។ បទថា **អកាសឹ វិវិធំ មាយំ ឧជ្ជគ្ឃន្តី ពហុំ ជនំ** សេចក្តីថា ខ្ញុំសើចដើម្បីលួងលោម បុរសល្ងង់ជាច្រើន ដែលស្រវឹងក្នុងវ័យក្មេងបានធ្វើនូវមាយាមានបែបផ្សេងៗ គឺមានប្រការផ្សេងៗដោយការប្រើគ្រឿងក្រអូបនិងពស្ត្រាភរណៈជាដើម បិទ បាំងសភាវៈពិតរបស់រាងកាយ និងដោយអាកប្បកិរិយានោះៗមានសើច និង កែក្រាយជាដើម ។

បទថា **សាជ្ជ បិណ្ឌំ ចរិត្វាន មុណ្ឌា សង្ឃាដិបារុតា និសិន្នា រុក្ខ-**

**ម្ហូលម្ហិ អរិតក្កស្ស លាភិនិ** ប្រកបសេចក្ដីថា ខ្ញុំនោះជាអ្នកនៅដោយសេចក្ដីប្រមាទយ៉ាងនេះ ថ្ងៃនេះ គឺឥឡូវនេះ បានតាំងនៅក្នុងឱវាទរបស់ព្រះមហាមោគ្គល្លានត្ថេរ បួសក្នុងសាសនា មានក្បាលត្រងោល ដណ្ដប់សង្ឃាដីត្រាច់បិណ្ឌបាត អង្គុយធាន់កិច្ចាហារ គឺអង្គុយត្រង់គល់ឈើ គឺលើអាសនៈដែលស្ងាត់ត្រង់គល់ឈើ ជាអ្នកបានឈាន ដែលមិនមានវិតក្កដោយការសម្រេចអរហត្តផលដែលមានទុតិយជ្ឈានជាបាទ ។

បទថា **សព្វេ យោគា** បានដល់ គ្រឿងជាប់ជំពាក់ទាំង ៤ មានគ្រឿងជាប់ជំពាក់ គឺកាមជាដើម ។ បទថា **សមុច្ឆិន្នា** សេចក្ដីថា កាត់ គឺលះដោយប្រពៃនោះឯង តាមសមគួរ ដោយបឋមមគ្គជាដើម ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា វិមលាថេរីគាថា ចប់

## សីហាថេរីគាថា

[ ៣០៥ ] កាលពីដើម អាត្មាអញត្រូវកាមរាគបៀតបៀន ជាអ្នកមានចិត្តរវើរវាយ មិនលុះក្នុងអំណាចការនាចិត្ត ព្រោះធ្វើទុកក្នុងចិត្តមិនជាឧបាយនៃប្រាជ្ញា ។ អាត្មាអញលុះត្រូវកិលេសទាំងឡាយរួបរឹតហើយជាអ្នកប្រព្រឹត្តតាមសេចក្ដីសំគាល់ក្នុងកាមថាជាសុខ ជាអ្នកលុះក្នុងអំណាចនៃចិត្តដែលប្រកបដោយរាគៈ ក៏មិនបាននូវសេចក្ដីស្ងប់ចិត្តឡើយ ។ អាត្មាអញទៅជាស្គមស្លេកស្លាំងស្អាប់សម្បុរប្រព្រឹត្តមកអស់ ៧ ឆ្នាំហើយ អាត្មាអញដល់នូវសេចក្ដីទុក្ខក្រៃពេក មិនបានសេចក្ដីសុខទាំងថ្ងៃទាំងយប់ ។ ព្រោះមិនមានសេចក្ដីសុខនោះ អាត្មាអញ ក៏បានកាន់ខ្សែចូលទៅក្នុងចន្លោះព្រៃ ( ដោយគិតថា ) អាត្មាអញចងកក្នុងទីនេះប្រសើរ ត្រង់វិលទៅកាន់ភេទថោកទាបវិញមិនប្រសើរឡើយ ។ អាត្មាអញបានធ្វើអន្ទាក់យ៉ាងមាំចងនឹងមែកឈើ ដាក់អន្ទាក់ត្រង់កក៏ស្រាប់តែចិត្តរបស់អាត្មាអញរួចស្រឡះ ។

សីហាថេរី ។

## អដ្ឋកថា
## សីហាថេរីគាថា

[ ៣០៥ ] គាថារបស់ព្រះនាងសីហាថេរី មានពាក្យផ្ដើមថា **អយោ-និសោមនសិការា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធ

អន្តមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុង ពុទ្ធុប្បាទនេះ កើតជាកូនស្រី របស់ប្អូនស្រីនៃសីហសេនាបតី ក្នុងនគរវេសាលី ញាតិមិត្តបងប្អូនទាំងឡាយ ដាក់ឈ្មោះឲ្យតាមឈ្មោះឪពុកធំថា សីហា ។ ទារិកាឈ្មោះសីហានោះដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ស្តាប់ធម៌ដែល ព្រះសាស្តាទ្រង់សម្តែងដល់សីហសេនាបតី បាននូវសទ្ធាសូមមាតាបិតាបួស កាលបួសហើយ ផ្តើមវិបស្សនា ក៏មិនអាចធ្វើចិត្តដែលស្ទុះទៅក្នុងអារម្មណ៍ ដ៏ធំខាងក្រៅឲ្យត្រឡប់បាន ត្រូវមិច្ឆាវិតក្កបៀតបៀនអស់ ៧ ឆ្នាំ មិនបាននូវ ការស្ងប់ចិត្តទើបគិតថា ប្រយោជន៍អ្វីដោយជីវិតដ៏លាមករបស់អញនេះ អញ នឹងចងកឲ្យស្លាប់ដូច្នេះ កាន់យករនុកពាក់ត្រង់មែកឈើ រួចទាក់ត្រង់ករបស់ ខ្លួន បង្អោនចិត្តទៅក្នុងវិបស្សនាតាមដែលធ្លាប់អប់រំមក ព្រោះជាសត្វដែល កើតក្នុងភពចុងក្រោយ អន្ទាក់នៅចងត្រង់កនៅឡើយ ព្រះថេរីនោះចម្រើន វិបស្សនាបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយក្នុងខណៈ នោះឯង ។ ព្រោះញាណចាស់ក្លាហើយ អន្ទាក់ដែលចងត្រង់ក ក៏របូតដំ- ណាលគ្នានឹងពេលបានសម្រេចអរហត្តនោះឯង ព្រះថេរី តាំងនៅក្នុងអរហត្ត ហើយបានពោលគាថាទាំងនេះជាពាក្យឧទានថា

កាលពីដើម អាត្មាអញត្រូវកាមរាគបៀតបៀនជាអ្នកមានចិត្ត
រវើរវាយមិនលុះក្នុងអំណាចការនាចិត្ត ព្រោះធ្វើទុកក្នុងចិត្តមិន
ជាឧបាយនៃប្រាជ្ញា ។ អាត្មាអញ លុះត្រូវកិលេសទាំងឡាយ
រួបរឹតហើយ ជាអ្នកប្រព្រឹត្តតាមសេចក្តីសំគាល់ក្នុងកាមថាជា

សុខ ជាអ្នកលុះក្នុងអំណាចនៃចិត្តដែលប្រកបដោយរាគៈ ក៏មិនបាននូវសេចក្តីស្ងប់ចិត្តឡើយ ។ អាត្មាអញទៅជាស្តួមស្ងួកស្ងាំងស្អាប់សម្បុរប្រព្រឹត្តមកអស់ ៧ ឆ្នាំហើយ អាត្មាអញដល់នូវសេចក្តីទុក្ខក្រៃពេក មិនបានសេចក្តីសុខ ទាំងថ្ងៃទាំងយប់ ។ ព្រោះមិនមានសេចក្តីសុខនោះ អាត្មាអញ ក៏បានកាន់ខ្សែចូលទៅក្នុងចន្លោះព្រៃ ( ដោយគិតថា ) អាត្មាអញចងកក្នុងទីនេះប្រសើរ ត្រឡប់វិលទៅកាន់ភេទថោកទាបវិញមិនប្រសើរឡើយ ។ អាត្មាអញបានធ្វើអន្ទាក់យ៉ាងមាំចងនឹងមែកឈើដាក់អន្ទាក់ត្រង់ក ក៏ស្រាប់តែចិត្តរបស់អាត្មាអញរួចស្រឡះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយោនិសោមនសិការា** បានដល់ ព្រោះមិនធ្វើទុកក្នុងចិត្តដោយឧបាយ គឺព្រោះកាន់យកឃ្លៀងឃ្លាតក្នុងវត្ថុមិនស្អាតថាស្អាត ។ បទថា **កាមរាគេន អដ្ដិតា** សេចក្តីថា ត្រូវធ្វើនូវរាគៈក្នុងកាមគុណទាំងឡាយគ្របសង្កត់ ។ បទថា **អហោសឹ ឧទ្ធតោ បុព្វេ ចិត្តេ អវសវត្តិនី** សេចក្តីថា កាលមុនចិត្តរបស់ខ្ញុំមិនប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្ញុំ ខ្ញុំមានចិត្តរាយមាយ គឺមានចិត្តរាយទៅក្នុងអារម្មណ៍ផ្សេងៗ គឺមានចិត្តមិនតាំងមាំ ។ បទថា **បរិយុដ្ឋិតា កិលេសេហិ សុខសញ្ញានុវត្តិនី** សេចក្តីថា ដែលកិលេសទាំងឡាយមានកាមរាគៈជាដើមដែលដល់នូវការចោមរោមគ្របសង្កត់ហើយ មានប្រក្រតីប្រព្រឹត្តទៅតាមកាមសញ្ញាដែលប្រព្រឹត្តទៅក្នុងរូបជាដើម

ជាស្អាត ។ បទថា **សមំ ចិត្តស្ស ឆាលភឹ រាគចិត្តវសានុគា** សេចក្ដីថា ទៅតាមអំណាចរបស់ចិត្តដែលសម្បយុត្តដោយកាមរាគៈ ទើបមិនបាននូវការស្ងប់នៃចិត្ត គឺការស្ងប់ចិត្ត គឺភាពដែលចិត្តមានអារម្មណ៍មួយសូម្បីតែបន្តិចបន្តួច ។ បទថា **កិសា បណ្ឌុ វិវណ្ណា ច** សេចក្ដីថាជាអ្នកស្គម គឺមានខ្លួនដល់ព្រមដោយសរសៃ មានខ្លួនពណ៌លឿង ព្រោះជាអ្នកអផ្សុកយ៉ាងនេះ ព្រោះហេតុនោះទើបជាអ្នកមិនស្រស់ស្រាយ គឺជាអ្នកប្រាសចាកពណ៌សម្បុរ ។ បទថា **សត្ត វស្សានិ** ប្រែថា អស់ ៧ ឆ្នាំ ។ បទថា **ចារិហំ** កាត់បទជា **ចារឹ អហំ** ប្រែថា ខ្ញុំប្រព្រឹត្តមក ។ បទថា **ឆាហំ ទិវា វា រត្តឹ វា សុខំ វិន្ទឹ សុទុក្ខិតា** សេចក្ដីថា ខ្ញុំដល់នូវសេចក្ដីទុក្ខដោយកិលេសក្នុង ៧ ឆ្នាំយ៉ាងនេះមិនបាននូវសេចក្ដីសុខរបស់សមណៈសូម្បីត្រឹមតែម្ដង ទាំងពេលថ្ងៃទាំងពេលយប់ ។ បទថា **គតោ** បានដល់ ព្រោះមិនបាននូវសេចក្ដីសុខរបស់សមណៈ ព្រោះការចោមរោមរបស់កិលេស ។ បទថា **រជ្ជុំ គហេត្វាន ចាវិសឹ វនមន្តរំ** សេចក្ដីថា កាន់ខ្សែចូលទៅកាន់ដងព្រៃ ។ បើមានពាក្យសួរថា ចូលទៅធ្វើអ្វី ទើបព្រះថេរីពោលថា **វរម្មេ ឥធ ឧព្វន្ធំ យញ្ច ហីនំ បុនាចរេ** សេចក្ដីថា ព្រោះខ្ញុំមិនអាចបំពេញសមណធម៌ គប្បីត្រឡប់មកប្រព្រឹត្ត គឺគប្បីប្រព្រឹត្តដោយអើពើ គឺគប្បីតាំងនៅក្នុងហីនភេទ គឺភាពជាគ្រហស្ថទៀតដូច្នោះ អាត្មាអញចងកឲ្យស្លាប់ក្នុងដងព្រៃនេះល្អជាង គឺប្រសើរជាងរាប់រយរាប់ពាន់ដង ។ បទថា **អថ ចិត្តំ វិមុច្ចិ មេ** សេចក្ដីថា ខ្ញុំយករង្វង់ពាក់ត្រង់ក ចងនឹងមែកឈើ ក្នុងកាលណា ក្នុងកាលនោះ គឺក្នុងលំដាប់

នោះឯងចិត្តរបស់ខ្ញុំ ក៏រួចផុត គឺរួចផុតហើយចាកអាសវៈទាំងពួងតាមលំដាប់មគ្គព្រោះបន្តដោយវុដ្ឋានគាមិនីវិបស្សនានិងមគ្គ ។

## អដ្ឋកថា សីហាថេរគាថា ចប់

## នន្ទាថេរីគាថា

[ ៣០៦ ] ម្នាលនាងនន្ទា នាងចូរមើលរាងកាយដែលមានជំងឺជានិច្ច មិនស្អាត ជារបស់ពុករលួយ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំឡើងហើយ ( នេះ ) នាងចូរអប់រំចិត្តដោយអសុភសញ្ញា ឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ សរីរៈនេះយ៉ាងណា សរីរៈរបស់នាងហ្នឹង ក៏យ៉ាងនោះដែរ សរីរៈរបស់នាងហ្នឹងយ៉ាងណា សរីរៈនេះ ក៏យ៉ាងនោះដែរ នាងកុំខ្ជិលច្រអូស ខ្ញុំពិចារណារាងកាយនុ៎ះទាំងយប់ទាំងថ្ងៃយ៉ាងនេះឯងថា សរីរៈ ( នេះ ) ដែលពួកជនពាលរីករាយជារបស់ពុករលួយ មានក្លិនអាក្រក់ ។ លំដាប់អំពីនោះ ខ្ញុំក៏បានពិនិត្យឃើញដោយប្រាជ្ញារបស់ខ្លួន ។ ខ្ញុំនោះ មិនធ្វេសប្រហែស ខ្ញុំពិចារណាដោយឧបាយនៃប្រាជ្ញា ក៏បានឃើញកាយនេះ ទាំងខាងក្នុងទាំងខាងក្រៅតាមពិត ។ ខាងក្រោយមក ខ្ញុំនឿយណាយក្នុងកាយ រសាយក្នុងសន្តានជាអ្នកមិនធ្វេសប្រហែស ក៏បានប្រាសចាកយោគៈមានចិត្តស្ងប់មានទុក្ខរលត់ហើយ ។

នន្ទាថេរី ។

## អដ្ឋកថា

## សុន្ទរីនន្ទាថេរីគាថា

[ ៣០៦ ] គាថារបស់នន្ទាថេរី មានពាក្យផ្តើមថា **អាតុរំ អសុចឹ** ដូច្នេះជាដើម ។

បានឮ ថាកុលធីតានេះក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្នុងក្រុងហង្សវតីដល់នូវភាពជាអ្នកដឹងក្តីហើយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយអង្គក្នុងតំណែងឯតទគ្គៈ ក្រៃលែងជាងភិក្ខុនីទាំងឡាយខាងបានឈាន ទើបសន្សំបុញ្ញាធិការប្រាថ្នាតំណែងនោះ សន្សំកុសលត្រាច់ទៅក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទនេះកើតក្នុងសក្យរាជត្រកូលញាតិទាំងឡាយបានដាក់ឈ្មោះថានន្ទា ។

ក្នុងកាលតមក គេស្គាល់ទូទៅថា សុន្ទរីនន្ទាឬជនបទកល្យាណី ព្រោះមានរូបស្អាត ។ កុលធីតានេះ ក៏ដូចគ្នានឹងនាងភទ្ទកាបិលានី សូម្បីក្នុងបន្ទប់ ១២ ហត្ថដែលមានសភាពងងឹតមិនចាំបាច់អុជភ្លើងស្ពានទីនោះ ក៏ភ្លឺដោយពន្លឺដែលចេញអំពីរាងកាយរបស់នាង ។ ព្រះនាង ( ពិម្ពា ) យសោធរាស្អាតជាងស្រីទាំងពីរនេះរាប់រយដង ។ នាងសុន្ទរីនន្ទានោះ កាលព្រះមានព្រះភាគនៃយើងសម្រេចភាពជាព្រះសព្វញ្ញូហើយ យាងទៅកាន់ក្រុងកបិលពស្តុ ដោយលំដាប់ ទ្រង់ឲ្យនន្ទកុមារនិងរាហុលកុមារបួសហើយយាងទៅ ។ កាលព្រះបាទសុទ្ធោទនមហារាជបរិនិព្វានហើយ កាលព្រះនាងមហាបជាបតិគោតមីនិងព្រះនាងពិម្ពារាហុលមាតាបួសហើយ នាងគិតថា ព្រះជេដ្ឋភាតារបស់អញលះបង់ភាពជាស្តេចចក្រពត្តិ បួសត្រាស់ជាព្រះពុទ្ធ ជាអគ្គបុគ្គលក្នុងលោក សូម្បីរាហុលកុមារឱរសរបស់ព្រះអង្គក៏បួស នន្ទរាជកស្វាមីរបស់អញក្តី ព្រះនាងមហាបជាបតិគោតមីមាតាអញក្តី រាហុលមាតាបងស្រីអញក្តី ក៏បួសអស់

ហើយ ឥឡូវនេះអញនៅធ្វើអ្វីក្នុងផ្ទះ អញនឹងបួស ហើយទៅកាន់សម្នាក់ភិក្ខុនី បួសដោយសេចក្ដីស្រឡាញ់ក្នុងញាតិ មិនមែនបួសដោយសទ្ធា ហេតុនោះកាលបួសហើយ ក៏កើតសេចក្ដីស្រវឹងអាស្រ័យរូបមិនទៅកាន់ទីបម្រើព្រះពុទ្ធ ដោយគិតថា ព្រះសាស្ដាទ្រង់តិះដៀលរូបទ្រង់សម្ដែងទោសក្នុងរូបដោយអនេកបរិយាយ ។ រឿងទាំងអស់ដូចពោលមកនេះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងរឿងរបស់ព្រះនាងអភិរូបនន្ទាថេរី ( ក្នុងទុកបាត ) ដែលពោលមកហើយ ។ ឯសេចក្ដីប្លែកគ្នាមានដូច្នេះថា កាលព្រះថេរីឃើញរូបស្រីដែលព្រះសាស្ដាទ្រង់និម្មិត ត្រូវជរាគ្របសង្កត់ហើយដោយលំដាប់ ទើបមនសិការជាអនិច្ចំទុក្ខំអនត្តា ចិត្តបានបែរមុខត្រង់ចំពោះកម្មដ្ឋាន ព្រះសាស្ដាទ្រង់ឃើញដូច្នោះ កាលទ្រង់សម្ដែងធម៌ជាសប្បាយដល់ព្រះថេរី ទើបត្រាស់គាថា ៣ ថា

ម្នាលនាងនន្ទា នាងចូរមើលរាងកាយដែលមានជំងឺជានិច្ច មិនស្អាត ជារបស់ពុករលួយ ដែលធ្អើង ៣០០ កំណាត់ផ្គុំឡើងហើយ ( នេះ ) នាងចូរអប់រំចិត្តដោយអសុភសញ្ញាឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ សរីរៈនេះយ៉ាងណា សរីរៈរបស់នាងហ្នឹង ក៏យ៉ាងនោះដែរ សរីរៈរបស់នាងហ្នឹងយ៉ាងណា សរីរៈនេះ ក៏យ៉ាងនោះដែរ នាងកុំខ្ជិលច្រអូស ខំពិចារណារាងកាយនុ៎ះទាំងយប់ទាំងថ្ងៃ យ៉ាងនេះឯងថា សរីរៈ ( នេះ ) ដែលពួកជនពាលរីករាយ ជារបស់ពុករលួយ មាន

ក្លិនអាក្រក់ លំដាប់អំពីនោះ ខ្ញុំក៏បានពិនិត្យឃើញដោយប្រាជ្ញា
របស់ខ្លួន ដូច្នេះ(១) ។

ព្រះថេរី បញ្ជូនបញ្ញាទៅតាមគន្លងព្រះធម្មទេសនា តាំងនៅក្នុងសោតាបត្តិផល ព្រះសាស្តាកាលត្រាស់ប្រាប់កម្មដ្ឋាន ដើម្បីឲ្យព្រះថេរីតាំងនៅក្នុងមគ្គជាន់ខ្ពស់ដើម្បីសម្តែងថា ម្នាលនន្ទាក្នុងសរីរៈនេះ មិនមានខ្លឹមសូម្បីតិចតួច កាយនេះមានសាច់និងឈាមបូកលាប ជាលំនៅរបស់ជរាជាដើម ជាគំនរឆ្អឹងប៉ុណ្ណោះ ដូច្នេះ ទើបត្រាស់គាថានេះក្នុងធម្មបទថា

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តី
លុបគុណ ប្រជុំចុះក្នុងសរីរៈណា ( សរីរៈនោះ ) ដែល
កុសលាកុសលកម្មធ្វើហើយឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជា
គ្រឿងប្រឡាក់ដោយសាច់និងឈាម ដូច្នេះ ។

លុះចប់ទេសនា ព្រះថេរីនោះបានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំង
ពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន
អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ទូន្មានសត្វលោកញុំាងសត្វលោក
ឲ្យដឹងច្បាស់ ចម្លងសត្វទាំងពួង ឈ្លាសវៃក្នុងទេសនា ទ្រង់

---

១-គួរប្រែថា លំដាប់អំពីនោះ នាងនឹងបានពិនិត្យឃើញដោយប្រាជ្ញារបស់ខ្លួន ទើបត្រូវតាមន័យរបស់អដ្ឋកថា ព្រោះពាក្យនេះព្រះសាស្តាទ្រង់ជាអ្នកពោល ។

ញុាំងប្រជុំជនជាច្រើនឲ្យឆ្លងហើយ ។ ព្រះអង្គជាអ្នកអនុគ្រោះ ប្រកបដោយករុណា ស្វែងរកនូវប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុាំងតិរ្ថិយទាំងពួងដែលមកដល់ហើយឲ្យតាំងនៅក្នុងសីល ៥ ។ សីល ៥ ជារបស់មិនវិកវរយ៉ាងនេះ ជារបស់សូន្យពួកតិរ្ថិយ ជារបស់ដែលព្រះអរហន្តទាំងឡាយ អ្នកមានសេចក្តីស្អាតជំនាញ ប្រកបដោយតាទិគុណវិចិត្រហើយ ។ ព្រះពុទ្ធព្រះនាមបទុមុត្តរៈនោះ ជាអ្នកប្រាជ្ញធំ មានកម្ពស់ ៥៨ ហត្ថ មានទ្រង់ទ្រាយដូចជាចេតិយមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ។ ព្រះអង្គមានព្រះជន្ម ១ សែនឆ្នាំជាកំណត់ ទ្រង់ឋិតនៅអស់កាលប៉ុណ្ណោះ ទ្រង់ញុាំងប្រជុំជនជាច្រើន ឲ្យឆ្លងហើយ ។ កាលនោះខ្ញុំកើតក្នុងត្រកូលសេដ្ឋីជាត្រកូលរុងរឿងដោយកែវផ្សេងៗ ជាអ្នកស្កប់ស្កល់ដោយសេចក្តីសុខដ៏ធំនៅក្នុងក្រុងហង្សវតី ។ ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ព្រះអង្គមានព្យាយាមធំ ខ្ញុំបានស្តាប់នូវធម៌ទេសនា គឺអមតនិព្វានជាធម៌មានអានិសង្សក្រៃលែង មានប្រយោជន៍យ៉ាងល្អិតល្អន់ជាធម៌ដែលព្រះអង្គសម្តែងហើយ ។ គ្រានោះ ខ្ញុំមានចិត្តជ្រះថ្លាខ្វាំងបាននិមន្តព្រះលោកនាយក ព្រមទាំងភិក្ខុសង្ឃ ហើយថ្វាយមហាទានដល់ព្រះអង្គដោយដៃរបស់ខ្លួន ។ ខ្ញុំក្រាបជិតព្រះលោកនាយក ព្រះអង្គមានព្យាយាម ព្រមទាំងព្រះសង្ឃ

ដោយត្បូង ហើយប្រាថ្នានូវតំណែងដ៏ប្រសើរ ជាងពួកភិក្ខុនី ដែលមានឈាន ។ កាលនោះ ព្រះអង្គទូន្មានសត្វដែលមិនទាន់ទូន្មានហើយ ជាទីពឹងនៃលោកទាំង ៣ មានរស្មី ព្រះអង្គជានាយសារថីរបស់ពួកនរជន ទ្រង់ព្យាករថានាងនឹងបាន នូវតំណែង ដែលនាងប្រាថ្នាហើយដោយប្រពៃពន់ ។ ក្នុង ១ សែនកប្បអំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតមសម្ពក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌ទាំងឡាយរបស់ព្រះសាស្ដាអង្គនោះជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្ដា មានឈ្មោះថានាងនន្ទា ។ កាលនោះ ខ្ញុំបានស្ដាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តាបម្រើព្រះជិនស្រី ព្រះអង្គជានាយកដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះបានទៅកើតឯឋានយាមៈ ច្យុតចាកឋានយាមៈនោះបានទៅកាន់ឋានតុសិត ច្យុតចាកឋានតុសិតនោះបានទៅកាន់និម្មានរតី ច្យុតចាកនិម្មានរតីនោះហើយ បានទៅកាន់បរនិម្មិតវសវត្តីបុរី ។ ដោយផលនៃកុសលកម្មនោះ ខ្ញុំកើតក្នុងទីណាៗ តែងបានជា

មហេសីនៃស្តេចទាំងឡាយក្នុងទីនោះៗ ។ ខ្ញុំច្យុតចាកទីនោះ ហើយកើតជាមនុស្ស បានជាមហេសីនៃស្តេចចក្រពត្តិទាំងឡាយផង នៃស្តេចមានមណ្ឌល ទាំងឡាយផង ។ ខ្ញុំសោយនូវសម្បត្តិក្នុងទេវតា និងមនុស្សហើយដល់នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅអស់កប្បច្រើន ។ លុះដល់មកក្នុងបច្ឆិមភព ខ្ញុំកើតជាធីតានៃព្រះបាទសុទ្ធោធនៈ មិនមានអ្នកណាមួយតិះដៀលបាន ក្នុងបុរីឈ្មោះកបិលភស្តុ ។ ត្រកូលនោះក៏ដល់នូវសេចក្តីត្រេកអរ ព្រោះបានឃើញខ្ញុំជាស្រីមានរស្មី ព្រោះហេតុនោះ ឈ្មោះរបស់ខ្ញុំថានាងនន្ទា ខ្ញុំជាស្រីល្អប្រសើរ ។ មួយទៀត ខ្ញុំប្រាកដជាស្រីមានលំអជាងស្រីក្រមុំទាំងអស់វៀរលែងតែព្រះនាងយសោធរាក្នុងនគរជាទីរីករាយនោះចេញ ។ បងប្រុងច្បង ( របស់ខ្ញុំ ) បានជាកំពូលនៃលោកទាំង ៣ បងប្រុសបន្ទាប់ខាងក្រោយ ជាព្រះអរហន្តដូចគ្នា ខ្ញុំនៅជាគ្រហស្ថតែម្នាក់ឯង ដែលមានមាតាតែងជាស់តឿនថា នាងជាព្រះអនុជានៃព្រះពុទ្ធកើតក្នុងត្រកូលសក្យបុត្ត នាងបើវៀរចាកសេចក្តីត្រេកអរក្នុងធម៌ហើយ តើនឹងបាននូវអ្វីក្នុងផ្ទះ ។ សេចក្តីចម្រើនមានជរាជាទីបំផុតរូបជារបស់ដែលសម្មតិថាមិនស្អាត ការមិនមានរោគ មានរោគជាទីបំផុត ជីវិតមានសេចក្តីស្លាប់ទីបំផុត ។ រូបរបស់នាងនេះល្អគួរមើលមើល គួររីករាយ ជា

គ្រឿងប្រដាប់ របស់អ្នកស្និតស្នាងទាំងឡាយ ដូចជាទីលំនៅដែលមានសិរី ។ ( រូបរបស់នាង ) ដែលគេបូជាហើយដូចជាវត្ថុមានខ្លឹមក្នុងលោក ជាទីនាំមកនូវសេចក្តីរីករាយដល់ក្មេកទាំងឡាយ ជាទីញុំាងកិត្តិសព្ទឲ្យកើតដល់ជនអ្នកមានបុណ្យទាំងឡាយ ជាទីញុំាងឱក្កាកៈត្រកូលឲ្យត្រេកអរ ។ អស់កាលមិនយូរប៉ុន្មាន ជរានឹងគ្របសង្កត់ ( នូវរូបរបស់នាង ) មិនខាន នាងគួរលះបង់ផ្ទះដែលអ្នកប្រាជ្ញគប្បីតិះដៀល ហើយប្រព្រឹត្តធម៌ ដែលអ្នកប្រាជ្ញមិនតិះដៀលវិញ ។ ខ្ញុំបានស្តាប់ពាក្យរបស់មាតា ជាអ្នកមានចិត្តមិនរលោភរលាំដោយរាងកាយនិងរូបនិងវ័យហើយចូលទៅកាន់ផ្នួស ។ មាតារបស់ខ្ញុំ ពោលដើម្បីធ្វើនូវសេចក្តីរំឭក ដោយការរៀនឈានដ៏ធំជាធម្មជាតិស្អាត តែខ្ញុំមិនបានខ្វល់ខ្វាយក្នុងការរៀនឈាននោះទេ ។ លំដាប់នោះ ព្រះជិនស្រីប្រកបដោយមហាករុណាឃើញខ្ញុំមានមុខដូចផ្កាឈូកទ្រង់និម្មិតស្រីល្អគយរមិលមើលរុងរឿងក្រៃពេកមានរូបល្អជាងខ្ញុំក្នុងវង្វង់ចក្ខុរបស់ខ្ញុំដើម្បីឲ្យខ្ញុំនឿយណាយក្នុងរូប ដោយអានុភាពនៃព្រះអង្គ ។ ខ្ញុំឃើញស្រីនោះមានរាងកាយអស្ចារ្យក្រៃពេក ក៏ស្ញើចគិតថា ក្មេករបស់អញប្រកបដោយផល ព្រោះរូបជារបស់មនុស្សនេះជាលាភនៃក្មេក ។ ខ្ញុំនិយាយនឹងស្រីនោះថា ម្នាលស្រីល្អល្អះនាងចូរមកនាងមានសេចក្តីត្រូវការដោយ

វត្ថុណា នាងចូរប្រាប់វត្ថុនោះដល់ខ្ញុំបើ ( ពាក្យរបស់ខ្ញុំ ) ជាទីស្រឡាញ់នៃនាង ចូរនាងប្រាប់ខ្ញុំនូវត្រកូល នាម និងគោត្ត របស់នាង ។ ម្នាលស្រីល្អ ( កាលនេះ ) មិនមែនជាកាលគួរដោះស្រាយប្រស្នាទេ នាងចូរឲ្យខ្ញុំឋិតនៅលើភ្លៅ អវយវៈទាំងឡាយរបស់ខ្ញុំស្រុតចុះ នាងចូរឲ្យខ្ញុំដេកមួយរំពេច ។ លំដាប់នោះស្រីដែលព្រះពុទ្ធនិម្មិតដ៏ល្អនោះ ដេកកើយក្បាលលើភ្លៅនៃខ្ញុំ ខ្ញុំជាស្រីអាក្រក់យ៉ាងក្រៃលែង ក៏ដួលទៅលើថ្ងាសស្រីនោះ ពកក៏កើតឡើងដល់ស្រីនោះដំណាលគ្នានឹងការដួលចុះខ្ទុះនិងឈាមទាំងឡាយ ហូរចេញចាកសាកសពដែលបែកធ្លាយហើយផង មាត់មានក្លិនស្អុយ ដូចសាកសពបែកធ្លាយហើយផង សរីរៈទាំងមូលហើមប៉ោងឡើង មានសម្បុរខៀវផង ។ ស្រីនោះមានអវយវៈទាំងពួងញ័ររន្ធត់ដកដង្ហើមចេញម្តងៗ ទទួលវេទនារបស់ខ្លួន ខ្សឹកខ្សួល ( ព្រោះអាស្រ័យ ) នូវសេចក្តីករុណាថា អាត្មាអញលំបាកដោយសេចក្តីទុក្ខ ប៉ះពាល់នូវវេទនាជ្រមុជចុះក្នុងទុក្ខធំ អាត្មាអញមានសំឡាញ់ជាទីពឹងនៃអាត្មាអញ ។ ឱ! លំអមុខរបស់នាងបាត់ទៅឯណាទៅ ច្រមុះគោងរបស់នាងបាត់ទៅឯណាទៅ បបូរមាត់ដ៏ប្រសើរដូចជាផ្លែបាសទុំរបស់នាងបាត់ទៅឯណាទៅ មាត់របស់នាងបាត់ទៅឯណាទៅ ។ សម្បុររបស់នាងប្រហែលដោយព្រះចន្ទបាត់

ទៅឯណាទៅកដ៏ប្រដាប់ដោយមាសរបស់នាង បាត់ទៅឯណាទៅ ចង្កោមផ្កានិងកម្រងផ្កានិងត្រចៀករបស់នាងប្រកបដោយសម្បុរខុសគ្នា ។ ដោះរបស់នាងក្បុំមានអាការៈដូចផ្កាឈូកក្តោប សាកសពមានក្លិនស្អុយបែកធ្លាយហើយ មានក្លិនអាក្រក់ក្រៃពេក ។ នាងមានចង្កេះរលៃ មានត្រគាកធំ មានខ្លួនអាក្រក់ក្រៃលែង ដូចជ្រញ់ពេញដោយវត្ថុមិនស្អាត ឱហ្ន៎! រូបមិនទៀងទេតើ ។ ពួកពាលតែងត្រេកអរក្នុងរូបណា រូបទាំងអស់នោះដែលកើតហើយជាសរីរៈមានក្លិនស្អុយគួរខ្ពើច ជាទីខ្ពើមរអើមដូចជាព្រៃស្មសាន ។ កាលនោះ ព្រះសាស្តា ជាបងរបស់ខ្ញុំប្រកបដោយមហាករុណា ជានាយកនៃសត្វលោក ទ្រង់ឃើញខ្ញុំមានចិត្តតក់ស្លុត ទ្រង់បានត្រាស់នូវគាថាទាំងនេះថា ម្នាលនាងនន្ទា នាងចូរមើលនូវសាកសពដែលឈឺជានិច្ចមានក្លិនស្អុយ មានធ្អឹង ៣០០ កំណាត់លើកឡើងហើយ នាងចូរចម្រើនចិត្តដោយអសុភកម្មដ្ឋាន ឲ្យជាចិត្តមានអារម្មណ៍តែមួយតាំងនៅនាំដោយប្រពៃចុះ ។ រូបរបស់នាងនេះយ៉ាងណា រូបរបស់ស្រីទុ៎ះក៏យ៉ាងទុ៎ះដែរ រូបរបស់ស្រីទុ៎ះយ៉ាងណា រូបរបស់នាងនេះ ក៏យ៉ាងនោះដែរ រូបនេះមានក្លិនអាក្រក់ ស្អុយផ្សាយទៅតែពួកពាលប្រាថ្នាក្រៃពេក ។ ជនទាំងឡាយដែលមិនខ្ជិលទាំងយប់ទាំងថ្ងៃ រមែងពិចារណាឃើញរូបទុ៎ះ យ៉ាង

នេះឯង នាងទៀយណាយចាករូបនោះ ហើយឃើញដោយ
ប្រាជ្ញារបស់ខ្លួនចុះ ។ លំដាប់នោះខ្ញុំបានស្តាប់នូវគាថាជាសុភា
សិត ក៏មានចិត្តតក់ស្លុត ខ្ញុំឋិតនៅក្នុងទីនោះមានចិត្តស្ងប់បាន
ដល់នូវព្រះអរហត្ត ។ កាលនោះខ្ញុំអង្គុយក្នុងទីណាៗ ក៏មាន
ឈានជាទីប្រព្រឹត្តទៅខាងមុខ ព្រះជិនស្រី ត្រេកអរក្នុងគុណ
នោះហើយ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គ ។ កិលេសទាំងឡាយ
ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បាន
ប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ព្រះថេរីពិចារណាដល់បដិបទារបស់ខ្លួនបាន
ពោល ២ គាថា ដូចតទៅនេះ មួយអន្ទើដោយគាថា ៣ ដែលព្រះសាស្តា
ទ្រង់សម្តែងថា **អាតុរំ អសុចឹ បូតឹ** ជាដើម ជាពាក្យឧទានថា

ម្នាលនាងនន្ទា នាងចូរមើលរាងកាយដែលមានជំងឺជានិច្ច មិន
ស្អាត ជារបស់ពុករលួយដែលឆ្អឹង ៣០០ កំណាត់ ផ្គុំឡើង
ហើយ ( នេះ ) នាងចូរអប់រំចិត្តដោយអសុភសញ្ញា ឲ្យជា
ចិត្តមានអារម្មណ៍តែមួយតាំងនៅមាំល្អ ។ សរីរៈនេះយ៉ាងណា
សរីរៈរបស់នាងហ្នឹង ក៏យ៉ាងនោះដែរ សរីរៈរបស់នាងហ្នឹង
យ៉ាងណា សរីរៈនេះក៏យ៉ាងនោះដែរ នាងកុំខ្ជិលច្រអូស ខំ
ពិចារណារាងកាយនុ៎ះ ទាំងយប់ទាំងថ្ងៃយ៉ាងនេះឯងថា សរីរៈ
( នេះ ) ដែលពួកជនពាលរីករាយ ជារបស់ពុករលួយ មាន

ក្ខិនអាក្រក់ លំដាប់អំពីនោះខ្ញុំក៏បានពិនិត្យឃើញដោយប្រាជ្ញារបស់ខ្លួន[១] ។ ខ្ញុំនោះមិនធ្វេសប្រហែសខំពិចារណាដោយឧបាយនៃប្រាជ្ញា ក៏បានឃើញកាយនេះទាំងខាងក្នុងទាំងខាងក្រៅតាមពិត ។ ខាងក្រោយមកខ្ញុំនឿយណាយក្នុងកាយ រសាយក្នុងសន្តានជាអ្នកមិនធ្វេសប្រហែស ក៏បានប្រាសចាកយោគៈ មានចិត្តស្ងប់ មានទុក្ខរលត់ហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវមេតំ អវេក្ខន្តី រត្តិន្ទិវមតន្ទិតា តតោ សកាយ បញ្ញាយ អភិនិព្ពិជ្ឈ ទក្ខិសំ** សេចក្ដីថា នាងជាបុគ្គលមិនខ្ជិលច្រអូស ទាំងពេលយប់និងពេលថ្ងៃ គឺអស់កាលទាំងពួង ពិនិត្យ ពិចារណាកាយនោះ ដែលមានសភាពសោប់សល់ជាដើមយ៉ាងនោះ គឺដោយប្រការដែលពោលហើយថា រាងកាយនេះ យ៉ាងណា រាងកាយនាងនោះ ក៏យ៉ាងនោះជាដើមដោយញាណចក្ខុដែលជាចំណែកខាងដើម មានការចងចិត្តជាបុរេចារិកថា អញលះបង់សុតាមយញ្ញាណ ដែលមានបរតោឃោសៈជាហេតុ បន្ទាប់អំពីនោះ គឺព្រោះហេតុនោះនឹងចាក់ធ្លុះដោយធ្វើការបែកយនៈ គឺការសម្គាល់ថាជាដុំ ជាក្រុម តាមសេចក្ដីពិត ដោយបញ្ញាដែលឈ្មោះថា របស់ខ្លួនព្រោះកើតក្នុងខ្លួន បានដល់ ( បញ្ញា ) ដែលកើតអំពីភាវនាបានដូចម្ដេចហ្ន៎ ។

---

១-គួរប្រែថា លំដាប់អំពីនោះនាងនឹងបានពិនិត្យឃើញដោយប្រាជ្ញារបស់ខ្លួន ទើបត្រូវតាមន័យរបស់អដ្ឋកថា ព្រោះពាក្យនេះព្រះសាស្ដាទ្រង់ជាអ្នកពោល ។

ព្រោះហេតុនោះ ទើបព្រះថេរីពោលថា **តស្មា មេ អប្បមត្តាយ** ដូច្នេះជាដើម ពាក្យនោះមានអត្ថថា កាលខ្ញុំជាបុគ្គលមិនប្រមាទព្រោះមិនទៅប្រាសចាកសតិ ពិនិត្យពិច័យដោយឧបាយប្រាជ្ញា គឺដោយវិបស្សនាបញ្ញា ដោយភាពជាអនិច្ចលក្ខណៈជាដើម ឃើញកាយនេះពោលគឺខន្ធបញ្ចកៈទាំងខាងក្នុងនិងខាងក្រៅដោយចែកជាសន្តានរបស់ខ្លួន និងសន្តានរបស់អ្នកដទៃតាមសេចក្តីពិត ។

ពេលនោះ គឺក្រោយអំពីឃើញយ៉ាងនោះខ្ញុំជាអ្នកនឿយណាយក្នុងកាយ គឺនឿយណាយហើយក្នុងអត្តភាព ព្រោះប្រកបដោយវិបស្សនាបញ្ញា ប្រាសចាកតម្រេក គឺដល់នូវការប្រាសចាកត្រេកអរខាងក្នុងសន្តាន ដោយពិសេសនោះឯង ខ្ញុំជាអ្នកមិនប្រមាទ ព្រោះដល់ទីបំផុតនៃការបដិបត្តិនូវអប្បមាទធម៌តាមសេចក្តីពិត ជាអ្នកមិនជាប់ជំពាក់ក្នុងវត្ថុណាមួយ ព្រោះដកនូវសំយោជនៈបានអស់ហើយ មានចិត្តស្ងប់ មានទុក្ខរំលត់ហើយ ។

## អដ្ឋកថាសុន្ទរីនន្ទាថេរីគាថា ចប់

## ឆន្នុត្តរាថេរីគាថា

[ ៣០៧ ] អាត្មាអញបានថ្វាយបង្គំភ្លើងផង ព្រះចន្ទផង ព្រះអាទិត្យផងពួកទេវតាផង រួចហើយអាត្មាអញទៅកាន់កំពង់នៃស្ទឹងទាំងឡាយ ហើយចុះទៅក្នុងទឹក ។ អាត្មាអញសមាទាននូវវត្តច្រើនយ៉ាង គឺកោរក្បាលពាក់កណ្តាល សម្រេចការដេកលើផែនដី មិនបានបរិភោគបាយក្នុងវេលាយប់ ។ អាត្មាអញត្រេកអរក្នុងការស្អិតស្អាង និងការប្រដាប់ លុះកាមរាគបៀតបៀនហើយក៏បានទំនុកបម្រុងកាយនេះដោយគ្រឿងងូតនិងគ្រឿងអប់ ។ ក្នុងកាលខាងក្រោយមក ខ្ញុំបាននូវសទ្ធា ( ក្នុងសំណាក់នៃព្រះមហាមោគ្គល្លានត្ថេរ ) ហើយបួសក្នុងធម្មវិន័យ កាមរាគខ្ញុំបានដកចេញហើយ ព្រោះបានឃើញនូវរាងកាយតាមពិត ។ ភពទាំងអស់ផង សេចក្តីប្រាថ្នាផង សេចក្តីតាំងចិត្តទុកផង អាត្មាអញបានផ្តាច់ផ្តិលហើយ អាត្មាអញបានប្រាសចាកយោគៈទាំងពួងហើយ បានដល់នូវសេចក្តីស្ងប់ចិត្ត ។

នន្នុត្តរាថេរី ។

## អដ្ឋកថា

## ឆន្នុត្តរាថេរីគាថា

[ ៣០៧ ] គាថារបស់ព្រះនន្នុត្តរាថេរី មានពាក្យផ្តើមថា **អគ្គឹ ចន្ទញ្ច** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធ

អន្តមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកម្មាសធម្មនិគមដែនកុរុ រៀនវិជ្ជាជ័យភូមិណាមួយបួសជានិគ្រន្ថឱ្យឃាតក្នុងការលើកវាទៈ កាន់មែកព្រីងដើរទៅពេញជម្ពូទ្វីបដូចនាងកុណ្ឌលកេសាថេរីដែរ ។ ចូលទៅរកព្រះមហាមោគ្គ-ល្លានត្ថេរសួរប្រស្នា ដល់នូវភាពបរាជ័យ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈបួសក្នុងសាសនាបំពេញសមណធម៌មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ពិចារណាដល់ការបដិបត្តិ របស់ខ្លួនហើយពោលគាថា ៥ ជាឧទានថា

អាត្មាអញបានថ្វាយបង្គំភ្លើងផង ព្រះចន្ទផង ព្រះអាទិត្យផងពួកទេវតាផង រួចហើយអាត្មាអញ ទៅកាន់កំពង់នៃស្ទឹងទាំងឡាយហើយចុះទៅក្នុងទឹក ។ អាត្មាអញសមាទាននូវវត្តច្រើនយ៉ាង គឺកោរក្បាលពាក់កណ្តាល សម្រេចការដេកលើផែនដីមិនបានបរិភោគបាយក្នុងវេលាយប់ ។ អាត្មាអញត្រេកអរក្នុងការស្អិតស្អាងនិងការប្រដាប់ លុះកាមរាគបៀតបៀនហើយ ក៏បានទំនុកបម្រុងកាយនេះដោយគ្រឿងងូតនិងគ្រឿងអប់ ។ ក្នុងកាលខាងក្រោយមក ខ្ញុំបាននូវសទ្ធា ( ក្នុងសំណាក់នៃព្រះមហាមោគ្គល្លានត្ថេរ ) ហើយបួសក្នុងធម្មវិន័យ កាមរាគ ខ្ញុំបានដកចេញហើយ ព្រោះបានឃើញនូវរាងកាយតាមពិត ។ ភពទាំងអស់ផង សេចក្តីប្រាថ្នាផង សេចក្តីតាំងចិត្តទុកផង

អាត្មាអញ បានផ្ដាច់ផ្ដិលហើយ អាត្មាអញបានប្រាសចាក
យោគៈទាំងពួងហើយ បានដល់នូវសេចក្ដីស្ងប់ចិត្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អគ្គឹ ចន្ទញ្ច សុរិយញ្ច ទេវតា ច នមស្សិហំ** សេចក្ដីថា ខ្ញុំកាលស្វែងរកផ□រិសុទ្ធបានបូជា គឺបានធ្វើការនមស្ការភ្លើង ដោយផ្គងគ្រឿងបូជា ដើម្បីឲ្យទេវតាទាំងឡាយ មានព្រះឥន្ទ្រជាដើម ស្រឡាញ់រាប់អានដោយគិតថា ទេវតាទាំងឡាយមានភ្លើងជាប្រធាន ថ្វាយបង្គំព្រះចន្ទក្នុងថ្ងៃ ២ កើតរៀងរាល់ខែ ថ្វាយបង្គំព្រះអាទិត្យពេលល្ងាចរាល់ៗថ្ងៃ ថ្វាយបង្គំពួកទេវតាខាងក្រៅដទៃៗ មានព្រះហិរញ្ញគព្ភជាដើម ។ បទថា **នទីតិត្ថានិ គន្ត្វាន ឧទកំ ឱរុហាមិហំ** សេចក្ដីថា ខ្ញុំទៅកាន់កំពង់ទឹកនៃស្ទឹងគង្គា ជាដើម គឺកំពង់ទឹកដែលធ្វើការបូជា ហើយចុះទឹក គឺមុជចុះក្នុងទឹកជម្រះរាងកាយ ព្រឹកល្ងាច ។

បទថា **ពហូវត្តសមាទានា** បានដល់ សមាទានវត្តច្រើនយ៉ាង មានដុតភ្លើង ៥ កន្លែងនិងដុតកិលេសដោយតបៈជាដើម ។ បទថា **ពហុ** លោកធ្វើឲ្យជាទីឃៈថា **ពហូ** ដើម្បីងាយក្នុងការចងគាថា ។ បទថា **អឌ្ឍំ សីសស្ស ឱលិខឹ** សេចក្ដីថា ខ្ញុំកោរក្បាលរបស់ខ្ញុំពាក់កណ្ដាល អាចារ្យពួកខ្លះពោលអត្ថនៃបទថា **អឌ្ឍំ សីសស្ស ឱលិខឹ** នេះថា យកសក់ពាក់កណ្ដាលក្ដួចជាជដា ពាក់កណ្ដាលទៀតទម្លាក់ចុះ ។ បទថា **ឆមាយ សេយ្យំ កប្បេមិ** សេចក្ដីថា ខ្ញុំជាអ្នកដេកលើផែនដី រមែងដេកលើផែនដី ដែលមិនមានរណ្ដៅ ។ បទថា **រត្តឹ ភត្តំ ន ភុញ្ជិហំ** សេចក្ដីថា កាលដល់ពេលព្រលប់

ហើយ ខ្ញុំមិនបរិភោគភោជនាហារក្នុងពេលយប់ព្រលប់នោះ ។

បទថា **វិក្ខសាមណ្ឌនរតា** សេចក្តីថា ខ្ញុំលំបាកកាយ ព្រោះអត្តកិលមថានុយោគអស់កាលយូរ គិតថាព្រោះរាងកាយលំបាកយ៉ាងនេះការបរិសុទ្ធនៃបញ្ញាមែងមិនមាន តែការបរិសុទ្ធអាចមានដោយការធ្វើរាងកាយឲ្យឆ្អែតស្កប់ស្កល់ ធ្វើឥន្ទ្រិយឲ្យស្រស់បស់ កាលអនុគ្រោះកាយនេះ ទើបត្រេកអរក្នុងការប្រដាប់តាក់តែង គឺត្រេកអរក្រៃលែងក្នុងការតាក់តែងដោយគ្រឿងតាក់តែងគឺសំពត់និងក្នុងការប្រដាប់ដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ។ បទថា **ន្ហាបនុច្ឆាទនេហិ ច** បានដល់ ដោយឲ្យបុគ្គលដទៃៗគក់ប្របាច់ជាដើមហើយងូតទឹកប្រោះព្រំស្បែក ។ បទថា **ឧបកាសឹ ឥមំ កាយំ** សេចក្តីថា អនុគ្រោះកាយរបស់ខ្ញុំនេះ គឺឲ្យឆ្អែតស្កប់ស្កល់ ។ បទថា **កាមរាគេន អដ្ដិតា** សេចក្តីថា ខ្ញុំជាអ្នកមានរាងកាយរឹងប៉ឹងចម្រើនឡើងយ៉ាងនេះ ព្រោះមិនមានការដាក់ចិត្តដោយឧបាយ ទើបត្រូវកាមរាគៈចោមរោម គឺត្រូវបៀតបៀនរឿយៗ ។

បទថា **តតោ សទ្ធំ លភិត្វាន** សេចក្តីថា ទម្លាយវត្តដែលសមាទានយ៉ាងនោះហើយ មានកាយរឹងប៉ឹងបរិបូរណ៍ ជាអ្នកខ្វល់ខ្វាយក្នុងការលើកវាទៈ ដើរទៅក្នុងទីនោះៗ ក្រោយអំពីនោះ គឺក្នុងកាលតមក បានទទួលឱវាទនិងអនុសាសនីក្នុងសម្នាក់របស់ព្រះមហាមោគ្គល្លានត្ថេរ បាននូវសទ្ធា ។ បទថា **ឱស្សា កាយំ យថាភូតំ** សេចក្តីថា ខ្ញុំឃើញកាយរបស់ខ្ញុំនេះតាមសេចក្តីពិតដោយមគ្គប្បញ្ញាដោយវិបស្សនា ដកនូវកាមរាគៈអស់ដោយអនាគាមិ

*មគ្គ ។ បទថា* **សព្ពេ ភវា សមុច្ឆិន្នា ឥច្ឆា ច បត្ថនាបិ ច** *ប្រកបសេចក្ដីថា ភពទាំងឡាយទាំងដែលជាចំណង់ ពោលគឺតណ្ហាក្នុងបច្ចុប្បន្នក្ដី សេចក្ដីប្រាថ្នាពោលគឺតណ្ហាក្នុងភពតទៅក្ដី ខ្ញុំកាត់អស់ហើយដោយអគ្គមគ្គ ។ បទថា* **សន្តឹ បាបុណឹ ចេតសោ** *សេចក្ដីថា សម្រេច គឺដល់ការស្ងប់ គឺអរហត្តផលយ៉ាងពិតប្រាកដ ។*

*អដ្ឋកថានន្ទុត្តរាថេរគាថា ចប់*

## មិត្តកាលីថេរីគាថា

[ ៣០៨ ] អាត្មាអញចេញអំពីផ្ទះ ហើយមកបួសក្នុងធម្មវិន័យដោយសទ្ធា ខ្វល់ខ្វាយក្នុងលាភៈនិងសក្ការៈ ប្រព្រឹត្តដោយហេតុ ( ដែលញុំាងលាភឲ្យកើតឡើងមានពាហុសច្ចៈនិងធម្មកថាជាដើម ) នោះៗ ។ អាត្មាអញបានលះប្រយោជន៍ដ៏ឧត្តមចោល ហើយសេពនូវប្រយោជន៍ថោកទាប លុះក្នុងអំណាចនៃកិលេសទាំងឡាយ មិនត្រេកអរនឹងប្រយោជន៍នៃសមណៈ ។ សេចក្ដីសង្វេគក៏មានដល់អាត្មាអញនោះដែលអង្គុយក្នុងលំនៅថា អាត្មាអញដើរផ្លូវខុស លុះក្នុងអំណាចតណ្ហា ។ ជីវិតរបស់អាត្មាអញមានប្រមាណតិច ជរានិងព្យាធិតែងញាំញី មុនកាយនេះនឹងបែកធ្លាយមិនមែនជាកាលគួរអាត្មាអញធ្វេសប្រហែសឡើយ ។ អាត្មាអញកាលពិចារណានូវការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយតាមពិតក៏មានចិត្តរួចស្រឡះហើយចេញ ( ចាកកិលេសទាំងពួង ) ពុទ្ធសាសនាអាត្មាអញបានធ្វើហើយ ។

**មិត្តកាលីថេរី ។**

## អដ្ឋកថា
## មិត្តកាលីថេរីគាថា

[ ៣០៨ ] គាថារបស់ព្រះមិត្តកាលីថេរី មានពាក្យផ្ដើមថា **សទ្ធាយ បព្វជិត្វាន** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធ

អន្តមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកម្មាសធម្មនិគមដែនកុរុ ដល់នូវភាពជាអ្នកដឹងក្តីហើយ បាននូវសទ្ធា ព្រោះមហាសតិប្បដ្ឋានទេសនា បួសក្នុងសម្នាក់ភិក្ខុនី ត្រូវការដោយលាភសក្ការៈ បំពេញសមណធម៌ ត្រាច់ទៅក្នុងទីនោះៗអស់ ៧ ឆ្នាំ ក្នុងកាលតមក មានយោនិសោមនសិការកើតឡើងដល់នូវសេចក្តីសង្វេគ ផ្តើមវិបស្សនាមិនយូរប៉ុន្មានក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយពិចារណាបដិបទារបស់ខ្លួនហើយ បានពោលគាថាទាំងនេះជាឧទានថា

អាត្មាអញចេញអំពីផ្ទះហើយមកបួសក្នុងធម្មវិន័យដោយសទ្ធា ខ្វល់ខ្វាយក្នុងលាភៈនិងសក្ការៈ ប្រព្រឹត្តដោយហេតុ ( ដែលញុំាងលាភឲ្យកើតឡើងមានពាហុសច្ចៈ និងធម្មកថាជាដើម ) នោះៗ ។ អាត្មាអញបានលះប្រយោជន៍ដ៏ឧត្តមចោល ហើយសេពនូវប្រយោជន៍ថោកទាប លុះក្នុងអំណាចនៃកិលេសទាំងឡាយ មិនត្រេកអរនឹងប្រយោជន៍ នៃសមណៈ ។ សេចក្តីសង្វេគក៏មានដល់អាត្មាអញនោះដែលអង្គុយក្នុងលំនៅថាអាត្មាអញដើរផ្លូវខុសលុះក្នុងអំណាចតណ្ហា ។ ជីវិតរបស់អាត្មាអញមានប្រមាណតិច ជរា និងព្យាធិតែងញាំញី មុនកាយនេះនឹងបែកធ្លាយ មិនមែនជាកាលគួរអាត្មាអញ ធ្វេសប្រហែសឡើយ ។ អាត្មាអញកាលពិចារណានូវការកើតឡើង និងការ

សូន្យទៅនៃខន្ធទាំងឡាយតាមពិតក៏មានចិត្តរួចស្រឡះ ហើយ
ចេញ ( ចាកកិលេសទាំងពួង ) ពុទ្ធសាសនាអាត្មាអញបាន
ធ្វើហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិចរឹហំ តេន តេន លាភសក្ការឧស្សុក្កា** សេចក្ដីថា ខ្ញុំជាអ្នកខ្វល់ខ្វាយ គឺប្រកបហើយ ប្រកបទូទៅហើយ ក្នុងលាភនិងសក្ការៈ ត្រាច់ទៅដោយហេតុនោះៗ គឺដោយហេតុដែលឲ្យកើតលាភមានសម្ដែងធម៌ដែលទាក់ទងដោយពាហុសច្ចៈជាដើម ។

បទថា **រិញ្ចិត្វា បរមំ អត្ថំ** សេចក្ដីថា លះ គឺលះប្រយោជន៍ដ៏ឧត្តមមានឈាន វិបស្សនា មគ្គនិងផលជាដើម ។ បទថា **ហីនមត្ថំ អសេវិហំ** សេចក្ដីថា ខ្ញុំបានកាន់យកប្រយោជន៍ដ៏អាក្រក់ គឺលាមក ព្រោះជាអាមិសពោល គឺបច្ច័យ ៤ ដោយការស្វែងរកមិនមែនឧបាយ ។ បទថា **កិលេសានំ វសំ គន្ត្វា** សេចក្ដីថា ធ្លាក់នៅក្នុងអំណាចនៃកិលេសទាំងឡាយ មានមានះ មទៈនិងតណ្ហាជាដើម ។ បទថា **សាមញ្ញត្ថំ ន ពុជ្ឈិហំ** សេចក្ដីថា ខ្ញុំមិនដឹង គឺមិនជ្រាបកិច្ចរបស់សមណៈ ។

បទថា **និសិន្នាយ វិហារកេ** សេចក្ដីថា កាលខ្ញុំអង្គុយក្នុងបន្ទប់តូចបានកើតសេចក្ដីសង្វេគ ។ បើមានពាក្យសួរថាសង្វេគដូចម្ដេច ឆ្លើយថាសង្វេគថា អាត្មាអញដើរផ្លូវខុស ។ បណ្ដាបទទាំងនោះ បទថា **ឧម្មគ្គបដិបន្នាម្ហិ** សេចក្ដីថា សាសនានេះប្រព្រឹត្តទៅដើម្បីបរិនិព្វានដោយមិនប្រកាន់ អញបួសក្នុងសាសនានេះហើយមិនមនសិការកម្មដ្ឋាន ជាអ្នកបដិបត្តិខុសផ្លូវក្នុងសា-

សនានេះ ។ បទថា **តណ្ហាយ វសមាគតា** សេចក្តីថា ធ្លាក់នៅក្នុងអំ-ណាចនៃការចង់បានដែលកើតអំពីបច្ច័យ ។

បទថា **អប្បកំ ជីវិតំ មយ្ហំ** សេចក្តីថា ជីវិតរបស់អាត្មាអញតិច គឺតិចតួច បានដល់ រហ័ស ព្រោះមិនកំណត់កាល និងមានអន្តរាយច្រើន ។ បទថា **ជរា ព្យាធិ ច មទ្ទតិ** សេចក្តីថា ជរានិងព្យាធិរមែងញាំញី គឺកិនកម្ទេចនូវកាយនេះដូចភ្នំកិនកម្ទេចដោយជុំវិញ ។ បាឋៈថា **មទ្ទរេ** ដូច្នេះ ក៏មាន ។ បទថា **បុរាយំ ភិជ្ជតិ កាយោ** សេចក្តីថា កាយនេះរមែងបែកធ្លាយទៅខាងមុខ ប្រកបសេចក្តីថា ព្រោះកាយនោះមានការបែកធ្លាយដោយចំណែកមួយ ហេតុនោះ ទើបមិនមែនកាលដែលអាត្មាអញគួរប្រមាទ កាលនេះ វៀរខណៈទាំង ៨ ជាខណៈទី ៩ មិនមែនកាលដែលគួរប្រមាទ ព្រះថេរមានសេចក្តីសង្វេគ ដូច្នេះ ។

បទថា **យថាភូតមវេក្ខន្តិ** សេចក្តីថា ព្រះថេរកើតនូវសេចក្តីសង្វេគយ៉ាងនេះ ហើយចម្រើនវិបស្សនា ពិចារណាតាមសេចក្តីពិត មនសិការដល់អនិច្ចលក្ខណៈជាដើម ដើម្បីឆ្លើយនិងពាក្យសួរថា ពិចារណាអ្វី ទើបព្រះថេរពោលថា អាត្មាអញកាលពិចារណានូវការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយ ។ ខ្ញុំពិចារណាការកើតនិងការរលត់នៃឧបាទានក្ខន្ធ ៥ ដែលមានលក្ខណៈ ៥០ ដោយន័យជាដើមថា ព្រះយោគាវចរ ពិចារណាឃើញការកើតឡើងនៃរូបក្ខន្ធដោយការកើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូបព្រោះកើតឡើងនៃអវិជ្ជា ដូច្នេះ ដោយឧទយព្វយានុបស្សនាញាណ ខ្វល់ខ្វាយ

ចម្រើនវិបស្សនា មានចិត្តរួចផុតចាកកិលេសនិងភពទាំងឡាយដោយប្រការទាំងពួងតាមលំដាប់មគ្គ ក្រោកឈរហើយ គឺបានជាអ្នកចេញហើយចាកការកើត និងការរលត់ទាំង ២ យ៉ាង ដោយសេចក្ដីព្យាយាម និងចេញហើយចាកភព ៣ ដោយមគ្គ ដោយប្រការ ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា មិត្តកាលីថេរីគាថា ចប់

## សកុលាថេរីគាថា

[ ៣០៩ ] អាត្មាអញកាលនៅក្នុងផ្ទះ បានស្តាប់ធម៌របស់ភិក្ខុហើយ ឃើញធម៌ប្រាសចាកធូលី គឺកិលេស ជាធម៌នាំសត្វឲ្យចេញចាកតណ្ហា ជាហេតុនាំឲ្យបានសេចក្តីសុខមិនឃ្លាត ។ អាត្មាអញនោះ បានបោះបង់ចោលនូវកូនប្រុសផង កូនស្រីផង ទ្រព្យនិងស្រូវផង បានឲ្យគេកោរសក់ ហើយមកបួសក្នុងធម្មវិន័យ ។ អាត្មាអញកាលនៅជាសិក្ខមានា បានញុំាងមគ្គខាងលើឲ្យកើត បានលះរាគៈនិងទោសៈផង អាសវៈទាំងឡាយដែលតាំងនៅជាមួយគ្នានឹងរាគៈទោសៈនោះផង ។ លុះអាត្មាអញបានឧបសម្បទា ជាភិក្ខុនីហើយ ក៏រឭកឃើញនូវបុព្វជាតិ ទាំងទិព្វចក្ខុមិនមានមន្ទិលដែលពួកសប្បុរសចម្រើនហើយ ក៏អាត្មាអញបានជម្រះហើយ ។ អាត្មាអញបានឃើញសង្ខារទាំងឡាយដែលកើតអំពីហេតុ មានសភាពទ្រុឌទ្រោមថាជារបស់ដទៃ ហើយបានលះអាសវៈទាំងអស់ ជាអ្នកមានចិត្តត្រជាក់ បានរលត់ទុក្ខហើយ ។

សកុលាថេរី ។

## អដ្ឋកថា

## សកុលាថេរីគាថា

[ ៣០៩ ] គាថារបស់ព្រះនាងសកុលាថេរី មានពាក្យផ្តើមថា **អគារស្មឹ វសន្តីហំ** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ

កើតជារាជធីតារបស់អានន្ទរាជ ក្នុងនគរហង្សវតី ជាភគិនីមាតាដទៃនៃព្រះសាស្តា មាននាមថានន្ទា ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាឃើញព្រះសាស្តាស្ថាបនា ភិក្ខុនីមួយអង្គទុកក្នុងតំណែងឯតទគ្គៈខាងមានភ្នែកទិព្វ កើតនូវឧស្សាហៈ ធ្វើនូវបុញ្ញាធិការហើយ តាំងសេចក្តីប្រាថ្នាតំណែងនោះឯង កុលធីតានោះធ្វើកុសលកម្មដ៏ឧឡារ ដរាបដល់អស់ជីវិតក្នុងអត្តភាពនោះ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងសុគតិភូមិទាំងឡាយនោះឯង ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបៈកើតក្នុងត្រកូលព្រាហ្មណ៍ បួសជាបរិព្វាជិកាកាន់យកលទ្ធិត្រាច់ទៅ ។ ថ្ងៃមួយត្រាច់បិណ្ឌបាតប្រេង បានប្រេងហើយ យកប្រេងនោះធ្វើជាប្រទីបបូជាចេតិយរបស់ព្រះសាស្តាអស់មួយយប់ ចុតិចាកអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស ជាអ្នកមានទិព្វចក្ខុបរិសុទ្ធល្អ អន្ទោលទៅមកក្នុងទេវលោកប៉ុណ្ណោះអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលព្រាហ្មណ៍ នានគរសាវត្ថីមានឈ្មោះថាសកុលា ។ ដល់នូវភាពជាអ្នកដឹងក្តីហើយ បាននូវសទ្ធាថ្វាយខ្លួនជាឧបាសិកា ក្នុងកាលដែលព្រះសាស្តាទទួលវត្តជេតពន ក្នុងកាលតមក បានស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះខីណាស្រពមួយអង្គ កើតនូវសេចក្តីសង្វេគបួសហើយ ចម្រើនវិបស្សនា ប្រារព្ធព្យាយាម មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង
ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្ប

នេះ ។ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ។ ជាបុរស
អាជានេយ្យប្រតិបត្តិដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដើម្បី
សេចក្ដីចម្រើនដល់សព្វសត្វ ក្នុងមនុស្សលោកព្រមទាំងទេវ
លោក ។ ព្រះជិនស្រីទ្រង់ដល់នូវយសដ៏ប្រសើរមានសិរីពេញ
ពោរដោយកេរ្តិ៍ឈ្មោះ និងសេចក្ដីសរសើរដែលលោក ទាំង
ពួងបូជាហើយ ប្រាកដក្នុងទិសទាំងពួង ។ ព្រះអង្គមានសេចក្ដី
សង្ស័យធ្លងហើយ មានសេចក្ដីងឿងឆ្ងល់កន្លងបង់ហើយ មាន
សេចក្ដីត្រិះរិះក្នុងព្រះទ័យបរិបូណ៌ហើយ ទ្រង់ដល់នូវសម្ពោ-
ធិញ្ញាណដ៏ឧត្ដម ។ ព្រះសម្ពុទ្ធប្រសើរជាងនរជន ទ្រង់ញុំាង
មគ្គដែលមិនកើតឲ្យកើតឡើងផង សម្ដែងនូវមគ្គដែលមិនទាន់
សម្ដែងផង បណ្ដុះនូវមគ្គដែលមិនទាន់បណ្ដុះផង ។ ព្រះ
សម្ពុទ្ធជាអ្នកអង់អាចជាងនរជន ព្រះអង្គជ្រាបនូវមគ្គ ត្រាស់
ដឹងនូវមគ្គ ប្រាប់នូវមគ្គ ជាគ្រូប្រៀនប្រដៅដ៏ឧត្ដម ប្រសើរ
ជាងសារថីទាំងឡាយ ។ ព្រះសម្ពុទ្ធព្រះអង្គប្រកបដោយព្រះ
ទ័យករុណាដ៏ធំជាទីពឹងនៃសត្វលោក ជាអ្នកដឹកនាំសត្វលោក
ទ្រង់សម្ដែងធម៌ ស្រោចស្រង់នូវសត្វទាំងឡាយ ដែលមុជចុះ
ក្នុងកក់គឺកាម ។ កាលនោះ ខ្ញុំកើតក្នុងក្រុងហង្សវតី ឈ្មោះ
ខត្តិយនន្ទា ជាស្រីមានរូបល្អ ប្រកបដោយទ្រព្យ មានចិត្តអា-
ណិតអាសូរចំពោះអ្នកដទៃ ជាស្រីមានសិរី ។ ខ្ញុំជាធីតា នៃ

មហារាជព្រះនាមអានន្ទ ជាស្រីមានលម្អដ៏ប្រសើរ ជាប្អូនស្រី មានមាតាផ្សេងគ្នានៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ខ្ញុំស្អិតស្អាង ដោយគ្រឿងអាភរណៈទាំងពួង ជាមួយនឹងព្រះរាជកញ្ញាទាំង ឡាយ ហើយចូលទៅគាល់ព្រះពុទ្ធទ្រង់មានព្យាយាមធំហើយ ស្តាប់ធម៌ទេសនា ។ គ្រានោះ ព្រះអង្គជ្រាបច្បាស់នូវលោក ទ្រង់តាំងភិក្ខុនីនោះដែលមានចក្ខុដូចជាទិព្វ ក្នុងឋានៈដ៏ប្រសើរ ក្នុងកណ្តាលនៃបរិស័ទ ៤ ។ ខ្ញុំបានស្តាប់ព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ ថ្វាយទានដល់ព្រះសាស្តា បូជាព្រះសម្ពុទ្ធ ហើយប្រាថ្នានូវទិព្វចក្ខុ ។ លំដាប់នោះ ព្រះសាស្តាបានត្រាស់ នឹងខ្ញុំថា ម្នាលនាងនន្ទា នាងនឹងបានតំណែងដែលនាងប្រាថ្នា ឋានៈដែលនាងប្រាថ្នាដោយប្រពៃន៉ុះ ជាផលនៃធម្មទានដូចជា ប្រទីប ។ ក្នុងកប្បទី ១ សែនអំពីកប្បនេះ ព្រះសាស្តាព្រះ នាមគោតម កើតក្នុងឱក្កាកៈត្រកូល នឹងត្រាស់ដឹងឡើងក្នុង លោក ។ នាងនឹងបានជាព្រះញាតិក្នុងធម៌ទាំងឡាយ នៃព្រះ សាស្តានោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកាព្រះសាស្តា មានឈ្មោះថាសកុលា ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះ ផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជា របស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះ ពុទ្ធព្រះនាមកស្សបៈព្រះអង្គមានផៅពង្សដ៏ប្រសើរមានយសធំ

ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ក្នុងភទ្ទកប្ប នេះ ។ កាលនោះ ខ្ញុំបួសជានាងបរិព្វាជិកា ប្រព្រឹត្តម្នាក់ឯង ត្រាច់ទៅដើម្បីភិក្ខា ហើយបាននូវវត្ថុត្រឹមតែប្រេងប៉ុណ្ណោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានអុជប្រទីបដោយប្រេងនោះ បម្រើព្រះ ចេតិយប្រសើរសមរម្យជាងចេតិយទាំងពួងនៃព្រះពុទ្ធប្រសើរ ជាងសត្វមានជើងពីរ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផងលុះខ្ញុំលះបង់រាងកាយជារបស់ មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដោយផល នៃកម្មនោះ ខ្ញុំកើតក្នុងទីណាៗ ប្រទីបដ៏ធំទាំងឡាយ បំភ្លឺដល់ ខ្ញុំដែលនៅក្នុងទីនោះៗ ។ ខ្ញុំប្រាថ្នារបស់ណាខ្ញុំឃើញ ( របស់ នោះ ) ធ្លុះរហូតខាងក្រៅជញ្ជាំង ធ្លុះរហូតខាងក្រៅនៃភ្នំថ្ម នេះ ជាផល នៃការឲ្យប្រទីប ។ ខ្ញុំជាអ្នកមានភ្នែកស្អាត រុងរឿង ដោយយស មានសទ្ធា មានប្រាជ្ញា នេះជាផល នៃការឲ្យ ប្រទីប ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូល ព្រាហ្មណ៍មានទ្រព្យនឹងស្រូវច្រើន ជាត្រកូលរីករាយ ដែល ស្តេចរាប់អានបូជាហើយ ។ ខ្ញុំបរិបូណ៌ដោយអវយវៈគ្រប់យ៉ាង ស្អិតស្អាងដោយអាភរណៈទាំងពួង ខ្ញុំឈរនៅត្រង់បង្អួចឃើញ ព្រះសុគត ត្រង់ប្រទេសជាទីចូលទៅកាន់បុរី ។ ខ្ញុំឃើញព្រះ ពុទ្ធរុងរឿងដោយយស ដែលទេវតា និងមនុស្សធ្វើសក្ការៈ

ហើយទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ស្អិតស្អាងដោយលក្ខណៈទាំងឡាយ ។ ខ្ញុំមានចិត្តអណ្តែតឡើង មានចិត្តល្អ ពេញចិត្តនឹងផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានដល់ព្រះអរហត្ត ។ ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំបានញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកបរិសុទ្ធស្អាតមិនមានមន្ទិលឡើយ ។ ព្រះសាស្តាខ្ញុំបានបម្រើហើយសាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះគឺការអស់ទៅនៃសំយោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ ។ លំដាប់នោះ ព្រះពុទ្ធប្រសើរជាងនរជន ព្រះអង្គប្រកបដោយមហាករុណា ទ្រង់តាំងខ្ញុំជាឯតទគ្គ ដោយព្រះពុទ្ធដីកាថា នាងសកុលាថេរី ជាភិក្ខុនីប្រសើរផុតជាងថេរីទាំងឡាយដែលមានទិព្វចក្ខុ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ព្រះថេរីបានជាអ្នកសន្សំនូវវសីក្នុងទិព្វចក្ខុ

ញ្ញាណ ព្រោះជាអ្នកមានអធិការដែលធ្វើទុកហើយ ព្រោះហេតុនោះទើបព្រះសាស្តាស្ថាបនាព្រះថេរីទុកក្នុងឯតទគ្គលើសភិក្ខុនីអ្នកមានទិព្វចក្ខុ ។ ព្រះថេរីពិចារណាបដិបទានៃខ្លួន កើតនូវបីតិសោមនស្ស បានពោលគាថាទាំងនេះជាឧទានថា

អាត្មាអញកាលនៅក្នុងផ្ទះ បានស្តាប់ធម៌របស់ភិក្ខុហើយឃើញធម៌ប្រាសចាកធូលីគឺកិលេស ជាធម៌នាំសត្វឲ្យចេញចាកតណ្ហា ជាហេតុនាំឲ្យបានសេចក្តីសុខមិនឃ្លាត ។ អាត្មាអញនោះបានបោះបង់ចោលនូវកូនប្រុសផង កូនស្រីផង ទ្រព្យនិងស្រូវផង បានឲ្យគេកោរសក់ ហើយមកបួសក្នុងធម្មវិន័យ ។ អាត្មាអញកាលនៅជាសិក្ខមានា បានញុំាងមគ្គខាងលើឲ្យកើត បានលះរាគៈនិងទោសៈផង អាសវៈទាំងឡាយ ដែលតាំងនៅជាមួយគ្នានឹងរាគៈទោសៈនោះផង ។ លុះអាត្មាអញបានឧបសម្បទាជាភិក្ខុនីហើយ ក៏រឭកឃើញនូវបុព្វជាតិ ទាំងទិព្វចក្ខុមិនមានមន្ទិលដែលពួកសប្បុរសចម្រើនហើយ ក៏អាត្មាអញបានជម្រះហើយ ។ អាត្មាអញបានឃើញសង្ខារទាំងឡាយដែលកើតអំពីហេតុមានសភាពទ្រុឌទ្រោមថាជារបស់ដទៃ ហើយបានលះអាសវៈទាំងអស់ ជាអ្នកមានចិត្តត្រជាក់ បានរលត់ទុក្ខហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អគារស្មឹ វសន្តីហំ ធម្មំ សុត្វាន ភិក្ខុនោ**

សេចក្តីថា កាលមុនខ្ញុំនៅកណ្តាលផ្ទះ ស្តាប់ធម្មកថាដែលឲ្យសម្រេចអរិយសច្ច ៤ ក្នុងសម្នាក់របស់ភិក្ខុដែលទម្លាយកិលេសហើយមួយអង្គ ។ បទថា **អទ្ទសំ វិរជំ ធម្មំ និព្វានំ បទមច្ចុតំ** សេចក្តីថា ខ្ញុំបានឃើញ គឺឃើញហើយនូវធម៌ ពោលគឺបានឈ្មោះថា **វិរជំ** ព្រោះមិនមានធូលី គឺរាគៈជាដើម ឈ្មោះថា **និព្វានំ** ព្រោះផុតចាកកិលេសជាគ្រឿងជោតក្រង ឈ្មោះថា **បទំ** ព្រោះជាហេតុឲ្យសម្រេចសេចក្តីសុខ ឈ្មោះថា **អច្ចុតំ** ព្រោះមិនមានការឃ្លាតដោយធម្មចក្ខុ ពោលគឺទស្សនៈដែលប្រដាប់ដោយន័យ ១០០០ ។

បទថា **សាហំ** សេចក្តីថា ខ្ញុំជាព្រះសោតាបន្នដោយប្រការដូចពោលហើយ ។ បទថា **សិក្ខមានា អហំ សន្តី** សេចក្តីថា ខ្ញុំនៅជាសិក្ខមានានោះឯង ព្រោះបួសក្នុងកាលអាយុមិនទាន់គ្រប់ ( ឧបសម្បទា ) ។ បទថា **ភាវេន្តី មគ្គមញ្ជសំ** សេចក្តីថា ញ៉ាំងផ្លូវ គឺមគ្គខាងលើឲ្យកើតឡើងដោយការបដិបត្តិមជ្ឈិមប្បដិបទា ។ បទថា **នាហេសាវេ ច អាសវេ** សេចក្តីថា បានលះ គឺកាត់ផ្តាច់នូវអាសវៈទាំងឡាយដែលតាំងនៅរួមគ្នាដោយការកើតព្រមជាមួយរាគៈនិងទោសៈដែលសម្លាប់បានដោយអនាគាមិមគ្គ ។

បទថា **ភិក្ខុនី ឧបសម្បជ្ជ** សេចក្តីថា កាលអាយុគ្រប់ហើយ ខ្ញុំឧបសម្បទាជាភិក្ខុនី ។ បទថា **វិមលំ** បានដល់ មានមន្ទិលទៅប្រាសហើយ ព្រោះរួចផុតចាកឧបក្កិលេសទាំងឡាយ មានអភិជ្ឈាជាដើម ។ បទថា **សាធុ** បានដល់ អប់រំហើយដោយគោរព គឺដោយប្រពៃនោះឯង ។ ម្យ៉ាងទៀតភ្ជាប់សេចក្តីថា ជម្រះទិព្វចក្ខុដែលសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើមអប់រំ

ហើយ គឺឲ្យកើតហើយ ។

បទថា **សង្ខារេ** បានដល់ សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **បរតោ** ស្មើគ្នានឹង **អនត្តតោ** ប្រែថា ជាអនត្តា ។ បទថា **ហេតុជាតេ** បានដល់ កើតឡើងចំពោះមុខ ។ បទថា **បលោកិនេ** សេចក្តីថា ឃើញសង្ខារទាំងឡាយមានការទ្រុឌទ្រោមទៅជាធម្មតា ស្អុយរលួយ ដោយបញ្ញាចក្ខុ ។ បទថា **បហាសឹ អាសវេ សព្វេ** សេចក្តីថា ខ្ញុំលះអាសវៈទាំងអស់ដែលនៅសល់ គឺធ្វើឲ្យអស់ទៅដោយអរហត្តមគ្គ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថាសកុលាថេរីគាថា ចប់

## សោណាថេរីគាថា

[ ៣១០ ] អាត្មាអញបានសម្រាលកូនដប់ ក្នុងសរីរៈគឺរូបនេះ ព្រោះហេតុនោះ អាត្មាអញមានកម្លាំងថយ គ្រាំគ្រា បានចូលទៅរកភិក្ខុនីមួយរូប ។ លោកបានសំដែងធម៌ គឺខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ លុះអាត្មាអញបានស្តាប់ធម៌របស់លោកហើយ ក៏បានកោរសក់បួស អាត្មាអញនោះ កំពុងសិក្សា ( សិក្ខាបី ) បានជម្រះទិព្វចក្ខុដ៏ផងនូវបុព្វេនិវាសដែលអាត្មាអញបានអាស្រ័យនៅហើយ ក្នុងកាលមុន ។ អាត្មាអញមានអារម្មណ៍តែមួយ មានចិត្តតម្កល់មាំចម្រើនអនិមិត្តវិមោក្ខ ជាអ្នកបានវិមោក្ខក្នុងលំដាប់ ( នៃមគ្គដ៏ប្រសើរ ) រលត់កិលេសហើយ ព្រោះមិនប្រកាន់ ។ បញ្ចក្ខន្ធអាត្មាអញបានកំណត់ហើយ មានឫសផ្តាច់ផ្តិលហើយ អាត្មាអញមិនមានតណ្ហាដែលកើតអំពីវត្ថុដែលតាំងនៅ ឥឡូវនេះភពថ្មីមិនមាន ។

សោណាថេរី ។

## អដ្ឋកថា

## សោណាថេរីគាថា

[ ៣១០ ] គាថារបស់ព្រះសោណាថេរី មានពាក្យផ្តើមថា **ទស បុត្តេ វិជាយិត្វា** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលនាហង្សវតីនគរដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ

ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះសាស្តាស្ថាបនាភិក្ខុនីមួយអង្គទុក ក្នុងតំណែងឯតទគ្គលើសភិក្ខុនី អ្នកប្រារព្ធព្យាយាម ក៏ធ្វើកុសលឲ្យក្រៃលែង ប្រាថ្នាតំណែងនោះធ្វើបុណ្យជាបដល់អស់ជីវិតចុតិអំពីភពនោះហើយអន្ទោល ទៅក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទនេះកើត ក្នុងផ្ទះមានត្រកូលក្នុងក្រុងសាវត្ថី ពេញក្រមុំហើយ នៅក្នុងត្រកូលប្តី មាន កូន ១០ នាក់ ទើបបានឈ្មោះថា ពហុបុត្តិកា កាលប្តីចេញបួស នាងក៏ រៀបចំឲ្យកូនប្រុសស្រីដែលពេញវ័យហើយគ្រប់គ្រងផ្ទះចាត់ចែងទ្រព្យសម្បត្តិ ប្រគល់ឲ្យបុត្តទាំងឡាយ មិនបន្សល់ទ្រព្យណាមួយសម្រាប់ខ្លួនឡើយ បុត្ត និងកូនប្រសាបម្រើនាងបាន ២-៣ ថ្ងៃ ក៏មើលងាយ នាងគិតថា ប្រយោជន៍ អ្វីដែលអញនៅក្នុងផ្ទះដែលកូនទាំងឡាយនេះមើលងាយហើយ ទើបចូលទៅ រកភិក្ខុនីសូមបួស ភិក្ខុនីទាំងឡាយក៏ឲ្យនាងបួស នាងបានឧបសម្បទាហើយ គិតថា អញបួសឯចាស់មិនគប្បីប្រមាទកាលធ្វើវត្តបដិបត្តិដល់ភិក្ខុនីទាំងឡាយ គិតថា អញនឹងធ្វើសមណធម៌មួយយប់ទល់ភ្លឺ ក៏យកដៃម្ខាងចាប់សសរខាង ក្រោមប្រាសាទមិនលះសសរនោះធ្វើសមណធម៌ កាលដើរចង្ក្រមគិតថា ក្នុង ទីងងឹតក្បាលរបស់អញអាចដល់នឹងដើមឈើណាមួយ ទើបយកដៃម្ខាងចាប់ ដើមឈើមិនលះដើមឈើនោះ ធ្វើសមណធម៌ ។ តាំងអំពីនោះមក នាងក៏ ល្បីទៅថាជាអ្នកប្រារព្ធព្យាយាម ។ ព្រះសាស្តាទ្រង់ឃើញថា កុលធីតានេះ មានញាណចាស់ក្លា គង់ក្នុងព្រះគន្ធកុដិនោះឯងផ្សាយរស្មីទៅ សម្តែងព្រះ កាយហាក់បីដូចគង់ក្នុងទីចំពោះមុខ បានត្រាស់គាថា ( ធម្មបទ ) ថា

បុគ្គលណារស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ប្រសើរជាង ដូច្នេះ ។

កាលចប់គាថានាងក៏សម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយកទ្រង់កើតឡើងហើយក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីដល់នូវសេចក្ដីសុខជាស្រីមានគេជាប់ចិត្តជាទីស្រឡាញ់ ( នៃជនដទៃ ) ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ជាអ្នកប្រាជ្ញដ៏ប្រសើរ បានស្ដាប់តម្រាស់ដ៏ពីរោះ ។ ព្រះជិនស្រីទ្រង់សរសើរភិក្ខុនីអ្នកមានព្យាយាមលើសលុប ជាងភិក្ខុនីទាំងឡាយអ្នកមានព្យាយាមប្រារព្ធ ខ្ញុំបានស្ដាប់ព្រះពុទ្ធតម្រាស់នោះ ក៏មានចិត្តរីករាយហើយធ្វើនូវសក្ការៈចំពោះព្រះសាស្ដា ។ កាលនោះ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធហើយប្រាថ្នានូវតំណែងនោះ ព្រះមហាវីរបុរសទ្រង់អនុមោទនាថា សេចក្ដីប្រាថ្នានៃនាងនឹងសម្រេច ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតមកើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌ទាំងឡាយនៃព្រះសាស្ដានោះ ជាឱរស

ជាធម្មទិន្និតជាសាវិកានៃព្រះសាស្តាមានឈ្មោះថាសោណា ។ កាលនោះ ខ្ញុំបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះជិនស្រីជានាយកនៃសត្វលោក ដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះដល់មកក្នុងបច្ឆិមភព ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋីជាត្រកូលស្តុកស្តម្ភធំទូលាយ មានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ជាបូរីដ៏ប្រសើរ ។ កាលណា ខ្ញុំដល់នូវវ័យទៅត្រកូលប្តី បានបង្កើតកូន ១០ នាក់ មានរូបល្អប្លែកៗគ្នា កូនទាំងអស់នោះ ឋិតនៅក្នុងសេចក្តីសុខ ជាទីគាប់ភ្នែកនឹងចិត្តនៃជន សូម្បីសត្រូវទាំងឡាយក៏គង់គាប់ចិត្តដែរ នឹងបាច់និយាយទៅថ្វី ដល់កូនទាំងនោះដែលជាទីស្រឡាញ់នៃខ្ញុំ ។ លំដាប់នោះ ប្តីរបស់ខ្ញុំនោះ មានកូន ១០ នាក់ចោមរោមទៅបួសក្នុងសាសនាព្រះពុទ្ធជាទេវតាកន្លងទេវតាដោយខុសបំណងរបស់ខ្ញុំ ។ គ្រានោះខ្ញុំតែម្នាក់ឯងបានគិតថា ជីវិតមិនគួរដល់អញដែលជាស្រីចាស់កំព្រាព្រាត់ប្រាសចាកប្តីនិងកូនទាំងឡាយឡើយដូច្នេះ ប្តីរបស់អញនៅក្នុងទីណា អញនឹងទៅក្នុងទីនោះ លុះខ្ញុំគិតយ៉ាងនេះ

ហើយ ក៏ចូលទៅកាន់ផ្ទះ ។ លំដាប់នោះ ភិក្ខុនីទាំងឡាយ លះបង់ខ្ញុំម្នាក់ឯង ក្នុងលំនៅនៃភិក្ខុនី ហើយក៏ទៅឲ្យឱវាទថា នាងចូរដាំទឹក ។ គ្រានោះខ្ញុំនាំទឹកមកហើយចាក់អំពីក្អមតម្កល់ទុកក្នុងភាជន៍តូចហើយអង្គុយ តម្កល់ចិត្តមាំ ក្នុងខណៈនោះ ។ ខ្ញុំឃើញនូវខន្ធទាំងឡាយថាមិនទៀងផង ជាទុក្ខផង ជាអនត្តាផងបានញុំាងអាសវៈទាំងពួងឲ្យអស់ហើយដល់ព្រះអរហត្ត ។ គ្រានោះមានភិក្ខុនីទាំងឡាយមកសួររកទឹកក្តៅខ្ញុំក៏បានអធិដ្ឋានតេជោធាតុ ហើយញុំាងទឹកឲ្យក្តៅយ៉ាងរហ័ស ។ ភិក្ខុនីទាំងនោះស្ញើចហើយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះជិនស្រីដ៏ប្រសើរ ព្រះពុទ្ធជាទីពឹងនៃសត្វលោក ទ្រង់ព្រះសណ្តាប់សេចក្តីនោះហើយក៏រីករាយត្រាស់គាថានេះថា បុគ្គលណាមួយជាអ្នកខ្ជិលច្រអូសមានព្យាយាមថោកថយ គប្បីរស់នៅអស់ ១០០ ឆ្នាំ ជីវិតរបស់បុគ្គលដែលមានព្យាយាមប្រារព្ធមាំ រស់នៅតែមួយថ្ងៃប្រសើរជាង ។ ព្រះមហាមុនីមានព្យាយាមធំ ខ្ញុំបានធ្វើឲ្យរីករាយហើយដោយសេចក្តីប្រតិបត្តិដ៏ប្រពៃហើយទ្រង់ត្រាស់ថា ខ្ញុំជាស្រីប្រសើរផុតជាងភិក្ខុនីទាំងឡាយ អ្នកមានព្យាយាមប្រារព្ធហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលនោះ ព្រះមានព្រះភាគ កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុង

តំណែងឯតទគ្គៈតាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះនាងសោណាថេរីនោះ ទុកក្នុងតំណែងឯតទគ្គៈ គឺជាកំពូលជាងភិក្ខុនីទាំងឡាយ ខាងប្រារព្ធព្យាយាម ។ ថ្ងៃមួយ ព្រះថេរីពិចារណាបដិបទារបស់ខ្លួន ទើបពោលគាថានេះ ជាឧទានថា

*អាត្មាអញបានសម្រាលកូនដប់ ក្នុងសរីរៈគឺរូបនេះ ព្រោះហេតុនោះអាត្មាអញមានកម្លាំងថយ គ្រាំគ្រា បានចូលទៅរកភិក្ខុនីមួយរូប ។ លោកបានសំដែងធម៌គឺខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ លុះអាត្មាអញបានស្តាប់ធម៌របស់លោកហើយ ក៏បានកោរសក់បួស អាត្មាអញនោះ កំពុងសិក្សា ( សិក្ខាបី ) បានជម្រះទិព្វចក្ខុ ដឹងនូវបុព្វេនិវាស ដែលអាត្មាអញបានអាស្រ័យនៅហើយក្នុងកាលមុន ។ អាត្មាអញមានអារម្មណ៍តែមួយមានចិត្តតម្កល់មាំចម្រើនអនិមិត្តវិមោក្ខ ជាអ្នកបានវិមោក្ខក្នុងលំដាប់ ( នៃមគ្គដ៏ប្រសើរ ) រលត់កិលេសហើយ ព្រោះមិនប្រកាន់ ។ បញ្ចក្ខន្ធអាត្មាអញបានកំណត់ហើយ មានឫសផ្តាច់ផ្តិលហើយអាត្មាអញមិនមានតណ្ហាដែលកើតអំពីវត្ថុដែលតាំងនៅ ឥឡូវនេះភពថ្មីមិនមាន ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **រូបសមុស្សយេ** បានដល់ ក្នុងសរីរៈ ពោលគឺរូប ។ សេចក្តីពិត **រូប** សព្ទនេះមកក្នុងអត្ថថារូបាយតនៈ ដូចក្នុងប្រយោគជាដើមថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** វិញ្ញាណកើតឡើង

ព្រោះអាស្រ័យភ្នែកនិងរូប ដល់នូវកិរិយារាប់ថា ចក្ខុវិញ្ញាណ ដូច្នេះ ។ មកក្នុងអត្ថថា រូបក្ខន្ធ ដូចក្នុងប្រយោគជាដើមថា **យង្កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ** រូបក្ខន្ធឯណាមួយដែលជាអតីត អនាគត និងបច្ចុប្បន្ន ដូច្នេះ ។ មកក្នុងអត្ថថា សភាវៈ ដូចក្នុងប្រយោគជាដើមថា **បិយរូបេ រូបេ សារជ្ជតិ** ក៏កើតតម្រេកក្នុងរូបដែលគួរស្រឡាញ់ ដូច្នេះ ។ មកក្នុងអត្ថថា អាយតនៈ គឺកសិណ ដូចក្នុងប្រយោគជាដើមថា **ពហិទ្ធា រូបានិ បស្សតិ** ឃើញរូបកសិណខាងក្រៅ ដូច្នេះ ។ មកក្នុងអត្ថថា រូបជ្ឈាន ដូចក្នុងប្រយោគជាដើមថា **រូបី រូបានិ បស្សតិ** ប្រែថា បុគ្គលមានរូបជាអារម្មណ៍ រមែងឃើញរូបទាំងឡាយ ដូច្នេះ ។ មកក្នុងអត្ថថា រូបកាយ ដូចក្នុងប្រយោគជាដើមថា **អដ្ឋិញ្ច បដិច្ច ន្ហារុញ្ច មំសញ្ច បដិច្ច ចម្មញ្ច បដិច្ច អាកាសោ បរិវារិតោ រូបន្តេវ សង្ខ្យំ គច្ឆតិ** ប្រែថា អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថារូបបាន ដូច្នេះ ។ ក្នុងទីនេះគប្បីជ្រាបថាមកក្នុងអត្ថថា រូបកាយប៉ុណ្ណោះឯង ។

**សមុស្សយ** សព្ទ ជាពាក្យហៅគ្រោងឆ្អឹងដោយអមក៏បាន **សមុស្សយ** សព្ទ មកក្នុងអត្ថថា គ្រោងឆ្អឹងដោយអម ដូចក្នុងប្រយោគជាដើមថា **សតដ្ឋិសមុស្សិយា** ព្រោះគ្រោងឆ្អឹង ៣០០ កំណាត់ ដូច្នេះ ។ មកក្នុងអត្ថថា រាងកាយ ដូចក្នុងប្រយោគជាដើមថា **អាតុរំ អសុចឹ បូតឹ បស្ស នន្ទេ ស-មុស្សយំ** ម្នាលនាងនន្ទា នាងចូរមើលរាងកាយដែលមានជំងឺជានិច្ច មិនស្អាត

ជារបស់ពុករលួយ ដូច្នេះ ។ ក្នុងទីនេះ គប្បីជ្រាបថា មកក្នុងអត្ថថា រាងកាយនោះឯង ។ ដោយហេតុនោះ ទើបព្រះថេរីពោលថា **រូបសមុស្សយេ** ប្រែថា ក្នុងសរីរៈពោលគឺរូប អធិប្បាយថា ក្នុងរាងកាយ ។ គប្បីបន្ថែមពាក្យថា **ឋត្វា** ចូលមកផងដែរ ។ បទថា **អស្មិ រូបសមុស្សយេ** ប្រកបសេចក្តីថាតាំងនៅក្នុងសរីរៈ គឺរូបនេះ បានដល់ អាស្រ័យរូបកាយដែលប្រសូតបុត្ត ១០ នាក់ ។ បទថា **តតោ** ប្រែថា ព្រោះប្រសូតបុត្ត ១០ នាក់នោះ ។ ពិតហើយ ព្រោះនាងប្រសូតបុត្តក្នុងកាលកន្លងបឋមវ័យទៅហើយ ទើបមានសរីរៈទន់ខ្សោយនិងទ្រុឌទ្រោមព្រោះជរាដោយលំដាប់ ដោយហេតុនោះទើបព្រះថេរីពោលថា **តតោហំ ទុព្វលា ជិណ្ណា** ព្រោះហេតុនោះ អាត្មាអញមានកម្លាំងថយ គ្រាំគ្រា ។

បទថា **តស្សា** ប្រែថា អំពីភិក្ខុនីនោះ ម្យ៉ាងទៀត ពាក្យថា **តស្សា** ប្រែថា ក្នុងសម្នាក់របស់ភិក្ខុនីនោះ ។ ម្យ៉ាងទៀត បទថា **តស្សា** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ មានសេចក្តីស្មើនឹង **តាយ** ប្រែថា នោះ ។ បទថា **សិក្ខមានាយ** បានដល់ សិក្សាសិក្ខាទាំង ៣ ។

បទថា **អនន្តរាវិមោក្ខាសិ** សេចក្តីថា ខ្ញុំមានវិមោក្ខកើតក្នុងលំដាប់នៃអរហត្តមគ្គ ។ ពិតហើយ វិមោក្ខ ៨ មានវិមោក្ខថា បុគ្គលមានរូបជាអារម្មណ៍ រមែងឃើញរូបទាំងឡាយជាដើម មិនឈ្មោះថា វិមោក្ខក្នុងលំដាប់ឡើយ ។ ពិតហើយ ផលវិមោក្ខដែលសម្រេចក្នុងលំដាប់នៃមគ្គ សូម្បីប្រព្រឹត្តទៅក្នុងពេលចូលផលសមាបត្តិ ក៏ឈ្មោះថា អនន្តរវិមោក្ខ ព្រោះអា-

ស្រ័យផលសមាបត្តិនោះកើត ព្រោះកើតព្រមក្នុងលំដាប់នៃបឋមមគ្គនោះឯង ដូចមគ្គសមាធិ លោកហៅថា អនន្តរិកសមាធិ ដូចគ្នា ។ បទថា **អនុបាទាយ និព្វុតា** បានដល់ ខ្ញុំមិនប្រកាន់បណ្ដាអារម្មណ៍ណាមួយ មានរូបជាដើម ជាអ្នករំលត់ដោយឥតសេសសល់ ព្រោះរំលត់កិលេសជាសមុច្ឆេទ ។

ព្រះថេរីនេះចង្អុលបង្ហាញវិជ្ជា ៣ ឧទានចេញមកដោយចាប់យកកំពូលដោយអរហត្តផលយ៉ាងនេះហើយ ឥឡូវនេះ កាលតិះដៀលសរីរៈ ដែលត្រូវជរាបៀតបៀនអស់កាលយូរ ដើម្បីចង្អុលបង្ហាញថា នាងឈានកន្ទងផុតសរីរៈនោះមួយអន្លើដោយវត្ថុដែលកន្លងទៅហើយ ទើបពោលគាថាចុងក្រោយថា **បញ្ចក្ខន្ធា បរិញ្ញាតា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ធិ តវត្ថុ ជរេ ជម្មេ** សេចក្ដីថា គួរតិះដៀលសេចក្ដីជរា ដែលអាក្រក់ថោកទាប ព្រោះធ្វើអវយវៈឲ្យទុព្វលជាដើម ខ្ញុំសូមតិះដៀលគឺការតិះដៀលមានដល់ខ្ញុំ ។ បទថា **នត្ថិទានិ បុនព្ភវោ** អធិប្បាយថា ព្រោះដូច្នោះ ខ្ញុំកន្លងផុតអ្នកទៅហើយ អ្នកត្រូវខ្ញុំគ្របសង្កត់ហើយ ។

## អដ្ឋកថា សោណាថេរីគាថា ចប់

## ភទ្ទាកុណ្ឌលាថេរីគាថា

[ ៣១១ ] អាត្មាអញមានសក់ដកហើយ ( ដោយបន្ទាត្នោត ) ទ្រទ្រង់ភក់ មានសំពត់សាដកតែមួយ ប្រព្រឹត្តក្នុងកាលមុន មានសេចក្តីសំគាល់ថា ទោសក្នុងរបស់ដែលមិនមានទោស ទាំងមានសេចក្តីយល់ឃើញថា មិនមានទោសក្នុងរបស់ដែលមានទោស ចេញទៅអំពីទីសម្រាកក្នុងវេលាថ្ងៃ បានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលីគឺរាគាទិក្កិលេស មានភិក្ខុសង្ឃហែហមលើភ្នំគិជ្ឈកូដ ក៏លុតជង្គង់ថ្វាយបង្គំប្រណម្យអញ្ជលីក្នុងទីចំពោះព្រះភក្ត្រ ។ ព្រះមានព្រះភាគ បានត្រាស់ថា ម្នាលនាង នាងចូរមកចុះ ឧបសម្បទានោះក៏សម្រេចដល់ខ្ញុំ ។ អាត្មាអញ បានដើរទៅកាន់ជនបទឈ្មោះអង្គៈ មគធៈ វជ្ជីកាសីនិងកោសលៈ ជាអ្នកមិនមានបំណុល បានបរិភោគដុំបាយរបស់ជនអ្នកនៅក្នុងដែន ( នោះៗ ) អស់ ៥០ ឆ្នាំ ។ ឧបាសកណាបានឲ្យចីវរដល់នាងភទ្ទាដែលរួចចាកគន្ថៈទាំងពួង ឧបាសកនោះប្រកបដោយបញ្ញា បានសោយបុណ្យច្រើន ។

ភទ្ទាកុណ្ឌលាថេរី ។

## អដ្ឋកថា

## ភទ្ទាកុណ្ឌលកេសាថេរីគាថា

[ ៣១១ ] គាថារបស់ព្រះភទ្ទាកុណ្ឌលកេសាថេរី មានពាក្យផ្តើមថា **លូនកេសី បង្កធរី** ដូច្នេះជាដើម ។

បានឮថា កុលធីតានេះក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលនាក្រុងហង្សវតីដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា ឃើញព្រះសាស្ដាស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈជាងភិក្ខុនីទាំងឡាយ ខាងខិប្បាភិញ្ញា ក៏ធ្វើកុសលឲ្យក្រៃលែងប្រាថ្នាតំណែងនោះធ្វើបុណ្យដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ អស់មួយសែនកប្ប ក្នុងសាសនាព្រះពុទ្ធព្រះនាមថាកស្សបៈ កើតជាព្រះរាជធីតាមួយអង្គក្នុងវាំងបងប្អូនស្រី ៧ អង្គ ក្នុងរាជវាំងរបស់ព្រះបាទកាសី ព្រះនាមថា កិកិ សមាទានសីល ១០ ប្រព្រឹត្តកោមារិព្រហ្មចរិយៈ អស់ពីរម៉ឺនឆ្នាំ សាងបរិវេណថ្វាយសង្ឃ អន្ទោលទៅក្នុងសុគតិប៉ុណ្ណោះ អស់ពុទ្ធន្តរមួយ លុះដល់ពុទ្ធុប្បាទនេះ កើតក្នុងផ្ទះសេដ្ឋីក្រុងរាជគ្រឹះឈ្មោះថាភទ្ទា ។ ធំពេញវ័យដោយបរិវារច្រើន ឃើញចោរឈ្មោះសត្តុកៈដែលជាកូនបុរោហិតក្នុងនគរនោះឯងតាមបង្អួច ដែលត្រូវអ្នករក្សានគរចាប់ចងកាត់ទោសមួយអន្ទើដោយភស្ដុតាងកំពុងនាំខ្លួនទៅកាន់ទីសម្លាប់ តាមព្រះរាជអាជ្ញា មានចិត្តប្រតិព័ទ្ធដេកផ្កាប់មុខលើគ្រែ ខ្សឹកខ្សួលថា បើខ្ញុំបានបុរសនោះ ទើបមានជីវិត បើមិនបាន ក៏នឹងស្លាប់ ។

បិតារបស់នាងជ្រាបរឿងនោះមានសេចក្ដីស្រឡាញ់ក្នុងកូនស្រីច្រើនព្រោះជាកូនស្រីតែមួយ ទើបយកសំណូក ១០០០ កហាបណៈ ឲ្យភ្នាក់ងារ អ្នករក្សានគរ ដើម្បីដោះលែងចោរដោយឧបាយ ។ ឲ្យគេតែងខ្លួន ប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ឲ្យឡើងទៅកាន់ប្រាសាទ ។ កុលធីតា ឈ្មោះភទ្ទា

មានសេចក្ដីប្រាថ្នាសម្រេចហើយ ក៏ប្រដាប់ដោយគ្រឿងអលង្ការ ដ៏ក្រៃលែង ប្រតិបត្តិចោរសត្តុកៈ ។ កន្លងទៅ ២-៣ ថ្ងៃ សត្តុកៈចោរមានចិត្តលោភលន់ចង់បានគ្រឿងអលង្ការទាំងនោះ ពោលនឹងនាងថា កទ្ទូ អញត្រូវក្នាក់ងារអ្នករក្សានគរចាប់ ក៏បន់ទេវតាដែលស្ថិតនៅនាភ្នំសម្រាប់ទម្លាក់ចោរថា បើខ្ញុំបានរួចរស់ជីវិតនឹងនាំពលីកម្មទៅថ្វាយលោក សូមនាង ជួយចាត់ចែងគ្រឿងពលីកម្មសម្រាប់ទេវតានោះផងចុះ ។ នាងគិតថា នឹងបំពេញបំណងស្វាមីទើបរៀបចំគ្រឿងពលីកម្ម ប្រដាប់ដោយគ្រឿងអាភរណៈសព្វយ៉ាង ឡើងយានជាមួយស្វាមី ផ្ដើមឡើងកាន់ភ្នំជាទីទម្លាក់ចោរដោយបំណងថាធ្វើពលីកម្មដល់ទេវតា ។ សត្តុកចោរគិតថា បើឡើងទៅជាមួយគ្នាទាំងអស់អញនឹងដណ្ដើមនូវអាភរណៈរបស់ស្រីនេះមិនបាន ទើបបញ្ឈប់បរិវារក្នុងទីនោះឯង ហើយឲ្យឡើងភ្នំចំពោះតែភាជនៈដាក់គ្រឿងពលិកម្ម កាលឡើងដល់លើភ្នំហើយមិនបាននិយាយល្អ ជាមួយនាងឡើយ ។ នាងក៏ដឹងបំណង របស់សត្តុកចោរដោយអាកប្បកិរិយា ដែលសម្ដែងចេញមកនោះឯង ។ សត្តុកចោរពោលថា នែ កទ្ទូ ចូរនាងដោះសំពត់ដណ្ដប់របស់នាងវេចគ្រឿងប្រដាប់ដែលជាប់នឹងខ្លួននាងភ្លាម ។ នាងពោលថា នែអ្នក ខ្ញុំធ្វើខុសអ្វីឬ ចោរពោលថា ស្រីល្ងង់ នាងស្មានថាអញមកធ្វើពលិកម្មឬ តាមពិត អញមកដើម្បីដណ្ដើមយកអាភរណៈរបស់ឯងដោយអាងពលិកម្មទេតើ នាងពោលថា នែអ្នក គ្រឿងប្រដាប់ជារបស់នរណា ខ្លួនខ្ញុំជារបស់នរណា ។ ចោរពោលថា អញមិនដឹងនូវការចែកយ៉ាងនេះឡើយ នាងពោលថាណ្ហើយចុះ សូមអ្នកជួយធ្វើបំណង

របស់ខ្ញុំម្យ៉ាងឲ្យពេញផងចុះ សូមឲ្យខ្ញុំបានឱបអ្នកទាំងនៅតាក់តែងគ្រឿងប្រ-
ដាប់ផងចុះ ចោរក៏ទទួលពាក្យ ។ នាងដឹងថា ចោរទទួលពាក្យហើយ ធ្វើជា
ឱបខាងមុខ ហើយឱបខាងក្រោយ បានច្រានចោរធ្លាក់ត្រង់ភ្នំដែលដាច់ ចោរ
នោះក៏ធ្លាក់បែកខ្ទេចខ្ទីជាលម្អិតតូចធំ ។ ទេវតាដែលអាស្រ័យត្រង់ភ្នំ ឃើញ
ហេតុការណ៍គួរអស្ចារ្យ ដែលនាងធ្វើហើយ កាលនឹងប្រកាសភាពដែលនាង
ជាមនុស្សវាងវៃ ទើបពោលគាថាទាំងនេះថា

ប្រុសមិនមែនឈ្មោះថាបណ្ឌិតក្នុងហេតុទាំងអស់ទេ សូម្បីស្រី
សោះតែជាអ្នកមានឧបាយវាងវៃក្នុងហេតុនោះ ៗ ក៏ឈ្មោះថា
បណ្ឌិតបាន ។ ប្រុសមិនមែនឈ្មោះថាបណ្ឌិត ក្នុងហេតុទាំង
អស់ទេសូម្បីស្រីសោះតែជាអ្នកគិតឃើញនូវប្រយោជន៍រហ័ស
ក៏ឈ្មោះថាបណ្ឌិតដែរ ដូច្នេះ ។

លំដាប់នោះ នាងកុណ្ឌលកេសាគិតថា អញធ្វើយ៉ាងនេះ នឹងត្រឡប់ទៅផ្ទះមិន
បាន អញនឹងទៅអំពីទីនេះ ហើយបួស ទើបបានទៅកាន់អារាមរបស់និគ្រន្ថ
សូមបួសជានិគ្រន្ថ ។ និគ្រន្ថទាំងនោះពោលនឹងនាងថា តើនាងបួសដូចម្តេច
នាងពោលថា ការបួសបែបណាដែលឧក្រិដ្ឋសម្រាប់ពួកលោក សូមលោក
ធ្វើយ៉ាងនោះចុះ ។ និគ្រន្ថទាំងនោះពោលថា សាធុ ហើយក៏នាំគ្នាដកសក់
របស់នាងដោយគ្រាប់ត្នោត ឲ្យនាងបួស ។ សក់ដែលដុះមកវិញ ក៏រួញដុះ
ឡើងមក ចាប់ពីនោះមក នាងក៏មានឈ្មោះថា កុណ្ឌលកេសា នាងរៀន
លទ្ធិសម័យ និងគន្លងនៃវាទៈដែលគួររៀន ក្នុងសម្នាក់និគ្រន្ថនោះ ក៏ដឹងថា

មនុស្សទាំងនេះមានប្រមាណប៉ុណ្ណោះ ក្រៃលែងជាងនេះមិនមាន ក៏ចៀសចេញអំពីសម្នាក់នោះ ទៅក្នុងទីដែលមានបណ្ឌិត រៀនចំណេះដឹងរបស់បណ្ឌិតទាំងនោះ មិនឃើញបុគ្គលណាដែលអាចពោលជាមួយខ្លួនបាន ចូលទៅកាន់ស្រុកនិគមណា ក៏ពូកពំនូកខ្សាច់ទុកក្បែរទ្វារស្រុកនិគមនោះ ដោយដោតមែកព្រីងលើពំនូកខ្សាច់នោះ ឲ្យសញ្ញាដល់ពួកក្មេងដែលឈរក្បែរៗថា អ្នកណាអាចលើកវាទៈជាមួយយើងបាន អ្នកនោះចូរជាន់មែកព្រីងនេះ ហើយក៏ទៅកាន់ទីសម្រាក កាលមែកព្រីងដោតយ៉ាងនោះ ៧ ថ្ងៃ នាងក៏កាន់មែកព្រីងនោះបន្តដំណើរទៅទៀត ។

សម័យនោះ ព្រះមានព្រះភាគទ្រង់កើតឡើងក្នុងលោក ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ទ្រង់អាស្រ័យក្រុងសាវត្ថីគង់នៅក្នុងវត្តជេតពនដោយលំដាប់ ។ ឯនាងកុណ្ឌលកេសាត្រាច់ទៅក្នុងគាមនិគម រាជធានីទាំងឡាយ ដោយន័យដែលពោលហើយដល់ក្រុងសាវត្ថី ក៏ដោតមែកព្រីងលើគំនរខ្សាច់ ក្បែរទ្វារព្រះនគរ ឲ្យសញ្ញាដល់ពួកក្មេងៗហើយចូលទៅកាន់ក្រុងសាវត្ថី ។

កាលនោះ ព្រះធម្មសេនាបតីចូលទៅកាន់នគរមួយអង្គឯង ឃើញមែកឈើនោះ បំណងនឹងញាំញីវាទៈ ទើបសួរក្មេងៗថា ហេតុអ្វី ទើបមែកព្រីងត្រូវដោតយ៉ាងនេះ ។ ពួកក្មេងក៏ប្រាប់សេចក្តីនោះ ។ ព្រះថេរៈពោលថា បើយ៉ាងនោះ ពួកឯងចូរនាំគ្នាជាន់មែកព្រីងនោះចុះ ។ ពួកក្មេងក៏នាំគ្នាជាន់មែកព្រីងនោះ ។ នាងកុណ្ឌលកេសា បរិភោគអាហារស្រេចហើយ ក៏ចេញអំពីនគរ ឃើញមែកព្រីងត្រូវជាន់ទើបសួរថា អ្នកណាជាន់ បានដឹងថា ព្រះថេរៈ

ឲ្យជាន់គិតថា វាទៈដែលមិនមានគ្នីគ្នា មិនប្រពៃទើបចូលទៅក្នុងនគរសាវត្ថី ត្រាច់ទៅពីផ្លូវមួយទៅកាន់ផ្លូវមួយឃោសនាថា អ្នកទាំងឡាយ ចូរមកមើលវាទៈរបស់ខ្ញុំនឹងសមណសក្យបុត្តចុះ មានមហាជនចោមរោមហើយ ចូលទៅរកព្រះធម្មសេនាបតីដែលគង់ក្រោមដើមឈើមួយដើម ធ្វើបដិសណ្ឋារៈហើយឈរក្នុងទីសមគួរនាចំណែកម្ខាងពោលថា មែកព្រីងដែលខ្ញុំដោតលោកម្ចាស់ឲ្យក្មេងជាន់ឬ ព្រះថេរៈឆ្លើយថា ពិតហើយ អាត្មាឲ្យក្មេងជាន់ ។ នាងកុណ្ឌលកេសាពោលថា បើដូច្នោះ វាទៈរបស់ខ្ញុំនិងលោកម្ចាស់រមែងមាន ។ ព្រះថេរៈពោលថា ចូរនាងអញ្ជើញចុះ នាងពោលថា ខ្ញុំនិងលោកម្ចាស់ អ្នកណាសួរអ្នកណាឆ្លើយ ព្រះថេរៈពោលថា ធម្មតាការសួរ អាត្មាត្រូវសួរមុនតែនាងត្រូវសួរសេចក្តីដែលនាងដឹងមុនចុះ ។ កាលព្រះថេរៈអនុញ្ញាត នាងក៏សួរវាទៈ ដែលជាចំណេះដឹងរបស់ខ្លួនទាំងអស់ ។ ព្រះថេរៈឆ្លើយបានទាំងអស់ ។ នាងមិនដឹងការដែលត្រូវសួរឲ្យក្រៃលែងជាងនោះទើបនៅស្ងៀម ។ ព្រះថេរៈពោលថា នាងសួរអាត្មាមកច្រើនហើយ អាត្មានឹងសួរបញ្ហាមួយ ។ នាងពោលថា សូមលោកម្ចាស់សួរចុះ ។ ព្រះថេរៈ សួរបញ្ហានេះថា **ឯកំ នាម កឹ** ប្រែថា អ្វីដែលឈ្មោះថា ១ ។ នាងកុណ្ឌលកេសាមើលមិនឃើញកំណួចខាងដើមនិងកំណួចខាងចុង ដូចចូលទៅកាន់ទីងងឹត ទើបពោលថា ខ្ញុំមិនដឹងឡើយ ព្រះថេរៈពោលថា ប្រស្នាមួយប៉ុណ្ណោះ នាងមិនដឹង តើប្រការដទៃៗ នាងនឹងដឹងបានដូចម្តេច ហើយសម្តែងធម៌ ។ នាងក្រាបចុះទៀបបាតជើងទាំង ២ របស់ព្រះថេរៈ ពោលថា បពិត្រលោកម្ចាស់ខ្ញុំសូមដល់លោក

ម្ចាស់ជាសរណៈ ។ ព្រះថេរៈពោលថា ភទ្ទា នាងកុំដល់អាត្មាជាសរណៈឡើយចូរនាងដល់ព្រះមានព្រះភាគ ដែលជាអគ្គបុគ្គលក្នុងលោក មួយអន្លើដោយទេវលោកជាសរណៈចុះ ។ នាងពោលថា ខ្ញុំធ្វើតាមយ៉ាងនោះ ហើយចូលទៅគាល់ព្រះសាស្តាក្នុងកាលដែលទ្រង់សម្តែងធម៌ក្នុងវេលាល្ងាច ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានឈរក្នុងទីសមគួរនាចំណែកម្ខាង ព្រះសាស្តាទ្រង់ជ្រាបថា នាងមានញាណចាស់ក្លាហើយ ទើបត្រាស់ព្រះគាថានេះថា

បើវាចាសូម្បី ១ ពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រ-
យោជន៍ វាចានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទមានប្រ-
យោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍
នោះសូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ដូច្នេះ ។

ចប់គាថា កំពុងឈរនោះឯង នាងក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌
ទាំងពួង ជានាយកទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពី
ភទ្ទកប្បនេះ ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋី ក្នុងក្រុង
ហង្សវតីជាត្រកូលរុងរឿងដោយរតនវត្ថុផ្សេងៗ ខ្ញុំជាស្រីស្កប់
ស្កល់ដោយសេចក្តីសុខច្រើនប្រការ ។ ខ្ញុំចូលទៅរកព្រះពុទ្ធ
ជាមហាវីរបុរសអង្គនោះ ហើយបានស្តាប់ធម៌ដ៏ឧត្តម លំដាប់
នោះខ្ញុំមានសេចក្តីជ្រះថ្លាកើតឡើងហើយ បានដល់ព្រះជិនស្រី

ជាទីពឹង ។ ក្នុងកាលនោះឯង ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈប្រកបដោយមហាករុណាទ្រង់តាំងសុភាភិក្ខុនីថាជាភិក្ខុនីប្រសើរជាងពួកភិក្ខុនីដែលត្រាស់ដឹងឆាប់រហ័ស ។ លុះខ្ញុំបានស្តាប់ព្រះពុទ្ធវាចានោះហើយ ខ្ញុំមានសេចក្តីរីករាយ បានថ្វាយទានដល់ព្រះពុទ្ធជាមហេសីហើយក្រាបចុះទៀបព្រះបាទាដោយត្បូងប្រាថ្នានូវតំណែងនោះ ។

ព្រះពុទ្ធជាមហាវីរបុរស ទ្រង់អនុមោទនាថា ម្នាលនាងដ៏ចម្រើនតំណែងណា ដែលនាងប្រាថ្នាហើយតំណែងទាំងអស់នោះនឹងសម្រេចពុំខាន ចូរនាងបានសេចក្តីសុខរំលត់ទុក្ខចុះ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឈ្មោះឱក្កាកៈ នឹងកើតឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុង ធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្តាឈ្មោះនាងកុណ្ឌលកេសីដ៏ចម្រើន ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយបានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះទៅកើតក្នុងឋានយាមៈ ច្យុតចាកឋានយាមៈនោះ បានទៅកើតក្នុងឋានតុសិតច្យុតចាកឋានតុសិតនោះ ក៏បានទៅកើតក្នុងឋាន

និម្មានរតី រួចទៅកើតក្នុងបរនិម្មិតវសវត្តីបុរី ។ ខ្ញុំកើតក្នុងទីណាៗ ខ្ញុំបាននូវភាពជាមហេសីរបស់ស្តេចទាំងឡាយ ក្នុងទីនោះៗ ព្រោះអានិសង្សនៃបុញ្ញកម្មនោះឯង ។ ខ្ញុំច្យុតចាកអត្តភាពនោះហើយបានមកកើតក្នុងមនុស្សលោក បាននូវភាពជាមហេសី របស់ស្តេចចក្រពត្តិទាំងឡាយផង របស់ស្តេចក្នុងមណ្ឌលទាំងឡាយផង ។ ខ្ញុំបាននូវសម្បត្តិក្នុងទេវលោកផងក្នុងមនុស្សលោកផង ហើយជាស្រីដល់នូវសេចក្តីសុខ ក្នុងទីទាំងពួងអន្ទោលទៅក្នុងកប្បដ៏ច្រើន ។ ព្រះពុទ្ធព្រះនាមកស្សបៈព្រះអង្គមានផៅពង្សដ៏ប្រសើរ មានយសច្រើន ប្រសើរជាងពួកអ្នកប្រាជ្ញទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ។ គ្រានោះ ព្រះរាជាក្នុងដែនកាសីព្រះនាមកិកី ក្នុងពារាណសីបុរីដ៏ឧត្តម ជាឥស្សរៈលើប្រជាជន បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។ ខ្ញុំជាធីតាទី ៤ របស់ព្រះរាជាអង្គនោះដែលប្រាកដជាភិក្ខុទាសី បានស្តាប់ធម៌របស់ព្រះជិនស្រីដ៏ប្រសើរហើយក៏ពេញចិត្តចំពោះបព្វជ្ជា ។ ព្រះបិតាយើងទ្រង់មិនអនុញ្ញាតឲ្យបួសទេ កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារីអស់ ២ ម៉ឺនឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញាឋិតនៅក្នុងសេចក្តីសុខ ត្រេកអរក្នុងការបម្រើព្រះពុទ្ធគឺនាង សមណី ១ សមណគុត្តា ១ ភិក្ខុនី

១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ នាងសង្ឃទាសិកា ជាគម្រប់ ៧ ។ កាលនោះ ( ព្រះរាជធីតាទាំង ៧ នាក់នោះ ចេរវិលវឹងមក ) បានជានាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ ខ្ញុំ ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ជាគម្រប់ ៧ ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយបានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ចិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋីដ៏ស្តុកស្តម្ភក្នុងបុរីដ៏ឧត្តមឈ្មោះគិរិព្វជៈ ឋិតនៅក្នុងវ័យដ៏ចម្រើន ។ ខ្ញុំឃើញនូវចោរដែលគេកំពុងបណ្តើរ យកទៅដើម្បីសម្លាប់ ហើយស្រឡាញ់ចំពោះចោរនោះ លំដាប់នោះបិតារបស់ខ្ញុំដោះចោរនោះ ចេញអំពីទោសដែលត្រូវសម្លាប់ដោយកហាបណៈមួយពាន់ ។ បិតាបានឲ្យខ្ញុំទៅចោរនោះព្រោះដឹងច្បាស់នូវចិត្តខ្ញុំ ខ្លួនខ្ញុំជាស្រីឥតវង្វៀសជាអ្នកអាណិតអនុគ្រោះក្រៃពេកចំពោះចោរនោះ ។ ឯចោរនោះ នាំមកនូវគ្រឿងបូជាហើយនាំខ្ញុំទៅកាន់ជ្រោះសម្រាប់ទម្លាក់ចោរហើយគិតសម្លាប់ខ្ញុំលើភ្នំដោយ សេចក្តីចង់បាននូវគ្រឿងប្រដាប់របស់ខ្ញុំ ។ គ្រានោះខ្ញុំធ្វើអញ្ជលីដ៏ល្អ ប្រណម្យចំពោះចោរឈ្មោះសត្តុកៈ រក្សានូវជីវិតរបស់ខ្លួនទុកសិនហើយពោលពាក្យនេះថា បពិត្រអ្នកដ៏ចម្រើនអ្នកចូរនាំយកនូវសង្វារ

ជាវិការៈនៃមាសព្រមទាំងកែវមុក្តា កែវពៃទូរ្យដ៏ច្រើនទាំងអស់ នេះទៅចុះ រួចសូមឲ្យអ្នកប្រាប់គេឲ្យដឹងថា ខ្ញុំជាទាសីចុះ ។ ម្នាលនាងកល្យាណី នាងចូរដាក់នូវគ្រឿងប្រដាប់ មកឲ្យអញចុះ នាងកុំខ្សឹកខ្សួលខ្លាំងឡើយ អញមិនដែលថាមិនសម្លាប់នូវមនុស្សដែលមកក្នុងព្រៃសោះទេ ។ អញនឹករកមើលនូវខ្លួនអញ ចាប់តាំងពីអញដល់នូវភាពជាអ្នកដឹងក្តីមក អញមិនដែលស្គាល់អ្នកដទៃឲ្យជាទីស្រឡាញ់ជាងនាងឡើយ ។ អ្នកចូរមកនេះ ខ្ញុំនឹងបានកៀកកើយអ្នកសិន ហើយសូមធ្វើប្រទក្សិណអ្នក ថ្វាយបង្គំអ្នក ព្រោះថាការរួបរួមគ្នារវាងខ្ញុំនឹងអ្នកមិនមានទៀតទេ ។ ( ទេវតាពោលថា ) ប្រុសមិនមែនឈ្មោះថាបណ្ឌិតក្នុងហេតុទាំងអស់ទេ សូម្បីស្រីសោះ តែជាអ្នកមានឧបាយវាងវៃក្នុងហេតុនោះៗក៏ឈ្មោះថាបណ្ឌិតបាន ។ ប្រុសមិនមែនឈ្មោះថាបណ្ឌិតក្នុងហេតុទាំងអស់ទេ សូម្បីស្រីសោះ តែជាអ្នកគិតឃើញនូវប្រយោជន៍រហ័ស ក៏ឈ្មោះថាបណ្ឌិតដែរ ។ បុគ្គលណា ត្រិះរិះឃើញនូវប្រយោជន៍ច្រើនដ៏រហ័សផង ឆាប់ផង ដូចជាបុគ្គលកាលឃើញតាមហេតុនៃសំបុត្របួតម្រាដ៏វិចិត្រ បុគ្គលនោះ ឈ្មោះបណ្ឌិត គ្រានោះខ្ញុំបានសម្លាប់នូវចោរឈ្មោះសត្តុកៈ ។ បុគ្គលណា មិនយល់ឆាប់នូវប្រយោជន៍ដែលកើតឡើងហើយ បុគ្គលនោះ ឈ្មោះ

ថាមានគំនិតទន់រមែងទុក្ខព្រួយ ដូចជាចោរដែលធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ។ បុគ្គលណា យល់ច្បាស់ធាប់នូវប្រយោជន៍ដែលកើតឡើងហើយ បុគ្គលនោះ រមែងរួចអំពីការបង្អៀតដោយសត្រូវ ដូចជាខ្ញុំរួចចាកបុរសឈ្មោះសត្តុកៈ ក្នុងកាលនោះឯង ។ ខ្ញុំច្រានបុរសឈ្មោះសត្តុកៈ ទៅក្នុងជ្រោះភ្នំ រួចហើយចូលទៅកាន់សំណាក់ពយកតាបស អ្នកស្លៀកពាក់សំពត់សហើយបួស ។ ក្នុងកាលនោះ ខ្ញុំទុកសក់របស់ខ្ញុំដោយចន្ទាសដោយប្រការទាំងពួង ហើយបួស ពួកតាបសក៏ប្រាប់នូវលទ្ធិឥតមានចន្លោះឡើយ ។ លំដាប់នោះខ្ញុំរៀននូវលទ្ធិនោះហើយអង្គុយតែម្នាក់ឯងគិតនូវលទ្ធិនោះ ( គាប់ជួន ) ឆ្កែក៏ពាំយកដៃរបស់មនុស្ស ។ ឆ្កែពាំដៃរបស់មនុស្សដែលដាច់មកទម្លាក់ចោលក្នុងទីជិតខ្ញុំ ហើយចៀសចេញទៅ ខ្ញុំបានឃើញហើយក៏បាននូវនិមិត្តចំពោះត្រកូលនៃជង្គង់ដែលឋិតនៅ ( ក្នុងសាកសពនោះ ) ។ លំដាប់នោះ ខ្ញុំតក់ស្លុតហើយក្រោកទៅសួរពួកសហធម្មិកៈ ឯពួកសហធម្មិកទាំងនោះប្រាប់ថា ពួកភិក្ខុជាសក្យបុត្ត ទើបដឹងច្បាស់នូវសេចក្តីនោះបាន ។ ខ្ញុំនោះបានចូលទៅរកពួកសាវករបស់ព្រះពុទ្ធហើយសួរសេចក្តីនោះ ពួកសាវកទាំងនោះ ក៏នាំខ្ញុំទៅក្នុងសំណាក់នៃព្រះពុទ្ធប្រសើរ ។ ព្រះពុទ្ធជានាយកនោះ ទ្រង់សម្តែងនូវព្រះធម៌ចំពោះខ្ញុំថា ខន្ធ

អាយតនៈ ធាតុ ជាធម្មជាតមិនស្អាតផង មិនទៀងផង ជាទុក្ខផង ជាអនត្តាផង ។ លុះខ្ញុំបានស្តាប់នូវធម៌របស់ព្រះអង្គហើយបានជម្រះធម្មចក្ខុ គឺសោតាបត្តិផលលំដាប់នោះ ខ្ញុំបានដឹងច្បាស់នូវព្រះសទ្ធម្មហើយក៏សូមនូវបព្វជ្ជានិងឧសម្បទា ។ កាលនោះព្រះពុទ្ធជានាយក ដែលខ្ញុំសូមហើយទើបទ្រង់ត្រាស់ថា ម្នាលនាងដ៏ចម្រើននាងចូរមកចុះ កាលនោះខ្ញុំក៏បានឧបសម្បទាហើយបានឃើញទឹកបន្តិច ។ ខ្ញុំដឹងនូវរូបប្រកបដោយការកើតឡើងនឹងការសូន្យទៅដោយគ្រាន់តែលាងជើង ហើយគិតក្នុងកាលនោះថា សង្ខារទាំងឡាយទាំងពួង មានសភាពដូចគ្នា ។ លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួចស្រឡះចាកអាសវៈព្រោះមិនប្រកាន់ដោយប្រការទាំងពួង គ្រានោះព្រះជិនស្រីទ្រង់តាំងខ្ញុំថា ប្រសើរលើសជាងពួកភិក្ខុនី ដែលត្រាស់ដឹងឆាប់រហ័ស ខ្ញុំជាស្រីស្ទាត់ក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុជាទិព្វផងខ្ញុំជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា ដឹងនូវចិត្តនៃបុគ្គលដទៃផង ។ ខ្ញុំដឹងនូវបុព្វេនិវាស ទាំងទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធមិនមានមន្ទិល ព្រោះញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ។ ព្រះសាស្តាខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំដាក់ចេញហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភពថ្មី ខ្ញុំគាស់រំលើង

ចេញហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណធម៌ណា ប្រយោជន៍គឺគុណធម៌នោះរបស់ខ្ញុំជាទីអស់ទៅនៃសញ្ញោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ ។ ញាណរបស់ខ្ញុំដ៏ទូលាយ ស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណក៏ដូចគ្នា ព្រោះហេតុនៃព្រះពុទ្ធជាបុគ្គលប្រសើរ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។ បេ ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលនាងសម្រេចអរហត្តហើយ ក៏ទូលសូមបព្វជ្ជា ព្រះសាស្តាទ្រង់ក៏អនុញ្ញាតបព្វជ្ជាដល់នាង ទើបនាងទៅកាន់សម្នាក់ភិក្ខុនីបួសហើយ សម្ងំនៅដោយសុខក្នុងផល និងសុខក្នុងព្រះនិព្វាន ពិចារណាបដិបទារបស់ខ្លួន ទើបពោលគាថាទាំងនេះជាឧទានថា

អាត្មាអញមានសក់ដកហើយ ( ដោយបន្ទាត្នោត ) ទ្រទ្រង់ភក់មានសំពត់សាដកតែមួយប្រព្រឹត្តក្នុងកាលមុន មានសេចក្តីសំគាល់ថាទោស ក្នុងរបស់ដែលមិនមានទោស ទាំងមានសេចក្តីយល់ឃើញថា មិនមានទោសក្នុងរបស់ដែលមានទោស ចេញទៅអំពីទីសម្រាកក្នុងវេលាថ្ងៃ បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺរាគាទិក្កិលេស មានភិក្ខុសង្ឃហែហម លើភ្នំគិជ្ឈកូដ ក៏លុតជង្គង់ថ្វាយបង្គំ ប្រណម្យអញ្ជលីក្នុងទីចំពោះព្រះភក្ត្រ ។ ព្រះមានព្រះភាគបានត្រាស់ថា ម្នាលនាង នាង

ចូរមកចុះ ឧបសម្បទានោះក៏សម្រេចដល់ខ្ញុំ ។ អាត្មាអញបាន
ដើរទៅកាន់ជនបទឈ្មោះអង្គៈ មគធៈ វជ្ជី កាសី និងកោ-
សលៈ ជាអ្នកមិនមានបំណុល បានបរិភោគដុំបាយរបស់ជន
អ្នកនៅក្នុងដែន ( នោះៗ ) អស់ ៥០ ឆ្នាំ ។ ឧបាសកណា
បានឲ្យចីវរ ដល់នាងភទ្ទាដែលរួចចាកគន្ថៈទាំងពួង ឧបាសក
នោះ ប្រកបដោយបញ្ញា បានសោយបុណ្យច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លូនកេសី** បានដល់ ឈ្មោះថា **លូនកេសី** ព្រោះខ្ញុំត្រូវដកសក់ គឺមានសក់ដកហើយដោយគ្រាប់ត្នោត ក្នុងការបួសនៃលទ្ធិនិគ្រន្ថ ព្រះថេរីពោលដល់ការដកសក់នោះ ។ បទថា **បង្កធារី** បានដល់ ឈ្មោះថា **បង្កធារី** ព្រោះទ្រទ្រង់ទុកនូវបង្កៈគឺមន្ទិលក្នុងធ្មេញទាំងឡាយព្រោះមិនទំពាឈើស្ទន់ ។ បទថា **ឯកសាដី** បានដល់ មានសំពត់មួយផ្ទាំងតាមចរិតរបស់និគ្រន្ថ ។ បទថា **បុរេ ចរឹ** បានដល់ ពីមុនខ្ញុំជាស្រីនិគ្រន្ថ ត្រាច់ទៅយ៉ាងនេះ ។ បទថា **អវជ្ជេ វជ្ជមតិនី** បានដល់ សម្គាល់ក្នុងវត្ថុដែលមិនមានទោស មានការងូតទឹក ដុសខ្លួន និងទំពាឈើស្ទន់ជាដើម ថាមានទោស ។ បទថា **វជ្ជេ ចាវជ្ជទស្សិនី** បានដល់ ឃើញក្នុងវត្ថុ ដែលមានទោស មានមានះ មក្ខៈ បលាសៈ និងវិបល្លាសជាដើម ថាមិនមានទោស ។

បទថា **ទិវាវិហារា និក្ខម្ម** បានដល់ ចេញអំពីទីសម្រាកពេលថ្ងៃរបស់ខ្លួន ។ ភទ្ទាបរិព្វាជិកានេះមកជួបព្រះថេរៈក្នុងពេលថ្ងៃត្រង់ ត្រូវព្រះថេរៈកម្ចាត់នូវការរឹងត្អឹងដោយមានះដោយការឆ្លើយបញ្ហានោះ និងដោយការសម្តែងធម៌

ក៏មានចិត្តជ្រះថ្លា បំណងនឹងចូលគាល់ ( ព្រះសាស្តា ) ទើបត្រឡប់ទៅកាន់លំនៅរបស់ខ្លួន អង្គុយសម្រាកពេលថ្ងៃ ពេលល្ងាច ទើបចូលទៅគាល់ព្រះសាស្តា ។

បទថា **និហច្ច ជានុំ វន្ទិត្វា** សេចក្តីថា ដោយការលុតជង្គង់ទាំង ២ លើផែនដី ឈ្មោះថាតាំងនៅក្នុងអង្គ ៥ ។ បទថា **សម្មុខា អញ្ជលឹ អកំ** សេចក្តីថា បានធ្វើអញ្ជលីដ៏រុងរឿងដោយប្រជុំនៃម្រាម ១០ ចំពោះព្រះភក្ត្រព្រះសាស្តា ។ បទថា **ឯហិ ភទ្ទេតិ មំ អវច សា មេ អាសូបសម្បទា** សេចក្តីថា ព្រះមានព្រះភាគត្រាស់ប្រាប់ខ្ញុំដែលសម្រេចអរហត្តហើយ ទូលសូមបព្វជ្ជាឧបសម្បទាកំពុងឈរថា ម្នាលនាងភទ្ទា មកចុះ នាងចូរទៅកាន់សម្នាក់ភិក្ខុនី ហើយបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ភិក្ខុនីចុះ ដូច្នេះ យ៉ាងណា ព្រះតម្រាស់របស់ព្រះសាស្តា បានជាឧបសម្បទា ព្រោះជាហេតុនៃការឧបសម្បទារបស់ខ្ញុំ ។

២ គាថាថា **ចិណ្ណា** ជាដើម ជាគាថាសម្តែងនូវការព្យាករអរហត្ត ។ បណ្តាបទទាំងនោះ បទថា **ចិណ្ណា អង្គា ច មគធា** សេចក្តីថា ជនបទទាំងនោះគឺ អង្គៈ មគធៈ កាសី កោសល អំពីមុន ខ្ញុំបរិភោគដុំបាយរបស់អ្នកដែនទាំងបំណុល ត្រាច់ទៅ តាំងពីខ្ញុំជួបនឹងព្រះសាស្តាខ្ញុំមិនមានបំណុលមិនមានទោស ប្រាសចាកកិលេសបរិភោគដុំបាយរបស់អ្នកដែន ៥០ ឆ្នាំ ក្នុងជនបទនោះឯង ។

ព្រះថេរី កាលព្យាករអរហត្ត ដោយបំណងប្រាប់បុញ្ញវិសេសដល់ឧបា-

សកដែលមានចិត្តជ្រះថ្លា ប្រគេនចីវរដល់ខ្លួន ទើបពោលគាថាចុងក្រោយថា **បុញ្ញំ ច បសវិ ពហុំ** ជាដើម គាថានោះយល់បានងាយហើយ ។

## អដ្ឋកថាភទ្ទាកុណ្ឌលកេសាថេរីគាថា ចប់

## បដាចារាថេរីគាថា

[ ៣១២ ] ពួកមាណពក្ករស្រែដោយនង្គ័លទាំងឡាយ ហើយព្រោះពូជទាំងឡាយលើផែនដី តែងបាននូវទ្រព្យចិញ្ចឹមកូន និងប្រពន្ធទាំងឡាយ ។

អាត្មាអញបរិបូណ៌ដោយសីល មិនខ្ជិល មិនរវើរវាយធ្វើតាមសាសនារបស់ព្រះសាស្តា ដូចម្តេចក៏មិនបានព្រះនិព្វាន ។ អាត្មាអញលាងជើងក្នុងទឹក ឃើញទឹកសម្រាប់លាងជើង ហូរអំពីទីទួលមកកាន់ទីទាបហើយធ្វើ ( ឲ្យជានិមិត្ត ) ក្នុងទឹកទាំងឡាយ លំដាប់ពីនោះមកអាត្មាអញ ក៏បានតម្កល់ចិត្តមាំ ដូចសេះអាជានីយដ៏ចម្រើន ។ លំដាប់នោះអាត្មាអញកាន់ប្រទីប ចូលទៅកាន់លំនៅមើលមើលដំណេកហើយអង្គុយលើគ្រែតូច ។ ក្នុងកាលនោះ អាត្មាអញកាន់ទន្ទុកទ្វារ ហើយបន្ទឹមចុះនូវប្រឆេះ ( នៃប្រទីប ) ចិត្តក៏បានរួចស្រឡះចាកកិលេស ដូចជាការរលត់នៃប្រទីប ។

**បដាចារាថេរី ។**

## អដ្ឋកថា

## បដាចារាថេរីគាថា

[ ៣១២ ] គាថារបស់ព្រះនាងបដាចារាថេរីមានពាក្យផ្តើមថា **នង្គលេហិ កសំ ខេត្តំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កុលធីតារូបនេះក្នុងសាសនាព្រះមានព្រះភាគព្រះនាមជាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលក្នុងក្រុងហង្សវតី ដឹងក្តីហើយ ថ្ងៃមួយ

ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះមានព្រះភាគ ស្ថាបនាភិក្ខុនីមួយរូបក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុនីទាំងឡាយខាងទ្រទ្រង់វិន័យ ធ្វើកុសលឲ្យក្រៃលែងប្រាថ្នាតំណែងនោះ ។ នាងធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ កាលសាសនាព្រះពុទ្ធព្រះនាមថាកស្សបៈ បដិសន្ធិក្នុងព្រះរាជវាំងរបស់ព្រះបាទកាសីព្រះនាមថាកិកី ជាព្រះរាជធីតាមួយអង្គក្នុងចំណោមបងប្អូនស្រីទាំង ៧ អង្គ ប្រព្រឹត្តកោមារិព្រហ្មចរិយៈអស់ពីរម៉ឺនឆ្នាំ សាងបរិវេណថ្វាយភិក្ខុសង្ឃ ។ ចុតិអំពីនោះ កើតក្នុងទេវលោកសោយទិព្វសម្បត្តិអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទនេះកើតក្នុងត្រកូលសេដ្ឋីជំនឹងក្តីហើយធ្វើសេចក្តីស្និទ្ធស្នេហាជាមួយកម្មករម្នាក់ ក្នុងផ្ទះរបស់ខ្លួន ។ មាតាបិតាបានកំណត់ថ្ងៃបញ្ជូននាងឲ្យទៅសេដ្ឋីបុត្តម្នាក់ដែលមានជាតិស្មើគ្នា ។ នាងដឹងរឿងនោះហើយ ក៏ប្រមូលទ្រព្យដែលមានតម្លៃទុកក្នុងដៃ ចេញទៅតាមទ្វារជាមួយបុរសដែលខ្លួនស្រឡាញ់នោះ នៅអាស្រ័យត្រង់តំបន់មួយ ក៏តាំងគភ៌ ។ កាលគភ៌គ្រប់ខែ នាងក៏ពោលថា នែអ្នក ប្រយោជន៍អ្វីដោយការនៅអនាថាក្នុងទីនេះ ខ្ញុំនឹងត្រឡប់ទៅកាន់ផ្ទះរបស់ត្រកូល កាលស្វាមីពោលពន្យាថា ថ្ងៃនេះសឹមទៅ ស្អែកនេះសឹមទៅ នាងគិតថា បុរសនេះល្ងង់ ពិតជាមិននាំអញត្រឡប់ទៅផ្ទះពិត កាលប្តីចេញក្រៅផ្ទះ ក៏ទុកដាក់ទ្រព្យដែលគួរទុកដាក់ក្នុងផ្ទះហើយប្រាប់មនុស្សដែលនៅជិតខាងឲ្យជួយប្រាប់ប្តីថា នាងត្រឡប់ទៅផ្ទះត្រកូលហើយ នាងធ្វើដំណើរទៅតែឯងដោយគិតថា ត្រឡប់ទៅកាន់ផ្ទះនៃត្រកូល ។ ស្វាមីត្រឡប់មកផ្ទះមិនឃើញភរិយាសួរមនុស្សអ្នកស្និទ្ធ

ស្គាល ក៏ដឹងថានាងត្រឡប់ទៅកាន់មាតុភូមិគិតថា ព្រោះខ្លួនអញ ទើបកូនស្រីអ្នកមានត្រកូលក្លាយជាមនុស្សអនាថា ក៏ធ្វើដំណើរទៅតាម ជួបគ្នាត្រង់ពាក់កណ្តាលផ្លូវ ។ នាងប្រសូតបុត្តក្នុងចន្លោះផ្លូវនោះឯង លុះប្រសូតបុត្តហើយ នាងក៏រម្ងាប់សេចក្តីខ្វល់ខ្វាយដែលចង់ទៅផ្ទះ នាំប្តីត្រឡប់មកវិញ ។ សូម្បីលើកទី ២ នាងក៏មានគភ៌ ពាក្យដែលគួរពោលគប្បីឲ្យពិស្តារ ដោយន័យមុននោះឯង ។ សេចក្តីប្លែកគ្នាមានដូច្នេះថា ត្រង់ពាក់កណ្តាលផ្លូវ ខ្យល់កម្មជវាតបក់ឡើង ភ្លៀងពុំជួកាលក៏ធ្លាក់ចុះមកយ៉ាងធំ ផ្ទៃមេឃធ្លាក់នូវតំណក់ភ្លៀងមិនដាច់ ផ្លេកបន្ទោរជាលច្រវាត់ដោយជុំវិញ សំឡេងផ្គរលាន់គំរាមហាក់ដូចបែកមេឃ នាងឃើញហើយក៏ពោលនឹងប្តីថា សូមអ្នកជួយធ្វើទីបាំងភ្លៀងបន្តិច ប្តីក៏ពិនិត្យមើលក្នុងទីផ្សេងៗ ឃើញគុម្ពឈើមានស្មៅស៊ុមទ្រុមមួយកន្ទែង ទើបទៅក្នុងទីនោះ បំណងនឹងកាប់គុម្ពឈើនោះដោយកាំបិតដែលកាន់ក្នុងដៃ ទើបកាប់ដើមឈើត្រង់គុម្ពឈើនោះខាងចុងដំបូក ដែលមានស្មៅស៊ុមទ្រុម ភ្នាមនោះពស់មានពិសក៏លូនចេញមកពីដំបូកនោះ ចឹកបុរសនោះដួលស្លាប់ក្នុងទីនោះឯង ។ កុលធីតាជួបទុក្ខច្រើន រង់ចាំការត្រឡប់របស់ប្តីឱបកូនទាំង ២ ដែលអត់ធន់នឹងខ្យល់ភ្លៀងមិនបានក៏យំ ដាក់កូនត្រង់ទ្រូងជង្គង់ទាំង ២ និងដៃទាំង ២ ច្រត់ផែនដីយ៉ាងមាំ នៅដោយឥរិយាបថនោះអស់មួយរាត្រី ។ កាលរាត្រីអស់ហើយ ក៏បីកូនមួយដែលមានពណ៌ដូចដុំសាច់ដាក់លើសំពត់ចាស់ ឱបដោយដៃ ផ្ទាប់នឹងដើមទ្រូង ហើយពោលនឹងកូនមួយទៀតថា នែកូន ឪពុករបស់កូនទៅតាមផ្លូវនេះ ហើយដើរទៅតាមផ្លូវ

ដែលប្ដីទៅ ជួបប្ដីដេកស្លាប់ក្បែរដំបូក ក៏ទ្រហោយំថា ព្រោះខ្លួនអញនេះឯង ទើបប្ដីស្លាប់ ។ ធ្វើដំណើរទៅតាមផ្លូវ ដល់ស្ទឹងដែលមានក្រសែទឹកខ្លួលខ្លាញ់ ព្រោះភ្លៀងទើបតែធ្លាក់កាលពីយប់មិញ មិនអាចនាំកូនទាំង ២ ឆ្លងក្នុងពេល តែមួយបាន ព្រោះខ្លួនមានការបេះដឹងតិច និងទន់ខ្សោយ ទើបដាក់កូនច្បង ត្រង់ត្រើយអាយ នាំកូនតូចទៅកាន់ត្រើយនាយ កាច់មែកឈើបាំងកូនតូចឲ្យ ដេកលើកន្ទបចាស់ គិតត្រឡប់មកយកកូនម្នាក់ទៀត តែមិនអាចលះកូនតូច បាន ទើបត្រឡប់ទៅត្រឡប់មក សម្លឹងមើលបណ្ដើរចុះទឹកបណ្ដើរ ។

ខណៈដែលនាងទៅដល់កណ្ដាលស្ទឹង ខ្លែងមួយឃើញទារកនោះ គិត ថាជាដុំសាច់ ទើបសម្ទបស្លាបអំពីអាកាស នាងឃើញខ្លែងនោះ ក៏លើកដៃ ទាំង ២ ដេញ ធ្វើសំឡេងខ្លាំងៗ ៣ ដងថា សុ សុ ខ្លែងមិនចាប់អារម្មណ៍ក្នុង អាការរបស់នាងព្រោះនៅឆ្ងាយ ក៏ឆាបយកទារកនោះ ហើរទៅក្នុងអាកាស កូនច្បង ដែលឈរត្រង់ត្រើយអាយ ឃើញមាតាលើកដៃទាំង ២ ស្រែក ដោយសំឡេងខ្លាំងគិតថា ម្ដាយហៅ ក៏លោតចូលទឹកដោយរហ័ស កូនតូច ត្រូវខ្លែងឆាបទៅ កូនច្បងត្រូវទឹកកួចទៅដោយប្រការដូច្នេះ ។ កុលធីតាទ្រ-ហោយំថា កូនខ្ញុំមួយត្រូវខ្លែងឆាបទៅ កូនមួយត្រូវទឹកកួចទៅ ប្ដីខ្ញុំក៏ស្លាប់ កណ្ដាលផ្លូវ ដើរទៅជួបបុរសម្នាក់ដែលមកអំពីនគរសាវត្ថី ទើបសួរថា នែ អ្នកអ្នកជាអ្នកស្រុកណា បុរសនោះឆ្លើយថា អើនាងខ្ញុំជាអ្នកស្រុកសាវត្ថី ។ នាងសួរថា ត្រកូលឈ្មោះនោះនៅត្រង់ផ្លូវនោះ ក្នុងក្រុងសាវត្ថី តើអ្នកស្គាល់ ដែរឬទេ បុរសនោះឆ្លើយថា អើនាង ខ្ញុំស្គាល់ តែនាងកុំសួររឿងនោះឡើយ

ចូរសួររឿងដទៃចុះ នាងពោលថា រឿងដទៃខ្ញុំមិនត្រូវការ ខ្ញុំសូមសួររឿងនោះឯង ។ បុរសនោះឆ្លើយថា នែនាង បើខ្ញុំមិនប្រាប់ នាងក៏មិនព្រម ថ្ងៃនេះសូម្បីនាងក៏ឃើញភ្លៀងធ្លាក់មួយយប់ទល់ភ្លឺមែនដែរឬទេ ។ កុលធីតាពោលថា ខ្ញុំឃើញភ្លៀងមួយយប់ទល់ភ្លឺសម្រាប់ខ្ញុំនេះឯង តែខ្ញុំនឹងពោលហេតុនេះខាងក្រោយ សូមអ្នកប្រាប់រឿងក្នុងផ្ទះសេដ្ឋីនោះដល់ខ្ញុំសិនចុះ ។ បុរសនោះពោលថា អើនាង យប់មិញនេះ ផ្ទះបាក់សង្កត់មនុស្សទាំង ៣ គឺលោកសេដ្ឋី ភរិយា និងកូនប្រុស ជនទាំង ៣ នាក់ ត្រូវដុតលើជើងថ្ករតែមួយផ្សែងភ្លើងមិនទាន់បាត់ហុយនៅឡើយ ។ ខណៈនោះ កុលធីតាចាំមិនបានថាខ្លួនប្រាសចាកសំពត់ ដល់នូវភាពជាមនុស្សឆ្កួត ដោយសេចក្តីសោក ទើបនាងរវើរវាយថា

កូនទាំងពីរធ្វើមរណកាលហើយ ទាំងប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងព្រៃ
មានបិតានិងបងប្រុសក៏ត្រូវគេដុតលើជើងថ្ករជាមួយគ្នាដូច្នេះ។

តាំងពីនោះមក នាងក៏មានឈ្មោះថា បដាចារា ព្រោះមានអាចារធ្លាក់ទៅ មិនត្រាច់ទៅដោយសំពត់ សូម្បីត្រឹមតែសំពត់ស្លៀក ។ មនុស្សទាំង-ឡាយឃើញនាង អ្នកខ្លះក៏បាចសំរាមដាក់លើក្បាល ពួកខ្លះក៏បាចអាចម៍ដីពួកខ្លះក៏ចោលដោយដុំដីនិងអង្កត់ឧស ព្រមទាំងបណ្តេញថា ទៅចុះមេមនុស្សឆ្កួត ។ ព្រះសាស្តាកំពុងគង់សម្តែងធម៌ត្រង់កណ្តាលបរិស័ទនាជេតពនមហាវិហារ ទតឃើញនាងកំពុងត្រាច់វិលវល់យ៉ាងនេះ និងទ្រង់រំពឹងមើលដល់ការចាស់ក្លានៃញាណ ទើបទ្រង់អធិដ្ឋានធ្វើដោយអាការដែលនាងបែរមុខមកកាន់

វិហារ ។ បរិស័ទឃើញនាង ទើបពោលថា កុំឲ្យស្រីឆ្កួតមកទីនេះឡើយ ។ ព្រះមានព្រះភាគត្រាស់ថាកុំហាមនាងឡើយ កាលនាងមកដល់ក្នុងទីមិនឆ្ងាយ ទើបត្រាស់ថា ចូរនាងបាននូវសតិចុះ ។ រំពេចនោះនាងក៏បាននូវសតិ ព្រោះពុទ្ធានុភាព ដឹងថាសំពត់ដែលខ្លួនស្លៀកអស់ហើយ កើតនូវហិរិឱត្តប្បៈអង្គុយលុតជង្គង់ បុរសម្នាក់ក៏បោះសំពត់ដណ្តប់ឲ្យ នាងស្លៀកសំពត់នោះហើយ ក៏ចូលគាល់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយក្រាបទូលហេតុដែលគួរឲ្យតក់ស្លុតថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ជាទីពឹងរបស់ខ្ញុំផងចុះ ខ្លែងឆាបកូនរបស់ខ្ញុំម្នាក់ ម្នាក់ទៀតត្រូវទឹកកួចទៅ ប្តីក៏ស្លាប់កណ្តាលអទ្ធា ( ផ្លូវ ) មាតាបិតានិងបងប្រុសផ្ទះបាក់សង្កត់ស្លាប់ដុតត្រង់ជើងថ្ករតែមួយ ។ ព្រះសាស្តាត្រាស់ថា ម្នាលបដាចារា នាងកុំទោមនស្សថ្វីឡើយនាងមករកតថាគតដែលអាចជាទីពឹងនៃនាងបាន ឥឡូវនេះនាងបង្ហូរទឹកភ្នែកព្រោះការស្លាប់របស់កូនជាដើមជាហេតុ យ៉ាងណា ក្នុងសង្សារវដ្ត ដែលមិនមានខាងដើម និងខាងចុងក៏យ៉ាងនោះ ទឹកភ្នែកដែលហូរព្រោះសេចក្តីស្លាប់របស់កូនជាដើម ច្រើនជាងទឹករបស់មហាសមុទ្រទាំង ៤ កាលទ្រង់សម្តែងធម៌ទើបត្រាស់គាថាថា

ទឹកក្នុងមហាសមុទ្រទាំង ៤ នៅមានប្រមាណតិច ទឹកភ្នែក
របស់នរជនដែលត្រូវសេចក្តីទុក្ខពាល់ត្រូវហើយសោយសោក
មិនមែនតិច មានប្រមាណច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤
នោះទៅទៀត ម្នាលនាង ហេតុអ្វីទើបនាងប្រមាទ ដូច្នេះ ។

កាលព្រះសាស្តាកំពុងត្រាស់កថា បរិយាយអំពីសង្សារវដ្តដែលមិនមានទីបំផុតខាងដើមនិងខាងចុងហើយ សេចក្តីសោករបស់នាងក៏ស្រាកស្រាន ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបថា នាងមានសេចក្តីសោកធូរស្រាលហើយ កាលទ្រង់សម្តែងថា ម្នាលបជាចារា ឈ្មោះថា បិយជនមានបុត្តជាដើម ក៏មិនអាចជាទីជ្រកកោន ឬជាទីពឹងរបស់បុគ្គល ដែលកំពុងទៅកាន់បរលោកបានឡើយ ដូច្នោះបិយជនទាំងនោះសូម្បីមាន ក៏ឈ្មោះថា មិនមាន ព្រោះហេតុនោះបណ្ឌិតគប្បីជម្រះសីលរបស់ខ្លួន ហើយជម្រះផ្លូវទៅកាន់ព្រះនិព្វានឲ្យសម្រេច ដូច្នេះ ទើបទ្រង់សម្តែងធម៌ដោយគាថាទាំងនេះថា

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន ។ សច្ចៈ ១ ធម្មៈ ១ អហឹសា ១ សញ្ញមៈ ១ ទមៈ ១ មាននៅក្នុងបុគ្គលណា ព្រះអរិយទាំងឡាយ រមែងសេពគប់នូវបុគ្គលនុ៎ះ គុណជាតនុ៎ះឈ្មោះថា មិនចេះស្លាប់ ក្នុងលោក ។ បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឲ្យបាន ដូច្នេះ[១] ។

---

១-គាថាពីរ គឺគាថាខាងដើមនិងខាងចុង មានក្នុងធម្មបទ ឯគាថាមួយត្រង់កណ្តាលមានក្នុងឧបសាឡ្ហកជាតក ។

ចប់ទេសនា នាងបដាចារាក៏តាំងនៅក្នុងសោតាបត្តិផល ទូលសូមបព្វជ្ជាជាមួយព្រះសាស្តា ព្រះសាស្តាទ្រង់នាំទៅកាន់សម្នាក់ភិក្ខុនី ឲ្យបព្វជ្ជា នាងបានឧបសម្បទាហើយ ក៏ធ្វើកិច្ចកម្មក្នុងវិបស្សនា ដើម្បីមគ្គខាងលើតទៅ ។ ថ្ងៃមួយ យកក្អមទឹកមកលាងជើង ទឹកនោះក៏ហូរទៅបន្តិច ហើយក៏រីងស្ងួតទៅ ចាក់លើកទី ២ ទឹកក៏ហូរបានឆ្ងាយជាងលើកទី ១ នោះ លើកទី ៣ ទឹកក៏ហូរទៅបានឆ្ងាយជាងលើកទី ២ នោះ នាងទាញយកទឹកនោះឯងមកជាអារម្មណ៍កំណត់ដោយវ័យទាំង ៣ គិតថា សត្វទាំងនេះស្លាប់ក្នុងបឋមវ័យក៏មាន ដូចទឹកដែលអញចាក់ដំបូង ស្លាប់ក្នុងមជ្ឈិមវ័យក៏មាន ដូចទឹកដែលអញចាក់លើកទី ២ ដែលហូរទៅឆ្ងាយជាងលើកទី ១ ស្លាប់ក្នុងបច្ឆិមវ័យក៏មានដូចទឹកដែលអញស្រោចលើកទី ៣ ដែលហូរទៅឆ្ងាយជាងលើកទី ២ ។ ព្រះសាស្តា គង់ក្នុងព្រះគន្ធកុដិ ទ្រង់ផ្សាយរស្មីទៅ ហាក់ដូចគង់ក្នុងទីចំពោះមុខ កាលទ្រង់សម្តែងសេចក្តីនេះថា ម្នាលបដាចារា សេចក្តីនោះ យ៉ាងនោះឯង សត្វទាំងអស់សុទ្ធតែមានការស្លាប់ជាធម្មតា ព្រោះដូច្នោះ បុគ្គលដែលឃើញការកើត ការវិនាសរបស់បញ្ចក្ខន្ធ មានជីវិតរស់នៅមួយថ្ងៃក្តី មួយខណៈក្តី គង់ប្រសើរជាងបុគ្គលដែលមិនឃើញការកើតនិងការវិនាសនោះទោះបីមានជីវិតរស់នៅរាប់រយឆ្នាំ ទើបត្រាស់គាថា ( ក្នុងធម្មបទថា ) ថា

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើងនិង
ការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែល
ឃើញការកើតឡើងនិងការវិនាសទៅ ប្រសើរជាង ដូច្នេះ ។

លុះចប់ព្រះគាថា បដាចារាភិក្ខុនី ក៏សម្រេចអរហត្តមួយអន្លើដោយបដិ-សម្ភិទា ៤ សមដូចគាថាព័ន្ធដែលលោកពោលក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួងជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំពីកប្បនេះ ។ ក្នុងគ្រានោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្នុងនគរហង្សវតី រុងរឿងដោយរតនៈផ្សេងៗ ។ ជាស្រីឆ្អែតស្កប់ស្កល់ ដោយសេចក្តីសុខច្រើនយ៉ាង ។ ខ្ញុំបានចូលទៅគាល់ព្រះអង្គជាមហាវីរបុរសនោះ បានស្តាប់ធម្មទេសនា លំដាប់នោះ ខ្ញុំកើតសេចក្តីជ្រះថ្លា ហើយដល់នូវព្រះជិនស្រីជាទីពឹង ។ លំដាប់នោះ ព្រះពុទ្ធជានាយក ទ្រង់សរសើរភិក្ខុនីជាអ្នកអៀនខ្មាស មានចិត្តនឹងធឹង ក្លៀវក្លាក្នុងហេតុគួរនិងមិនគួរជាភិក្ខុនីខ្ពង់ខ្ពស់ជាងភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់នូវវិន័យ ។ ក្នុងកាលនោះ ខ្ញុំមានចិត្តរីករាយ ប៉ុនប៉ងចំពោះតំណែងនោះ ហើយនិមន្តព្រះទសពលជាលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់អស់ ៧ ថ្ងៃ ហើយបានថ្វាយបាត្រនិងចីវរ ក្រាបទៀបព្រះបាទាដោយត្បូង ហើយពោលពាក្យនេះថា បពិត្រព្រះមុនីជាធីរបុរសភិក្ខុ-នីណា ដែលព្រះអង្គសរសើរហើយ បពិត្រព្រះអង្គជានាយក ខ្ញុំម្ចាស់សូមឲ្យបានដូចភិក្ខុនីនោះ ក្នុងកប្បទី ៨ អំពីកប្បនេះ បើសេចក្តីប្រាថ្នានឹងសម្រេច ។ ក្នុងកាលនោះ ព្រះសាស្តា

បានត្រាស់នឹងខ្ញុំថា ម្នាលនាងដ៏ចម្រើន នាងកុំខ្លាច ចូរនាង ត្រេកអរចុះក្នុងកាលអនាគត នាងនឹងបានតំណែងទុំះ ដូចចិត្ត ប្រាថ្នា ។ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូល ក្សត្រឱក្កាកៈ នឹងមានក្នុងលោក ក្នុងកប្បទី ១ សែន អំពី កប្បនេះ ។ នាងនឹងបានជាផៅពង្សក្នុងធម៌ទាំងឡាយនៃព្រះ សាស្តាអង្គនោះ ជាឱរសជាធម្មនិម្មិត មានឈ្មោះថា នាងបដា ចារា ជាសាវិការបស់ព្រះសាស្តា ។ ក្នុងគ្រានោះ ខ្ញុំមានចិត្ត រីករាយ មានមេត្តាចិត្តបម្រើព្រះជិនស្រីជាលោកនាយក ព្រម ទាំងព្រះសង្ឃដរាបអស់ជីវិត ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះ ផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាង កាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធព្រះនាមកស្សប មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងពួកជនអ្នកពោល ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ក្នុងកាលនោះ ព្រះរាជាក្នុងដែនកាសីព្រះនាមកិកី ជាឧបដ្ឋាក របស់ព្រះពុទ្ធជាមហេសី ជាឥស្សរៈលើប្រជាជន ក្នុងក្រុង ពារាណសីបុរីដ៏ឧត្តម ។ ខ្ញុំបានជាធីតាទី ៣ នៃព្រះបាទកិកី នោះដែលប្រាកដថាភិក្ខុនី បានស្តាប់ធម៌របស់ព្រះជិនស្រីដ៏ប្រ- សើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ តែក្នុងកាលនោះ ព្រះបិតា របស់យើងទ្រង់ពុំអនុញ្ញាត យើងក៏ជាស្ត្រីមិនខ្ជិលប្រអូសបាន

ប្រព្រឹត្តព្រហ្មចរិយសម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំនៅក្នុងផ្ទះ ជាព្រះរាជកញ្ញា ឋិតនៅក្នុងសេចក្ដីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាធីតា ៧ អង្គ គឺ នាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគម្រប់ ៧ ។ ( រាជកញ្ញាទាំងនោះលុះចេរវិលវឹងមកក្នុងពុទ្ធុប្បាទនេះ ) បានមកជា ខ្ញុំ ១ ឧប្បលវណ្ណា ១ ខេមា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ ៧ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុក នូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថីជាបុរីដ៏ប្រសើរមាំមួន ស្តុកស្តម្ភ មានធនធានច្រើន ។ ខ្ញុំកំពុងប្រកបដោយវ័យដ៏ចម្រើន លុះក្នុងអំណាចនៃវិតក្កៈ ខ្ញុំបានឃើញនូវបុរស អ្នកនៅក្នុងជនបទហើយ ក៏បានទៅនៅជាមួយនឹងបុរសនោះ ។ ខ្ញុំមានបុត្តប្រុស ១ នាក់ ប្រសូតហើយ បុត្ត ទី ២ នៅក្នុងផ្ទៃរបស់ខ្ញុំ ក្នុងកាលនោះខ្ញុំកាត់ចិត្តថា អញត្រូវទៅរកជួបមាតាបិតាវិញ ។ គ្រានោះខ្ញុំមិនបានប្រាប់ស្វាមីរបស់ខ្ញុំទេ លុះស្វាមីនោះឃ្លាតចេញទៅ ខ្ញុំជាស្ត្រីតែម្នាក់ឯង រត់ចេញចាកផ្ទះ ដើរទៅកាន់ក្រុងសាវត្ថីដ៏ឧត្តម ។ លំដាប់

នោះប្តីរបស់ខ្ញុំមកតាមទាន់ក្នុងផ្លូវបបួលខ្ញុំទៅវិញ ក្នុងគ្រានោះ ខ្យល់កម្មជវាត ( ខ្យល់កើតអំពីកម្ម ) ដ៏អាក្រក់ពន់ពេកកើតឡើងដល់ខ្ញុំ ។ ស្រាប់តែភ្លៀងធំតាំងឡើង ក្នុងសម័យជាទីប្រសូតិនូវកូននៃខ្ញុំ គ្រានោះប្តី ( របស់ខ្ញុំ ) ទៅដើម្បីប្រយោជន៍ដល់ឱសថ ត្រូវពស់ចឹកស្លាប់ទៅ ។ គ្រានោះ ខ្ញុំជាស្រីកំព្រា មិនមានទីពឹងដោយសេចក្តីទុក្ខ ព្រោះសម្រាលកូន ខ្ញុំដើរទៅកាន់លំនៅនៃត្រកូលរបស់ខ្លួន ឃើញនូវស្ទឹងតូចមានទឹកពេញព្រៀប ។ ខ្ញុំជាស្រីម្នាក់ឯង នាំយកកូនតូច ឆ្លងទៅដាក់ឯច្រាំងត្រើយនាយ ហើយញុំាងកូនតូចឲ្យបៅ រួចត្រឡប់មកចម្លងកូនបង ។ មានសត្វខ្លែងមួយឆាបយកកូនតូច ដែលកំពុងយំ ទាំងខ្សែទឹកក៏កួចយកកូនបងទៅទៀត ខ្ញុំជាស្រីចុកណែនដោយសេចក្តីសោក ។ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី បានឮថា ពួកជនរបស់ខ្លួន គឺមាតាបិតាត្រូវស្លាប់អស់ហើយ គ្រានោះខ្ញុំមានសេចក្តីសោកគ្របសង្កត់ ចុកណែន ដោយសេចក្តីសោកដ៏ធំហើយបានពោលថា កូនទាំងពីរធ្វើមរណកាលហើយ ទាំងប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងព្រៃ មាតាបិតានិងបងប្រុសក៏ត្រូវគេដុតលើជើងថ្ករជាមួយគ្នា កាលនោះខ្ញុំជាស្រីស្គាំងស្គមផង កើតរោគលឿងផង ឥតមានទីពឹង មានចិត្តប្រកបដោយសេចក្តីទុក្ខលំដាប់នោះ ខ្ញុំដើរចេញទៅអំពីទីនេះ បានឃើញព្រះពុទ្ធ

ព្រះអង្គជាសារថី របស់ប្រជាជន ។ លំដាប់នោះ ព្រះសាស្តា ទ្រង់ត្រាស់ចំពោះខ្ញុំថា នាងចូរកុំសោកស្តាយ ចំពោះកូនទាំងឡាយឡើយ ចូរនាងស្រស់ស្រាយឡើង ចូរនាងស្វែងរកខ្លួនរបស់នាងវិញ នាងព្រួយឥតប្រយោជន៍សោះទេ ។ កូនទាំងឡាយពឹងពុំបាន ញាតិក៏ពឹងពុំបាន ទាំងផៅពង្សក៏ពឹងពុំបាន បុគ្គល ដែលត្រូវសេចក្តីស្លាប់គ្របសង្កត់ ទីពឹងចំពោះញាតិពុំបានឡើយ ។ លុះខ្ញុំបានស្តាប់ព្រះវាចានោះរបស់ព្រះមុនី ក៏បាននូវផលទី ១ ខ្ញុំបួសមិនយូរប៉ុន្មាន ក៏បានសម្រេចនូវព្រះអរហត្ត ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងសោតធាតុជាទិព្វផង ខ្ញុំជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា រមែងដឹងនូវចិត្តនៃបុគ្គលដទៃផង ។ ខ្ញុំដឹងនូវបុព្វេនិវាស ទាំងទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធឥតមានមន្ទិល ព្រោះបានញ៉ាំងអាសវៈទាំងពួងឲ្យអស់ហើយ ។ លំដាប់នោះ ខ្ញុំបានរៀនវិន័យទាំងអស់ក្នុងសំណាក់របស់ព្រះពុទ្ធ ព្រះអង្គឃើញហេតុទាំងអស់ផង ខ្ញុំឆ្លើយដោះស្រាយនូវសេចក្តីពិស្តារគ្រប់យ៉ាង តាមពិតផង ។ ព្រះជិនស្រីត្រេកអរចំពោះគុណនោះហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈថា នាងបដាចារាជាភិក្ខុនីឯក ប្រសើរជាងពួកភិក្ខុនី អ្នកទ្រទ្រង់វិន័យ ។ ព្រះសាស្តា ខ្ញុំបានប្រព្រឹត្តតាមហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់

ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណធម៌ណា ប្រយោជន៍គឺគុណធម៌នោះរបស់ខ្ញុំជាទីអស់ទៅនៃសញ្ញោជនៈទាំងពួងខ្ញុំក៏បានសម្រេចហើយ។ កិលេសទាំងឡាយ ខ្ញុំផ្ចុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលបដាចារាថេរីសម្រេចអរហត្តហើយ ពិចារណាដល់ការបដិបត្តិនៃខ្លួនក្នុងពេលជាសេក្ខបុគ្គល កាលចង់លបង្ហាញអាការដែលនាងធ្វើផលខាងលើឲ្យកើតឡើង ទើបពោលគាថាទាំងនេះជាឧទានថា

ពួកមាណពភ្ជួរស្រែ ដោយនង្គ័លទាំងឡាយ ហើយព្រោះពូជទាំងឡាយលើផែនដី តែងបាននូវទ្រព្យចិញ្ចឹមកូន និងប្រពន្ធទាំងឡាយ ។

អាត្មាអញបរិបូណ៌ដោយសីល មិនខ្ជិលមិនរវើរវាយ ធ្វើតាមសាសនារបស់ព្រះសាស្តា ដូចម្តេចក៏មិនបានព្រះនិព្វាន ។ អាត្មាអញលាងជើងក្នុងទឹក ឃើញទឹកសម្រាប់លាងជើង ហូរអំពីទីទួលមកកាន់ទីទាបហើយធ្វើ (ឲ្យជានិមិត្ត) ក្នុងទឹកទាំងឡាយ លំដាប់ពីនោះមកអាត្មាអញក៏បានតម្កល់ចិត្តមាំ ដូចសេះអាជានីយដ៏ចម្រើន ។ លំដាប់នោះ អាត្មាអញកាន់ប្រទីប ចូលទៅកាន់លំនៅ រមិលមើលដំណេកហើយអង្គុយលើគ្រែតូច ។ ក្នុង

កាលនោះអាត្មាអញកាន់វន្ទុកទ្វារ ហើយបន្ទឹមចុះនូវប្រឆេះ ( នៃប្រទីប ) ចិត្តក៏បានរួចស្រឡះចាកកិលេស ដូចជាការរលត់នៃប្រទីប ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កសំ** ស្មើគ្នានឹង **កសន្តា** ប្រែថា ភ្ជួរស្រែបានដល់ ធ្វើកសិកម្ម សេចក្ដីពិត ពាក្យនេះជាឯកវចនៈ ប្រើក្នុងអត្ថពហុវចនៈ ។ បទថា **បវបំ** បានដល់ ព្រោះនូវគ្រាប់ពូជ ។ បទថា **ឆមា** ស្មើគ្នានឹង **ឆមាយំ** ប្រែថា លើផែនដី ។ សេចក្ដីពិត ពាក្យនេះជាបឋមាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ ក្នុងសេចក្ដីនេះ មានសេចក្ដីសង្ខេបដូចតទៅនេះថា បុរស គឺសត្វទាំងនេះ ភ្ជួរស្រែដោយនង្គ័ល គឺផាលទាំងឡាយ សាបព្រោះនូវពូជទាំងឡាយ មានបុព្វណ្ណជាតិខ្លះ អបរណ្ណជាតិខ្លះ លើផែនដី តាមដែលបំណងរមែងបានទ្រព្យមកចិញ្ចឹមខ្លួននិងបុត្តភរិយាជាដើម ព្រោះការភ្ជួរស្រែនិងសាបព្រោះពូជនោះជាហេតុ ជានិមិត្ត ធម្មតាការធ្វើរបស់កូនប្រុស គឺសេចក្ដីព្យាយាមចំពោះខ្លួនដែលបុគ្គលប្រកបដោយឧបាយក្នុងលោកនេះគង់មានផលកម្រៃយ៉ាងនោះ ។

បណ្ដាបទទាំងនោះ បទថា **កិមហំ សីលសម្បន្នា សត្ថុសាសនការិកា និព្វានំ នាធិគច្ឆាមិ អកុសីតា អនុទ្ធតា** សេចក្ដីថា ខ្ញុំមានសីលបរិសុទ្ធល្អ ឈ្មោះថា **អកុសីតា** ព្រោះជាអ្នកប្រារព្ធព្យាយាម និងឈ្មោះថា **អនុទ្ធតា** ព្រោះជាអ្នកមានចិត្តតាំងមាំល្អខាងក្នុង ធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ពោលគឺចម្រើនកម្មដ្ឋានដែលមានសច្ចៈ ៤ ជាអារម្មណ៍ហេតុ

អ្វីមិនសម្រេច គឺមិនដល់ព្រះនិព្វាននោះ ។

ព្រះថេរីកាលគិតយ៉ាងនេះហើយចម្រើនវិបស្សនា ថ្ងៃមួយកាន់យកនិមិត្តក្នុងទឹកលាងជើង ដោយហេតុនោះ ទើបព្រះថេរីពោលថា **បាទេ បក្ខាលយិត្វាន** ជាដើម ។ ពាក្យនោះមានសេចក្ដីថា កាលខ្ញុំលាងជើង បណ្ដាទឹកដែលចាក់ ៣ ដង ក៏ឃើញទឹកលាងជើងហូរអំពីទីទួលមកកាន់ទីទាប ធ្វើឲ្យជានិមិត្ត ។

ខ្ញុំពិចារណាអនិច្ចលក្ខណៈយ៉ាងនេះថា ទឹកនេះអស់ទៅវិនាសទៅជាធម្មតាយ៉ាងណា អាយុនិងសង្ខាររបស់សត្វទាំងឡាយ ក៏យ៉ាងនោះ កាលពិចារណាទុក្ខលក្ខណៈនិងអនត្តលក្ខណៈតាមគន្លងនោះចម្រើនវិបស្សនា បន្ទាប់អំពីនោះអាត្មាអញក៏បានតម្កល់ចិត្តមាំ ដូចសេះអាជានីយដ៏ចម្រើន អធិប្បាយថា សារថីអ្នកឈ្លាសទូន្មានសេះអាជានេយ្យដែលជាសត្វពិសេស ឲ្យស្ដាប់បង្គាប់ដោយងាយយ៉ាងណា ខ្ញុំទូន្មានចិត្តរបស់ខ្ញុំឲ្យតាំងមាំដោយងាយ ក៏យ៉ាងនោះ បានធ្វើចិត្តឲ្យតាំងមាំហើយ ដោយសមាធិដែលសម្បយុត្តដោយវិបស្សនា ។ ម្យ៉ាងទៀត ខ្ញុំកាលចម្រើនវិបស្សនាយ៉ាងនោះ ចូលកាន់បន្ទប់តូចដើម្បីឧតុជាទីសប្បាយកាន់ប្រទីបដើម្បីកម្ចាត់ងងឹត ចូលបន្ទប់ហើយដាក់ប្រទីប អង្គុយលើគ្រែ ក៏មួលប្រឆេះប្រទីបឡើងចុះដើម្បីសម្ងំប្រទីប រំពេចនោះឯង ចិត្តរបស់ខ្ញុំក៏តាំងមាំព្រោះបានឧតុជាទីសប្បាយ ឈមចុះកាន់វិថីនៃវិបស្សនាបន្តដោយមគ្គ បន្ទាប់អំពីនោះអាសវៈទាំងឡាយ ក៏អស់ទៅដោយប្រការទាំងពួងតាមលំដាប់មគ្គ ដោយហេតុនោះទើបព្រះថេរីពោលថា ក្នុងកាលនោះ អាត្មា

អញ្ចកាន់វនុកទ្វារហើយបន្ទឹមចុះនូវប្រឆេះ ( នៃប្រទីប ) ។បេ។ ដូចជាការរលត់នៃប្រទីប ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សេយ្យំ ឱលោកយិត្វាន** បានដល់ មើលនូវទីដេកដោយពន្លឺនៃប្រទីប ។ បទថា **សូចឹ** បានដល់ វនុកទ្វារ ។ បទថា **វដ្ដឹ ឱកស្សយាមិ** បានដល់ មួលប្រឆេះប្រទីបឡើងចុះ ដើម្បីលត់ប្រទីប ។ បទថា **វិមោក្ខោ** បានដល់ រួចផុតចាកកិលេសទាំងឡាយ ។ ព្រោះវិមោក្ខនោះ ដោយបរមត្ថ បានដល់ ការបន្តនៃចិត្តបរមត្ថ ដោយហេតុនោះ ទើបព្រះថេរីពោលថា **ចេតសោ** ដូច្នេះ ។ កាលបច្ច័យមានប្រឆេះនិងប្រេងមានប្រទីបគួរឆេះឡើង លោកហៅថារលត់ ព្រោះមិនមានបច្ច័យនោះ យ៉ាងណា កាលបច្ច័យមានកិលេសជាដើមមាន ចិត្តគួរកើតឡើងលោកហៅថារលត់ព្រោះកាលមិនមានបច្ច័យនោះ ក៏កើតឡើងមិនបាន ក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបព្រះថេរីពោលថាចិត្ត ក៏បានរួចស្រឡះចាកកិលេសដូចជាការរលត់នៃប្រទីប ដូច្នោះ ។

## អដ្ឋកថាបដាចារាថេរីគាថា ចប់

# តឹសមត្ថាថេរីគាថា

[ ៣១៣ ] ពួកមាណព កាន់អង្រែទាំងឡាយបុកស្រូវតែងបាននូវទ្រព្យទាំងឡាយចិញ្ចឹមកូននិងប្រពន្ធ ។ ពួកនាងចូរធ្វើនូវពុទ្ធសាសនាដែលគេធ្វើហើយមិនក្តៅក្រហាយតាមក្រោយ ចូរលាងជើងទាំងឡាយឲ្យឆាប់ ហើយអង្គុយក្នុងទីសមគួរប្រកបរឿយៗនូវសេចក្តីស្ងប់ចិត្តហើយចូរធ្វើនូវពុទ្ធសាសនាចុះ។

ភិក្ខុនីទាំងនោះ បានស្តាប់ពាក្យប្រៀនប្រដៅរបស់បដាចារាថេរីនោះហើយក៏លាងជើងហើយចូលទៅក្នុងទីសមគួរប្រកបរឿយៗនូវសមថធម៌ បានធ្វើនូវ ( កិច្ចក្នុង ) ពុទ្ធសាសនា ។ ក្នុងបឋមយាមនៃរាត្រី ពួកព្រះថេរីក៏បានរឭកឃើញនូវបុព្វជាតិក្នុងមជ្ឈិមយាមនៃរាត្រីបានជម្រះនូវទិព្វចក្ខុ ក្នុងបច្ឆិមយាមនៃរាត្រី ក៏បានទម្លាយនូវគំនរងងឹត ។ ពួកព្រះថេរីទាំងនោះ ក្រោកឡើងថ្វាយបង្គំបាទា ( នៃបដាចារាថេរីហើយពោលថា ) ពាក្យប្រៀនប្រដៅរបស់នាងយើងបានធ្វើតាមហើយ ពួកទេវតានៅក្នុងឋានត្រៃត្រិង្ស ( ហែហម ) ព្រះឥន្ទ្រដែលបានឈ្នះក្នុងសង្គ្រាមយ៉ាងណា ពួកយើងជាអ្នកមានវិជ្ជាបី មិនមានអាសវៈនឹងនៅហែហម ( នាងយ៉ាងនោះ ) ។

ពួកភិក្ខុនីជាថេរីចំនួន ៣០ រូបនេះ បានធ្វើឲ្យច្បាស់លាស់នូវព្រះអរហត្តក្នុងសំណាក់នៃបដាចារាថេរី ។

## អដ្ឋកថា

## តឹសមត្តាថេរីគាថា

[ ៣១៣ ] គាថារបស់ព្រះថេរី ៣០ មានពាក្យផ្ដើមថា **មុសលានិ គ-ហេត្វាន** ដូច្នេះជាដើម ។

កុលធីតាទាំងនោះ ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ សន្សំបុណ្យដើម្បីរួចផុតដោយលំដាប់ ក្នុងពុទ្ធុប្បាទនេះត្រូវកម្មរបស់ខ្លួនដាស់តឿនហើយកើតក្នុងផ្ទះមានត្រកូលផ្សេងៗគ្នា ដល់នូវភាពជាអ្នកដឹងក្ដីហើយស្ដាប់ធម៌ក្នុងសម្នាក់ព្រះនាងបដាចារាថេរី បាននូវសទ្ធាហើយនាំគ្នាចេញបួសមានសីលបរិសុទ្ធ បំពេញវត្តបដិបត្តិ ថ្ងៃមួយ ព្រះនាងបដាចារាថេរីកាលឲ្យឱវាទដល់ភិក្ខុនីទាំងនោះ ទើបបានពោលគាថា ២ ថា

> ពួកមាណព កាន់អង្រែទាំងឡាយបុកស្រូវ តែងបាននូវទ្រព្យ
> ទាំងឡាយ ចិញ្ចឹមកូននិងប្រពន្ធ ។ ពួកនាងចូរធ្វើនូវពុទ្ធសាសនា
> ដែលគេធ្វើហើយ មិនក្ដៅក្រហាយតាមក្រោយ ចូរលាងជើង
> ទាំងឡាយឲ្យឆាប់ ហើយអង្គុយក្នុងទីសមគួរ ប្រកបរឿយៗ
> នូវសេចក្ដីស្ងប់ចិត្ត ហើយចូរធ្វើនូវពុទ្ធសាសនាចុះ ដូច្នេះ ។

ក្នុងគាថានោះ មានសេចក្ដីសង្ខេបដូច្នេះថា សត្វ ( មាណព ) ទាំងនេះកាន់អង្រែបុកស្រូវធ្វើការបុកស្រូវឲ្យអ្នកដទៃ គឺធ្វើការស៊ីឈ្នួលបុកស្រូវចិញ្ចឹមជីវិត ធ្វើការងាររថោកថយបែបនេះដទៃទៀត សន្សំទ្រព្យបានសមគួរ ចិញ្ចឹម

បុត្តកិរិយា តែការងាររបស់សត្វទាំងនោះ ជាការងារថោកថយ ជាការងាររបស់បុថុជ្ជន ជាទុក្ខ និងមិនប្រកបដោយប្រយោជន៍ ព្រោះដូច្នោះ នាងទាំងឡាយចូរលះការងារយឺតយូរ ដែលប្រកបដោយសេចក្តីសៅហ្មងបែបនេះហើយធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺចូរធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធពោលគឺត្រៃសិក្ខា បានដល់ ចូរឲ្យកើតក្នុងសន្តានរបស់ខ្លួន ព្រះថេរីបានពោលហេតុក្នុងរឿងនោះថា ដែលគេធ្វើហើយ មិនក្តៅក្រហាយតាមក្រោយ បានដល់ ព្រោះធ្វើតាមពាក្យប្រៀនប្រដៅណា ការក្តៅក្រហាយមិនជាប់តាមមកក្នុងបច្ចុប្បន្ននិងអនាគត ។ ឥឡូវនេះ ដើម្បីសម្តែងកិច្ចខាងដើមនិងវិធីប្រកបរឿយៗក្នុងការធ្វើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះ ទើបព្រះថេរីពោលថា **ខិប្បំ ធានានិ ធោវិត្វា** ជាដើម ។ ក្នុងពាក្យនោះ ព្រោះសេចក្តីសុខក្នុងការអង្គុយ និងការបានឧត្តុជាទីសប្បាយ មិនមានដល់អ្នកមិនលាងជើងមិនលុបមុខ តែការអង្គុយនិងការបាននូវឧត្តុជាទីសប្បាយមានដល់អ្នកលាងជើង និងលុបមុខហើយអង្គុយក្នុងទីគួរ ទើបព្រះថេរីពោលថា នាងទាំងឡាយ កុំឃ្លៀងឃ្លាតចាកខណៈតាមដែលបានហើយនេះ ចូរប្រញាប់លាងជើងរបស់ខ្លួនហើយអង្គុយក្នុងទីសមគួរ គឺក្នុងឱកាសស្ងាត់ នាងទាំងឡាយចូរបង្ខចិត្តរបស់ខ្លួនទុកក្នុងអារម្មណ៍ ៣៨ ចំពោះអារម្មណ៍ដែលគាប់ចិត្តឯណានីមួយ ប្រកបនូវការស្ងប់ចិត្តរឿយៗ ចូរធ្វើនូវសាសនា គឺឱវាទានុសាសនីរបស់ព្រះពុទ្ធដោយការចម្រើនកម្មដ្ឋាន មានសច្ចៈ ៤ ជាអារម្មណ៍ ដោយចិត្តដែលតាំងមាំចុះ ។

កាលនោះ ភិក្ខុនីទាំងនោះ តាំងនៅក្នុងឱវាទរបស់ព្រះថេរីនោះ ផ្តើមវិបស្សនា ធ្វើនូវភាវនា សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ព្រោះមានញាណចាស់ក្លានិងព្រោះសម្បូរដោយហេតុ កាលពិចារណាដល់ការបដិបត្តិរបស់ខ្លួនបានពោលគាថាទាំងនេះមួយអន្លើដោយគាថាដែលជាឱវាទរបស់ព្រះនាងបដាចារាថេរីថា

ភិក្ខុនីទាំងនោះ បានស្តាប់ពាក្យប្រៀនប្រដៅរបស់បដាចារាថេរី
នោះហើយ ក៏លាងជើងហើយចូលទៅក្នុងទីសមគួរ ប្រកប
រឿយៗនូវសមថធម៌ បានធ្វើនូវ ( កិច្ចក្នុង ) ពុទ្ធសាសនា ។
ក្នុងបឋមយាមនៃរាត្រីពួកព្រះថេរីក៏បានរឭកឃើញនូវបុព្វជាតិ
ក្នុងមជ្ឈិមយាមនៃរាត្រី បានជម្រះនូវទិព្វចក្ខុ ក្នុងបច្ឆិមយាម
នៃរាត្រី ក៏បានទម្លាយនូវគំនរងងឹត ។ ពួកព្រះថេរីទាំងនោះ
ក្រោកឡើងថ្វាយបង្គំបាទា ( នៃបដាចារាថេរីហើយពោលថា )
ពាក្យប្រៀនប្រដៅរបស់នាង យើងបានធ្វើតាមហើយ ពួកទេវ
តានៅក្នុងឋានត្រៃត្រិង្ស ( ហែហម ) ព្រះឥន្ទ្រដែលបានឈ្នះ
ក្នុងសង្គ្រាមយ៉ាងណា ពួកយើងជាអ្នកមានវិជ្ជាបីមិនមានអា-
សវៈនឹងនៅហែហម ( នាងយ៉ាងនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្សា តា វចនំ សុត្វា វដាចារាយ សាសនំ** សេចក្តីថា ពាក្យប្រៀនប្រដៅដែលជាឱវាទនោះៗរបស់បដាចារាថេរីនោះ ឈ្មោះថា **សាសនំ** ព្រោះអត្ថថា ជាពាក្យប្រៀនប្រដៅ ឲ្យលះ

នូវកិលេសទាំងឡាយ ភិក្ខុនី ៣០ រូបនោះស្តាប់ហើយទទួល គឺទទួលដោយសិរសា ។

បទថា **ឧដ្ឋាយ បាទេ វន្ទិសុ កតា តេ អនុសាសនី** សេចក្តីថា ភិក្ខុនីទាំងនោះធ្វើទុកក្នុងផ្ទឹងគឺធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅតាមដែលស្តាប់មក ហើយអង្គុយការនាក្នុងទីតាមសប្បាយ ធ្វើការនាឲ្យដល់ទីបំផុតហើយ ដើម្បីប្រាប់គុណវិសេសដែលខ្លួនសម្រេច ទើបក្រោកចាកអាសនៈ ចូលទៅរកព្រះថេរីពោលថា បពិត្រអ្នកនាងម្ចាស់ជាមហាថេរីពួកខ្ញុំធ្វើតាមអនុសាសនីរបស់ព្រះនាងម្ចាស់ តាមដែលប្រៀនប្រដៅហើយ ហើយថ្វាយបង្គំបាទារបស់ព្រះថេរីដោយបញ្ចង្គប្រតិស្ឋាន ។ បទថា **ឥន្ទំវ ទេវា តិទសា សង្គាមេ អបរាជិតំ** សេចក្តីថា បពិត្រមហាថេរី ពួកខ្ញុំចោមរោមនាងដូចទេវតាជាន់តាវត្តិង្សចោមរោមព្រះឥន្ទ ដែលជាអ្នកមិនចាញ់ គឺឈ្នះក្នុងសង្គ្រាមរវាងទេវតានិងអសុរ ព្រោះមិនមានកិច្ចដទៃដែលត្រូវធ្វើ ព្រោះហេតុនោះ កាលភិក្ខុនីទាំងនោះ ប្រកាសភាពដែលខ្លួនជាអ្នកសម្រេចព្រះនិព្វានថា ពួកយើងជាអ្នកមានវិជ្ជាបី មិនមានអាសវៈ ។ ពាក្យនេះស្មើគ្នានឹងពាក្យព្យាករណ៍អរហត្តរបស់ភិក្ខុនីទាំងនោះផងដែរ ។ តែបើពោលដោយអត្ថក្នុងពាក្យនេះ ក៏មានអត្ថដទៃ គឺមានន័យដូចពោលហើយខាងដើមនោះឯង ។

## អដ្ឋកថាតឹសមត្តាថេរីគាថា ចប់

# ចន្ទាថេរីគាថា

[ ៣១៤ ] កាលពីដើម អាត្មាអញជាស្រីទុគ៌ត ជាស្រីមេម៉ាយមិនមានកូន ព្រាត់ប្រាសចាកមិត្តចាកញាតិទាំងឡាយ មិនដែលបានបាយនិងសំពត់ ( បរិភោគប្រើប្រាស់គ្រប់គ្រាន់ ) ទេ ។ អាត្មាអញកាន់កាជន៍ដីនិងឈើច្រត់ដើរសូមអំពីត្រកូលមួយទៅកាន់ត្រកូលមួយ ត្រូវត្រជាក់ និងក្តៅបៀតបៀនដើរទៅអស់ ៧ ឆ្នាំ ។ លុះកាលជាខាងក្រោយមក អាត្មាអញបានឃើញភិក្ខុនី ( បដាចារាថេរី ) ជាស្រីបានបាយនិងទឹកហើយចូលទៅនិយាយសូមបួសក្នុងធម្មវិន័យ ។ ឯបដាចារាភិក្ខុនីនោះ បានបំបួសអាត្មាអញដោយសេចក្តីអនុគ្រោះ ខាងក្រោយអំពីនោះមកលោកបានទូន្មានអាត្មាអញ ដឹកនាំក្នុងប្រយោជន៍យ៉ាងសំខាន់ ។ អាត្មាអញបានស្តាប់ពាក្យរបស់លោកក៏បានធ្វើតាមពាក្យប្រៀនប្រដៅ ឯឱវាទរបស់ព្រះថេរីជាម្ចាស់មិនឥតអំពើឡើយ ខ្ញុំជាអ្នកមានវិជ្ជាបី មិនមានអាសវៈ ។

ចន្ទាថេរី ។

**ចប់ បញ្ចកនិបាត ។**

## អដ្ឋកថា

# ចន្ទាថេរីគាថា

[ ៣១៤ ] គាថារបស់ព្រះនាងចន្ទាថេរី មានពាក្យផ្តើមថា **ទុគ្គតាហំ បុរេ អាសឹ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ធ្វើសមោធានធម៌ដែលជាគ្រឿងតាក់តែងវិមោក្ខដោយលំដាប់មានញាណចាស់ក្លាហើយ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងផ្ទះព្រាហ្មណ៍ដែលមិនប្រាកដឈ្មោះក្នុងស្រុកព្រាហ្មណ៍មួយ តាំងពីនាងកើតមកត្រកូលនោះក៏វិនាសទ្រព្យរឿយៗ ។ នាងដឹងក្តីតាមលំដាប់ មានជីវិតរស់នៅយ៉ាងលំបាក ។ សម័យនោះ អហិវាតករោគកើតឡើងក្នុងផ្ទះនោះ ដោយរោគនោះ ញាតិរបស់នាងក៏នាំគ្នាស្លាប់អស់ កាលអស់ញាតិនាងមិនអាចរស់នៅបានក៏ទៅកាន់ទីដទៃ កាន់អំបែងដើរសូមអាហារតាមផ្ទះផ្សេងៗ ញុំាងជីវិតឲ្យតាំងនៅដោយអាហារដែលបាន ។ ថ្ងៃមួយ ទៅកាន់ទីដែលព្រះនាងបដាចារាថេរីចែកបាយ ភិក្ខុនីទាំងឡាយឃើញកុលធីតានោះដល់នូវសេចក្តីទុក្ខ ត្រូវសេចក្តីទុក្ខគ្របសង្កត់ កើតចិត្តករុណាសង្គ្រោះដោយពាក្យពីរោះ ហើយឲ្យបរិភោគអាហារដែលមានរសឆ្ងាញ់ដែលមានក្នុងបរិវេណនោះរហូតឆ្អែត ។ នាងជ្រះថ្លាក្នុងអាចារនិងសីលរបស់ភិក្ខុនីទាំងនោះចូលទៅរកព្រះថេរីថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះថេរីបានសម្តែងធម៌ដល់នាង នាងស្តាប់ធម៌នោះហើយ ក៏រឹងរឹតតែជ្រះថ្លាក្នុងពាក្យប្រៀនប្រដៅ និងកើតសេចក្តីសង្វេគក្នុងសង្សារវដ្តទើបបួស ។ កាលបួសហើយនៅក្នុងឱវាទរបស់ព្រះថេរី ផ្តើមចម្រើនវិបស្សនា ប្រកបភាវនារឿយៗ ព្រោះជាអ្នកបំពេញបារមីទុកនិងព្រោះញាណចាស់ក្លា មិនយូរប៉ុន្មានក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ពិចារណាបដិបទារបស់

ខ្លួន បានពោលគាថាទាំងនេះជាឧទានថា

កាលពីដើម អាត្មាអញជាស្រីទុគ៌ត ជាស្រីមេម៉ាយ មិនមានកូនព្រាត់ប្រាសចាកមិត្តចាកញាតិទាំងឡាយមិនដែលបានបាយនិងសំពត់ ( បរិភោគប្រើប្រាស់គ្រប់គ្រាន់ ) ទេ ។ អាត្មាអញកាន់ភាជន៍ដីនិងឈើច្រត់ដើរសូមអំពីត្រកូលមួយទៅកាន់ត្រកូលមួយ ត្រូវត្រជាក់និងក្តៅបៀតបៀន ដើរទៅអស់ ៧ ឆ្នាំ ។ លុះកាលជាខាងក្រោយមក អាត្មាអញបានឃើញភិក្ខុនី ( បដាចារាថេរី ) ជាស្រីបានបាយនិងទឹក ហើយចូលទៅនិយាយសូមបួសក្នុងធម្មវិន័យ ។ ឯបដាចារាភិក្ខុនីនោះ បានបំបួសអាត្មាអញដោយសេចក្តីអនុគ្រោះ ខាងក្រោយអំពីនោះមកលោកបានទូន្មានអាត្មាអញ ដឹកនាំក្នុងប្រយោជន៍យ៉ាងសំខាន់ ។ អាត្មាអញបានស្តាប់ពាក្យរបស់លោក ក៏បានធ្វើតាមពាក្យប្រៀនប្រដៅ ឯឱវាទរបស់ព្រះថេរីជាម្ចាស់ មិនឥតអំពើឡើយ ខ្ញុំជាអ្នកមានវិជ្ជាបី មិនមានអាសវៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុគ្គតា** បានដល់ ក្រីក្រ ទុគ៌ត ។ បទថា **បុរេ** បានដល់ មុនបួស ។ ពិតហើយ នាងបួសហើយ បុគ្គលណាមួយក្នុងសាសនានេះមិនគួរពោលថាជាអ្នកមានឬជាអ្នកក្រតែព្រះថេរីនេះ មាំទាំដោយគុណទាំងឡាយ ដោយហេតុនោះ ទើបព្រះថេរីពោលថា **ទុគ្គតាហំ បុរេ អាសឹ** ។ ក្នុងបទថា **វិធវា** ស្វាមី លោកហៅថា **ធវ** ឈ្មោះថា **វិធវា**

ព្រោះមិនមានប្តីនោះ អធិប្បាយថា ស្រីប្តីស្លាប់ ។ បទថា **អបុត្តិកា** បាន ដល់ មិនមានបុត្ត ។ បទថា **វិនា មិត្តេហិ ញាតីហិ** បានដល់ វិនាស គឺ ប្រាសចាកមិត្តនិងញាតិ ។ បទថា **ភត្តចោឡស្ស នាធិគំ** សេចក្តីថា មិន ជួបនូវការបរិបូណ៌នៃអាហារនិងសំពត់ អធិប្បាយថា ខ្ញុំមិនបានសូម្បីត្រឹមតែ អាហារនិងសំពត់បិទបាំង គឺដុំបាយនិងសំពត់ចាស់ៗ ។ ដោយហេតុនោះទើប ព្រះថេរីពោលថា **បត្តំ ទណ្ឌញ្ច គណ្ហិត្វា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បត្តំ** បានដល់ អំបែងធ្វើអំពីដី ។ បទថា **ទណ្ឌំ** បានដល់ ឈើច្រត់ដែលប្រើសម្រាប់ការពារគោនិងឆ្កែជាដើម ។ បទ ថា **កុលា កុលំ** បានដល់ ចេញអំពីត្រកូលមួយទៅកាន់ត្រកូលមួយ ។ បទ ថា **សីតុណ្ហេន ច ឌយ្ហន្តិ** បានដល់ ត្រូវរងានិងក្តៅបៀតបៀនព្រោះមិនមាន ផ្ទះសម្បែង ។

ដោយបទថា **ភិក្ខុនី** ព្រះថេរីពោលសំដៅដល់នាងបដាចារាថេរី ។ បទ ថា **បុន** បានដល់ ខាងក្រោយ គឺតមក ៧ ឆ្នាំ ។

បទថា **បរមត្ថេ** បានដល់ ប្រយោជន៍យ៉ាងក្រៃលែង គឺឧត្តម បានដល់ បដិបទាដែលឲ្យដល់នូវព្រះនិព្វាន និងក្នុងព្រះនិព្វាន ។ បទថា **និយោជយិ** បានដល់ ប្រាប់កម្មដ្ឋានប្រកបខ្ញុំទុក ។ ពាក្យដ៏សេសមានន័យដូចពោលរួច ហើយនោះឯង ។

អដ្ឋកថា ចន្ទាថេរីគាថា ចប់

ថេរីគាថា បញ្ចកនិបាត ចប់

# ថេរីគាថា ឆក្កនិបាត

## បញ្ចសតមត្តាថេរីគាថា

[ ៣១៥ ] នាងមិនដឹងផ្លូវរបស់សត្វណា ដែលមកឬទៅទេហើយយំរកកូនដែល ( មិនដឹងជា ) មកអំពីទីណានោះថា ឱកូនអាត្មាអញអើយ ។ ទុកជានាងដឹងផ្លូវរបស់កូននោះដែលមកឬទៅ ក៏មិនគប្បីសោករកកូននោះឡើយ ព្រោះសត្វមានយ៉ាងនេះជាធម្មតា ។ ( សត្វនោះ ) មិនមានអ្នកណាមួយអង្វរឲ្យមកអំពីបរលោកនោះ ទាំងមិនមានអ្នកណាមួយអនុញ្ញាតឲ្យទៅអំពីលោកនេះឡើយ ទំនងជាមកអំពីទីណាមួយ ( មាននរកជាដើម ) មកអាស្រ័យនៅ ( ក្នុងទីនេះ ) អស់ពីរបីថ្ងៃ ។ សត្វសូម្បីទៅអំពីកពនេះ មកកាន់កពដទៃ ទៅអំពីកពនោះទៅកាន់កពដទៃ ចែកឋានទៅហើយ ដោយសភាពជាមនុស្ស នឹងអន្ទោលទៅបើមកយ៉ាងណា ក៏ទៅយ៉ាងនោះ ការខ្សឹកខ្សួលព្រោះតែសត្វនោះ មានប្រយោជន៍អ្វី ។

លោកម្ចាស់បានដកព្រួញគឺសេចក្តីសោកដែលឃើញដោយកម្រអាស្រ័យនូវហឫទ័យរបស់ខ្ញុំ លោកម្ចាស់បានបន្ទោបង់សេចក្តីសោក ព្រោះកូនរបស់ខ្ញុំដែលត្រូវសេចក្តីសោកគ្របសង្កត់ហើយ ។ ក្នុងថ្ងៃនេះខ្ញុំនោះ មានព្រួញរដកហើយ មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ ខ្ញុំសូមដល់នូវព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ។

បដាចារាថេរី ៥០០ ។

# អដ្ឋកថា

# ថេរីគាថា ឆក្កនិបាត

## បញ្ចសតមត្តាថេរីគាថា

[ ៣១៥ ] ក្នុងឆក្កនិបាត គាថារបស់ព្រះបញ្ចសតមត្តាថេរី មានពាក្យផ្តើមថា **យស្ស មគ្គំ ន ជានាសិ** ដូច្នេះជាដើម ។

កុលធីតាទាំងនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗមានធម៌ជាគ្រឿងតាក់តែងវិមោក្ខដែលសាងមកដោយលំដាប់ក្នុងពុទ្ធុប្បាទនេះកើតក្នុងផ្ទះមានត្រកូលផ្សេងៗ ធំពេញវ័យដោយលំដាប់មាតាបិតាក៏រៀបចំឲ្យមានប្តី បានកូនច្រើននាក់ក្នុងត្រកូលនោះៗ កាលនៅគ្រប់គ្រងផ្ទះ កូនក៏ស្លាប់អស់ព្រោះពួកគេមានជាតិស្មើគ្នា ធ្វើកម្មមកដូចគ្នា ត្រូវសេចក្តីសោកដល់បុត្តគ្របសង្កត់ហើយ ចូលទៅរកនាងបដាចារាថេរី ថ្វាយបង្គំហើយ អង្គុយរៀបរាប់ដល់ហេតុនៃសេចក្តីសោករបស់ខ្លួន ។ ព្រះថេរីកាលបន្ទោបង់ សេចក្តីសោករបស់ស្រីទាំងនោះ ទើបសម្តែងដោយគាថាទាំងឡាយ ៤ ថា

នាងមិនដឹងផ្លូវរបស់សត្វណាដែលមកឬទៅទេហើយយំរកកូនដែល ( មិនដឹងជា ) មកអំពីទីណានោះថា ឱកូនអាត្មាអញអើយ ។ ទុកជានាងដឹងផ្លូវរបស់កូននោះដែលមកឬទៅ ក៏មិនគប្បីសោករកកូននោះឡើយ ព្រោះសត្វមានយ៉ាងនេះជាធម្មតា ។ ( សត្វនោះ ) មិនមានអ្នកណាមួយអង្វរ ឲ្យមកអំពីបរលោក

នោះ ទាំងមិនមានអ្នកណាមួយ អនុញ្ញាតឲ្យទៅអំពីលោកនេះ ឡើយទំនងជាមកអំពីទីណាមួយ ( មាននរកជាដើម ) មក អាស្រ័យនៅ ( ក្នុងទីនេះ ) អស់ពីរបីថ្ងៃ ។ សត្វសូម្បីទៅ អំពីកពនេះ មកកាន់កពដទៃ ទៅអំពីកពនោះទៅកាន់កពដទៃ បែកឋានទៅហើយដោយសភាពជាមនុស្សទើងអន្ទោលទៅ បើ មកយ៉ាងណា ក៏ទៅយ៉ាងនោះ ការខ្សឹកខ្សួល ព្រោះតែសត្វ នោះ មានប្រយោជន៍អ្វី ដូច្នេះ ។

ស្រីទាំងនោះ បានស្តាប់ធម៌របស់បដាចារាថេរីនោះហើយ កើតសេចក្តី សង្វេគ ទើបនាំគ្នាបួសក្នុងសម្នាក់ព្រះថេរី កាលបួសហើយ បំពេញវិបស្សនា កម្មដ្ឋាន មិនយូរប៉ុន្មានក៏តាំងនៅក្នុងអរហត្តមួយអន្លើដោយបដិសម្ភិទា ព្រោះ ធម៌ជាគ្រឿងអប់រំបន្ទុំវិមុត្តិចាស់ក្លាហើយ ។ លំដាប់នោះ ព្រះថេរីទាំង ៥០០ អង្គនោះសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន ទើបពោលគាថា ទាំងនេះជាពាក្យឧទានមួយអន្លើដោយគាថា ជាពាក្យឱវាទ ( របស់ព្រះនាង បដាចារាថេរី ) ថា

លោកម្ចាស់បានដកព្រួញគឺសេចក្តីសោក ដែលឃើញដោយ កម្រ អាស្រ័យនូវហឫទ័យរបស់ខ្ញុំ លោកម្ចាស់បានបន្ទោបង់ សេចក្តីសោក ព្រោះកូនរបស់ខ្ញុំ ដែលត្រូវសេចក្តីសោកគ្រប សង្កត់ហើយ ។ ក្នុងថ្ងៃនេះខ្ញុំនោះមានព្រួញរដកហើយ មិន មានសម្រេកគម្ពាន មានទុក្ខរលត់ហើយ ខ្ញុំសូមដល់នូវព្រះ

ពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស មគ្គំ ន ជានាសិ អាគតស្ស គតស្ស វា** បានដល់ នាងមិនដឹងផ្លូវមករបស់សត្វណាដែលមកហើយក្នុងទីនេះ ឬផ្លូវទៅរបស់សត្វណាដែលទៅហើយអំពីទីនេះ លោកពោលសំដៅយកការចូលដល់កពដែលជាអតីតនិងអនាគតជាប់តគ្នា ។ បទថា **តំ កុតោ ចាគតំ សត្តំ** សេចក្តីថា ដូចម្តេច គឺព្រោះហេតុអ្វីទើបនាងធ្វើនូវការប្រកាន់ឲ្យកើតឡើងតែម្យ៉ាងថា បុត្តរបស់អញ ហើយយំសោកដល់សត្វនោះ ដូចបុរសជួបគ្នាកណ្តាលផ្លូវជាមួយអ្នកមកកាន់ផ្លូវដែលមិនស្គាល់ថា មកអំពីណាទៅណា គឺផ្លូវមកអំពីគតិណាយ៉ាងនេះមិនទាន់ធ្វើនូវការស្និទ្ធស្នាល អធិប្បាយថា មិនមានហេតុដែលត្រូវយំក្នុងសេចក្តីនេះ ព្រោះបុត្តមិនទាន់ធ្វើកិច្ចតបស្នងដល់នាងឡើយ ។

បទថា **មគ្គញ្ច ខោស្ស ជានាសិ** សេចក្តីថា បើនាងដឹងផ្លូវមករបស់សត្វទាំងនោះ នាងរមែងទទួលថា ជាបុត្តដែលមកហើយ និងផ្លូវទៅរបស់កូននោះដែលទៅហើយ ។ បទថា **ន នំ សមនុសោចសិ** សេចក្តីថា នាងក៏មិនគួរសោកដល់បុគ្គលនោះយ៉ាងនេះឡើយ ព្រោះហេតុអ្វី ព្រោះថា សត្វទាំងឡាយមានយ៉ាងនេះជាធម្មតា ព្រោះក្នុងជាតិបច្ចុប្បន្ន សត្វទាំងឡាយគង់វៀររបស់ផ្សេងៗ គឺព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ របស់ជាទីចម្រើនចិត្តទាំងឡាយ ព្រោះខ្លួនមិនមានអំណាចក្នុងរបស់ដែលស្រឡាញ់នោះ នឹង

ពោលថ្វីដល់កពខាងមុខនោះ ។

បទថា **អយាចិតោ តតាគច្ឆិ** សេចក្តីថា បុគ្គលនោះ មិនមានអ្នកណាមួយអញ្ជើញអំពីបរលោក ក៏មកក្នុងលោកនេះ អំពីលោកនោះ ។ បាលីថា **អាគតោ** ប្រែថា មកហើយ ដូច្នេះក៏មាន ឯសេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **អននុញ្ញាតោ ឥតោ គតោ** សេចក្តីថា ដែលបុគ្គលណាមួយ មិនបានអនុញ្ញាតអំពីឥធលោក ក៏ទៅកាន់បរលោក ។ បទថា **កុតោចិ** បានដល់ ចាកគតិណានីមួយ មាននិរយគតិជាដើម ។ បទថា **នូន** ជានិបាត ចុះក្នុងអត្ថថា មិនប្រាកដប្រជាក្នុងចិត្ត ។ បទថា **វសិត្វា កតិថាហកំ** សេចក្តីថា ស្នាក់នៅក្នុងលោកនេះត្រឹមថ្ងៃបន្តិចបន្តួច ។ បទថា **ឥតោបិ អញ្ញេន គតោ** សេចក្តីថា ចូលទៅអំពីកពនេះកាន់កពដទៃ គឺចូលដល់កពដទៃអំពីកពនេះ ដោយអំណាចបដិសន្ធិ ។ បទថា **តតោបញ្ញេន គច្ឆតិ** សេចក្តីថា បុគ្គលនោះនឹងទៅកពដទៃអំពីកពនោះទៀត គឺនឹងចូលដល់កពដទៃទៀត ។

បទថា **បេតោ** សេចក្តីថា បុគ្គលនោះចេញទៅ គឺចូលដល់កពនោះៗ ហើយ ក៏ទៅអំពីកពនោះទៀត ។

បទថា **មនុស្សរូបេន** នេះ គ្រាន់តែជាតឹកតាង អធិប្បាយថា ជាមនុស្សក៏បានជាតិរច្ឆានជាដើមក៏បាន ។ បទថា **សំសរន្តោ** បានដល់ វិលវល់ដោយអំណាចការកើតទៅមកៗ ។ បទថា **យថាគតោ តថា គតោ** សេចក្តីថា បុគ្គលនោះមិនបានទទួលអញ្ជើញក៏មកអំពីគតិ ដែលមិនស្គាល់ យ៉ាងណា បុគ្គលណាមួយមិនបានអនុញ្ញាត ក៏ទៅអំពីគតិដែលមិនស្គាល់ក៏យ៉ាងនោះ ។

បទថា **កា តត្ថ បរិទេវនា** សេចក្ដីថា ខ្សឹកខ្សួលធ្វើអ្វីក្នុងសេចក្ដីនោះ គឺក្នុងកាមាវចរដែលមិននៅក្នុងអំណាចបែបនោះ អធិប្បាយថា ប្រយោជន៍អ្វីដោយការខ្សឹកខ្សួល ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ក្នុងគាថាទាំងនោះ ៤ គាថាដំបូង បដាចារាថេរីសម្ដែងទុកតែម្ដង ដើម្បីបន្ទោបង់សេចក្ដីសោករបស់ស្រី ៥០០ នោះ ។ ចំណែកគាថា ៦ ( រាប់ទាំងគាថា ៤ នោះផង ) គប្បីជ្រាបថា ភិក្ខុនីប្រមាណ ៥០០ អង្គនោះ តាំងនៅក្នុងឱវាទរបស់បដាចារាថេរីនោះ នាំគ្នាបួស បានសម្រេចគុណវិសេសហើយបានពោលទុករៀងៗខ្លួន ។

បទថា **បញ្ចសតា បដាចារា** សេចក្ដីថា ភិក្ខុនីទាំង ៥០០ នេះ បានឈ្មោះថា បដាចារា ព្រោះមានវិគ្គហថា ជាអ្នកដឹងពាក្យដែលបដាចារាថេរីពោលដោយបានទទួលឱវាទក្នុងសម្នាក់របស់ព្រះនាងបដាចារាថេរីនោះ ។

## អដ្ឋកថាបញ្ចសតមត្តាថេរីគាថា ចប់

# វាសិដ្ឋីថេរីគាថា

[ ៣១៦ ] អាត្មាអញត្រូវសេចក្ដីសោកព្រោះកូនបៀតបៀនហើយ មានចិត្តវាយមាយ ប្រាសចាកសញ្ញា មានកាយអាក្រាត មានសក់រាត់រាយអាត្មាអញដើរទ្រហោយំ ។ អាត្មាអញពោរពេញដោយសេចក្ដីស្រេកឃ្លាន បានដើរទៅលើគំនរសំរាម ក្បែរថ្នល់ផង ក្នុងព្រៃស្មសានផង ក្នុងច្រករហកផង អស់បីឆ្នាំ ។ ក្នុងកាលជាខាងក្រោយមក អាត្មាអញបានជួបប្រទះនឹងព្រះសុគត ព្រះអង្គទូន្មាននូវពួកសត្វដែលមានខ្លួនមិនទាន់បានទូន្មាន ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង មិនមានភ័យអំពីទីណា កំពុងស្ដេចទៅកាន់ក្រុងមិថិលា ។ អាត្មាអញត្រឡប់បាននូវចិត្តជាប្រក្រតី ហើយក៏ចូលទៅជិតថ្វាយបង្គំ ឯព្រះគោតមនោះ បានសំដែងធម៌ដល់អាត្មាអញដោយសេចក្ដីអនុគ្រោះ ។ លុះអាត្មាអញបានស្ដាប់ធម៌របស់ព្រះអង្គហើយ ក៏បានបួសក្នុងធម្មវិន័យ ប្រកបព្យាយាមក្នុងសាសនានៃព្រះសាស្ដា បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបទដ៏ជាទីក្សេម ។ សេចក្ដីសោកទាំងឡាយទាំងពួង អាត្មាអញផ្ដាច់ផ្ដិលហើយ បានលះបង់ហើយ ឲ្យមានទីបំផុតត្រឹមព្រះអរហត្តនេះ ព្រោះថាវត្ថុទាំងឡាយដែលជាដែនកើតនៃសេចក្ដីសោក អាត្មាអញកំណត់ហើយ ។

វាសិដ្ឋីថេរី ។

# អដ្ឋកថា

# វាសិដ្ឋីថេរីគាថា

[ ៣១៦ ] គាថារបស់ព្រះនាងវាសិដ្ឋីថេរីមានពាក្យផ្ដើមថា **បុត្តសោ-កេនហំ អដ្ដា** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ មានធម៌ជាគ្រឿងតាក់តែងវិមោក្ខដោយលំដាប់ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះកើតក្នុងផ្ទះមានត្រកូល នានគរវេ-សាលី ដឹងក្ដីហើយ មាតាបិតាក៏លើកឲ្យកុលបុត្តដែលមានជាតិស្មើគ្នា មានប្ដីហើយ រស់នៅដោយសុខជាមួយស្វាមីនោះ បានកូនប្រុសម្នាក់ កាលកូននោះស្លាប់ក្នុងកាលដែលចេះរត់លេង ត្រូវសេចក្ដីសោកគ្របសង្កត់ដល់បុត្តក៏ក្លាយជាមនុស្សឆ្កួត កាលពួកញាតិនិងប្ដីនាំគ្នាជួយព្យាបាល ក៏រត់ទៅក្នុងកាលដែលអ្នកទាំងនោះមិនដឹង ។ កុលធីតានោះ ត្រាច់ទៅព្រោះការឆ្កួត ដល់មិថិលានគរ ហើយជួបនឹងព្រះមានព្រះភាគទ្រង់ជាបុគ្គលប្រសើរ ទ្រង់ជាអ្នកទូន្មានខ្លួន រក្សាខ្លួនហើយ ជាអ្នកសង្រួមឥន្ទ្រិយ កំពុងយាងទៅក្នុងចន្លោះផ្លូវក្នុងមិថិលានគរនោះ ។ កាលឃើញហើយ ក៏ជាអំពីឆ្កួត បាននូវប្រក្រតីចិត្តដំណាលគ្នានឹងបានឃើញ ព្រោះពុទ្ធានុភាព ។ កាលនោះ ព្រះសាស្ដាទ្រង់សម្ដែងធម៌ដល់នាងដោយសង្ខេប នាងបានស្ដាប់ធម៌នោះហើយ បាននូវសេចក្ដីសង្វេគ ទូលព្រះសាស្ដាសូមបួស បានបួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយតាម

ព្រះតម្រាស់របស់ព្រះសាស្តា ធ្វើកិច្ចខាងដើមហើយ បានផ្តើមវិបស្សនា ព្យាយាមមិនយូរប៉ុន្មាន ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ព្រោះមានញាណចាស់ក្លា ពិចារណាបដិបទារបស់ខ្លួនហើយ បានពោលគាថាទាំងនេះជាឧទានថា

អាត្មាអញត្រូវសេចក្តីសោក ព្រោះកូនបៀតបៀនហើយ មានចិត្តរាយមាយ ប្រាសចាកសញ្ញាមានកាយអាក្រាត មានសក់រាត់រាយ អាត្មាអញដើរទ្រហោយំ ។ អាត្មាអញពោរពេញដោយសេចក្តីស្រេកឃ្លាន បានដើរទៅលើគំនរសំរាមក្បែរថ្នល់ផង ក្នុងព្រៃស្មសានផង ក្នុងប្រករហកផង អស់បីឆ្នាំ ។ ក្នុងកាលជាខាងក្រោយមក អាត្មាអញបានជួបប្រទះនឹងព្រះសុគតព្រះអង្គទូន្មាននូវពួកសត្វដែលមានខ្លួនមិនទាន់បានទូន្មាន ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងមិនមានភ័យអំពីទីណា កំពុងស្តេចទៅកាន់ក្រុងមិថិលា ។ អាត្មាអញត្រឡប់បាននូវចិត្តជាប្រក្រតីហើយក៏ចូលទៅជិតថ្វាយបង្គំ ឯព្រះគោតមនោះ បានសំដែងធម៌ដល់អាត្មាអញ ដោយសេចក្តីអនុគ្រោះ ។ លុះអាត្មាអញបានស្តាប់ធម៌ របស់ព្រះអង្គហើយ ក៏បានបួសក្នុងធម្មវិន័យប្រកបព្យាយាមក្នុងសាសនា នៃព្រះសាស្តា បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបទដ៏ជាទីក្សេម ។ សេចក្តីសោកទាំងឡាយទាំងពួងអាត្មាអញផ្តាច់ផ្តិលហើយ បានលះបង់ហើយ ឲ្យមាន

ទីបំផុតត្រឹមព្រះអរហត្តនេះ ព្រោះថាវត្ថុទាំងឡាយដែលជាដែន
កើតនៃសេចក្តីសោក អាត្មាអញកំណត់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អដ្ដា** ប្រែថា បៀតបៀន ម្យ៉ាងទៀត បាលី ក៏ដូច្នេះឯង អធិប្បាយថា គ្របសង្កត់ បៀតបៀន ។ បទថា **ខិត្តចិត្តា** បានដល់ មានហទយៈរវើរវាយ ព្រោះការឆ្កួតកើតឡើងអំពីសេចក្តីសោក បន្ទាប់អំពីនោះ ក៏មានសញ្ញាវិបល្លាស ព្រោះប្រាសចាកសតិតាមប្រក្រតី ។ ឈ្មោះថា **នគ្គា** ព្រោះប្រាសចាកសំពត់ដណ្តប់ មិនមានហិរិនិងឱត្តប្បៈ ។ ឈ្មោះថា **បកិណ្ណកេសី** ព្រោះមានសក់ មិនបានសិតត្រឹមត្រូវ ។ បទថា **តេន តេន** សេចក្តីថា ខ្ញុំបានត្រាច់ទៅអំពីស្រុកចូលទៅកាន់ស្រុក អំពីនគរចូលទៅកាន់នគរ អំពីថ្នល់ចូលទៅកាន់ថ្នល់ ។ សព្ទថា **អថ** ប្រែថា ខាងក្រោយ បានដល់ ពេលអស់កម្មដែលធ្វើឲ្យឆ្កួត ។ បទថា **សុគតំ** សេចក្តីថា ព្រះមានព្រះភាគឈ្មោះថា ព្រះសុគត ព្រោះទ្រង់មានដំណើរល្អ ព្រោះយាងទៅកាន់ទីល្អ ព្រោះត្រាស់ដោយប្រពៃ និងព្រោះយាងទៅដោយប្រពៃ ។ បទថា **មិថិលំ គតំ** សេចក្តីថា កំពុងយាងទៅកាន់មិថិលា គឺទៅកាន់នគរមិថិលា ។

បទថា **សចិត្តំ បដិលទ្ធាន** បានដល់ លះនូវការឆ្កួត បាននូវប្រក្រតីចិត្តរបស់ខ្លួន ព្រោះពុទ្ធានុភាព ។

បទថា **យុញ្ជន្តី សត្ថុ វចនេ** បានដល់ ធ្វើនូវសេចក្តីព្យាយាម គឺប្រកបការនៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធជាសាស្តា ។ បទថា **សច្ឆាកាសឹ បទំ សិវំ** សេចក្តីថា បានធ្វើឲ្យជាក់ច្បាស់នូវបទ គឺព្រះនិព្វានដែលជា

ធម៌ដ៏រុងរឿង ជាធម៌ក្សេម មិនត្រូវយោគៈ ៤ បៀតបៀន ។ បទថា **ឯត ទន្តិកា** សេចក្តីថា សេចក្តីសោកទាំងឡាយ ឈ្មោះថា **ឯតទន្តិក** ព្រោះមានព្រះអរហត្ត ដែលខ្ញុំសម្រេចក្នុងឥឡូវនេះ ជាទីបំផុត ជាបរិយោសាន អធិប្បាយថា ឥឡូវនេះ ហេតុកើតនៃសេចក្តីសោកទាំងនោះមិនមាន ។ បទថា **យតោ សោកាន សម្ភវោ** ប្រកបសេចក្តីថា ព្រោះហេតុដែលខ្ញុំកំណត់ដឹងហេតុនៃសេចក្តីសោកដែលមានការក្រៀមក្រំខាងក្នុងជាលក្ខណៈ កំណត់ដឹងទីតាំងពោលគឺឧបាទានក្ខន្ធ ៥ បានដល់ ទីតាំងទទួលនៃសេចក្តីសោកទាំងនោះដោយញាតបរិញ្ញា តីរណបរិញ្ញានិងបហានបរិញ្ញា ព្រោះដូច្នោះ ទើបសេចក្តីសោក មានអរហត្តផលនោះជាទីបំផុត ។

អដ្ឋកថា វាសិដ្ឋីថេរីគាថា ចប់

# ខេមាថេរីគាថា

[ ៣១៧ ] ហៃនាងខេមា នាងនៅក្មេង ជាស្រីមានរូប យើងសោត ក៏នៅក្មេងកំលោះ នាងចូរមកយើងនឹងត្រេកត្រអាល ដោយតូរ្យតន្ត្រីប្រកប ដោយអង្គ ៥ ។

អាត្មានឿយណាយ ធុញទ្រាន់ដោយកាយស្អុយដែលមានជំងឺជានិច្ច ពុក ផុយនេះ កាមតណ្ហា អាត្មាបានដកចេញហើយ ។ កាមទាំងឡាយ មាន ឧបមាដោយលំពែងនិងអណ្តោតជាទីកាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកនិយាយ ចំពោះតម្រេកក្នុងកាមណា ឥឡូវនេះតម្រេកក្នុងកាមនោះ មិនជាទីត្រេកអរ នៃអាត្មាទេ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញ ហើយ គំនរងងឹតអាត្មាក៏បានទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកចូរដឹង យ៉ាងនេះចុះ ម្នាលមារលាមកអ្នកឯងអាត្មាបានកម្ចាត់ចេញហើយ ។ ពួកជន ពាលមិនដឹងតាមពិត សំពះនក្ខត្តឫក្សទាំងឡាយ បូជាភ្លើងក្នុងព្រៃ ហើយ សម្គាល់ថាជាការបរិសុទ្ធ ។ ចំណែកខាងអាត្មានមស្ការព្រះសម្ពុទ្ធ ជាបុរស ខ្ពង់ខ្ពស់ ជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា បានរួចស្រឡះហើយចាក ទុក្ខទាំងពួង ។

**ខេមាថេរី ។**

# អដ្ឋកថា

## ខេមាថេរីគាថា

[ ៣១៧ ] គាថារបស់ព្រះនាងខេមាថេរី មានពាក្យផ្ដើមថា **ទហរា ត្វំ រូបវតី** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ ជាទាសីរបស់អ្នកដទៃ អាស្រ័យអ្នកដទៃចិញ្ចឹមជីវិតក្នុងក្រុងហង្សវតី នាងចិញ្ចឹមជីវិតដោយការជួយខ្វល់ខ្វាយការងាររបស់អ្នកដទៃ ថ្ងៃមួយ បានឃើញព្រះសុជាតត្ថេរ អគ្គសាវករបស់ព្រះបទុមុត្តរសម្មាសម្ពុទ្ធ កំពុងត្រាច់បិណ្ឌបាត បានប្រគេននំ ៣ ដុំ ។ ក្នុងថ្ងៃតែមួយនោះ ក៏បានលះសក់របស់ខ្លួនដូរយកតម្លៃថ្វាយទានដល់ព្រះថេរៈ ធ្វើសេចក្ដីប្រាថ្នាថា ខ្ញុំគប្បីជាពុទ្ធសាវិកាជាអ្នកមានបញ្ញាច្រើនក្នុងអនាគត ។ កុលធីតានោះមិនប្រមាទក្នុងកុសលធម៌ដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយ បានជាមហេសីរបស់ទេវរាជក្នុងជាន់កាមាវចរមានសក្កទេវរាជជាដើម ដោយលំដាប់ក្នុងមនុស្សលោកក៏បានជាមហេសីរបស់ស្ដេចចក្រពត្តិ និងរបស់ស្ដេចបវរីមណ្ឌលច្រើនដង សោយមហាសម្បត្តិហើយ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវិបស្សី កើតក្នុងមនុស្សលោកដល់នូវភាពជាអ្នកដឹងក្ដីហើយស្ដាប់ធម៌ក្នុងសម្នាក់ព្រះសាស្ដា បាននូវសេចក្ដីសង្វេគ បួសប្រព្រឹត្តព្រហ្មចរិយៈអស់ ១ ម៉ឺនឆ្នាំ ជាពហូសូត ជាធម្មកថិក ធ្វើកម្មដែលនាំឲ្យកើតបញ្ញា ដោយការពោលធម៌ដល់មហាជនជាដើម ចុតិអំពីភពនោះហើយ អន្ទោលទៅក្នុង

សុគតិភពប៉ុណ្ណោះ ក្នុងកប្បនេះ កាលព្រះមានព្រះភាគព្រះនាមថាកកុសន្ធៈ និងព្រះកោនាគមនៈ កើតក្នុងផ្ទះមានត្រកូលដែលសម្បូរដោយសម្បត្តិដល់នូវភាពជាអ្នកដឹងក្តីហើយ សាងមហាសង្ឃារាមថ្វាយដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។

ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបទសពល បានជាព្រះរាជធីតាច្បង មាននាមថាសមណី នៃព្រះបាទកាសីព្រះនាមកិកិ ។ កុលធីតានេះស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាហើយ បាននូវសេចក្តីសង្វេគ តាំងនៅក្នុងព្រះរាជមន្ទីរនោះឯង ប្រព្រឹត្តកោមារិព្រហ្មចរិយៈអស់ ២ ម៉ឺនឆ្នាំ ឲ្យសាងបរិវេណដែលគួរជាទីត្រេកអរ មួយអន្លើដោយប្អូនស្រីទាំងឡាយរបស់ព្រះនាង មាននាងសមណគុត្តាជាដើមស្រេចហើយបានវេរថ្វាយដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន នាងបានធ្វើបុញ្ញកម្មដ៏ក្រៃលែងជាប់តមកក្នុងភពនោះៗ ដោយអាការយ៉ាងនេះ វិលវល់ក្នុងសុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងរាជត្រកូល នាសាគលនគរដែនមទ្ទៈ មាននាមថាខេមា មានព្រះវណ្ណៈដូចមាសមានព្រះឆវីដូចមាស ។ ព្រះនាងចម្រើនវ័យជារាជកុមារីហើយ បានជាព្រះទេវីរបស់ព្រះបាទពិម្ពិសារ ។ កាលព្រះសាស្តាគង់នៅក្នុងវត្តវេឡុវ័នព្រះនាងជាអ្នកស្រវឹងក្នុងព្រះរូបឆោម ខ្លាចក្រែងព្រះសាស្តាទ្រង់សម្តែងនូវទោសក្នុងរូប ទើបមិនយាងទៅគាល់ព្រះសាស្តា ។

ព្រះរាជាត្រាស់ឲ្យមនុស្សទាំងឡាយ ពណ៌នាវត្តវេឡុវ័ន ធ្វើឲ្យព្រះទេវីកើតព្រះទ័យចង់ទៅទស្សនាព្រះវិហារ កាលព្រះទេវីត្រិះរិះថា អញនឹងមើល

ព្រះវិហារ ទើបទូលលាព្រះរាជាថា ខ្ញុំម្ចាស់ចង់ទៅមើលវិហារ ។ ព្រះរាជាត្រាស់ថា បើនាងទៅវិហារហើយមិនបានគាល់ព្រះសាស្តាកុំត្រឡប់មកហើយទ្រង់ឲ្យសញ្ញាដល់ពួករាជបុរសថា អ្នកទាំងឡាយចូរឲ្យព្រះទេវីគាល់ព្រះទសពលដោយកម្លាំងឲ្យបាន ។ ព្រះទេវីយាងទៅកាន់វិហារ ឲ្យកាលវេលាកន្លងទៅកន្លះថ្ងៃ មិនចូលគាល់ព្រះសាស្តាគិតយាងត្រឡប់ ។ លំដាប់នោះ រាជបុរសទាំងឡាយនាំព្រះទេវីទាំងដែលមិនប្រាថ្នា ចូលគាល់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ឃើញព្រះទេវីកំពុងយាងមក ទ្រង់និមិត្តស្ត្រីម្នាក់ ប្រហែលនឹងទេពអប្សរដោយឫទ្ធិ ធ្វើឲ្យកាន់ផ្លិតស្លឹកត្នោតបក់ថ្វាយទ្រង់ ។ ព្រះនាងខេមាទេវីឃើញស្រីនោះ ព្រះតម្រិះថា ស្រីនេះមានចំណែកប្រៀបដូចទេពអប្សរឈរមិនឆ្ងាយអំពីព្រះមានព្រះភាគ អាត្មាអញ មិនល្មមជាស្រីបម្រើរបស់ស្រីនោះ អញត្រូវវិនាសដោយអំណាចនៃចិត្តអាក្រក់ ព្រោះហេតុបន្តិចបន្តួច ។ ព្រះនាងកាន់យកនិមិត្ត ប្រថាប់ឈរមើលស្រីនោះ កាលព្រះនាងកំពុងទតស្រីនោះក៏កន្លងបឋមវ័យ មជ្ឈិមវ័យដល់នូវបច្ឆិមវ័យហើយ ធ្មេញបាក់ សក់ស្កូវ ស្បែកយុរយារ ដួលចុះទាំងផ្លិតស្លឹកត្នោតដោយកម្លាំងនៃអធិដ្ឋានរបស់ព្រះសាស្តា ។ បន្ទាប់អំពីនោះ ព្រោះនាងបានធ្វើអធិការទុក ព្រះនាងខេមាទតឃើញហេតុនោះហើយព្រះនាងព្រះតម្រិះថា សរីរៈសូម្បីមានសភាពយ៉ាងនេះ គង់ដល់នូវវិបត្តិបែបនេះ សរីរៈរបស់អញ ក៏នឹងមានគតិយ៉ាងនេះដូចគ្នា លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបវារៈចិត្តរបស់ព្រះនាងហើយ ក៏ត្រាស់ព្រះគាថា ( ក្នុងអបទាន ) ថា

ពួកជនណា ដែលត្រេកអរដោយរាគៈ រមែងធ្លាក់ទៅកាន់ខ្សែ
គឺតណ្ហា ដូចជាសត្វពីងពាងដែលជាប់នឹងបណ្ដាញ ដែលខ្លួន
ឯងធ្វើ លុះតែពួកជនទាំងនោះជាអ្នកមិនមានអាល័យ កាត់
នូវខ្សែគឺតណ្ហានុ៎ះ លះបង់នូវកាមសុខហើយ ទើបចេញបួស
បាន ដូច្នេះ ។

ពាក្យដែលមកក្នុងអដ្ឋកថាថា ចប់គាថាព្រះនាងខេមានោះសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ឯពាក្យដែលមកក្នុងអបទានថា ស្ដាប់គាថានេះ ហើយតាំងនៅក្នុងសោតាបត្តិផល សូមព្រះរាជាឲ្យទ្រង់អនុញ្ញាតបួស ហើយសម្រេចអរហត្ត សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុចំពោះធម៌ទាំង
ពួង ជាលោកនាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែន អំ-
ពីកទ្ទកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋីក្នុងនគរ
ហង្សវតី ដែលរុងរឿងដោយរតនៈផ្សេងៗ ខ្ញុំឆ្អែតស្កប់ស្កល់
ហើយដោយសេចក្ដីសុខច្រើន ។ ខ្ញុំចូលទៅគាល់ព្រះមហាវីរ
បុរស ហើយបានស្ដាប់ធម្មទេសនា លំដាប់នោះខ្ញុំមានសេចក្ដី
ជ្រះថ្លាកើតឡើង ហើយដល់នូវព្រះជិនស្រីជាទីពឹង ។ ខ្ញុំសូម
អង្វរមាតាបិតា ហើយនិមន្តព្រះពុទ្ធជានាយក ព្រមទាំងព្រះ
សាវកមកឆាន់អស់ ៧ ថ្ងៃ ។ លុះអន្លង ៧ ថ្ងៃផុតទៅ ព្រះ
ពុទ្ធជានរសារថី ទ្រង់តាំងភិក្ខុនីដែលឧត្តមជាង ពួកភិក្ខុនីមាន

បញ្ញាច្រើនក្នុងទីជាឯតទគ្គ ។ ខ្ញុំឮព្រះពុទ្ធវាចានោះហើយក៏រីក រាយ បានធ្វើសក្ការៈចំពោះព្រះពុទ្ធ ជាមហេសីនោះទៀតក្រាប ចុះហើយប្រាថ្នានូវ តំណែងនោះ ។

លំដាប់នោះ ព្រះជិនស្រីទ្រង់ត្រាស់ចំពោះខ្ញុំថា សេចក្តីប្រា-ថ្នារបស់នាងសម្រេចហើយ សក្ការៈដែលនាងធ្វើហើយចំពោះ តថាគតព្រមទាំងព្រះសង្ឃ ជាសក្ការៈមានផលរាប់មិនបាន ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាក នឹងឧប្បត្តិឡើងក្នុងលោក ។ នាងនឹងបានជាភិក្ខុនីឈ្មោះខេមា ជាធម្មទាយាទ ជាឱរស ជា ធម្មនិម្មិត នៃព្រះសាស្តានោះ ដល់នូវទីជាឯតទគ្គ ។

ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ចូលទៅកើត ក្នុង ឋានតាវត្តិង្ស ដោយបុញ្ញកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការ តម្កល់នូវចេតនាផង ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះហើយ ទើបទៅកើតក្នុងឋានយាមៈ លុះច្យុតចាកឋានយាមៈនោះហើយ ក៏ទៅកើតក្នុងតុសិត លុះច្យុតចាកឋានតុសិតនោះហើយ ក៏ទៅ កើតក្នុងឋាននិម្មានរតី ទៅកើតក្នុងឋានបរនិម្មិតវសវត្តីបុរី ។ ខ្ញុំ កើតក្នុងត្រកូលណាៗ ខ្ញុំបានធ្វើភាពជាមហេសីនៃពួកស្តេចក្នុង ត្រកូលនោះៗ ព្រោះអានិសង្សនៃបុញ្ញកម្មនោះ ។ លុះច្យុតចាក អត្តភាពនោះហើយ បានធ្វើជាមហេសីនៃពួកស្តេចចក្រពត្តិផង

នៃពួកស្តេចមានមណ្ឌលផង ក្នុងអត្តភាពជារបស់មនុស្ស ។ ខ្ញុំបានទទួលសម្បត្តិ ក្នុងទេវលោកទាំងឡាយផង ក្នុងមនុស្សលោកទាំងឡាយផង ដល់នូវសេចក្តីសុខក្នុងទីទាំងពួង ហើយអន្ទោលទៅក្នុងកប្បទាំងឡាយដ៏ច្រើន ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធវិបស្សីជាលោកនាយក មានព្រះនេត្រដ៏រុងរឿង ឃើញនូវពួកធម៌ទាំងអស់ទ្រង់កើតឡើងហើយ ។ ខ្ញុំចូលទៅគាល់ព្រះលោកនាយកនោះ ព្រះអង្គជានរសារថី បានស្តាប់ធម៌ដ៏ប្រសើរហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសាសនានៃព្រះពុទ្ធជាវីរបុរសនោះប្រកបព្យាយាមជាពហុស្សុតអស់ ១ ម៉ឺនឆ្នាំ ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងធម៌ជាបច្ចយាការ ក្លៀវក្លាក្នុងចតុរារិយសច្ច មានបញ្ញាដ៏ល្អិត ជាធម្មកថិកាដ៏វិចិត្រ ជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តាលុះខ្ញុំច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងឋានតុសិត ជាទេវតាមានយសគ្របសង្កត់ពួកទេវតាដទៃ ក្នុងឋានតុសិតនោះ ដោយផលនៃព្រហ្មចរិយធម៌ ។ ខ្ញុំទៅកើតក្នុងទីណាៗ ជាស្រីមានភោគៈច្រើន មានទ្រព្យច្រើន មានប្រាជ្ញា មានរូបល្អ ទាំងបរិស័ទក៏មានសណ្តាប់ធ្នាប់ ។ ខ្ញុំតែងកើតទាន់សាសនានៃព្រះជិនស្រី ដោយបុញ្ញកម្មនិងសេចក្តីព្យាយាមនោះ សម្បត្តិទាំងអស់ខ្ញុំរកបានដោយងាយ ទាំងជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំ

សូម្បីបុរសណាជាកស្តាររបស់ខ្ញុំដែលខ្ញុំដើរទៅក្នុងទីណាៗ កស្តា នោះៗ មិនដែលមើលងាយខ្ញុំឡើយ ព្រោះផលនៃការប្រតិបត្តិ របស់ខ្ញុំ ។ ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកោនាគមនៈ ទ្រង់ មានផៅពង្សប្រសើរ មានយសច្រើន ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើង ។ កាលនោះជន ៣ នាក់ គឺនាងធនញ្ជានី ១ សុមេធា ១ ខ្ញុំ ១ កើតក្នុងត្រកូលដ៏ស្តុកស្តម្ភ ក្នុងនគរ ពារាណសី ។ យើងទាំងឡាយ ជាអ្នកកសាងវិហារ ហើយ ឧទ្ទិសថ្វាយចំពោះព្រះពុទ្ធព្រមទាំងព្រះសង្ឃបានវេរថ្វាយសង្ឃា រាមនិងទានរាប់ដោយពាន់ដ៏ច្រើនចំពោះព្រះមុនី ។ លុះយើង ទាំងឡាយគ្រប់គ្នាច្យុតចាកអត្តភាពនេះហើយបានទៅកើតឯឋាន តាវត្តិង្សដល់នូវភាពជាបុគ្គលប្រសើរដោយយស ទាំងក្នុងមនុស្ស លោកក៏ដូចគ្នា ។ ក្នុងកប្បនេះដដែល ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សប្រសើរ មានយសធំ ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើង ។ គ្រានោះព្រះរាជាក្នុងដែនកាសីព្រះនាម កិកី ជាធំលើប្រជាជន ក្នុងនគរពារាណសី ជាបុរីដ៏ឧត្តមជាឧបដ្ឋាក របស់ព្រះពុទ្ធជាមហេសី ។ ខ្ញុំត្រូវជាធីតាច្បង របស់ព្រះរាជា អង្គនោះដែលគេឮប្រាកដថាឈ្មោះសមណី ខ្ញុំបានស្តាប់ព្រះធម៌ របស់ព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ ព្រះ វររាជបិតាទ្រង់ពុំអនុញ្ញាតដល់យើង គ្រានោះយើងជាអ្នកមិន

ខ្ញុំលប្រមូសទេ ប្រព្រឹត្តព្រហ្មចរិយ សម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំក្នុងផ្ទះ ជាព្រះរាជកញ្ញាឋិតនៅក្នុងសេចក្តីសុខ ត្រេកអរ រីករាយក្នុងការបម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ គឺនាង សមណី ១ សមណាគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ ៧ ។ ( ក្នុងពុទ្ធុប្បាទព្រះ សមណគោតមនេះធីតាទាំង ៧ នោះ ) គឺខុទខ្ញុំ ១ ឧប្បល វណ្ណា ១ បដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ ៧ ។ ក្នុងកាលមួយ ព្រះអង្គ ជាអទិច្ចវង្សរបស់ជនកំពុងសម្តែងធម៌ ខ្ញុំបានស្តាប់មហានិទាន សូត្រ ដែលជាសូត្រមិនទាន់ដែលកើតមាន ហើយរៀនយកនូវ សូត្រនោះ ។ ខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ ក៏ ទៅកើតក្នុងឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំធ្វើល្អនោះផងដោយ ការតម្កល់នូវចេតនានោះផង ។ លុះដល់មកក្នុងបច្ឆិមភពឥឡូវ នេះខ្ញុំបានជាធីតា ជាទីពេញចិត្ត ជាទីស្រឡាញ់ ជាទីប្រោស ប្រាណរបស់ស្តេចព្រះនាមមទ្ទះក្នុងបុរីដ៏ឧត្តមឈ្មោះសាកលា ។ ការក្សេមក្សាន្តកើតមានឡើង ក្នុងបុរីនោះ ដំណាលគ្នានឹងការ ដែលខ្ញុំកើតឡើង ព្រោះហេតុនោះពាក្យថានាងខេមា ជាឈ្មោះ របស់ខ្ញុំកើតឡើងដោយគុណ ។ កាលណា ខ្ញុំដល់នូវវ័យដ៏ ចម្រើនស្អិតស្អាងរូបនិងពណ៌ក្នុងកាលនោះ ព្រះវររាជបិតាបាន

ប្រទានខ្ញុំទៅព្រះបាទពិម្ពិសារ ។ ខ្ញុំជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ព្រះរាជាអង្គនោះ ជាស្រីត្រេកអរក្នុងការប្រកាន់រូប ខ្ញុំមិនដែលបានចូលទៅគាល់ព្រះពុទ្ធព្រះអង្គមានសេចក្ដីអាណិតធំ ដោយខ្ញុំគិតឃើញថាព្រះពុទ្ធជាអ្នកពោលទោសចំពោះរូប ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ញុំាងអ្នកច្រៀងឲ្យច្រៀងសរសើរវត្តវេឡុវ័នឲ្យខ្ញុំស្ដាប់ ដោយឧបាយក្នុងការអនុគ្រោះចំពោះខ្ញុំដូច្នេះថាពួកយើងសម្គាល់ថា បុគ្គលណាមិនឃើញនូវវត្តវេឡុវ័ន ជាទីរីករាយ ជាលំនៅនៃព្រះសុគតទេ នន្ទនឧទ្យាន ក៏ឈ្មោះថាបុគ្គលនោះមិនឃើញដែរ ។ វត្តវេឡុវ័នជាទីរីករាយដ៏ក្រៃលែងរបស់ប្រជាជន បុគ្គលណាបានឃើញហើយឧទ្យានឈ្មោះនន្ទនៈជាទីរីករាយដ៏ក្រៃលែងរបស់សម្ដេចអមរិន្ទ្រាធិរាជ ក៏ឈ្មោះថាបុគ្គលនោះ ឃើញហើយដែរ ។ ពួកទេវតាលះបង់នន្ទនឧទ្យាន ចុះមកលើផ្ទៃផែនដី បានឃើញវត្តវេឡុវ័នជាទីរីករាយហើយ ក៏អស្ចារ្យចំឡែក មិនឆ្អែតក្នុងការមើល ។ វត្តវេឡុវ័ននេះ កើតឡើងដោយបុណ្យព្រះរាជាដែលស្អិតស្អាងហើយដោយបុណ្យរបស់ព្រះពុទ្ធនរណាឡើយអាចពោលនូវការសន្សំគុណរបស់វត្តវេឡុវ័ន ដោយសព្វគ្រប់បាន ។

គ្រានោះខ្ញុំឮនូវសមិទ្ធិនៃវត្តឡុវ័នជារឿងនាំមកដល់ត្រចៀក

និងចិត្តរបស់ខ្ញុំ ខ្ញុំមានប្រាថ្នាចង់ទៅមើលឧទ្យាននោះ ទើបក្រាបទូលព្រះរាជា ។ គ្រានោះព្រះរាជាម្ចាស់ផែនដីអង្គនោះ ទ្រង់បញ្ជូនខ្ញុំដែលកំពុងខ្វល់ខ្វាយដើម្បីទៅ មើលឧទ្យាន ដោយបរិវារច្រើន ដោយព្រះបន្ទូលថា ម្នាលនាងមានភោគៈច្រើន ព្រៃណាដែលគេត្រេកអរហើយ ដោយពន្លឺព្រះសុគត រមែងភ្លឺដោយសិរីគ្រប់កាលទាំងពួង ចូរនាងទៅចុះ ចូរនាងមើលព្រៃនោះដែលជាទីត្រេកអរនៃក្មេក ។ ព្រះមុនីសម្ពុទ្ធ ស្តេចទៅកាន់បុរីដ៏ឧត្តមឈ្មោះគិរិព្វជៈ ដើម្បីបិណ្ឌបាត ក្នុងកាលណា ខ្ញុំក៏ចូលទៅមើលវត្តវេឡុវ័នក្នុងកាលនោះ ។ គ្រានោះវត្តវេឡុ-វ័ននោះ មានដើមឈើរីកផ្កាស្គុសស្គាយដែលទ្រហឹង ដោយភមរជាតិផ្សេងៗប្រកបដោយចម្រៀងនៃសត្វតាវៅ ដែលពួកក្ងោកកំពុងពង់ពេន ។ វត្តវេឡុវ័នជាវត្តមានសំឡេងតិច មិនកុះករដោយមនុស្ស ស្អិតស្អាងដោយទីចង្ក្រមផ្សេងៗ មានកុដិនិងមណ្ឌបរៀបជាជួររៀងរាយដែល យោគីវីរបុរសគួរត្រេកអរដ៏វិសេស ។ កាលខ្ញុំដើរទៅ បានសម្គាល់ឃើញថា ក្មែករបស់ខ្ញុំប្រកបដោយផល ក្នុងគ្រានោះខ្ញុំបានឃើញភិក្ខុកម្ពោះមួយរូបជាអ្នកព្យាយាម ខ្ញុំគិតថា ភិក្ខុនេះឋិតនៅក្នុងព្រៃគួរីករាយបែបនេះប្រកបដោយរូបជាទីត្រេកអរ ហាក់ដូចជារូប កាលនៅក្នុងវ័យក្មេង ។ យី! ភិក្ខុត្រងោលនេះ ឃុំសង្ឃាដីអង្គុយពិនិត្យទៀប

គល់ឈើលះបង់នូវតម្រេកដែលកើតអំពីអារម្មណ៍ ។ ធម៌នេះជា
ធម៌ដ៏ល្អ ក្រែងគ្រហស្ថចាស់ទុំ បរិភោគកាមសុខតាមសប្បាយ
គប្បីប្រព្រឹត្តក្នុងកាលខាងក្រោយទេឬ ។ ខ្ញុំដឹងច្បាស់ថា ព្រៃ
នេះស្ងាត់ ហើយចូលទៅកាន់គន្ធកុដិជាលំនៅព្រះជិនស្រី បាន
ឃើញព្រះជិនស្រីដូចជាព្រះអាទិត្យ កំពុងរះឡើង ។ ខ្ញុំបាន
ឃើញព្រះអង្គគង់ ជាសុខតែមួយព្រះអង្គដែលស្រីដ៏ប្រសើរកំ-
ពុងបក់ថ្វាយ ហើយគិតយ៉ាងនេះថា ព្រះជិនស្រីនេះ ជាបុគ្គល
ប្រសើរជាងជនមិនសៅហ្មងទេ ។ នាងកញ្ញានោះ មានស្បែដូច
មាស មានមាត់និងភ្នែកដូចត្របកផ្កាឈូក មានបបូរមាត់ក្រ-
ហម មានមុខស្រស់បស់ ជាទីត្រេកអរនៃចិត្តនិងភ្នែក មានដង
ខ្លួនល្អ មានសម្បុរដូចមាស មានមាត់ល្អ មានស្តនល្អ មាន
អាការដូចផ្កាឈូក មានពាក់កណ្តាលដងខ្លួនមូលក្លំ មានត្រគាក
ល្អ មានភ្លៅគួរជាទីត្រេកអរ មានគ្រឿងស្អិតស្អាងល្អ ។ មាន
សំពត់បង់លើស្នា ពណ៌ក្រហម មានសំពត់សំលៀកសាច់ម៉ដ្ឋ
ទាំងមានពណ៌ខៀវ ជាកញ្ញាប្រដាប់ដោយអាភរណៈ គ្រប់បែប
ដោយសភាពគួរមើល មិនចេះឆ្អែត ។ លុះខ្ញុំឃើញយ៉ាងនេះ
ហើយទើបគិតថា ឱហ្ន៎ ស្រីនេះមានរូបល្អណាស់ តាំងពីកាល
ណាមក អញមិនដែលឃើញដោយភ្នែកនេះទេ ។ លំដាប់នោះ
ស្រីនោះត្រូវជរាគ្របសង្កត់ទៅជាមានសម្បុរប្លែក មានមាត់វៀច

មានធ្មេញបាក់ មានក្បាលស្កូវព្រោងមានមាត់កខ្វក់ប្រកបដោយទឹកមាត់ហៀរកក្អាក់ ។ មានស្អឹកត្រចៀកខ្វូរ មានភ្នែកសល្អក់ មានស្តនមិនល្អ ស្វិតយុរយារ មានអវយវៈទាំងអស់ជ្រួញជ្រីវ មានសាច់រទុះ មានរាងកាយរវាមដោយសរសៃ ។ មានខ្នងកោង មានឈើច្រត់ជាគម្រប់ពីរ មានសម្បុរលឿងស្លេកស្លាំង ស្គាំងស្គម ញាប់ញ័រចំប្រប់ ដួលដេកស្រេតឹក ដកដង្ហើមផ្ដឹតៗ ។ លំដាប់នោះ ខ្ញុំមានសេចក្ដីសង្វេគដ៏ចំឡែក ជាគ្រឿងព្រឺព្រួចរោម ថា ថ្វីយ ពួកជនពាលតែងរីករាយចំពោះរូបណា រូបនោះជារបស់មិនស្អាត ។ ក្នុងកាលនោះឯង ព្រះបរមសាស្ដា ប្រកបដោយមហាករុណា ឃើញខ្ញុំមានចិត្តសង្វេគ ព្រះអង្គក៏មានព្រះហឫទ័យរីករាយត្រេកអរ បានសម្ដែងនូវគាថាទាំងនេះថា ម្នាលនាងខេមា ចូរនាងមើលគ្រោងកាយ ជារបស់ក្ដៅ ជារបស់មិនស្អាត ជារបស់ស្អុយរលួយដែលហូរខ្ទុចុះខ្ទុរចេញ ដែលមានតែពួកជនពាលទេ ត្រេកត្រអាល ។ នាងចូរអប់រំចិត្ត ដោយអសុភសញ្ញា ឲ្យជាចិត្តមានអារម្មណ៍មូលតែមួយ ឲ្យជាសមាធិចិត្តដ៏ល្អ ចូរនាងមានកាយគតាសតិចុះ ចូរនាងច្រើនដោយនិព្វិទានុបទស្សនាចុះ ។ រូបនេះយ៉ាងណា សរីរៈនៃនាងនោះក៏យ៉ាងនោះ សរីរៈនៃនាងនុ៎ះយ៉ាងណា រូបនេះក៏យ៉ាងនោះដែរ នាងចូរបន្សាត់នូវសេចក្ដីប្រាថ្នា ក្នុងកាយទាំងខាងក្នុង និងខាងក្រៅ

ចេញ ។ មួយទៀត ចូរនាងអប់រំនូវអនិមិត្តសមាធិ លះបង់បោលនូវមានានុស័យ តពីនោះនាងនឹងបានជាបុគ្គលស្ងប់ព្រោះយល់ច្បាស់នូវមានានុស័យ ។

ពួកជនណា ដែលត្រេកអរដោយរាគៈ រមែងធ្លាក់ទៅកាន់ខ្សែគឺតណ្ហាដូចជាសត្វពីងពាងដែលជាប់នឹងបណ្តាញ ដែលខ្លួនឯងធ្វើ លុះតែពួកជនទាំងនោះ ជាអ្នកមិនមានអាល័យ កាត់នូវខ្សែគឺតណ្ហានុ៎ះ លះបង់នូវកាមសុខហើយ ទើបចេញបួសបាន ។

លំដាប់នោះ ព្រះមានព្រះភាគជានរសារថី ជ្រាបច្បាស់នូវខ្ញុំថាជាអ្នកមានចិត្តស្រួលក៏ទ្រង់សម្តែងនូវមហានិទានសូត្រ ដើម្បីបន្ទោរបង់ ( នូវកិលេស ) របស់ខ្ញុំ ។ លុះខ្ញុំបានស្តាប់នូវព្រះសូត្រដ៏ប្រសើរនោះហើយ ក៏រឭកឃើញនូវសញ្ញា ក្នុងកាលមុនខ្ញុំឋិតនៅក្នុងទីនោះបានជម្រះនូវធម្មចក្ខុគឺសោតាបត្តិផលជាគុណដ៏ស្ងប់ ។ ខ្ញុំក្រាបចុះទៀបបាទមូលនៃព្រះសម្ពុទ្ធជាមហេសី ក្នុងខណៈនោះភ្លាមបានពោលពាក្យនេះដើម្បីសម្តែងទោសថា បពិត្រព្រះអង្គទ្រង់ឃើញនូវហេតុទាំងពួង ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គ ទ្រង់មានករុណាជាលំនៅ ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គ ទ្រង់មានសង្សារឆ្លងហើយ ( ខ្ញុំម្ចាស់) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គ ទ្រង់ឲ្យនូវអមតធម៌ ( ខ្ញុំម្ចាស់ ) សូមនមស្ការចំពោះ

ព្រះអង្គ ។ ពួកជនដែលស្ទុះទៅកាន់ព្រៃស្បាតគឺទិដ្ឋិដែលវង្វេង ឈ្លប់ក្នុងកាមរាគៈ ព្រះអង្គបានទូន្មានឲ្យត្រេកអរក្នុងវិន័យដោយឧបាយដ៏ប្រពៃ ។ ពួកសត្វដែលឃ្លាតចាកប្រយោជន៍ ព្រោះមិនបានជួបប្រទះនូវព្រះមហេសីដែលប្រាកដដូចជាព្រះអង្គទេ រមែងរងសេចក្តីទុក្ខធំក្នុងសាគរគឺសង្សារ ។ ក្នុងកាលណា ខ្ញុំមិនបានឃើញព្រះពុទ្ធជាទីពឹងរបស់សត្វលោក ព្រះអង្គមិនមានកងកិលេស ដល់នូវទីបំផុតនៃមរណៈ ខ្ញុំនឹងសម្តែងទោសនោះ មានអត្ថដ៏ពីរោះក្នុងកាលនោះ ។ ខ្ញុំព្រះអង្គឥតមានរង្កៀសចំពោះព្រះពុទ្ធព្រះអង្គមានប្រយោជន៍ធំ ឲ្យនូវគុណដ៏ប្រសើរថា ព្រះអង្គឥតប្រយោជន៍ដូច្នេះឡើយ ខ្ញុំជាអ្នកត្រេកអរក្នុងរូប ទើបមិនបានចូលមកស្គាល់ព្រះអង្គ ខ្ញុំនឹងសូមសម្តែងនូវទោសនោះ ។ កាលនោះព្រះពុទ្ធជិនស្រីមានសំឡេងពីរោះ ប្រកបដោយមហាករុណាស្រោចខ្ញុំដោយទឹកគឺអម្រឹតហើយបានត្រាស់ថា ម្នាលនាងខេមាចូរនាងឈប់សិន ។ ក្នុងកាលនោះ ខ្ញុំឱនប្រណម្យដោយត្បូងធ្វើប្រទក្សិណចំពោះព្រះអង្គហើយទើបដើរចេញទៅ លុះខ្ញុំឃើញព្រះនរបតីហើយ ខ្ញុំពោលពាក្យនេះថា បពិត្រព្រះអង្គទូន្មាននូវសត្រូវ ឱហ្ន៎! ឧបាយនេះព្រះអង្គទ្រង់ព្រះចិន្តាហើយដោយប្រពៃ បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ការរំលត់ ( កិលេស ) ដែលខ្ញុំម្ចាស់ប្រាថ្នាដើម្បីមើលនូវវត្តវេឡុវ័នក៏បានឃើញហើយ ។ បពិត្រ

ព្រះរាជា បើព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ចំពោះសាសនារបស់ព្រះពុទ្ធ ជាបុគ្គលនឹងធឹងនោះ បពិត្រព្រះអង្គជាអ្នកប្រាជ្ញខ្ញុំម្ចាស់ជាអ្នកទៀយណាយក្នុងរូបដោយព្រះវាចា នឹងសូមបួសក្នុងកាលឥឡូវនេះ ។

កាលនោះព្រះរាជាជាម្ចាស់ផែនដីផ្គងអញ្ជលីត្រាស់ថា ម្នាលនាងដ៏ចម្រើន ខ្ញុំអនុញ្ញាតឲ្យនាង សូមបព្វជ្ជារបស់នាងសម្រេចចុះ ។ ក្នុងកាលនោះ ខ្ញុំបួសរួចហើយ លុះដល់ខែ ៧ ប្រាកដហើយ ខ្ញុំបានឃើញនូវការកើតឡើងនិង ការបែកធ្លាយនៃប្រទីបហើយក៏មានចិត្តតក់ស្លុតរន្ធត់ ។ ខ្ញុំជាអ្នកទៀយណាយក្នុងសង្ខារទាំងពួងធ្មៀវខ្លាសក្នុងបច្ចយាការកទ្ធងផុតនូវឱឃៈទាំង ៤ ហើយបាននូវភាពនៃខ្លួនជាព្រះអរហន្ត ។ ខ្ញុំជាស្រីស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុ ក៏ខ្ញុំបានជម្រះហើយ អាសវៈទាំងអស់របស់ខ្ញុំអស់រលីងហើយឥឡូវនេះភពថ្មីទៀតមិនមានទេញាណរបស់ខ្ញុំដ៏បរិសុទ្ធក្នុងអត្ថ ធម៌ និរុត្តិនិងបដិភាណ កើតឡើងហើយ ក្នុងពុទ្ធសាសនា ។ ខ្ញុំជាស្រីវាងវៃក្នុងវិសុទ្ធិទាំងឡាយផង ក្លៀវក្លាក្នុងកថាវត្ថុទាំងឡាយផង ស្គាល់ន័យក្នុងអភិធម្មផង ដល់នូវការស្ទាត់ក្នុងសាសនាផង ។ លំដាប់នោះខ្ញុំដែលព្រះរាជាម្ចាស់ដែនកោសល ទ្រង់សាកសួរទៀបទីក្លោងទ្វារ

ក៏ដោះនូវប្រស្នាទាំងឡាយដ៏ល្អិត តាមសេចក្ដីពិត ។ គ្រានោះ ព្រះរាជានោះ ទ្រង់ចូលទៅគាល់ព្រះសុគត ហើយទូលសួរ ឯព្រះពុទ្ធក៏ទ្រង់ដោះស្រាយដូចខ្ញុំបានដោះស្រាយប្រស្នា ទាំងនោះដែរ ។ ព្រះជិនស្រី ព្រះអង្គជាបុគ្គលឧត្តមជាងជន ត្រេកអរចំពោះគុណនោះ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គថា ខេមាភិក្ខុនីនេះប្រសើរផុតជាងភិក្ខុនីទាំងឡាយដែលមានប្រាជ្ញាច្រើន ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ព្រះថេរីសម្រេចអរហត្តហើយ នៅដោយផលសុខ និព្វានសុខ សូម្បីព្រះថេរីដែលជាទីណាស្រពអង្គដទៃ បរិបូណ៌ដោយបញ្ញាក៏ពិត តែព្រោះនាងធ្វើអធិការទុកមក ទើបគេស្គាល់នាងថាជាអ្នកមានបញ្ញាច្រើន បណ្ដាព្រះថេរីទាំងនោះ ពិតហើយ ព្រះមានព្រះភាគគង់ត្រង់កណ្ដាលព្រះអរិយសង្ឃទាំងឡាយក្នុងវត្តជេតពនមហាវិហារ ទ្រង់កំពុងស្ថាបនាភិក្ខុនីទាំងឡាយ ក្នុងតំណែងតាមលំដាប់ ទ្រង់ក៏ស្ថាបនាព្រះថេរីនោះ ក្នុងតំណែងឯតទគ្គៈ ព្រោះជាអ្នកមានបញ្ញាច្រើនថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុនីដែលជាសាវិការបស់តថាគត ពួកភិក្ខុនីអ្នកមានប្រាជ្ញាច្រើនស្រេចនឹងនាងខេមាប្រសើរជាងគេដូច្នេះ ។

ថ្ងៃមួយ ព្រះថេរីនោះអង្គុយសម្រាកពេលថ្ងៃ ត្រង់គល់ឈើមួយដើមមារមានចិត្តបាបកាឡាខ្លួនជាបុរសកំលោះចូលទៅរក កាលលួងលោមដោយកាម

ទាំងឡាយ ក៏បានពោលគាថាថា

ហៃនាងខេមា នាងនៅក្មេងជាស្រីមានរូប យើងសោត ក៏នៅ
ក្មេងកំលោះ នាងចូរមក យើងនឹងត្រេកត្រអាលដោយតូរ្យតន្ត្រី
ប្រកបដោយអង្គ ៥ ដូច្នេះ ។

គាថានោះ មានសេចក្តីថា នៃនាងខេមា នាងក៏នៅក្មេង នៅក្នុងបឋមវ័យ រូបក៏ស្អាត ខ្ញុំក៏នៅកំលោះ មានវ័យក្មេង ព្រោះដូច្នោះ យើងទាំង ២ កុំឲ្យវ័យក្មេងអស់ទៅទទេ តន្ត្រីមានអង្គ ៥ មាន មកយើងនឹងត្រេកអរជាមួយគ្នា ដោយការត្រេកអរក្នុងការលេងដែលគួរស្រឡាញ់ចុះ ។

នាងខេមាថេរីនោះ ស្តាប់ពាក្យនោះហើយ កាលប្រកាសភាពដែលខ្លួនអស់នូវតម្រេកក្នុងកាមទាំងពួង ១ ភាពដែលបុគ្គលនោះជាមារ ១ ការមិនជ្រះថ្លាក្រៃលែង ក្នុងសត្វដែលប្រកាន់មាំក្នុងអត្តា ១ និងភាពដែលខ្លួនធ្វើកិច្ចស្រេចហើយ ១ ទើបពោលគាថាទាំងនេះថា

អាត្មានឿយណាយ ធុញទ្រាន់ដោយកាយស្អុយ ដែលមាន
ជំងឺជានិច្ចពុកផុយនេះ កាមតណ្ហាអាត្មាបានដកចេញហើយ ។
កាមទាំងឡាយមានឧបមាដោយលំពែងនិងអណ្តោត ជាទីកាប់
ចិញ្ច្រាំ នូវខន្ធទាំងឡាយ អ្នកនិយាយចំពោះតម្រេកក្នុងកាម
ណា ឥឡូវនេះតម្រេកក្នុងកាមនោះ មិនជាទីត្រេកអរនៃអាត្មា
ទេ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់
ចេញហើយ គំនរងងឹតអាត្មាក៏បានទម្លាយហើយ ម្នាលមារ

មានចិត្តបាបអ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯង អាត្មាបានកម្ចាត់ចេញហើយ ។ ពួកជនពាលមិនដឹងតាមពិត សំពះនក្ខត្តឫក្សទាំងឡាយ បូជាភ្លើងក្នុងព្រៃ ហើយសម្គាល់ ថាជាការបរិសុទ្ធ ។ ចំណែកខាងអាត្មា នមស្ការព្រះសម្ពុទ្ធជា បុរសខ្ពង់ខ្ពស់ ជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តាបានរួច ស្រឡះហើយចាកទុក្ខទាំងពួង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អគ្គឹ បរិចរំ វនេ** បានដល់ ត្រាច់បូជាភ្លើង ក្នុងព្រៃគឺតបៈ ។ បទថា **យថាភុច្ចមជានន្តា** បានដល់ មិនដឹងរឿងតាម សេចក្តីពិត ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះ មានន័យដូចពោលមកហើយខាងដើម ។

## អដ្ឋកថាខេមាថេរីគាថា ចប់

# សុជាតាថេរីគាថា

[ ៣១៨ ] អាត្មាអញមានខ្លួនស្អិតស្អាង មានគ្រឿងស្លៀកពាក់ល្អទ្រទ្រង់ផ្កាកម្រងលាបស្រឡាបដោយខ្លឹមចន្ទន៍ បិទបាំងជិតដោយ គ្រឿងអាភរណៈគ្រប់យ៉ាង មានពួកទាសីហែហមហើយ ។ អាត្មាអញ បានយកបាយ ទឹកបង្អែម និងចម្អាបដ៏ច្រើន ចេញទៅអំពីគ្រឹហា នាំចូលទៅកាន់ឧទ្យាន ។ អាត្មាអញត្រេកអរលេងក្នុងឧទ្យាននោះ រួចហើយក៏មកកាន់ផ្ទះរបស់ខ្លួន បានឃើញវិហារហើយ ក៏ចូលទៅកាន់វិហារ ក្នុងព្រៃអញ្ជន ជិតក្រុងសាកេត ។ អាត្មាអញបានឃើញព្រះពុទ្ធ ជាប្រទីបនៃលោក ហើយចូលទៅថ្វាយបង្គំ ឯព្រះអង្គជាបុគ្គលមានចក្ខុ បានសំដែងធម៌ដល់អាត្មាអញ ដោយសេចក្ដីអនុគ្រោះ ។ លុះអាត្មាអញបានស្ដាប់ធម៌ របស់ព្រះមហេសីហើយ ក៏បានចាក់ធ្លុះនូវសច្ចៈបានសម្រេចនូវនិព្វានបទ ឈ្មោះអមតៈ ជាធម៌មិនមានធូលីគឺកិលេស ក្នុងវិហារនោះឯង ។ លំដាប់ពីនោះ អាត្មាអញបានដឹងច្បាស់នូវព្រះសទ្ធម្មហើយ បួសក្នុងធម្មវិន័យបានសម្រេចត្រៃវិជ្ជា ព្រះពុទ្ធសាសនាមិនឥតអំពើឡើយ ។

សុជាតាថេរី ។

## អដ្ឋកថា

# សុជាតាថេរីគាថា

[ ៣១៨ ] គាថារបស់ព្រះនាងសុជាតាថេរី មានពាក្យផ្ដើមថា **អលង្កតា សុវសនា** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ សន្សំបុណ្យដើម្បីការរួចផុតដោយលំដាប់ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងសាកេតនគរ ធំពេញវ័យហើយ មាតាបិតាលើកឲ្យសេដ្ឋីបុត្តដែលមានជាតិស្មើគ្នា មានប្តីហើយ នៅជាមួយប្តីក្នុងត្រកូលនោះជាសុខសប្បាយ ថ្ងៃមួយ ទៅកាន់ឧទ្យានលេងនក្ខត្តឫក្ស កាលមកកាន់នគរជាមួយនឹងមនុស្សដែលចោមរោម បានជួបព្រះសាស្តាក្នុងអញ្ជនវ័ន មានចិត្តជ្រះថ្លា ចូលទៅគាល់ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់នាងហើយ ទ្រង់ជ្រាបថា នាងមានចិត្តសមគួរហើយ ទើបប្រកាសធម្មទេសនាឈ្មោះ សាមុក្កំសិក: ( អរិយសច្ច ៤ ) ឲ្យក្រៃលែង ។ ចប់ព្រះធម៌ទេសនា ទាំងកំពុងអង្គុយនោះ ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ព្រោះខ្លួនបានបំពេញបារមីមកហើយ ១ ព្រោះមានញាណចាស់ក្លា ១ និងព្រោះលម្អនៃទេសនារបស់ព្រះសាស្តា ១ ថ្វាយបង្គំព្រះសាស្តាហើយទៅកាន់ផ្ទះ សូមឲ្យប្តីនិងមាតាបិតាអនុញ្ញាតហើយ ទៅកាន់សម្នាក់របស់ភិក្ខុនីតាមព្រះតម្រាស់របស់ព្រះសាស្តា បួសហើយក្នុងសម្នាក់នៃភិក្ខុនីទាំងឡាយ កាលបួសហើយ ក៏បានពិចារណានូវការបដិបត្តិរបស់ខ្លួន ហើយទើបពោលគាថាទាំងនេះជាឧទានថា

អាត្មាអញមានខ្លួនស្អិតស្អាង មានគ្រឿងស្លៀកពាក់ល្អទ្រទ្រង់
ផ្កាកម្រង លាបស្រឡាបដោយខ្លឹមចន្ទន៍ បិទបាំងជិតដោយ

គ្រឿងអាភរណៈគ្រប់យ៉ាង មានពួកទាសីហែហមហើយ ។ អាត្មាអញ បានយកបាយ ទឹក បង្អែមនិងចម្អាបដ៏ច្រើនចេញទៅអំពីគ្រឹហា នាំចូលទៅកាន់ឧទ្យាន ។ អាត្មាអញត្រេកអរលេងក្នុងឧទ្យាននោះ រួចហើយក៏មកកាន់ផ្ទះរបស់ខ្លួន បានឃើញវិហារហើយ ក៏ចូលទៅកាន់វិហារក្នុងព្រៃអញ្ជនជិតក្រុងសាកេត ។ អាត្មាអញបានឃើញព្រះពុទ្ធ ជាប្រទីបនៃលោកហើយចូលទៅថ្វាយបង្គំ ឯព្រះអង្គជាបុគ្គលមានចក្ខុបានសំដែងធម៌ដល់អាត្មាអញដោយសេចក្តីអនុគ្រោះ ។ លុះអាត្មាអញបានស្តាប់ធម៌របស់ព្រះមហេសីហើយ ក៏បានចាក់ធ្លុះនូវសច្ចៈ បានសម្រេចនូវនិព្វានបទ ឈ្មោះអមតៈ ជាធម៌មិនមាន ធូលីគឺកិលេសក្នុងវិហារនោះឯង ។ លំដាប់ពីនោះ អាត្មាអញបានដឹងច្បាស់នូវព្រះសទ្ធម្មហើយបួសក្នុងធម្មវិន័យ បានសម្រេចត្រៃវិជ្ជា ព្រះពុទ្ធសាសនាមិនឥតអំពើឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលង្កតា** គឺប្រដាប់ ។ បទថា **សុវសនា មាលិនី ចន្ទនោក្ខិតា** នេះ លោកពោលដល់ការតែងខ្លួននោះ ។ បណ្តាបទទាំងនោះបទថា **មាលិនី** គឺកម្រងមាល័យ ។ បទថា **ចន្ទនោក្ខិតា** គឺលាបដោយខ្លឹមចន្ទន៍ ។ បទថា **សព្វាភរណសញ្ឆន្នា** សេចក្តីថា មានរាងកាយបិទបាំងដោយអាភរណៈគ្រប់យ៉ាង មានគ្រឿងប្រដាប់ដៃជាដើម ។ បទថា **អន្នំ ចានំ ច អាទាយ ខជ្ជំ ភោជ្ជំ អនប្បកំ** សេចក្តីថា កាន់យក

បាយ មានបាយនៃស្រូវសាលីជាដើម ទឹកបាន មានទឹកស្វាយជាដើម របស់ទំពា មានរបស់ទំពាធ្វើពីម្សៅជាដើម ក្រៅអំពីនោះ ក៏មានរបស់បរិភោគពោលគឺអាហារដ៏ច្រើន ។ បទថា **ឧយ្យានមភិហារយឹ** បានដល់ ខ្ញុំនាំទៅដើម្បីលេងនក្ខត្តឫក្ស អធិប្បាយថា នាំនូវបាយ និងទឹកជាដើមមកក្នុងឧទ្យាននោះ លេងជាសុខមួយអន្លើដោយអ្នកចោមរោម ។

បាទគាថាថា **សាកេតេ អញ្ជនំ វនំ** សេចក្ដីថា ខ្ញុំចូលទៅកាន់វិហារក្នុងព្រៃអញ្ជនវន ក្នុងនគរសាកេត ។

បទថា **លោកបជ្ជោតំ** បានដល់ ជាពន្លឺនៃលោក ដោយពន្លឺគឺញាណ ។

បទថា **ផុសយឹ** គឺពាល់ត្រូវហើយ អធិប្បាយថា បានសម្រេចអមតធម៌នោះ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា សុជាតាថេរីគាថា ចប់

## អនោបមាថេរីគាថា

[ ៣១៩ ] អាត្មាអញកើតក្នុងត្រកូលខ្ពង់ខ្ពស់ដែលមានគ្រឿងឧបករណ៍ជាទីរីករាយច្រើន មានទ្រព្យច្រើន ជាស្រីបរិបូណ៌ដោយសម្បុរនិងរូប ជាធីតាបង្កើតនៃសេដ្ឋីឈ្មោះមេឃិ ។ ពួកព្រះរាជបុត្ត ក៏ចង់បាន ពួកសេដ្ឋីបុត្តក៏ជាប់ចិត្ត ទើបប្រើទូតទៅ ( ក្នុងសម្នាក់ ) បិតារបស់អាត្មាអញ ( ថា ) សូមអ្នកឲ្យនាងអនោបមាដល់ខ្ញុំ ។ ធីតារបស់អ្នកឈ្មោះអនោបមានុ៎ះ ( លក្ខណញ្ញូជន ) កាត់ថ្លៃចំនួនទ្រព្យប៉ុន្មាន ខ្ញុំសូមជូនប្រាក់និងកែវជា ៨ គុណអំពីទ្រព្យនោះ ។ អាត្មាអញនោះ បានឃើញព្រះសម្ពុទ្ធ ជាចម្បងនៃលោក ព្រះអង្គប្រសើរបំផុត ក៏ចូលទៅក្នុងទីសមគួរ ថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។ ព្រះគោតមនោះ បានសំដែងធម៌ដល់អាត្មាអញដោយសេចក្តីអនុគ្រោះ អាត្មាអញអង្គុយលើអាសនៈនោះ ហើយបានសម្រេចនូវផលទី ៣ ។ លំដាប់ពីនោះមក អាត្មាអញបានកោរសក់ទាំងឡាយ ហើយបួសក្នុងធម្មវិន័យ រាត្រីគម្រប់ ៧ របស់អាត្មាអញក្នុងថ្ងៃនេះ ជារាត្រីដែលតណ្ហារីងស្ងួត ។

**អនោបមាថេរី ។**

## អដ្ឋកថា

## អនោបមាថេរីគាថា

[ ៣១៩ ] គាថារបស់ព្រះនាងអនោបមាថេរី មានពាក្យផ្តើមថា **ឧច្ចេ កុលេ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ចម្រើននូវធម៌ទាំងឡាយដែលជាគ្រឿងអប់រំបន្ទំវិមុត្តិមកដោយលំដាប់ ក្នុងពុទ្ធុប្បាទនេះ កើតជាធីតារបស់សេដ្ឋីឈ្មោះមេឃី ក្នុងនគរសាកេត នាងមានរូបស្អាត ទើបមានឈ្មោះថាអនោបមា ក្នុងកាលដែលនាងធំពេញក្រមុំហើយ សេដ្ឋីបុត្ត មហាមាត្យរបស់ព្រះរាជា និងព្រះរាជា ជាច្រើន បាននាំគ្នាបញ្ជូនទូតទៅសូមដល់បិតាថា សូមលោកឲ្យធីតាឈ្មោះអនោបមា ដល់ខ្ញុំចុះ យើងទាំងឡាយនឹងឲ្យវត្ថុឈ្មោះនេះៗដល់លោក នាងបានស្តាប់ទូតនោះហើយ ព្រោះដល់ព្រមដោយឧបនិស្ស័យគិតថា អញមិនត្រូវការនៅជាយរាវាសទើបទៅគាល់ព្រះសាស្តា ស្តាប់ធម៌ ផ្តើមវិបស្សនា តាមក្រសែព្រះធម្មទេសនា ព្រោះញាណចាស់ក្លាហើយ កាលខ្មីឃ្មាតក្នុងវិបស្សនានោះ បានតាំងនៅហើយក្នុងផលទី ៣ តាមលំដាប់នៃមគ្គ ។ នាងទូលសូមបព្វជ្ជាជាមួយព្រះសាស្តា ហើយចូលទៅកាន់សម្នាក់របស់ភិក្ខុនី តាមព្រះតម្រាស់របស់ព្រះសាស្តាបួសក្នុងសម្នាក់របស់ភិក្ខុនីទាំងឡាយ បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តក្នុងថ្ងៃទី ៧ ពិចារណាដល់ការបដិបត្តិរបស់ខ្លួនហើយ បានពោលគាថាទាំងនេះ ជាឧទានថា

អាត្មាអញកើតក្នុងត្រកូលខ្ពង់ខ្ពស់ ដែលមានគ្រឿងឧបករណ៍
ជាទីរីករាយច្រើនមានទ្រព្យច្រើន ជាស្រីបរិបូណ៌ដោយសម្បុរ
និងរូប ជាធីតាបង្កើតនៃសេដ្ឋីឈ្មោះមេឃិ ។ ពួកព្រះរាជបុត្ត

ក៏ចង់បាន ពួកសេដ្ឋីបុត្តក៏ជាប់ចិត្ត ទើបប្រើទូតទៅ ( ក្នុងសម្នាក់ ) បិតារបស់អាត្មាអញ ( ថា ) សូមអ្នកឲ្យនាងអនោបមាដល់ខ្ញុំ ។ ធីតារបស់អ្នកឈ្មោះអនោបមានុ៎ះ ( លក្ខណញ្ញូជន ) កាត់ថ្លៃចំនួនទ្រព្យប៉ុន្មាន ខ្ញុំសូមជូនប្រាក់និងកែវជា ៨ គុណ អំពីទ្រព្យនោះ ។ អាត្មាអញនោះ បានឃើញព្រះសម្ពុទ្ធជាចម្បងនៃលោក ព្រះអង្គប្រសើរបំផុត ក៏ចូលទៅក្នុងទីសមគួរ ថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។ ព្រះគោតមនោះ បានសំដែងធម៌ដល់អាត្មាអញ ដោយសេចក្ដីអនុគ្រោះអាត្មាអញអង្គុយលើអាសនៈនោះ ហើយបានសម្រេចនូវផលទី ៣ ។ លំដាប់ពីនោះមក អាត្មាអញបានកោរសក់ទាំងឡាយហើយបួសក្នុងធម្មវិន័យ រាត្រីគម្រប់ ៧ របស់អាត្មាអញក្នុងថ្ងៃនេះជារាត្រីដែលតណ្ហារីងស្ងួត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧច្ចេ កុលេ** បានដល់ ក្នុងត្រកូលវេស្សៈដែលប្រសើរបំផុត ។ បទថា **ពហុវិត្តេ** បានដល់ ឧបករណ៍និងទ្រព្យជាគ្រឿងត្រេកអរនៃចិត្តជាច្រើនមានគ្រឿងប្រដាប់ជាដើម ។ បទថា **មហទ្ធនេ** ប្រកបសេចក្ដីថា ខ្ញុំកើតហើយក្នុងត្រកូលមានទ្រព្យច្រើន ព្រោះមានទ្រព្យច្រើនប្រមាណ ៤០ កោដិ ដែលរក្សាទុក ។ បទថា **វណ្ណរូបេន សម្បន្នា** សេចក្ដីថា សម្បូរដោយពណ៌សម្បុរ សណ្ឋាន និងសម្បូរដោយរូប គឺមានពណ៌សម្បុរគួរស្រឡាញ់ ប្រកបដោយសម្បត្តិ គឺធាវីវណ្ណស្អាតផូរផង់ និងសម្បត្តិ

នៃចំណែកកាងកាយ មានពស្រ្តាភរណៈជាដើម ។ បទថា **ធីតា មេឃិស្ស អត្រជា** សេចក្តីថា ជាធីតាបង្កើតរបស់សេដ្ឋីឈ្មោះមេឃី ។

បទថា **បត្ថិតា រាជបុត្តេហិ** សេចក្តីថា ព្រះរាជកុមារទាំងឡាយប្រាថ្នាថា ពួកយើងគប្បីបានធីតានោះដូចម្តេចហ្ន៎ ។ បទថា **សេដ្ឋិបុត្តេហិ គិជ្ឈិតា** បានដល់ សេដ្ឋីកុមារទាំងឡាយក៏ត្រូវការ គឺប្រាថ្នាយ៉ាងនោះដូចគ្នា ។ បទថា **ធេដ មយ្ហំ អនោបមំ** សេចក្តីថា ព្រះរាជបុត្តជាដើម បានបញ្ជូនទូតមកសូមក្នុងសម្នាក់បិតាថា សូមលោកឲ្យអនោបមាធីតា ដល់យើងខ្ញុំចុះ សូមលោកឲ្យអនោបមាធីតា ដល់យើងខ្ញុំចុះ ។ បទថា **យត្តកំ តុលិតា ឯសា** ប្រកប សេចក្តីថា ឥស្សរជន មានកុមារជាដើម បញ្ជូនទូតមកកាន់បិតារបស់ខ្ញុំប្រាប់ថា អ្នកចេះមើលលក្ខណៈវាយតម្លៃ គឺកំណត់ថា អនោបមាធីតារបស់លោក គួរដល់តម្លៃទ្រព្យប៉ុនណា ខ្ញុំនឹងបន្ថែម ៨ ដង អំពីតម្លៃនោះ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយខាងដើមនោះឯង ។

## អដ្ឋកថា អនោបមាថេរីគាថា ចប់

# មហាបជាបតិគោតមីថេរីគាថា

[ ៣២០ ] បពិត្រព្រះពុទ្ធមានព្យាយាម អ្នកខ្ពង់ខ្ពស់ជាងសព្វសត្វទាំងឡាយខ្ញុំសូមថ្វាយបង្គំព្រះអង្គដែលទ្រង់បានប្រោសខ្ញុំព្រះអង្គនិងជនដទៃច្រើនគ្នាឲ្យរួចចាកទុក្ខ ។ សេចក្តីទុក្ខទាំងពួងខ្ញុំព្រះអង្គបានកំណត់ដឹងហើយ តណ្ហាជាដើមចម ( នៃទុក្ខ ) ខ្ញុំព្រះអង្គបានធ្វើឲ្យរីងស្ងួតហើយ មគ្គប្រកបដោយអង្គ ៨ ខ្ញុំព្រះអង្គបានចម្រើនហើយនិរោធធម៌ខ្ញុំព្រះអង្គបានសម្រេចហើយ ។ មាតាបិតា បុត្ត បងប្អូន និងជីដូនជីតាដែលមានក្នុងកាលមុន ខ្ញុំព្រះអង្គក៏មិនដឹងតាមពិតមិនបាន ( នូវទីពឹងក្នុងសមុទ្ទគឺសង្សារ ) បានអន្ទោលទៅ ( យកកំណើតផ្សេងៗ ) ព្រះមានព្រះភាគអង្គនោះ ខ្ញុំព្រះអង្គបានឃើញហើយ រាងកាយ ( របស់ខ្ញុំព្រះអង្គ ) នេះជាទីបំផុតហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះភពថ្មីមិនមាន ។ សូមព្រះអង្គទតនូវពួកសាវ័ក អ្នកមានព្យាយាមតឹងតែង មានចិត្តស្ទុងទៅរកព្រះនិព្វាន មានព្យាយាមមាំជានិច្ច ជាអ្នកព្រមព្រៀងគ្នានេះជាការថ្វាយបង្គំចំពោះព្រះពុទ្ធទាំងឡាយ ។ ឱហ្ន៎ ព្រះនាងមាយាបានបង្កើតព្រះគោតមដើម្បីជាប្រយោជន៍ដល់ពួកជនច្រើនគ្នា ( ព្រោះថា ) ព្រះគោតម បានបន្ទោបង់នូវគំនរទុក្ខនៃពួកជន ដែលត្រូវព្យាធិ និងមរណៈចាក់ដោត ។

**មហាបជាបតិគោតមីថេរី ។**

# អដ្ឋកថា
## មហាបជាបតិគោតមីថេរីគាថា

[ ៣២០ ] គាថារបស់ព្រះនាងមហាបជាបតិគោតមីថេរី មានពាក្យផ្ដើមថា **ពុទ្ធវីរ នមោ ត្យត្ថុ** ដូច្នេះជាដើម ។

បានឮថា កុលធីតាអង្គនេះ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលក្នុងក្រុងហង្សវតី ដល់នូវភាពជាអ្នកដឹងក្ដីហើយ កំពុងស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ឃើញព្រះសាស្ដា ទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈរបស់ភិក្ខុនី ខាងរតញ្ញូធ្វើកុសលកម្មឲ្យក្រៃលែង ហើយប្រាថ្នាតំណែងនោះ ធ្វើបុណ្យមានទានជាដើមដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយសែនកប្ប ក្នុងលោកដែលមិនមានព្រះពុទ្ធ ក្នុងចន្លោះព្រះមានព្រះភាគ ព្រះនាមកស្សបៈនិងព្រះមានព្រះភាគនៃយើងទាំងឡាយ បានកើតជាប្រធាននៃទាសី ៥០០ នាក់ ក្នុងនគរពារាណសី ។ កាលនោះនាងបានឃើញព្រះបច្ចេកពុទ្ធ ៥ អង្គ ក្នុងថ្ងៃចូលវស្សា ចុះអំពីភ្នំនន្ទមូលកៈមកកាន់ឥសិបតនៈ ហើយត្រាច់បិណ្ឌបាតក្នុងនគរត្រឡប់ទៅកាន់ឥសិបតនៈវិញ ស្វែងរកហត្ថកម្មដើម្បីសាងកុដិក្នុងថ្ងៃចូលវស្សាបានបបួលស្រីទាសីទាំងនោះ មួយអន្លើដោយស្វាមីរៀងៗខ្លួនឲ្យនាំគ្នាសាងកុដិ ៥ ខ្នង មួយអន្លើដោយវត្ថុប្រកប មានទីចង្រ្កមជាដើមតម្កល់គ្រែ តម្កល់ទឹកឆាន់ទឹកប្រើប្រាស់ និងភាជនៈជាដើមស្រេចបាច់និមន្តព្រះបច្ចេកពុទ្ធដើម្បីនៅចាំវស្សាអស់ត្រៃមាស ក្នុងទីនោះៗឯងហើយតាំង

ភិក្ខាប្រគេនតាមវារៈ ។ ស្ត្រីម្នាក់មិនអាចថ្វាយភិក្ខាក្នុងថ្ងៃដែលដល់វារៈរបស់ខ្លួនបាន នាងក៏នាំយកភិក្ខាអំពីផ្ទះរបស់ខ្លួនទៅថ្វាយជំនួស នាងបដិបត្តិយ៉ាងនេះអស់ ៣ ខែ កាលដល់ថ្ងៃបវារណា ឲ្យទាសីម្នាក់លះបង់សំពត់សាដកម្នាក់មួយផ្ទាំង រួមជាសំពត់សាដកសាច់គ្រោតគ្រាត ៥០០ ផ្ទាំង ឲ្យរៀបចំសំពត់ទាំងនោះ ធ្វើជាត្រៃចីវរថ្វាយដល់ព្រះបច្ចេកពុទ្ធ ៥ អង្គ ព្រះបច្ចេកពុទ្ធទាំង ៥ អង្គ បានហោះទៅកាន់ភ្នំគន្ធមាទន៍ឲ្យស្រីទាំងនោះឃើញនោះឯង ។

ស្រីទាំងនោះ បានធ្វើកុសលជាបដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោក ប្រធានស្រីទាំងនោះចុតិអំពីទេវលោកកើតក្នុងផ្ទះរបស់មេជាងតម្បាញក្នុងស្រុកនៃជាងតម្បាញ ដែលមិនឆ្ងាយអំពីក្រុងពារាណសី ដល់នូវភាពជាអ្នកដឹងក្តីហើយ បានជួបព្រះបច្ចេកពុទ្ធ ៥០០ អង្គ ជាឱរសរបស់ព្រះនាងបទុមវតី មានចិត្តស្រឡាញ់រាប់អានថ្វាយបង្គំគ្រប់អង្គហើយ ប្រគេនភិក្ខា ។ ព្រះបច្ចេកពុទ្ធទាំងនោះឆាន់ស្រេចហើយ ក៏ត្រឡប់ទៅកាន់ភ្នំគន្ធមាទន៍ ស្រីជាភរិយាប្រធានអ្នកតម្បាញនោះ ធ្វើកុសលជាបដល់អស់ជីវិត អន្ទោលក្នុងទេវតានិងមនុស្សទាំងឡាយហើយ បដិសន្ធិក្នុងព្រះរាជវាំង របស់ព្រះបាទមហាសុប្បពុទ្ធនគរទេវទហៈ មុនព្រះសាស្តានៃយើងទ្រង់កើតឡើង មានព្រះនាមតាមគោត្តថាគោតមី ជាកនិដ្ឋភគិនីរបស់ព្រះនាងមហាមាយាទេវីពួកហោរាអ្នកទាយលក្ខណៈបានព្យាករថាទារកទាំងឡាយដែលនៅក្នុងផ្ទៃរបស់ស្រីទាំង ២ នេះនឹងបានជាស្តេចចក្រពត្តិ ។ កាលចម្រើនវ័យហើយ ព្រះបាទសុទ្ធោទនមហារាជទ្រង់ធ្វើមង្គលទាំង ២ អង្គ ហើយនាំទៅកាន់ព្រះរាជវាំងរបស់ព្រះ

អដ្ឋ ។

តមកកាលព្រះសាស្តានៃយើងទាំងឡាយ ទ្រង់កើតឡើងទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ធ្វើនូវការអនុគ្រោះ ប្រោសវេនេយ្យសត្តទាំងឡាយក្នុងទីនោះៗ ដោយលំដាប់ទ្រង់អាស្រ័យក្រុងវេសាលី គង់នៅក្នុងកូដាគារសាលា ។ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវអរហត្តហើយ ទ្រង់បរិនិព្វានខាងក្រោមមហាស្វេតច្ឆត្រ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី មានបំណងនឹងបួស កាលទូលសូមបព្វជ្ជានឹងព្រះសាស្តាលើកទី ១ មិនបាន លើកទី ២ ឲ្យកោរកេសាហើយស្លៀកដណ្តប់សំពត់កាសាវៈ បានយាងទៅកាន់ក្រុងវេសាលីជាមួយស្រីដែលជាបាទបរិចារិការបស់សក្យកុមារ ៥០០ ដែលមានបំណងបួស ក្រោយអំពីព្រះពុទ្ធសម្តែងកលហវិវាទសូត្រចប់ សូមឲ្យព្រះអានន្ទទូលអង្វរព្រះសាស្តា ទើបបានបព្វជ្ជានិងឧបសម្បទា ដោយគរុធម៌ ៨ ប្រការ ឯស្រីក្រៅអំពីនេះបានឧបសម្បទាជាមួយគ្នាទាំងអស់ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ឯសេចក្តីពិស្តារក្នុងរឿងនោះក៏មកក្នុងបាលី ( វិនយបិដក ចុល្លវគ្គភិក្ខុនីខន្ធក ) ទាំងអស់នោះឯង ។

ចំណែកព្រះនាងមហាបជាបតិគោតមីបានឧបសម្បទាយ៉ាងនេះហើយបានចូលទៅគាល់ព្រះសាស្តា អភិវាទហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង កាលនោះព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះនាងហើយព្រះនាងរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ព្យាយាមភាវនាមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត មួយអន្លើដោយអភិញ្ញានិងបដិសម្ភិទា ឯភិក្ខុនីទាំង ៥០០ ដ៏សេស

បានអភិញ្ញា ៦ ក្នុងកាលចប់នន្ទកោវាទសូត្រ ។ ថ្ងៃមួយ ព្រះសាស្តាគង់កណ្តាលព្រះអរិយៈទាំងឡាយ ក្នុងវត្តជេតពនមហាវិហារ ទ្រង់តាំងព្រះនាងមហាបជាបតិគោតមីថេរីទុកក្នុងតំណែងឯតទគ្គៈទើបព្រះនាងជាកំពូលជាងភិក្ខុនីទាំងឡាយអ្នកដឹងរាត្រីយូរ ។ ព្រះនាងសម្ងំនៅដោយផលសុខ និងដោយនិព្វានសុខ តាំងនៅក្នុងភាពជាកតញ្ញូ ។ ថ្ងៃមួយ កាលព្យាករអរហត្តដោយមុខ គឺធ្វើនូវការសរសើរនូវព្រះគុណនិងប្រកាស ភាពដែលនាងមានឧបការៈដល់ព្រះសាស្តាមុន ទើបពោលគាថាទាំងនេះថា

បពិត្រព្រះពុទ្ធមានព្យាយាម ខ្ពង់ខ្ពស់ជាងសព្វសត្វទាំងឡាយ ខ្ញុំសូមថ្វាយបង្គំព្រះអង្គដែលទ្រង់បានប្រោសខ្ញុំព្រះអង្គ និងជនដទៃច្រើនគ្នាឲ្យរួចចាកទុក្ខ ។ សេចក្តីទុក្ខទាំងពួង ខ្ញុំព្រះអង្គបានកំណត់ដឹងហើយ តណ្ហាជាដើមចម ( នៃទុក្ខ ) ខ្ញុំព្រះអង្គបានធ្វើឲ្យរីងស្ងួតហើយ មគ្គប្រកបដោយអង្គ ៨ ខ្ញុំព្រះអង្គបានចម្រើនហើយនិរោធធម៌ខ្ញុំព្រះអង្គបានសម្រេចហើយ។ មាតាបិតា បុត្ត បងប្អូននិងជីដូនជីតាដែលមានក្នុងកាលមុន ខ្ញុំព្រះអង្គក៏មិនដឹងតាមពិត មិនបាន ( នូវទីពឹងក្នុងសមុទ្ទគឺសង្សារ ) បានអន្ទោលទៅ ( យកកំណើតផ្សេងៗ ) ព្រះមានព្រះភាគអង្គនោះ ខ្ញុំព្រះអង្គបានឃើញហើយ រាងកាយ ( របស់ខ្ញុំព្រះអង្គ ) នេះ ជាទីបំផុតហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះភពថ្មីមិនមាន ។ សូមព្រះអង្គទតនូវ

ពួកសាវកអ្នកមានព្យាយាមតឹងតែង មានចិត្តស្ងួនទៅរកព្រះនិព្វាន មានព្យាយាមមាំជានិច្ច ជាអ្នកព្រមព្រៀងគ្នា នេះជាការថ្វាយបង្គំចំពោះព្រះពុទ្ធទាំងឡាយ ។ ឱហ្ន៎ ព្រះនាងមាយាបានបង្កើតព្រះគោតម ដើម្បីជាប្រយោជន៍ ដល់ពួកជនច្រើនគ្នា ( ព្រោះថា ) ព្រះគោតមបានបន្ទោបង់នូវគំនរទុក្ខនៃពួកជនដែលត្រូវព្យាធិនិងមរណៈចាក់ដោត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពុទ្ធវីរ** បានដល់ ជាអ្នកក្លៀវក្លាក្នុងពួកបុគ្គលដែលត្រាស់ដឹងសច្ចៈ ៤ ។ ពិតហើយ ព្រះពុទ្ធគ្រប់អង្គឈ្មោះថា ជាអ្នកក្លៀវក្លាជាងបុគ្គលដែលមានសេចក្តីព្យាយាម ឬបុគ្គលដែលត្រាស់ដឹងសច្ចៈ ៤ ព្រោះទ្រង់បាននូវជ័យជម្នះ ដោយការធ្វើកិច្ចឲ្យសម្រេចដោយសេចក្តីព្យាយាម គឺសម្មប្បធាន ៤ យ៉ាង ។ ឯព្រះមានព្រះភាគគួរបានទទួលនូវពាក្យសរសើរថាវីរៈ ព្រោះទ្រង់ប្រកបដោយសេចក្តីព្យាយាមជាពិសេស ព្រោះបរិបូណ៌ដោយវីរិយបារមី គឺការធ្វើកិច្ចឲ្យសម្រេចដោយសម្មប្បធាន ៤ យ៉ាង ដោយការអធិដ្ឋានសេចក្តីព្យាយាមដែលប្រកបទៅដោយអង្គ ៤ ទ្រង់ញ៉ាំងការធ្វើកិច្ចឲ្យសម្រេចនោះប្រតិស្ឋានដោយប្រពៃ ក្នុងសន្តានរបស់វេនេយ្យសត្វ។ បទថា **នមោ ត្យត្ថុ** សេចក្តីថា កិរិយានមស្ការ គឺការឱនលំទោន សូមមានដល់ព្រះអង្គ ។ បទថា **សព្វសត្តានមុត្តម** បានដល់ បពិត្រព្រះមានព្រះភាគ ទ្រង់ឧត្តមដោយគុណមានសីលជាដើម ជាងសត្វទាំងឡាយ មានសត្វឥតជើងជាដើម ។ ដើម្បីសម្តែងគុណរបស់ព្រះសាស្តា ដែលជាចំណែកមួយ

នៃគុណ មានសីលគុណជាដើមនោះទើបព្រះថេរីពោលថា **យោ មំ ទុក្ខា បមោចេសិ អញ្ញញ្ច ពហុកំ ជនំ** ដូច្នេះ កាលប្រកាសភាពដែលខ្លួនរួចផុតហើយចាកទុក្ខ បានពោលគាថាថា **សព្វទុក្ខំ** ដូច្នេះជាដើម ។

ព្រះនាងកាលសម្ដែងហេតុដែលដោះវដ្ដទុក្ខបានដោយឯកទេសបានពោលគាថានេះថា **មាតា បុត្តោ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **មាតា បុត្តោ** ជាដើម សេចក្ដីថា ក្នុងភពណាបានជាមាតារបស់បុត្តម្នាក់ហើយ ក្នុងភពដទៃអំពីភពនោះបានជាបុត្តរបស់បុគ្គលនោះឯងទៀតអធិប្បាយថា ភពតទៅក៏ជាបិតា ជាបងប្រុស ប្អូនប្រុស ។ បទថា **យថាភុច្ចំ អជានន្តី** គឺមិនដឹងដល់បវត្តិនិងហេតុជាដើមតាមសេចក្ដីពិត ។ បទថា **សំសរឹហំ អ-និព្វិសំ** ព្រះនាងត្រាស់ថា ខ្ញុំកាលមិនជួប គឺមិនបាននូវទីពឹងក្នុងសមុទ្រ គឺសង្សារវដ្ដ ទើបអន្ទោលស្លាប់កើតក្នុងភពជាដើម បានត្រាស់ពាក្យជាដើមថា **មាតា បុត្តោ** ដូច្នេះ អធិប្បាយថា ក្នុងភពណាជាមាតាបន្ទាប់អំពីភពនោះជាបុត្តនោះឯង ភពតទៅទៀតជាបិតា ជាបងប្រុស ជាប្អូនប្រុស ។

ព្រះថេរីប្រកាសភាពដែលខ្លួនផុតហើយចាកទុក្ខ ដោយគាថាថា **ទិដ្ឋោ ហិ មេ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ទិដ្ឋោ ហិ មេ សោ ភគវា** សេចក្ដីថា ខ្ញុំបានជួបព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯងអង្គនោះ ដោយប្រចក្ស ដោយចក្ខុ គឺញាណ ដោយការឃើញនូវលោកុត្តរធម៌ដែលព្រះអង្គទ្រង់ឃើញហើយ ។ ពិតហើយ បុគ្គលណាឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញព្រះមានព្រះភាគ ដូចទ្រង់ត្រាស់ទុក ( ក្នុង

សំយុត្តនិកាយខន្ធវារវគ្គ ) ថា ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌បុគ្គល នោះ ឈ្មោះថា ឃើញតថាគត ដូច្នេះជាដើម ។

បទថា **អារទ្ធវីរិយេ** គឺផ្គងសេចក្ដីព្យាយាមទុក ។ បទថា **បហិតត្តេ** គឺជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ បទថា **និច្ចំ ទឡ្ហបរក្កមេ** បានដល់ ដែលមានសេចក្ដីព្យាយាមសព្វកាល ដើម្បីសម្រេចធម៌ដែលមិនទាន់សម្រេច ដើម្បីភាពបរិបូណ៌នៃធម៌ដែលសម្រេចហើយ និងដើម្បីផលសមាបត្តិ ។ បទថា **សមគ្គេ** បានដល់ ឈ្មោះថា ជាអ្នកព្រមព្រៀងគ្នា ព្រោះត្រូវប្រមូលទុកដោយសីលសាមញ្ញតានិងទិដ្ឋិសាមញ្ញតា ។ ឈ្មោះថា **សាវកេ** ព្រោះជាអ្នកកើតក្នុងទីបំផុតនៃការស្ដាប់ទេសនារបស់ព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់ឃើញពួកសាវកតាមសេចក្ដីពិតថា ជនទាំងនេះតាំងនៅក្នុងមគ្គ ជនទាំងនេះតាំងនៅក្នុងផល ។ បទថា **ឯសា ពុទ្ធាន វន្ទនា** សេចក្ដីថា ធ្វើឲ្យប្រចក្សដល់ខ្លួននូវលោកុត្តរធម៌ដែលជាធម្មសរីរៈរបស់ព្រះសាស្ដានិងជាអរិយភាវៈរបស់អរិយសាវកទាំងឡាយឯណា នុ៎ះជាការថ្វាយបង្គំ គឺការបង្អោនទៅក្នុងព្រះគុណតាមសេចក្ដីពិតដល់ព្រះសម្មាសម្ពុទ្ធ និងសាវកពុទ្ធទាំងឡាយ។

ព្រះថេរបានប្រកាសភាពដែលព្រះសាស្ដា ជាអ្នកមានឧបការៈច្រើនដល់លោកដោយគាថាចុងក្រោយថា **ពហូនំ វត អត្ថាយ** ជាដើម តែដោយអត្ថពាក្យដែលមិនថៃកទុកក្នុងទីនេះដឹងបានងាយហើយ ។

សម័យមួយ កាលព្រះសាស្ដាគង់នៅក្នុងកូដាគារសាលានាព្រៃមហាវន ក្រុងវេសាលី ព្រះនាងមហាបជាបតិគោតមីថេរី នៅក្នុងសម្នាក់នៃភិក្ខុនីក្នុង

ក្រុងវេសាលីនោះដែរ ក្នុងវេលាព្រឹកត្រាច់បិណ្ឌបាត សោយភត្តាហារហើយ សម្រាំនៅដោយសេចក្ដីសុខក្នុងផលសមាបត្តិ តាមកាលដែលកំណត់ទុកក្នុងទីសម្រាកពេលថ្ងៃរបស់ព្រះនាង ចេញអំពីផលសមាបត្តិ ពិចារណាការបដិ-បត្តិរបស់ខ្លួនកើតសោមនស្ស ពិចារណាដល់អាយុសង្ខាររបស់ព្រះនាង ដឹងថា អាយុសង្ខារទាំងនោះអស់ហើយ ព្រះនាងត្រិះរិះយ៉ាងនេះថា បើដូច្នោះអញនឹងទៅកាន់វិហារ សូមឲ្យព្រះមានព្រះភាគទ្រង់អនុញ្ញាត ហើយលាព្រះថេរៈទាំងឡាយនិងសព្រហ្មចារីគ្រប់រូបដែលជាទីចម្រើនចិត្តរបស់ខ្លួន ហើយមកបរិនិព្វានក្នុងទីនេះឯង ភិក្ខុនី ៥០០ រូបដែលជាបរិវាររបស់ព្រះនាង ក៏មានបរិវិតក្កដូចព្រះថេរី សមដូចគាថាព័ន្ធដែលលោកពោលទុក ក្នុងអបទានថា

ក្នុងសម័យមួយ ព្រះសម្ពុទ្ធជាប្រទីបនៃលោកព្រះអង្គជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់គង់នៅក្នុងកូដាគារសាលាក្នុងមហាវ័នទៀបក្រុងវេសាលី ។ កាលនោះ ភិក្ខុនីឈ្មោះមហាបជាបតិគោតមី ជាព្រះមាតុច្ឆា នៃព្រះជិនស្រី នៅក្នុងសំណាក់ភិក្ខុនី ជិតបុរីជាទីរីករាយនោះឯង ។ ព្រះនាងមហាបជាបតិគោតមីភិក្ខុនី នៅក្នុងទីស្ងាត់ជាមួយនឹងពួកភិក្ខុនីដែលមានចិត្តរួចស្រឡះចាកកិលេសចំនួន ៥០០ រូប ព្រះនាងមានចិត្តត្រិះរិះយ៉ាងនេះថា អញ ( បើរស់នៅ ) មិនបានទាន់ការបរិនិព្វាននៃព្រះសម្ពុទ្ធ នៃគូសាវ័ក នៃរាហុល អានន្ទ និង

នន្ទទេ នឹងសូមអនុញ្ញាតព្រះលោកនាថជាមហេសី លះបង់នូវអាយុសង្ខារទៅកាន់ព្រះនិព្វានក្លាមៗ ។ សេចក្តីត្រិះរិះរបស់នាងភិក្ខុនី ៥០០ រូបក្តី សេចក្តីត្រិះរិះរបស់នាងភិក្ខុនីទាំងឡាយមាននាងភិក្ខុនីឈ្មោះខេមាជាដើមនេះក្តី ក៏ដូចព្រះនាងគោតមីដែរ ។ គ្រានោះមាន ការកក្រើកផែនដី ទាំងផ្គរក៏លាន់ឮឡើង ទេវតាទាំងឡាយដែលអាស្រ័យនៅក្នុងសំណាក់ភិក្ខុនី ក៏ត្រូវសេចក្តីសោកបៀតបៀន ។ ( ទេវតាទាំងនោះ ) យំទួញញុំាងទឹកភ្នែកនិងសេចក្តីករុណា ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ភិក្ខុនីទាំងអស់ចូលទៅជិតនាងគោតមីភិក្ខុនី ជាមួយនឹងទេវតាទាំងនោះ ហើយក្រាបចុះដោយសិរ្សៈទៀបបាទា ពោលនូវពាក្យនេះថា បពិត្រព្រះនាងជាម្ចាស់ យើងទាំងឡាយនៅក្នុងទីស្ងាត់ ត្រូវតំណក់ទឹកស្រោចស្រពហើយ ក្នុងទីនោះ ។ បពិត្រព្រះនាងគោតមីជាម្ចាស់ ផែនដីនោះ កក្រើក ញាប់ញ័រ ទាំងផ្គរក៏លាន់ឮឡើងទាំងសេចក្តីខ្សឹកខ្សួល ពួកយើងក៏បានឮដែរតើមានហេតុដូចម្តេច ។ គ្រានោះព្រះនាង ក៏ប្រាប់នូវហេតុទាំងអស់ដែលនាងត្រិះរិះ ។ លំដាប់នោះភិក្ខុនីទាំងអស់ បានប្រាប់នូវហេតុ ដែលខ្លួនត្រិះរិះហើយដែរថា បពិត្រព្រះនាងជាម្ចាស់ ព្រះនិព្វានជាទីក្សេមយ៉ាងក្រៃលែង បើព្រះនាងពេញចិត្តហើយ បពិត្រព្រះនាង ដែលបានព្រះពុទ្ធអនុញ្ញាតហើយ

យើងទាំងអស់គ្នានឹងនិព្វានដែរ ។ យើងទាំងឡាយនឹងចេញចាកផ្ទះចាកភពជាមួយនឹងព្រះនាងដែរ យើងនឹងទៅកាន់ព្រះនិព្វានជាបុរីដ៏ឧត្តមជាមួយនឹងព្រះនាងទៀត ។ កាលភិក្ខុនីទាំងឡាយពោលដើម្បីនិព្វាន គ្រានោះព្រះនាងក៏ពោលថា ខ្ញុំនឹងថាអ្វី ហើយក៏ចេញទៅចាកលំនៅភិក្ខុនីជាមួយនឹងភិក្ខុនីទាំងអស់រូបពោលថា ទេវតាណាដែលអាស្រ័យនៅក្នុងសំណាក់ភិក្ខុនីទេវតាទាំងនោះ សូមអត់ទោសដល់ខ្ញុំ ការឃើញលំនៅនាងភិក្ខុនីនេះជាការឃើញទីបំផុតរបស់ខ្ញុំ ។ ជរាក្តី មច្ចុក្តី មិនមានក្នុងទីណាការជួបប្រទះដោយសត្វនិងសង្ខារមិនជាទីស្រឡាញ់ក្តី ការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ក្តី មិនមានក្នុងទីណា ទីនោះហៅថាអសង្ខតៈ ។ ពួកភិក្ខុនីជាឱរសរបស់ព្រះសុគតដែលមិនទាន់ប្រាសចាករាគៈ បានស្តាប់នូវពាក្យនោះហើយ ត្រូវសេចក្តីសោកគ្របសង្កត់ ក៏ខ្សឹកខ្សួលថាឱហ្ន៎! យើងទាំងឡាយជាបុគ្គលឥតបុណ្យ ។ ទីលំនៅភិក្ខុនីនេះ បើវៀរចាកពួកភិក្ខុនីទាំងនោះហើយ ក៏នឹងសូន្យឈឹង ពួកនាងភិក្ខុនីជាឱរសរបស់ព្រះជិនស្រីក៏លែងប្រាកដ ដូចជាផ្កាយដែលមិនប្រាកដក្នុងពេលភ្លឺច្បាស់ ។ ព្រះនាងគោតមី នឹងទៅកាន់និព្វានជាមួយភិក្ខុនី ៥០០ រូប ដូចទន្លេគង្គាហូរទៅកាន់សាគរជាមួយស្ទឹង ៥០០ ដូច្នោះ ។ ពួកឧបាសិកាដែលមានសទ្ធា

ចេញអំពីផ្ទះដើរទៅតាមច្រក បានឃើញព្រះនាងគោតមីនោះ ក៏ក្រាបទៀបបាទា ហើយពោលនូវពាក្យនេះថា ព្រះនាងម្ចាស់ ចូរជ្រះថ្លាក្នុងភោគៈដ៏ច្រើនចុះ ព្រះនាងមិនគួរលះបង់នូវយើង ខ្ញុំទាំងឡាយឲ្យនៅឥតទីពឹង ហើយនិព្វានទេ ឧបាសិកាទាំង នោះ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយក៏យំរៀបរាប់ ( យ៉ាង នេះ ) ។ ព្រះនាងគោតមី បានពោលវាចាដ៏ពីរោះ ដើម្បី បន្ទោបង់នូវសេចក្តីសោករបស់ស្រីទាំងនោះថា ម្នាលកូនទាំង ឡាយ នាងទាំងឡាយមិនគួរយំស្រែកទេ ថ្ងៃនេះ ជាកាលគួរ នាងទាំងឡាយសើចសប្បាយទេតើ ។ ព្រោះសេចក្តីទុក្ខ ខ្ញុំ បានកំណត់ដឹងហើយ ហេតុនាំឲ្យកើតទុក្ខខ្ញុំវៀរស្រឡះហើយ ព្រះនិព្វាន ជាទីរលត់ទុក្ខខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំង មគ្គទៀត ខ្ញុំក៏បានអប់រំល្អហើយ ។

ព្រះសាស្តាខ្ញុំបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើ ហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាធម្មជាតិ នាំ សត្វទៅក្នុងភព ខ្ញុំក៏បានដកចោលហើយ ស្រីទាំងឡាយចេញ ចាកផ្ទះហើយចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណាប្រយោជន៍ ជាទីអស់ទៅនៃសំយោជនៈទាំងពួងនោះខ្ញុំក៏បានដល់ហើយ ។ ព្រះពុទ្ធក្តី ព្រះសទ្ធម្មរបស់ព្រះពុទ្ធនោះក្តី ឋិតនៅមិនខ្វះខាត ដរាបណា កាលនេះជាកាលគួរដើម្បីខ្ញុំនឹងនិព្វាន ដរាបនោះ

ម្នាលកូនស្រីទាំងឡាយ នាងទាំងឡាយ កុំសោកស្តាយខ្ញុំឡើយ ។ ព្រះកោណ្ឌញ្ញៈ ព្រះអានន្ទ ព្រះនន្ទ ព្រះរាហុល ព្រះជិនស្រី ព្រមទាំងព្រះសង្ឃចូរឋិតនៅជាសុខចុះ ទាំងពួកតិរ្ថិយដែលមានសេចក្តីល្ងង់ខ្លៅសាបសូន្យហើយ ក៏ឋិតនៅជាសុខចុះ ។ យសនៃវង្សរបស់ស្តេចឱក្កាកៈចម្រើនឡើងហើយ ញ៉ាំញីនូវមារ ម្នាលកូនស្រីទាំងឡាយ ក្រែង ( កាលនេះ ) ជាសម្បត្តិកាលដើម្បីឲ្យខ្ញុំនិព្វានហើយឬ ។ ចាប់តាំងអំពីយូរយារមកហើយ សេចក្តីប្រាថ្នាណាដែលខ្ញុំតម្កល់ទុក ( សេចក្តីប្រាថ្នានោះ ) នឹងសម្រេចក្នុងថ្ងៃនេះ កាលនេះ ជាកាលគួរទូងភេរី គឺសេចក្តីត្រេកអរក្នុងធម៌ ម្នាលកូនស្រីទាំងឡាយនាងទាំងឡាយមានប្រយោជន៍អ្វី នឹងសម្រក់ទឹកភ្នែក ។ បើនាងទាំងឡាយមានសេចក្តីអាណិតខ្ញុំ ឬក៏ជាអ្នកកតញ្ញូនឹងខ្ញុំ នាងទាំងអស់គ្នា ចូរធ្វើព្យាយាមឲ្យមាំដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យតាំងនៅមាំចុះ ។ ព្រះសម្ពុទ្ធដែលខ្ញុំអង្វរសូមហើយ ព្រះអង្គក៏ទ្រង់ប្រទាននូវផ្នួសដល់ស្រីទាំងឡាយ ព្រោះហេតុនោះខ្ញុំនឹងត្រេកអរ យ៉ាងណា នាងទាំងឡាយចូរប្រព្រឹត្តតាមដំណើរនោះយ៉ាងនោះចុះ ។ ព្រះនាងគោតមីបានប្រៀនប្រដៅនូវពួកឧបាសិកាទាំងនោះយ៉ាងនេះហើយ ពួកភិក្ខុនីក៏ហែហម ហើយចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធ បានពោលនូវពាក្យនេះថា បពិត្រព្រះ

សុគត ខ្ញុំព្រះអង្គជាព្រះមាតារបស់ព្រះអង្គ បពិត្រព្រះអង្គទ្រង់មានប្រាជ្ញា តែព្រះអង្គជាព្រះបិតានៃខ្ញុំព្រះអង្គ បពិត្រព្រះលោកនាថ ព្រោះព្រះអង្គទ្រង់ប្រទាននូវព្រះសទ្ធម្ម និងសេចក្តីសុខ បពិត្រព្រះគោតម ខ្ញុំព្រះអង្គឈ្មោះថា កើតអំពីព្រះអង្គ ។ បពិត្រព្រះសុគត រូបកាយនៃព្រះអង្គនេះ ខ្ញុំឲ្យចម្រើនហើយ ធម្មកាយជាទីត្រេកអររបស់ខ្ញុំ ព្រះអង្គឲ្យចម្រើនហើយ ។ ខ្ញុំម្ចាស់ឲ្យព្រះអង្គបៅទឹកក្សីរ ដែលរម្ងាប់នូវសេចក្តីស្រេកឃ្លានមួយរំពេច ព្រះអង្គឲ្យខ្ញុំបៅទឹកក្សីរ គឺធម៌ មានសេចក្តីស្ងប់រម្ងាប់ជាទីបំផុត បពិត្រព្រះមហាមុនី ព្រះអង្គមិនមានបំណុលដល់ខ្ញុំក្នុងការរក្សានូវចំណងទេ ស្រីទាំងឡាយចង់បានកូនកាលបន់ស្រន់រមែងបានកូនប្រាកដដូចព្រះអង្គ ។ បពិត្រព្រះអង្គជាឱរស មាតាណារបស់ស្តេចជាធំជាងនរៈ មានស្តេចមន្ធាតុជាដើម មាតានោះគឺខ្ញុំព្រះអង្គដែលលិចចុះក្នុងសមុទ្ទគឺភព បានព្រះអង្គចម្លងហើយចាកសមុទ្ទគឺភព ។ ព្រះនាមជាព្រះមាតាជាព្រះមហេសីរបស់ស្តេច គឺស្រីទាំងឡាយ តែងបានដោយងាយទេ ឯព្រះនាមថាព្រះពុទ្ធមាតានេះ គឺស្រីទាំងឡាយសឹងបានដោយកម្រក្រៃពេក ។ បពិត្រព្រះមហាវីរៈ ឯសេចក្តីប្រាថ្នាជាដំបូងនោះ ខ្ញុំព្រះអង្គបានហើយ ដោយសារព្រះអង្គ សេចក្តីប្រាថ្នាទាំងអស់នោះទោះតូចក្តីធំក្តី ព្រះអង្គបានបំពេញ

ឲ្យហើយ ។ ខ្ញុំម្ចាស់សូមលះបង់នូវសាកសពនេះ ប្រាថ្នានឹង
បរិនិព្វាន បពិត្រព្រះអង្គមានព្យាយាមជានាយក ទ្រង់ធ្វើនូវទី
បំផុតនៃទុក្ខ សូមព្រះអង្គអនុញ្ញាតដល់ខ្ញុំព្រះអង្គ ។ សូមព្រះ
អង្គសណ្ដូកនូវព្រះបាទទាំងគូ ដ៏ទន់ល្វន់ដូចផ្កាឈូកដេរដាស
ដោយស្នាមចក្រកង្វេរនិងទង់ ខ្ញុំព្រះអង្គមានសេចក្ដីស្រឡាញ់
ចំពោះព្រះឱរសនឹងថ្វាយបង្គំព្រះបាទាទាំងគូនោះ សរីរៈរបស់
ព្រះអង្គប្រាកដស្មើដោយគំនរមាស ដែលប្រាកដក្នុងដែន កុរុ
សូមព្រះអង្គ ធ្វើឲ្យជារាងកាយ គឺខ្ញុំព្រះអង្គឃើញបានដោយ
ងាយ បពិត្រព្រះនាយក ខ្ញុំព្រះអង្គនឹងទៅកាន់ព្រះនិព្វាន ជា
ទីស្ងប់រម្ងាប់ ។ ព្រះជិនស្រីទ្រង់សម្ដែងនូវរាងកាយ ប្រកប
ដោយលក្ខណៈ ៣២ ប្រដាប់ ដោយពន្លឺដ៏ល្អដូចព្រះអាទិត្យ
ដ៏ស្រទន់នាអាកាសក្នុងវេលាល្ងាច ។ លំដាប់នោះ ព្រះនាង
គោតមីនោះ ក្រាបចុះដោយសិរ្សៈ ទៀបព្រះបាទាប្រាកដស្មើ
ដោយផ្កាឈូករីក មានរស្មីដូចព្រះអាទិត្យទើបនឹងរះ ប្រដាប់
ដោយចក្រហើយទូលថា ខ្ញុំសូមថ្វាយបង្គំព្រះអង្គជាព្រះអាទិត្យ
របស់នរជន ជាទង់ក្នុងអាទិច្ចត្រកូល ព្រះអង្គជាទីពឹងរបស់ខ្ញុំ
ក្នុងកាលជាទីបំផុត ខ្ញុំមិនបានឃើញព្រះអង្គទៀតទេ ។ ប-
ពិត្រព្រះអង្គជាកំពូលនៃលោក ធម្មតាស្ត្រីទាំងឡាយ ធ្វើនូវ
ទោសទាំងពួងហើយស្លាប់ទៅបើទោសរបស់ខ្ញុំមានបន្ដិចបន្តួច

បពិត្រព្រះអង្គទ្រង់ធ្វើសេចក្ដីករុណា សូមព្រះអង្គ អត់ទោស នោះដល់ខ្ញុំ ។ មួយវិញទៀត ខ្ញុំសូមផ្ទុសរឿយៗ ដើម្បីស្រីទាំងឡាយ បើខ្ញុំមានទោសក្នុងហេតុនោះ បពិត្រព្រះអង្គដ៏ប្រសើរជាងនរជន សូមព្រះអង្គអត់នូវទោសនោះ ។ បពិត្រព្រះអង្គមានព្យាយាម ភិក្ខុនីទាំងឡាយដែលខ្ញុំប្រៀនប្រដៅហើយតាមសេចក្ដីអនុញ្ញាតរបស់ព្រះអង្គ បើខ្ញុំទូន្មានមិនល្អក្នុងរឿងនោះ ទេបពិត្រព្រះអង្គទ្រង់មានសេចក្ដីអត់ធន់និងមានព្យាយាមសូមព្រះអង្គអត់នូវទោសនោះដល់ខ្ញុំ ។

( ព្រះសម្ពុទ្ធត្រាស់តបថា ) តថាគតអត់ទោស ក្នុងហេតុដែលតថាគតមិនទាន់អត់ ប្រយោជន៍អ្វី ក្នុងកាលដែលប្រដាប់ដោយគុណ តថាគត នឹងពោលនូវអ្វីដ៏លើសលុបជាងនាងដែលពោលដើម្បីនិព្វាន ។ កាលភិក្ខុសង្ឃរបស់តថាគតស្អាតគ្រប់គ្រាន់ ភិក្ខុសង្ឃក៏គួរដើម្បីវៀវនចេញចាកលោកនេះ ដូចកាលព្រះចន្ទ និងផ្កាយទាំងឡាយដល់នូវសេចក្ដីវិនាស ក្នុងកាលព្រះអាទិត្យរះឡើង ស្នាមព្រះចន្ទដែលគេឃើញច្បាស់ក៏រលុបបាត់ទៅ ។

ភិក្ខុនីដទៃ ក្រៅអំពីព្រះនាងមហាបជាបតិគោតមីនោះ ធ្វើប្រទក្សិណ ព្រះជិនស្រីដ៏ប្រសើរ ដូចជាផ្កាយប្រព្រឹត្តទៅតាមព្រះចន្ទ ដើរប្រទក្សិណភ្នំសិនេរុ ហើយក្រាបចុះទៀបព្រះបាទា

រូបឈររមិលមើលនូវព្រះកក្រ្តនៃព្រះសាស្តានោះ ។ ព្រះនាង បជាបតិគោតមីក្រាបទូលថា ត្រចៀកខ្ញុំមិនធ្លាប់ឆ្អែតដោយ ការឃើញនូវព្រះអង្គ ត្រចៀករបស់ខ្ញុំមិនធ្លាប់ឆ្អែតដោយភាសិត របស់ព្រះអង្គ ។ ចិត្តរបស់ខ្ញុំតែមួយប៉ុណ្ណោះ ដល់នូវសេចក្តី ឆ្អែតដោយរសនៃធម៌ដ៏ពេញលេញ ។

កាលព្រះមានព្រះភាគទ្រង់បន្លឺឡើង ក្នុងកណ្តាលបរិស័ទ ទ្រង់ប្រហារនូវសេចក្តីរឹងត្អឹង របស់ជនអ្នកមានវាទៈ ពួកជន ណាបានឃើញព្រះឱស្ឋ បពិត្រព្រះអង្គជាធំជាងនរ ជនទាំង ឡាយនោះ ឈ្មោះថាមានបុណ្យ ។ ជនទាំងឡាយណា ថ្វាយ បង្គំនូវព្រះបាទាមានព្រះអង្គុលីវែង មានព្រះនខាក្រហម មាន ព្រះបញ្ហិវែងល្អ បពិត្រព្រះអង្គ ទ្រង់ដល់នូវទីបំផុតនៃសេចក្តី សៅហ្មង ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ។ ជន ទាំងឡាយណា ស្តាប់នូវពាក្យទាំងឡាយដ៏ពិរោះ ជាទីរីករាយ ចិត្ត ជាគ្រឿងដុតចោលនូវទោសៈ ជាទីនាំមកនូវប្រយោជន៍ បពិត្រព្រះអង្គប្រសើរជាងនរ ជនទាំងឡាយនោះ ឈ្មោះថា មានបុណ្យ ។ បពិត្រព្រះមហាវីរៈ ខ្ញុំជាស្រីមានបុណ្យ ជា អ្នកយកចិត្តទុកដាក់ ក្នុងការបូជានូវព្រះបាទារបស់ព្រះអង្គ ជា ស្រីឆ្លងចាកផ្លូវលំបាក គឺសង្សារ តាមព្រះពុទ្ធដីកា របស់ព្រះ អង្គមានសិរី ។ លំដាប់នោះ ព្រះនាងគោតមី បានក្រាបទូល

ព្រះមានព្រះភាគ ជាស្រីមានវត្តល្អចំពោះភិក្ខុសង្ឃ រួចថ្វាយបង្គំព្រះរាហុល ព្រះអានន្ទ និងព្រះនន្ទ ហើយពោលនូវពាក្យនេះថា ខ្ញុំមានសេចក្តីទៀយណាយ ក្នុងសាកសព ជាលំនៅរបស់រោគ ស្មើដោយលំនៅនៃសត្វមានពិស ជាគ្រឿង កំណាត់នៃទុក្ខ ជាទីគោចរនៃជរានិងមរណៈ ។ ជារូបជេរជាសដោយមន្ទិល គឺសាកសពផ្សេងៗ ជាអាយត្ត[១]នៃបុគ្គលដទៃ ជារូបប្រាសចាកអំណាច ព្រោះហេតុនោះ ខ្ញុំប្រាថ្នាដើម្បីព្រះនិព្វានបពិត្រកូនទាំងឡាយ លោកទាំងឡាយចូរសម្គាល់ចុះ ។

ព្រះនន្ទ និងព្រះរាហុលដ៏ចម្រើន ជាអ្នកមិនមានសេចក្តីសោក មិនមានអាសវៈ មានចិត្តនឹងធឹង មិនមានកម្រើកមានប្រាជ្ញា មានព្យាយាម គិតរំពឹងនូវធម៌ថា ថ្វើយ! សង្ខតធម៌ជារបស់វិនាស ជារបស់មិនមានខ្លឹម មានឧបមាដូចដើមចេក ប្រាកដស្មើដោយកលមាយានិងថ្ងៃបណ្តើរកូន ជារបស់តិចតួចមិនបានតាំងនៅយឺនយូរឡើយ ។ ព្រះនាងគោតមីនេះជាព្រះមាតុច្ឆានៃព្រះជិនស្រី បានចិញ្ចឹមព្រះសម្ពុទ្ធ ដើរទៅកាន់សេចក្តីស្លាប់ក្នុងទីណា ( ទីនោះ ) មិនទៀង ត្រូវមានបច្ច័យតាក់តែងទាំងអស់ ។ ចំណែកឯព្រះអានន្ទនៅជាសេក្ខ-បុគ្គល ជាប្អូនជាទីស្រឡាញ់នៃព្រះជិនស្រី ព្រះអានន្ទនោះ

---

១-ដែលពឹងផ្អែកអ្នកដទៃ ដែលឥតអំណាចលើខ្លួន ។

បង្ហូរទឹកភ្នែកក្នុងទីនោះធ្វើនូវសេចក្ដីករុណាទួញយំ ខ្សឹកខ្សួល ថា ព្រះនាងគោតមី ពោលលាទៅកាន់ព្រះនិព្វានហើយ មិនយូរប៉ុន្មានទេ ព្រះសម្ពុទ្ធក៏គង់ទៅកាន់ព្រះនិព្វានពុំខានដែរ ដូចភ្លើងមិនមានកំញម ។ ព្រះនាងគោតមី បានមានព្រះសវនីយ៍ទៅកាន់ព្រះអានន្ទ ដែលកំពុងតែយំរៀបរាប់យ៉ាងនេះ ជាអ្នកមានវេទដ៏ជ្រៅ ដូចសាគរ ជាអ្នកយកចិត្តទុកដាក់ក្នុងការបម្រើព្រះសម្ពុទ្ធថា បពិត្រលោកកូន កាលបើកាលជាទីរីករាយប្រាកដហើយ លោកកូនមិនគួរសោយសោកទេ បពិត្រលោកកូន សេចក្ដីស្លាប់របស់ខ្ញុំនោះ ជាកិច្ចចូលទៅកាន់ព្រះនិព្វានជាទីបំផុតវិញតើ ។ បពិត្រលោកកូន ព្រះសាស្ដាដែលលោកកូនបានទូលសូមហើយទ្រង់ក៏អនុញ្ញាតនូវផ្នួសដល់យើង បពិត្រលោកកូន ចូរលោកកូនកុំតូចចិត្តឡើយ ព្រោះសេចក្ដីខ្វល់ខ្វាយរបស់លោកកូនជាការមួយប្រកបដោយផល ។ បទណាដែលពួកតិត្ថិកាចារ្យជាន់ចាស់មិនបានយល់ បទនោះ សូម្បីពួកកុមារីដែលមានអាយុ ៧ ឆ្នាំ ក៏យល់ច្បាស់ហើយ ។ លោកកូនចូររក្សាព្រះពុទ្ធសាសនាចុះការឃើញលោកកូន ( គ្រានេះ ) ជាកិច្ចទីបំផុត ( របស់ខ្ញុំ ) បពិត្រលោកកូន បុគ្គលទៅហើយមិនប្រាកដក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ។ ព្រះនាយកជាកំពូលនៃលោក ទ្រង់សម្ដែងធម៌ផ្សាយទៅ ក្នុងកាល

ណា កាលនោះ ខ្ញុំជាស្រីអនុគ្រោះ ខ្ញុំបានពោលនូវវាចាឲ្យពរថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ បពិត្រព្រះមហាមុនី សូមព្រះអង្គគង់នៅអស់ ១ កប្បចុះ សូមព្រះអង្គកុំមានជរានឹងមរណៈ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងអស់ ។ ព្រះពុទ្ធនោះទ្រង់ត្រាស់នឹងខ្ញុំដែលជាអ្នកក្រាបទូលដូច្នោះនូវពាក្យនេះថា បពិត្រព្រះនាងគោតមី ព្រះនាងថ្វាយបង្គំយ៉ាងណា ព្រះពុទ្ធទាំងឡាយគេមិនដែលថ្វាយបង្គំយ៉ាងនោះទេ ។

ព្រះតថាគតទាំងឡាយ ជាសព្វញ្ញូ បុគ្គលគប្បីថ្វាយបង្គំដោយប្រការដូចម្តេច ព្រះពុទ្ធទាំងឡាយ បុគ្គលមិនគប្បីថ្វាយបង្គំតើដោយប្រការដូចម្តេច ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់នូវហេតុនោះឲ្យទាន ។

នាងចូរមើលនូវសាវកទាំងឡាយ ដែលមានព្យាយាមតឹងតែង មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានសេចក្តីប្រឹងប្រែងដ៏មាំជានិច្ច ជាអ្នកព្រមព្រៀងគ្នា នេះឈ្មោះថាការថ្វាយបង្គំនូវព្រះពុទ្ធទាំងឡាយ ។

លំដាប់នោះ ខ្ញុំទៅកាន់លំនៅភិក្ខុនីតែម្នាក់ឯង ក៏គិតយ៉ាងនេះថា ព្រះលោកនាថ ទ្រង់ដល់នូវទីបំផុតនៃត្រៃភព ទ្រង់ពេញព្រះហឫទ័យនឹងបរិស័ទ ដែលព្រមព្រៀងគ្នា ។ ណ្ហើយ

ចុះខ្ញុំនឹងបរិនិព្វានកុំឲ្យឃើញនូវវិបត្តិនោះ ខ្ញុំគិតយ៉ាងនេះហើយ ក៏ឃើញនូវព្រះពុទ្ធជាឥសីទី ៧ ។ ខ្ញុំក្រាបទូលនូវកាល បរិ-និព្វានរបស់ខ្ញុំ ចំពោះព្រះនាយក លំដាប់នោះ ព្រះអង្គទ្រង់អនុញ្ញាតថា បពិត្រព្រះនាងគោតមី ព្រះនាងចូរដឹងនូវកាលជាទីបរិនិព្វានចុះ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

ពួកជនពាលណា ដល់នូវសេចក្តីសង្ស័យក្នុងការត្រាស់ដឹងនូវធម៌នៃស្ត្រីទាំងឡាយ បពិត្រព្រះនាងគោតមី ព្រះនាងចូរសម្តែងនូវឫទ្ធិដើម្បីកម្ចាត់បង់នូវទិដ្ឋិនៃពួកជនពាលនោះ ។

គ្រានោះ ព្រះនាងគោតមី ក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ហើយហោះឡើងទៅឯអាកាស សម្តែងនូវឫទ្ធិដ៏ច្រើនជាអនេក តាមពុទ្ធានុញ្ញាត គឺស្ត្រីតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ស្ត្រីច្រើននាក់ ធ្វើឲ្យទៅជាម្នាក់ក៏បាន ទៅកាន់ទីវាលជាទីខាងក្រៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំក៏បាន ដើរទៅមិនទើសទាក់ មុជ

ចុះក្នុងផែនដីក៏បាន ដើរលើទឹកមិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ។ ទៅទាំងភ្នែនលើអាកាស ដូចជាសត្វស្លាបក៏បាន ញុំាងអំណាចកាយឲ្យអណ្តែតទៅដរាបដល់លំនៅនៃព្រហ្មក៏បាន ។ យកភ្នំសិនេរុធ្វើជាដងឆត្រ យកផែនដីធំធ្វើជាឆត្របង្វិលដងឆត្របាំងដើរលើផ្ទៃអាកាស ។ ធ្វើនូវលោកឲ្យរុងរឿងដូចជាព្រះអាទិត្យ ៦ រះឡើងផង ធ្វើនូវលោកនោះឲ្យជាកម្រងសំណាញ់ដូចជានៅលើភ្នំយុគន្ធផង ។ កាន់យកនូវវត្ថុទាំងពួងគឺដើមមុច្ចលិន្ទ ថ្មធំ ភ្នំសិនេរុ ដើមមន្ទារៈ និងដើមទទ្ទរៈទាំងឡាយដោយក្តាប់ដៃ ១ ដូចជាកាន់គ្រាប់ស្ពៃ ។ បិទបាំងព្រះអាទិត្យ ព្រះចន្ទ ដោយចុងម្រាម ទ្រទ្រង់នូវព្រះចន្ទ ព្រះអាទិត្យ ១ ពាន់ ដូចជាទ្រទ្រង់នូវគ្រឿងប្រដាប់ក្បាល ទ្រទ្រង់នូវទឹកក្នុងសមុទ្ទទាំង ៤ ដោយដៃម្ខាង ញុំាងភ្លៀងធំមានអាការដូចជាទឹកហូរអំពីភ្នំយុគន្ធឲ្យបង្អុរចុះ ។ ព្រះនាងគោតមីនោះបាននិម្មិតជាស្តេចចក្រពត្តិព្រមទាំងបរិស័ទ សម្តែងនូវអត្តភាពជាគ្រុឌផងដំរីផង សីហៈផង បន្លឺនូវសម្រែកលើផ្ទៃនៃអាកាស ។ ព្រះនាងតែម្នាក់ឯង និម្មិតនូវពួកភិក្ខុនីដ៏ច្រើនប្រមាណមិនបានហើយឲ្យបាត់ទៅវិញនៅតែម្នាក់ឯងទើបពោលនឹងព្រះមុនីថាបពិត្រព្រះមហាវីរៈ ខ្ញុំជាមាតុច្ឆារបស់ព្រះអង្គជាស្ត្រីអ្នកធ្វើតាមនូវសាសនារបស់ព្រះអង្គ បានសម្រេចប្រយោជន៍របស់ខ្លួនហើយ បពិត្រ

ព្រះអង្គមានចក្ខុ ខ្ញុំសូមថ្វាយបង្គំព្រះបាទាទាំងគូ ។ ព្រះនាង គោតមីនោះ លុះសម្តែងឫទ្ធិផ្សេងៗហើយក៏ចុះចាកផ្ទៃនៃអាកាស មកថ្វាយបបង្គំព្រះសម្ពុទ្ធ ជាពន្លឺនៃលោក ហើយអង្គុយក្នុងទីដ៏សមគួររួចក្រាបទូលថា បពិត្រព្រះមហាមុនីខ្ញុំកើតមកបានអាយុ ១២០ ហើយបពិត្រព្រះមហាវីរៈ ខ្ញុំល្មមប៉ុណ្ណោះហើយ បពិត្រព្រះនាយក ខ្ញុំនឹងបរិនិព្វាន ។ គ្រានោះ បរិស័ទទាំងពួងនោះ មានសេចក្តីអស្ចារ្យក្រៃពេកផ្គងអញ្ជលី ហើយពោលថា បពិត្រព្រះនាងមានឫទ្ធិប្លែងពុំបាន មានព្យាយាម កិច្ចទាំងពួងព្រះនាងបានធ្វើហើយ ។

ព្រះជិនស្រីព្រះនាម បទុមុត្តរៈ មានបញ្ញាចក្ខុក្នុងធម៌ទាំងពួងជានាយក ទ្រង់ត្រាស់ឡើងក្នុងកប្បទី ១ សែនអំពីកប្បនេះ ។ ក្នុងកាលនោះ ខ្ញុំកើតក្នុងត្រកូលនៃអាមាត្យក្នុងនគរហង្សវតី ជាត្រកូលបរិបូណ៌ដោយឧបការៈទាំងពួង ដ៏ស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន ។ ក្នុងកាលមួយ ខ្ញុំទៅជាមួយនឹងបិតាមានពពួកខ្ញុំស្រីចោមរោម មានបរិវារច្រើន ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គប្រសើរជាងនរៈ ។ ខ្ញុំបានឃើញព្រះជិនស្រី មិនមានអាសវៈ ប្រាកដស្មើដោយព្រះអាទិត្យ ក្នុងសរទកាលដ៏ដេរដាសដោយកម្រងគីរស្មី ទ្រង់បន្តរបុះនូវភ្លៀងគឺធម៌ ដូចជាព្រះឥន្ទ្រ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា បានស្តាប់សុភាសិតនៃព្រះពុទ្ធ

នោះ ព្រះអង្គជានាយកនៃនរៈ ទ្រង់តាំងនូវនាងភិក្ខុនី ជាព្រះមាតុច្ឆាក្នុងទីដ៏ប្រសើរលើស ។ លុះខ្ញុំស្តាប់ហើយ ក៏បានថ្វាយនូវមហាទានផង នូវបច្ច័យដ៏ច្រើនផង ដល់ព្រះសម្ពុទ្ធដ៏ប្រសើរជាងនរជនអង្គនោះ ទ្រង់ជាតាទិបុគ្គល ព្រមទាំងព្រះសង្ឃអស់ ៧ ថ្ងៃរួចខ្ញុំក្រាបចុះទៀបព្រះបាទាហើយប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធជាឥសីទី ៧ បានពោលក្នុងបរិស័ទច្រើនថា ស្ត្រីណា បានញុំាងព្រះលោកនាយកព្រមទាំងព្រះសង្ឃឲ្យឆាន់អស់ ៧ ថ្ងៃ តថាគតនឹងសរសើរនូវស្ត្រីនោះ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យដែលតថាគតនឹងសម្តែងដូចតទៅនេះ ។ ក្នុងកប្បទី ១ សែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាកៈនឹងត្រាស់ ឡើងក្នុងលោក ។ ស្ត្រីនោះនឹងបានជាឱរស ជាអ្នកទទួលមរតកក្នុងធម៌នៃព្រះពុទ្ធនោះ ជាធម្មនិម្មិត ឈ្មោះនាងគោតមីនឹងបានជាសាវិកានៃព្រះសាស្តាអង្គនោះ ។ នាងគោតមីនេះជាព្រះមាតុច្ឆា ជាអ្នករក្សានូវជីវិតនៃព្រះពុទ្ធនោះ នឹងបាននូវទីដ៏ប្រសើរលើស ជាងភិក្ខុនីទាំងឡាយជាអ្នកដឹងនូវរាត្រីដ៏វែង ( មានអាយុវែង ) ។ គ្រានោះ ខ្ញុំស្តាប់នូវព្រះពុទ្ធដីកានោះ ក៏មានចិត្តរីករាយ បានបម្រើនូវព្រះជិនស្រីដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិតតមកខ្ញុំក៏ធ្វើមរណកាល ។ ខ្ញុំទៅកើតក្នុងពួកទេវតាជាន់តាវត្តិង្ស

សម្រេចនូវសេចក្តីប្រាថ្នាទាំងពួង បានគ្របសង្កត់នូវទេវតា ទាំងឡាយដទៃដោយអង្គ ១០ យ៉ាង គឺដោយរូប សំឡេង ក្លិន រស សម្ផស្ស អាយុ វណ្ណៈ សុខៈ យស ។ មួយទៀត ខ្ញុំឈ្នះឈ្នានរុងរឿងដោយអធិបតេយ្យ ( ជាគម្រប់ ១០ ) ខ្ញុំបានជាមហេសីរបស់ព្រះឥន្ទក្នុងឋាននោះ ។ ខ្ញុំត្រូវខ្យល់គឺកម្មបក់ផាត់ទៅ អន្ទោលទៅក្នុងសង្សារ បានទៅកើតក្នុងស្រុកទាសគ្រាមក្នុងដែននៃស្តេចឈ្មោះកាសិកៈ ។ គ្រានោះ ខ្ញុំប្រុស ៥០០ នាក់ឥតខ្វះខាត នៅក្នុងស្រុកនោះ ជនណាជាធំជាងជនទាំងពួងក្នុងស្រុកនោះ ខ្ញុំបានជាប្រពន្ធរបស់ជននោះ ។ ភិក្ខុ ៥០០ អង្គរបស់ព្រះសយម្ភូ[១] បានចូលទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាត ខ្ញុំព្រមទាំងញាតិទាំងអស់ឃើញភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ ខ្ញុំព្រមទាំងប្តី មានចិត្តជ្រះថ្លាបានធ្វើកុដិ ៥០០ ខ្នង ( ប្រគេន ) ចូលទៅបម្រើអស់ ៤ ខែ ហើយប្រគេននូវត្រៃចីវរ ។ ខ្ញុំព្រមទាំងប្តី លុះច្យុតចាកអត្តភាពនោះ បានទៅកើតក្នុងឋានតាវត្តិង្ស ឥឡូវនេះ ខ្ញុំកើតក្នុងបុរីឈ្មោះទេវទហៈក្នុងកពជាទីបំផុត ។ ព្រះបិតារបស់ខ្ញុំជាសក្យព្រះនាមអញ្ជនៈ ព្រះមាតារបស់ខ្ញុំ ព្រះនាមសុលក្ខណា លំដាប់នោះ ខ្ញុំបានទៅកាន់សំណាក់ ( អគ្គទេពី ) នៃព្រះរាជាព្រះនាមសុទ្ធោទនៈក្នុងក្រុងកបិលពស្តុ ។ ស្ត្រីទាំង

---

១-បាលីថា សយម្ភុនោ បញ្ចសតា គួរប្រែថា ព្រះសយម្ភូ ( ព្រះបច្ចេកពុទ្ធ ) ៥០០ អង្គ ។

អស់កើតក្នុងសក្យត្រកូល បានទៅកាន់សំណាក់ ( ស្រីស្នំ ) របស់ព្រះបាទសុទ្ធោទនៈនោះ ខ្ញុំប្រសើរជាងស្ត្រីទាំងអស់បានជាអ្នករក្សានូវព្រះជិនស្រី ។ ព្រះសមុទ្ទនោះ ជានាយក ជាបុត្តរបស់ខ្ញុំទ្រង់ចេញទៅបព្វជ្ជា លុះកាលជាខាងក្រោយ ខ្ញុំក៏ចេញទៅបួសជាមួយនឹងស្ត្រី ៥០០ នាក់ ។ ខ្ញុំបានពាល់ត្រូវនូវសន្តិសុខជាមួយនឹងពួកនាងសាកិយានីទាំងឡាយ ជាស្ត្រីមានព្យាយាម ក្នុងកាលនោះជនទាំងឡាយណា ជាស្វាមីរបស់យើងក្នុងជាតិមុន ។ ជនទាំងនោះ ជាអ្នកធ្វើបុណ្យអ្នកធ្វើលទ្ធិដ៏ធំ ដែលព្រះសុគតអនុគ្រោះហើយ ក៏បាននូវព្រះអរហត្ត ។

ភិក្ខុនីទាំងឡាយដទៃ ក្រៅអំពីព្រះនាងមហាបជាបតិគោតមីនោះ ហោះទៅកាន់ផ្ទៃអាកាស មានឫទ្ធិច្រើន រុងរឿង ដូចជាផ្កាយប្រជុំគ្នា សម្តែងឫទ្ធិជាអនេកជាស្ត្រីសិក្សាក្នុងបុញ្ញកម្មទាំងឡាយ ដូចជាជាងមាសធ្វើនូវគ្រឿងប្រដាប់ដ៏ប្លែកៗ ។ គ្រានោះភិក្ខុនីទាំងឡាយ សម្តែងនូវបាដិហារ្យផ្សេងៗជាច្រើន ញុំាងព្រះមុនីដ៏ប្រសើរ ដូចជាព្រះអាទិត្យ ព្រមទាំងបរិស័ទឲ្យត្រេកអរ ។ ចុះអំពីផ្ទៃអាកាសមកថ្វាយបង្គំព្រះពុទ្ធជាឥសីទី ៧ លុះព្រះពុទ្ធដ៏ប្រសើរជាងនរៈទ្រង់អនុញ្ញាតហើយ ក៏គង់ក្នុងទីដដែលវិញរួចទូលថា បពិត្រព្រះមហាវីរៈ ព្រះនាងគោតមី បានអនុគ្រោះខ្ញុំព្រះអង្គទាំងអស់គ្នា ពួកខ្ញុំព្រះអង្គបានព្រះនាងគោតមីនោះអប់រំ

ដោយបុណ្យទាំងឡាយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ កិលេសទាំងឡាយ ពួកខ្ញុំម្ចាស់ដុតបំផ្លាញហើយ ភពទាំងពួង ពួកខ្ញុំម្ចាស់ដកចោលហើយពួកខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណងដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ! ពួកខ្ញុំម្ចាស់មកល្អហើយក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ពួកខ្ញុំម្ចាស់បានដល់ហើយ សាសនារបស់ព្រះពុទ្ធ ពួកខ្ញុំម្ចាស់បានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ពួកខ្ញុំម្ចាស់បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ពួកខ្ញុំព្រះអង្គក៏បានប្រតិបត្តិហើយ ។ បពិត្រព្រះមហាមុនី ពួកខ្ញុំម្ចាស់ ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ស្ទាត់ក្នុងទិព្វសោតធាតុនិងចេតោបរិយញ្ញាណផង ។ ពួកខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាសៈ ជម្រះនូវទិព្វចក្ខុ អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីមិនមានឡើយ ។ បពិត្រព្រះមហាវីរៈ ញាណរបស់ខ្ញុំម្ចាស់ កើតឡើងក្នុងសំណាក់នៃព្រះអង្គ រមែងមានក្នុងអត្ថផង ក្នុងធម៌ផង ក្នុងនិរុត្តិផង ក្នុងបដិភាណផង ។ បពិត្រព្រះនាយក ពួកខ្ញុំព្រះអង្គមានមេត្តាចិត្ត បានបម្រើព្រះអង្គហើយ បពិត្រព្រះមហាមុនី សូមព្រះអង្គអនុញ្ញាតពួកខ្ញុំព្រះអង្គទាំងអស់ដើម្បីបរិនិព្វាន។ព្រះជិនស្រីទ្រង់ត្រាស់ថា តថាគតនឹងពោលដូចម្តេច ចំពោះនាងទាំងឡាយដែលចេះតែទទូចនិយាយយ៉ាងនេះថាយើងទាំងឡាយ

សុំបរិនិព្វានឥឡូវនេះ ( កាលបើយ៉ាងនេះ ) នាងទាំងឡាយ ចូរសម្គាល់នូវកាលគួរដើម្បីនិព្វានចុះ ។ កាលនោះ ភិក្ខុនីទាំងឡាយនោះ មានព្រះនាងគោតមីជាដើម ថ្វាយបង្គំព្រះជិនស្រី ក្រោកចាកអាសនៈ ហើយដើរទៅ ។ ព្រះលោកនាយក ជាកំពូលនៃលោក ជាអ្នកប្រាជ្ញ មួយអន្លើដោយពួកជនដ៏ច្រើនបាន ស្តេចទៅតាមព្រះមាតុច្ឆាដរាបដល់បន្ទប់ ។ គ្រានោះឯង ព្រះនាងគោតមី ក្រាបចុះទៀបព្រះបាទាទាំងគូ នៃព្រះលោកពន្ធុជាមួយនឹងពួកភិក្ខុនីទាំងអស់នុ៎ះ នេះឈ្មោះថា ការថ្វាយបង្គំនូវព្រះបាទជាទីបំផុត ។

ការឃើញព្រះលោកនាថនៃខ្ញុំនេះ ជាការឃើញទីបំផុត ខ្ញុំនឹងមិនបានឃើញនូវព្រះភក្ត្ររបស់ព្រះអង្គ ដែលមានអាការមិនស្លាប់ទៀតឡើយ ។ បពិត្រព្រះអង្គមានព្យាយាម ការថ្វាយបង្គំរបស់ខ្ញុំចំពោះព្រះបាទារបស់ព្រះអង្គដ៏ទន់ល្មន់ នឹងមិនមានទៀតឡើយ បពិត្រព្រះអង្គជាកំពូលនៃលោក ខ្ញុំនឹងទៅកាន់ព្រះនិព្វានក្នុងថ្ងៃនេះ ។

( ព្រះសម្ពុទ្ធទ្រង់ត្រាស់តបថា ) ព្រះនាងនឹងមានប្រយោជន៍អ្វីដោយរូបក្នុងបច្ចុប្បន្ននេះ ព្រោះរូបទាំងអស់នុ៎ះ សុទ្ធតែមានបច្ច័យតាក់តែង ជារបស់មិនមាំមួន ជារបស់ស្កួចស្តើង ។ ព្រះនាងគោតមីនោះ ទៅកាន់សំណាក់ភិក្ខុនី មួយអន្លើដោយភិក្ខុនី

ទាំងនោះ អង្គុយបត់ជើងលើអាសនៈប្រសើរ ។ គ្រានោះ ឧបាសិកាទាំងឡាយក្នុងទីនោះ ជាអ្នកស្រឡាញ់ព្រះពុទ្ធសាសនាបានឮដំណឹងព្រះនាងគោតមី ក៏ទៅថ្វាយបង្គំព្រះបាទា ។ យកដៃគក់ទ្រូងយំស្រែក គួរអាណិតសោយសោក ផ្ទួលខ្លួនលើផែនដីដូចជាវល្លិ៍ដែលគេកាត់ឫដ៏គល់ ពោលដូច្នេះថា បពិត្រព្រះនាងជាទីពឹងទីរឭក ព្រះនាងកុំលះបង់នូវយើងទាំងឡាយ ទៅកាន់ព្រះនិព្វានឡើយ យើងទាំងអស់គ្នាក្រាបចុះដោយសិរ្សៈ សូមអង្វរឃាត់ ។ ឧបាសិកាណាមានសទ្ធាមានបញ្ញា ជាប្រធាននៃស្រីទាំងនោះ ព្រះនាងគោតមីបានពោលនូវពាក្យនោះ នឹងឧបាសិកានោះ ដែលកំពុងប្របាច់ព្រះសិរៈរបស់ព្រះនាងថា នែកូនស្រីកុំពិលាបឡើយព្រោះការយំសោក ជាហេតុនាំឲ្យប្រព្រឹត្តទៅតាមនូវអន្ទាក់នៃមារទេ រូបទាំងអស់ ដែលមានបច្ច័យប្រជុំតាក់តែងហើយ សុទ្ធតែមិនទៀង មានការព្រាត់ប្រាសជាទីបំផុតជារបស់នាំឲ្យចលាចល ។ លំដាប់នោះ ព្រះនាងលះបង់នូវឧបាសិកាទាំងនោះ ចូលកាន់បឋមជ្ឈានដ៏ឧត្តម ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ចូលកាន់អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានា-សញ្ញាយតនជ្ឈានតាមលំដាប់ ។ ព្រះនាងគោតមីចូលកាន់ឈានទាំងឡាយជាបដិលោម តាំងពីចតុត្ថជ្ឈានមកដល់បឋមជ្ឈាន ។

ព្រះនាងគោតមី មិនមានអាសវៈ ចេញពីចតុត្ថជ្ឈានទោះហើយ ក៏និព្វានដូចជាប្រទីបអស់ប្រេងះ ការកម្រើកផែនដីដ៏ធំ ក៏កើតមានឡើង ផ្គរបន្ទោរក៏ផ្ទៀលធ្លាត់ធ្លាក់ចុះពីអាកាស ។ ទាំងផ្គរក៏លាន់ឮគគ្រឹកគគ្រេង ទេវតាទាំងឡាយក៏យំខ្សឹកខ្សួលភ្លៀងផ្កាក៏ធ្លាក់ចុះអំពីអាកាសមកកាន់ផែនដី ។ ស្តេចភ្នំឈ្មោះសិនេរុក៏កក្រើកញាប់ញ័រដូចអ្នករបាំក្នុងកណ្តាលរឿណរង្គទាំងសាគរក៏ស្រែកហាក់ដូចជាមានសេចក្តីសោកគ្របសង្កត់ ។ ទេវតានាគ អសុរ ព្រហ្ម មានសេចក្តីសង្វេគ បានពោលក្នុងខណៈនោះថា ឱហ្ន៎ សង្ខារទាំងឡាយមិនទៀងទេ ដូចយ៉ាងព្រះនាងគោតមីនេះ គង់ដល់នូវការរលាយបាត់ទៅ ។ ស្រីទាំងឡាយណា ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ចោមរោមព្រះនាងគោតមីនេះស្រីទាំងនោះមិនមានឧបាទាននិព្វានហើយដូចជាអណ្តាតប្រទីបដែលរលត់ ។ ហី! ការប្រកបមានសេចក្តីព្រាត់ប្រាស ជាទីបំផុត ហី! រូបទាំងពួង ដែលបច្ច័យតាក់តែងហើយ សុទ្ធតែមិនទៀង ហី! ជីវិតមានសេចក្តីវិនាសជាទីបំផុត មានសេចក្តីខ្សឹកខ្សួល ដូច្នេះឯង ។ លំដាប់នោះ ទេវតា ព្រហ្ម ចូលទៅគាល់ព្រះពុទ្ធជាឥសីទី ៧ ធ្វើនូវការប្រព្រឹត្តទៅតាមធម្មតាលោក ដ៏សមគួរតាមកាល គ្រានោះព្រះសាស្តា ទ្រង់ត្រាស់ហៅព្រះអានន្ទដែលមានវេទដ៏ជ្រៅដូចសាគរថា ម្នាលអានន្ទ អ្នកចូរទៅប្រាប់នូវ

បរិនិព្វានរបស់ព្រះមាតាដល់ភិក្ខុទាំងឡាយចុះ ។ គ្រានោះព្រះ
អានន្ទ មានសេចក្តីទុក្ខមានភ្នែកពេញដោយទឹកភ្នែកមានសំឡេង
រអាក់រអួលពោលថា ភិក្ខុទាំងឡាយណា នៅក្នុងទិសខាងកើត
ខាងត្បូង ខាងលិច ខាងជើង ភិក្ខុទាំងឡាយនោះ ចូរប្រជុំគ្នា
ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនីនោះ ជាព្រះមាតារបស់ខ្ញុំជាឱរស
របស់ព្រះសុគត ។ ព្រះនាងគោតមីណា ថ្វាយបង្គំព្រះសរីរៈ
របស់ព្រះមុនីជាទីបំផុតដោយការផ្ចិតផ្ចង់ ព្រះនាងគោតមីនោះទៅ
ហើយកាន់ទីស្ងប់រម្ងាប់គឺព្រះនិព្វាន ដូចជាផ្កាយបាត់ទៅក្នុងកាល
ជាទីរះឡើងនៃព្រះអាទិត្យ ។ ព្រះលោកនាយក សូម្បីមានព្រះ
នេត្រ ៥ មិនឃើញ ( នូវគតិរបស់ព្រះនាងបជាបតិគោតមី )
ទីស្ងប់រម្ងាប់ណា ព្រះនាងបជាបតិគោតមីភិក្ខុនី តម្កល់ទុកនូវ
ឈ្មោះថាពុទ្ធមាតាទៅហើយកាន់ទីស្ងប់រម្ងាប់នោះ ។ បុគ្គលណា
មានជំនឿចំពោះព្រះសុគត មា្យ៉ងទៀតសិស្សណា របស់ព្រះ
មហាមុនី សិស្សនោះជាឱរសរបស់ព្រះសុគត ចូរធ្វើសក្ការៈ
ដល់ព្រះពុទ្ធមាតាចុះ ។ ភិក្ខុទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយក្រៃ
ពេក លុះឮដំណឹងនោះក៏មកដោយរហ័ស ភិក្ខុពួកខ្លះមកដោយ
ពុទ្ធានុភាព ភិក្ខុពួកខ្លះជាអ្នកឈ្លាស ក្នុងឫទ្ធិទាំងឡាយ ក៏មក
ដោយឫទ្ធិ ។ ព្រះនាងគោតមីផ្ទុំលើគ្រែណា ជនទាំងឡាយលើក
នូវគ្រែនោះដាក់ក្នុងផ្ទះកំពូលដ៏ប្រសើរ ជាទីរីករាយដ៏ស្អាត ជា

វិការៈនៃមាសទាំងអស់ លោកបាលទាំង ៤ ក៏សែងដោយស្មា ទាំងឡាយ ទេវតាដ៏សេសមានព្រះឥន្ទជាដើម ក៏បានចាប់កាន់ ផ្ទះកំពូល ។ ផ្ទះកំពូលទាំងអស់មានចំនួន ៥០០ ខ្នងដែលព្រះ វិស្សុកម្មទេវបុត្តនិម្មិតហើយ មានពណ៌ដូចជាព្រះអាទិត្យ ក្នុង សរទកាល ។ កិក្ខុនីទាំងអស់សឹងនៅលើគ្រែក្នុងទីនោះ ទេវតា ទាំងឡាយសែងគ្រែដោយស្មានាំចេញទៅតាមលំដាប់ ។ ផ្ទៃអា កាសបិទបាំងដោយពិតានទាំងអស់ ព្រះចន្ទព្រះអាទិត្យនិងផ្កាយ សឹងមានស្លាមសុទ្ធតែមាសទាំងអស់ ។ ទង់ទាំងឡាយជាអនេក ដ៏វិចិត្រដូចជាអាវផ្កា ដែលគេលើកឡើងហើយ មានផ្កាឈូក ធ្លាក់ចុះអំពីអាកាស ផ្កាផុះឡើងអំពីផែនដី ។ ព្រះចន្ទនិងព្រះ អាទិត្យក៏ប្រាកដ ទាំងផ្កាយក៏រុងរឿង ព្រះអាទិត្យត្រង់ជាក់ តែ មិនក្តៅដូចព្រះចន្ទ ។ ទេវតាទាំងឡាយ ក៏បូជាដោយគ្រឿង ក្រអូប កម្រងផ្កាជាទិព្វមានក្លិនឈ្ងុយឈ្ងប់ផង ដោយគ្រឿងប្រ- គំផង ដោយការរាំច្រៀងផង ។ នាគ អសុរ ព្រហ្ម ក៏បូជា សមគួរតាមសេចក្តីអង់អាច សមគួរតាមកម្លាំង នាំចេញទៅនូវ ពុទ្ធមាតាដែលនិព្វានហើយ ។ កិក្ខុនីទាំងអស់ជាឱរសព្រះសុគត ដែលនិព្វានហើយ ជនទាំងឡាយនាំទៅខាងមុខ ឯព្រះនាងគោ- តមីដែលចិញ្ចឹមព្រះពុទ្ធ ទេវតាធ្វើនូវសក្ការៈ ហើយនាំចេញទៅ ខាងក្រោយ ។ ទេវតាមនុស្ស ព្រមទាំងនាគ អសុរ ព្រហ្ម

ដើរខាងមុខ ឯព្រះពុទ្ធព្រមទាំងសាវ័កយាងទៅខាងក្រោយដើម្បីបូជាព្រះមាតា ។ បរិនិព្វានរបស់ព្រះនាងគោតមី ជាការណ៍អស្ចារ្យក្រៃពេក យ៉ាងណា បរិនិព្វានរបស់ព្រះពុទ្ធ មិនដូច្នោះទេ ។ ( ព្រោះថា ) ក្នុងពុទ្ធបរិនិព្វាន មិនមានព្រះពុទ្ធនិងពួកភិក្ខុមានព្រះសារីបុត្តជាដើម ( ជាអធិបតីទេ ) ក្នុងគោតមីបរិនិព្វានមានព្រះពុទ្ធនិងពួកភិក្ខុមានព្រះសារីបុត្តជាដើម ( ជាអធិបតី ) ទេវតាទាំងឡាយធ្វើជើង ថ្ករទាំងឡាយជាវិការៈនៃគ្រឿងក្រអូបទាំងអស់ ដេរដាសដោយលំអិត មានក្លិនក្រអូបហើយបូជាសពភិក្ខុនីទាំងឡាយក្នុងទីនោះ ។ ចំណែកនៃសរីរាវយវៈសេសសល់និងឆ្អឹងដែលសេសសល់ក៏ឆេះសុះអស់ គ្រានោះព្រះអានន្ទ បានពោលនូវវាចាដែលញុំាងសេចក្ដីសង្វេគ ឲ្យកើតថា ព្រះនាងគោតមីទៅកាន់សេចក្ដីស្លាប់ ទាំងសរីរៈរបស់ព្រះនាងក៏ឆេះសុសអស់ មិនយូរប៉ុន្មានព្រះពុទ្ធនឹងបរិនិព្វាន ជាប្រាកដដែរ ។ លំដាប់នោះ ព្រះអានន្ទនោះ ដែលព្រះពុទ្ធទ្រង់ដាស់តឿន ក៏អង្គោននូវព្រះធាតុ របស់ព្រះនាងគោតមី ដែលតម្កល់ទុកក្នុងបាត្ររបស់ព្រះនាង មកថ្វាយព្រះលោកនាថ ។ ព្រះពុទ្ធជាឥសីទី ៧ ទ្រង់ទទួលនូវព្រះធាតុទាំងឡាយនោះដោយព្រះហស្តហើយទ្រង់ត្រាស់ដូច្នេះថា ដើមឈើធំមានក្លិន កាលនៅរស់ទាំងទំហំដើមដ៏ធំ គប្បីបាក់ទៅ ព្រោះសភាវៈមិនទៀង

យ៉ាងណា ព្រះនាងគោតមីជាប្រធាននៃភិក្ខុនីសង្ឃ បរិនិព្វាន ហើយក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ អ្នកចូរមើលចុះ ព្រះពុទ្ធមាតាដែលបរិនិព្វានហើយ សល់តែសរីរៈទេ អ្នកកុំសោកខ្សឹកខ្សួលឡើយ ។ ព្រះនាងគោតមីនោះ ឆ្លងចាកសាគរគឺសង្សារ ហើយវៀរចាកសេចក្ដីក្ដៅក្រហាយ មានសេចក្ដីត្រជាក់មានទុក្ខរលត់ហើយ មិនមែនព្រោះតែសេចក្ដីសោក របស់ពួកជនដទៃឡើយ ។ ព្រះនាងគោតមីភិក្ខុនីនោះជាបណ្ឌិត មានបញ្ញាច្រើន មានប្រាជ្ញាក្រាស់ មួយទៀត ព្រះនាងជាអ្នកដឹងនូវរាត្រីវែង គឺអាយុវែង ជាងភិក្ខុនីទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរដឹងយ៉ាងនេះចុះ ។ ព្រះនាងគោតមី ស្ទាត់ក្នុងឫទ្ធិផង ស្ទាត់ក្នុងទិព្វសោតធាតុ និងចេតោបរិយញ្ញាណផង ដឹងបុព្វេនិវាស ជម្រះទិព្វចក្ខុ មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ ។ ញាណក្នុងអត្ថផង ក្នុងធម៌ផង ក្នុងនិរុត្តិផង ក្នុងបដិភាណផងដ៏បរិសុទ្ធព្រោះហេតុនោះ អ្នកមិនគួរសោកស្ដាយព្រះនាងគោតមីនោះឡើយ ។ គតិរបស់បុគ្គលដែលមានចិត្តស្ងប់រម្ងាប់តាមលំដាប់ រមែងមិនប្រាកដ ដូចដុំដែកដែលបុគ្គលដំហើយក៏ភ្លឺរុងរឿងដោយសារភ្លើង យ៉ាងណា គតិរបស់បុគ្គលមានចិត្តផុតចាកកិលេសហើយដោយប្រពៃ ឆ្លងចាកចំណងគឺកាមនិងឱឃៈ ដល់នូវអចលបទ គឺព្រះនិព្វានហើយក៏

មិនប្រាកដ យ៉ាងនោះដែរ ។ អ្នកទាំងឡាយ ចូរមានខ្លួនជាទីពឹងចុះ មានសតិប្បដ្ឋានជាអារម្មណ៍ចុះ ចូរចម្រើននូវសត្តពោជ្ឈង្គចុះ ចូរធ្វើនូវទីបំផុតនៃកងទុក្ខចុះ ដូច្នេះ ។

បានឮថា ព្រះនាងមហាបជាបតិគោតមីភិក្ខុនី បានពោលគាថាទាំងនេះ ដោយប្រការដូច្នេះឯង ។

## អដ្ឋកថាមហាបជាបតិគោតមីថេរីគាថា ចប់

# គុត្តាថេរីគាថា

[ ៣២១ ] ម្នាលនាងគុត្តា ការដែលនាងលះបង់កូននិងគំនរទ្រព្យហើយបួសដើម្បីប្រយោជន៍ណា នាងចូរចម្រើនឲ្យរឿយៗនូវប្រយោជន៍នោះឯងនាងកុំលុះអំណាចនៃចិត្តឡើយ ។ ពួកសត្វ ត្រូវចិត្តបញ្ឆោតហើយ ត្រេកអរក្នុងវិស័យនៃមារ មិនដឹងថា អាត្មាអញត្រាច់រង្គាត់ទៅកាន់សង្សារ អស់ជាតិមិនតែមួយ ។ កាមច្ឆន្ទៈ ព្យាបាទៈ សក្កាយទិដ្ឋិ សីលព្វតបរាមាសៈ និងវិចិកិច្ឆាជាគម្រប់ ៥ ។ ម្នាលភិក្ខុនី លុះនាងលះនូវសំយោជនៈ ជាចំណែកខាងក្រោម ទាំងនោះហើយ ទើបលែងវិលមកកាន់កាមភពនេះទៀត ។ នាងបើខំសង្កត់សង្កិនកាត់ផ្តាច់នូវសំយោជនៈទាំងឡាយ គឺរូបរាគៈ អរូបរាគៈ មានៈ អវិជ្ជា ឧទ្ធច្ចៈហើយនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខបាន ។ នាងបើញុំាងជាតិសង្សារឲ្យអស់ហើយ កំណត់ដឹងនូវភពថ្មី នឹងទៅជាអ្នកមិនមានតណ្ហាប្រព្រឹត្តស្ងប់រម្ងាប់ក្នុងបច្ចុប្បន្នពិតប្រាកដបាន ។

**គុត្តាថេរី ។**

# អដ្ឋកថា

# គុត្តាថេរីគាថា

[ ៣២១ ] គាថារបស់ព្រះនាងគុត្តាថេរី មានពាក្យផ្តើមថា **គុត្តេ យ-ទត្ថំ បព្វជ្ជា** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុង

ព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុង ភព នោះ ៗ ប្រមូលនូវធម៌ជាគ្រឿងតាក់តែងវិមោក្ខដោយលំដាប់ មានកុសលមូលចាស់ក្លាហើយ អន្ទោលទៅក្នុងសុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងសាវត្ថី មានឈ្មោះថា គុត្តា ។ កុលធីតានោះដឹងក្តីហើយ ត្រូវឧបនិស្ស័យសម្បត្តិដាស់តឿនទៀយណាយក្នុងការនៅគ្រប់គ្រងផ្ទះ សូមអនុញ្ញាតមាតាបិតាហើយ បួសក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមី កាលបួសហើយ ផ្តើមចម្រើនវិបស្សនា ប្រកបការនារឿយៗ ចិត្តរបស់នាងក៏ស្ទុះទៅក្នុងអារម្មណ៍ខាងក្រៅ ព្រោះសន្សំមកអស់កាលយូរ មិនមានឯកគ្គតារម្មណ៍ឡើយ ព្រះសាស្តាទ្រង់គង់ក្នុងព្រះគន្ធកុដិ ទ្រង់ឃើញហេតុនោះ កាលទ្រង់អនុគ្រោះព្រះថេរី ទ្រង់ផ្សាយរស្មីទៅ ទ្រង់បង្ហាញព្រះកាយ ដូចគង់លើអាកាសក្បែរនាងគុត្តានោះ កាលទ្រង់ឲ្យឱវាទទើបត្រាស់គាថាទាំងនេះថា

ម្នាលនាងគុត្តា ការដែលនាងលះបង់កូននិងគំនរទ្រព្យ ហើយបួស ដើម្បីប្រយោជន៍ណា នាងចូរចម្រើនឲ្យរឿយៗនូវប្រយោជន៍នោះឯង នាងកុំលុះអំណាចនៃចិត្តឡើយ ។ ពួកសត្វត្រូវចិត្តបញ្ឆោតហើយ ត្រេកអរក្នុងវិស័យនៃមារ មិនដឹងថា អាត្មាអញត្រាច់រង្គាត់ទៅកាន់សង្សារ អស់ជាតិមិនតែមួយ ។ កាមច្ឆន្ទៈ ព្យាបាទៈ សក្កាយទិដ្ឋិ សីលព្វតបរាមាសៈ និងវិចិកិច្ឆាជាគម្រប់ ៥ ។ ម្នាលភិក្ខុនី លុះនាងលះនូវសំយោ

ជនៈជាចំណែកខាងក្រោមទាំងនោះហើយ ទើបលែងវិលមក
កាន់កាមភពនេះទៀត ។ នាងបើខំសង្កត់សង្កិនកាត់ផ្តាច់នូវសំ-
យោជនៈទាំងឡាយគឺ រូបរាគៈ អរូបរាគៈ មានៈ អវិជ្ជា ឧទ្ធច្ចៈ
ហើយនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខបាន ។ នាងបើញ៉ាំង
ជាតិសង្សារឲ្យអស់ហើយ កំណត់ដឹងនូវភពថ្មី នឹងទៅជាអ្នក
មិនមានតណ្ហា ប្រព្រឹត្តស្ងប់រម្ងាប់ ក្នុងបច្ចុប្បន្នពិតប្រាកដបាន
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យទត្ថំ** បានដល់ ដើម្បីជាប្រយោជន៍ ដល់ការរំលត់នៃកិលេសនិងការរំលត់នៃខន្ធឯណា ។ បទថា **ហិត្វា បុត្តំ វសុំ បិយំ** បានដល់ ការលះនូវពួកញាតិ និងគំនរនៃភោគៈដែលជាទីស្រឡាញ់ ប្រាថ្នាការបួសគឺការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសាសនារបស់តថាគត ។ បទថា **តមេវ អនុព្រូហេហិ** បានដល់ នាងគប្បីចម្រើនគឺគប្បីឲ្យនិព្វាននោះដល់ព្រម ។ បទថា **មា ចិត្តស្ស វសំ គមិ** បានដល់ នាងកុំធ្លាក់ក្នុងអំណាចនៃចិត្តដែលវៀចវេរដែលធាត់ធំដោយអារម្មណ៍មានរូបជាដើម អស់កាលយូរឡើយ ។ ព្រោះចិត្តនេះ ប្រៀបដូចកលមាយាបុថុជ្ជនល្ងង់ខ្លៅ ត្រូវចិត្តបោកបញ្ឆោតហើយ រមែងធ្លាក់នៅក្នុងអំណាចនៃមារ កន្លងនូវសង្សារទៅមិនបាន ដោយហេតុនោះ ទើបទ្រង់ត្រាស់ពាក្យថា **ចិត្តេន វញ្ចិតា** ដូច្នេះជាដើម ។

បទថា **សំយោជនានិ ឯតានិ** សេចក្ដីថា ឈ្មោះថា សំយោជនៈ ព្រោះអត្ថថាជាគ្រឿងចង ៥ យ៉ាងតាមដែលពោលហើយដោយន័យមានកាមច្ឆន្ទៈ

ព្យាបាទជាដើមនោះ ។ បទថា **បជហិត្វាន** បានដល់ កាត់ហើយដោយអនាគាមិមគ្គ ។ បទថា **ភិក្ខុនី** ជាពាក្យហៅភិក្ខុនីនោះ ។ បទថា **ឱរម្ភាគមិនិយានិ** បានដល់ ឧបការៈដល់ការរស់នៅ របស់មនុស្សក្នុងកាមធាតុ ដែលជាចំណែកទាបជាងរូបធាតុ និងអរូបធាតុ ព្រោះជាបច្ច័យនៃបដិសន្ធិក្នុងកាមធាតុនោះ ។ **ម** អក្ខរៈ គ្រាន់តែជាសន្ធិ ។ បាលីថា **ឱរមាគមនីយានិ** ក៏មាន ឯសេចក្តីយ៉ាងនោះដូចគ្នា ។ បទថា **នយិទំ បុនរេហិសិ** សេចក្តីថា នាងកុំមកកាន់កាមភពដែលជាទីតាំងនៃកាមនេះទៀត ដោយអំណាចបដិសន្ធិ ព្រោះលះសំយោជនៈដែលជាចំណែកខាងក្រោមបាន ។ **រ** អក្ខរៈ គ្រាន់តែជាសន្ធិ ។ បាលីថា **ឥត្ថំ** ដូច្នេះក៏មាន ឯសេចក្តីយ៉ាងនេះ គឺកាមភព ។

បទថា **រាគំ** បានដល់ រូបរាគៈ និងអរូបរាគៈ ។ បទថា **មានំ** បានដល់មានៈគប្បីសម្លាប់ដោយអរហត្តមគ្គក្នុងបទថា **អវិជ្ជញ្ច ឧទ្ធច្ចញ្ច** នេះ ក៏មានន័យដូចគ្នា ។ បទថា **វិវជ្ជិយ** បានដល់ សង្កត់ទុកបានដោយវិបស្សនា ។

បទថា **សំយោជនានិ ឆេត្វាន** បានដល់ កាត់នូវសំយោជនៈទាំងឡាយដែលជាចំណែកខាងលើ ៥ យ៉ាង មានរូបរាគៈទាំងនោះជាដើម បានជាសមុច្ឆេទហើយ ។ បទថា **ទុក្ខស្សន្តំ ករិស្សសិ** សេចក្តីថា នាងនឹងដល់ទីបំផុតនៃវដ្តទុក្ខទាំងពួង ។

បទថា **ខេបេត្វា ជាតិសំសារំ** បានដល់ ធ្វើនូវការប្រព្រឹត្តទៅនៃសង្សារមានជាតិជាមូលឲ្យអស់ទៅហើយ ។ បទថា **និប្ផាតា** បានដល់ អស់នូវតណ្ហា ។ បទថា **ឧបសន្តា** បានដល់ ចូលទៅស្ងប់រម្ងាប់ ដោយការចូលទៅ

ស្ងប់កិលេសទាំងឡាយ ដោយប្រការទាំងពួង ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

កាលព្រះសាស្តាទ្រង់ភាសិតគាថាទាំងនេះ យ៉ាងនេះហើយ លុះចប់នូវព្រះគាថា ព្រះថេរីក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ក៏បានពោលគាថាទាំងនេះ ដោយទំនងដែលព្រះមានព្រះភាគទ្រង់ភាសិតហើយ ជាឧទាននោះឯង ដោយហេតុនោះទើបគាថាទាំងនោះឈ្មោះថាថេរីគាថា ។

អដ្ឋកថា គុត្តាថេរីគាថា ចប់

## វិជយាថេរីគាថា

[ ៣២២ ] អាត្មាអញមិនលុះអំណាចក្នុងការនាចិត្ត មិនបានសេចក្តីស្ងប់ចិត្តបានចេញអំពីលំនៅ ៤ លើក ៥ លើក អាត្មាអញបាន ចូលទៅរកភិក្ខុនី ( ព្រះថេរីឈ្មោះខេមា ) ហើយសាកសួរដោយគោរព លោកបានសំដែងធម៌ គឺធាតុ អាយតនៈ អរិយសច្ច ៤ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ អដ្ឋង្គិកមគ្គដល់អាត្មាអញ ដើម្បីដល់នូវប្រយោជន៍ដ៏ឧត្តម ។ លុះអាត្មាអញបានស្តាប់ពាក្យរបស់ភិក្ខុនីនោះហើយ ក៏បានធ្វើតាមពាក្យប្រៀនប្រដៅរបស់លោក ក្នុងបុរិមយាមនៃរាត្រីបានរឭកឃើញនូវបុព្វជាតិ ក្នុងមជ្ឈិមយាមនៃរាត្រីបានជម្រះនូវទិព្វចក្ខុ ក្នុងបច្ឆិមយាមនៃរាត្រីបានទម្លាយនូវគំនរងងឹតវេលានោះ អាត្មាអញបានជ្រួតជ្រាបកាយដោយបីតិនិងសុខៈ ទម្លាយនូវគំនរងងឹតហើយលាងជើងទាំងគូក្នុងរាត្រីទី ៧ ។

វិជយាថេរី ។

ចប់ ឆក្កនិបាត ។

## អដ្ឋកថា

## វិជយាថេរីគាថា

[ ៣២២ ] គាថារបស់ព្រះនាងវិជយាថេរី មានពាក្យផ្តើមថា **ចតុក្ខត្តុំ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះ

ពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ជាអ្នកមានកុសលមូលដែលចម្រើនមកដោយលំដាប់ អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងក្រុងរាជគ្រឹះ ដល់នូវភាពជាអ្នកដឹងក្ដីហើយ បានជាសម្លាញ់របស់ព្រះនាងខេមាថេរីកាលនៅជាគ្រហស្ថ ។ បានឮមកថា នាងខេមានោះ បួសហើយគិតថា អម្បាលមហេសីនោះ ទ្រង់គង់បួស នឹងពោលប្ដីដល់អញ អញនឹងបួសដែរ ទើបចូលទៅរកព្រះនាងខេមាថេរី ។ ព្រះថេរីជ្រាបអធ្យាស្រ័យ របស់នាងហើយ ក៏សម្ដែងធម៌ឲ្យនាងមានចិត្តសង្វេគក្នុងសង្សារ ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា នាងស្ដាប់ធម៌នោះហើយ កើតនូវសេចក្ដីសង្វេគបាននូវសទ្ធាហើយ ក៏សូមបួស ។ ព្រះថេរីបានឲ្យនាងបួសហើយ កាលបួសហើយ ធ្វើកិច្ចខាងដើមស្រេច ចម្រើនវិបស្សនាមិនយូរប៉ុន្មាន ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ព្រោះសម្បូរដោយហេតុសម្បទា ពិចារណាដល់បដិបទារបស់ខ្លួនហើយ ពោលនូវគាថាទាំងនេះជាឧទានថា

អាត្មាអញមិនលុះអំណាចក្នុងការនៃចិត្ត មិនបានសេចក្ដីស្ងប់
ចិត្ត បានចេញអំពីលំនៅ ៤ លើក ៥ លើក អាត្មាអញបាន
ចូលទៅរកភិក្ខុនី ( ព្រះថេរីឈ្មោះខេមា ) ហើយសាកសួរ
ដោយគោរព លោកបានសំដែងធម៌គឺធាតុ អាយតនៈ អរិយ
សច្ច ៤ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ អដ្ឋង្គិកមគ្គ ដល់អាត្មា
អញ ដើម្បីដល់នូវប្រយោជន៍ដ៏ឧត្ដម ។ លុះអាត្មាអញបាន

ស្ដាប់ពាក្យរបស់ភិក្ខុនីនោះហើយ ក៏បានធ្វើតាមពាក្យប្រៀនប្រដៅរបស់លោក ក្នុងបុរិមយាមនៃរាត្រី បានរឭកឃើញនូវបុព្វជាតិក្នុងមជ្ឈិមយាមនៃរាត្រី បានជម្រះនូវទិព្វចក្ខុក្នុងបច្ឆិមយាមនៃរាត្រី បានទម្លាយនូវគំនរងងឹត វេលានោះអាត្មាអញបានជ្រួតជ្រាបកាយដោយបីតិ និងសុខៈ ទម្លាយនូវគំនរងងឹតហើយលាងជើងទាំងគូក្នុងរាត្រីទី ៧ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភិក្ខុនី** ព្រះថេរីពោលសំដៅដល់ព្រះនាងខេមាថេរី ។ បទថា **ពោជ្ឈង្គដ្ឋង្គិកំ មគ្គំ** បានដល់ ពោជ្ឈង្គ ៧ និងអរិយមគ្គមានអង្គ ៨ ។ បទថា **ឧត្តមត្ថស្ស បត្តិយា** បានដល់ ដើម្បីសម្រេចអរហត្ត ឬនិព្វានប៉ុណ្ណោះ ។

បទថា **បីតិសុខេន** បានដល់ ដោយបីតិ និងសុខ ទាក់ទងដោយផលសមាបត្តិ ។ បទថា **កាយំ** បានដល់ នាមកាយដែលប្រកបគ្នានឹងរូបកាយដែលទៅតាមនាមកាយនោះ ។ បទថា **ផរិត្វា** បានដល់ ពាល់ត្រូវឬជ្រួតជ្រាប ។ បទថា **សត្តមិយា ចាទេ បសារេសឹ** សេចក្ដីថា រាប់អំពីថ្ងៃផ្ដើមវិបស្សនាទៅ ក្នុងថ្ងៃទី ៧ ទើបខ្ញុំរំសាយក្អែន ។ សួរថា ទម្លាយនូវគំនរងងឹតបានដូចម្ដេច ឆ្លើយថា ទម្លាយនូវគំនរមោហៈដែលមិនធ្លាប់ទម្លាយដោយដាវ គឺអរហត្តមគ្គញ្ញាណ ។ ពាក្យដ៏សេសមានន័យដូចពោលហើយខាងដើមនោះឯង ។

អដ្ឋកថាវិជយាថេរីគាថា ចប់

ថេរីគាថា ឆក្កនិបាត ចប់

# ថេរីគាថា សត្តកនិបាត

## ឧត្តរាថេរីគាថា

[ ៣២៣ ] ពួកមាណពកាន់អង្រែទាំងឡាយបុកស្រូវ ពួកមាណពរមែងបាននូវទ្រព្យចិញ្ចឹមកូននិងប្រពន្ធទាំងឡាយ នាងទាំងឡាយ ចូរព្យាយាមធ្វើអំពើដែលធ្វើហើយមិនក្តៅក្រហាយតាមក្រោយក្នុងព្រះពុទ្ធសាសនា ចូរលាងជើងទាំងឡាយឲ្យធាប់ ហើយអង្គុយក្នុងទីសមគួរ ។ នាងទាំងឡាយចូរតាំងចិត្តតម្កល់ឲ្យមាំឲ្យមានអារម្មណ៍តែមួយ ហើយពិចារណានូវសង្ខារទាំងឡាយថាជារបស់ដទៃទាំងមិនមែនជារបស់ខ្លួន ។

អាត្មាបានស្តាប់ពាក្យរបស់ព្រះថេរីនោះ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះថេរីឈ្មោះបដាចារា ហើយបានលាងជើង រួចចូលទៅអង្គុយក្នុងទីសមគួរ ។ ក្នុងបុរិមយាមនៃរាត្រី អាត្មាបានរឭកឃើញនូវបុព្វជាតិ ក្នុងមជ្ឈិមយាមនៃរាត្រីអាត្មាបានជម្រះនូវទិព្វចក្ខុ ។ ក្នុងបច្ឆិមយាមនៃរាត្រី អាត្មាបានទម្លាយនូវគំនរងងឹត ជាស្រីបាននូវត្រៃវិជ្ជា បានក្រោកចេញ ( អំពីអាសនៈ ) ក្នុងកាលជាខាងក្រោយ ពាក្យប្រៀនប្រដៅរបស់លោកម្ចាស់ ខ្ញុំបានប្រព្រឹត្តហើយ ។ ពួកទេវតាក្នុងឋានត្រៃត្រិង្ស ( ហែហម ) នូវសក្កទេវរាជដែលឈ្នះក្នុងសង្គ្រាមយ៉ាងណា ខ្ញុំបាននូវត្រៃវិជ្ជាមិនមានអាសវៈក៏ហែហម ( លោកម្ចាស់ ) យ៉ាងនោះដែរ ។

ឧត្តរាថេរី ។

# អដ្ឋកថា

# ថេរីគាថា សត្តកនិបាត

## ឧត្តរាថេរីគាថា

[ ៣២៣ ] ក្នុងសត្តកនិបាត គាថារបស់ព្រះនាងឧត្តរាថេរី មានពាក្យផ្ដើមថា **មុសលានិ គហេត្វាន** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ បានធ្វើកុសលមូល សន្សំធម៌ជាគ្រឿងគាក់តែងវិមោក្ខដោយលំដាប់ មានធម៌ជាគ្រឿងអប់រំបន្ទំវិមុត្តិចាស់ក្លា ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលមួយក្នុងនគរសាវត្ថី មានឈ្មោះថាឧត្តរាដល់នូវភាពជាអ្នកដឹងក្ដីហើយចូលទៅកាន់សម្នាក់បដាចារាថេរី ។ ព្រះថេរីបានសម្ដែងធម៌ដល់នាង នាងស្ដាប់ធម៌ហើយ កើតសេចក្ដីសង្វេគក្នុងសង្សារវដ្ដជាអ្នកជ្រះថ្លាក្រៃលែង ក្នុងសាសនាក៏បួស កាលបួសហើយធ្វើកិច្ចខាងដើមស្រេច ចម្រើនវិបស្សនាក្នុងសម្នាក់របស់ព្រះនាងបដាចារាថេរី ប្រកបភាវនារឿយៗ ពិចារណាវិបស្សនាមិនយូរប៉ុន្មានក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ព្រោះឥន្ទ្រិយចាស់ក្លាសម្បូរដោយឧបនិស្ស័យ កាលសម្រេចអរហត្តហើយពិចារណាការបដិបត្តិរបស់ខ្លួនបានពោលគាថាទាំងនេះជាឧទានថា

ពួកមាណពកាន់អង្រែទាំងឡាយបុកស្រូវ ពួកមាណព រមែងបាននូវទ្រព្យចិញ្ចឹមកូន និងប្រពន្ធទាំងឡាយ នាងទាំងឡាយ

ចូរព្យាយាមធ្វើអំពើ ដែលធ្វើហើយ មិនក្តៅក្រហាយតាមក្រោយក្នុងព្រះពុទ្ធសាសនា ចូរលាងជើងទាំងឡាយឲ្យធាប់ហើយអង្គុយក្នុងទីសមគួរ ។ នាងទាំងឡាយចូរតាំងចិត្តតម្កល់ឲ្យមាំ ឲ្យមានអារម្មណ៍តែមួយហើយពិចារណានូវសង្ខារទាំងឡាយថាជារបស់ដទៃ ទាំងមិនមែនជារបស់ខ្លួន ។

អាត្មាបានស្តាប់ពាក្យរបស់ព្រះថេរីនោះ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះថេរីឈ្មោះបដាចារា ហើយបានលាងជើង រួចចូលទៅអង្គុយក្នុងទីសមគួរ ។ ក្នុងបុរិមយាមនៃរាត្រី អាត្មាបានរឭកឃើញនូវបុព្វជាតិក្នុងមជ្ឈិមយាមនៃរាត្រី អាត្មាបានជម្រះនូវទិព្វចក្ខុ ។ ក្នុងបច្ឆិមយាមនៃរាត្រី អាត្មាបានទម្លាយនូវគំនរងងឹត ជាស្រីបាននូវត្រៃវិជ្ជា បានក្រោកចេញ ( អំពីអាសនៈ ) ក្នុងកាលជាខាងក្រោយ ពាក្យប្រៀនប្រដៅរបស់លោកម្ចាស់ ខ្ញុំបានប្រព្រឹត្តហើយ ។ ពួកទេវតាក្នុងឋានត្រៃត្រិង្ស ( ហែហម ) នូវសក្កទេវរាជដែលឈ្នះក្នុងសង្គ្រាមយ៉ាងណា ខ្ញុំបាននូវត្រៃវិជ្ជាមិនមានអាសវៈ ក៏ហែហម ( លោកម្ចាស់ ) យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចិត្តំ ឧបដ្ឋបេត្វាន** បានដល់ ចូលទៅតាំងចិត្ត ប្រកបដោយការនាំទុកក្នុងកម្មដ្ឋាន ប្រកបដូចម្តេច គឺឲ្យចិត្តមានអារម្មណ៍មួយឲ្យតាំងមាំដោយល្អ ។ បទថា **ឯកគ្គំ សុសមាហិតំ បច្ចវេក្ខថ** បាន

ដល់នាងទាំងឡាយចូរពិចារណានូវការបដិបត្តិ អធិប្បាយថា នាងទាំងឡាយចូរជាអ្នកឃើញច្បាស់នូវលក្ខណៈ ៣ ក្នុងសង្ខារ ថាជារបស់មិនទៀងខ្លះ ថាជាទុក្ខខ្លះ ថាជាអនត្តាខ្លះ ។ ក្នុងកាលឲ្យឱវាទ ព្រះនាងបដាចារាថេរី ពោលពាក្យនេះអនុលោមតាមឱវាទរបស់នាងផង ឲ្យឱវាទភិក្ខុនីថេរីអង្គដទៃជាដើមផង ។ បទថា **បដាចារានុសាសនឹ** បានដល់ ពាក្យប្រៀនប្រដៅរបស់បចាដារាថេរី ។ម្យ៉ាងទៀតបាលីថា **បដាចារាយ សាសនំ** ដូច្នេះក៏មាន ។

បទថា **អថ វុដ្ឋាសឹ** សេចក្ដីថា ព្រោះខ្ញុំសម្រេចវិជ្ជា ៣ ទើបក្រោកចាកអាសនៈខាងក្រោយ ។ ថ្ងៃមួយព្រះថេរីរូបនេះ ជម្រះកម្មដ្ឋានក្នុងសម្នាក់ព្រះនាងបដាចារាថេរីហើយ ចូលទៅកាន់លំនៅរបស់ខ្លួន ហើយអង្គុយពត់ភ្នែនដាក់ចិត្តថា អញមិនលាភ្នែននេះ ដរាបចិត្តរបស់អញរួចផុតចាកអាសវៈទាំងឡាយ ព្រោះការមិនប្រកាន់មាំ ពិចារណាវិបស្សនាដោយលំដាប់ ក៏សម្រេចអរហត្តមានអភិញ្ញា និងបដិសម្ភិទាជាបរិវារតាមលំដាប់នៃមគ្គ កាលបច្ចវេក្ខណញ្ញាណ ១៩ កំពុងប្រព្រឹត្តទៅ ក៏កើតសោមនស្សថា ឥឡូវនេះអាត្មាអញធ្វើកិច្ចស្រេចហើយ ក៏ពោលឧទានគាថាទាំងនេះ លាជើងក្នុងកាលអរុណរះបន្ទាប់អំពីនោះរាត្រីក៏ភ្លឺ ទៅកាន់សម្នាក់របស់ព្រះថេរី បានពោលគាថាទាំងនេះដដែលទៀត ដោយហេតុនោះ ទើបនាងឧត្តរាថេរីពោលពាក្យជាដើមថា **កតា តេ អនុសាសនី** ពាក្យប្រៀនប្រដៅរបស់លោកម្ចាស់ ខ្ញុំបានប្រព្រឹត្តហើយ ជាដើម ។ ពាក្យដ៏សេសមានន័យដូចពោលមកខាងដើមនោះឯង ។

**អដ្ឋកថាឧត្តរាថេរីគាថា ចប់**

# ចាលាថេរីគាថា

[ ៣២៤ ] អាត្មាជាភិក្ខុនី បានចម្រើននូវឥន្ទ្រិយ ផ្ចង់ស្មារតី បានចាក់ធ្លុះនូវព្រះនិព្វាន ជាទីស្ងប់រម្ងាប់នូវសង្ខារ ជាសុខក្រៃលែង ។

នាងជាស្ត្រីកំណោរ ប្រាកដដូចជាសមណី តើឧទ្ទិសចំពោះលទ្ធិណានាង មិនគាប់ចិត្តនឹងលទ្ធិទាំងឡាយ ហេតុអ្វីក៏នាងជាស្ត្រីវង្វេងប្រព្រឹត្តបែបនេះ ។

លទ្ធិទាំងឡាយខាងក្រៅអំពីសាសនានេះ អាស្រ័យនូវទិដ្ឋិទាំងឡាយ ពួកជន ( ប្រកាន់លទ្ធិ ) នោះ មិនដឹងច្បាស់នូវធម៌ ពួកជននោះ មិនវាងវៃក្នុងធម៌ ។ មាន ( ព្រះរាជបុត្តមួយអង្គ ) កើតក្នុងសក្យត្រកូល បានត្រាស់ជាព្រះពុទ្ធ មិនមានបុគ្គលផ្ទឹមបានព្រះអង្គបានសំដែងប្រាប់អាត្មានូវអរិយសច្ចធម៌ ជាធម៌ប្រព្រឹត្តកន្លងនូវទិដ្ឋិគឺ ទុក្ខ ១ ហេតុនាំឲ្យកើតទុក្ខ ១ ទីដែលប្រព្រឹត្តកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធអាត្មាបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួងអាត្មា បានកម្ចាត់ហើយ គំនរងងឹតអាត្មាបានទម្លាយហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងយើងកម្ចាត់ចេញហើយ ។

ចាលាថេរី ។

# អដ្ឋកថា

# ចាលាថេរីគាថា

[ ៣២៤ ] គាថារបស់ព្រះនាងចាលាថេរី មានពាក្យផ្ដើមថា **សតឹ ឧបដ្ឋ-បេត្វាន** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងពុទ្ធុប្បាទនេះកើតក្នុងគភ៌របស់ព្រាហ្មណីឈ្មោះរូបសារី ក្នុងនាលកគាមដែនមគធៈ ក្នុងថ្ងៃដាក់ឈ្មោះ ញាតិទាំងឡាយ បានដាក់ឈ្មោះថា ចាលា ។ ចាលានោះមានប្អូនស្រីឈ្មោះឧបចាលា ឧបចាលានោះមានប្អូនស្រីម្នាក់ទៀតឈ្មោះសីសូបចាលា ទាំង ៣ នាក់នេះ ជាប្អូនស្រីរបស់ព្រះធម្ម-សេនាបតី ។ កូនប្រុស ៣ នាក់ មានឈ្មោះដូចគ្នានឹងជនទាំងនេះដែលលោកហៅក្នុងថេរគាថាថា ចាលា ឧបចាលា សីសូបចាលា[១] ។

បងប្អូនស្រីទាំង ៣ នេះ បានដឹងថា ព្រះធម្មសេនាបតីបួសហើយ នាំគ្នាគិតថា ធម៌វិន័យដែលបងប្រុសរបស់អញទៅបួស គង់មិនថោកថយ ពិតបព្វជ្ជាគង់មិនថោកថយ កើតនូវឧស្សាហ៍ មានឆន្ទៈខ្លាំងក្លា នាំគ្នាលះញាតិនិងអ្នកស្និទ្ធស្នាលដែលកំពុងយំមានមុខជោកដោយទឹកភ្នែក ចេញបួស លុះបួសហើយ ក៏ប្រឹងប្រែងព្យាយាម មិនយូរប៉ុន្មានក៏សម្រេចអរហត្តនៅដោយនិព្វានសុខនិងផលសុខ ។

បណ្ដាភិក្ខុនីទាំងនោះ នឹងពោលដល់ចាលាភិក្ខុនីមុន ។ ថ្ងៃមួយ ត្រឡប់

---

១-សេចក្ដីពិស្ដារសូមមើលក្នុងថេរគាថាឯកនិបាតត្រង់ខទិរវនិយត្ថេរគាថា ឯណោះ ។

អំពីបិណ្ឌបាត ក្រោយពីឆាន់ភត្តាហារហើយ ក៏ចូលទៅកាន់ព្រៃអន្ធវ័នអង្គុយសម្រាកពេលថ្ងៃ កាលនោះ មារចូលទៅរកលួងលោមព្រះថេរី ដោយកាមទាំងឡាយ ដែលលោកសំដៅដល់ពោលទុក ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា

គ្រានោះ ចាលាភិក្ខុនី ស្លៀកដណ្តប់ក្នុងបុព្វណ្ហសម័យ ។បេ។ អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។ គ្រានោះ មារមានចិត្តបាប ចូលទៅរកចាលាភិក្ខុនី ។បេ។ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងចាលាភិក្ខុនីថា... ដូច្នេះ ។

ព្រះថេរីនោះ អង្គុយសម្រាកពេលថ្ងៃ ក្នុងព្រៃអន្ធវ័ន មារចូលទៅរកបំណងនឹងកាត់ព្រះថេរីអំពីការនៅប្រព្រឹត្តព្រហ្មចរិយៈ បានសួរថា នាងជាស្ត្រីកំណោរ ប្រាកដដូចជាសមណី តើឧទ្ទិសចំពោះលទ្ធិណា ដូច្នេះជាដើម ។ លំដាប់នោះ ព្រះនាងចាលាភិក្ខុនីកាលប្រកាសគុណរបស់ព្រះសាស្តា និងប្រកាសថា ព្រះធម៌នាំសត្វចេញចាកទុក្ខដល់មារនោះ ឲ្យមារដឹងដល់ភាពដែលនាងកន្លងវិស័យរបស់មារបានហើយ ដោយការចង្អុលបង្ហាញដល់ការដែលខ្លួនបានធ្វើកិច្ចស្រេចហើយ មារបានស្តាប់ពាក្យនោះ មានចិត្តទោមនស្ស ក៏អន្តរធានទៅក្នុងទីនោះឯង ។ ព្រះនាង ចាលាភិក្ខុនីកាលពោលគាថាដែលខ្លួននិងមារពោលហើយជាឧទាន ទើបពោលគាថាទាំងនេះថា

អាត្មាជាភិក្ខុនី បានចម្រើននូវឥន្ទ្រិយ ផ្ចង់ស្មារតី បានចាក់ធ្លុះនូវព្រះនិព្វានជាទីស្ងប់រម្ងាប់នូវសង្ខារ ជាសុខក្រៃលែង ។

នាងជាស្ត្រីកំណោរ ប្រាកដដូចជាសមណី តើឧទ្ទិសចំពោះលទ្ធិណា នាងមិនគាប់ចិត្តនឹងលទ្ធិទាំងឡាយ ហេតុអ្វីក៏នាងជាស្ត្រីវង្វេងប្រព្រឹត្តបែបនេះ ។

លទ្ធិទាំងឡាយ ខាងក្រៅអំពីសាសនានេះ អាស្រ័យនូវទិដ្ឋិទាំងឡាយពួកជន ( ប្រកាន់លទ្ធិ ) នោះមិនដឹងច្បាស់នូវធម៌ ពួកជននោះមិនវាងវៃក្នុងធម៌ ។ មាន ( ព្រះរាជបុត្តមួយអង្គ ) កើតក្នុងសក្យត្រកូល បានត្រាស់ជាព្រះពុទ្ធ មិនមានបុគ្គលផ្ទឹមបាន ព្រះអង្គបានសំដែងប្រាប់អាត្មា នូវអរិយសច្ចធម៌ ជាធម៌ប្រព្រឹត្តកន្លងនូវទិដ្ឋិគឺទុក្ខ ១ ហេតុនាំឲ្យកើតទុក្ខ ១ ទីដែលប្រព្រឹត្តកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធអាត្មាបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ហើយ គំនរងងឹតអាត្មាបានទម្លាយហើយ ម្នាលមារកំបាបអ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងយើងកម្ចាត់ចេញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតី ឧបដ្ឋបេត្វាន** សេចក្តីថា ធ្វើនូវសតិឲ្យតាំងមាំដោយល្អដោយការចម្រើនសតិប្បដ្ឋាន គឺតម្កល់ស្មារតីទុកយ៉ាងល្អ

ក្នុងកាយជាដើម ដោយភាពជារបស់មិនស្អាត ជាទុក្ខ មិនទៀង និងជា អនត្តា ។ ព្រះថេរីហៅខ្លួនឯងថា ភិក្ខុនី ។ បទថា **ភាវិតិន្ទ្រិយា** សេចក្ដីថា មានឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ដែលអប់រំហើយដោយការចម្រើន អរិយមគ្គ ។ បទថា **បដិវិជ្ឈិ បទំ សន្តំ** សេចក្ដីថា ចាក់ធ្លុះ គឺធ្វើឲ្យជាក់ ច្បាស់នូវសន្តិបទ គឺព្រះនិព្វានដោយការធ្វើឲ្យជាក់ច្បាស់និងចាក់ធ្លុះ ។ បទ ថា **សង្ខារូបសមំ** បានដល់ ហេតុនៃការស្ងប់សង្ខារទាំងពួង ។ បទថា **សុខំ** គឺជាសុខពិតៗ ។ គាថាថា **កំ នុ ឧទ្ទិស្ស** សេចក្ដីថា គាថាដែលមារពោល ហើយក្នុងគាថានេះ មានសេចក្ដីសង្ខេបដូចតទៅនេះថា ក្នុងលោកនេះ មាន លទ្ធិនិងអ្នកសម្ដែងលទ្ធិទាំងនោះជាច្រើន គឺមេលទ្ធិជាច្រើន បណ្ដាមេលទ្ធិ ទាំងនោះនាងជាអ្នកមានក្បាលត្រងោល គឺកោរសក់បួសឧទ្ទិសចំពោះនរណា ហ្ន៎មិនមែនក្បាលត្រងោលតែម្យ៉ាងប៉ុណ្ណោះទេថែមទាំងបង្ហាញខ្លួនដូចសមណៈ ព្រោះទ្រទ្រង់នូវសំពត់កាសាវៈទៀតផង ។ បាទគាថាថា **ន ច រោចេសិ បាសណ្ឌេ** សេចក្ដីថា នាងមិនពេញចិត្តក្នុងលទ្ធិតិរ្ថិយទាំងនោះដែលជាកញ្ចក់ របស់ពួកតាបសនិងបរិព្វាជកជាដើមដោយប្រកាន់ថាជាលទ្ធិដទៃ ។ បាទគាថា ថា **កិមិទំ ចរសិ មោមុហា** សេចក្ដីថា នាងលះនូវផ្លូវនិព្វាន ដែលជាផ្លូវ ត្រង់ មិនមែនលទ្ធិតិរ្ថិយ ហេតុអ្វីថ្ងៃនេះទើបដើរផ្លូវខុសដែលជាផ្លូវវង្វេងម្ចាល ជាផ្លូវវង្វេងនិងជាផ្លូវឲ្យយឺតយូរ ។

ព្រះថេរី ស្ដាប់ពាក្យនោះហើយ កាលនឹងសម្កុតមារនោះ ដោយពាក្យ ជំទាស់ ទើបពោលថា **ឥតោ ពហិទ្ធា** ជាដើម ។ លទ្ធិខាងក្រៅសាសនា របស់ព្រះសម្មាសម្ពុទ្ធដូចជា **កុដីសក** និង **ពហុការ** ជាដើម ឈ្មោះថា

លទ្ធិតិត្ថិយក្រៅសាសនានេះ ក្នុងពាក្យថា **ឥតោ ពហិទ្ធា** នោះ ។ ពិតហើយ ពួកអ្នកកាន់យកលទ្ធិតិត្ថិយទាំងនោះ រមែងជាក់នូវអន្ទាក់ គឺតណ្ហានិងអន្ទាក់ គឺទិដ្ឋិដល់សត្វទាំងឡាយ ទើបលទ្ធិនោះត្រូវហៅថា **បាសណ្ឌ** គឺលទ្ធិដូចជាអន្ទាក់ ដោយហេតុនោះទើបព្រះនាងចាលាថេរីពោលថា **ទិដ្ឋិយោ ឧប-និស្សិតា** បានដល់ អាស្រ័យសស្សតទិដ្ឋិ អធិប្បាយថា កាន់យកនូវទិដ្ឋិ ម្យ៉ាងទៀត មនុស្សទាំងឡាយអាស្រ័យទិដ្ឋិ ដោយចំណែកណា ក៏អាស្រ័យពួកអ្នកកាន់លទ្ធិតិត្ថិយដោយចំណែកនោះ ។ បាទគាថាថា **ន តេ ធម្មំ វិជា-នន្តិ** សេចក្តីថា តិត្ថិយពួកណាអាស្រ័យសស្សតទិដ្ឋិ តិត្ថិយទាំងនោះ រមែងមិនដឹងសូម្បីបវត្តិ ( ទុក្ខ ) តាមសេចក្តីពិតថា នេះជាបវត្តិ ។ បទថា **ន តេ ធម្មស្ស កោវិទា** បានដល់ មិនឈ្លាសក្នុងនិវត្តិ ( ការរំលត់ទុក្ខ ) ថា នេះជានិវត្តិ និវត្តិយ៉ាងនេះ ។ តិត្ថិយទាំងនោះវង្វេងក្នុងផ្លូវគឺបវត្តិធម៌ រឿងអ្វីដែលមិនវង្វេងក្នុងនិវត្តិធម៌នោះ ។

ព្រះនាងចាលាថេរី កាលសម្តែងថា លទ្ធិតិត្ថិយមិននាំសត្វចេញចាកទុក្ខយ៉ាងនេះហើយ ឥឡូវនេះដើម្បីវិសជ្ជនាបញ្ហាថា នាងជាស្ត្រីកំណោរ ប្រាកដដូចជាសមណី តើឧទ្ទិសចំពោះលទ្ធិណា ទើបពោលពាក្យថា មាន ( ព្រះរាជបុត្តមួយអង្គ ) កើតក្នុងសក្យត្រកូល ដូច្នេះជាដើម ។ បណ្តាពាក្យទាំងនោះបាទគាថាថា **ទិដ្ឋីនំ សមតិក្កមំ** បានដល់ ជាឧបាយឈានកន្លងនូវទិដ្ឋិទាំងពួងគឺដកចាកអន្ទាក់ គឺទិដ្ឋិ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

**អដ្ឋកថា ចាលាថេរីគាថា ចប់**

# ឧបចាលាថេរីគាថា

[ ៣២៥ ] អាត្មាជាភិក្ខុនី មានស្មារតី មានចក្ខុគឺបញ្ញា មានឥន្ទ្រិយចម្រើនហើយ បានចាក់ធ្លុះនូវព្រះនិញ្វានជាទីស្ងប់ដែលបុរសថោកទាប មិនដែលបានសេពហើយ ។

នាងមិនគាប់ចិត្តនឹងជាតិទេឬ សត្វដែលកើតហើយតែងបរិភោគកាមទាំងឡាយ នាងចូរបរិភោគនូវតម្រេកក្នុងកាមទាំងឡាយកុំ ឲ្យមានសេចក្តីស្តាយក្រោយ ។

សេចក្តីស្លាប់និងការកាត់នូវដៃជើង រមែងមានដល់សត្វដែលកើតហើយ សត្វដែលកើតហើយរមែងដល់នូវសេចក្តីទុក្ខ មានការសម្លាប់និងការចង ជាកំណាត់ ។ មាន ( ព្រះរាជបុត្តមួយព្រះអង្គ ) កើតក្នុងសក្យត្រកូល បានត្រាស់ជាព្រះពុទ្ធ ព្រះអង្គផ្ចាញ់នូវមារមានកិលេសមារជាដើម ព្រះអង្គបានសំដែងប្រាប់អាត្មានូវអរិយសច្ចធម៌ ជាធម៌កន្លងនូវជាតិ គឺទុក្ខ ១ ហេតុនាំឲ្យកើតទុក្ខ ១ ទីដែលប្រព្រឹត្តកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយសាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ។ សេចក្តីរីករាយ ក្នុងអារម្មណ៍ទាំងពួងអាត្មាបានកម្ចាត់ចេញហើយ គំនរងងឹតអាត្មាបានទម្លាយចេញហើយ ម្នាលមារកំបាបអ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងយើងកម្ចាត់ចេញហើយ ។

ឧបចាលាថេរី ។

ចប់ សត្តកនិបាត ។

# អដ្ឋកថា

## ឧបចាលាថេរីគាថា

[ ៣២៥ ] គាថារបស់ព្រះនាងឧបចាលាថេរី មានពាក្យផ្ដើមថា **សតិមតី** ដូច្នេះជាដើម ។

រឿងរបស់នាងឧបចាលាថេរីនោះ បានពោលហើយក្នុងរឿងនាងចាលាថេរីនោះឯង ។ នាងឧបចាលាថេរីនេះ បួសហើយដូចនាងចាលាថេរី ផ្ដើមចម្រើនវិបស្សនា សម្រេចអរហត្ត កាលបន្លឺឧទាន បានពោលគាថានេះថា

អាត្មាជាភិក្ខុនី មានស្មារតី មានចក្ខុគឺបញ្ញា មានឥន្ទ្រិយចម្រើនហើយ បានចាក់ធ្លុះនូវព្រះនិព្វានជាទីស្ងប់ ដែលបុរសថោកទាប មិនដែលបានសេពហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សតិមតី** សេចក្ដីថា ដល់ព្រមដោយសតិ គឺជាបុគ្គលប្រកបដោយសតិ រក្សាខ្លួនបានយ៉ាងក្រៃលែងដែលជាចំណែកខាងដើម ប្រកបដោយសតិដ៏ឧត្ដម ដោយដល់នូវការបរិបូណ៌នៃសតិ ព្រោះចម្រើនអរិយមគ្គក្នុងកាលខាងក្រោយ ។

បទថា **ចក្ខុមតី** បានដល់ ប្រកបដោយបញ្ញាចក្ខុ គឺប្រកបដោយបញ្ញាដែលភ្លឺស្វាងតាំងអំពីជំបូងដែលជ្រែកនូវកិលេសចេញបានយ៉ាងប្រសើរលោក អធិប្បាយថា ប្រកបដោយបញ្ញាចក្ខុដ៏ក្រៃលែង ព្រោះមានបញ្ញាបរិបូណ៌ ។ បទថា **អកាបុរិសសេវិតំ** បានដល់ បុរសមិនថោកថយ គឺឧត្ដមបុរស បានដល់ព្រះអរិយៈ មានព្រះពុទ្ធជាដើមសេពហើយ ។

បទថា **កឹ នុ ជាតឹ ន រោចេសិ** ជាដើម មារបបួលព្រះថេរីចូលទៅរកកាម ទើបពោល ។ សេចក្តីពិត ព្រះថេរីត្រូវមារសួរថា នែភិក្ខុនី នាងមិនពេញចិត្តអ្វី ទើបឆ្លើយថា នែមារ ខ្ញុំមិនពេញចិត្តជាតិ គឺការកើតពិតៗ លំដាប់នោះ មារកាលសំដែងថាសត្វដែលកើតហើយ បរិភោគកាម ព្រោះហេតុនោះ ទើបប្រាថ្នាជាតិខ្លះ បរិភោគកាមខ្លះ បានពោលគាថានេះថា

នាងមិនគាប់ចិត្តនឹងជាតិទេឬ សត្វដែលកើតហើយ តែងបរិ-
ភោគកាមទាំងឡាយ នាងចូរបរិភោគនូវតម្រេកក្នុងកាមទាំង
ឡាយ កុំឲ្យមានសេចក្តីស្តាយក្រោយ ដូច្នេះ ។

គាថានោះមានសេចក្តីថា ហេតុនោះដូចម្តេច នែនាង នាងមិនគាប់ចិត្ត គឺមិនពេញចិត្តនូវការកើតដោយហេតុណា ហេតុនោះក៏មិនមាន ព្រោះហេតុដែលបុគ្គលកើតហើយរមែងបរិភោគកាមទាំងឡាយ គឺបុគ្គលកើតហើយក្នុងលោកនេះ កាលសេពនូវរូបជាដើមដែលប្រកបដោយកាមគុណ រមែងឈ្មោះថា បរិភោគកាមសុខ បុគ្គលមិនកើតប៉ុណ្ណោះទើបមិនចាំបាច់បរិភោគ ព្រោះហេតុនោះ សូមនាងបរិភោគការត្រេកអរក្នុងកាមទាំងឡាយចុះ គឺសូមនាងសោយនូវការត្រេកអរក្នុងការលេងដោយកាមទាំងឡាយ ។ បទថា **មាហុ បច្ឆានុតាបិនី** សេចក្តីថា កុំជាអ្នកមានការក្តៅក្រហាយ ក្នុងកាលជាខាងក្រោយថា កាលនៅក្មេង កាលភោគៈមាន ខ្ញុំមិនបានសោយកាមសុខ អធិប្បាយថា ធម្មតាថា ធម៌ទាំងឡាយក្នុងលោកនេះ គេតែងដឹងថាដើម្បីឲ្យសម្រេចប្រយោជន៍នេះនិងដើម្បីត្រូវការកាមសុខ ។

ព្រះថេរីស្តាប់ពាក្យនោះហើយ ក៏ប្រកាសថា ការកើតជាហេតុនៃទុក្ខ និងថា ខ្លួនបានឈានកន្លងវិស័យរបស់មារហើយ កាលគំរាមនូវមារទើបពោលគាថាទាំងនេះថា

សេចក្តីស្លាប់និងការកាត់នូវដៃជើង រមែងមានដល់សត្វ ដែលកើតហើយ សត្វដែលកើតហើយរមែងដល់នូវសេចក្តីទុក្ខមានការសម្លាប់និងការចងជាកំណត់ ។ មាន ( ព្រះរាជបុត្តមួយព្រះអង្គ ) កើតក្នុងសក្យត្រកូល បានត្រាស់ជាព្រះពុទ្ធ ព្រះអង្គផ្ចាញ់នូវមារមានកិលេសមារជាដើម ព្រះអង្គបាន សំដែងប្រាប់អាត្មានូវអរិយសច្ចធម៌ ជាធម៌កន្លងនូវជាតិ គឺទុក្ខ ១ ហេតុនាំឲ្យកើតទុក្ខ ១ ទីដែលប្រព្រឹត្តកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធអាត្មាអញបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួងអាត្មាបានកម្ចាត់ចេញហើយ គំនរងងឹតអាត្មាបានទម្លាយចេញហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមកអ្នកឯងយើងកម្ចាត់ចេញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជាតស្ស មរណំ ហោតិ** សេចក្តីថា ព្រោះហេតុដែលការស្លាប់ រមែងមានដល់សត្វដែលកើតមកហើយ មិនមានដល់

សត្វដែលមិនកើតឡើយ មិនមែនតែការស្លាប់តែម្យ៉ាងប៉ុណ្ណោះទេ សេចក្តីពិតនោះ រោគទាំងឡាយ មានរោគជរាជាដើម មានប្រមាណប៉ុនណា រោគទាំងនោះដែលជារបស់គ្មានប្រយោជន៍ មានជាតិជាហេតុ រមែងមានដល់អ្នកដែលកើតមកហើយ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រោះជាតិជាបច្ច័យ ទើបជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសៈមាន ដោយហេតុនោះឯង ទើបនាងឧបចាលាថេរីពោលថា **ហត្ថច្ឆេទនំ** ជាដើម អធិប្បាយថា ការដែលត្រូវកាត់ដៃនិងជើង រមែងមានដល់អ្នកកើតហើយ មិនមែនមានដល់អ្នកមិនកើតនោះទេ ក្នុងសេចក្តីនេះ គប្បីឃើញថា លោកបានសម្តែងកម្មករណៈ ៣២ យ៉ាង ទុកដោយការអាងដល់ការកាត់ដៃជើងជាតឹកតាង ។ ២ បាទថា **វធពន្ធបរិក្លេសំ ជាតោ ទុក្ខំ និគច្ឆតិ** សេចក្តីថា ការសម្លាប់ មានការផ្តាច់ជីវិតនិងការចងជាដើម ការចងមានចងដោយច្រវាក់ជាដើម និងកម្មករណៈដទៃគ្រប់យ៉ាង ឈ្មោះថា ទុក្ខ បុគ្គលដែលកើតហើយ រមែងបានជួបនូវទុក្ខទាំងអស់នោះ បុគ្គលមិនកើតមិនជួបឡើយ ព្រោះហេតុនោះ ទើបខ្ញុំមិនគាប់ចិត្តក្នុងការកើត ។

ឥឡូវនេះ ព្រះនាងឧបចាលាថេរី កាលសម្តែងការកន្លងផុតជាតិជាការកន្លងផុតកាមទាំងឡាយ និងភាពដែលនាងឈានកន្លងជាតិបានហើយ ទើបពោលពាក្យថា មាន ( ព្រះរាជបុត្តមួយព្រះអង្គ ) កើតក្នុងសក្យត្រកូល ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អបរាជិតោ** បានដល់ បុគ្គលដែលមារណាមួយ មានកិលេសមារជាដើម ឲ្យចាលចាញ់មិនបាន ។ ពិត

ហើយ ព្រះសាស្តាទ្រង់ជាព្រះសព្វញ្ញូ ទ្រង់គ្របសង្កត់លោក ព្រមទាំងទេវលោកបានដោយពិត ព្រោះហេតុនោះ ទើបជាបុគ្គលដែលអ្នកណាមួយឲ្យបាញ់មិនបាន ពាក្យដ៏សេសមានអត្ថងាយយល់ ព្រោះមានន័យដូចពោលមកហើយ ។

អដ្ឋកថា ឧបចាលាថេរីគាថា ចប់

ថេរីគាថា សត្តកនិបាត ចប់

# ថេរីគាថា អដ្ឋកនិបាត

## សីសូបចាលាថេរីគាថា

[ ៣២៦ ] ភិក្ខុនីបរិបូណ៌ដោយសីល សង្រួមដោយប្រពៃក្នុងឥន្ទ្រិយទាំងឡាយ គប្បីបាននូវព្រះនិព្វានជាទីស្ងប់មានឱជៈ មិនប្របូកប្របល់ដោយវត្ថុអ្វីមួយ ។

ពួកទេវតាណា នៅក្នុងឋានតាវត្តិង្សក្តី នៅក្នុងឋានយាមៈក្តី នៅក្នុងឋានតុសិតក្តី ពួកទេវតានៅក្នុងឋាននិម្មានរតីក្តី ពួកទេវតានៅក្នុងឋានបរនិម្មិតវសវត្តីក្តី នាងចូរតាំងចិត្តទៅរកពួកទេវតាទាំងនោះដែលនាងធ្លាប់នៅហើយ ក្នុងកាលមុន ។

ពួកទេវតាណា នៅក្នុងឋានតាវត្តិង្សក្តី នៅក្នុងឋានយាមៈក្តី នៅក្នុងឋានតុសិតក្តី ពួកទេវតានៅក្នុងឋាននិម្មានរតីក្តី ពួកទេវតានៅក្នុងឋានបរនិម្មិតវសវត្តីក្តី ( ទេវតាទាំងនោះចេញ ) អំពីភពទៅកាន់ភព សព្វៗកាល តម្កល់នៅក្នុងសក្កាយ គឺខន្ធបញ្ចកៈ មិនប្រព្រឹត្តកន្លងនូវសក្កាយៈ ជាអ្នកអន្ទោលទៅកាន់ជាតិនិងមរណៈ ។ លោកទាំងមូលឆេះ លោកទាំងមូលប្រាលរន្ទាល លោកទាំងមូលសន្ធោសន្ធៅ លោកទាំងមូលញាប់ញ័រ ( ដោយភ្លើង ១១ មានរាគៈជាដើម ) ។ ព្រះពុទ្ធបានសំដែងធម៌ប្រាប់អាត្មា ជាធម៌ដែលមិនកម្រើក មិនមានអ្វីផ្ទឹមបានដែលបុថុជ្ជនសេពមិនបានហើយ ចិត្តរបស់អាត្មាត្រេកអរចំពោះក្នុងធម៌នោះ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះ

ពុទ្ធ អាត្មាបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញហើយ គំនរងងឹតអាត្មាបានទម្លាយចេញហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមកអ្នកឯងយើងកម្ចាត់ចេញហើយ ។

**សីសូបចាលាថេរី ។**

**ចប់ អដ្ឋកនិបាត ។**

# អដ្ឋកថា

# ថេរីគាថា អដ្ឋកនិបាត

## សីសូបចាលាថេរីគាថា

[ ៣២៦ ] ក្នុងអដ្ឋកនិបាត គាថារបស់ព្រះនាងសីសូបចាលាថេរី មានពាក្យផ្តើមថា **ភិក្ខុនី សីលសម្បន្នា** ដូច្នេះជាដើម ។

រឿងរបស់នាងសីសូបចាលាថេរីរូបនេះ បានពោលហើយក្នុងរឿងរបស់ចាលាថេរី ។ ឯនាងសីសូបចាលាថេរីនេះ ដឹងថា ព្រះធម្មសេនាបតីបួសហើយ ក៏កើតនូវឧស្សាហៈឡើងឯង បួសហើយធ្វើបុព្វកិច្ចស្រេច ចូលទៅតាំងវិបស្សនា ព្យាយាមមិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត កាលសម្រេចអរហត្តហើយ នៅដោយសុខក្នុងផលសមាបត្តិ ។ ថ្ងៃមួយ ពិចារណាការបដិបត្តិរបស់ខ្លួន កើតនូវសោមនស្ស បានពោលគាថាជាឧទានថា

ភិក្ខុនីបរិបូណ៌ដោយសីល សង្រួមដោយប្រពៃ ក្នុងឥន្ទ្រិយ

ទាំងឡាយ គប្បីបាននូវព្រះនិព្វានជាទីស្ងប់ មានឱជៈមិនប្រ-
បូកប្របល់ដោយវត្ថុអ្វីមួយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលសម្បន្នា** បានដល់ ប្រកបបរិបូណ៌ ដោយសីលរបស់ភិក្ខុនីដែលបរិសុទ្ធ ។ បទថា **ឥន្ទ្រិយេសុ សុសំវុតា** បានដល់ សង្រួមល្អហើយ ក្នុងឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦ គឺជាបុគ្គលលះនូវរាគៈក្នុងឥដ្ឋារម្មណ៍ មានរូបជាដើម លះនូវទោសៈក្នុងអនិដ្ឋារម្មណ៍ និងលះមោហៈក្នុងការសម្លឹងអារម្មណ៍ដែលមិនស្មើ ជាងអ្នកបិទនូវឥន្ទ្រិយដោយល្អហើយ ។ បទថា **អសេចនកមោជវំ** បានដល់ អរិយមគ្គ ឬនិព្វាន ដែលបុគ្គលណាមួយ ធ្វើឲ្យវិនាសមិនបាន មានឱជៈគឺមានរសផ្អែមជាសភាវៈ ជាថ្នាំរម្ងាប់រោគ គឺកិលេសគ្រប់ប្រភេទ ។ សេចក្តីពិត អរិយមគ្គក៏ហៅថាសន្តិបទបាន ព្រោះបុគ្គលត្រូវការនិព្វានគប្បីបដិបត្តិ និងព្រោះមិនមានការក្តៅក្រហាយដោយកិលេស ។ មារបំណាងឲ្យព្រះថេរីឃ្លាតចាកសមាបត្តិ ដោយបញ្ជូនទៅក្នុងកាមាវចរសួគ៌ថា ចូរនាងប្រាថ្នាជាប់ជំពាក់ក្នុងកាមាវចរសួគ៌ចុះ ទើបពោលគាថានេះថា

ពួកទេវតាណា នៅក្នុងឋានតាវត្តិង្សក្តី នៅក្នុងឋានយាមៈក្តី
នៅក្នុងឋានតុសិតក្តី ពួកទេវតានៅក្នុងឋាននិម្មានរតីក្តី ពួក
ទេវតានៅក្នុងឋានបរនិម្មិតវសវត្តីក្តី នាងចូរតាំងចិត្តទៅរកពួក
ទេវតាទាំងនោះដែលនាងធ្លាប់នៅហើយក្នុងកាលមុន ដូច្នេះ ។

ទីដែលជន ៣៣ នាក់ ធ្វើបុណ្យរួមគ្នាទៅកើត ឈ្មោះថា តាវត្តិង្ស

បុគ្គលដែលកើតក្នុងជាន់តាវត្តិង្សនោះ ឈ្មោះថា ពួកទេវតានៅក្នុងជាន់តាវត្តិង្ស ។ តែអាចារ្យពួកខ្លះពោលថា ពាក្យថា តាវត្តិង្ស ត្រឹមតែជាឈ្មោះរបស់ទេវតាទាំងនោះប៉ុណ្ណោះ ឈ្មោះថា **យាមា** ព្រោះចូលដល់ទិព្វសុខវិសេសជាងទេវលោកទាំង ២ ។ ឈ្មោះថា **តុសិតា** ព្រោះអត្ថថា ត្រេកអរដោយទិព្វសម្បត្តិ ឈ្មោះថា **និម្មានរតិនោ** ព្រោះនិម្មិតភោគៈទាំងឡាយបានតាមគាប់ចិត្ត ក្នុងពេលដែលត្រូវការ និងត្រេកអរជាងអារម្មណ៍តាមប្រក្រតី ។ ឈ្មោះថា **បរនិម្មិតវសវត្តិនោ** ព្រោះប្រើអំណាចក្នុងភោគៈទាំងឡាយ ដែលបុគ្គលដទៃដឹងនូវការពេញចិត្តនិម្មិតឲ្យ ។

បទថា **តត្ថ ចិត្តំ បណិធេហិ** សេចក្តីថា ចូរនាងតាំងចិត្ត គឺចូរធ្វើនូវការប្រាថ្នាដើម្បីកើតក្នុងពួកទេវតា មានជាន់តាវត្តិង្សជាដើមនោះ មារពោលដល់ទេវតាជាន់តាវត្តិង្សជាដើមឡើងទៅដោយបំណងថា ភោគសម្បត្តិរបស់ទេវតាជាន់ចាតុម្មហារាជិកាថោកទាបជាងទេវតាជាន់ដ៏សេស ។ បទថា **យត្ថ តេ វុសិតំ បុរេ** បានដល់ ក្នុងពួកទេវតាដែលនាងធ្លាប់នៅមកអំពីមុន បានឮថា នាងសីសូបចាលាថេរីនោះ កើតក្នុងទេវតាទាំងឡាយក្នុងកាលមុន បានជម្រះផ្លូវស្ថានសួគ៌ជាន់កាមាវចរ ៥ ជាន់ តាំងអំពីតាវត្តិង្សឡើងទៅ ហើយធ្លាក់មកនៅជាន់ទាបវិញ តាំងនៅក្នុងជាន់តុសិត បន្ទាប់អំពីនោះហើយ ចុតិមកកើតក្នុងបច្ចុប្បន្ន ។

ព្រះថេរីបានស្តាប់ពាក្យនោះ សម្តែងភាពដែលខ្លួនមានចិត្តចេញអំពីកាម និងចេញអំពីលោកថា នែមារ ចូរអ្នកឈប់ចុះ កាមាវចរលោកដែលអ្នក

ពោលក្តី លោកដទៃៗក្តី ត្រូវភ្លើងគឺរាគៈជាដើមឆេះសន្ធោសន្ធៅ ចិត្តរបស់វិញ្ញូជន រមែងមិនត្រេកអរក្នុងលោកទាំងនោះឡើយ កាលគំរាមនូវមារនោះ ក៏ពោលគាថាទាំងនេះថា

ពួកទេវតាណា នៅក្នុងឋានតាវត្តិង្សក្តី នៅក្នុងឋានយាមៈក្តី នៅក្នុងឋានតុសិតក្តី ពួកទេវតានៅក្នុងឋាននិម្មានរតីក្តី ពួកទេវតានៅក្នុងឋានបរនិម្មិតវសវត្តីក្តី ( ទេវតាទាំងនោះចេញ ) អំពីភពទៅកាន់ភពសព្វៗកាល តម្កល់នៅក្នុងសក្កាយ គឺខន្ធបញ្ចកៈ មិនប្រព្រឹត្តកន្លងនូវសក្កាយៈ ជាអ្នកអន្ទោលទៅកាន់ជាតិនិងមរណៈ ។ លោកទាំងមូលឆេះ លោកទាំងមូលប្រោលរន្ទាល លោកទាំងមូលសន្ធោសន្ធៅ លោកទាំងមូលញាប់ញ័រ ( ដោយភ្លើង ១១ មានរាគៈជាដើម ) ។ ព្រះពុទ្ធបានសំដែងធម៌ប្រាប់អាត្មា ជាធម៌ដែលមិនកម្រើក មិនមានអ្វីផ្ទឹមបានដែលបុថុជ្ជនសេពមិនបានហើយ ចិត្តរបស់អាត្មាត្រេកអរចំពោះក្នុងធម៌នោះ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីការបស់ព្រះ-អង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធអាត្មាបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញហើយ គំនរងងឹតអាត្មាបានទម្លាយចេញហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងយើងកម្ចាត់ចេញ

ហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាលំ កាលំ** បានដល់ អស់កាលនោះៗ ។ បទថា **ភវាភវំ** បានដល់ ចាកភពកាន់ភព ។ បទថា **សក្កាយស្មឹ** បានដល់ ក្នុងបញ្ចក្ខន្ធ ។ បទថា **បុរក្ខតា** ប្រែថា ធ្វើទុកខាងមុខ លោកអធិប្បាយថា នៃមារ ទេវតាជាន់តាវត្តិង្សជាដើម ដែលអ្នកពោលដល់ កាលទៅអំពីភពមួយក៏ចូលកាន់ភពមួយ ក៏តាំងនៅក្នុងសក្កាយ ដែលដេរដាសដោយទោសច្រើនយ៉ាងមានការមិនទៀងជាដើម ព្រោះហេតុនោះ ទើបទេវតាយកសក្កាយនោះឯងនាំមុខក្នុងកាលនោះៗ គឺក្នុងពេលកើត ក្នុងពេលកណ្ដាល ក្នុងពេលចុងបញ្ចប់ តាំងនៅក្នុងភពនោះ បន្ទាប់អំពីនោះក៏មិនកន្លងផុតសក្កាយ មិនបែរមុខចេញអំពីទុក្ខ ស្ទុះទៅតាមត្រើយសក្កាយប៉ុណ្ណោះ ឈ្មោះថា **ជាតិមរណសារិនោ** ព្រោះត្រូវភគៈជាដើមជាប់តាមហើយ រមែងស្ទុះទៅរកជាតិនិងមរណៈរឿយៗទៅ រមែងមិនផុតចាកជាតិនិងមរណៈនោះបានឡើយ ។

បទថា **សព្វោ អាទីបិតោ លោកោ** សេចក្ដីថា នៃមារ មិនមែនត្រឹមតែកាមលោកដែលគេដឹងថាមាន ៣ ធាតុ ប៉ុណ្ណោះឡើយ សូម្បីលោកទាំងអស់ក៏ត្រូវភ្លើង ១១ កង មានភ្លើងគឺរាគៈជាដើមឆេះហើយ ។ ឈ្មោះថា **បទីបិតោ** ព្រោះត្រូវភ្លើងឆេះរឿយៗ ឈ្មោះថា **បជ្ជលិតោ** ព្រោះឆេះសន្ធោសន្ធៅជានិច្ចនិរន្តរ៍ ឈ្មោះថា **បកម្បិតោ** ព្រោះញាប់ញ័រ គឺឃ្លាតទៅផ្លូវនោះផ្លូវនេះដោយតណ្ហានិងដោយកិលេសសព្វយ៉ាង ។

កាលត្រូវភ្លើងឆេះសន្ធោសន្ធៅញាប់ញ័រយ៉ាងនេះ ព្រះមានព្រះភាគ មាន

ព្រះទ័យដែលមហាករុណាជាស់តឿនហើយ ទ្រង់បានសម្តែងលោកុត្តរធម៌ ៩ យ៉ាង ចែកជាមគ្គផលនិងនិព្វាន ឈ្មោះថា **អកម្បិយំ** ព្រោះបុគ្គលណាមួយមិនអាចឲ្យញាប់ញ័រ គឺកម្រើកបាន ។ ឈ្មោះថា **អតុលិយំ** ព្រោះបុគ្គលណាមួយមិនអាចថ្លឹងគុណបានថា មានប្រមាណប៉ុណ្ណេះ ដ្បិតមិនមានបុគ្គលដូចព្រះអង្គ ។ ឈ្មោះថា **អបុថុជ្ជនសេវិតំ ពុទ្ធោ** ព្រោះព្រះអរិយៈ មានព្រះពុទ្ធជាដើមសេពហើយ ព្រោះកាន់យកជាផ្លូវចម្រើនគោចរ គឺអារម្មណ៍ ទ្រង់បានប្រកាសហើយដល់លោកព្រមទាំងទេវលោក ។ ចិត្តរបស់ខ្ញុំត្រេកអរក្រៃលែងក្នុងអរិយធម៌នោះ អធិប្បាយថា មិនត្រឡប់អំពីអរិយធម៌នោះ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា សីសូបចាលាថេរីគាថា ចប់

ថេរីគាថា អដ្ឋកនិបាត ចប់

# ថេរីគាថា នវកនិបាត

## វឌ្ឍមាតាថេរីគាថា

[ ៣២៧ ] ហៃវឌ្ឍៈ ព្រៃគឺកិលេស កុំមានដល់លោក ក្នុងកាលណាៗឡើយ ហៃកូន លោកកុំមានចំណែកនៃសេចក្តីទុក្ខរឿយៗឡើយ ។ ហៃវឌ្ឍៈ ព្រោះថា អ្នកប្រាជ្ញទាំងឡាយលោកមិនមានតណ្ហា កាត់សេចក្តីសង្ស័យ ជាអ្នកត្រជាក់ត្រជុំ ដល់នូវសេចក្តីរាបសា មិនមានអាសវៈ តែងនៅជាសុខ ។ ហៃវឌ្ឍៈ ចូរលោកចម្រើនឲ្យរឿយៗ ដើម្បីដល់នូវការឃើញមគ្គ ដែលពួកឥសីនោះ ធ្លាប់សន្សំមកហើយ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខ ។

បពិត្រមាតា លោកក្លៀវក្លាប្រាប់សេចក្តីនេះដល់ខ្ញុំ បពិត្រមាតា ខ្ញុំសំគាល់ថា ព្រៃគឺកិលេសរបស់លោកមិនមានដោយពិត ។

ហៃវឌ្ឍៈ សង្ខារទាំងឡាយឯណានីមួយដ៏ថោកទាប ឧត្តម និងកណ្តាល ព្រៃគឺកិលេស សូម្បីតូចធ្មារក្តី សូម្បីបន្តិចបន្តួចក្តីនៃខ្ញុំមិនមានឡើយ ។ ខ្ញុំជាអ្នកមិនប្រមាទ បានចម្រើនឈាន មានអាសវៈទាំងពួងអស់ហើយ ត្រៃវិជ្ជាខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។

មាតារបស់ខ្ញុំ បានចាក់ជន្លួញដ៏លើសលុប គឺគាថាប្រកបដោយប្រយោជន៍យ៉ាងសំខាន់ៗដោយពិត ដូចជាពួកជនអ្នកអនុគ្រោះ ។ ខ្ញុំបានស្តាប់ពាក្យប្រៀនប្រដៅរបស់លោកដែលជាមាតាបង្កើតហើយ ក៏ដល់នូវធម្មសង្វេគ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ។ ខ្ញុំនោះ មានចិត្តស្ទុងទៅរកព្រះនិព្វាន ដោយសម្មប្បធាន មិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ ជាអ្នកដែលមាតាដាស់

តឿនហើយ ក៏ស្ងប់រម្ងាប់ បានសម្រេចនូវព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ។

វឌ្ឍមាតាថេរី ។

ចប់ នវកនិបាត ។

# អដ្ឋកថា

# ថេរីគាថា នវកនិបាត

## វឌ្ឍមាតុថេរីគាថា

[ ៣២៧ ] ក្នុងនវកនិបាត គាថារបស់ព្រះនាងវឌ្ឍមាតុថេរី មានពាក្យផ្តើមថា **មា សុ តេ វឌ្ឍ លោកម្ហិ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ សន្សំបុណ្យដើម្បីការរួចផុតដោយលំដាប់ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះមានត្រកូលក្នុងការុកច្ឆនគរ ចម្រើនវ័យហើយ មានប្តី ប្រសូតបុត្តម្នាក់ បុត្តនោះមានឈ្មោះថាវឌ្ឍៈ ។ តាំងអំពីនោះមក ជនទាំងឡាយក៏ហៅនាងថា វឌ្ឍមាតា នាងស្តាប់ធម៌ក្នុងសម្នាក់ភិក្ខុនីបាននូវសទ្ធា ក៏ប្រគល់បុត្តដល់ពួកញាតិ ហើយនៅអាស្រ័យក្នុងសម្នាក់ភិក្ខុនី រឿងដែលគួរពោលបន្ទាប់អំពីនេះ មានក្នុងរឿងរបស់ព្រះវឌ្ឍត្ថេរ ( ថេរគាថាអដ្ឋកនិបាត ) ឯណោះ ។ នាងសំណេះសំណាលជាមួយព្រះវឌ្ឍត្ថេរដែលជាបុត្ត ដែលប្រញាប់ប្រញាល់មក

ដើម្បីសួរសុខទុក្ខក្នុងសម្នាក់ភិក្ខុនីមួយអង្គឯងថា ហេតុអ្វី ទើបលោកម្ចាស់ប្រញាប់ប្រញាល់មកក្នុងទីនេះ ត្រឹមតែមួយអង្គឯង កាលទូន្មាន ទើបពោលគាថាទាំងនេះថា

ហៃវឌ្ឍៈ ព្រៃគឺកិលេសកុំមានដល់លោកក្នុងកាលណាៗឡើយ
ហៃកូន លោកកុំមានចំណែកនៃសេចក្តីទុក្ខរឿយៗឡើយ ។
ហៃវឌ្ឍៈ ព្រោះថា អ្នកប្រាជ្ញទាំងឡាយ លោកមិនមានតណ្ហា
កាត់សេចក្តីសង្ស័យ ជាអ្នកត្រជាក់ត្រជុំ ដល់នូវសេចក្តីរាប
សា មិនមានអាសវៈ តែងនៅជាសុខ ។ ហៃវឌ្ឍៈ ចូរលោក
ចម្រើនឲ្យរឿយៗ ដើម្បីដល់នូវការឃើញមគ្គ ដែលពួកឥសី
នោះ ធ្លាប់សន្សំមកហើយ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខ
ដូច្នេះ ។

បណ្តាបទទាំងនោះ ក្នុងពាក្យថា **មា សុ តេ វឌ្ឍ លោកម្ហិ វនថោ អហុ កុទាចនំ** ពាក្យថា **សុ** ត្រឹមតែជានិបាត នៃវឌ្ឍៈ តណ្ហាគឺកិលេស ដូចព្រៃក្នុងសត្វលោកនិងសង្ខារលោកទាំងអស់កុំបីមានដល់កូនក្នុងកាលណាឡើយ ក្នុងសេចក្តីនោះ ព្រះថេរីពោលហេតុថា នៃកូន កូនកុំមានចំណែកនៃទុក្ខ មានការកើតទៅមកៗជាដើមរឿយៗ គឺកាលកាត់តណ្ហាមិនដាច់ កុំជាភាគីបុគ្គល គឺជាអ្នកមានចំណែកនៃទុក្ខ មានការកើតវិលវល់ទៅមកជាដើមរឿយៗ ដែលមានកិលេសនោះជាហេតុ ។ ព្រះថេរីកាលសម្តែងទោសក្នុងការកាត់កិលេសដូចព្រៃមិនបានយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងអានិសង្សក្នុងការ

កាត់នូវកិលេសបាន ទើបពោលថា **សុទំ ហិ វឌ្ឍ** ជាដើម សេចក្តីថា នែវឌ្ឍៈ កូនឈ្មោះថា **មុនយោ** ព្រោះជាអ្នកប្រកបដោយមោនេយ្យធម៌ ឈ្មោះថា **អនេជា** ព្រោះមិនមានតណ្ហាដែលឈ្មោះថាឯជា ឈ្មោះថា **ឆិន្នសំសយា** ព្រោះកាត់សេចក្តីសង្ស័យបានដោយសោតាបត្តិមគ្គ ឈ្មោះថា **សីតិភូតោ** ព្រោះមិនមានកម្តៅ ដោយកម្តៅគឺកិលេសទាំងពួង ឈ្មោះថា **ទមប្បត្តា** ព្រោះសម្រេចការទូន្មានដ៏កំពូល ឈ្មោះថា **អនាសវា** ព្រោះអស់ អាសវៈហើយរមែងនៅជាសុខ ឥឡូវនេះ ទុក្ខផ្លូវចិត្តរបស់លោកមិនមាន តទៅទុក្ខគ្រប់យ៉ាងក៏នឹងមិនមាន ។

ព្រោះហេតុយ៉ាងនេះឯង ទើបព្រះថេរីពោលថា **តេហានុចិណ្ណំ ឥសីភិ ។បេ។ អន្តព្រហាយ** សេចក្តីថា នែកូនវឌ្ឍៈ កូនគប្បីចម្រើនមគ្គ គឺសមថៈនិងវិបស្សនា ដែលព្រះឥសីណាស្រេចអ្នកស្វែងរកគុណធំទាំងនោះ ប្រព្រឹត្តតាមៗគ្នា គឺបដិបត្តិមកហើយ ដើម្បីសម្រេចញាណទស្សនៈ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខក្នុងវដ្តៈទាំងអស់ ។

ព្រះវឌ្ឍត្ថេរស្តាប់ពាក្យមាតាហើយ គិតថា មាតារបស់អញ ពិតជាតាំងនៅក្នុងអរហត្ត កាលប្រកាសសេចក្តីនោះ ទើបពោលគាថាថា

> បពិត្រមាតាលោកក្មៀវក្លា ប្រាប់សេចក្តីនេះដល់ខ្ញុំ បពិត្រមាតា
> ខ្ញុំសំគាល់ថាព្រៃ គឺកិលេសរបស់លោក មិនមានដោយពិត
> ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិសារទា វ ភណសិ ឯតមត្ថំ ជនេត្តិ មេ**

សេចក្ដីថា បពិត្រមាតា នាងពោលមិនខ្វាចក្រែង គឺពោលមិនទើសទាក់ មិនយឺតយូរ ពោលសេចក្ដីនេះគឺឲ្យឱវាទនោះដល់អាត្មាថា ហៃវឌ្ឍៈ ព្រៃគឺកិលេស កុំមានដល់លោកក្នុងកាលណាៗឡើយ ដូច្នេះ ។

ព្រោះហេតុនោះ ទើបខ្ញុំសំគាល់ថា ព្រៃគឺកិលេសរបស់លោក មិនមានដោយពិត អធិប្បាយថា បពិត្រមាតា ខ្ញុំយល់ថា កិលេសដូចព្រៃ ត្រឹមតែការស្រឡាញ់ ព្រោះអាស្រ័យផ្ទះរបស់មាតា គង់មិនមានក្នុងកូន មិនមែនឬ អធិប្បាយថា មិនប្រកាន់ថា ជាកូនរបស់មាតាហើយ មិនមែនឬ ។

ព្រះថេរីស្ដាប់ពាក្យបុត្តហើយ ពោលថា កិលេសសូម្បីតិចតួចមិនមានក្នុងអារម្មណ៍ណាមួយរបស់មាតាឡើយ ដូច្នេះ កាលប្រកាសភាពដែលខ្លួនធ្វើកិច្ចស្រេចហើយទើបពោល ២ គាថានេះថា

*ហៃវឌ្ឍៈ សង្ខារទាំងឡាយឯណានីមួយដ៏ថោកទាប ឧត្ដម និងកណ្ដាល ព្រៃគឺកិលេសសូម្បីតូចឆ្មារក្ដី សូម្បីបន្តិចបន្តួចក្ដីនៃខ្ញុំមិនមានឡើយ ។ ខ្ញុំជាអ្នកមិនប្រមាទ បានចម្រើនឈាន មានអាសវៈទាំងពួងអស់ហើយ ត្រៃវិជ្ជាខ្ញុំបានសម្រេចហើយសាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **យេ កេចិ** ជាពាក្យពោលការមិនមានកំណត់ៗ បទថា **សង្ខារា** បានដល់ សង្ខតធម៌ ។ បទថា **ហីន** បានដល់ ទាប គួររង្កៀស ។ បទថា **ឧក្កដ្ឋមជ្ឈិមា** បានដល់ ប្រណីត និងកណ្ដាល បណ្ដាសង្ខារ ៣ នោះ សង្ខារដែលជរាមរណៈតាក់តែង ឈ្មោះថា ថោកទាប

សង្ខារដែលជាតិតាក់តែង ឈ្មោះថា ប្រណីត សង្ខារដែលផ្សំគ្នាទាំងពីរយ៉ាង ឈ្មោះថា កណ្តាល ។ ន័យម្យ៉ាងទៀត សង្ខារដែលឆន្ទៈជាដើម យ៉ាងថោកទាបធ្វើឲ្យកើត ឈ្មោះថាថោកទាប ដែលឆន្ទៈជាដើម យ៉ាងកណ្តាលធ្វើឲ្យកើត ឈ្មោះថាកណ្តាល ដែលឆន្ទៈជាដើមយ៉ាងប្រណីតធ្វើឲ្យកើត ឈ្មោះថាឧត្តម ។ ន័យម្យ៉ាងទៀត អកុសលធម៌ ឈ្មោះថាថោកទាប លោកុត្តរធម៌ ឈ្មោះថាខ្ពង់ខ្ពស់ ក្រៅអំពីនេះ ឈ្មោះថាកណ្តាល ។ បទថា **អណុម្បិ អណុមត្តោបិ** សេចក្តីថា មិនមែនសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ក្នុងកូនតែម្យ៉ាងដោយពិត កិលេសដូចព្រៃក្នុងសង្ខារគ្រប់យ៉ាង មានការបែកសង្ខារជាថោកទាបជាដើម ដ៏តូចតាចក្តី ដ៏តូចឆ្មារក្តី របស់មាតាមិនមានឡើយ សង្ខារគ្រប់យ៉ាង មានថោកទាបជាដើម ឯណានីមួយ តណ្ហារបស់មាតាក្នុងសង្ខារទាំងអស់នោះដ៏តូចតាចក្តី ដ៏តូចឆ្មារក្តី ល្អិតក្រៃលែងក្តី មិនមានឡើយ ។

ព្រះថេរីពោលហេតុនោះថា ខ្ញុំជាអ្នកមិនប្រមាទ បានចម្រើនឈាន មានអាសវៈទាំងពួងអស់ហើយជាដើម ។ បណ្តាបទទាំងនោះ បទថា **អប្បមត្តស្ស ឈាយតោ** បានដល់ មិនប្រមាទសម្លឹងឈាន ពាក្យនេះ លោកពោលជាលិង្គវិបល្លាស ។ ក្នុងពាក្យនោះប្រកបសេចក្តីថា ព្រោះវិជ្ជា ៣ មាតាដល់ហើយ ដូច្នោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទើបឈ្មោះថា មាតាធ្វើស្រេចហើយ ព្រោះមាតាមិនប្រមាទ សម្លឹងឈាន ដូច្នោះទើបអាសវៈរបស់មាតាអស់ទៅ តណ្ហារបស់មាតាសូម្បីប៉ុន ១ អណុ ក៏មិនមាន ។

ព្រះថេរៈធ្វើឱវាទដែលព្រះថេរីពោលហើយឲ្យដូចជាកង្វេរ កើតសេចក្តី

សង្វេគ ទៅកាន់វិហារ អង្គុយសម្រាកពេលថ្ងៃ ចម្រើនវិបស្សនាហើយ ក៏សម្រេចអរហត្ត ពិចារណាដល់ការបដិបត្តិរបស់ខ្លួន កើតនូវសោមនស្ស ទៅកាន់សម្នាក់របស់មាតា កាលព្យាករអរហត្ត ទើបពោល ៣ គាថានេះថា

មាតារបស់ខ្ញុំ បានចាក់ជន្លួញដ៏លើសលុប គឺគាថាប្រកបដោយប្រយោជន៍យ៉ាងសំខាន់ៗដោយពិត ដូចជាពួកជនអ្នកអនុគ្រោះ ។ ខ្ញុំបានស្តាប់ពាក្យប្រៀនប្រដៅរបស់លោក ដែលជាមាតាបង្កើតហើយ ក៏ដល់នូវធម្មសង្វេគ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ។ ខ្ញុំនោះមានចិត្តស្ទុងទៅរកព្រះនិព្វាន ដោយសម្មប្បធាន មិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ ជាអ្នកដែលមាតាដាស់តឿនហើយក៏ស្ងប់រម្ងាប់ បានសម្រេចនូវព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ដូច្នេះ ។

កាលនោះ ព្រះថេរីមានការពេញចិត្តដែលបុត្តរបស់នាងធ្វើពាក្យ របស់នាងឲ្យដូចជាកង្វេរហើយបានសម្រេចអរហត្ត ទើបពោលគាថាដែលព្រះថេរៈពោលទៀត ហាក់ដូចជាគាថារបស់ខ្លួន ទើបគាថានោះ ជាថេរីគាថា ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧឡារំ** បានដល់ បរិបូណ៌ គឺធំក្រៃលែង ។ បទថា **បតោទំ** បានដល់ កង្វេរ គឺឱវាទ ។ បទថា **សមវស្សរិ** ប្រកបសេចក្តីថា ឲ្យប្រព្រឹត្តទៅដោយប្រពៃហើយហ្ន៎ ។ បើសួរថា កង្វេរនោះគឺអ្វី ព្រោះហេតុនោះទើបព្រះថេរៈពោលថា គឺគាថាប្រកបដោយប្រយោជន៍យ៉ាង

សំខាន់ៗដោយពិត ដូចជាពួកជនអ្នកអនុគ្រោះ ដូច្នេះ ។ ពាក្យឆ្លើយនោះ ព្រះថេរៈពោលសំដៅដល់គាថាតាំងអំពីដើមដែលមាតាពោលថា **មា សុ តេ វឌ្ឍ លោកម្ហិ** ជាដើម ។ បទថា **យថាបិ អនុកម្បិកា** សេចក្តីថា មាតារបស់ខ្ញុំប្រគល់កន្ត្រៃ គឺជំបងសម្រាប់ទូន្មានដ៏ឧឡារ ពោលគឺគាថាដែលប្រកាសបវត្តិ គឺទុក្ខនិងនិវត្តិ គឺការរំលត់ទុក្ខដែលត្រូវជាសំគៀន ឲ្យកើតកម្លាំងញាណដល់ខ្ញុំ ។

បទថា **ធម្មសំវេគមាបាទិ** បានដល់ ដល់នូវការខ្វាច ការសង្វេគយ៉ាងក្រៃលែង ព្រោះនាំមកនូវភ័យដោយញាណ ។

បទថា **បធានបហិតត្តោ** បានដល់ មានចិត្តក្បួចក្នុងព្រះនិព្វាន ដោយការប្រកបសម្មប្បធាន ៤ យ៉ាង ។ បទថា **អផុសឹ សន្តិមុត្តមំ** សេចក្តីថា ពាល់ត្រូវ គឺសម្រេចសន្តិដ៏កំពូល គឺព្រះនិព្វាន ។

អដ្ឋកថាវឌ្ឍមាតាថេរីគាថា ចប់

ថេរីគាថា នវកនិបាត ចប់

# ថេរីគាថា ឯកាទសកនិបាត

## កិសាគោតមីថេរីគាថា

[ ៣២៨ ] ភាពនៃកល្យាណមិត្ត ចំពោះសត្វលោក ព្រះមហាមុនី ទ្រង់សរសើរហើយ បុគ្គលកាលគប់រកនូវពួកកល្យាណមិត្ត សូម្បីខ្លួនជាបុគ្គលពាលក៏គង់បានទៅជាបណ្ឌិត ។ បុគ្គលគួរគប់រកនូវពួកសប្បុរស ប្រាជ្ញានៃពួកបុគ្គលដែលរាប់រក ( នូវសប្បុរស ) រមែងចម្រើនដោយពិត បុគ្គលឯណានីមួយ មានក្សត្រជាដើម កាលគប់រកនូវពួកសប្បុរសគប្បីរួចចាកទុក្ខទាំងអស់ផង គប្បីដឹងនូវអរិយសច្ចទាំង ៤ ផង គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ ទុក្ខនិរោធសច្ច ១ មគ្គសច្ច ប្រកបដោយអង្គ ៨ ប្រការ ១ ។ ព្រះមានព្រះភាគ ជាសារថីទូន្មាននូវបុរស ទ្រង់ត្រាស់ថា ឥត្ថីភាពនាំមកនូវសេចក្តីទុក្ខ ។ មែនពិត ការនៅរួមជាមួយនឹងស្វាមីនាំមកនូវទុក្ខ ស្រីពួកខ្លះសម្រាលបុត្តតែម្តង ដាច់បំពង់ស្បូន ( ស្លាប់ ) ក៏មាន ( ស្រីពួកខ្លះ ) ជាសុខុមាលជាតិ មានគភ៌វាងពាក់កណ្តាល ប្រាថ្នាសម្លាប់កូនក្នុងគភ៌ ស៊ីថ្នាំពិស ដល់នូវសេចក្តីវិនាសទាំងពីរនាក់ ( កូននិងម្តាយ ) ក៏មាន ។ ខ្ញុំកាលទៅរកទីសម្រាល ( កូន ) បានឃើញប្តីស្លាប់ ខ្ញុំទៅមិនទាន់ដល់ផ្ទះរបស់ខ្លួន ក៏សម្រាល ( កូន ) កណ្តាលផ្លូវ ។ កូនទាំងពីរក៏ធ្វើមរណកាល ប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងផ្លូវ ខ្ញុំជាស្រីកំព្រា ឯមាតាបិតានិងបងប្អូនប្រុស ក៏ត្រូវគេដុតក្នុងជើងថ្ករជាមួយគ្នា នាងរងទុក្ខប្រមាណមិនបាន ក្នុងត្រកូលដែលអស់ភោគសម្បត្តិ ជាត្រកូលកំព្រា ទឹកភ្នែករបស់នាងប្រព្រឹត្តទៅ អស់ពាន់

ជាតិជាច្រើន ។ ខ្ញុំឃើញនាង ( កើតជា ) ចចកញី ស៊ីសាច់មនុស្សក្នុងកណ្ដាលព្រៃស្មសាន មួយទៀតសាច់កូនក៏នាងបានស៊ីហើយ ( ក្នុងអត្តភាពនេះ ) ខ្ញុំមានវង្សត្រកូលសាបសូន្យត្រូវអ្នកផងតិះដៀល មានប្ដីក៏ស្លាប់ តែបានត្រាស់ដឹងនូវអមតៈ ។ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានឈ្មោះអមតៈនេះខ្ញុំបានចម្រើនហើយ ទាំងព្រះនិព្វាន ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយដែរ ខ្ញុំបានឃើញហើយនូវកញ្ចក់គឺធម៌ ។ ខ្ញុំមានសរ គឺរាគាទិក្កិលេសកាត់ហើយ មានភារៈដាក់ចុះហើយ កិច្ចដែលគួរធ្វើខ្ញុំបានធ្វើរួចស្រេចហើយ នាងកីសាគោតមីថេរី មានចិត្តផុតស្រឡះហើយ ( ចាកកិលេស ) បានពោលនូវសេចក្ដីនេះ ។

**កីសាគោតមីថេរី ។**

**ចប់ ឯកាទសកនិបាត ។**

# អដ្ឋកថា

# ថេរីគាថា ឯកាទសកនិបាត

## កីសាគោតមីថេរីគាថា

[ ៣២៨ ] ក្នុងឯកាទសកនិបាត គាថារបស់ព្រះនាងកីសាគោតមីថេរី មានពាក្យផ្ដើមថា **កល្យាណមិត្តតា** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ កាលសាសនាព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូល ក្រុងហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីហើយ ថ្ងៃមួយ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនី មួយរូបក្នុងតំណែងឯតទគ្គៈ គឺជាកំពូលជាងភិក្ខុនីដែលទ្រទ្រង់នូវចីវរសៅហ្មង ទើបសន្សំកុសលឲ្យក្រៃលែង ហើយប្រាថ្នាតំណែងនោះ នាងអន្ទោលទៅក្នុង ទេវតានិងមនុស្សទាំងឡាយអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទនេះ កើតក្នុង ត្រកូលទុគ៌ត ក្រុងសាវត្ថី មានឈ្មោះថា គោតមី តែព្រោះស្គម ទើបហៅថា កីសាគោតមី ។ នាងទៅកាន់ត្រកូលស្វាមី មាតាបិតា និងញាតិមើលងាយ ថា កូនស្រីរបស់ត្រកូលក្រីក្រ នាងប្រសូតបុត្តម្នាក់ ព្រោះបានកូនប្រុស មាតាបិតានិងញាតិក៏ធ្វើការរាប់អានក្រៃលែង តែកូនប្រុសនោះក៏ស្លាប់ ក្នុង កាលដែលចេះរត់លេង ដោយហេតុនោះ ក៏ក្លាយជាមនុស្សឆ្កួត ព្រោះសេចក្តីសោក ។

នាងគិតថា ពីមុនអញត្រូវគេមើលងាយ តាំងពីបានកូនប្រុស អញក៏ បានទទួលនូវការស្រឡាញ់រាប់អាន មនុស្សទាំងនេះព្យាយាមចោលកូនអញ ខាងក្រៅស្រុក ដោយភាពជាមនុស្សឆ្កួត ព្រោះសេចក្តីសោក ទើបពសរីរៈ កូនប្រុសដែលស្លាប់ហើយ ត្រាច់ទៅក្នុងនគរតាមលំដាប់ទ្វារផ្ទះ ដោយពោល ថា សូមលោកមេត្តា ឲ្យថ្នាំដល់កូនប្រុសរបស់ខ្ញុំផងចុះ ។ មនុស្សទាំងឡាយ ជេរប្រទេចថា យកថ្នាំព្យាបាលអ្នកស្លាប់មកអំពីណា នាងមិនជឿពាក្យរបស់ មនុស្សទាំងនោះ កាលនោះ បុរសបណ្ឌិតម្នាក់គិតថា ស្រីនេះ មានចិត្តរវើ

វង្វាយ ជាមនុស្សឆ្កួត ព្រោះសោកដល់កូនប្រុស ព្រះទសពលប៉ុណ្ណោះ គង់ស្គាល់ថ្នាំសម្រាប់ស្រីនេះ ទើបពោលថា ចូរនាងទៅគាល់ព្រះសម្មាសម្ពុទ្ធ ហើយទូលសួរដល់ថ្នាំសម្រាប់កូនប្រុសរបស់នាងចុះ នាងទៅកាន់វិហារពេលព្រះសាស្តាកំពុងសម្តែងធម៌ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានថ្នាំសម្រាប់កូនប្រុសនៃខ្ញុំម្ចាស់ចុះ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់នាង ទើបត្រាស់ថា ចូរនាងទៅកាន់ព្រះនគរ ផ្ទះណាដែលមិនធ្លាប់មានមនុស្សស្លាប់ ចូរនាំគ្រាប់ស្ពៃអំពីផ្ទះនោះមក ។ នាងទទួលព្រះពុទ្ធតម្រាស់ថា សាធុ ត្រេកអរ ចូលទៅកាន់នគរក្នុងផ្ទះដំបូង ពោលថា ព្រះសាស្តាទ្រង់ឲ្យខ្ញុំនាំគ្រាប់ស្ពៃទៅដើម្បីធ្វើថ្នាំ សម្រាប់កូនប្រុសរបស់ខ្ញុំ បើក្នុងផ្ទះនេះមិនធ្លាប់មាននរណាស្លាប់សូមឲ្យគ្រាប់ស្ពៃដល់ខ្ញុំផងចុះ មនុស្សក្នុងផ្ទះនោះពោលថា អ្នកណាអាចរាប់មនុស្សដែលស្លាប់ទៅហើយក្នុងផ្ទះនេះបាន ។ នាងទៅកាន់ផ្ទះទី ២ ទី ៣ ដោយពុទ្ធានុភាពក៏ត្រឡប់បានស្មារតីទើបគិតថា ប្រយោជន៍អ្វីដោយគ្រាប់ស្ពៃនោះ អញមិនត្រូវការគ្រាប់ស្ពៃក្នុងទីនេះ ។ នាងគិតថា និយាមនេះឯងគង់នឹងមានទូទៅក្នុងព្រះនគរ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះដោយបំណងល្អទ្រង់ឃើញហើយ នាងក៏បាននូវសេចក្តីសង្វេគ បន្ទាប់អំពីនោះ ក៏ចេញទៅខាងក្រៅនគរ បោះកូនប្រុសក្នុងព្រៃស្មសាន ពោលគាថានេះថា

អនិច្ចតាធម៌នេះ នឹងថាជាធម៌សម្រាប់ស្រុក ១ ក៏ទេ ជាធម៌
សម្រាប់និគម ១ ក៏ទេ ជាធម៌សម្រាប់ត្រកូល ១ ក៏ទេ ធម៌

នុ៎ះឯង សម្រាប់លោកព្រមទាំងទេវលោកទាំងអស់ ដូច្នេះ ។

កាលនាងពោលយ៉ាងនេះហើយ ក៏ទៅគាល់ព្រះសាស្តា ព្រះសាស្តាត្រាស់សួរនាងថា គោតមី នាងបានគ្រាប់ស្ពៃមកហើយឬ ។ នាងទូលថា បពិត្រព្រះអង្គដ៏ចម្រើន កិច្ចដោយគ្រាប់ស្ពៃចប់ហើយ សូមទ្រង់ជាទីពឹងរបស់ខ្ញុំម្ចាស់ផងចុះ លំដាប់នោះ ព្រះសាស្តាត្រាស់គាថា ( ក្នុងធម្មបទ ) ដល់នាងថា

មច្ចុតែសេចក្តីស្លាប់តែងនាំយកនរជន អ្នកស្រវឹងជ្រប់ ក្នុងកូន
នឹងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗនោះ
ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ដូច្នេះ ។

ចប់គាថា នាងក៏តាំងនៅក្នុងសោតាបត្តិផលដោយអាការដែលឈរ ទូលសូមបព្វជ្ជាជាមួយព្រះសាស្តា ព្រះសាស្តាទ្រង់អនុញ្ញាតឲ្យបព្វជ្ជា ក្នុងសម្នាក់របស់ភិក្ខុនី នាងថ្វាយបង្គំព្រះសាស្តា ធ្វើប្រទក្សិណ ៣ ជុំ ហើយទៅកាន់សម្នាក់ភិក្ខុនី បព្វជ្ជាឧបសម្បទាហើយ មិនយូរប៉ុន្មាន ធ្វើយោនិសោមនសិការ ចម្រើនវិបស្សនា កាលនោះ ព្រះសាស្តាត្រាស់ឱភាសគាថា ( ក្នុងធម្មបទ ) ដល់នាងដូច្នេះថា

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការ
រស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន
ប្រសើរជាង ដូច្នេះ ។

ចប់គាថា នាងក៏សម្រេចអរហត្ត ។ នាងជាអ្នកសន្តោសយ៉ាងឧក្រិដ្ឋ

ក្នុងការប្រើប្រាស់បរិក្ខារ គ្រងតែចីវរប្រកបដោយការសៅហ្មង ៣ យ៉ាង[១] ។ កាលនោះ ព្រះសាស្តាគង់នៅក្នុងជេតពនវិហារ ទ្រង់កំពុងស្ថាបនាភិក្ខុនីទាំងឡាយ ក្នុងតំណែងឯតទគ្គៈ តាមលំដាប់ ទ្រង់ក៏ស្ថាបនាព្រះថេរីក្នុងតំណែងឯតទគ្គៈជាងភិក្ខុនីទាំងឡាយខាងទ្រទ្រង់ចីវរសៅហ្មង ។ ព្រះថេរី ពិចារណាការបដិបត្តិនៃខ្លួនគិតថា អញអាស្រ័យព្រះសាស្តា ទើបបានគុណវិសេសនេះ បានពោលគាថាទាំងនេះ ដោយប្រាថ្នាសរសើរកល្យាណមិត្តថា

ភាពនៃកល្យាណមិត្ត ចំពោះសត្វលោក ព្រះមហាមុនី ទ្រង់សរសើរហើយ បុគ្គលកាលគប់រកនូវពួកកល្យាណមិត្តសូម្បីខ្លួនជាបុគ្គលពាល ក៏គង់បានទៅជាបណ្ឌិត ។ បុគ្គលគួរគប់រកនូវពួកសប្បុរស ប្រាជ្ញានៃពួកបុគ្គលដែលរាប់រក ( នូវសប្បុរស ) រមែងចម្រើនដោយពិត បុគ្គលឯណានីមួយមានក្សត្រជាដើម កាលគប់រកនូវពួកសប្បុរស គប្បីរួចចាកទុក្ខទាំងអស់ផង គប្បីដឹងនូវអរិយសច្ចទាំង ៤ ផង គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ ទុក្ខនិរោធសច្ច ១ មគ្គសច្ចប្រកបដោយអង្គ ៨ ប្រការ ១ ។

( យក្ខិនីមួយរូបពោលថា )

ព្រះមានព្រះភាគ ជាសារថី ទូន្មាននូវបុរស ទ្រង់ត្រាស់ថា ឥត្ថីភាពនាំមកនូវសេចក្តីទុក្ខ ។ មែនពិត ការនៅរួមជាមួយនឹងស្វាមី នាំមកនូវទុក្ខ ស្រីពួកខ្លះសម្រាលបុត្តតែម្តង ដាច់

បំពង់ស្បូន ( ស្លាប់ ) ក៏មាន ( ស្រីពួកខ្លះ ) ជាសុខុមាលជាតិ មានគភ៌វាងពាក់កណ្តាល ប្រាថ្នាសម្លាប់កូនក្នុងគភ៌ ស៊ីថ្នាំពិសដល់នូវសេចក្តីវិនាសទាំងពីរនាក់ ( កូននិងម្តាយ ) ក៏មាន ។

( ព្រះនាងបដាចារាថេរីពោលថា )

ខ្ញុំកាលទៅរកទីសម្រាល ( កូន ) បានឃើញប្តីស្លាប់ ខ្ញុំទៅមិនទាន់ដល់ផ្ទះរបស់ខ្លួន ក៏សម្រាល ( កូន ) កណ្តាលផ្លូវ ។ កូនទាំងពីរក៏ធ្វើមរណកាល ប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងផ្លូវ ខ្ញុំជាស្រីកំព្រា ឯមាតាបិតានិងបងប្អូនប្រុស ក៏ត្រូវគេដុតក្នុងជើងថ្ករជាមួយគ្នា ។

( ព្រះនាងកិសាគោតមីពោលជាស់តឿនខ្លួនឯងថា )

នាងវេទុក្ខប្រមាណមិនបាន ក្នុងត្រកូលដែលអស់ភោគសម្បត្តិជាត្រកូលកំព្រា ទឹកភ្នែករបស់នាងប្រព្រឹត្តទៅអស់ពាន់ជាតិជាច្រើន ។ ខ្ញុំឃើញនាង ( កើតជា ) ចចកញី ស៊ីសាច់មនុស្សក្នុងកណ្តាលព្រៃស្មសាន មួយទៀតសាច់កូន ក៏នាងបានស៊ីហើយ ( ក្នុងអត្តភាពនេះ ) ខ្ញុំមានវង្សត្រកូល សាបសូន្យ ត្រូវអ្នកផងតិះដៀល មានប្តីក៏ស្លាប់ តែបានត្រាស់ដឹងនូវអមតៈ ។ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានឈ្មោះអមតៈនេះ ខ្ញុំបានចម្រើនហើយ ទាំង

ព្រះនិព្វាន ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយដែរ ខ្ញុំបានឃើញហើយនូវកញ្ចក់គឺធម៌ ។ ខ្ញុំមានសរគឺរាគាទិក្កិលេសកាត់ហើយ មានភារៈដាក់ចុះហើយកិច្ចដែលគួរធ្វើខ្ញុំបានធ្វើរួចស្រេចហើយ នាងកិសាគោតមីថេរី មានចិត្តផុតស្រឡះហើយ ( ចាកកិលេស ) បានពោលនូវសេចក្ដីនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កល្យាណមិត្តតា** សេចក្ដីថា ឈ្មោះថាកល្យាណមិត្តព្រោះមានមិត្តល្អចម្រើនល្អ សម្បូរដោយសីលជាដើម កម្ចាត់ទុក្ខដល់បុគ្គលដែលមានទុក្ខ ជួយរក្សានូវប្រយោជន៍ ជាមិត្តមានឧបការៈគ្រប់យ៉ាង ដូចពោលមកនេះ បុគ្គលនោះឈ្មោះថាកល្យាណមិត្ត ភាវៈគឺការមានកល្យាណមិត្តនោះ ឈ្មោះថា **កល្យាណមិត្តតា** គឺភាពជាអ្នកមានមិត្តល្អ ។ បទថា **មុនិនា** បានដល់ ព្រះសាស្ដា ។ បទថា **លោកំ អាទិស្ស វណ្ណិតា** បានដល់ ចំពោះសត្វលោកថា បុគ្គលគួរដើរតាមកល្យាណមិត្ត ទ្រង់សរសើរដោយន័យ ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា ម្នាលអានន្ទ មគ្គព្រហ្មចរិយៈនុ៎ះ កើតប្រាកដដល់ភិក្ខុដែលជាអ្នកមានមិត្តល្អ អ្នកមានសម្លាញ់ល្អ អ្នកបង្អោនទៅរកកល្យាណជនជាដើមនិងពុទ្ធដីកាមួយកន្លែងទៀត ( ក្នុងខុទ្ទកនិកាយឧទាន ) ថា ម្នាលមេឃិយៈ គុណជាតិនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ មានសំឡាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានសីលសង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខសំវរៈ ដូច្នេះ ។

ពាក្យថា **កល្យាណមិត្តេ ភជមានោ** ជាដើម ជាពាក្យសម្ដែងនូវអានិ

សង្ស័នៃភាពជាអ្នកមានមិត្តល្អ ។ បណ្ដាបទទាំងនោះ បទថា **អបិ ពាលោ បណ្ឌិតោ អស្ស** សេចក្ដីថា បុគ្គលគប់រកកល្យាណមិត្ត សូម្បីជាបុគ្គលពាលក្នុងកាលមុន ព្រោះខ្វះនូវការស្ដាប់ជាដើមក៏គប្បីជាបណ្ឌិតបានខ្លះ ព្រោះស្ដាប់រឿងដែលមិនធ្លាប់ស្ដាប់ជាដើម ។

បទថា **ភជិតព្វា សប្បុរិសា** សេចក្ដីថា ព្រោះហេតុដែលបុគ្គលជាពាលក៏ជាបណ្ឌិតបាន ទើបគួរសេពគប់សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ដោយការចូលទៅរកតាមកាលគួរជាដើម ។

បទថា **បញ្ញា តថាបិ វឌ្ឍតិ ភជន្តានំ** ប្រកបសេចក្ដីថា សម្រាប់បុគ្គលដែលគប់រកកល្យាណមិត្ត បញ្ញារមែងចម្រើន កើនបរិបូណ៌ដូចបណ្ដាបុគ្គលទាំងនោះ បុគ្គលណាមួយមានក្សត្រជាដើម កាលសេពគប់សប្បុរសរមែងផុតចាកទុក្ខគ្រប់យ៉ាងមានជាតិជាដើម ។

ព្រះថេរី កាលសម្ដែងវិធីផុតទុក្ខដោយវិធីសេពគប់កល្យាណមិត្ត ទើបពោលពាក្យថា **ទុក្ខញ្ច វិជានេយ្យ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ចត្តារិ អរិយសច្ចានិ** ប្រកបសេចក្ដីថាគប្បីដឹងច្បាស់ចាក់ធ្លុះនូវអរិយសច្ច ៤ គឺទុក្ខ ទុក្ខសមុទយៈ និរោធនិងមគ្គ មានអង្គ ៨ ។

២ គាថាថា **ទុក្ខោ ឥត្ថិភាវោ** ជាដើម យក្ខិនីម្នាក់ កាលតិះដៀលភាពជាស្រីទើបពោល ។ បណ្ដាបទទាំងនោះ បទថា **ទុក្ខោ ឥត្ថិភាវោ អក្ខាតោ** សេចក្ដីថា ភាពជាស្រី ព្រះមានព្រះភាគទ្រង់ជាបុគ្គលដែលគួរទូន្មាន

បុរសត្រាស់ថា ជាទុក្ខ ព្រោះទោសទាំងឡាយមានការទន់ខ្សោយ ការតាំងគភ៌និងភាពជាអ្នកដែលត្រូវអាស្រ័យអ្នកដទៃសព្វកាល ។ បទថា **សបត្តិកម្បិ ហិ ទុក្ខំ** បានដល់ ការនៅជាមួយសត្រូវក្តី ការនៅជាមួយស្រីរួមប្តីក្តី ក៏ជាទុក្ខ អធិប្បាយថា នេះក៏ជាទោសក្នុងភាពជាស្រី ។ បទថា **អប្បេកច្ចា សកឹ វិជាតាយោ** បានដល់ ស្រីពួកខ្លះប្រសូតកូនម្តងប៉ុណ្ណោះ ក៏អត់ធន់នឹងការប្រសូតកូនមិនបាន ។ បទថា **គលកេ អបិ កន្តន្តិ** បានដល់ អារបំពង់កខ្លួនឯងក៏មាន[១]។ បទថា **សុខុមាលិនិយោ វិសានិ ខាទន្តិ** បានដល់ ស្រីដែលមានរាងកាយទន់ខ្សោយ ព្រោះភាពដែលខ្លួនជាមនុស្សទន់ខ្សោយ អត់ធន់នឹងសេចក្តីទុក្ខមិនបាន ទើបបរិភោគថ្នាំពិសក៏មាន ក្នុងពាក្យថា **ជន-មារកមជ្ឈគតា** នោះ បុគ្គលវង្វេងគភ៌ ( ប្រសូតមិនរួច ) លោកហៅថា **ជនមារក** គឺទារកដែលសម្លាប់មនុស្ស គឺមាតា អធិប្បាយថា អ្នកសម្លាប់មនុស្ស ជាអ្នកនៅខាងក្នុង គឺនៅក្នុងផ្ទៃ បានដល់ សត្វដែលវង្វេងគភ៌ ។ បទថា **ឧភោបិ ព្យសនានិ អនុភោន្តិ** សេចក្តីថា ជនទាំង ២ គឺសត្វកើតក្នុងផ្ទៃ និងមាតាដែលមានគភ៌ រមែងជួបនូវការស្លាប់ និងអន្តរាយស្មើរតែស្លាប់ ។ ឯអាចារ្យដទៃទៀតពោលថា កិលេសទាំងឡាយ ឈ្មោះថា ជាអ្នកសម្លាប់ជន ដែលនៅត្រង់កណ្តាលនៃកិលេសទាំងនោះ គឺមានកិលេសដេកត្រាំនៅក្នុងសន្តានរមែងជួបនូវសេចក្តីវិនាស ដោយអំណាចការក្តៅក្រហាយនៃកិលេសក្នុងបច្ចុប្បន្ននេះ រមែងជួបនូវសេចក្តីវិនាស ដោយអំណាចសេចក្តី

---

១-បិដកខ្មែរថា ដាច់បំពង់ស្បូន ។

សៅហ្មងនៃទុគ្គតិក្នុងអនាគត ។ បានឮថា យក្ខិនីនោះបានរឭកដល់ទុក្ខដែលខ្លួនជួបក្នុងភពមុនទើបពោល ២ គាថានេះ ឯព្រះថេរី បានពោលដដែលទៀត ដើម្បីធ្វើឲ្យជាក់ច្បាស់នូវទោសក្នុងភាពជាស្រី ។

២ គាថាថា **ឧបវិជញ្ញា គច្ឆន្តី** ជាដើម ព្រះថេរីពោលប្រារព្ធប្រវត្តិនៃនាងបដាចារាថេរី ។ បណ្ដាបទទាំងនោះ បទថា **ឧបវិជញ្ញា គច្ឆន្តី** ប្រកបសេចក្ដីថា ខ្ញុំមានគភ៌ចាស់ជិតប្រសូត ធ្វើដំណើរមិនទាន់ដល់ផ្ទះខ្លួនឯង ក៏ប្រសូតបុត្តត្រង់ផ្លូវ បានជួបប្ដីស្លាប់ ។

បទថា **កបណិកាយ** ប្រែថា ជាអ្នកក្រីក្រ បានឮថា ពោលគាថា ២ នេះ ព្រះថេរីពោលដើម្បីចង្អុលបង្ហាញទោសក្នុងភាពជាស្រី ដោយអនុលោមតាមព្រឹត្តិការណ៍ដែលព្រះនាងបដាចារាថេរី ដល់នូវការឆ្កួត ព្រោះសេចក្ដីសោកក្នុងកាលនោះ ហើយពោលទុក ។

ព្រះថេរីកាលនាំយករឿងទាំង ២ នេះ មកជាឧទាហរណ៍ហើយ ឥឡូវនេះដើម្បីចង្អុលបង្ហាញនូវទុក្ខដែលខ្លួនជួប ទើបពោលថា **វីណាកុលិនេ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **វីណាកុលីនេ** បានដល់ មានត្រកូលត្រូវជួបនូវសេចក្ដីវិនាសភោគៈជាដើម ។ បទថា **កបណោ** បានដល់ ជាអ្នកក្រីក្រក្រៃលែង ពាក្យទាំង ២ នេះ ជាពាក្យពោលដល់ខ្លួនឯង ។ បទថា **អនុភូតំ តេ ទុក្ខំ អបរិមាណំ** សេចក្ដីថា នាងសោយនូវទុក្ខមិនមែនតិចក្នុងអត្តភាពនេះ ឬក្នុងអត្តភាពមុនអំពីនេះ ឥឡូវនេះ ព្រះថេរីដើម្បីសម្ដែងនូវទុក្ខនោះដោយឯកទេស ទើបពោលថា **អស្សុ ច តេ បវត្តំ** ដូច្នេះជាដើម

ពាក្យនោះមានសេចក្តីថា នាងវិលវល់ក្នុងសង្សារវដ្ត ដែលមិនដឹងទីបំផុតខាងដើមនិងខាងចុង ត្រូវសេចក្តីសោក គ្របសង្កត់ច្រើនពាន់ជាតិ ទឹកភ្នែកហូរហើយ ។ ពាក្យនេះព្រះថេរីពោលមិនប្លែក ព្រោះទឹកភ្នែកមានចំនួនច្រើនជាងទឹកក្នុងមហាសមុទ្ទ ។

បទថា **វសិតា សុសានមជ្ឈេ** សេចក្តីថា នាងជាឆ្កែស្រុក នាងជាឆ្កែចចក រង់ចាំស៊ីសាច់មនុស្សត្រង់ព្រៃស្មសាន ។ បទថា **ខាទិតានិ បុត្ត-មំសានិ** បានដល់ ក្នុងកាលនៅជាខ្លាធំ ខ្លាដំបង និងខ្លាត្រីជាដើម ស៊ីទាំងសាច់កូនរបស់ខ្លួនឯង ។ បទថា **ហតកុលិកា** បានដល់ មានវង្ស ត្រកូលវិនាសហើយ ។ បទថា **សព្វគរហិតា** បានដល់ ត្រូវអ្នកគ្រប់គ្រងផ្ទះគ្រប់គ្នាតិះដៀល គឺដល់នូវការតិះដៀល ។ បទថា **មតបតិកា** ប្រែថា ជាស្រីមេម៉ាយ ព្រះថេរីពោលដល់រឿងទាំង ៣ ដែលពោលដល់ខ្លួន ក្នុងជាតិមុនទោះយ៉ាងនេះ ក៏គង់សម្រេចអមតធម៌ គឺសម្រេចព្រះនិព្វាន មានការសេពនូវកល្យាណមិត្តជាសំខាន់ ។

ឥឡូវនេះ ព្រះថេរីដើម្បីសម្តែងការសម្រេចអមតៈនោះឲ្យប្រាកដ ទើបពោលថា **ភាវិតោ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ភាវិតោ** បានដល់ឲ្យមានហើយ ឲ្យកើតហើយ ឲ្យចម្រើនហើយ ចាក់ធ្លុះហើយដោយការអប់រំនូវការត្រាស់ដឹង ។ បទថា **ធម្មាទាសំ អវេក្ខឹហំ** បានដល់ ខ្ញុំបានជួបបានឃើញនូវកញ្ចក់ធម៌ ។ បទថា **អហាមត្ថិ កន្តសល្លា** សេចក្តីថា ខ្ញុំជាអ្នកមានកិលេសដូចព្រួញមានរាគៈជាដើមដកបានហើយដោយអរិយមគ្គ ។

បទថា **ឱហិតភារា** បានដល់ មានភារៈ គឺកាម ( ភារៈ ) ខន្ធ ( ភារៈ ) កិលេស ( ភារៈ ) អភិសង្ខារ ( ភារៈ ) ដាក់ចុះហើយ ។ បទថា **កតំ ហិ ករណីយំ** បានដល់ កិច្ច ១៦ មានបរិញ្ញាកិច្ចជាដើម ខ្ញុំក៏ធ្វើសម្រេចហើយ គឺសម្រេចហើយ ។ ដោយបទថា **សុវិមុត្តចិត្តា ឥមំ ភណិ** ព្រះថេរីពោលដល់ខ្លួនឯងដូចជាអ្នកដទៃថា កិសាគោតមីថេរី ជាអ្នកមានចិត្តរួចផុតហើយដោយប្រការទាំងពួង បានពោលគាថានេះ ដោយការចងជាគាថា ដោយពាក្យថា **កល្យាណមិត្តតា** ជាដើម ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទី ១ សែនអំពីកប្បនេះទៅ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូល ១ នៅក្នុងក្រុងហង្សវតី បានចូលទៅគាល់ព្រះពុទ្ធព្រះនាមបទុមុត្តរៈទ្រង់ប្រសើរជាងនរជននោះ ហើយយកព្រះអង្គជាទីពឹង ។ ខ្ញុំបានស្តាប់ធម៌ដ៏ពីរោះរបស់ព្រះអង្គ ជាធម៌ប្រកបដោយសច្ច ៤ មានអានិសង្សដ៏ក្រៃលែង នាំមកនូវសេចក្តីស្ងប់ និងសេចក្តីសុខក្នុងចិត្ត ។ កាលនោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់សរសើរ តាំងភិក្ខុនីអ្នកទ្រទ្រង់ចីវរដ៏សៅហ្មងក្នុងទីជាឯតទគ្គ ។ ខ្ញុំញុំាងបីតិមានប្រមាណច្រើនឲ្យកើត ស្តាប់នូវគុណនៃភិក្ខុនី ខ្ញុំធ្វើនូវគ្រឿងសក្ការៈដល់ព្រះពុទ្ធ តាមគួរ

ដល់សេចក្តីអង់អាច តាមគួរដល់កម្លាំង ។ ខ្ញុំបានក្រាបចុះជិតព្រះអង្គជាអ្នកប្រាជ្ញ មានប្រាជ្ញាខ្ជាប់ខ្ជួននោះ ហើយប្រាថ្នានូវតំណែងនោះ កាលនោះ ព្រះសម្ពុទ្ធជានាយក ទ្រង់អនុមោទនាចំពោះ ការបាននូវតំណែងនោះថា ក្នុងកប្បទី ១ សែនអំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាកត្រកូលនឹងត្រាស់ឡើងក្នុងលោក ។ នាងនេះនឹងបានជាព្រះញាតិក្នុងធម៌ទាំងឡាយនៃព្រះគោតមនោះ ជាឱរសជាធម្មនិម្មិត បានជាសាវិកានៃព្រះសាស្តា មានឈ្មោះថាកិសាគោតមី ។ កាលនោះ ខ្ញុំស្តាប់នូវពុទ្ធព្យាករណ៍នោះ ក៏រីករាយ មានចិត្តប្រកបដោយមេត្តាបានបម្រើព្រះជិនស្រីជានាយកដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយក្នុងភទ្ទកប្បនេះ ។ កាលនោះ ព្រះរាជាក្នុងដែនកាសី ទ្រង់ព្រះនាមកិកី ព្រះអង្គជាធំជាងនរជន ក្នុងក្រុងពារាណសីដ៏ឧត្តម ទ្រង់ជាឧបដ្ឋាកនៃព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ខ្ញុំជាធីតាទី ៥ នៃព្រះរាជានោះ មានឈ្មោះប្រាកដថាធម្មា បាន

ស្តាប់ធម៌ របស់ព្រះពុទ្ធជិនស្រីដ៏ប្រសើរហើយ ពេញចិត្តនឹងផ្នួស ។ ព្រះបិតានៃយើងមិនទ្រង់អនុញ្ញាតឲ្យបួសទេ កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយធម៌ សម្រាប់កុមារីអស់ ២ ម៉ឺន ឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញានៃស្តេចឋិតនៅក្នុងសេចក្តីសុខត្រេកអរ រីករាយក្នុងការបម្រើព្រះពុទ្ធ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកាជាគម្រប់ ៧ ។ ( ព្រះរាជធីតា ៧ អង្គនោះ បេរ-វិលវិលមកបានជា ) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលា ១ ខ្ញុំ ១ ធម្មទិន្នា ១ វិសាខា ជាគម្រប់ ៧ ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផងដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋីដែលជាអ្នកធ្លាក់ខ្លួនកម្សត់ឥតទ្រព្យ ជាត្រកូលទន់ទាបវិញ តែខ្ញុំបានមានប្តីត្រកូលសម្បូណ៌ ដោយទ្រព្យសម្បត្តិ ។ ជនទាំងឡាយដ៏សេសវៀរលែងតែប្តីរបស់ខ្ញុំចេញ សុទ្ធតែជាអ្នកឥតទ្រព្យ ខ្ញុំប្រសូតកូនក្នុងកាលណា ជនទាំងពួងក៏អាណិតខ្ញុំក្នុងកាលនោះ ។ កាលណាកូនខ្ញីរបស់ខ្ញុំនោះ ជាកុមារតូច ឋិតនៅក្នុងសេចក្តីសុខ ជាទីស្រឡាញ់របស់ខ្ញុំ

ដូចជាជីវិតរបស់ខ្លួន កាលនោះកូននោះ ក៏លុះអំណាចនៃសេចក្តីស្លាប់ទៅ ។ ខ្ញុំមានសេចក្តីសោកគ្របសង្កត់ មានមុខប្រកបដោយសេចក្តីទុក្ខ មានភ្នែកពេញដោយទឹកភ្នែក មានមាត់យំ ពរសាកសពដែលស្លាប់នោះដើរយំត្អូញត្អែរ ។ កាលនោះ ខ្ញុំបានជួបបុរសម្នាក់ ក៏ចូលទៅរកព្រះពុទ្ធជាគ្រូពេទ្យដ៏ប្រសើរ ហើយពោលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គឲ្យថ្នាំប្រោសកូនឲ្យរស់ ។ ព្រះជិនស្រី ព្រះអង្គជាអ្នកឈ្លាសវៃក្នុងឧបាយនៃការទូន្មានទ្រង់ត្រាស់ថា ជនទាំងឡាយដែលស្លាប់ហើយ មិនមានក្នុងផ្ទះណា ចូរនាងយកគ្រាប់ស្ពៃអំពីផ្ទះនោះមក ( ឲ្យតថាគត ) ។ កាលនោះ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី រកមិនបានផ្ទះប្រាកដដូច្នោះ ព្រោះហេតុនោះ នឹងរកគ្រាប់ស្ពៃអំពីផ្ទះណាបាន លំដាប់នោះ ខ្ញុំក៏បាននូវស្មារតីឡើង ។ ខ្ញុំបោលនូវសាកសព ហើយចូលទៅគាល់ព្រះពុទ្ធជាលោកនាយក ចំណែកខាងព្រះអង្គមានសំឡេងពីរោះ ទ្រង់ទតឃើញខ្ញុំអំពីចម្ងាយ ហើយត្រាស់ថា បុគ្គលណា កាលមិនបានឃើញនូវការកើតនិងការសូន្យទៅ ( នៃបញ្ចក្ខន្ធ ) ទេ ហើយរស់នៅ ១០០ ឆ្នាំក៏ដោយ ជីវិតរបស់បុគ្គល អ្នកឃើញនូវការកើតឡើងនិងការសូន្យទៅ ( នៃបញ្ចក្ខន្ធ ) សូម្បីរស់នៅតែ ១ ថ្ងៃ ក៏ប្រសើរជាង ។

អនិច្ចតាធម៌នេះ នឹងជាជាធម៌សម្រាប់ស្រុក ១ ក៏ទេ ជាធម៌សម្រាប់និគម ១ ក៏ទេ ជាធម៌សម្រាប់ត្រកូល ១ ក៏ទេ ធម៌នុ៎ះឯងសម្រាប់លោក ព្រមទាំងទេវលោកទាំងអស់ ។

ខ្ញុំនោះ បានស្តាប់នូវគាថាទាំងឡាយនេះហើយ ជម្រះនូវធម្មចក្ខុ គឺសោតាបត្តិមគ្គ លំដាប់នោះ ខ្ញុំក៏ដឹងច្បាស់នូវព្រះសទ្ធម្ម ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសរួចហើយ ក៏មានចិត្តស្ងប់ ប្រកបក្នុងសាសនាព្រះជិនស្រី អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចនូវព្រះអរហត្ត ។ ខ្ញុំជាអ្នកធ្វើនូវសាសនានៃព្រះសាស្តា ស្អាត់ក្នុងឫទ្ធិទាំងឡាយ ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំក៏បានជម្រះហើយ ខ្ញុំបានញុំាងអាសវៈទាំងពួងឲ្យអស់ទៅ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលសោះឡើយ ។ ព្រះសាស្តាខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាដែលជាគ្រឿងនាំសត្វទៅកាន់ភពខ្ញុំគាស់រំលើងចោលហើយ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ណា ប្រយោជន៍នោះគឺកិរិយាអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានសម្រេចហើយ ។ ញាណរបស់ខ្ញុំដ៏ធំទូលាយស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ព្រោះអំណាចនៃព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំនាំសំ-

ពត់ អំពីគំនរសំរាមផង អំពីព្រៃស្មសានផង អំពីប្រកផង ហើយធ្វើជាសង្ឃាដីទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ព្រះជិនស្រី ជានាយក ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំ គឺការទ្រទ្រង់នូវចីវរ ដ៏សៅហ្មងនោះ បានតាំងខ្ញុំក្នុងទីជាឯតទគ្គ ក្នុងពួកបរិស័ទ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

## អដ្ឋកថាកិសាគោតមីថេរីគាថា ចប់

## ឯកាទសកនិបាត ចប់

# ថេរីគាថា ទ្វាទសកនិបាត

## ឧប្បលវណ្ណាថេរីគាថា

[ ៣២៩ ] យើងទាំងពីរនាក់គឺមាតានិងធីតាមានប្តីជាមួយគ្នា ( ភរិយារួមប្តី ) សេចក្តីតក់ស្លុត សេចក្តីព្រឺរោមអស្ចារ្យចម្លែកកើតមានដល់ខ្ញុំនោះ ។ ថ្វីយ កាមទាំងឡាយ ជារបស់មិនស្អាត មានក្លិនអាក្រក់ ដូចជាបន្លាច្រើន យ៉ាងដែលនាំយើងទាំងពីរនាក់ គឺមាតានិងធីតា ឲ្យជាភរិយាជាមួយគ្នា ។ លុះខ្ញុំឃើញទោសក្នុងកាមទាំងឡាយហើយ ឃើញនេក្ខម្មៈថាជារបស់ក្សេម ទើបចេញចាកផ្ទះក្នុងក្រុងរាជគ្រឹះ ចូលកាន់ផ្នួស ។ ខ្ញុំដឹងនូវបុព្វេនិវាស ឯទិព្វចក្ខុនិងចេតោបរិយញ្ញាណ ខ្ញុំជម្រះហើយ ទិព្វសោតធាតុ ខ្ញុំជម្រះហើយដែរ ។ ទាំងឫទ្ធិខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ទៅនៃអាសវៈ ខ្ញុំបានដល់ហើយ អភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ ខ្ញុំនិម្មិតនូវរថទឹមសេះ ៤ ដោយឫទ្ធិ ហើយថ្វាយ បង្គំព្រះបាទទាំងគូនៃព្រះពុទ្ធដ៏មានសិរី ជាទីពឹងនៃសត្វលោក ។

នាងជាស្រីម្នាក់ឯងចូលមកកាន់ដើមរាំងភ្នំ ដែលនៅចុងមានផ្ការីកស្គុសស្គាយ ហើយឈរនៅទៀបគល់ឈើ បុគ្គលណាមួយជាគម្រប់ពីររបស់នាងក៏មិនមាន នែស្ត្រីពាល នាងមិនខ្លាចពួកអ្នកលេងទេឬ ។

បើទុកជាអ្នកលេងទាំងឡាយមួយរយឬមួយពាន់ ជាបុគ្គលមានសភាពយ៉ាងនេះ មកជួបជុំគ្នា ក៏រោម ( របស់យើង ) មិនព្រឺព្រួច មិនញាប់ញ័រ នែមារ អ្នកម្នាក់ឯងនឹងធ្វើនូវអ្វីដល់យើងកើត ។ យើងនេះនឹងបាត់ទៅ ឬនឹង

ចូលទៅកាន់ផ្ទៃរបស់អ្នកក៏បាន ឬបើទុកជាឈរនៅក្បែរចន្លោះចិញ្ចើមរបស់អ្នក ក៏អ្នកមើលមិនឃើញយើងឈរដែរ ។ យើងជាស្ត្រីស្ទាត់ក្នុងអធិចិត្ត ឥទ្ធិបាទទាំងឡាយយើងបានចម្រើនហើយដោយប្រពៃ អភិញ្ញា ៦ យើងបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនាយើងបានធ្វើហើយ កាមទាំងឡាយប្រៀបដោយលំពែងនិងឈើស្រួចសម្រាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកពោលនូវតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ មិនមែនជាតម្រេករបស់យើងឡើយ ។ សេចក្តីរីករាយក្នុងកាមទាំងអស់ យើងបានកម្ចាត់ចេញហើយ គំនរនៃងងឹត ( អវិជ្ជា ) យើងបានទម្លាយចោលហើយ នៃមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ នៃមារថោកទាប អ្នកយើងកម្ចាត់ចេញហើយ ។

ឧប្បលវណ្ណាថេរី ។

ចប់ ទ្វាទសកនិបាត ។

# អដ្ឋកថា

# ថេរីគាថា ទ្វាទសកនិបាត

## ឧប្បលវណ្ណាថេរីគាថា

[ ៣២៩ ] ក្នុងទ្វាទសកនិបាត គាថារបស់ព្រះនាងឧប្បលវណ្ណាថេរីមានពាក្យផ្ដើមថា **ឧភោ មាតា ច ធីតា ច** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក្នុងសាសនាព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ កើតក្នុងផ្ទះមានត្រកូលក្នុងក្រុងហង្សវតី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ចូលគាល់ព្រះសាស្ដាជាមួយនឹងមហាជនស្ដាប់ធម៌ ឃើញព្រះសាស្ដាស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុនីទាំងឡាយ ខាងមានឫទ្ធិ ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ប្រាថ្នាតំណែងនោះ នាងធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងសាសនាព្រះកស្សបសម្ពុទ្ធ ក៏បដិសន្ធិក្នុងរាជវាំងរបស់ព្រះបាទកាសី ព្រះនាមកិកិ នៅក្នុងនគរពារាណសី ជារាជធីតាមួយអង្គក្នុងចំណោមបងប្អូនស្រីទាំង ៧ អង្គ ព្រះនាងប្រព្រឹត្តព្រហ្មចរិយៈអស់ពីរម៉ឺនឆ្នាំ សាងបរិវេណថ្វាយភិក្ខុសង្ឃហើយកើតក្នុងទេវលោក ។

កាលចុតិអំពីទេវលោកនោះហើយ ត្រឡប់មកកាន់មនុស្សលោកវិញ កើតក្នុងផ្ទះរបស់អ្នកធ្វើការងារដោយដៃចិញ្ចឹមជីវិត ក្នុងតំបន់មួយ ។ ថ្ងៃមួយកំពុងដើរទៅកាន់ខ្ទមស្រែ ក្នុងចន្លោះផ្លូវ ឃើញផ្កាឈូករីកអំពីព្រលឹម ក្នុងស្រះមួយ ក៏ចុះកាន់ស្រះនោះ បេះផ្កាឈូកនោះនិងស្លឹកឈូកសម្រាប់ដាក់

លាជ ក្តិចស្រូវសាលីអំពីស្រែមក អង្គុយក្នុងខ្ទម លីងស្រូវធ្វើជាលាជរើស លាជ ៥០០ គ្រាប់ទុក ។ ខណៈនោះ នៅឯភ្នំគន្ធមាទន៍ ព្រះបច្ចេកពុទ្ធមួយអង្គ ចេញអំពីនិរោធសមាបត្តិ មកឈរក្នុងទីមិនឆ្ងាយ នាងឃើញព្រះបច្ចេកពុទ្ធហើយ ក៏កាន់យកផ្កាឈូកមួយអន្ទើដោយលាជ ចេញអំពីខ្ទម ដាក់លាជក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ យកផ្កាឈូកបិទបាត្រ ហើយប្រគេន ។ ខណៈនោះ កាលព្រះបច្ចេកពុទ្ធនិមន្តទៅបានបន្តិច នាងក៏គិតថា ធម្មតាអ្នកបួស មិនត្រូវការផ្កា អញនឹងទៅកាន់យកផ្កាមកប្រដាប់ខ្លួនឯង ទើបទៅកាន់យកផ្កាអំពីដៃរបស់ព្រះបច្ចេកពុទ្ធ ហើយក៏គិតទៀតថា បើលោកម្ចាស់មិនត្រូវការផ្កា គង់មិនឲ្យដាក់លើបាត្រ លោកម្ចាស់គង់នឹងត្រូវការពិត ទើបយកផ្កានោះទៅដាក់លើបាត្រម្តងទៀត សូមខមាទោសព្រះបច្ចេកពុទ្ធហើយ ធ្វើសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ដោយផលនៃលាជរបស់ខ្ញុំនេះ សូមបុត្ររបស់ខ្ញុំមានចំនួនស្មើនឹងគ្រាប់លាជ ដោយផលនៃផ្កាឈូក សូមផ្កាឈូកផុសឡើងគ្រប់ ជំហានក្នុងទីដែលខ្ញុំកើតហើយ ព្រះបច្ចេកពុទ្ធហោះទៅកាន់ភ្នំគន្ធមាទន៍ទាំងដែលនាងកំពុងឃើញនោះឯង ដាក់ផ្កាឈូកជាគ្រឿងជូតជើងក្បែរជណ្តើររបស់ព្រះបច្ចេកពុទ្ធទាំងឡាយក្នុងញកភ្នំនន្ទមូលកៈ ។

ដោយផលនៃកម្មនោះ នាងបដិសន្ធិក្នុងទេវលោក តាំងពីនាងកើត ផ្កាឈូកធំ ក៏ផុសឡើងគ្រប់ជំហានរបស់នាង នាងចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្កាឈូក ក្នុងស្រះឈូកមួយកន្លែង ក្បែរជើងភ្នំ តាបសមួយអង្គនៅអាស្រ័យក្បែរជើងភ្នំនោះ បានទៅកាន់ស្រះអំពីព្រលឹមដើម្បីលុបមុខ ឃើញ

ផ្កាឈូកនោះ ក៏គិតថា ផ្កាឈូកនេះធំជាងផ្កាដទៃ ផ្កាឈូកដទៃៗរីកហើយ ផ្កាឈូកនេះនៅតែក្រពុំ ប្រហែលជាមានហេតុ ក្នុងផ្កាឈូកនេះ ទើបចុះទឹកចាប់ផ្កាឈូកនោះ ផ្កាឈូកនោះ គ្រាន់តែតាបសចាប់ប៉ុណ្ណោះក៏រីក តាបសឃើញទារិកាដេកក្នុងផ្កាឈូក គ្រាន់តែបានឃើញ ក៏កើតសេចក្ដីស្រឡាញ់ដូចកូនស្រី នាំទៅកាន់បណ្ណសាលាមួយអន្លើដោយផ្កាឈូក ដាក់ឲ្យដេកលើគ្រែលំដាប់នោះទឹកដោះក៏កើតត្រង់ម្រាមមេដៃដោយអានុភាពរបស់នាង កាលផ្កាឈូកនោះស្វិត តាបស ក៏នាំយកផ្កាឈូកដទៃមកដាក់ឲ្យទារិកានោះដេក តាំងពីនាងចេះរត់ទៅមកបាន ផ្កាឈូកក៏ផុសឡើងគ្រប់ៗជំហាន ។ ពណ៌សម្បុរនៃសរីរៈរបស់នាងមានពណ៌ដូចផ្កាឈូក តែមិនដល់ពណ៌ សម្បុររបស់ទេវតា តែក្រៃលែងជាងពណ៌សម្បុររបស់មនុស្ស ។ កាលឥសី បិតាទៅរកផលាផល ក៏ទុកនាងឲ្យនៅក្នុងបណ្ណសាលា ។

កាលនាងចម្រើនវ័យហើយ សម័យថ្ងៃមួយ កាលបិតាទៅស្វែងរកផលាផល ព្រានព្រៃម្នាក់ឃើញនាងហើយគិតថា ឈ្មោះថាមនុស្សទាំងឡាយមានរូបយ៉ាងនេះមិនមានឡើយ ដូច្នោះ អាត្មាអញនឹងសាកល្បងនាង ទើបអង្គុយរង់ចាំតាបសត្រឡប់មក ។ កាលបិតាត្រឡប់ នាងក៏ដើរប្រាសផ្លូវទៅទទួលអម្រែកនិងកំសៀវទឹកអំពីដៃបិតា កាលបិតាអង្គុយហើយ ក៏សម្ដែងទំនៀមគឺកិច្ចដែលខ្លួនធ្លាប់ធ្វើ ។ កាលនោះ ព្រានព្រៃដឹងថាទារិកាជាមនុស្ស ទើបអង្គុយសំពះតាបស តាបសអញ្ជើញ ព្រានព្រៃនោះដោយមើមឈើ និងផ្លែឈើមួយអន្លើដោយទឹកផឹក ហើយសួរថា នែបា អ្នកស្នាក់នៅទីនេះ ឬ

ត្រឡប់ទៅ ព្រានឆ្លើយថា ខ្ញុំនឹងទៅ ប្រយោជន៍អ្វីដោយការនៅទីនេះ ។ តាបសពោលថា ហេតុការណ៍ដែលអ្នកឃើញហើយនេះ អ្នកកុំពោលក្នុងទីដែលអ្នកទៅហើយ ព្រានតបថា បើលោកម្ចាស់មិនប្រាថ្នា ខ្ញុំនឹងពោលធ្វើអ្វី ថ្វាយបង្គំតាបស ធ្វើគ្រឿងសម្គាល់ត្រង់មែកឈើនិងដើមឈើ ដោយអាការល្មមចំណាំផ្លូវបាន ហើយត្រឡប់ទៅ ។

ព្រានព្រៃនោះ ទៅកាន់ក្រុងពារាណសី ហើយគាល់ព្រះរាជា ព្រះរាជាត្រាស់សួរថា អ្នកមកធ្វើអ្វី ព្រានព្រៃក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជាព្រានព្រៃរបស់ព្រះអង្គ ជួបនារីរត្នដ៏អស្ចារ្យក្បែរជើងភ្នំ ទើបមកគាល់រួចទូលថ្វាយរឿងរ៉ាវសព្វអន្លើ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យ របស់ព្រានព្រៃហើយ ក៏ប្រញាប់យាងទៅកាន់ជើងភ្នំ បោះព្រះពន្លាក្នុងទីមិនឆ្ងាយ មួយអន្លើដោយព្រានព្រៃ និងពួកទាហាន យាងទៅកាន់បណ្ណសាលានោះ ក្នុងពេលដែលតាបសឆាន់ស្រេចហើយអង្គុយសម្រាក ទ្រង់ថ្វាយបង្គំ ទ្រង់ធ្វើបដិសណ្ឋារៈ ហើយប្រថាប់គង់ក្នុងទីសមគួរទាចំណែកម្ខាង ព្រះរាជាទ្រង់ដាក់គ្រឿងបរិក្ខារសម្រាប់បព្វជិតទៀបបាទារបស់តាបស ត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងធ្វើអ្វីខ្លះក្នុងទីនេះ ហើយក៏នឹងទៅ ។ តាបសថ្វាយព្រះពរថា សូមទ្រង់មានបន្ទូលមកចុះ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ បានឮមកថា បរិស័ទដែលជាសត្រូវមាននៅក្បែរលោកម្ចាស់ បរិស័ទនោះមិនគួរដល់បព្វជិត បរិស័ទនោះ សូមទៅជាមួយខ្ញុំចុះ តាបសទូលថា ចិត្តរបស់មនុស្សធ្វើឲ្យពេញចិត្តបានលំបាក តើកូនស្រីខ្ញុំ នៅត្រង់កណ្តាលពួកមនុស្ស

ជាច្រើនបានដូចម្ដេច ព្រះរាជាត្រាស់ថា តាំងពីខ្ញុំពេញចិត្តនាង ខ្ញុំអាចតាំងនាងទុកក្នុងតំណែងខ្ពង់ខ្ពស់ជាងស្រីដទៃ ហើយទំនុកបម្រុង ។

តាបសស្ដាប់ព្រះរាជតម្រាស់ ទើបហៅធីតាតាមនាមដែលតាំងទុក គ្រានៅជាទារិកាថា បទុមវតី ដោយការហៅត្រឹមតែម្ដងប៉ុណ្ណោះ នាងក៏ចេញអំពីបណ្ណសាលា មកឈរថ្វាយបង្គំឪពុក ខណៈនោះ តាបសពោលថា នែកូននាងធំពេញវ័យហើយ តាំងពីព្រះរាជាទ្រង់ឃើញ នាងនៅក្នុងទីនេះ មិនមានផាសុកឡើយ ចូរទៅតាមព្រះរាជាចុះ ។ នាងទទួលពាក្យឪពុកថា សាធុ ថ្វាយបង្គំហើយ ឈរយំ ។ ព្រះរាជាត្រាស់ថា ខ្ញុំនឹងចងចិត្តបិតារបស់នាង ទ្រង់ដាក់គំនរកហាបណៈក្នុងទីនោះឯង ហើយទ្រង់ធ្វើការអភិសេក ។ ព្រះ-រាជាទ្រង់នាំនាងទៅកាន់ព្រះនគររបស់ព្រះអង្គ រាប់តាំងអំពីនាងមកដល់ ក៏មិនបានដាក់ចិត្តក្នុងស្រីដទៃ ទ្រង់ស្រឡាញ់តែនាង ស្រីទាំងនោះ ជាអ្នកមានប្រក្រតីច្រណែន បំណងនឹងធ្វើនាងឲ្យបែកអំពីព្រះរាជា ទើបនាំគ្នាពិតទូលយ៉ាងនេះថា បពិត្រព្រះអង្គ ស្រីនេះមិនមែនមនុស្សទេ ទ្រង់ធ្លាប់ទតឃើញផ្កាឈូកផុសឡើងត្រង់ទីដែលមនុស្សដើរទៅមក ក្នុងទីណាដែរឬទេ ស្រីនេះជាយក្ខិនីពិត សូមទ្រង់និរទេសនាងចោលចុះ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យស្រីទាំងនោះ ទ្រង់ក៏នៅស្ងៀម ។ ក្នុងកាលតមក ជាយដែនរបស់ព្រះអង្គកើតនូវការបះបោរ ទ្រង់ព្រះតម្រិះថា បទុមវតីមានគភ៌ចាស់ខែ ទើបទ្រង់ទុកនាងក្នុងព្រះនគរ ហើយយាងទៅកាន់ជាយដែន ។ កាលនោះ ស្ត្រីទាំងនោះឲ្យសំណូកដល់ទាសីដែលប្រណិប័តន៍នាង ប្រាប់ថា បើទារករបស់នាងប្រសូត

មក ចូរនាងនាំយកទៅបោះចោល ហើយយកឈាមលាបកំណាត់ឈើមួយ ដាក់ក្បែរនោះ ។ មិនយូរប៉ុន្មាន ព្រះនាងបទុមវតី ក៏ប្រសូត ។ ព្រះមហាបទុមកុមារមួយអង្គប៉ុណ្ណោះ បដិសន្ធិក្នុងព្រះឧទរ ព្រះរាជកុមារ ៤៩៩ អង្គដទៃទៀតកើតក្នុងសំសេទជកំណើត (កើតអំពីញើស) ក្នុងពេលដែលមហាបទុមកុមារប្រសូតចាកផ្ទៃរបស់មាតា ហើយដេក ខណៈនោះស្រីអ្នកបម្រើរបស់ព្រះនាងដឹងថា ព្រះនាងមិនទាន់ដឹងខ្លួន ក៏យកឈាមលាបកំណាត់ឈើមួយហើយដាក់ក្បែរនោះ ឲ្យសញ្ញាដល់ស្ត្រីទាំងនោះ ។ ស្ត្រី ៥០០ ក៏នាំយកព្រះរាជកុមារម្នាក់មួយអង្គៗ ទៅកាន់សម្នាក់ជាងក្រឡឹង ឲ្យនាំជន្ទាប់មកដាក់ព្រះរាជកុមារឲ្យផ្ទំក្នុងជន្ទាប់នោះប្រថាប់ត្រា ។

ឯនាងបទុមវតី ដឹងខ្លួនហើយ សួរទាសីថា ខ្ញុំប្រសូតហើយឬ ស្រីអ្នកបម្រើនិយាយគំហកថា ព្រះនាងបានទារកមកអំពីណា ដាក់កំណាត់ឈើដែលមានឈាមក្នុងទីចំពោះព្រះភក្ត្រ ទូលថា នេះជាទារកដែលប្រសូតចាកផ្ទៃនៃព្រះនាង ព្រះនាងទតឃើញកំណាត់ឈើនោះ ក៏ទោមនស្ស ឲ្យពុះកំណាត់ឈើនោះដោយរហ័ស ហើយត្រាស់ថា ចូរនាងនាំចេញទៅបើអ្នកណាឃើញក៏នឹងខ្មាសគេ ។ ស្រីបម្រើនោះទទួលព្រះរាជសវនីយ៍ហើយ ធ្វើដូចជាបំណងល្អ ក៏នាំកំណាត់ឈើយកទៅដាក់ក្នុងជើងក្រាន ។

ឯព្រះរាជាយាងត្រឡប់អំពីជាយដែន ទ្រង់រាប់អានឫក្សនិងយាម ត្រាស់ឲ្យបោះព្រះពន្លា ប្រថាប់ខាងក្រៅព្រះនគរ ។ ខណៈនោះ ស្រីទាំងនោះ នាំគ្នាចេញទៅទទួលព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់មិនជឿពួកខ្ញុំ

ម្ចាស់ ពាក្យដែលពួកខ្ញុំម្ចាស់ក្រាបទូល មិនមែនជារឿងសំខាន់ សូមទ្រង់ហៅអ្នកបម្រើរបស់ព្រះមហេសីមកសាកសួរចុះ ព្រះទេវីរបស់ព្រះអង្គប្រសូតដុំឈើ ព្រះរាជាទ្រង់មិនទាន់ពិចារណាហេតុការណ៍នោះ គិតថា ស្រីនេះមិនមែនមនុស្សពិត ទើបទ្រង់បណ្តេញព្រះនាងចេញអំពីព្រះរាជវាំង ដំណាលគ្មានទីងការយោងចេញអំពីព្រះរាជវាំង ផ្កាឈូកក៏អន្តរធានទៅ សូម្បីតែពណ៌សម្បុរនៃព្រះសរីរៈ ក៏ស្រអាប់ទៅ ។ ព្រះនាងតែមួយព្រះអង្គឯងយាងទៅតាមវិថី ខណៈនោះ ស្រីជរាម្នាក់ឃើញហើយ ក៏កើតសេចក្តីស្រឡាញ់ដូចជាកូនស្រីរបស់ខ្លួន ទើបសួរថា នែកូន នាងទៅណាមកណា ព្រះនាងត្រាស់តបថា ខ្ញុំជាអ្នកដំណើរ កំពុងស្វែងរកទីលំនៅ ស្រីជរាពោលថា មកកូន ហើយនាំនាងទៅកាន់លំនៅ រៀបចំអាហារផ្គត់ផ្គង់ ។

កាលព្រះនាងគង់នៅក្នុងទីនោះ ដោយទំនងនោះឯង ស្ត្រី ៥០០ ក៏នាំគ្នាក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ កាលទ្រង់បោះពន្ធ ខ្ញុំម្ចាស់ប្រាថ្នាថា កាលទ្រង់ឈ្នះសង្គ្រាម ត្រឡប់មក ពួកខ្ញុំម្ចាស់នឹងធ្វើពលីកម្មបួងសួងលេងឧទកកីឡាថ្វាយដល់គង្គាទេវតា សូមទ្រង់ប្រកាសសេចក្តីនេះផងចុះ ។ ព្រះរាជាទ្រង់ត្រេកអរតាមពាក្យរបស់ស្ត្រីទាំងនោះ ទ្រង់បានយាងទៅដើម្បីលេងឧទកកីឡាក្នុងស្ទឹងគង្គា ។ ស្ត្រីទាំងនោះនាំគ្នាកាន់ជន្ទាប់ដែលបិទជិត ម្នាក់មួយៗ នាំគ្នាទៅកាន់ស្ទឹង យកសំពត់គ្របដើម្បីបិទបាំងជន្ទាប់ទាំងនោះ ចុះក្នុងទឹកបណ្តែតជន្ទាប់ទៅ ។ ជន្ទាប់ទាំងនោះទៅព្រមគ្នា ជាប់ត្រង់សំណាញ់ដែលគេសន្ទឹងក្រោមខ្សែទឹកទាំងអស់ បន្ទាប់អំពីព្រះរាជាទ្រង់ ក្រសាលឧទក

កីឡាស្រេចទ្រង់យានឡើង ពួករាជបុរសឃើញជន្ទាប់ទាំងនោះ ទើបនាំមកថ្វាយព្រះរាជា ។

ព្រះរាជាទ្រង់ទតជន្ទាប់ ត្រាស់សួរថា នែបា អ្វីនៅក្នុងជន្ទាប់ ពួករាជបុរសក្រាបទូលថា មិនដឹងទេ ព្រះអង្គ ។ ព្រះរាជាទ្រង់ត្រាស់ឲ្យបើកជន្ទាប់ទាំងនោះមើល ។ ទ្រង់ឲ្យបើកជន្ទាប់របស់ព្រះមហាបទុមកុមារមុនគេ ។ តាំងពីថ្ងៃដែលគេដាក់ព្រះរាជកុមារគ្រប់អង្គ ក្នុងជន្ទាប់ ទឹកដោះក៏កើតត្រង់មេដៃសម្រាប់ព្រះរាជកុមារគ្រប់អង្គដោយបុញ្ញឫទ្ធិ ។ សក្កទេវរាជត្រាស់ឲ្យចារឹកអក្សរខាងក្នុងជន្ទាប់ ដើម្បីឲ្យព្រះរាជាអស់សេចក្ដីសង្ស័យថា ព្រះកុមារទាំងនោះកើតក្នុងគភ៌របស់ព្រះនាងបទុមវតី ជាព្រះឱរសរបស់ព្រះបាទពារាណសី កាលនោះ ស្ត្រីទាំង ៥០០ ដែលជាសត្រូវរបស់នាងបទុមវតី ដាក់ព្រះរាជកុមារទាំងនោះក្នុងជន្ទាប់ ហើយបោះក្នុងទឹក សូមព្រះរាជា ទ្រង់ជ្រាបហេតុការណ៍នេះ ។ លុះបើកជន្ទាប់ ព្រះរាជាទ្រង់អានអក្ខរា ឃើញព្រះរាជ កុមារទ្រង់លើកព្រះមហាបទុមកុមារឡើង ប្រញាប់ទឹមរថ ត្រាស់ថា ពួកអ្នកចូររៀបចំសេះឲ្យឆាប់ ថ្ងៃនេះនឹងចូលទៅក្នុងព្រះនគរ ហើយធ្វើ ព្រះនាងបទុមវតីឲ្យជាទីស្រឡាញ់របស់ស្រីពួកខ្លះ ហើយឡើងកាន់មហាប្រាសាទ ដាក់នូវថង់ទ្រព្យ ១០០០ កហាបណៈលើកដំរីឲ្យវាយស្គរប្រកាសពេញព្រះនគរថា អ្នកណាឃើញព្រះនាងបទុមវតី អ្នកនោះចូរទទួលទ្រព្យ ១០០០ កហាបណៈនេះ ។

ព្រះនាងបទុមវតីស្ដាប់ពាក្យប្រកាសនោះហើយ បានឲ្យសញ្ញាដល់មាតា

ថា សូមអ្នកម៉ែទទួលថង់ទ្រព្យ ១០០០ កហាបណៈអំពីកដីរ ស្ត្រីចាស់ជរាពោលថា ម៉ែទទួលទ្រព្យបែបនេះមិនបានទេ កាលព្រះនាងប្រាប់អស់វារៈ ២ ដង ៣ ដង ទើបសួរថា នៃកូន ម៉ែពោលដូចម្ដេច ទើបបានទ្រព្យ ព្រះនាងត្រាស់ថា ចូរប្រាប់គេថា កូនស្រីខ្ញុំឃើញព្រះនាងបទុមវតី ហើយទទួលទ្រព្យមក មាតាគិតថា រឿងនេះដូចម្ដេច ហើយទើបចូលទៅទទួលយកថង់ទ្រព្យ ១០០០ កហាបណៈ ។ គ្រានោះ ត្រូវមនុស្សទាំងឡាយសួរថា អ្នកម៉ែ ជួបព្រះនាងបទុមវតីឬ ស្ត្រីចំណាស់ពោលថា ខ្ញុំមិនជួបទេ តែកូនស្រីខ្ញុំជួប ។ មនុស្សទាំងនោះសួរថា កូនស្រីរបស់លោកយាយនៅឯណាហើយក៏ទៅជាមួយ ស្គាល់នាងបទុមវតីក្រាបចុះទៀបបាទាទាំងទ្វេ ពេលនោះ ទើបស្រីចំណាស់ដឹងថា កូនរបស់ខ្លួន គឺព្រះនាងបទុមវតីទេវី ទើបពោលថា ស្រីនេះធ្វើការងារជូនយ៉ាង សូម្បីជាមហេសីរបស់ព្រះរាជា ក៏មករស់នៅមិនមានអ្នករក្សាក្នុងទីមានសភាពដូច្នេះ ។

រាជបុរសទាំងនោះ ធ្វើនូវការសម្អាតទីប្រថាប់របស់ព្រះនាង បទុមវតី ហើយព័ទ្ធដោយវាំងនន រៀបចំការរក្សាត្រង់ទ្វារ ត្រឡប់ទៅក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់បញ្ជូនវមាសមក ។ ព្រះនាងបទុមវតីត្រាស់ថា ខ្ញុំមិនទៅដោយរបៀបយ៉ាងនេះ សូមទ្រង់ឲ្យក្រាលកម្រាលដ៏វិចិត្រ ដោយសំពត់សម្បុកឈើយ៉ាងល្អ តាំងពីលំនៅរបស់ខ្ញុំ រហូតដល់ក្រុងរាជគ្រឹះ ឲ្យបាំងពិតានដោយសំពត់ដែលវិចិត្រដោយផ្កាយមាស អំពីខាងលើ កាលបញ្ជូនគ្រឿងអលង្ការគ្រប់យ៉ាងមកឲ្យ ខ្ញុំប្រដាប់តាក់តែងហើយ នឹងដើរទៅដោយ

ជើង អ្នកនគរនឹងឃើញសម្បត្តិរបស់ខ្ញុំដោយវិធីយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរធ្វើតាមព្រះទ័យរបស់ព្រះនាងបទុមវតីចុះ ។

លំដាប់នោះ ព្រះនាងបទុមវតី ប្រដាប់ដោយគ្រឿងប្រដាប់សព្វយ៉ាងហើយ ព្រះនាងព្រះតម្រិះថា នឹងយាងទៅកាន់ព្រះរាជនិវេសន៍ ក៏ផ្តើមធ្វើដំណើរ ។ គ្រានោះ ផ្កាឈូកទាំងឡាយក៏ផុសជ្រែកកម្រាល ដ៏វិចិត្រដោយសំពត់សម្បកឈើយ៉ាងល្អ ក្នុងទីដែលព្រះនាងឈានជំហានទៅ កាលព្រះនាងសម្តែងនូវសម្បត្តិរបស់នាងដល់មហាជនហើយ យាងឡើងកាន់ព្រះរាជនិវេសន៍ ឲ្យព្រះរាជទានកម្រាលដ៏វិចិត្រទាំងអស់ ដល់ស្រីជរានោះ ជាថ្លៃចិញ្ចឹម ។ ឯព្រះរាជាត្រាស់ឲ្យហៅស្ត្រីទាំង ៥០០ នោះមកហើយ ត្រាស់ថា នែទេវី យើងឲ្យស្ត្រីទាំងនេះជាទាសីរបស់នាង នាងទូលថា សាធុ សូមទ្រង់ប្រកាសក្នុងព្រះនគរថា ព្រះរាជាប្រទានស្រីទាំងនេះ ជាទាសីដល់ខ្ញុំហើយ ។ ព្រះរាជាឲ្យវាយស្គរប្រកាសថា ស្រី ៥០០ ដែលជាសត្រូវរបស់ព្រះនាងបទុមវតី យើងបានឲ្យជាទាសីរបស់ព្រះនាងហើយ ។ ព្រះនាងទ្រង់ជ្រាបថា អ្នកនគរកំណត់ដឹងថា ស្រីទាំងនេះជាទាសីហើយ ទើបទូលសួរព្រះរាជាថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើទាសីរបស់ខ្ញុំម្ចាស់ឲ្យជាអ្នកជា តើបានដែរឬទេ ព្រះរាជាត្រាស់ថា តាមតែទេវីប្រាថ្នាចុះ ទើបក្រាបទូលថា បើដូច្នោះ សូមទ្រង់ឲ្យវាយស្គរប្រកាសម្តងទៀតថា ស្ត្រីទាំង ៥០០ ដែលព្រះរាជាប្រកាសព្រះរាជទានឲ្យធ្វើជាទាសី របស់ព្រះនាងបទុមវតី ព្រះនាងធ្វើឲ្យជាអ្នកជាគ្រប់គ្នាហើយ ។ កាលព្រះនាងធ្វើស្រីទាំងនោះឲ្យជាអ្នកជាហើយ ព្រះនាងក៏

ប្រគល់ព្រះរាជឱរស ៤៩៩ អង្គ ក្នុងដៃស្ត្រីទាំងនោះ ដើម្បីថែរក្សា ព្រះមហាបទុមកុមារមួយអង្គប៉ុណ្ណោះ ព្រះនាងថែរក្សាដោយដៃឯង ។

ក្នុងកាលតមក កាលព្រះរាជកុមារទាំងនោះ ដល់នូវវ័យលេង ព្រះរាជាឲ្យធ្វើទីសម្រាប់លេងច្រើនប្រភេទក្នុងព្រះរាជឧទ្យាន លុះមានវស្សា ១៦ ព្រះរាជកុមារទាំងនោះ ព្រមចិត្តគ្នាថា លេងក្នុងស្រះមង្គលបោក្ខរណី ដែលដេរដាសដោយផ្កាឈូកក្នុងព្រះរាជឧទ្យាន ទតឃើញផ្កាឈូករីកថ្មី និងផ្កាឈូកចាស់ដែលរុះរោយ ទ្រង់ពិចារណាជាអារម្មណ៍ថា ជរាបែបនេះ នឹងមកដល់អនុបាទិន្នកសង្ខារយ៉ាងនេះហ្ន៎ នឹងពោលថ្វីថាជរាមិនមកដល់សរីរៈរបស់ពួកយើង សរីរៈនេះគង់មានគតិយ៉ាងនេះដូចគ្នា ហើយបានសម្រេចនូវបច្ចេកពោធិញ្ញាណគ្រប់អង្គ ទ្រង់ក្រោកឡើងគង់ពត់ភ្នែនលើផ្កាឈូកទាំងឡាយ ។

លំដាប់នោះ ពួករាជបុរសដែលតាមព្រះរាជកុមារ ដឹងថា ពេលថ្ងៃបានកន្លងទៅច្រើនហើយ ទើបទូលថា បពិត្រអយ្យបុត្ត សូមទ្រង់ជ្រាបកាលរបស់ទ្រង់ចុះ ព្រះរាជកុមារទាំងនោះក៏នៅស្ងៀម ។ ពួករាជបុរសក៏ទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារទាំងឡាយគង់លើត្របកឈូក កាលពួកទូលបង្គំទូលសួរក៏មិនមានព្រះវាចាអ្វីឡើយ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរឲ្យព្រះរាជាកុមារទាំងនោះអង្គុយតាមគាប់ចិត្តចុះ ។ ព្រះរាជកុមារទាំងនោះ បានទទួលការរក្សាមួយយប់ទល់ភ្លឺ រហូតដល់ថ្ងៃរះ ក៏នៅតែគង់លើផ្កាឈូកនោះឯង ។ ពួករាជបុរស ចូលគាល់ក្នុងថ្ងៃស្អែក ទូលថា បពិត្រទេវៈ សូមទ្រង់ជ្រាបកាលចុះ ព្រះរាជកុមារទាំងនោះត្រាស់ថា ពួក

អាត្មាមិនមែនជាទេវៈ ពួកអាត្មាឈ្មោះថា បច្ចេកពុទ្ធទេតើ ។ ពួករាជបុរស ទូលថា បពិត្រអយ្យបុត្ត ទ្រង់ត្រាស់ពាក្យធ្ងន់ពេក ធម្មតាព្រះបច្ចេកពុទ្ធ មិនមែនដូចទ្រង់ទេ ព្រះបច្ចេកពុទ្ធទាំងឡាយ ជាអ្នកមានសក់ ពុកមាត់ ពុកចង្កា ២ ធ្នាប់ ទ្រទ្រង់បរិក្ខារ ៨ លើរាងកាយ ។ ព្រះរាជកុមារទាំងនោះយកព្រះហស្តស្ទាំអង្អែលសីសៈ រំពេចនោះឯង ភេទគ្រហស្ថក៏បាត់ទៅ បរិក្ខារ ៨ ក៏មកប្រដាប់ត្រង់កាយ ហោះទៅកាន់ញកភ្នំនន្ទមូលកៈ ទាំងមហាជនកំពុងឃើញនោះឯង ។

ឯព្រះនាងបទុមវតីទេវី ទ្រង់សោកសង្រេងថា អាត្មាអញមានកូនច្រើន ក៏ក្លាយជាមនុស្សឥតកូនដោយសេចក្តីសោកនោះឯង ក៏សោយព្រះទិវង្គតក្នុងព្រះវិហារនោះ ទៅកើតក្នុងផ្ទះរបស់អ្នកធ្វើការដោយដៃចិញ្ចឹមជីវិត ក្នុងភូមិមួយកន្លែង ក្បែរទ្វារនគររាជគ្រឹះ មានប្តីហើយ ថ្ងៃមួយ ទូលបបរទៅស្រែឲ្យប្តី ឃើញព្រះ-បច្ចេកពុទ្ធ ៨ អង្គ ក្នុងចំនួនបុត្តរបស់ខ្លួនឯង កំពុងហោះមកក្នុងពេលភិក្ខាចារ ទើបប្រញាប់ទៅប្រាប់ប្តីថា នែអ្នក មើលព្រះបច្ចេកពុទ្ធចុះ យើងនឹងនិមន្តលោកមកឆាន់ ។ ប្តីពោលថា ធម្មតាសមណៈបក្សីទាំងនេះ ក៏ត្រាច់ទៅក្នុងទីផ្សេងៗយ៉ាងនេះ សមណៈបក្សីទាំងនោះមិនមែនព្រះបច្ចេកពុទ្ធទេ ។ ខណៈដែលជនទាំងពីរកំពុងនិយាយគ្នានោះឯង ព្រះបច្ចេកពុទ្ធទាំងនោះ ក៏ចុះមក ក្នុងទីមិនឆ្ងាយ ។ ស្រីនោះក៏ប្រគេនភោជន គឺបាយនិងសម្លដែលជាចំណែករបស់ខ្លួនក្នុងថ្ងៃនោះដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយនិមន្តថា ស្អែកនេះ សូមលោកម្ចាស់ទាំង ៨ អង្គ មេត្តាទទួលភិក្ខាហាររបស់ខ្ញុំចុះ ។ ព្រះ

បច្ចេកពុទ្ធ ពោលថា សាធុ ឧបាសិកា នាងចូររៀបចំសក្ការៈមានប្រមាណស្មើនឹងថ្ងៃនេះ អាសនៈក៏ចូរមាន ៨ តែបើនាងឃើញព្រះបច្ចេកពុទ្ធដទៃៗមកច្រើន ក៏គប្បីធ្វើចិត្តរបស់នាងឲ្យជ្រះថ្លាចុះ ។ ស្អែកឡើង ស្រីនោះក៏ក្រាលអាសនៈ ៨ រៀបចំនូវគ្រឿងសក្ការៈសម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គហើយអង្គុយរង់ចាំ ។

ព្រះបច្ចេកពុទ្ធដែលបានទទួលនិមន្ត ឲ្យសញ្ញាព្រះបច្ចេកពុទ្ធដទៃៗថាអ្នកនិទ្ទុក្ខទាំងឡាយ ថ្ងៃនេះ អ្នកទាំងឡាយកុំទៅកាន់ទីដទៃ ទាំងអស់គ្នាចូរធ្វើសេចក្តីអនុគ្រោះដល់មាតារបស់លោកចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ស្តាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធ ៨ អង្គនោះហើយ ស្រុះស្រួលគ្នាគ្រប់អង្គ ហោះទៅប្រាកដក្បែរទ្វារផ្ទះរបស់មាតា ។ នាងឃើញព្រះបច្ចេកពុទ្ធច្រើនអង្គ មិនញាប់ញ័រ ព្រោះបានសញ្ញាអំពីមុនហើយ និមន្តព្រះបច្ចេកពុទ្ធទាំងនោះចូលកាន់ផ្ទះឲ្យគង់លើអាសនៈ កាលព្រះបច្ចេកពុទ្ធទាំងនោះគង់តាមលំដាប់ អង្គទី ៩ ក៏និម្មិតអាសនៈ ៨ ខ្លួនឯងក៏អង្គុយអាសនៈក្បែរផ្ទះ ផ្ទះក៏ធំប៉ុននឹងចំនួនអាសនៈដែលបន្ថែមឡើង កាលព្រះបច្ចេកពុទ្ធទាំងឡាយអង្គុយ រៀបរយយ៉ាងនេះ ស្រីនោះក៏ថ្វាយសក្ការៈដែលខ្លួនរៀបចំ សម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គរហូតគ្រប់គ្រាន់ដល់ព្រះបច្ចេពុទ្ធ ៥០០ ហើយនាំយកផ្កាឈូក ៨ ក្តាប់ដាក់ទៀបបាទជើងព្រះបច្ចេកពុទ្ធដែលខ្លួននិមន្តមកប៉ុណ្ណោះ តាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ សូមពណ៌សម្បុរនៃសរីរៈ របស់ខ្ញុំ ដូចពណ៌សម្បុរខាងក្នុងនៃផ្កាឈូកនេះ ក្នុងទីដែលខ្ញុំកើតហើយនោះឯង ព្រះបច្ចេកពុទ្ធទាំង

ឡាយធ្វើអនុមោទនាដល់មាតាហើយ នាំគ្នាទៅកាន់ភ្នំគន្ធមាទន៍ ។

កុលធីតានោះ ធ្វើកុសលដរាបដល់អស់ជីវិតចុតិអំពីមនុស្សលោកហើយ កើតក្នុងទេវលោក ។ ក្នុងពុទ្ធុប្បាទនេះ បដិសន្ធិក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី មាតាបិតាដាក់ឈ្មោះថា ឧប្បលវណ្ណា ព្រោះមានពណ៌សម្បុរដូចពណ៌នៃផ្កាឧប្បល ។ សម័យនោះ ក្នុងកាលដែលនាងពេញវ័យហើយ ព្រះរាជានិងសេដ្ឋីទាំងឡាយ ក្នុងជម្ពូទ្វីប នាំគ្នាបញ្ជូនទូតទៅកាន់សម្នាក់សេដ្ឋីថា សូមឲ្យធីតាដល់ខ្ញុំចុះ ព្រះរាជាដែលឈ្មោះថាមិនបញ្ជូនទូតទៅមិនមានឡើយ ដូច្នោះសេដ្ឋីក៏គិតថា អញមិនអាចតម្រូវចិត្តព្រះរាជាទាំងអស់បាន អញនឹងធ្វើឧបាយមួយ ដូច្នេះហើយទើបហៅធីតាមកសួរថា នែកូន តើនាងបួសឬ ។ ពាក្យរបស់បិតា ប្រៀបដូចជាប្រេង ដែលគេចម្រាញ់ហើយអស់មួយរយដងស្រោចលើសីសៈ ព្រោះជាកពចុងក្រោយ ព្រោះហេតុនោះ ទើបនាងឆ្លើយនឹងបិតាថា កូននឹងបួស ។ សេដ្ឋីនោះក៏ធ្វើសក្ការៈដល់កូន នាំទៅកាន់សម្នាក់ភិក្ខុនី ហើយឲ្យបួស កាលនាងបួសមិនយូរប៉ុន្មាន វារៈតាមកាល គឺវេនក្នុងរោងឧបោសថក៏មកដល់ នាងអុជប្រទីបហើយ បោសរោងឧបោសថ កាន់យកនិមិត្តនៃអណ្តាតប្រទីប ពិចារណាមើលរឿយៗ ធ្វើឈានដែលមានតេជោកសិណជាអារម្មណ៍ឲ្យកើតឡើង ធ្វើឈាននោះឯងឲ្យជាបាទ សម្រេចអរហត្តមួយអន្លើដោយអភិញ្ញានិងបដិសម្ភិទា ក៏កើតជំណាលគ្នានឹងអរហត្តនោះឯងក្រៃលែងជាងនោះ នាងក៏ជាអ្នកជំនាញក្នុងការនិម្មិតកាយ ដោយឫទ្ធិទៀតផងសមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ឧប្បលវណ្ណាភិក្ខុនី ដល់នូវត្រើយនៃឫទ្ធិ បានថ្វាយបង្គំព្រះបាទាព្រះសាស្តា ហើយពោលនូវពាក្យនេះថា បពិត្រព្រះមហាមុនីខ្ញុំម្ចាស់ចូងផុតនូវជាតិសង្សារហើយ ដល់នូវព្រះនិព្វានជាទីមិនកម្រើក ខ្ញុំម្ចាស់សូមក្រាបទូលនូវទុក្ខទាំងពួង របស់ខ្ញុំម្ចាស់ដែលអស់ហើយ ។ ពួកបរិស័ទទាំងប៉ុន្មាន ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី កំហុសរបស់ខ្ញុំម្ចាស់ មានចំពោះពួកជនណា សូមពួកជននោះអត់ទោសក្នុងទីចំពោះព្រះភក្ត្រនៃព្រះជិនស្រីឲ្យទាន ។ បពិត្រព្រះអង្គ ជាមហាវីរបុរស ខ្ញុំម្ចាស់កំពុងអន្ទោលទៅក្នុងសង្សារ បើខ្ញុំម្ចាស់មានសេចក្តីភ្ញាត់ភ្លាំងខ្ញុំម្ចាស់សូមអង្វរ សូមព្រះអង្គអត់ ទោសចំពោះកំហុសនៃខ្ញុំម្ចាស់នោះ ។ ម្នាលនាងអ្នកធ្វើតាមសាសនារបស់តថាគតបើដូច្នោះ ចូរនាងសម្តែងនូវឫទ្ធិចុះ ចូរនាងញ៉ាំងបរិស័ទទាំង ៤ ឲ្យកាត់នូវសេចក្តីសង្ស័យទាំងប៉ុន្មាន ក្នុងថ្ងៃនេះចុះ ។ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿង ខ្ញុំម្ចាស់ជាធីតារបស់ព្រះអង្គ ចំណែកខាងអំពើដ៏ច្រើនដែលគេកម្រធ្វើបាន ខ្ញុំព្រះអង្គ បានធ្វើឲ្យជាអំពើរឹតតែកម្រក្រៃលែង ។ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញាចក្ខុសម្បុររបស់ខ្ញុំម្ចាស់ដូចជាសម្បុរនៃផ្កាឧប្បលខ្ញុំម្ចាស់ មានឈ្មោះថាឧប្បលវណ្ណា ជាធីតារបស់ព្រះអង្គ សូមថ្វាយបង្គំ

ព្រះបាទា ។ ព្រះរាហុលត្ថេរនឹងខ្ញុំម្ចាស់ ធ្លាប់កើតក្នុងភពតែមួយអស់រយនៃជាតិជាច្រើន ជាអ្នកមានចិត្តនឹងធនូរៈស្មើគ្នា ។ ការកើតឡើងក្នុងទីជាមួយគ្នាក៏មាន ក្នុងជាតិជាមួយគ្នាក៏មាន លុះដល់បច្ឆិមភព ជនទាំងពីរនាក់កើតដោយឈ្មោះ ( ផ្សេងគ្នា ) ។ ព្រះរាជបុត្តបានមកជាកុមារឈ្មោះរាហុល ខ្ញុំម្ចាស់បានមកជាធីតាឈ្មោះឧប្បលវណ្ណា បពិត្រព្រះអង្គជាវីរបុរស សូមព្រះអង្គទតឫទ្ធិនៃខ្ញុំម្ចាស់ចុះខ្ញុំម្ចាស់នឹងសម្តែងកម្លាំងថ្វាយព្រះសាស្តា ។ នាងឧប្បលវណ្ណា ដាក់មហាសមុទ្រទាំង ៤ លើផ្ទៃបាតដៃ ហាក់ដូចកូនក្មេងលេងប្រេង ដែលតាំងនៅលើបាតដៃ ។ នាងឧប្បលវណ្ណាគ្ដីរផែនដីដាក់លើផ្ទៃបាតដៃ ដូចជាក្មេងជំទង់ដកនូវស្មៅយាប្លង់ដ៏វិចិត្រ ។ នាងឧប្បលវណ្ណាបាំងនូវបាតដៃស្មើចក្រវាឡលើក្បាល ហើយញុំាងគ្រាប់ភ្លៀងមានពណ៌ផ្សេងៗឲ្យធ្លាក់ចុះ ។ នាងធ្វើផែនដីជាត្បាល់ ធ្វើក្រួសជាស្រូវ ធ្វើភ្នំសិនេរុជាអង្រែ ដូចក្មេងស្រីបុកស្រូវ ។ ខ្ញុំម្ចាស់ឈ្មោះឧប្បលវណ្ណា ជាធីតារបស់ព្រះពុទ្ធដ៏ប្រសើរ ជាអ្នកស្ទាត់ក្នុងអភិញ្ញាទាំងឡាយ ជាអ្នកធ្វើតាមសាសនារបស់ព្រះពុទ្ធអង្គ ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំម្ចាស់សូមធ្វើនូវវិកុព្វនឫទ្ធីផ្សេង ៗ សម្តែងថ្វាយព្រះលោកនាយក ហើយប្រកាសនូវនាម និងគោត្ត ទើបថ្វាយបង្គំព្រះបាទាព្រះអង្គ ។

បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វ-សោតធាតុឫទ្ធិផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាសទាំងទិព្វចក្ខុក៏ខ្ញុំម្ចាស់ជម្រះហើយ អាសវៈទាំងអស់ ក៏អស់រលីងហើយ ឥឡូវនេះភពថ្មីទៀត មិនមានទៀតទេ ។ ញាណរបស់ខ្ញុំម្ចាស់ដ៏ទូលាយស្អាតក្នុងអត្ថធម៌និរុត្តិនិងបដិភាណ តាមសភាពរបស់ព្រះពុទ្ធជាមហេសី ។ បពិត្រព្រះមហាមុនី ព្រះអង្គធ្លាប់សម្ដែងនូវសង្គ្រាមចំពោះព្រះជិនស្រីដ៏ប្រសើរទាំងឡាយ ក្នុងកាលមុន កិច្ចការដ៏ក្រៃលែងច្រើនយ៉ាងរបស់ខ្ញុំម្ចាស់ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី អំពើណាមានក្នុងកាលមុនដែលខ្ញុំម្ចាស់ធ្វើហើយ សូមព្រះអង្គរឭកនូវអំពើជាកុសលរបស់ខ្ញុំម្ចាស់នោះ បពិត្រព្រះមហាវីរបុរស បុណ្យដែលខ្ញុំម្ចាស់សន្សំទុកហើយដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់វៀរ ( នូវអំពើ ) ក្នុងទីមិនគួរ ហើយបានទាត់ចោលនូវអនាចារៈ ជីវិតដ៏ឧត្តមដែលខ្ញុំម្ចាស់លះបង់ហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានជីវិត ដល់ខ្ញុំម្ចាស់អស់ ១០ ពាន់កោដិទាំងខ្លួនខ្ញុំម្ចាស់ដែលខ្ញុំម្ចាស់បានលះបង់ហើយដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ គ្រានោះ បរិស័ទទាំង អស់ស្ងប់ស្ងែងក្រៃ

លែង ធ្វើអញ្ជលីដោយត្បូងពោលថា បពិត្រនាងម្ចាស់សេចក្តីព្យាយាម មានឫទ្ធិថ្លឹងមិនបាន ដែលនាងធ្វើហើយ តើដូចម្តេច ។

ក្នុងកប្បទី ១ សែន អំពីកប្បនេះ កាលនោះខ្ញុំកើតជាកញ្ញានៃនាគ ឈ្មោះនាងវិមលា ដែលគេសន្មតិហៅថាស្រីល្អជាងនាគកញ្ញាទាំងឡាយ ។ ពស់ធំឈ្មោះមហានាគ ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី បាននិមន្តព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់មានតេជះច្រើនព្រមទាំងសាវ័ក ។ មហានាគនោះ បានរៀបចំនូវមណ្ឌប ជាវិការៈនៃកែវផង នូវបល្ល័ង្កជាវិការៈនៃកែវផង នូវគ្រឿងឧបភោគជាវិការៈនៃកែវផង ដែលលាយដោយខ្សាច់ជាវិការៈនៃកែវផង នូវផ្លូវដែលស្អិតស្អាងដោយទង់ជ័យជាវិការៈនៃកែវផង ហើយប្រគំដោយតូរ្យតន្ត្រី ទទួលព្រះសម្ពុទ្ធ ។ ចំណែកខាងព្រះលោកនាយកដែលបរិស័ទទាំង ៤ បានហែហមហើយ ទ្រង់គង់លើអាសនៈដ៏ប្រសើរ ក្នុងលំនៅនៃមហានាគ ។ ស្តេចនាគបានថ្វាយនូវបាយទឹកផង នូវភោជនដែលគួរបរិភោគមានថ្លៃច្រើនផង នូវពរដ៏ប្រសើរផង ចំពោះព្រះពុទ្ធទ្រង់មានយសធំ ។ លុះព្រះសម្ពុទ្ធនោះ ទ្រង់សោយហើយ ទ្រង់លាងបាត្រ ហើយធ្វើអនុមោទនា ដោយឧបាយនៃប្រាជ្ញាថា ចូរនាងនាគកញ្ញា មានឫទ្ធិច្រើនចុះ ។ នាង

នាគកញ្ញាបានឃើញព្រះសព្វញ្ញុពុទ្ធ ដែលទ្រង់ស្រស់បស់មាន យសច្រើន ចិត្តក៏ជ្រះថ្លាចំពោះព្រះសាស្តាផង ចិត្តក៏ប្រតិព័ទ្ធ ចំពោះព្រះសាស្តាផង ក្នុងខណៈនោះព្រះសម្ពុទ្ធ ជាមហាវីរ បុរសព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំ ទ្រង់ បង្ហាញនូវភិក្ខុនីដោយឫទ្ធិ ។ ភិក្ខុនីនោះក្លៀវក្លា សម្ដែងនូវឫទ្ធិ ច្រើនប្រការ ខ្ញុំក៏រីករាយត្រេកអរបានពោលពាក្យនេះ ចំពោះ ព្រះសាស្តាថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ខ្ញុំម្ចាស់បានឃើញ ឫទ្ធិទាំងនេះ ដែលរាប់ថាក្រៃលែងជាងឫទ្ធិឯទៀត ភិក្ខុនីនោះ ក្លៀវក្លាដោយឫទ្ធិខ្លាំងម៉្លេះ តើដោយប្រការដូចម្ដេច ។

ភិក្ខុនីនេះ ជាធីតា ជាឱរស កើតអំពីមាត់របស់តថាគត ទើបជាភិក្ខុនីមានឫទ្ធិច្រើន ជាអ្នកធ្វើតាមអនុសាសនី របស់ តថាគត បានជាមានសេចក្តីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ។

លុះខ្ញុំស្តាប់ព្រះវាចា នៃព្រះពុទ្ធហើយ ក៏ត្រេកអរពោលនូវ ពាក្យយ៉ាងនេះថា សូមឲ្យខ្ញុំម្ចាស់ជាស្ត្រីក្លៀវក្លាក្រៃលែងដោយ ឫទ្ធិប្រាកដដូចជាភិក្ខុនីនោះ ។ បពិត្រព្រះអង្គ ជានាយក ខ្ញុំ ម្ចាស់មានចិត្តអរសប្បាយរីករាយ មានចិត្តខ្ពង់ខ្ពស់ សូមឲ្យ បានដូចភិក្ខុនីនេះ ក្នុងកាលអនាគតពុំខាន ។ ( ខ្ញុំបានថ្វាយ ) នូវបល្ល័ង្កជាវិការៈនៃកែវមណីផង នូវមណ្ឌបដ៏ក្លីផ្ទេកផងហើយ ញុំាងព្រះពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆ្អាន់ឆ្អែត

ស្អប់ស្អល់ដោយបាយនិងទឹក ។ ខ្ញុំបូជាផ្កាឧប្បលឈ្មោះអ-
រុណជាផ្កាដ៏ប្រសើរ របស់ពួកនាគចំពោះព្រះពុទ្ធ ជាលោក
នាយកហើយសូមឲ្យពណ៌សម្បុររបស់ខ្ញុំដូចផ្កានេះ ។ ដោយ
អំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះ
ផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើត
ក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្ស នោះហើយ
ក៏មកកើតក្នុងឋានមនុស្ស បានថ្វាយបិណ្ឌបាត ដែលបិទបាំង
ដោយផ្កាឧប្បលទាំងឡាយចំពោះព្រះពុទ្ធ ជាសយម្ភូ ។ ក្នុង
កប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយកព្រះនាម វិបស្សី
មានព្រះនេត្រដ៏ក្លីថ្លា មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ទ្រង់កើត
ឡើង ។ ក្នុងកាលនោះខ្ញុំបានកើតជាសេដ្ឋីធីតា ក្នុងបុរីដ៏ឧត្តម
ឈ្មោះពារាណសី បាននិមន្តព្រះសម្ពុទ្ធជាលោកនាយក ព្រម
ទាំងព្រះសង្ឃ ខ្ញុំថ្វាយមហាទាន បូជាព្រះពុទ្ធជានាយកដោយ
ផ្កាឧប្បលទាំងឡាយ ហើយប្រាថ្នាឲ្យមានពណ៌សម្បុរល្អដូច
ផ្កាឧប្បលទាំងនោះ ។ ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាម
កស្សបៈមានផៅពង្សដ៏ប្រសើរ មានយសច្រើន ប្រសើរជាង
ពួកជនអ្នកពោល ទ្រង់កើតឡើង ។ គ្រានោះ ព្រះរាជាដែន
កាសីព្រះនាមកិកី ជាឥស្សរៈលើប្រជាជន ក្នុងពារាណសីបុរី
ដ៏ប្រសើរ បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។ ខ្ញុំជាធីតាទី

២ របស់ព្រះរាជាអង្គនោះឈ្មោះនាងសមណីគុត្តា[១]បានស្តាប់ធម៌របស់ព្រះពុទ្ធជិនស្រីជាបុគ្គលប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ ក្នុងគ្រានោះ ព្រះវររាជបិតារបស់យើង ទ្រង់មិនអនុញ្ញាត យើងក៏មិនខ្ជិលប្រអូសប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំ នៅក្នុងផ្ទះជាព្រះរាជកញ្ញា ឋិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ គឺនាងសមណី ១ សមណាគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគម្រប់ ៧ ។ ( ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះធីតាទាំងនោះបានមកជា ) ខ្ញុំនេះ ១ នាងខេមាមានប្រាជ្ញា ១ បដាចារា ១ កណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ ៧ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយ ជារបស់មនុស្ស ហើយបានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងមនុស្សត្រកូលធំ បានថ្វាយនូវសំពត់សាច់ម៉ដ្តមានពណ៌លឿងដល់ព្រះអរហន្ត ។ លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងអរិដ្ឋបុរី ក្នុងត្រកូលព្រាហ្មណ៍ ជាធីតានៃតិរិដិវច្ឆសេដ្ឋីឈ្មោះនាង ឧម្មាទន្តី ជាទី

[១]- នាងសមណីគុត្តានេះ គឺនាងសមណាគុត្តានោះឯង ។

ពេញចិត្ត ( របស់ជន ) លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងជនបទ ក្នុងត្រកូល ១ ជាអ្នកខ្វល់ខ្វាយ មិនជាអ្នកស្តុកស្តម្ភណាស់ណាទេ ។ គ្រានោះ ខ្ញុំថែរក្សានូវស្រូវសាលី ខ្ញុំបានឃើញព្រះបច្ចេកសម្ពុទ្ធ ហើយថ្វាយលាជ ៥០០ កន្ទោង ដែលគ្របដោយផ្កាឈូក ហើយប្រាថ្នានូវកូន ៥០០ រូប ខ្ញុំថ្វាយទឹកឃ្មុំដល់ព្រះពុទ្ធជាសយម្ភូ ព្រោះតែកូនទាំងនោះ លុះច្យុតចាកអត្តភាពនោះហើយ បានមកកើត ក្នុងត្របកផ្កាឈូកនៅក្នុងព្រៃ ។ ខ្ញុំបានជាមហេសី របស់ស្តេចដែនកាសី ដែលគេធ្វើសក្ការៈបូជា បានបង្កើតព្រះរាជបុត្តចំនួន ៥០០ ឥតខ្វះ ។ កាលណា ព្រះរាជបុត្តទាំងនោះ ដល់នូវវ័យចម្រើនឡើង កំពុងលេងល្បែងក្នុងទឹក បានឃើញស្លឹក និងផ្កាឈូកសំយុងចុះ ( មានចិត្តនឿយណាយក្នុងសង្ខារក៏ចេញបួស ) បានជាព្រះបច្ចេកពុទ្ធជានាយកក្នុងកាលនោះ ។ ខ្ញុំនោះជាអ្នកព្រាត់ប្រាសចាករាជបុត្តដ៏ប្រសើរទាំងនោះក៏មានសេចក្តីសោកស្តាយ លុះច្យុត ( ចាកអត្តភាពនោះហើយ ) បានមកកើតក្នុងស្រុកតូចមួយ ទៀបភ្នំឥសិគិលិ ។ កាលណា ខ្ញុំមានចិត្តក្អកទឹកដល់កូន ដែលជាព្រះបច្ចេកពុទ្ធ ក៏នាំយកបបរដើរទៅដើម្បីកូនទាំងឡាយផង ដើម្បីខ្លួនផង ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធជានាយក ៨ ព្រះអង្គ ដែលកំពុងដើរទៅកាន់ស្រុកដើម្បី

ភិក្ខា ក៏នឹករឭកកូនទាំងឡាយ កាលនោះទឹកដោះរបស់ខ្ញុំក៏ខ្ចរចេញព្រោះសេចក្ដីស្រឡាញ់ចំពោះកូន ។ លំដាប់នោះខ្ញុំជ្រះថ្លាបានប្រគេនបបរ ដល់ព្រះបច្ចេកពុទ្ធទាំងនោះដោយដៃរបស់ខ្លួន លុះច្យុតចាកអត្តភាពនោះ ក៏បានទៅកើតឯឧទ្យានឈ្មោះនន្ទនៈ ក្នុងឋានត្រៃត្រិង្ស ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់បានទទួលសុខទុក្ខ អន្ទោលទៅក្នុងភពតូចភពធំ ទាំងជីវិតក៏ខ្ញុំលះបង់ដើម្បីប្រយោជន៍នៃព្រះអង្គ ។ សេចក្ដីទុក្ខផ្សេង ៗ ជាច្រើនយ៉ាងក្ដី សម្បត្តិផ្សេង ៗ ជាច្រើនក្ដី ( របស់ខ្ញុំ ) រមែងមានយ៉ាងនេះឯង លុះដល់បច្ឆិមភព ខ្ញុំមកកើតក្នុងសាវត្ថីបុរី ។ ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋីមានទ្រព្យច្រើន ដល់នូវសេចក្ដីសុខ ជាត្រកូលចាត់ចែងល្អហើយ រុងរឿងដោយរតនវត្ថុផ្សេងៗ សម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ ខ្ញុំត្រូវគេធ្វើសក្ការៈបូជាផង រាប់អានកោតក្រែងដូច្នោះផង ដល់នូវរូបសិរី ត្រូវគេធ្វើសក្ការៈក្រៃលែងក្នុងត្រកូលទាំងឡាយ ។ ខ្ញុំជាស្ត្រី ដែលពួកជនអ្នកមានសិរីដោយរូបនិងភោគៈ ប្រាថ្នាលើសលុបផង ដែលពួកកូនសេដ្ឋីជាច្រើនរយនាក់ប្រាថ្នាហើយផង ខ្ញុំលះបង់នូវផ្ទះហើយចូលទៅកាន់ផ្នួស កាលមិនទាន់ដល់កន្លះខែនៅឡើយ ក៏បានលុះនូវសច្ច ៤ ។ ខ្ញុំនិម្មិតនូវរថមានជ្រុង ៤ ដោយឫទ្ធិហើយថ្វាយបង្គំនូវព្រះបាទានៃព្រះពុទ្ធ ព្រះ

អង្គជាទីពឹងដ៏មានសិរីរបស់សត្វលោក ។

( មារពោលថា ) នាងអាស្រ័យនៅដើមឈើ ដែលមានចុងរីកផ្កាស្គុសស្គាយ ឋិតនៅទៀបគល់វាំងតែម្នាក់ឯង ទាំងអ្នកណាមួយជាគម្រប់ពីរនឹងនាង ក៏មិនមាន តើនាងមិនខ្លាចពួកជនពាល ឬពួកអ្នកលេង ទេឬ ។

( ខ្ញុំឆ្លើយថា ) ពួកជនអ្នកលេងចំនួន ១០០ ក្តី ១០០០ ក្តី ដែលប្រាកដដូច្នោះ មកក្នុងទីនេះ យើងក៏ឥតព្រឺរោម ឥតញាប់ញ័រ ម្នាលមារអ្នកជាបុគ្គលម្នាក់ឯង តើនឹងធ្វើម្តេចដល់យើង ។

យើងនុ៎ះ អាចបំបាត់ខ្លួនក៏បាន ចូលទៅក្នុងពោះអ្នកឯងក៏បានកាលយើងឋិតនៅត្រង់ប្រជុំចិញ្ចើម ក៏អ្នកមើលមិនឃើញ ។ យើងជាស្រីស្ទាត់ក្នុងផ្លូវចិត្ត ទាំងឥទ្ធិបាទទាំងឡាយ យើងក៏បានចម្រើនល្អហើយ យើងជាស្រីរួចចាកចំណង ទាំងអស់ហើយ នែអាវុសោ យើងមិនខ្លាចអ្នកទេ ។ អ្នកពោលនូវសេចក្តីត្រេកអរ ក្នុងកាមចំពោះគំនរកាមណា គំនរកាមនោះឧបមាដូចមុខលំពែងដ៏មុតក្រៃលែង ឥឡូវនេះ យើងមិនមានសេចក្តីត្រេកអរក្នុងកាមនោះទៀតទេ ។ សេចក្តីរីករាយ ក្នុងអារម្មណ៍ទាំងអស់ យើងបានកំចាត់បង់ហើយ ទាំងគំនរនៃសេចក្តីងងឹត យើងក៏ទម្លាយចេញហើយ ម្នាលមារមានចិត្ត

បាបអ្នកចូរដឹងយ៉ាងនេះចុះ ខ្លួនអ្នកត្រូវយើងកំចាត់បានហើយ ។ ព្រះជិនស្រីជានាយក ត្រេកអរចំពោះគុណនោះ តាំងខ្ញុំក្នុងទីជាឯតទគ្គៈក្នុងបរិស័ទទាំងឡាយថា នាងឧប្បលវណ្ណា ជាស្រីប្រសើរបំផុត ជាងភិក្ខុនីដែលមានឫទ្ធិទាំងឡាយ ។ ព្រះសាស្តា ខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំក៏ទម្លាក់ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់គុណវិសេសណា ប្រយោជន៍គឺគុណវិសេសនោះឯងជាគ្រឿងអស់ទៅនៃសំយោជនៈទាំងអស់ ខ្ញុំក៏បានដល់ជាលំដាប់ហើយ ។ ចំនួនពាន់នៃពួកជនដោយជុំវិញ រមែងបង្អោនមកនូវបច្ច័យ គឺចីវរ បិណ្ឌបាត សេនាសនៈ ដោយកាលភ្លាមៗ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដូច្នេះ ។

ព្រះថេរីរូបនេះ កាលព្រះមានព្រះភាគ យាងចូលកាន់គល់ស្វាយរបស់នាយគណ្ឌៈ ដើម្បីធ្វើយមកប្បាដិហារ្យក្បែរទ្វារក្រុងសាវត្ថី ។ គ្រានោះ ក៏ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគទ្រង់អនុញ្ញាត ខ្ញុំនឹងធ្វើបាដិហារ្យ ហើយបន្លឺសីហនាទ ។

ព្រះសាស្តាទ្រង់ធ្វើហេតុនោះ ឲ្យជាអត្ថុប្បត្តិហេតុ គង់កណ្តាលពួកព្រះអរិយៈក្នុងវត្តជេតពន ទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយ ទុកក្នុងតំណែងឯតទគ្គៈតាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីអង្គនេះទុកក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុនីទាំងឡាយខាងមានឫទ្ធិ ។ ព្រះនាងឧប្បលវណ្ណាថេរីនោះ ញ៉ាំងកាលវេលាឲ្យកន្លងទៅដោយសុខក្នុងឈាន សុខក្នុងផលនិងសុខក្នុងព្រះនិព្វាន ថ្ងៃមួយពិចារណានូវទោសគ្រោតគ្រាត និងសេចក្តីសៅហ្មង របស់កាមទាំងឡាយ កាលពោលដដែលនូវគាថា ( ដែលព្រះថេរីជា ) មាតារបស់ព្រះគង្គាតីរិយត្ថេរពោល ព្រោះកើតសេចក្តីសង្វេគដែលបាននៅជាមួយស្វាមី តែមួយជាមួយនឹងកូនស្រីទើបពោលគាថា ៣ ថា

យើងទាំងពីរនាក់គឺមាតានិងធីតា មានប្តីជាមួយគ្នា ( ភរិយារួមប្តី ) សេចក្តីតក់ស្លុត សេចក្តីព្រឺរោម អស្ចារ្យចម្លែកកើតមានដល់ខ្ញុំនោះ ។ ថ្វីយ កាមទាំងឡាយជារបស់មិនស្អាត មានក្លិនអាក្រក់ ដូចជាបន្លាច្រើនយ៉ាង ដែលនាំយើងទាំងពីរនាក់គឺមាតានិងធីតា ឲ្យជាភរិយាជាមួយគ្នា ។ លុះខ្ញុំឃើញទោសក្នុងកាមទាំងឡាយហើយ ឃើញនេក្ខម្មៈថាជារបស់ក្សេមទើបចេញចាកផ្ទះក្នុងក្រុងរាជគ្រឹះបួលកាន់ផ្នួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧភោ មាតា ច ធីតា ច មយំ អាសុំ សបត្តិយោ** សេចក្តីថា យើងទាំង ២ គឺមាតានិងធីតា បានជាស្រីរួមប្តីគ្នា ។ បានឮថា ភរិយារបស់ឈ្មួញម្នាក់ក្នុងក្រុងសាវត្ថី តាំងគភ៌ក្នុងពេលទៀប

ភ្ញី នាងក៏មិនដឹងការតាំងគភ៌នោះ ។ លុះភ្ញីស្វាង ឈ្មួញក៏ផ្ទុកទំនិញក្នុងរទេះ ធ្វើដំណើរទៅជួញក្នុងក្រុងរាជគ្រឹះ លុះកន្លងទៅ គភ៌របស់នាងក៏ធំរហូតចាស់ខែ ។ កាលនោះ ម៉ែក្មេកពោលនឹងនាងថា កូនប្រុសរបស់យើង ទៅយូរហើយ នាងក៏មានគភ៌ នាងធ្វើអាក្រក់ឬ ។ នាងពោលថា ក្រៅអំពីកូនប្រុសរបស់ម៉ែ ខ្ញុំមិនស្គាល់បុរសដទៃ ។ ម៉ែក្មេកស្ដាប់នាងហើយ មិនជឿ ទើបបណ្ដេញចេញអំពីផ្ទះ នាងក៏ទៅតាមរកស្វាមីដល់ក្រុងរាជគ្រឹះតាមលំដាប់ ។ ខណៈនោះ ខ្យល់កម្មជ្ជវាតក៏បក់ឡើង នាងចូលទៅកាន់សាលាមួយកន្លែងក្បែរផ្លូវ ហើយក៏ប្រសូត នាងប្រសូតកូនប្រុសដូចគ្នានឹងបដិមាមាស ឲ្យដេកលើសាលាអនាថា ហើយចេញទៅរកទឹកខាងក្រៅសាលា ។ គ្រានោះ មេឈ្មួញរទេះម្នាក់ ជាមនុស្សមិនមានកូន ធ្វើដំណើរមកតាមផ្លូវនោះ គិតថាទារករបស់ស្ត្រីមិនមានប្ដីនឹងជាកូនរបស់អញ ទើបយកទារកនោះទៅ ប្រគល់ក្នុងដៃមេដោះ ។ បន្ទាប់មក មាតារបស់ទារកនោះ ធ្វើកិច្ចដោយទឹកហើយត្រឡប់មក មិនឃើញកូនសោយសោកកន្ទក់កន្ទេញ មិនចូលទៅកាន់ក្រុងរាជគ្រឹះ ធ្វើដំណើរតទៅ ។ មេចោរម្នាក់ជួបនាងក្នុងរវាងផ្លូវកើតចិត្តប្រតិព័ទ្ធ ទើបយកនាងធ្វើជាភរិយារបស់ខ្លួន នាងនៅក្នុងផ្ទះចោរនោះ ក៏ប្រសូតកូនស្រីម្នាក់ ។ ថ្ងៃមួយ នាងឈរពកូនស្រី ដោយឈ្លោះជាមួយប្ដី ក៏បោះទារិកាលើគ្រែ ក្បាលរបស់ទារិកាក៏បែកបន្តិច បន្ទាប់អំពីនោះ នាងខ្លាចប្ដីទើបត្រាច់ទៅកាន់ក្រុងរាជគ្រឹះរស់នៅតាមគាប់ចិត្ត កូនប្រុសរបស់នាង ធំពេញកំលោះមិនដឹងថាជាមាតា ក៏យកមាតាធ្វើជាភរិយារបស់ខ្លួន ។

តមក បុរសនោះមិនដឹងថា កូនស្រីមេចោរនោះជាប្អូនស្រី ក៏នាំមកផ្ទះ បុរសនោះធ្វើមាតានិងប្អូនស្រីឲ្យជាភរិយារបស់ខ្លួន ដោយប្រការដូច្នេះ ទើបបុគ្គលទាំង ២ នោះ នៅជាមួយគ្នាដោយការព្រមព្រៀង ។ ថ្ងៃមួយ មាតាស្រាយផ្នួងសក់របស់កូនស្រី រកចៃ ឃើញស្នាមត្រង់ក្បាល គិតថា ស្រីនេះពិតជាកូនស្រីរបស់អញ ហើយក៏សួរ កើតសេចក្ដីសង្វេគ ទើបទៅកាន់នគររាជគ្រឹះ ហើយបួស ធ្វើកិច្ចខាងដើមស្រេច នៅយ៉ាងស្ងប់ស្ងាត់ ពិចារណាវត្តដែលខ្លួនធ្វើក្នុងកាលមុន ក៏បានពោលគាថាថា **ឧភោ មាតា ច ធីតា ច** ជាដើម ។ ព្រះថេរីនេះពោលម្ដងទៀតនូវគាថាដែលស្រីនោះពោលហើយទាំងនោះ ដើម្បីចង្អុលបង្ហាញនូវទោស ក្នុងកាមទាំងឡាយ ទើបពោលថា **ឧភោ មាតា ច ធីតា ច** ជាដើម ។ ដោយហេតុនោះ ទើបខ្ញុំពោលថា ព្រះនាងឧប្បលវណ្ណាថេរី ញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្ដីសុខក្នុងឈាន សុខក្នុងផលនិងសុខក្នុងព្រះនិព្វាន ទើបបានពោលគាថា ៣ នេះ ។

បណ្ដាបទទាំងនោះ បទថា **អសុចី** បានដល់ ឈ្មោះថា **អសុចី** ព្រោះមានរបស់មិនស្អាតគឺកិលេសហូរចេញ ។ បទថា **ទុគ្គន្ធា** បានដល់ មានក្លិនស្អុយ ព្រោះក្លិនស្អុយផ្សាយទៅ ។ បទថា **ពហុកណ្ដកា** បានដល់ ឈ្មោះថា **ពហុកណ្ដកា** ព្រោះអត្ថថា ចាក់ទម្លុះសុចរិត ដោយភាពជាសត្រូវ ។ ពិតហើយ លោកហៅកិលេសទាំងនោះថា កាមទាំងឡាយ ប្រៀបដូចលំពែង ។ បទថា **យត្ថ** បានដល់ ក្នុងកាមពួកណាដែលបុគ្គលគប្បីបរិភោគ ។ បទថា **សហាភរិយា** បានដល់ ជាភរិយាស្មើគ្នា គឺរួមប្ដីតែមួយ ។

២ គាថាមានគាថាថា **បុព្វេនិវាសំ** ជាដើម ព្រះថេរីពោលព្រោះពិ-
ចារណាគុណវិសេសដែលខ្លួនស្រឡាញ់ហើយកើតនូវបីតិសោមនស្ស ។ បទ
ថា **ចេតោបរិយញ្ញាណំ** បានដល់ ចេតោបរិយញ្ញាណ ក៏ធ្វើឲ្យជាក់ច្បាស់
ហើយ ឬភ្ជាប់សេចក្តីថា សម្រេចហើយ ។

ខ្ញុំនិម្មិតនូវរថទឹមសេះ ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំព្រះបាទ
ទាំងគូនៃព្រះពុទ្ធដ៏មានសិរី ជាទីពឹងនៃសត្វលោក ដូច្នេះ ។

ក្នុងកាលព្រះមានព្រះភាគចូលកាន់មណ្ឌលដើមស្វាយរបស់នាយគណ្ឌៈ
ដើម្បីធ្វើយមកប្បាដិហារ្យ កាលនោះ ព្រះថេរីនិម្មិតរថ ចូលទៅគាល់មួយ
អន្លើដោយរថនោះ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំម្ចាស់នឹងធ្វើបា-
ដិហារដើម្បីទម្លាយសេចក្តីស្រវឹងរបស់តិរ្ថិយសូមទ្រង់អនុញ្ញាតផងចុះ ហើយ
ឈរក្នុងសម្នាក់ព្រះសាស្តា ព្រះថេរីសំដៅដល់បាដិហារនោះ ទើបពោលគា
ថាខាងលើនេះ ។

បណ្តាបទទាំងនោះ បទថា **ឥទ្ធិយា អភិនិម្មិត្វា ចតុរស្សំ រថំ អហំ**
អធិប្បាយថា ខ្ញុំនិម្មិតរថទឹមដោយសេះ ៤ ដោយឫទ្ធិហើយ ថ្វាយបង្គំព្រះ
យុគលបាទរបស់ព្រះមានព្រះភាគ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។

មារសួរព្រះថេរីថា នាងជាស្រីម្នាក់ឯង ចូលមកកាន់ដើមរាំងភ្នំ ដែល
នៅចុងមានផ្ការីកស្គុសស្គាយ ហើយឈរនៅទៀបគល់ឈើ បុគ្គលណាមួយ
ជាគម្រប់ពីររបស់នាងក៏មិនមាន នៃស្ត្រីពាល នាងមិនខ្លាចពួកអ្នកលេងទេឬ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុបុប្ផិតគ្គំ** សេចក្តីថា មានផ្ការីកល្អ គឺរីកស្គុសស្គាយ តាំងពីដើមដល់ចុង ។ បទថា **ទុមេ** ប្រែថា ដើមឈើ ក្នុងទីនេះ លោកសំដៅយកដើមសាលព្រឹក្ស ។ បទថា **ឯកា តុវំ** សេចក្តីថា នាងឈរម្នាក់ឯងក្នុងទីនេះ ។ បទថា **ន ចាបិ តុយ្ហំ ទុតិយត្ថិ កោចិ** សេចក្តីថា នាងមិនមានបុគ្គលណាមួយជាសម្លាញ់ ជាអ្នករក្សាទេឬ ។ ម្យ៉ាងទៀត ដោយរូបសម្បត្តិក៏មិនមានបុគ្គលគម្រប់ពីរ មិនមានអ្នកណាស្អាតស្មើឈរម្នាក់ឯង ក្នុងទីស្ងាត់ចាកមនុស្ស ។ បទថា **ន ត្វំ ពាលេ ភាយសិ ធុត្តកានំ** សេចក្តីថា នែស្រីក្មេង នាងមិនខ្លាចពាក្យ លួងលោមរបស់បុរសអ្នកលេងទេឬ អធិប្បាយថា ពួកអ្នកលេងដែលធ្វើនូវការផ្តោះផ្តងវាចា ។

បានឮថា ថ្ងៃមួយ មារឃើញព្រះថេរីអង្គុយសម្រាកក្នុងពេលថ្ងៃ ក្នុងព្រៃសាលព្រឹក្សដែលមានផ្ការីក ត្រូវការផ្តាច់ព្រះថេរីអំពីវិវេក កាលសាកល្បងទើបពោលគាថានេះ ។ លំដាប់នោះ ព្រះថេរីកាលគំរាមនូវមារនោះ ទើបពោលគាថាទាំងនេះដោយអានុភាពរបស់ខ្លួនថា

> បើទុកជាអ្នកលេងទាំងឡាយមួយរយ ឬមួយពាន់ ជាបុគ្គល
> មានសភាពយ៉ាងនេះ មកជួបជុំគ្នា ក៏រោម ( របស់យើង )
> មិនព្រឺព្រួច មិនញាប់ញ័រ នែមារ អ្នកម្នាក់ឯង នឹងធ្វើនូវអ្វី
> ដល់យើងកើត ។ យើងនេះនឹងបាត់ទៅ ឬនឹងចូលទៅកាន់ផ្ទៃ
> របស់អ្នកក៏បាន ឬបើទុកជាឈរនៅក្បែរចន្លោះចិញ្ចើម របស់
> អ្នកក៏អ្នកមើលមិនឃើញយើងឈរដែរ ។ យើងជាស្ត្រីស្ទាត់

ក្នុងអធិចិត្ត ឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយដោយប្រពៃ អភិញ្ញា ៦ យើងបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនាយើងបានធ្វើហើយ កាមទាំងឡាយ ប្រៀបដោយលំពែងនិងឈើស្រួច សម្រាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកពោលនូវតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះមិនមែនជាតម្រេករបស់យើងឡើយ ។ សេចក្ដីរីករាយក្នុងកាមទាំងអស់យើងបានកម្ចាត់ចេញហើយគំនរនៃងងឹត ( អវិជ្ជា ) យើងបានទម្លាយចោលហើយ នែមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ នែមារថោកទាប អ្នកយើងកម្ចាត់ចេញហើយដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សតំ សហស្សានិបិ ធុត្តកានំ សមាគតា ឯតិសកា ភវេយ្យុំ** សេចក្ដីថា ទោះបីពួកអ្នកលេងច្រើនសែននាក់ គឺបែបនោះ គប្បីមកប្រជុំគ្នា ។ បទថា **លោមំ ន ឥញ្ជេ នបិ សម្បវេធេ** សេចក្ដីថា សូម្បីត្រឹមតែរោមក៏មិនញាប់ញ័រ ។ បទថា **កឹ មេ តុវំ មារ ករិស្ស-សេ កោ** សេចក្ដីថា នែមារ អ្នកត្រឹមតែម្នាក់នឹងធ្វើអ្វីយើងបាន ។

ឥឡូវនេះ ព្រះថេរីកាលចង្អុលបង្ហាញថា មារមិនអាចធ្វើអ្វីដល់ខ្លួនបាន ទើបពោលគាថាថា **ឯសា អន្តរធាយាមិ** ជាដើម ។ គាថានេះមានសេចក្ដីថា នែមារ យើងនោះ ឈរចំពោះមុខអ្នក ក៏បាត់ខ្លួនបាន អ្នកមើលមិនឃើញ យើងចូលក្នុងពោះអ្នក ទាំងអ្នកមិនដឹងនោះក៏បាន ឈររវាងចិញ្ចើមក៏បាន

កាលយើងឈរយ៉ាងនោះ អ្នកក៏មើលមិនឃើញ ។

បើសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា យើងជាស្ត្រីស្ទាត់ ក្នុងអធិចិត្ត ឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយដោយប្រពៃ អធិប្បាយថា នែមារ យើងធ្វើបាន ព្រោះចិត្តរបស់យើងជំនាញហើយ ឥទ្ធិបាទ ៤ យើងក៏អប់រំល្អហើយ ធ្វើឲ្យច្រើនហើយ ព្រោះហេតុនោះ ទើបយើងអាច ព្រោះនៅក្នុងឥទ្ធិវិស័យ តាមដែលពោលមកហើយ ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ព្រោះមានន័យដូចពោលមកហើយខាងដើមនោះឯង ។

**អដ្ឋកថា ឧប្បលវណ្ណាថេរីគាថា ចប់**

**ថេរីគាថា ទ្វាទសកនិបាត ចប់**

# ថេរីគាថា សោឡសកនិបាត

## បុណ្ណិកាថេរីគាថា

[ ៣៣០ ] ខ្ញុំជាស្រ្តីអ្នកដងទឹក មានការខ្លាចទណ្ឌភ័យ នៃជនជាម្ចាស់ទាំងឡាយ ត្រូវភ័យអំពីវាចានិងទោសបៀតបៀន ហើយចុះទឹករាល់ពេលក្នុងកាលត្រជាក់រងារ ។ ម្នាលព្រាហ្មណ៍ អ្នកខ្លាចអ្នកណា ទើបចុះទឹករាល់ពេល មានខ្លួនញាប់ញ័រ ទទួលរងរងារដ៏ក្រៃលែង ។

ម្នាលនាងបុណ្ណិកាដ៏ចម្រើន នាងដឹង ( ថាខ្ញុំ ) កំពុងធ្វើកុសលកម្ម ជាគ្រឿងបិទនូវបាបកម្មដែរ ម្តេចក៏សួរដេញដោល បុគ្គលណាទោះចាស់ក្តី ក្មេងក្តី ធ្វើបាបកម្មបុគ្គលនោះរមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹក ។

អ្នកល្ងង់ណាហ្ន៎ បាននិយាយពាក្យនេះទៅរកអ្នកដែលល្ងង់ដែរ ( ថាបុគ្គល ) រមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹក ( បើដូច្នោះ ) កង្កែប អណ្តើក នាគ ក្រពើ ឬសត្វដទៃណាមួយ ដែលត្រាច់ទៅក្នុងទឹកទាំងអស់ នឹងទៅកាន់ឋានសួគ៌ដោយពិត ។ ពួកជនអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក នេសាទត្រី អ្នកចាប់ម្រឹគ ពួកចោរ ពួកពេជ្ឈឃាតឬពួកជនឯទៀតដែលមានកម្មដ៏លាមក ពួកជនទាំងនោះ ក៏រួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹក ។ ប្រសិនបើស្ទឹងទាំងនោះ អាចបន្សាត់ចោលនូវបាប ដែលអ្នកធ្វើក្នុងកាលមុនបាន ស្ទឹងទាំងនោះ ក៏អាចបន្សាត់ចោលនូវបុណ្យរបស់អ្នកបានដែរ ព្រោះហេតុនោះខ្លួនអ្នកនឹងទៅជាបុគ្គលក្រៅស្រឡះ ម្នាលព្រាហ្មណ៍

អ្នកខ្លាចចំពោះបាបកម្មណា ហើយចុះត្រាំទឹកគ្រប់ៗពេល ម្នាលព្រាហ្មណ៍អ្នកកុំធ្វើនូវបាបកម្មនោះវិញ កុំ ( ចុះត្រាំទឹក ) ឲ្យរងារ បៀតបៀននូវសម្បុរសរីរៈរបស់អ្នកឡើយ ។

នាងដឹកនាំខ្ញុំដែលដើរផ្លូវខុស ឲ្យដើរទៅតាមផ្លូវដ៏ប្រសើរ ម្នាលនាងដ៏ចម្រើន ខ្ញុំសូមជូនសាដកសម្រាប់ស្រោចស្រពទឹកនេះដល់នាង ។

សំពត់សាដក ចូរនៅជារបស់អ្នកដដែលចុះ ខ្ញុំមិនត្រូវការសំពត់សាដក ( របស់អ្នក ) ទេ ។ បើអ្នកខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់នៃអ្នកទេ អ្នកកុំធ្វើបាបកម្ម ទោះបីក្នុងទីវាលក្តី ក្នុងទីកំបាំងក្តី ។ បើអ្នកនឹងធ្វើឬកំពុងធ្វើនូវបាបកម្ម សូម្បីអ្នកហោះរត់ទៅ ក៏មិនរួចចាកទុក្ខ ។ បើអ្នកខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងចុះ ចូរសមាទានសីលទាំងឡាយចុះ ការដល់នូវទីពឹង និងការសមាទានសីលនោះ នឹងញុំាងអ្នកឲ្យរួចចាក ( ទុក្ខ ) ។

ពីដើមខ្ញុំជាព្រាហ្មណ៍តែពូជថ្ងៃនេះខ្ញុំជាព្រាហ្មណ៍ពិតមានត្រៃវិជ្ជា បរិបូណ៌ដោយវេទ ជាអ្នកមានសួស្តី ជាអ្នកលាងបាប ។

**បុណ្ណិកាថេរី ។**

**ចប់ សោឡសកនិបាត ។**

# អដ្ឋកថា

# ថេរីគាថា សោឡសកនិបាត

## បុណ្ណាថេរីគាថា

[ ៣៣០ ] ក្នុងសោឡសកនិបាត គាថារបស់ព្រះនាងបុណ្ណាថេរី មានពាក្យផ្ដើមថា **ឧទហារី អហំ សីតេ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា វិបស្សី កើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្ដីហើយ ព្រោះជាអ្នកដល់ព្រមដោយហេតុសម្បទា ក៏ទៅក្នុងសម្នាក់ភិក្ខុនីស្ដាប់ធម៌បាននូវសទ្ធា ហើយបួស មានសីលបរិសុទ្ធ រៀនព្រះត្រៃបិដក ជាពហូស្សុត ទ្រទ្រង់នូវធម៌ និងជាធម្មកថិក ។ នាងបួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថាសិខី វេស្សភូ កកុសន្ធៈ កោនាគមនៈ និងកស្សបៈ ជាអ្នកសម្បូរដោយសីល ជាពហូស្សុត ទ្រទ្រង់នូវធម៌ និងជាធម្មកថិក ដូចកាលបួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សី ដូច្នោះដែរ តែព្រោះខ្លួនជាអ្នកមានមានះ មិនអាចកាត់កិលេសបាន និងព្រោះធ្វើនូវកម្មដោយមានមានះជាសន្តាន ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទៃទាសីក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី មានឈ្មោះថា បុណ្ណា នាងជាសោតាបន្ន ព្រោះព្រះធម្មទេសនាឈ្មោះសីហនាទសូត្រ ក្រោយមកទូន្មានព្រាហ្មណ៍ដែលប្រកាន់ថា បរិសុទ្ធិ ដោយការចុះងូតទឹក លោកសេដ្ឋី

សរសើរហើយ ធ្វើនាងឲ្យជាអ្នកជា អនុញ្ញាតឲ្យនាងបួស កាលបួសហើយ ចម្រើនកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំបានបួសក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះនាមវិបស្សី ផង ព្រះនាមសិខីផង ព្រះនាមវេស្សភូផង ព្រះនាមកកុសន្ធៈ ផង ព្រះនាមកោនាគមនៈផង ប្រកបដោយតាទិគុណផង ព្រះ នាមកស្សបៈផង ខ្ញុំជាភិក្ខុនី បរិបូណ៌ដោយសីល មានប្រាជ្ញា ចាស់ក្លា មានឥន្រ្ទិយសង្រួមល្អ ។ ជាពហុស្សូត ចងចាំនូវ ធម៌ ជាអ្នកសាកសួរនូវធម៌និងអត្ថ ហើយរៀនធម៌ស្តាប់ធម៌ ទាំងជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធជាម្ចាស់ ។ ខ្ញុំបានសម្តែង នូវសាសនារបស់ព្រះជិនស្រី ក្នុងកណ្តាលនៃប្រជុំជន ខ្ញុំមាន សីលជាទីស្រឡាញ់ បានមើលងាយគេ ដោយអាងខ្លួនជា ពហុស្សូតនោះ ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមកព ខ្ញុំបានកើត ក្នុងផ្ទៃនៃស្រីកុម្ភទាសី ក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋី ក្នុងបុរីដ៏ ឧត្តមឈ្មោះសាវត្ថី ។ ខ្ញុំទៅកាន់កំពង់ទឹកបានឃើញសោត្ថិយ ព្រាហ្មណ៍ ដែលជាអ្នកត្រូវត្រជាក់គ្របសង្កត់ ក្នុងកណ្តាល ទឹក លុះខ្ញុំឃើញព្រាហ្មណ៍នោះហើយ បានពោលពាក្យនេះថា ខ្ញុំជាស្រីដងទឹក ចុះទឹកដ៏ត្រជាក់សព្វៗកាល ព្រោះភ័យភិត នឹងអាជ្ញានៃម្ចាស់ ព្រោះភ័យនឹងពាក្យកំហឹងគ្របសង្កត់ ។ នៃ

ព្រាហ្មណ៍ ចុះអ្នកខ្លាចនរណាបានជាអ្នកចុះត្រាំទឹកសព្វៗកាល មានខ្លួនញាប់ញ័រ រងនូវត្រជាក់ដ៏ក្រៃលែង ។

ម្នាលនាងបុណ្ណិកាដ៏ចម្រើន យីអើ! នាងស្គាល់យើងច្បាស់ បានជាហ៊ានសាកសួរយើងដែលកំពុងធ្វើកុសលកម្ម បន្ទោបង់នូវកម្មដ៏លាមក ។ បុគ្គលណាទោះបីចាស់ក្តី ក្មេងក្តី ធ្វើបាបកម្មហើយ បុគ្គលនោះឯងលុះតែជងទឹកមកស្រោចស្រពកាយ ទើបរួចចាកបាបកម្មបាន ។

កាលព្រាហ្មណ៍នោះ ឡើងមកអំពីទឹកវិញ ខ្ញុំក៏បានពោលនូវបទប្រកបដោយធម៌និងអត្ថ ឯព្រាហ្មណ៍បានឮភាសិតនោះហើយ ក៏តក់ស្លុត ចេញទៅបួស បានសម្រេចជាព្រះអរហន្ត ខ្ញុំតាំងពីកើតក្នុងទាសីត្រកូល បានបំពេញជាទាសីមួយរយខ្វះមួយ ចាប់ដើមអំពីនោះមក នាមរបស់ខ្ញុំឈ្មោះថាបុណ្ណា ជនទាំងនោះ បានធ្វើខ្ញុំឲ្យរួចជាអ្នកជា លំដាប់នោះ ខ្ញុំបានញ៉ាំងសេដ្ឋីឲ្យរីករាយតាម ហើយចូលទៅកាន់ផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ។ បពិត្រ ព្រះមហាមុនី ខ្ញុំម្ចាស់ជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំម្ចាស់ដឹងច្បាស់នូវបុព្វេនិវាសទាំងទិព្វចក្ខុ ខ្ញុំម្ចាស់ បានជម្រះស្អាតល្អហើយ អាសវៈទាំងពួង

អស់ហើយ ឥឡូវនេះភពថ្មីទៀតមិនមានឡើយ ។ ខ្ញុំម្ចាស់ មានសេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធប្រសើរ ។ ខ្ញុំមានប្រាជ្ញាច្រើន ព្រោះការអប់រំ ជាអ្នកចេះដឹង ព្រោះការស្តាប់ ជាអ្នកកើតក្នុងត្រកូលទាប ព្រោះមានះ ព្រោះថាកម្មរបស់ខ្ញុំ មិនបានវិនាសឡើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលនាងសម្រេចអរហត្តហើយ ពិចារណាបដិបទារបស់ខ្លួន បានពោលគាថាទាំងនេះ ជាឧទានថា

ខ្ញុំជាស្រ្តីអ្នកដងទឹក មានការខ្លាចទណ្ឌភ័យនៃជនជាម្ចាស់ទាំងឡាយ ត្រូវភ័យអំពីវាចានិងទោសបៀតបៀន ហើយចុះទឹករាល់ពេល ក្នុងកាលត្រជាក់រងារ ។ ម្នាលព្រាហ្មណ៍ អ្នកខ្លាចអ្នកណា ទើបចុះទឹករាល់ពេល មានខ្លួនញាប់ញ័រ ទទួលរងរងារដ៏ក្រៃលែង ។

ម្នាលនាងបុណ្ណិកាដ៏ចម្រើន នាងដឹង ( ថាខ្ញុំ ) កំពុងធ្វើកុសលកម្មជាគ្រឿងបិទទូវបាបកម្មដែរ ម្តេចក៏សួរដេញដោលបុគ្គលណា ទោះចាស់ក្តី ក្មេងក្តី ធ្វើបាបកម្ម បុគ្គលនោះរមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹក ។

អ្នកល្ងង់ណាហ្ន៎ បាននិយាយពាក្យនេះទៅរកអ្នកដែលល្ងង់ដែរ ( ថាបុគ្គល ) រមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹក ( បើដូច្នោះ ) កង្កែប អណ្តើក នាគ ក្រពើ ឬសត្វដទៃណាមួយដែលត្រាច់ទៅក្នុងទឹកទាំងអស់ នឹងទៅកាន់ឋានសួគ៌ដោយពិត ។ ពួកជនអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក នេសាទត្រី អ្នកចាប់ម្រឹគ ពួកចោរ ពួកពេជ្ឈឃាត ឬពួកជនឯទៀតដែលមានកម្មដ៏លាមក ពួកជនទាំងនោះ ក៏រួចចាកបាបកម្មព្រោះការស្រោចស្រពដោយទឹក ។ ប្រសិនបើស្ទឹងទាំងនោះ អាចបន្សាត់ចោលនូវបាប ដែលអ្នកធ្វើក្នុងកាលមុនបាន ស្ទឹងទាំងនោះ ក៏អាចបន្សាត់ចោលនូវបុណ្យរបស់ អ្នកបានដែរ ព្រោះហេតុនោះខ្លួនអ្នកនឹងទៅជាបុគ្គលក្រៅស្រឡះ ម្នាលព្រាហ្មណ៍ អ្នកខ្លាចចំពោះបាបកម្មណា ហើយចុះត្រាំទឹករឿយៗពេល ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើនូវបាបកម្មនោះវិញ កុំ ( ចុះត្រាំទឹក ) ឲ្យរងាររបៀតបៀននូវសម្បុរសរីរៈរបស់អ្នកឡើយ ។

នាងជីកនាំខ្ញុំដែលដើរផ្លូវខុស ឲ្យដើរទៅតាមផ្លូវដ៏ប្រសើរ ម្នាលនាងដ៏ចម្រើន ខ្ញុំសូមជូនសាដក សម្រាប់ស្រោចស្រពទឹកនេះដល់នាង ។

សំពត់សាដក ចូរនៅជារបស់អ្នកដដែលចុះ ខ្ញុំមិនត្រូវការសំពត់សាដក ( របស់អ្នក ) ទេ ។ បើអ្នកខ្លាចសេចក្តីទុក្ខ

បើសេចក្តីទុក្ខមិនជាទីស្រឡាញ់នៃអ្នកទេ អ្នកកុំធ្វើបាបកម្មទោះ បីក្នុងទីវាលក្តី ក្នុងទីកំបាំងក្តី ។ បើអ្នកនឹងធ្វើ ឬកំពុងធ្វើនូវ បាបកម្ម សូម្បីអ្នកហោះរត់ទៅ ក៏មិនរួចចាកទុក្ខ ។ បើអ្នក ខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់ របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង នូវព្រះធម៌ផង នូវព្រះ សង្ឃផង ជាទីពឹងចុះ ចូរសមាទានសីលទាំងឡាយចុះ ការ ដល់នូវទីពឹងនិងការសមាទានសីលនោះ នឹងញុំាងអ្នកឲ្យរួច ចាក ( ទុក្ខ ) ។

ពីដើមខ្ញុំជាព្រាហ្មណ៍តែពូជ ថ្ងៃនេះ ខ្ញុំជាព្រាហ្មណ៍ពិត មាន ត្រៃវិជ្ជា បរិបូណ៌ដោយវេទ ជាអ្នកមានសួស្តី ជាអ្នកលាង បាប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទហារី** បានដល់ ជាអ្នកនាំទឹកមកដោយ ក្អម ។ បទថា **សទា ឧទកមោតរឹ** បានដល់ ចុះត្រាំទឹកសព្វកាល គឺទាំង ពេលថ្ងៃ និងពេលយប់ សូម្បីក្នុងខែរងា អធិប្បាយថា ពេលណាដែល ចៅហ្វាយត្រូវការទឹក ពេលនោះ ខ្ញុំក៏ត្រូវចុះដងទឹក កាលចុះដងទឹកហើយ ក៏ត្រូវនាំទៅឲ្យ ។ បទថា **អយ្យានំ ទណ្ឌភយភីតា** បានដល់ ខ្លាចភ័យ គឺការដាក់ទោសរបស់ចៅហ្វាយ ។ បទថា **វាចាទោសភយដ្ដិតា** បានដល់ ត្រូវភ័យ គឺការដាក់ទោសដោយវាចា គឺការជេរប្រទេច និងភ័យ គឺការដាក់ ទោសផ្លូវកាយ ប្រកបសេចក្តីថា ត្រូវចុះដងទឹក សូម្បីតែក្នុងខែរងា ។

ថ្ងៃមួយ នាងបុណ្ណាទាសី ទៅកំពង់ទឹកដើម្បីយកក្អមដងទឹកមក ក្នុងទីនោះ បានជួបនឹងព្រាហ្មណ៍ម្នាក់ ដែលកាន់យកលទ្ធិថា បរិសុទ្ធដោយការងូតទឹក កាលភាពរងាខ្លាំងប្រព្រឹត្តទៅ ក្នុងសម័យសន្សើមធ្លាក់ ចុះទឹកអំពីព្រលឹមមុជទឹកលិចក្បាល រាយមន្តហើយ ឡើងអំពីទឹក សំពត់សើម សក់សើម មានដើងញ័រ មានធ្មេញរណ្ដំ ដូច្នោះ កាលឃើញហើយ នាងបុណ្ណា មានចិត្តដែលសេចក្ដីករុណាជាស់តឿនហើយ បំណងនឹងដោះព្រាហ្មណ៍នោះ ឲ្យផុតចាកទិដ្ឋិនោះ ទើបពោលគាថាថា **កស្ស ព្រាហ្មណ ត្វំ ភីតោ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **កស្ស ព្រាហ្មណ ត្វំ ភីតោ** សេចក្ដីថា នៃព្រាហ្មណ៍ លោកខ្លាចហេតុនៃភ័យដូចម្ដេច ។ បទថា **សទា ឧទកមោតរិ** បានដល់ ចុះទឹកសព្វកាល គឺទាំងពេលព្រឹក ទាំងពេលល្ងាច កាលចុះហើយ ក៏មានខ្លួន គឺចំណែកនៃរាងកាយរងាញ័រញ្ញាក់ គឺរងាខ្លាំង ។ បទថា **សីតំ វេទយសេ ភុសំ** បានដល់ ជួប គឺសោយទុក្ខដែលកើតអំពីរងាពន់ពេក គឺអត់ធន់បានដោយក្រ ។

បទថា **ជានន្តី វត មំ ភោតិ** សេចក្ដីថា នៃបុណ្ណាដ៏ចម្រើន នាងក៏ដឹងថា ដោយការចុះងូតទឹកនេះ ខ្ញុំកំពុងធ្វើកុសលកម្មដែលអាចបិទ គឺអាចរារាំងនូវបាបកម្មដែលសន្សំទុកយូរបាន នៅសួរយើងឬហ្ន៎ ។

ព្រាហ្មណ៍កាលសម្ដែងថា សេចក្ដីនេះប្រាកដក្នុងលោកហើយ មិនមែនឬ សូម្បីយ៉ាងនោះ យើងក៏នឹងប្រាប់ដល់នាង ទើបពោលគាថាថា **យោ ច វុឌ្ឍោ** ជាដើម ។ គាថានោះមានសេចក្ដីថា បុគ្គលណាមួយ មិនថា ចាស់

ក្មេង ឬកណ្ដាល ប្រកប គឺធ្វើច្រើននូវបាបកម្ម មានបាណាតិបាត ជាដើម ជនទាំងនោះសូម្បីធ្វើបាបកម្មច្រើន ក៏រួចផុត គឺរួចផុតចាកបាបកម្មនោះដោយចំណែកមួយ ដោយការស្រោចទឹក គឺដោយការងូតទឹក ។

នាងបុណ្ណាស្ដាប់ពាក្យរបស់ព្រាហ្មណ៍នោះ កាលនឹងឆ្លើយដល់ព្រាហ្មណ៍នោះ ទើបពោលគាថាថា **កោ នុ តេ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **កោ នុ តេ ឥទមក្ខាសិ អជានន្តស្ស ជានកោ** សេចក្ដីថា នរណាហ្ន៎មិនដឹង អ្នកណាហ្ន៎មិនយល់ ជាអ្នកល្ងង់ខ្លៅ ព្រោះមិនដឹងវិបាករបស់កម្មដោយប្រការទាំងពួង មកប្រាប់ដល់លោក ដែលមិនដឹងវិបាករបស់កម្ម នូវរឿងនេះ គឺសេចក្ដីនេះថា បុគ្គលរមែងរួចផុតចាកបាបកម្មបាន ព្រោះហេតុដែលងូតទឹក បុគ្គលនោះ មានពាក្យមិនគួរជឿបានឡើយ អធិប្បាយថា ពាក្យនោះមិនត្រឹមត្រូវ ។

ឥឡូវនេះ នាងបុណ្ណា កាលចង្អុលបង្ហាញដល់ការមិនត្រឹមត្រូវនោះដល់ព្រាហ្មណ៍នោះ ទើបពោលគាថាថា **សគ្គំ នូន គមិស្សន្តិ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឆាគា** ប្រែថា ពស់ ។ បទថា **សុំសុមារា** ប្រែថា ក្រពើ ។ បទថា **យេ ចញ្ញេ ឧទកេ ចរា** សេចក្ដីថា សត្វដទៃទាំងឡាយណា រកស៊ីក្នុងទឹក មានត្រី មករ និងសត្វដែលនៅក្នុងទឹកជាដើម សត្វទាំងនោះប្រហែលជាទៅស្ថានសួគ៌ ចូលដល់ទេវលោកដោយពិត បើរួចផុតចាកបាប-កម្មបាន ព្រោះការងូតទឹកនោះ ។

បទថា **ឱរព្ភិកា** ប្រែថា អ្នកសម្លាប់ពពែ ។ បទថា **សូករិកា** ប្រែថា

អ្នកសម្លាប់ជ្រូក ។ បទថា **មច្ឆិកា** ប្រែថា អ្នកប្រមង់ ។ បទថា **មិគពន្ធកា** ប្រែថា ព្រានម្រឹគ ។ បទថា **វជ្ឈឃាតា** បានដល់ អ្នកមាននាទីសម្លាប់ គឺពេជ្ឈឃាត ។

បទថា **បុញ្ញម្បិមា វហេយ្យុំ** សេចក្ដីថា បើទឹកទាំងនោះ មានស្ទឹងអចិរវតីជាដើម គប្បីនាំទៅ គឺនាំចេញទៅនូវបាបដែលលោកធ្វើមកអំពីមុនដោយការចុះងូតទឹកក្នុងស្ទឹងទាំងនោះបានសោត ទឹកទាំងនោះ ក៏គប្បីបន្សាត់នូវបុណ្យដែលលោកធ្វើហើយ ក៏ដូច្នោះ លោកនឹងឆ្ងាយចាកបុញ្ញកម្មនោះ គឺបែបនោះ លោកក៏នឹងទទេចាកបុញ្ញកម្មនោះ អធិប្បាយថា ពាក្យនោះមិនត្រឹមត្រូវ ។ ម្យ៉ាងទៀត ការបន្សាត់នូវបុណ្យរបស់បុគ្គលដែលចុះទឹក ក៏រមែងមិនមានព្រោះទឹក យ៉ាងណា សូម្បីការបន្សាត់បាប ក៏រមែងមិនមានយ៉ាងនោះដូចគ្នា ព្រោះហេតុអ្វី ព្រោះការងូតទឹក មិនជាបដិបក្ខចំពោះហេតុនៃបាបទាំងឡាយ សភាវៈណា ធ្វើវត្ថុណាឲ្យវិនាស សភាវៈនោះក៏ជា បដិ-បក្ខចំពោះវត្ថុនោះ ។ ការភ្លឺស្វាងជាបដិបក្ខ ចំពោះងងឹត វិជ្ជា ជាបដិបក្ខចំពោះ អវិជ្ជា យ៉ាងណា ការងូតទឹក ក៏មិនជាបដិបក្ខចំពោះបាប ក៏យ៉ាងនោះ ព្រោះហេតុនោះ គប្បីបាននូវយុត្តិក្នុងរឿងនេះថា រួចផុតចាកបាបកម្មព្រោះការងូតទឹកមិនបានដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងខុទ្ទកនិកាយឧទាន ) ថា

បុគ្គល មិនមែនស្អាតព្រោះទឹកទេ អ្នកផងច្រើនគ្នារមែង
ងូតទឹកនោះដែរ សច្ចៈ ១ ធម្មៈ ១ ( មាននៅ ) ក្នុង

បុគ្គលណា បុគ្គលនោះទើបឈ្មោះថា ជាអ្នកស្អាតផង ឈ្មោះ
ថា ជាព្រាហ្មណ៍ផង ដូច្នេះ ។

ឥឡូវនេះ នាងបុណ្ណាទាសី ដើម្បីសម្តែងថា បើលោកត្រូវការបន្សាត់បាបសោត លោកកុំធ្វើបាបសព្វយ៉ាងឡើយ ទើបពោលគាថាថា **យស្ស ព្រាហ្មណា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **តមេវ ព្រហ្មេ មាកាសិ** សេចក្តីថា នែព្រាហ្មណ៍ លោកខ្លាចបាបណា លោកកុំធ្វើនោះឡើយ ដ្បិតថា ការចុះទឹកក្នុងរដូវរងានេះ បៀតបៀនរាងកាយតែម្យ៉ាងប៉ុណ្ណោះ ដោយហេតុនោះទើបនាងបុណ្ណាពោលថា **មាតេ សីតំ ឆវី ហានេ** អធិប្បាយថា រងាដែលកើតព្រោះការងូតទឹកក្នុងរដូវរងានេះ កុំប្រទូស្ត កុំបៀតបៀនទូវពណ៌សម្បុរនៃរាងកាយរបស់លោកឡើយ ។ បទថា **កុម្មគ្គបដិបន្នំ** បានដល់ខ្ញុំជាអ្នកដំណើរ គឺជាអ្នកដើរក្នុងផ្លូវខុស គឺប្រកាន់ខុសនេះ ។ បទថា **អរិយមគ្គំ សមានយិ** សេចក្តីថា លោកនាំ គឺបង្អោននាំមកដោយប្រពៃ កាន់ផ្លូវដែលព្រះអរិយទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់ធ្វើដំណើរមកហើយនេះថា ការមិនធ្វើបាបទាំងពួង ការធ្វើកុសលឲ្យដល់ព្រម ដូច្នេះជាដើមព្រោះហេតុនោះ នាងបុណ្ណាដ៏ចម្រើន ខ្ញុំសូមជូនសំពត់សាដកមួយនេះ ដល់នាងដោយសេចក្តីត្រេកអរ ជាចំណែកនៃការបូជាអាចារ្យ សូមនាងទទួលសំពត់សាដកនេះចុះ ។

នាងបុណ្ណានោះបដិសេធសំពត់នោះ តែដើម្បីនឹងពោលធម៌ ធ្វើព្រាហ្មណ៍ឲ្យតាំងនៅក្នុងសរណៈ និងសីល ទើបពោលថា សំពត់សាដក ចូរនៅជា

របស់អ្នកដដែលចុះ ខ្ញុំមិនត្រូវការសំពត់សាដកក ( របស់អ្នក ) ទេ ដូច្នេះ ហើយ ពោលបន្តថា បើអ្នកខ្លាចសេចក្តីទុក្ខ ដូច្នេះជាដើម ។ ពាក្យនោះ មានសេចក្តីថា បើលោកខ្លាចទុក្ខ មានការមិនផាសុក និងការមានឧបទ្រវជា ដើមក្នុងអបាយទាំងពួង និងក្នុងសុគតិ បើទុក្ខនោះមិនជាទីស្រឡាញ់ មិនជា ទីប្រាថ្នាសម្រាប់លោក លោកកុំធ្វើ កុំប្រកបកម្មអាក្រក់ សូម្បីមានប្រមាណ តិចតួច ដោយកម្ម មានបាណាតិបាត ជាដើម ផ្លូវកាយ វាចា ក្នុងទីវាល គឺធ្វើឲ្យបើកផ្សារដោយប្រាកដដល់មនុស្សដទៃ ឬដោយមនោកម្ម មានអភិជ្ឈា ជាដើម ក្នុងមនោទ្វារតែម្យ៉ាងក្នុងទីកំបាំង គឺធ្វើការបិទបាំង ដោយមិនប្រាកដ បើលោកធ្វើបាបកម្មនោះក្នុងអនាគត ឬកំពុងធ្វើក្នុងបច្ចុប្បន្ន ទោះលោកចង់ គេចទៅ ដោយបំណងថា កាលអញគេចទៅ ផ្លូវនេះ ផ្លូវនេះ ទុក្ខ ដែលជាផលនៃកម្មនោះក៏មិនជាប់តាមទៅក្នុងបាយ ៤ មាននរក និងមនុស្ស ជាដើម ឈ្មោះថា រួចផុតចាកបាបកម្មនោះមិនមានឡើយ អធិប្បាយថា កាល បច្ច័យដទៃ មានគតិនិងកាលជាដើមនៅប្រជុំគ្នា កម្មក៏រមែងឲ្យផលបានទាំង អស់ បាលីថា **ឧបច្ច** ក៏មាន សេចក្តីថា ហោះទៅ ។

នាងបុណ្ណា កាលសម្តែងនូវការមិនមានទុក្ខ ព្រោះមិនធ្វើបាបយ៉ាងនេះ ហើយ ឥឡូវនេះដើម្បីសម្តែងការមិនមានទុក្ខព្រោះការធ្វើបុណ្យ ទើបពោល ថា **សចេ ភាយសិ** ជាដើម បណ្តាបទទាំងនោះ បទថា **តាទិសំ** បានដល់ ដល់នូវភាពជាអ្នកមិនញាប់ញ័រក្នុងអារម្មណ៍ដែលឃើញហើយជាដើម ម្យ៉ាង ទៀត ប្រកបសេចក្តីថា សូមលោកចូលដល់ព្រះសម្មាសម្ពុទ្ធ ជាតាទិបុគ្គល អង្គនោះ ជាសរណៈ ព្រោះលោកគប្បីឃើញ ដូចព្រះសម្មាសម្ពុទ្ធអង្គមុនៗ

ទ្រង់ឃើញ ។ ក្នុងព្រះធម៌និងព្រះសង្ឃ ក៏មានន័យដូចគ្នា ប្រកបសេចក្ដីថា សូមចូលដល់ព្រះធម៌របស់ព្រះពុទ្ធដ៏ប្រសើរជាតាទិបុគ្គល និងដល់នូវពួកអរិយបុគ្គល ៨ ជាសរណៈ ។ បទថា **គតំ** បានដល់ ការដល់នូវសរណៈ និងការសមាទាននូវសីល ។ បទថា **ហោហិតិ** ប្រែថា ប្រព្រឹត្តទៅ ។

ព្រាហ្មណ៍នោះ តាំងនៅក្នុងសរណៈនិងសីលហើយ តមកស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា បាននូវសទ្ធា បួស ព្យាយាមមិនយូរប៉ុន្មាន ក៏ជាបុគ្គលមានវិជ្ជា ៣ ពិចារណាបដិបទារបស់ខ្លួន កាលនឹងឧទាន ទើបពោលគាថាថា **ព្រហ្មពន្ធុ** ជាដើម ។

គាថានោះមានសេចក្ដីថា ក្នុងកាលមុន ខ្ញុំមានឈ្មោះថា **ព្រហ្មពន្ធុ** ដោយហេតុត្រឹមតែកើតក្នុងត្រកូលព្រាហ្មណ៍ ខ្ញុំជាអ្នកមានត្រៃវិជ្ជា បរិបូណ៌ដោយវេទ ដោយហេតុត្រឹមតែរៀនជាដើម នូវត្រៃវេទ មានឥរុព្វេទជាដើម មានឈ្មោះថា ជាអ្នកមានសួស្ដី ជាអ្នកលាងបាប ឥឡូវនេះ ខ្ញុំជាព្រាហ្មណ៍ពិត គឺជាព្រាហ្មណ៍ដោយបរមត្ថ ព្រោះបន្សាត់នូវបាបបាន ដោយប្រការទាំងពួង ឈ្មោះថា **តេវិជ្ជោ** ព្រោះ សម្រេចវិជ្ជា ៣ ឈ្មោះថា **វេទសម្បន្នោ** ព្រោះប្រកបដោយវេទ ពោលគឺមគ្គញ្ញាណ និងឈ្មោះថា **ន្ហាតកោ** ព្រោះដកនូវបាបបានទាំងអស់ សូម្បីគាថានេះជាគាថាដែលព្រាហ្មណ៍ពោល ក្រោយមកព្រះថេរីពោលដដែលទៀត ព្រោះហេតុនោះ ទើបឈ្មោះថា ថេរីគាថាទាំងអស់ ។

អដ្ឋកថាបុណ្ណាថេរីគាថា ចប់

ថេរីគាថា សោឡសកនិបាត ចប់

# ថេរីគាថា វីសតិនិបាត

## អម្ពបាលីថេរីគាថា

[ ៣៣១ ] កាលពីដើមសក់របស់ខ្ញុំ មានចុងង មានពណ៌ខ្មៅ ប្រាកដស្មើដោយពណ៌នៃស្មាបកខ្មួង ឥឡូវនេះសក់ទាំងឡាយនោះប្រាកដស្មើដោយសម្បកធ្មៃ និងសម្បកក្រចៅព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ( កាលពីដើម ) សំណុំសក់របស់ខ្ញុំ ពេញដោយផ្កា ហាក់ដូចជាប្រអប់ដាក់គ្រឿងក្រអូប ដែលគេអប់ ( ឥឡូវនេះ ) សំណុំសក់នោះ មានក្លិនដូចជាក្លិននៃរោមទន្សាយ ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ( កាលពីដើម ) សក់របស់ខ្ញុំវិចិត្រដោយក្រាសនិងស្នៀតសក់ ល្អលើសលុប ដូចជាព្រៃឫស្សីដុះស្អាប់ល្អ ( ឥឡូវនេះ ) សក់នោះ ល្បោះរង្វើលក្នុងសីស:ប្រទេសនោះៗព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ( កាលពីដើមសក់របស់ខ្ញុំ ) ល្អិតមានក្លិនក្រអូប ស្អិតស្អាងដោយក្រាសមាស ប្រដាប់ដោយផ្នួងទាំងឡាយដ៏ល្អត្រកាល ( ឥឡូវនេះ ) សក់នោះថ្ពកព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ( កាលពីដើម ) ចិញ្ចើមទាំងឡាយរបស់ខ្ញុំស្អាតល្អ ដូចជាគំនូសដែលជាងរចនាល្អ ( ឥឡូវនេះ ) ចិញ្ចើមទាំងនោះយុរយារ ដោយអាការជ្រួញជ្រីវព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។

( កាលពីដើម ) ក្អែកទាំងឡាយ មានសម្បុរថ្លា ខៀវស្រងាត់ រុងរឿង ល្អ ក្រឡង់ដូចជាកែវមណី ( ឥឡូវនេះ ) ក្អែកទាំងនោះ ត្រូវជរាញាំញី ក៏ប្រែជាមិនល្អ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ប្រមុះ ( របស់ខ្ញុំ ) ប្រាកដស្មើដោយដំបារមាស ដែលគេមូរដ៏ល្អ ល្អក្នុងកាលនៃខ្លួននៅក្រមុំ ( ឥឡូវនេះ ) ប្រមុះនោះ ហាក់ដូចជាទ្រុឌទ្រោម ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ស្លឹកត្រចៀកទាំងឡាយរបស់ខ្ញុំល្អ ហាក់ដូចជាដំបារមាស ដែលជាងធ្វើល្អហើយដែលសម្រេចហើយដោយប្រពៃ ( ឥឡូវនេះ ) ស្លឹកត្រចៀកទាំងនោះ យុរយារដោយអាការជ្រួញជ្រីវ ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ( កាលពីដើម ) ធ្មេញទាំងឡាយរបស់ខ្ញុំល្អណាស់ ប្រាកដស្មើដោយពណ៌នៃផ្កាប្រទៀងក្រពុំ ( ឥឡូវនេះ ) ធ្មេញទាំងនោះបាក់ មានពណ៌លឿងដូចជាស្រូវដំណើប ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ( កាលពីដើម ) សម្តីដែលខ្ញុំនិយាយពីរោះ ដូចជាសម្តីមេតាវៅ ដែលហើរទៅកាន់ព្រៃស្រោង ក្នុងព្រៃ ( ឥឡូវនេះ ) សម្តីនោះ ស្អកស្អា ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ករបស់ខ្ញុំល្អ ដូចជាស័ង្ខមាស ដែលជាងខាត់ហើយដោយល្អ ( ឥឡូវនេះ ) កនោះបាក់ឱនព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យ

ពិតមិនប្រែប្រួល ។ កាលពីដើម ដើមដៃទាំងពីររបស់ខ្ញុំ ល្អដូចជាសសរខឿនដែលជាងលញ់ហើយ ( ឥឡូវនេះ ) ដើមដៃទាំងនោះ ដូចជាស័ង្ខបែកហើយព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ដៃទាំងឡាយរបស់ខ្ញុំ មានចិញ្ចៀនល្អ ប្រដាប់ដោយមាស សមរម្យល្អ ( ឥឡូវនេះ ) ដៃទាំងនោះ ដូចជាដើមដំឡូង យារ ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ដោះទាំងពីររបស់ខ្ញុំ ពេញលេញមូលក្បំកៀកគ្នា មានសណ្ឋានដ៏ត្រង់ល្អណាស់ ( ឥឡូវនេះដោះទាំងនោះ ) មិនមានទឹក ( ជ្រាយ ) បាក់សំយុងចុះ ដូចជាបំពង់ទឹក ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើមកាយរបស់ខ្ញុំល្អស្រស់ដូចជាផែនក្តារមាសដែលគេខាត់ហើយដោយប្រពៃ ( ឥឡូវនេះ ) កាយនោះប្រែប្រួលដោយអាការជ្រួញជ្រីវដ៏ល្អិត ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ភ្លៅទាំងពីររបស់ខ្ញុំល្អល្អះ ដូចជាប្រមោយនៃដំរីដ៏ប្រសើរ ( ឥឡូវនេះ ) ភ្លៅទាំងនោះដូចជាថ្នាំងឫស្សីព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ស្មងទាំងឡាយរបស់ខ្ញុំប្រដាប់ដោយស្រោមជាវិការៈនៃមាស ដែលគេប៉ាក់ជិតស្និទ្ធល្អណាស់ ( ឥឡូវនេះ ) ស្មងទាំងនោះ ដូចជាដើមល្ង ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ជើងទាំងពីរ

របស់ខ្ញុំល្អដូចជាទ្រនាប់ជើងដែលគេញាត់ហើយដោយប៉ុយរកា ( ឥឡូវនេះ ) ជើងទាំងនោះ ប្រេះបែកជ្រួញជ្រីវព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ គ្រោងកាយមានសភាពដូច្នេះនេះ គ្រាំគ្រា ជាលំនៅនៃសេចក្តីទុក្ខច្រើនប្រការ គ្រោងកាយនេះ ដូចជាផ្ទះចាស់ដែលមានគ្រឿងបូកលាបជ្រុះចុះ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

**អម្ពបាលីថេរី ។**

# អដ្ឋកថា

# ថេរីគាថា វីសតិនិបាត

## អម្ពបាលីថេរីគាថា

[ ៣៣១ ] ក្នុងវីសតិនិបាត គាថារបស់ព្រះនាងអម្ពបាលីថេរី មានពាក្យផ្តើមថា **កាឡកា ភមរវណ្ណសទិសា** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា សិខី បព្វជ្ជា ឧបសម្បទា សមាទានសិក្ខាបទរបស់ភិក្ខុនី ។ ថ្ងៃមួយ ថ្វាយបង្គំព្រះចេតិយ

ធ្វើប្រទក្សិណមួយអន្ទើដោយភិក្ខុនីជាច្រើន កាលព្រះខីណាស្រវថេរីនិមន្តទៅមុន ជ្រលស្តោះទឹកមាត់ ទឹកមាត់ក៏ធ្លាក់ទៅលានព្រះចេតិយ ដោយកម្ចាំងនៃការស្តោះ ( ក្អក ) ព្រះខីណាស្រវថេរីមិនឃើញក៏និមន្តទៅ ភិក្ខុនីរូបនេះដើរអំពីខាងក្រោយ ឃើញទឹកមាត់នោះ ក៏ជេរថា មេពេស្យា មួយណាស្តោះទឹកមាត់ត្រង់ទីនេះ ។ កុលធីតារូបនេះ រក្សាសីលក្នុងកាលជាភិក្ខុនី ខ្ពើមការចូលទៅក្នុងគភ៌ តាំងចិត្តទុកក្នុងអត្តភាពជាឧបបាតិកៈ ។ ដោយការតាំងចិត្តនោះ ក្នុងអត្តភាពចុងក្រោយ កុលធីតារូបនេះ ក៏ជាឧបបាតិកកំណើត កើតត្រង់គល់ស្វាយ ក្នុងព្រះរាជឧទ្យាន ក្រុងវេសាលី ។ ភ្នាក់ងាររក្សាឧទ្យានបានឃើញស្ត្រីនោះ ក៏នាំចូលទៅកាន់ព្រះនគរ ។ ព្រោះនាងកើតត្រង់គល់ស្វាយ ទើបគេឲ្យឈ្មោះថា អម្ពបាលី ។ កាលនោះ ពួក ព្រះរាជកុមារច្រើនអង្គឃើញនាងស្អាត គួរសរសើរ គួរជ្រះថ្លា មានទូវគុណសម្បត្តិវិសេសក្នុងការរាំច្រៀង ជាដើម ក៏នាំគ្នាប្រាថ្នាមកធ្វើជាគូគ្រងរៀងៗខ្លួន ដើម្បីរម្ងាប់នូវវិវាទរបស់ព្រះរាជកុមារទាំងនោះ ពួកចៅក្រមត្រូវកម្មរបស់នាងជាស់តៀនទើបតាំងនាងទុកក្នុងតំណែងជាស្រីគណិកា ( ស្រីរបស់គណៈ ) ថា នាងចូរជារបស់មនុស្សគ្រប់គ្នា ។ នាងមានសទ្ធាក្នុងព្រះសាស្តា សាងវិហារទុកក្នុងចម្ការរបស់ខ្លួន វេរថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ក្រោយមកស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះវិមលកោណ្ឌញ្ញត្ថេរ ដែលជាកូនរបស់ខ្លួន ក៏បួសចម្រើនវិបស្សនា អាស្រ័យភាពដែលសរីរៈរបស់ខ្លួនទ្រុឌទ្រោមថមថយព្រោះជរា ក៏កើតសេចក្តីសង្វេគ កាលចង្អុលបង្ហាញដល់ភាពដែលសង្ខារមិន

ទៀង ទើបពោលគាថាទាំងនេះថា

កាលពីដើមសក់របស់ខ្ញុំ មានចុងង មានពណ៌ខ្មៅ ប្រាកដស្មើដោយពណ៌នៃស្វាបកន្ទង់ ឥឡូវនេះ សក់ទាំងឡាយនោះប្រាកដស្មើដោយសម្បកធ្មៃនិងសម្បកក្រចៅព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ( កាលពីដើម ) សំណុំសក់របស់ខ្ញុំ ពេញដោយផ្កា ហាក់ដូចជាប្រអប់ដាក់គ្រឿងក្រអូប ដែលគេអប់ ( ឥឡូវនេះ ) សំណុំសក់នោះមានក្លិនដូចជាក្លិននៃរោមទន្សាយព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ( កាលពីដើម ) សក់របស់ខ្ញុំវិចិត្រដោយក្រាសនិងស្នៀតសក់ ល្អលើសលុប ដូចជាព្រៃឫស្សីដុះស្អាប់ល្អ ( ឥឡូវនេះ ) សក់នោះ ល្បោះរង្វើលក្នុងសីសៈប្រទេសនោះៗព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ( កាលពីដើមសក់របស់ខ្ញុំ ) ល្អិត មានក្លិនក្រអូប ស្អិតស្អាងដោយក្រាសមាស ប្រដាប់ដោយផ្នួងទាំងឡាយដ៏ល្អត្រកាល ( ឥឡូវនេះ ) សក់នោះថ្ពកព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ( កាលពីដើម ) ចិញ្ចើមទាំងឡាយរបស់ខ្ញុំស្អាតល្អ ដូចជាគំនូសដែល

ជាងរចនាល្អ ( ឥឡូវនេះ ) ចិញ្ចើមទាំងនោះយុរយារដោយអាការជ្រួញជ្រីវព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ( កាលពីដើម ) ភ្នែកទាំងឡាយ មានសម្បុរថ្លា ខៀវស្រងាត់ រុងរឿង ល្អក្រឡង់ដូចជាកែវមណី ( ឥឡូវនេះ ) ភ្នែកទាំងនោះ ត្រូវជរាញាំញី ក៏ប្រែជាមិនល្អ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ ច្រមុះ ( របស់ខ្ញុំ ) ប្រាកដស្មើដោយដំបារមាស ដែលគេមូរដ៏ល្អ ល្អក្នុងកាលនៃខ្លួននៅក្រមុំ ( ឥឡូវនេះ ) ច្រមុះនោះហាក់ដូចជាទ្រុឌទ្រោមព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ស្លឹកត្រចៀកទាំងឡាយរបស់ខ្ញុំល្អ ហាក់ដូចជាដំបារមាសដែលជាងធ្វើល្អហើយដែលសម្រេចហើយដោយប្រពៃ ( ឥឡូវនេះ ) ស្លឹកត្រចៀកទាំងនោះ យុរយារដោយអាការជ្រួញជ្រីវព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ( កាលពីដើម ) ធ្មេញទាំងឡាយរបស់ខ្ញុំល្អណាស់ប្រាកដស្មើដោយពណ៌នៃផ្កាប្រទៀងក្រពុំ ( ឥឡូវនេះ ) ធ្មេញទាំងនោះបាក់ មានពណ៌លឿងដូចជាស្រូវដំណើប ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យ

ពិតមិនប្រែប្រួល ។ ( កាលពីដើម ) សម្តីដែលខ្ញុំនិយាយ ពីរោះដូចជាសម្តីមេតាវៅ ដែលហើរទៅកាន់ព្រៃស្រោង ក្នុងព្រៃ ( ឥឡូវនេះ ) សម្តីនោះ ស្អកស្អាព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើមករបស់ខ្ញុំល្អដូចជាស័ង្ខមាស ដែលជាងខាត់ហើយដោយល្អ ( ឥឡូវនេះ ) កនោះបាក់ឱនព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ដើមដៃទាំងពីររបស់ខ្ញុំ ល្អដូចជាសសរខឿនដែលជាងលញ់ហើយ ( ឥឡូវនេះ ) ដើមដៃទាំងនោះ ដូចជាស័ង្ខបែកហើយព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ដៃទាំងឡាយរបស់ខ្ញុំ មានចិញ្ចៀនល្អ ប្រដាប់ដោយមាស សមរម្យល្អ ( ឥឡូវនេះ ) ដៃទាំងនោះដូចជាដើមដំឡូង យារ ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ដោះទាំងពីររបស់ខ្ញុំ ពេញលេញ មូលក្បំកៀកគ្នា មានសណ្ឋានដ៏ត្រង់ល្អណាស់ ( ឥឡូវនេះដោះទាំងនោះ ) មិនមានទឹក ( ជ្រាយ ) បាក់សំយុងចុះ ដូចជាបំពង់ទឹក ព្រះពុទ្ធដីការបស់ ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិន

ប្រែប្រួល ។ កាលពីដើមកាយ របស់ខ្ញុំល្អស្រស់ដូចជាផែន ក្តារមាសដែលគេខាត់ហើយដោយប្រពៃ ( ឥឡូវនេះ ) កាយ នោះប្រែប្រួលដោយអាការជ្រួញជ្រីវដ៏ល្អិត ព្រះពុទ្ធដីការបស់ ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ភ្លៅទាំងពីររបស់ខ្ញុំល្អល្អះ ដូចជាប្រមោយនៃដំរី ដ៏ប្រសើរ ( ឥឡូវនេះ ) ភ្លៅទាំងនោះដូចជាថ្នាំងឫស្សីព្រោះ តែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះ អង្គពោលនូវ ពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ស្មងទាំងឡាយរបស់ ខ្ញុំប្រដាប់ដោយស្រោមជាវិការៈនៃមាស ដែលគេប៉ាក់ជិតស្និទ្ធ ល្អណាស់ ( ឥឡូវនេះ ) ស្មងទាំងនោះ ដូចជាដើមល្ងព្រោះ តែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវ ពាក្យពិតមិនប្រែប្រួល ។ កាលពីដើម ជើងទាំងពីររបស់ខ្ញុំ ល្អដូចជាទ្រនាប់ជើង ដែលគេញាត់ហើយ ដោយប៉ុយរកា ( ឥឡូវនេះ ) ជើងទាំងនោះ ប្រេះបែកជ្រួញជ្រីវព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ គ្រោងកាយមានសភាពដូច្នេះនេះ គ្រាំគ្រា ជាលំនៅនៃសេចក្តីទុក្ខច្រើនប្រការ គ្រោងកាយនេះ ដូចជាផ្ទះ ចាស់ដែលមានគ្រឿងបូកលាបជ្រុះចុះ ព្រះពុទ្ធដីការបស់ព្រះ សម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាឡកា** ប្រែថា មានពណ៌ខ្មៅ ។ បទថា **ភមរវណ្ណសទិសា** សេចក្ដីថា សក់សូម្បីពណ៌ខ្មៅក៏មានពណ៌ដូចស្លាបកំភេម គឺពណ៌ខៀវស្រស់ ។ បទថា **វេល្លិតគ្គា** ប្រែថា មានចុងង អធិប្បាយថា មានចុងបះឡើង ។ បទថា **មុទ្ធជា** ប្រែថា សក់ ។ បទថា **ជរាយ** បានដល់ ព្រោះជរាជាហេតុ គឺព្រោះការស្អាតដែលត្រូវជរាបំផ្លាញហើយ ។ បទថា **សាណវាកសទិសា** បានដល់ ដូចក្រចៅ ដូចធ្មៃ សេចក្ដីថា ដូចសម្បកក្រចៅនិងដូចសម្បកធ្មៃ ដូច្នេះ ។ បទថា **សច្ចវាទិវចនំ អនញ្ញថា** សេចក្ដីថា ព្រះតម្រាស់ជាដើមថា រូបទាំងពួងមិនទៀង ត្រូវជរាគ្របសង្កត់ របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សេចក្ដីពិត គឺត្រាស់មិនជាពាក្យដទៃ ជាពាក្យមិនប្រែប្រួលទៅជាដទៃ គឺជាពាក្យពិតតែម្យ៉ាង ការមិនពិតមិនមានក្នុងព្រះតម្រាស់នោះ ។

បទថា **វាសិតោវ សុរភី ករណ្ឌកោ** សេចក្ដីថា សក់មានក្លិនក្រអូប ដូចជន្ទាប់ដាក់គ្រឿងប្រដាប់ដែលអប់ឲ្យមានក្លិនដោយផ្កានិងគ្រឿងក្រអូប ជាដើម ។ បទថា **បុប្ផបូរ មម ឧត្តមង្គភូតោ** សេចក្ដីថា ក្នុងកាលមុន ផ្នួងសក់របស់ខ្ញុំមិនមានមន្ទិល ពេញដោយផ្កា មានផ្កាចម្បា ផ្កាម្លិះជាដើម ។ បទថា **តំ** បានដល់ វត្ថុដែលកើតលើក្បាល គឺសក់ ។ ក្រោយមក គឺឥឡូវនេះ ប្រែជាមានក្លិន ដូចរោមតាមប្រក្រតី គឺក្លាយជាមានក្លិន ដូចរោមតាមប្រក្រតី ។ ន័យម្យ៉ាងទៀត បទថា **សលោមគន្ធិកំ**(១) បានដល់ មានក្លិនស្មើ

---

១-បិដកខ្មែរជា សសលោមគន្ធិកំ ទើបលោកប្រែថា មានក្លិនដូចរោមទន្សាយ តែក្នុងអដ្ឋកថាជា សលោមគន្ធិកំ ទើបប្រែថា មានក្លិនដូចរោមប្រក្រតី ។

*ដោយរោមពពែ អាចារ្យពួកខ្លះពោលថា មានក្លិនដូចរោមចៀមក៏មាន ។*

*បទថា* **កាននំវ សហិតំ សុរោបិតំ** *សេចក្ដីថា ដូចព្រៃក្រាស់ដែលមានដើមឈើ មានមែកឈើត្រង់និងវែង លូតឡើងទៅលើដែលគេដាំទុកល្អជិតគ្នានិងក្រាស់ ។ បទថា* **កោច្ចស្ចិរិចិតគ្គសោភិតំ** *សេចក្ដីថា កាលមុនសក់មានចុងរួបរួមគ្នា ដោយការសិតនិងចងដោយកម្រងមាសល្អវិចិត្រ ឬដូចធ្មេញស្និតព្រោះក្រាស់ ឈ្មោះថា* **សោភិតំ** *ព្រោះមានចុងប្រដាប់ដោយស្នៀតប្រាក់ ញែកជាចំរៀក ។ បទថា* **តំ** *បានដល់ សក់ ។ បទថា* **វិរលំ តហឹ តហឹ** *បានដល់ ដែលស្តើង គឺសក់ជ្រុះក្នុងទីនោះៗ ។ បទថា* **កណ្ហខន្ធកំ សុវណ្ណមណ្ឌិតំ** *បានដល់ សំណុំនៃសក់ខ្មៅ ប្រដាប់ដោយគ្រឿងតាក់តែង មានមាសនិងពេជ្រជាដើម ។ តែអាចារ្យពួកណាពោលថា ប្រដាប់ដោយស្នៀតមាសដ៏ល្អ និងមានក្លិនក្រអូប ពាក្យរបស់អាចារ្យទាំងនោះ មានអធិប្បាយថា ប្រដាប់ដោយផ្នួងសក់ដែលដោតដោយស្នៀតមាសដ៏ល្អ ។ បទថា* **សោភតេ សុវេណីហិលង្កតំ** *សេចក្ដីថា ក្នុងកាលមុន ប្រដាប់ដោយផ្នួងសក់ ដែលដូចគ្នានឹងកម្រងផ្កាពជព្រឹក្សដ៏ល្អ និងមានពន្លឺ ។ បទថា* **តំ ជរាយ ខលិតំ សិរំ កតំ** *សេចក្ដីថា ក្បាលដ៏ល្អបែបនេះ ឥឡូវនេះ ត្រូវជរាធ្វើឲ្យប្រែប្រួល គឺធ្វើឲ្យសក់ជ្រុះ ថ្ពកជាអន្ទើៗ ។ បទថា* **ចិត្តការសុកតាវ លេខិកា** *សេចក្ដីថា ក្នុងកាលមុន ចិញ្ចើមរបស់ខ្ញុំដូចគំនូរដែលវិចិត្រករផ្ចិតផ្ចង់ដោយពណ៌ខៀវ ។ បទថា* **សោភតេ សុ ភមុកា បុរេ មម** *សេចក្ដីថា ក្នុងកាលមុន ចិញ្ចើមដែលស្អាតរបស់ខ្ញុំរាប់ថាជាចិញ្ចើមស្អាតពិតៗ ។*

បទថា **វលីហិ បលម្ពិតា** បានដល់ យុរយារចុះ ព្រោះស្នាមជ្រួញដែលកើតត្រង់ថ្ពាស ។

បទថា **ភស្សរា** ប្រែថា មានពន្លឺ ។ បទថា **សុរុចិរា** ប្រែថា ស្អាតល្អ ។ បទថា **យថា មណិ** ប្រែថា ដូចកញ្ចក់កែវមណី ។ បទថា **នេត្តា-ហេសុំ** ប្រែថា បានជាភ្នែកដែលល្អ ។ បទថា **អភិនីលមាយតា** ប្រែថា មានពណ៌ខៀវមូលទូលាយ ។ បទថា **តេ** បានដល់ កែវភ្នែក ។ បទថា **ជរាយភិហតា** កាន់បទជា **ជរាយ អភិហតា** ប្រែថា ដែលជរាទម្លាយហើយ ។

បទថា **សណ្ហតុង្គសទិសី** ច បានដល់ ខ្ពស់ល្អ និងទទួលជាមួយចំណែកនៃទម្រង់មុខនិងអវយវៈដទៃ ។ បទថា **សោភតេ** សេចក្តីថា ច្រមុះរបស់ខ្ញុំល្អដូចដំបារហែរគោលដែលគេយកមកបិទ ។ បទថា **សុ អភិយោព្វនំ បតិ** សេចក្តីថា ច្រមុះក្នុងវ័យក្មេងដែលល្អនោះ ឥឡូវនេះ ហាក់ដូចជាស្រុតចុះ គឺមិនតាំងនៅព្រោះជរាឃាត់នូវភាពស្អាត ។

ដោយបទថា **កង្កណំវ សុកតំ សុនិដ្ឋិតំ** ជាដើម ព្រះនាងអម្ពបាលីថេរីពោលសំដៅដល់ការមូលក្បាំ ហាក់ដូចគ្រឿងប្រដាប់ដៃធ្វើអំពីមាសដែលជាងធ្វើយ៉ាងល្អ ។ បទថា **សោភតេ** ប្រែថា ល្អ បាលីថា **សោភន្តេ** ក៏មាន ។ ពាក្យថា **សុ** ត្រឹមតែជានិបាត ។ បទថា **កណ្ណាចាឡិយោ** ប្រែថា ស្លឹកត្រចៀក ។ បទថា **វលិភិប្បលម្ពិតា** សេចក្តីថា យារធ្លាក់ ព្រោះការជ្រីវជ្រួញកើតឡើងក្នុងទីនោះៗ ដូចកំណាត់សំពត់ដែលត្រូវមូរធ្លាក់សំយុងចុះ ។

បទថា **បត្តលិមក្កុលវណ្ណសទិសា** បានដល់ ធ្មេញដែលមានពណ៌និង សណ្ឋាន ដូចពន្លកកូនចេក ។ បទថា **ខណ្ឌិតា** បានដល់ បាក់ គឺដល់នូវ ការបាក់ រង្គោះរង្គើ ។ បទថា **អសិតា** បានដល់ ដល់នូវភាពជាពណ៌លឿង ព្រោះពណ៌ប្រែប្រួលទៅ ។

បទថា **កាននម្ហិ វនសណ្ឌចារិនី កោកិលាវ មធុរំ និក្កូជិហំ** សេចក្តីថា បន្លឺសំឡេងចរចាពីរោះ ដូចសត្វតាវៅ ត្រាច់រកអាហារក្នុងព្រៃ ទំគ្រង់មែកឈើ ស្រែកយំល្វេងល្វើយក្នុងព្រៃ ។ បទថា **តំ** បានដល់ និយាយចរចាគឺសំឡេងនោះ ។ បទថា **ខលិតំ តហឹ តហឹ** បានដល់ និយាយខុសភ្លាំងភ្លាត់ទៅក្នុងទីនោះៗ ព្រោះមានធ្មេញបាក់ជាដើម ។

បទថា **សណ្ហកម្ពុរិវ សុប្បមដ្ឋិតា** បានដល់ មានកមូលដូចស័ង្ខមាស ដែលគេខាត់យ៉ាងល្អ ។ បទថា **សា ជរាយ ភគ្គា វិនាមិតា** សេចក្តីថា កក៏ឱនចុះ ព្រោះជរាប្រាកដអំពីការដែលសាច់អស់ទៅ ។ បទថា **វដ្ដបលិឃសទិសោបមា** បានដល់ ប្រៀបដូចបង្កង់ដែលកោង ។ បទថា **តា** បានដល់ ដៃទាំង ២ នោះ ។ បទថា **ចាដលិប្បលិតា** បានដល់ ដូចមែកប្រទៀងដែលកោង ព្រោះភាពជរា ។

បទថា **សណ្ហមុទ្ទិកសុវណ្ណមណ្ឌិតា** បានដល់ ប្រដាប់ដោយចិញ្ចៀនដ៏រលោងដែលធ្វើដោយមាស ។ បទថា **យថា មូលមូលិកា** ប្រែថា ដូចមើមដំឡូង ។ បទថា **បីនវដ្ដសហិតុគ្គតា** បានដល់ មូលក្បំ កៀកគ្នាមាន សណ្ឋានត្រង់ល្អ ។ បទថា **សោភតេ សុ ថនកា បុរេ មម** សេចក្តីថា

ដោះទាំងគូរបស់ខ្ញុំ មានសភាពតាមដែលពោលហើយ ល្អដូចដន្ទាប់មាស ។ ពិតហើយ ពាក្យនេះជាឯកវចនៈចុះក្នុងអត្ថពហុវចនៈ ជាពាក្យបច្ចុប្បន្នកាលចុះក្នុងអត្ថអតីតកាល ។ បទថា **ថេវិកីវ លម្ពន្តិ នោទកា** សេចក្តីថា ស្តនរបស់ខ្ញុំទាំងគូនោះយារធ្លាក់ ដូចថង់ទឹកដែលមិនមានទឹក ដែលគេផឹកទឹកអស់ហើយ ព្យួរត្រង់កំណាត់ឫស្សី ។

បទថា **កញ្ចនស្ស ផលកំវ សុមដ្ឋំ** សេចក្តីថា រាងកាយរបស់ខ្ញុំដូចដំបារមាសដែលជាងយកជាតិហិង្គុលលាបហើយ ខាត់អស់កាលយូរ ។ បទថា **សោ វលីហិ សុខុមាហិ ឱតតោ** សេចក្តីថា រាងកាយរបស់ខ្ញុំនោះឥឡូវនេះក៏ទន់ជ្រាយ គឺស្បែកយុរយារក្នុងទីផ្សេងៗ ដោយស្នាមដែលជ្រីវជ្រួញ ។

បទថា **នាគភោគសន្និភោបមា** បានដល់ ប្រៀបដូចប្រមោយដំរីនៃស្តេចដំរី ដៃក្នុងទីនេះ លោកហៅថា ភោគៈ ប្រែថា ប្រមោយ ព្រោះជាគ្រឿងចាប់របស់យកមកបរិភោគ ។ បទថា **តេ** បានដល់ ភ្លៅទាំង ២ ។ បទថា **យថា វេឡុនាឡិយោ** សេចក្តីថា ឥឡូវនេះ ដូចជាបំពង់ឫស្សី ។

បទថា **សណ្ហនូបុរសុវណ្ណមណ្ឌិតា** សេចក្តីថា ប្រដាប់ដោយគ្រឿងប្រដាប់ជើងធ្វើអំពីមាសដ៏រលោង ។ បទថា **ជង្ឃា** បានដល់ ស្មង ។ បទថា **តា** បានដល់ ស្មងទាំងនោះ ។ បទថា **តិលទណ្ឌការិវ** សេចក្តីថា ដូចជាដើមល្ងក្រៀមដែលបាក់ ព្រោះស្គម គឺមានសាច់និងឈាមតិច ។ **រ** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ ។

បទថា **តូលបុណ្ណសន្និភោបមា** បានដល់ ដូចស្បែកជើងដែលញាត់

ដោយសំឡីរកា ព្រោះជារបស់ទន់ ។ ជើងទាំង ២ របស់ខ្ញុំនោះ ឥឡូវនេះ ប៉ះអ្វីក៏ប្រេះបែកកើតជាស្នាម ។

បទថា **ឯធិសោ** ប្រែថា បែបនេះ ។ រាងកាយមានសភាពដោយប្រការតាមដែលពោលមកហើយ ។ បទថា **អយំ សមុស្សយោ** បានដល់ រាងកាយរបស់ខ្ញុំនេះ ។ បទថា **ជជ្ជរោ** បានដល់ នៅជាមួយភាពទុព្វល ។ បទថា **ពហុទុក្ខានមាលយោ** បានដល់ ជាលំនៅនៃទុក្ខទាំងឡាយដ៏ច្រើនដែលមានជរាជាដើមជាហេតុ ។ បទថា **សោបលេបបតិតោ** សេចក្ដីថា រាងកាយនេះធ្លាក់ចេញអំពីគ្រឿងលាប ទ្រុឌទ្រោមទៅ ព្រោះអស់នូវគ្រឿងតាក់តែង មានតែបែរមុខធ្លាក់ទៅ ម្យ៉ាងទៀត កាត់បទថា **សោបិ អលេបបតិ-តោ** ក៏បាន ឯអត្ថក៏ដូចគ្នា ។ បទថា **ជរាឃរោ** បានដល់ ដូចជាផ្ទះដែលគ្រាំគ្រា ឬជាផ្ទះនៃជរា ព្រោះហេតុនោះ ព្រះតម្រាស់របស់ព្រះសាស្ដា ទើបជាសច្ចវាចារបស់លោកអ្នកដែលជាសច្ចវាទី ត្រាស់តែសេចក្ដីពិត ព្រោះទ្រង់ជ្រាបសភាវៈតាមសេចក្ដីពិតរបស់ធម៌ទាំងឡាយ ដោយប្រពៃហើយ ទើបទ្រង់ត្រាស់ ព្រះតម្រាស់នោះមិនប្រែប្រួលទៅជាដទៃឡើយ ។

ព្រះថេរីនេះ ពិចារណានូវអនិច្ចតាក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ដោយគោល គឺលក្ខណៈដែលពិតនៃការមិនទៀងក្នុងអត្តភាពរបស់ខ្លួន យ៉ាងនេះហើយ លើកឡើងកាន់ទុក្ខលក្ខណៈនិងអនត្តលក្ខណៈ ក្នុងអត្តភាពរបស់ខ្លួននោះ តាមគន្លងអនិច្ចលក្ខណៈនោះ ខ្នះខ្នែងចម្រើនវិបស្សនា ក៏សម្រេចអរហត្តដោយលំដាប់មគ្គ ។ សមដូចគាថាព័ន្ធ ដែលលោកពោលទុកក្នុងអប

ទានថា

ព្រះមហាមុនី ព្រះនាមផុស្សៈណា មានជួរនៃរស្មីដ៏រុងរឿង ខ្ញុំបានកើតក្នុងខត្តិយត្រកូល ជាប្អូនស្រីនៃព្រះមហាមុនីនោះ ។ ខ្ញុំបានស្តាប់ព្រះធម៌នៃព្រះមហាមុនីនោះហើយ មានចិត្តជ្រះថ្លា បានថ្វាយមហាទានហើយ ប្រាថ្នានូវរូបសម្បត្តិ ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រះជិនស្រីព្រះនាមសិខី ជានាយកដ៏ប្រសើរក្នុងលោក ជាពន្លឺនៃលោក ជាទីពឹងនៃត្រៃភពកើតឡើង ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលនៃព្រាហ្មណ៍ ក្នុងអរុណបុរី ជាទីក្រុងរីករាយ បានទីងជេរផ្តាសាភិក្ខុនី ដែលមានចិត្តរួចស្រឡះចាកកិលេសហើយ ។ មួយទៀត ខ្ញុំបានកើតជាស្រីផ្កាមាស ឥតមានអាចារៈ ជាអ្នកប្រទូស្តចំពោះសាសនានៃព្រះជិនស្រីសម្ពុទ្ធ បានជេរភិក្ខុនីតាមទំនងដូចគ្នា ព្រោះតែបាបកម្មនោះឯង ខ្ញុំបានទៅកើតក្នុងនរក ដ៏អាក្រក់ ឆ្អែតឆ្អល់ដោយសេចក្តីទុក្ខយ៉ាងខ្លាំង លុះខ្ញុំរួចចាកនរកនោះ បានមកកើតក្នុងមនុស្ស ជាស្រីមានតបៈ ។ ខ្ញុំកើតជាស្រី ផ្កាមាសអស់ ១០ ពាន់ជាតិ ខ្ញុំមិនរួចចាកបាបនោះទេ ដូចបុគ្គលបរិភោគថ្នាំពិសដ៏កាចអាក្រក់ ។ ខ្ញុំបានសេពគប់នូវភេទដ៏ប្រសើរកើតក្នុងសាសនានៃព្រះជិនស្រី ព្រះនាមកស្សបៈ ដោយអំណាចនៃផលកម្មនោះ ខ្ញុំបានទៅកើតក្នុងបុរីឋានត្រៃត្រឹង្ស ។

លុះមកដល់បច្ឆិមភព ខ្ញុំជាឱបបាតិកៈកំណើត បានកើតក្នុង ចន្លោះនៃមែកស្វាយ ព្រោះហេតុនោះ បានជាខ្ញុំឈ្មោះថាអម្ព- បាលី ។ ខ្ញុំមានពួកសត្វ ១ កោដិចោមរោមហើយ បួសក្នុង សាសនាព្រះជិនស្រី បានជាធីតា ជាឱរសនៃព្រះពុទ្ធ ហើយ បានដល់ឋានដ៏មិនកម្រើក បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញ ក្នុងសោត ធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញ ក្នុងចេតោបរិយញ្ញាណ ផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំបាន ជម្រះស្អាត ហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវនេះ ភពថ្មី ទៀតមិនមានឡើយ ។ ខ្ញុំមានសេចក្តីដឹងច្បាស់ ក្នុងអត្ថប្បដិ- សម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទានិងបដិភាណប្បដិ- សម្ភិទា ជាញាណស្អាតឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធ ដ៏ប្រសើរ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំ មកល្អហើយក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបាន ដល់ហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ហើយទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

ព្រះនាងអម្ពបាលីថេរី កាលសម្រេចអរហត្តហើយ ក៏ពិចារណាការបដិបត្តិរបស់ខ្លួន ទើបបន្លឺគាថានោះជាឧទាន ដោយប្រការដូច្នេះ ។

## អដ្ឋកថា អម្ពបាលីថេរីគាថា ចប់

# រោហិណីថេរីគាថា

[ ៣៣២ ] ( បិតាសួរនាងរោហិណីថា ) នែនាងដ៏ចម្រើន នាងចូបនឹងខ្ញុំ ពោលថា សមណៈ នាងភ្ញាក់ឡើងក៏ពោលថា សមណៈ នាងសរសើរចំពោះពួកសមណៈតែម្យ៉ាង នាងនឹងជាសមណីដោយពិត ។ នាងតែងផ្គត់ផ្គង់បាយទឹកដ៏ច្រើនចំពោះពួកសមណៈ នែនាងរោហិណី ឥឡូវនេះ យើងសួរនាង ចុះនាងមានសេចក្តីស្រឡាញ់ពួកសមណៈ តើដោយហេតុដូចម្តេច ។ ពួកសមណៈ ជាអ្នកមិនប្រាថ្នាក្នុងការងារ ខ្ជិលច្រអូស រស់នៅដោយសារទានដែលបុគ្គលដទៃឲ្យ ជាអ្នកប៉ុនប៉ងប្រាថ្នាតែអាហារមានរសឆ្ងាញ់ទេ ចុះនាងមានសេចក្តីស្រឡាញ់ពួកសមណៈ តើដោយហេតុដូចម្តេច ។

( នាងរោហិណីតបថា ) បពិត្របិតា អ្នកដេញដោលសួរខ្ញុំ អំពីពួកសមណៈ អស់កាលយូរណាស់ហើយ ខ្ញុំនឹងសំដែងនូវបញ្ញា សីល និងសេចក្តីខ្មីឃ្មាតរបស់សមណៈទាំងនោះដល់អ្នក ។ ពួកសមណៈជាអ្នកប្រាថ្នានូវការងារ មិនខ្ជិលច្រអូស ធ្វើចំពោះតែការងារដ៏ប្រសើរ រមែងលះបង់នូវរាគៈនិងទោសៈ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈជាអ្នកធ្វើនូវកម្មស្អាត រមែងកម្ចាត់បង់នូវឫសនៃបាបទាំងបី សមណៈទាំងនុ៎ះ បានលះបង់នូវបាបទាំងអស់ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ កាយកម្មរបស់សមណៈទាំងនោះស្អាត វចីកម្មស្អាតដូចគ្នា ទាំងមនោកម្មរបស់សមណៈទាំងនោះក៏ស្អាត ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈប្រាសចាកមន្ទិល ស្អាតទាំងខាងក្នុង ទាំងខាងក្រៅ ដូចជាស័ង្ខដែលខាត់ហើយ ពេញដោយធម៌ស

ទាំងឡាយ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈ ជាពហុស្សូត ទ្រទ្រង់នូវធម៌ ជាអរិយៈ រស់នៅដោយធម៌ តែងសម្តែងនូវអត្ថនិងធម៌ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈ ជាពហុស្សូត ទ្រទ្រង់នូវធម៌ ជាអរិយៈ រស់នៅដោយធម៌ មានចិត្តប្រសើរ មានអារម្មណ៍តែមួយ មានស្មារតី ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈទៅកាន់ទីឆ្ងាយបាន ( តាមសេចក្តីពេញចិត្ត ) មានស្មារតីពោលដោយឧបាយប្រាជ្ញា មិនរាយមាយ តែងដឹងនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈចៀសចេញទៅ អំពីស្រុកណារមែងមិនរមិលអ្វីមួយ ( ក្នុងស្រុកនោះ ) ចេញទៅឥតអាល័យ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ សមណៈទាំងនោះ មិនទុកដាក់ ( សម្បត្តិ ) ក្នុងជង្រុក មិនទុកដាក់ក្នុងអំបែង មិនទុកដាក់ល្អីកញ្ជើរស្វែងរកចំពោះតែភោជន ដែលសម្រេចហើយ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ សមណៈទាំងនោះ មិនទទួលនូវហិរញ្ញវត្ថុ ( កហាបណៈ ) មិនទទួលនូវមាស មិនទទួលនូវប្រាក់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុ ដែលកើតឡើងចំពោះមុខ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈចេញអំពីត្រកូលផ្សេងៗ អំពីជនបទផ្សេងៗទៅបួសរមែងរាប់រកគ្នាទៅវិញទៅមក ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។

( បិតានិយាយថា ) ម្នាលនាងរោហិណីដ៏ចម្រើន នាងកើតក្នុងត្រកូលនៃយើងដើម្បីប្រយោជន៍ពិត នាងជាស្ត្រីមានសទ្ធា មានសេចក្តីគោរពដ៏មុតមាំក្នុងព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ។ ដ្បិតនាងស្គាល់នូវបុញ្ញក្ខេត្តនុ៎ះ ជាបុញ្ញក្ខេត្តឧត្តមពិតមែន បើបានសមណៈទាំងនុ៎ះ ទទួលទក្ខិណាទានរបស់ខ្ញុំ ប្រហែលគ្រឿងបូជាដែលខ្ញុំតម្កល់ហើយចំពោះសមណៈទាំងនុ៎ះ នឹងមានផលបរិបូណ៌ ។

( នាងរោហិណីពោលថា ) បើអ្នកខ្លាចទុក្ខ បើទុក្ខមិនជាទីស្រឡាញ់របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ចូរសមាទានសីលទាំងឡាយចុះ ការដល់នូវទីពឹង និងការសមាទានសីលនោះ នឹងមានប្រយោជន៍ដល់អ្នក ។

( បិតាពោលថា ) ខ្ញុំសូមដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមសមាទានសីលទាំងឡាយ ការដល់ទីពឹងនិងសមាទានសីលនុ៎ះ នឹងមានប្រយោជន៍ដល់ខ្ញុំ ។ ក្នុងកាលមុន ខ្ញុំជាព្រាហ្មណ៍តែផៅពង្ស ឥឡូវនេះ ខ្ញុំជាព្រាហ្មណ៍ពិត ( មានបាបបន្សាត់ចោលហើយ ) ផង មានត្រៃវិជ្ជាផង មានសួស្តីផង ដល់នូវវេទផង ជាអ្នកងូតលាងបាបផង ។

## រោហិណីថេរី ។

# អដ្ឋកថា

## រោហិណីថេរីគាថា

[ ៣៣២ ] គាថារបស់ព្រះនាងរោហិណីថេរី មានពាក្យផ្ដើមថា **សមណាតិ ភោតិ សុបិ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ រាប់អំពីកប្បនេះថយក្រោយទៅ ៩១ កប្ប កើតក្នុងផ្ទះមានត្រកូល ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថា វិបស្សី ដល់នូវភាពជាអ្នកដឹងក្ដីហើយ ឃើញព្រះមានព្រះភាគត្រាច់បិណ្ឌបាតក្នុងនគរពន្ធុមវតី ថ្ងៃមួយទទួលបាត្រមកដាក់នំហើយថ្វាយដល់ព្រះមានព្រះភាគ កើតនូវបីតិសោមនស្សថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ដោយបុញ្ញកម្មនោះ នាងក៏អន្ទោលក្នុងទេវតានិងមនុស្សទាំងឡាយ សន្សំបុណ្យដើម្បីការរួចផុតដោយលំដាប់ ។ ក្នុងពុទ្ធុប្បាទនេះ កើតក្នុងផ្ទះព្រាហ្មណ៍ ជាអ្នកមានសម្បត្តិច្រើន ក្នុងក្រុងវេសាលី មានឈ្មោះថារោហិណី ដល់នូវភាពជាអ្នកដឹងក្ដីហើយ កាលព្រះសាស្ដាគង់នៅក្នុងក្រុងវេសាលី ក៏ទៅកាន់វិហារ ស្ដាប់ធម៌ បានជាសោតាបន្ន សម្ដែងធម៌ដល់មាតាបិតា ធ្វើឲ្យកើតសេចក្ដីជ្រះថ្លាក្នុងសាសនា ឲ្យមាតាបិតាអនុញ្ញាតហើយ ក៏ចេញបួសធ្វើកិច្ចកម្មក្នុងវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ក្នុងកាលនោះ ខ្ញុំបានថ្វាយនំដល់ព្រះពុទ្ធព្រះនាមថា វិបស្សី ទ្រង់ស្វែងរកគុណធំដែលទ្រង់យាងបិណ្ឌបាតក្នុងពន្ធុមវតីនគរ ។

ដោយកម្មដែលធ្វើល្អនោះ និងដោយចេតនាដែលតាំងមាំខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធបានចូលដល់ឋានសួគ៌ជាន់តាវត្តិង្ស ។ ខ្ញុំបានជាមហេសី របស់សក្កទេវរាជអស់ ៣៦ ដង បានជាមហេសីរបស់ស្តេចចក្រពត្តិ ៥០ ដង ។

វត្ថុដែលខ្ញុំប្រាថ្នាដោយចិត្ត សម្រេចដល់ខ្ញុំគ្រប់យ៉ាង ខ្ញុំសោយសម្បត្តិទាំងក្នុងពួកទេវតាទាំងក្នុងពួកមនុស្ស ។

ក្នុងភពចុងក្រោយ ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍មានឈ្មោះថារោហិណីដែលពួកញាតិរាប់អានច្រើន ។

ខ្ញុំទៅកាន់សម្នាក់របស់ភិក្ខុ ស្តាប់ធម៌តាមសេចក្តីពិត បាននូវសេចក្តីសង្វេគក៏បួសជាបព្វជិត ខ្ញុំតាំងនៅសេចក្តីព្យាយាមដោយឧបាយទើបសម្រេចព្រះអរហត្ត ក្នុងកប្បទី ៩១ អំពីកប្បនេះ ខ្ញុំបានថ្វាយទានណា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយនំ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនារបស់ព្រះពុទ្ធខ្ញុំក៏ធ្វើស្រេចហើយ[១]ដូច្នេះ ។

ព្រះនាងរោហិណីថេរី កាលសម្រេចអរហត្តហើយ ក៏ពិចារណាការបដិបត្តិរបស់ខ្លួន ហើយពោលជាឧទាននូវគាថាទាំងឡាយ ដែលបិតានិងខ្លួនឯង

---

១-អបទាននេះ មិនឃើញមានក្នុងបាលីអបទានឡើយ ។

ពោលឆ្លងឆ្លើយគ្នា ក្នុងពេលដែលខ្លួនទៅជាសោតាបន្នអំពីមុនថា

( បិតាសួរនាងរោហិណីថា ) នែនាងដ៏ចម្រើន នាងចូបនឹងខ្ញុំពោលថា សមណៈ នាងភ្ញាក់ឡើងក៏ពោលថា សមណៈ នាងសរសើរ ចំពោះពួកសមណៈតែម្យ៉ាង នាងនឹងជាសមណីដោយពិត ។ នាងតែងផ្គត់ផ្គង់បាយ ទឹក ដ៏ច្រើន ចំពោះពួកសមណៈ នែនាងរោហិណី ឥឡូវនេះ យើងសួរនាង ចុះនាងមានសេចក្តីស្រឡាញ់ពួកសមណៈ តើដោយហេតុដូចម្តេច ។ ពួកសមណៈជាអ្នកមិនប្រាថ្នាក្នុងការងារ ខ្ជិលច្រអូស រស់នៅដោយសារទានដែលបុគ្គលដទៃឲ្យ ជាអ្នកប៉ុនប៉ងប្រាថ្នាតែអាហារមានរសឆ្ងាញ់ទេ ចុះនាងមានសេចក្តីស្រឡាញ់ពួកសមណៈ តើដោយហេតុដូចម្តេច ។

( នាងរោហិណីតបថា ) បពិត្របិតា អ្នកដេញដោលសួរខ្ញុំអំពីពួកសមណៈ អស់កាលយូរណាស់ហើយ ខ្ញុំនឹងសំដែងនូវបញ្ញា សីល និងសេចក្តីខ្មីឃ្មាត របស់សមណៈទាំងនោះដល់អ្នក ។ ពួកសមណៈ ជាអ្នកប្រាថ្នានូវការងារ មិនខ្ជិលច្រអូស ធ្វើចំពោះតែការងារដ៏ប្រសើរ រមែងលះបង់នូវរាគៈនិងទោសៈ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈជាអ្នកធ្វើនូវកម្មស្អាត រមែងកម្ចាត់បង់នូវឫសនៃបាបទាំងបី សមណៈទាំងនុ៎ះ បានលះបង់នូវបាប

ទាំងអស់ ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈដោយហេតុនោះ ឯង ។ កាយកម្មរបស់សមណៈទាំងនោះស្អាត វចីកម្មស្អាតដូចគ្នា ទាំងមនោកម្មរបស់សមណៈទាំងនោះក៏ស្អាត ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈប្រាសចាកមន្ទិល ស្អាតទាំងខាងក្នុង ទាំងខាងក្រៅ ដូចជាស័ង្ខដែលខាត់ហើយ ពេញដោយធម៌សទាំងឡាយ ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈជាពហុស្សូត ទ្រទ្រង់នូវធម៌ ជាអរិយៈរស់នៅដោយធម៌ តែងសម្ដែងនូវអត្ថនិងធម៌ ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ ពួកសមណៈ ជាពហុស្សូត ទ្រទ្រង់នូវធម៌ ជាអរិយៈ រស់នៅដោយធម៌ មានចិត្តប្រសើរ មានអារម្មណ៍តែមួយ មានស្មារតី ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈដោយ ហេតុនោះឯង ។ ពួកសមណៈ ទៅកាន់ទីឆ្ងាយបាន ( តាមសេចក្ដីពេញចិត្ត ) មានស្មារតីពោលដោយឧបាយប្រាជ្ញា មិនរាយមាយ តែងដឹងនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈចៀសចេញទៅអំពីស្រុកណា រមែងមិនរមិលអ្វីមួយ ( ក្នុងស្រុកនោះ ) ចេញទៅឥតអាល័យ ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈដោយហេតុនោះឯង ។ សមណៈ

ទាំងនោះ មិនទុកដាក់ ( សម្បត្តិ ) ក្នុងជង្រុក មិនទុកដាក់ ឆ្នាំងអំបែង មិនទុកដាក់ល្អីកញ្ជើរ ស្វែងរកចំពោះតែភោជន ដែលសម្រេចហើយ ខ្ញុំមានសេចក្ដីស្រឡាញ់ ពួកសមណៈ ដោយហេតុនោះឯង ។ សមណៈទាំងនោះ មិនទទួលនូវហិរញ្ញវត្ថុ ( កហាបណៈ ) មិនទទួលនូវមាស មិនទទួលនូវប្រាក់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលកើតឡើងចំពោះមុខ ខ្ញុំមានសេចក្ដីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈចេញអំពីត្រកូលផ្សេងៗ អំពីជនបទផ្សេងៗ ទៅបួស រមែងរាប់រកគ្នា ទៅវិញទៅមក ខ្ញុំមានសេចក្ដីស្រឡាញ់ ពួកសមណៈដោយហេតុនោះឯង ។

( បិតានិយាយថា ) ម្នាលនាងរោហិណីដ៏ចម្រើន នាងកើតក្នុងត្រកូលនៃយើង ដើម្បីប្រយោជន៍ពិត នាងជាស្ត្រីមានសទ្ធា មានសេចក្ដីគោរពដ៏មុតមាំ ក្នុងព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ។ ដ្បិតនាងស្គាល់នូវបុញ្ញក្ខេត្តនុ៎ះ ជាបុញ្ញក្ខេត្តឧត្ដមពិតមែនបើបានសមណៈទាំងនុ៎ះ ទទួលទក្ខិណាទានរបស់ខ្ញុំ ប្រហែលគ្រឿងបូជា ដែលខ្ញុំតម្កល់ហើយ ចំពោះសមណៈទាំងនុ៎ះ នឹងមានផលបរិបូណ៌ ។

( នាងរោហិណីពោលថា ) បើអ្នកខ្លាចទុក្ខ បើទុក្ខមិនជាទីស្រឡាញ់របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធ ជាតាទិបុគ្គល

ផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ចូរសមាទានសីល ទាំងឡាយចុះ ការដល់នូវទីពឹងនិងការសមាទានសីលនោះនឹង មានប្រយោជន៍ដល់អ្នក ។

( បិតាពោលថា ) ខ្ញុំសូមដល់នូវព្រះពុទ្ធ ជាតាទិបុគ្គលផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមសមាទានសីលទាំង ឡាយ ការដល់ទីពឹងនិងសមាទានសីលនុ៎ះនឹងមានប្រយោជន៍ ដល់ខ្ញុំ ។ ក្នុងកាលមុន ខ្ញុំជាព្រាហ្មណ៍តែផៅពង្ស ឥឡូវនេះ ខ្ញុំជាព្រាហ្មណ៍ពិត ( មានបាបបន្សាត់ចោលហើយ ) ផងមាន ត្រៃវិជ្ជាផង មានសួស្តីផង ដល់នូវវេទផង ជាអ្នកងូតលាង បាបផង ដូច្នេះ ។

ក្នុងគាថាទាំងនោះ គាថា ៣ ដំបូង ព្រាហ្មណ៍ជាបិតាមិនចង់ឲ្យកូនស្រី របស់ខ្លួនវង្វេងក្នុងភិក្ខុទាំងឡាយជាអ្នកពោល ។ បណ្ដាបទទាំងនោះ បទថា **សមណាតិ ភោតិ សុបិ** សេចក្ដីថា នែកូន ពេលកូនដេកលក់ កូនក៏ពោល ថា សមណៈ សមណៈ ពោលតែពាក្យដែលទាក់ទងនឹងសមណៈរហូតដេក លក់ ។ បទថា **សមណាតិ បពុជ្ឈសិ** សេចក្ដីថា ទោះបីកូនក្រោកឡើង គឺក្រោកអំពីដំណេក ក៏ពោលយ៉ាងនេះថា សមណៈ ។ បទថា **សមណា-នេវ កិត្តេសិ** សេចក្ដីថា កូនប្រកាសសមណៈឬសរសើរគុណរបស់សមណៈ ប៉ុណ្ណោះ សព្វកាល ។ បទថា **សមណី នូន ភវិស្សសិ** សេចក្ដីថា ឥឡូវ នេះ កូននៅជាគ្រហស្ថ តែកូនមានចិត្តជាសមណៈពិត ។ ម្យ៉ាងទៀត បទថា

**សមណី ឆន្ន ភវិស្សសិ** បានដល់ ឥឡូវនេះ កូនស្ងួយនៅជាគ្រហស្ថ មិនយូរប៉ុន្មានកូននឹងក្លាយជាសមណៈតែម្យ៉ាង ព្រោះចិត្តរបស់កូនបង្អោនទៅក្នុងសមណៈប៉ុណ្ណោះ ។ បទថា **បវេច្ឆសិ** បានដល់ ឲ្យ ។ បទថា **រោហិណី ទានិ បុច្ឆាមិ** សេចក្តីថា ព្រាហ្មណ៍កាលនឹងសួរធីតារបស់ខ្លួន ទើបពោលថា នែនាងរោហិណី ឥឡូវនេះ យើងសួរនាង ។ បទថា **កេន តេ សមណា បិយា** សេចក្តីថា រោហិណីកូន នាងដេកលក់ក្តី ភ្ញាក់ក្តី ក្នុងកាលដទៃៗ ក្តី កូនប្រកាសតែគុណសមណៈប៉ុណ្ណោះ ព្រោះហេតុអ្វីទើបសមណៈទាំងឡាយជាទីស្រឡាញ់របស់កូន ។

ឥឡូវនេះ ព្រាហ្មណ៍កាលនឹងប្រាប់ទោសរបស់សមណៈដល់ធីតា ទើបពោលថា **អកម្មកាមា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អកម្មកាមា** ប្រែថា មិនស្រឡាញ់ការងារ បានដល់ មិនចង់ធ្វើការងារណាមួយដែលនាំប្រយោជន៍មកដល់ខ្លួននិងអ្នកដទៃ ។ បទថា **អលសា** ប្រែថាខ្ជិលប្រអូស បទថា **បរទត្តូបជីវិនោ** បានដល់ អាស្រ័យរបស់ដែលអ្នកដទៃគេឲ្យ ចិញ្ចឹមជីវិតជាប្រក្រតី ។ បទថា **អសំសុកា** បានដល់ រង់ចាំតែអាហារនិងសំពត់ជាដើមអំពីអ្នកដទៃប៉ុណ្ណោះ ។ បទថា **សាទុកាមា** បានដល់ ប្រាថ្នាតែអាហារដែលឆ្ងាញ់ប៉ុណ្ណោះ ។ ព្រាហ្មណ៍កាលមិនស្គាល់គុណ របស់សមណៈ ក៏ពោលទោសនោះសព្វយ៉ាងដែលខ្លួននឹកឃើញ ។

នាងរោហិណីស្តាប់ពាក្យបិតានោះហើយ ត្រេកអរថា អញបានឱកាសពោលដល់គុណលោកម្ចាស់ទាំងឡាយហើយ បំណងប្រកាសគុណរបស់ភិក្ខុ

*ទាំងឡាយជាមុន កាលនឹងប្រាប់ការសោមនស្សក្នុងការប្រកាសដល់ភិក្ខុទាំងនោះក្នុងលំដាប់ដំបូង ទើបពោលគាថាថា* **ចិរស្សំ វត មំ តាត** *ជាដើម ។ បណ្ដាបទទាំងនោះ បទថា* **ចិរស្សំ វត** *ប្រែថា ក្នុងកាលយូរហ្ន៎ ។ នាងរោហិណី ហៅបិតាដោយពាក្យថា* **តាត** *។ បទថា* **សមណានំ** *សេចក្ដីថា លោកឪពុកសួរដេញដោលដល់ពួកសមណៈ ឬគុណរបស់ពួកសមណៈដែលគប្បីជាទីស្រឡាញ់សម្រាប់កូន ។ បទថា* **តេសំ** *បានដល់ ពួកសមណៈ ។ បទថា* **បញ្ញាសីលបរក្កមំ** *បានដល់ បញ្ញា សីល និងឧស្សាហៈ ។ បទថា* **កិត្តយិស្សាមិ** *បានដល់ នឹងប្រាប់ ។ នាងរោហិណី កាលប្ដេជ្ញាហើយ កាលប្រាប់គុណទាំងនោះដើម្បីដោះនូវទោសដែលព្រាហ្មណ៍ជាបិតានោះពោលថាពួកសមណៈជាអ្នកមិនប្រាថ្នាក្នុងការងារ ខ្ជិលច្រអូស ហើយសម្ដែងគុណដែលផ្ទុយគ្នាតាមដែលព្រាហ្មណ៍បិតាពោល ទើបពោលគាថាថា* **កម្មកាមា** *ជាដើម ។ បណ្ដាបទទាំងនោះ បទថា* **កម្មកាមា** *សេចក្ដីថា សមណៈទាំងនោះ បំណង គឺប្រាថ្នាការងារ គឺកិច្ចរបស់សមណៈមានវត្តបដិបត្តិជាដើមដោយធ្វើឲ្យបរិបូណ៌ ព្រោះហេតុនោះទើបឈ្មោះថា ជាអ្នកប្រាថ្នានូវការងារ សមណៈទាំងនោះ ជាអ្នកខ្វល់ខ្វាយក្នុងសមណកិច្ចនោះ ខ្នះខ្នែងព្យាយាមមិនខ្ជិលច្រអូស ព្រោះហេតុនោះ ទើបឈ្មោះថាជាអ្នកមិនខ្ជិលច្រអូស ម្យ៉ាងទៀត សមណៈទាំងនោះធ្វើនូវការងារនោះឲ្យជាការងារប្រសើរឧត្តមនាំមកនូវព្រះនិព្វានតែម្យ៉ាង ព្រោះហេតុនោះ ទើបឈ្មោះថា ធ្វើចំពោះតែការងារដ៏ប្រសើរ ។ ម្យ៉ាងទៀត សមណៈទាំងនោះ កាលធ្វើការងារនោះ ឈ្មោះថា*

រមែងលះបង់នូវរាគៈនិងទោសៈ គឺសមណៈធ្វើការងារ ដោយវិធីដែលលះរាគៈទោសៈបាន ព្រោះការបដិបត្តិនោះមិនមានទោស ។ បទថា **តេន មេ សមណា បិយា** សេចក្តីថា ព្រោះការបដិបត្តិដោយប្រពៃតាមដែលពោលមកនោះ ទើបពួកសមណៈគួរជាទីស្រឡាញ់សម្រាប់កូន ។

បទថា **តីណិ ចាបស្ស មូលានិ** បានដល់ ឫសគល់របស់អកុសលមាន ៣ ពោល គឺលោភៈ ទោសៈ មោហៈ ។ បទថា **ធុនន្តិ** បានដល់ ទម្លាយ គឺលះបង់ ។ បទថា **សុចិការិនោ** បានដល់ ធ្វើនូវការងារដែលមិនមានទោស ។ បទថា **សព្វបាបំ បហីនេសំ** បានដល់ លះបាបនោះបានទាំងអស់ ព្រោះសម្រេចអរហត្តមគ្គ ។

នាងរោហិណីនោះ ដើម្បីនឹងសម្តែងអត្ថដោយសង្ខេបថា ពួកសមណជាអ្នកធ្វើនូវកម្មស្អាត យ៉ាងនេះហើយ ទើបពោលគាថាថា **កាយកម្មំ** ជាដើម ។ ពាក្យនេះយល់ងាយហើយ ។

បទថា **វិមលា សង្ខមុត្តាវ** សេចក្តីថា ប្រាសចាកមន្ទិល វៀរចាកមន្ទិល មានរាគៈជាដើម ដូចស័ង្ខដែលខាត់ល្អហើយ និងដូចកែវមុក្តា ។ បទថា **សុទ្ធា សន្តរពាហិរា** សេចក្តីថា ទាំងខាងក្នុងទាំងខាងក្រៅ ។ ឈ្មោះថា **សន្តរពាហិរ** គឺមានអជ្ឈាស្រ័យនិងសេចក្តីព្យាយាមស្អាតទាំងខាងក្នុងនិងខាងក្រៅនោះ ។ បទថា **បុណ្ណា សុក្កាន ធម្មានំ** សេចក្តីថា បរិបូណ៌ដោយធម៌ចំណែកសដោយចំណែកមួយ គឺធម៌ដែលមិនមានទោស បានដល់ប្រកបដោយសីលក្ខន្ធជាដើម ដែលជាធម៌របស់អសេក្ខៈ ។

សុតៈ មានសុត្តៈ គេឃ្យ:ជាដើមរបស់សមណៈទាំងនោះច្រើន ឬថា សមណៈទាំងនោះកើតហើយដោយសុតៈ ព្រោះហេតុនោះ ទើបឈ្មោះថា ជាពហូសូត អធិប្បាយថា ប្រកបព្រមដោយពាហុសច្ចៈ គឺបរិយត្តិនិង ពាហុសច្ចៈ គឺបដិវេទ ។ សមណៈទាំងនោះទ្រទ្រង់នូវធម៌ទាំង ២ យ៉ាងនោះទុក ហេតុនោះ ទើបឈ្មោះថា **ធម្មធរា** គឺជាអ្នកទ្រទ្រង់នូវធម៌ សមណៈទាំងនោះ រមែងប្រព្រឹត្តទៅដោយសិក្ខាបទដែលជាអាចារៈនិង សមាចារៈដើម្បីសត្វទាំងឡាយ ហេតុនោះទើបឈ្មោះថា ជាអរិយៈ ។ សមណៈទាំងនោះ រមែងជាអ្នកនៅដោយធម៌ គឺប្រពៃតាមធម៌ ហេតុនោះទើបឈ្មោះថា រស់នៅដោយធម៌ ។ បទថា **អត្ថំ ធម្មញ្ច ទេសេន្តិ** បានដល់ ពោលប្រកាសអត្ថនៃភាសិតនិងទេសនាធម៌ ឬម្យ៉ាងទៀត បានដល់ សម្ដែង គឺប្រាប់នូវធម៌ ដែលមិនប្រាសចាកអត្ថ និងអត្ថមិនប្រាសចាកធម៌ ។

បទថា **ឯកគ្គចិត្តា** បានដល់ មានចិត្តមាំទាំ ។ បទថា **សតិមន្តោ** បានដល់ មានសតិតាំងមាំ ។ បទថា **ទូរង្គមា** បានដល់ នៅព្រៃ ។ សមណៈទាំងនោះ លះនូវទឹកដីដែលជិតពួកមនុស្ស ទៅឆ្ងាយ ឬទៅកាន់ទីឆ្ងាយតាមគាប់ចិត្តដោយបុទ្ធានុភាព ហេតុនោះ ទើបឈ្មោះថា **ទូរង្គមា** គឺជាអ្នកទៅឆ្ងាយ ។ បញ្ញា លោកហៅថា **មន្តា** ។ សមណៈទាំងនោះ ឈ្មោះថា **មន្តភាណី** ព្រោះមានប្រក្រតីពោលដោយបញ្ញានោះ ។ បទថា **អនុទ្ធតា** បានដល់ មិនរាយមាយ គឺប្រាសចាកការរាយមាយ មានចិត្តស្ងប់ ។ បទថា **ទុក្ខស្សន្តំ បជានន្តិ** បានដល់ ចាក់ធ្លុះនូវព្រះនិព្វានដែលជាទីបំផុតនៃទុក្ខក្នុង

វដ្ដៈ ។ បទថា **ន វិលោកេន្តិ កិញ្ចនំ** សេចក្ដីថា សមណៈទាំងនោះចេញទៅអំពីស្រុកណា ក៏មិនសម្លឹងមើលសត្វ ឬសង្ខារណាមួយ ក្នុងស្រុកនោះដោយអាល័យ ដែលពិត មិនមានអាល័យ ចៀសចេញទៅ ។

បទថា **ន តេ សំ កោដ្ឋេ ឱបេន្តិ** សេចក្ដីថា សមណៈទាំងនោះមិនសន្សំ គឺមិនប្រមូលនូវសម្បត្តិផ្ទាល់ខ្លួនទុកក្នុងឃ្លាំង ( ជង្រុក ) ព្រោះមិនមានការចាំបាច់បែបនោះ ។ បទថា **កុម្ភឹ** បានដល់ ក្នុងឆ្នាំង ។ បទថា **ខឡោបិយំ** បានដល់ ក្នុងកញ្ជើល្អី ។ បទថា **បរិនិដ្ឋិតមេសានា** បានដល់ ស្វែងរកអាហារដែលសម្រេចស្រាប់ ដើម្បីជាប្រយោជន៍ របស់បុគ្គលដទៃៗ ក្នុងត្រកូលដទៃៗ ។

បទថា **ហិរញ្ញំ** បានដល់ កហាបណៈ ។ បទថា **រូបិយំ** បានដល់ ប្រាក់ ។ បទថា **បច្ចុប្បន្នេន យាបេន្តិ** បានដល់ មិនសោយសោកដល់អតីត និងមិនសង្ឃឹមក្នុងអនាគត ចិញ្ចឹមជីវិត គឺញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យបច្ចុប្បន្នដែលកើតចំពោះមុខ ។

បទថា **អញ្ញមញ្ញំ បិហាយន្តិ** បានដល់ ធ្វើមេត្រីក្នុងគ្នានឹងគ្នា ។ បាលីថា **បិហាយន្តិ** ដូច្នេះក៏មាន ឯសេចក្ដីក៏យ៉ាងនោះដូចគ្នា ។

ព្រាហ្មណ៍នោះ ស្ដាប់គុណរបស់ភិក្ខុទាំងឡាយ ក្នុងសម្នាក់កូនស្រីយ៉ាងនេះហើយ មានចិត្តជ្រះថ្លា កាលនឹងសរសើរ ទើបពោលគាថាថា **អត្ថាយ វត** ជាដើម ។ បទថា **អម្ហំបិ** ប្រែថា ដល់ពួកយើង ។ បទថា **ទក្ខិណំ** បានដល់ ទេយ្យធម៌ ។ បទថា **ឯត្ថ** បានដល់ ក្នុងសមណៈទាំងនោះ ។ បទ

ថា **យញ្ញោ** បានដល់ ធម៌គឺទាន ។ បទថា **វិបុលោ** បានដល់ មានផល ទូលាយ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ព្រាហ្មណ៍តាំងនៅក្នុងសរណៈនិងសីលយ៉ាងនេះហើយ តមកកើតសេចក្ដីសង្វេគក៏បួស ចម្រើនវិបស្សនា តាំងនៅក្នុងអរហត្ត ពិចារណាបដិបទារបស់ខ្លួន កាលនឹងឧទាន ទើបពោលគាថាថា **ព្រហ្មពន្ធុ** ជាដើម សេចក្ដីរបស់ឧទាននោះបានពោលមកហើយខាងដើមនោះឯង ។

## អដ្ឋកថា រោហិណីថេរីគាថា ចប់

## ចាបាថេរីគាថា

[ ៣៣៣ ] ( ឧបកៈពោលថា ) កាលពីដើម ខ្ញុំមានដៃកាន់ដំបង ឥឡូវនេះ ខ្ញុំនោះជាព្រានម្រឹគ មិនអាចបានដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្ដីប្រាថ្នាគឺតណ្ហា ព្រោះភក់គឺកាម និងទិដ្ឋិដ៏ខ្លាំងក្លា ។ នាងចាបា ស្មាននូវខ្ញុំថាជាមនុស្សស្រវឹងជ្រប់ ទើបលួងកូន ខ្ញុំកាត់ចំណងគឺកិលេសរបស់នាងចាបា ហើយទៅបួសម្ដងទៀត ។

( នាងចាបាពោលថា ) បពិត្រមហាវីរបុរស សូមអ្នកកុំខឹងនឹងខ្ញុំ បពិត្រមហាមុនី សូមអ្នកកុំខឹងនឹងខ្ញុំ សេចក្ដីស្អាតមិនមានដល់បុគ្គលដែលមានសេចក្ដីក្រោធគ្របសង្កត់ទេ តបធម៌នឹងមានមកពីណា ។

( ឧបកៈពោលថា ) ខ្ញុំនឹងគេចចេញអំពីស្រុកនាលៈ អ្នកណានឹងនៅក្នុងស្រុកនាលៈនេះបាន បើពួកស្រីៗចងនូវសមណៈទាំងឡាយដែលរស់នៅដោយធម៌ ដោយរូបនៃស្ត្រី ។

( នាងចាបាពោលថា ) ម្នាលបុរសខ្មៅ សូមអ្នកអញ្ជើញមកសិនសឹមត្រឡប់វិញ សូមបរិភោគនូវកាមទាំងឡាយ ដូចក្នុងកាលមុនចុះ ជនទាំងឡាយណាជាញាតិរបស់ខ្ញុំ ខ្ញុំនឹងធ្វើជនទាំងនោះឲ្យលុះក្នុងអំណាចនៃអ្នក ។

ម្នាលនាងចាបា នាងពោលនូវពាក្យនោះឲ្យមានភាគ ៤ អំពីពាក្យនេះក៏ដោយ ពាក្យនោះគប្បីជាពាក្យធើតធាយចំពោះតែបុរស ដែលត្រេកអរនឹងនាងប៉ុណ្ណោះទេ ។

ម្នាលបុរសខ្មៅ ហេតុអ្វី ទើបអ្នកលះបង់ចោលខ្ញុំ ជាស្ត្រីមានរូបឆោមលាបស្រឡាបអវយវៈដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវកាសិកពស្ត្រដ៏ឧត្ដម

( សំពត់ដែលគេនាំមកអំពីដែនកាសី ) ជាស្ត្រីមានអវយវៈល្អ ដូចជាត្នោត សាវដែលរីកលើកំពូលភ្នំ ឬដូចជាវល្លិកេសរីកហើយ ឬក៏ដូចជាឈើប្រទៀង ( រីកហើយ ) ខាងក្នុងទ្វីប ។

ព្រានសត្វស្លាប ប្រាថ្នាចាប់សត្វស្លាបយ៉ាងណា នាងនឹងបៀតបៀនអញ ដោយរូបដែលស្អិតស្អាង ( យ៉ាងនោះ ) ពុំបានទេ ។

នែបុរសខ្មៅ ហេតុអ្វីទើបអ្នកលះបង់ចោលនូវផ្លែ គឺកូនខ្ញុំ ដែលអ្នកបង្កើតនេះផង លះបង់ខ្ញុំដែលជាស្ត្រីមានកូនប្រាកដដូច្នោះផង ។

មហាវីរបុរសទាំងឡាយ ដែលមានប្រាជ្ញា តែងលះបង់នូវកូនទាំងឡាយ ទាំងពួកញាតិ ទាំងទ្រព្យ ហើយបួស ដូចជាដំរីដ៏ប្រសើរផ្តាច់នូវចំណង ( ហើយគេចចេញទៅ ) ។

ឥឡូវ ខ្ញុំនឹងបៀតបៀនកូនអ្នកនេះ ដោយដំបង ឬក្តិចដោយក្រចក ឬ ( បោក ) លើផែនដី អ្នកមិនដល់នូវការយំស្តាយចំពោះកូនទេឬ ។

នែស្ត្រីលាមក មានកូនតូច បើទុកជានាងឲ្យកូនទៅសត្វចចកនិងពួកឆ្កែ ក៏នាងញុំាងអញឲ្យត្រឡប់វិញពុំបានឡើយ ។

នែបុរសខ្មៅ ណ្ហើយចុះ ឥឡូវនេះ បើអ្នកនឹងទៅក្នុងទីណា គឺស្រុកណា និគមណា នគរណា រាជធានីណា ( ក៏ទៅចុះ ) ។

កាលពីដើម យើងជាអ្នកមានពួក មិនមែនជាសមណៈ សំគាល់ថាជាសមណៈហើយចេញពីស្រុកទៅកាន់ស្រុក កាន់នគរ រាជធានី ។ មែនពិត ព្រះសម្ពុទ្ធទ្រង់មានជោគអង្គនោះ តែងសំដែងធម៌ប្រោសពួកសត្វ ដើម្បីលះបង់

សេចក្តីទុក្ខទាំងពួង ក្នុងទីជិតស្ទឹងនេរញ្ជរា ខ្ញុំនឹងទៅក្នុងសំណាក់នៃព្រះសម្ពុទ្ធនោះ ព្រះអង្គនឹងជាគ្រូនៃខ្ញុំ ។

ឥឡូវនេះ អ្នកគប្បីទូលរៀបរាប់អំពីកិច្ចថ្វាយបង្គំ ( របស់ខ្ញុំ ) ចំពោះព្រះលោកនាថ ជាបុគ្គលប្រសើរ រួចហើយធ្វើប្រទក្សិណ ឧទ្ទិសនូវទក្ខិណាទាន ។

ម្នាលនាងចាបា នាងពោលនូវពាក្យនោះ យ៉ាងណា យើងគប្បីបាន ( អាចឲ្យ ) នូវចំណែកបុណ្យនោះ ឥឡូវនេះខ្ញុំនឹងទូលរៀបរាប់នូវកិច្ចថ្វាយបង្គំរបស់នាងចំពោះព្រះលោកនាថ ជាបុគ្គលប្រសើរនឹងធ្វើប្រទក្សិណឧទ្ទិសនូវទក្ខិណា ( បុណ្យ ) ។

លំដាប់នោះឯង បុរសខ្មៅចៀសចេញអំពីទីនោះទៅ បុរសខ្មៅនោះ ក៏បានចួបនឹងព្រះសម្ពុទ្ធ ក្បែរស្ទឹងនេរញ្ជរា កំពុងសំដែងនូវឧបាយនៃព្រះនិព្វានឈ្មោះអមតៈ គឺទុក្ខ ១ ហេតុកើតឡើងនៃទុក្ខ ១ ការកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ១ ។ បុរសខ្មៅថ្វាយបង្គំនូវព្រះបាទទាំងឡាយរបស់ព្រះសម្ពុទ្ធនោះ ហើយធ្វើប្រទក្សិណចំពោះព្រះអង្គ ឧទ្ទិសដល់នាងចាបាហើយ ចូលកាន់ផ្នួស ។ វិជ្ជាបីខ្ញុំបានហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។

**ចាបាថេរី ។**

# អដ្ឋកថា

## ចាបាថេរីគាថា

[ ៣៣៣ ] គាថារបស់ព្រះនាងចាបាថេរី មានពាក្យផ្ដើមថា **លដ្ឋិហត្ថោ បុរេ អាសិ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ សន្សំកុសលមូលមកដោយលំដាប់ សន្សំបុណ្យដើម្បីការរួចផុត ជាច្រើន ។ ក្នុងពុទ្ធុប្បាទនេះ កើតជាកូនស្រីប្រធានព្រានព្រៃក្នុងស្រុកព្រាន នាតំបន់មួយ ក្នុងវង្កហារជនបទ មានឈ្មោះថាចាបា[១]។ សម័យនោះ អ្នកបួសអាជីវកឈ្មោះឧបកៈ ជួបព្រះសាស្ដា ដែលយាងចេញអំពីពោធិមណ្ឌលដ្ឋានឆ្ពោះទៅកាន់ក្រុងពារាណសីដើម្បីប្រកាសធម្មចក្ក ។ ទើបសួរថា អាវុសោ ឥន្ទ្រិយរបស់លោកផូរផង់ ឆវីវណ្ណក៏បរិសុទ្ធផូរផង់ អាវុសោ លោកបួសឧទ្ទិសចំពោះអ្នកណា ឬថាអ្នកណាជាសាស្ដារបស់លោក លោកគាប់ចិត្តក្នុងធម៌របស់អ្នកណា កាលព្រះសាស្ដាទ្រង់ចង្អុលបង្ហាញថា ទ្រង់ជាសព្វញ្ញុពុទ្ធ និងការប្រកាសធម្មចក្រ ដូច្នេះថា

តថាគត ជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ បានលះបោល នូវតេភូមិកធម៌ទាំងអស់

---

១-ក្នុងទីខ្លះជា នាងចាវា ឬនាងនាវា ។

ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹង ច្បាស់នូវចតុភូមិកធម៌ ដោយខ្លួនឯង ( ចាំបាច់ ) ចំពោះ បុគ្គលណា ។ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃ ស្មើនឹងតថាគតឡើយ ក្នុងលោកនេះព្រមទាំងទេវលោក មិន មានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ។ ព្រោះថា តថា គតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត ជាអ្នកត្រាស់ ដឹងដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់ មាន ភ្លើងកិលេសរលត់ហើយ ។ ឥឡូវ តថាគតទៅកាន់ក្រុងនៃ ពួកជនអ្នកកាសីដើម្បីនឹងសម្តែងធម្មចក្ក ( ដោយបំណងថា ) តថាគតនឹងទូងនូវស្គរ គឺអមតនិព្វានចំពោះសត្វលោក ដែល ងងឹត គឺ អវិជ្ជាកំពុងគ្របសង្កត់ ដូច្នេះ ។

ឧបកៈមានចិត្តជ្រះថ្លាពោលថា អើអាវុសោ លោកគង់ជាអរហន្តជិនៈ លោកគង់ជាអនន្តជិនៈ ហើយក៏បែកផ្លូវទៅកាន់វង្កហារជនបទ ចូលទៅកាន់ ស្រុកព្រានម្រឹគក្នុងជនបទនោះ ប្រធានព្រានព្រៃក្នុងស្រុកនោះ បានឧបដ្ឋាក ដល់ឧបកាជីវក ។ ថ្ងៃមួយ ប្រធានព្រានព្រៃទៅបរបាញ់សត្វ ក្នុងទីឆ្ងាយ ទើបប្រាប់នាងចាបាដែលជាកូនស្រីរបស់ខ្លួនថាចូរនាងកុំភ្លេចព្រះអរហន្តរបស់ ពុក ហើយទៅជាមួយកូនប្រុសដែលជាបង ។ កូនស្រីរបស់នាយព្រាននោះ មានរូបល្អ គួរសរសើរ ។

កាលនោះ ឧបកាជីវកដល់ពេលអាហារ ក៏ទៅកាន់ផ្ទះរបស់នាយព្រាន

ឃើញនាងចាបាយកអាហារមកប្រគេន ត្រូវភគៈចោមរោម មិនអាចបរិភោគអាហារបាន ទើបកាន់ភាជនៈអាហារទៅកាន់លំនៅរបស់ខ្លួន ដាក់អាហារក្នុងទីមួយកន្លែង គិតថា បើអញបានចាបាទើបមានជីវិត បើមិនបាន ក៏នឹងស្លាប់ ហើយដេកអត់អាហារអស់ ៧ ថ្ងៃ ។ ព្រានព្រៃត្រឡប់មក ក៏សួរកូនស្រីថា នាងមិនក្រេចព្រះអរហន្តរបស់ឪពុកទេឬ ។ នាងចាបា ឆ្លើយថា ឃើញលោកមកតែមួយថ្ងៃប៉ុណ្ណោះ ហើយក៏មិនឃើញមកទៀត ។ រំពេចនោះឯង នាយព្រាន ក៏ទៅកាន់លំនៅរបស់ឧបកាជីវកនោះ ប្របាច់ជើងទាំង ២ សួរថា លោកម្ចាស់មិនសប្បាយឬ ឧបកាជីវកដកដង្ហើមធំ បានត្រឹមតែដេកបម្រះនទៀលនោះឯង ព្រានព្រៃបានបវារណាថា សូមលោកម្ចាស់ប្រាប់មកចុះកិច្ចណាល្មមធ្វើបានខ្ញុំនឹងធ្វើគ្រប់យ៉ាង ។ ឧបកាជីវក ក៏ប្រាប់ដល់អធ្យាស្រ័យក្នុងចិត្តដោយបរិយាយផ្លូវអមឯណាមួយ នាយព្រានសួរថា លោកម្ចាស់ចេះសិប្បៈណាមួយដែរឬ ឧបកៈឆ្លើយថា មិនចេះឡើយ នាយព្រានពោលថា មនុស្សមិនចេះសិប្បៈណាមួយ មិនអាចនៅគ្រប់គ្រងផ្ទះបានទេ ឧបកៈតបថា អាត្មាមិនចេះសិប្បៈណាមួយក៏ពិត តែអាត្មាអាចរែកសាច់ និងលក់សាច់បាន ព្រានព្រៃពោលថា បើយ៉ាងនេះក៏ពេញចិត្តខ្ញុំហើយ បញ្ជូនសំពត់ឲ្យមួយផ្ទាំងឲ្យនៅក្នុងផ្ទះរបស់សម្លាញ់ខ្លួនមួយរយៈតូចហើយ ក៏នាំមកកាន់ផ្ទះ ក្នុងថ្ងៃដ៏សមគួរ ប្រគល់កូនស្រីឲ្យ ។

កាលកន្លងមក មនុស្សទាំង ២ នៅរួមគ្នា ក៏មានកូនម្នាក់ ឈ្មោះថា សុភទ្ទ ។ ពេលកូនយំ នាងចាបាក៏ប្រើចម្រៀងបំពេកូនចំអកឲ្យឧបកៈថា កូន

ឧបកៈ កូនអាជីវក កូនអ្នករែកសាច់ កុំយំឡើយ នាយឧបកៈនោះអត់ទ្រាំពុំបាន ក៏ពោលថា នាងកុំមើលងាយអញថា ជាមនុស្សអនាថា អញមានសម្លាញ់ម្នាក់ ឈ្មោះអានន្ទជិនៈ អញនឹងទៅរកគេក៏បាន ។ នាងចាបាដឹងថាឧបកៈទាស់ចិត្តដោយវិធីនេះ ក៏ច្រៀងបំពេកូនយ៉ាងនោះរឿយៗ ។ ថ្ងៃមួយត្រូវនាងបំពេកូនចំអកយ៉ាងនោះក៏ក្រោធ គិតថានឹងទៅ សូម្បីនាងឃាត់យ៉ាងណាក៏មិនព្រម ទើបធ្វើដំណើរមានមុខទៅកាន់ទិសខាងលិច ។

សម័យនោះ ព្រះមានព្រះភាគគង់ក្នុងជេតពនមហាវិហារ នាក្រុងសាវត្ថី ផ្តាំនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ថ្ងៃនេះ បើអ្នកណាមកសួរថា អានន្ទជិនៈនៅឯណា ពួកអ្នកចូរបញ្ជូនបុរសនោះមកជួបតថាគត ។ ចំណែកឧបកៈសួរគេតាមផ្លូវរហូតថា អានន្ទជិនៈនៅឯណា មកដល់ក្រុងសាវត្ថីដោយលំដាប់ ចូលទៅកាន់អារាមឈរត្រង់កណ្តាលវត្តសួរថា អនន្តជិនៈនៅឯណា ភិក្ខុទាំងឡាយ ក៏នាំឧបកៈចូលគាល់ព្រះមានព្រះភាគ ។ លុះជួបព្រះមានព្រះភាគហើយ ក៏ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ស្គាល់ខ្ញុំដែរឬ ព្រះមានព្រះភាគត្រាស់ឆ្លើយព្រមទាំងសាកសួរថា តថាគតស្គាល់ អ្នករវល់ទៅណាក៏យូរដល់ម៉្លេះ ឧបកៈទូលថា ខ្ញុំទៅនៅត្រង់វង្កហារជនបទ ព្រះសាស្តាត្រាស់សួរថា ឧបកៈ ពេលនេះ អ្នកចាស់ហើយ តើបួសឬទេ ឧបកៈទូលថា ខ្ញុំបួស ។ ព្រះសាស្តាត្រាស់នឹងភិក្ខុមួយរូបថា មកភិក្ខុ ចូរអ្នកឲ្យកុលបុត្តនេះបួសចុះ ភិក្ខុនោះក៏ឲ្យឧបកៈបួស ។ ព្រះឧបកត្ថេរបួសហើយក៏ទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ប្រកបភាវនារឿយៗ មិនយូរប៉ុន្មាន ក៏តាំងនៅក្នុង

អនាគាមិផល ធ្វើកាលកិរិយា កើតក្នុងព្រហ្មលោកជាន់អវិហា ។ មានជន ៧ នាក់ គ្រាន់តែកើតក្នុងព្រហ្មលោកជាន់អវិហា ហើយបានសម្រេចអរហត្ត ឧបកៈនេះ ជាបុគ្គលមួយរូបក្នុងជនទាំង ៧ នាក់នោះ សមដូចលោកពោលទុកថា

ភិក្ខុទាំង ៧ រូប បានទៅកើតក្នុងព្រហ្មលោក ឈ្មោះអវិហា មានចិត្តរួចស្រឡះហើយ មានរាគៈ ទោសៈអស់ហើយ ឆ្លងនូវតណ្ហាក្នុងលោករួចហើយ ។ ភិក្ខុទាំងនោះ គឺព្រះឧបកៈ ១ ព្រះផលគណ្ឌៈ ១ ព្រះបុក្កុសាតិ ១ ជា ៣ រូប និងព្រះភទ្ទិយៈ ១ ព្រះខណ្ឌទេវៈ ១ ព្រះពហុទន្តី ១ ព្រះសិង្គិយៈ ១ ( ៤ រូបនេះទៀតជា ៧ ) ភិក្ខុទាំងនោះ បានលះបង់នូវរាងកាយ ជារបស់មនុស្សហើយ ទើបកន្លងនូវទិព្វយោគបាន ដូច្នេះ ។

កាលឧបកៈធ្វើដំណើរចេញទៅហើយ នាងចាបាក៏មានចិត្តនឿយណាយ ទើបប្រគល់កូនឲ្យព្រានដែលជាឪពុក ដើរទៅតាមផ្លូវ ដែលឧបកៈទៅហើយ ដល់ក្រុងសាវត្ថីហើយ ក៏បួសក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ធ្វើកិច្ចកម្មក្នុងវិបស្សនាក៏តាំងនៅក្នុងអរហត្តតាមលំដាប់មគ្គ កាលពិចារណាដល់ការបដិបត្តិរបស់ខ្លួន ក៏ធ្វើគាថាដែលឧបកៈនិងខ្លួននិយាយគ្នាក្នុងកាលមុនជាឧទានគាថាយ៉ាងនេះថា

( ឧបកៈពោលថា ) កាលពីដើម ខ្ញុំមានដៃកាន់ដំបងឥឡូវ

នេះ ខ្ញុំនោះជាព្រានម្រឹគ មិនអាចបានដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្តីប្រាថ្នាគឺតណ្ហា ព្រោះភក់គឺកាម និងទិដ្ឋិដ៏ខ្លាំងក្លា ។ នាងចាបាស្មាននូវខ្ញុំថាជាមនុស្សស្រវឹងជ្រប់ ទើបលួងកូន ខ្ញុំកាត់ចំណង គឺកិលេសរបស់នាងចាបា ហើយទៅបួសម្តងទៀត ។

( នាងចាបាពោលថា ) បពិត្រមហាវីរបុរស សូមអ្នកកុំខឹងនឹងខ្ញុំ បពិត្រមហាមុនី សូមអ្នកកុំខឹងនឹងខ្ញុំ សេចក្តីស្អាតមិនមានដល់បុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់ទេ តបធម៌នឹងមានមកពីណា ។

( ឧបកៈពោលថា ) ខ្ញុំនឹងគេចចេញអំពីស្រុកនាលៈ អ្នកណានឹងនៅក្នុងស្រុកនាលៈនេះបាន បើពួកស្រីៗ ចងនូវសមណៈទាំងឡាយដែលរស់នៅដោយធម៌ ដោយរូបនៃស្ត្រី ។

( នាងចាបាពោលថា ) ម្នាលបុរសខ្មៅ សូមអ្នកអញ្ជើញមកសិនសឹមត្រឡប់វិញ សូមបរិភោគនូវកាមទាំងឡាយ ដូចក្នុងកាលមុនចុះ ជនទាំងឡាយណាជាញាតិរបស់ខ្ញុំ ខ្ញុំនឹងធ្វើជនទាំងនោះឲ្យលុះក្នុងអំណាចនៃអ្នក ។

ម្នាលនាងចាបា នាងពោលនូវពាក្យនោះឲ្យមានភាគ ៤ អំពីពាក្យនេះក៏ដោយ ពាក្យនោះគប្បីជាពាក្យធើតធាយចំពោះតែបុរសដែលត្រេកអរនឹងនាងប៉ុណ្ណោះទេ ។

ម្នាលបុរសខ្មៅ ហេតុអ្វីទើបអ្នកលះបង់ចោលខ្ញុំ ជាស្ត្រីមានរូបឆោម លាបស្រឡាបអវយវៈ ដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវកាសិកពស្ត្រដ៏ឧត្តម ( សំពត់ដែលគេនាំមកអំពីដែនកាសី ) ជាស្ត្រីមានអវយវៈល្អ ដូចជាត្នោតសាវដែលរីកលើកំពូលភ្នំឬដូចជាវល្លិកេសរីកហើយឬក៏ដូចជាឈើប្រទៀង ( រីកហើយ ) ខាងក្នុងទ្វីប ។

ព្រានសត្វស្លាប ប្រាថ្នាចាប់សត្វស្លាបយ៉ាងណា នាងនឹងបៀតបៀនអញ ដោយរូបដែលស្អិតស្អាង ( យ៉ាងនោះ ) ពុំបានទេ ។

នែបុរសខ្មៅ ហេតុអ្វីទើបអ្នកលះបង់ចោលនូវផ្លែ គឺកូនខ្ញុំដែលអ្នកបង្កើតនេះផង លះបង់ខ្ញុំដែលជាស្ត្រីមានកូន ប្រាកដដូច្នោះផង ។

មហាវីរបុរសទាំងឡាយ ដែលមានប្រាជ្ញា តែងលះបង់នូវកូនទាំងឡាយ ទាំងពួកញាតិ ទាំងទ្រព្យ ហើយបួស ដូចជាដំរីដ៏ប្រសើរផ្តាច់នូវចំណង ( ហើយគេចចេញទៅ ) ។

ឥឡូវ ខ្ញុំនឹងបៀតបៀនកូនអ្នកនេះដោយដំបង ឬក្តិចដោយក្រចក ឬ ( បោក ) លើផែនដី អ្នកមិនដល់នូវការយំស្តាយចំពោះកូនទេឬ ។

នែស្ត្រីលាមក មានកូនតូច បើទុកជានាង ឲ្យកូនទៅសត្វ

ចបកនិងពួកក្តែ ក៏នាងញាំងអញឲ្យត្រឡប់វិញពុំបានឡើយ ។

នែបុរសខ្មៅ ណ្ហើយចុះ ឥឡូវនេះបើអ្នកនឹងទៅក្នុងទីណា គឺស្រុកណានិគមណានគរណារាជធានីណា ( ក៏ទៅចុះ ) ។

កាលពីដើម យើងជាអ្នកមានពួក មិនមែនជាសមណៈ សំគាល់ថាជាសមណៈហើយចេញពីស្រុកទៅកាន់ស្រុក កាន់នគរ រាជធានី ។ មែនពិត ព្រះសម្ពុទ្ធទ្រង់មានជោគអង្គនោះ តែងសំដែងធម៌ប្រោសពួកសត្វ ដើម្បីលះបង់សេចក្តីទុក្ខទាំងពួងក្នុងទីជិតស្ទឹងនេរញ្ជរា ខ្ញុំនឹងទៅក្នុងសំណាក់នៃព្រះសម្ពុទ្ធនោះ ព្រះអង្គនឹងជាគ្រូនៃខ្ញុំ ។

ឥឡូវនេះ អ្នកគប្បីទូលរៀបរាប់អំពីកិច្ចថ្វាយបង្គំ ( របស់ខ្ញុំ ) ចំពោះព្រះលោកនាថជាបុគ្គលប្រសើរ រួចហើយធ្វើប្រទក្សិណឧទ្ទិសនូវទក្ខិណាទាន ។

ម្នាលនាងចាបា នាងពោលនូវពាក្យនោះ យ៉ាងណា យើងគប្បីបាន ( អាចឲ្យ ) នូវចំណែកបុណ្យនោះ ឥឡូវនេះខ្ញុំនឹងទូលរៀបរាប់នូវកិច្ចថ្វាយបង្គំរបស់នាង ចំពោះព្រះលោកនាថជាបុគ្គលប្រសើរនឹងធ្វើប្រទក្សិណឧទ្ទិសនូវទក្ខិណា (បុណ្យ) ។

លំដាប់នោះឯង បុរសខ្មៅចៀសចេញអំពីទីនោះទៅ បុរសខ្មៅនោះ ក៏បានចួបនឹងព្រះសម្ពុទ្ធ ក្បែរស្ទឹងនេរញ្ជរា កំពុងសំដែងនូវឧបាយនៃព្រះនិព្វាន ឈ្មោះអមតៈ គឺទុក្ខ ១ ហេតុ

កើតឡើងនៃទុក្ខ ១ ការកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ១ ។ បុរសខ្មៅថ្វាយបង្គំនូវព្រះបាទទាំងឡាយរបស់ព្រះសម្ពុទ្ធនោះ ហើយធ្វើប្រទក្សិណចំពោះព្រះអង្គ ឧទ្ទិសដល់នាងចាបាហើយចូលកាន់ផ្នួស ។ វិជ្ជាបីខ្ញុំបានហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លដ្ឋិហត្ថោ** ប្រែថា កាន់ឈើច្រត់ ។ បទថា **បុរេ** ប្រែថា ក្នុងកាលមុន គឺក្នុងកាលជាបរិព្វាជក ខ្ញុំប្រើដៃកាន់ឈើច្រត់ ដើម្បីការពារគោកាចនិងឆ្កែកាចជាដើម ត្រាច់ទៅ ។ បទថា **សោទានិ មិគលុទ្ទកោ** សេចក្ដីថា ឥឡូវនេះ ខ្ញុំក្លាយជាព្រានម្រឹគ ព្រោះបរិភោគរួមដេករួមជាមួយពួកព្រានម្រឹគ ។ តណ្ហា លោកហៅថា **អាសយ** បាលីថា **អាសាយ** ក៏មាន សេចក្ដីថា ព្រោះគិតអាក្រក់ ។ បទថា **បលិបា** បានដល់ ចាកភក់ គឺកាម និងចាកភក់ គឺទិដ្ឋិ ។ បទថា **ឃោរា** បានដល់ ឈ្មោះថា **ឃោរា** ព្រោះឃោរឃៅ ព្រោះនាំមកនូវការវិនាស ដ៏ធំធេងដែលខ្លួនមិនដឹង ឧបកៈពោលយ៉ាងនេះថា **នាសក្ខិំ បារមេតវេ** ដូច្នេះ សំដៅយកចំពោះខ្លួនប៉ុណ្ណោះថា ខ្ញុំមិនអាច មិនអាចនឹងទៅកាន់ព្រះនិព្វានដែលជាត្រើយនាយរបស់ភក់ គឺតណ្ហានោះឯងបាន ។

បទថា **សុមត្តំ មំ មញ្ញមានា** សេចក្ដីថា នាងចាបាយល់ថា ខ្ញុំវង្វេងក្រៃលែងក្នុងនាង គឺដល់នូវការស្រវឹង ទើបធ្វើខ្ញុំឲ្យជាប់ជំពាក់ ឲ្យស្រវឹង

ដោយអំណាចការចិបជ្រប់ក្នុងកាម ។ បទថា **ចាបា បុត្តមតោសយិ** សេចក្តីថា ចាបាកូនស្រីព្រានព្រៃ បំពេកូនបៀតបៀនខ្ញុំ ចំអកដោយន័យថា កូនឧបកាជីវកជាដើម អាចារ្យពួកខ្លះពោលថា **សុបតិ មំ មញ្ញមានា** ក៏មានសេចក្តីថា សម្គាល់ខ្ញុំថាដេកលក់ ។ បទថា **ចាបាយ ពន្ធនំ ឆេត្វា** បានដល់ កាត់នូវគ្រឿងចង គឺកិលេសដែលកើតឡើងក្នុងខ្លួននាងចាបា ។ បទថា **បព្វជិស្សំ បុនោបហំ** បានដល់ ខ្ញុំនឹងបួសទៀត ជាលើកទី ២ ។ ឥឡូវនេះ នាងចាបា កាលបានស្តាប់ពាក្យដែលឧបកៈពោលថា មិនមានសេចក្តីត្រូវការខ្លួនហើយ កាលសូមទោសទើបពោលថា **មា មេ កុជ្ឈិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **មា មេ កុជ្ឈិ** បានដល់ សូមកុំក្រោធខ្ញុំដោយត្រឹមតែអាការធ្វើនូវការចំអន់ឡើយ នាងចាបាហៅឧបកៈថា មហាវីរៈ មហាមុនី ។ នាងចាបាគិតថា កាលមុនឧបកៈបួស គេចមកហើយ ឥឡូវនេះចង់គេចអំពីអញទៀត បំណងឲ្យឧបកៈអត់ធ្មត់ ទើបហៅថា មហាមុនី ។ ដោយហេតុនោះឯងទើបនាងពោលថា សេចក្តីស្អាតមិនមានដល់បុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់ទេ តបធម៌នឹងមានមកពីណា អធិប្បាយថាអ្នកអត់ធន់នូវហេតុបន្តិចបន្តួចមិនបាន នឹងទូន្មានចិត្តបានដូចម្តេច ឬនឹងប្រព្រឹត្តតបៈបានដូចម្តេច ។

គ្រានោះ ឧបកៈត្រូវនាងចាបាពោលថា អ្នកបំណងនឹងទៅស្រុក នាលៈឬ ទើបពោលថា ខ្ញុំនឹងគេចចេញអំពីស្រុកនាលៈ អ្នកណានឹង នៅក្នុងស្រុកនាលៈនេះបាន អធិប្បាយថា អ្នកណានឹងនៅក្នុងស្រុកនាលៈនេះបាន ខ្ញុំនឹង

*ចេញទៅអំពីស្រុកនាលៈនេះឯង ។ សេចក្តីពិត ស្រុកនាលៈនោះ ជាស្រុក កំណើតរបស់ឧបកៈនោះ គាត់ចេញអំពីស្រុកនាលៈនោះទៅបួស ។ ស្រុក នាលៈនោះនៅក្នុងទីជិតពោធិមណ្ឌលដ្ឋាន ក្នុងដែនមគធៈ ។ ឧបកៈសំដៅ ដល់ស្រុកនាលៈនោះ ទើបពោលយ៉ាងនេះ ។ បទថា* **ពន្ធន្តិ ឥត្ថិរូបេន សមណោ ធម្មជីវិនោ** *អធិប្បាយថា ហៃនាងចាបា នាងចង អ្នកបួសដែល រស់នៅដោយធម៌ តាំងនៅក្នុងធម៌ដោយរូបស្រ្តី ដោយមាយាស្រ្តី របស់ខ្លួន ឥឡូវនេះ ខ្ញុំមានសភាពដូច្នេះព្រោះហេតុណា ព្រោះហេតុនោះ ខ្ញុំនឹងរលាស់ ចោលនូវសភាពបែបនោះ ។*

*កាលឧបកៈពោលយ៉ាងនេះ នាងចាបាបំណងធ្វើឲ្យឧបកៈត្រឡប់ ទើប ពោលគាថាថា* **ឯហិ កាឡ** *ជាដើម ។ គាថានោះមានសេចក្តីថា បពិត្រ ឧបកៈឈ្មោះកាឡៈ ព្រោះជាមនុស្សមានស្បែកខ្មៅ ចូរមក ចូរត្រឡប់មក កុំចៀសចេញទៅឡើយ ចូរបរិភោគកាម ដូចអំពីកាលមុន ខ្ញុំលះពួកញាតិ របស់ខ្ញុំគ្រប់គ្នា រមែងនៅក្នុងអំណាចគឺព្រមនៅក្នុងអំណាច ព្រោះមិនត្រូវការ ឲ្យអ្នកចៀសចេញទៅ ។ ឧបកៈស្តាប់ពាក្យនោះហើយ ទើបពោលគាថាថា* **ឯត្តោ ចាបេ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ចាបេ** *ជាអាលបនៈ ។ ពិតហើយ នាងបានឈ្មោះថា ចាបា ព្រោះមានម្រាមដៃវៀវដូចដងធ្នូ ព្រោះ ហេតុនោះ ទើបហៅថា ចាបា អធិប្បាយថា នែចាបា នាងពោលយ៉ាងណា ឥឡូវនេះ ពោលពាក្យបែបណា នាងគប្បីធ្វើនូវពាក្យដែលជាទីស្រឡាញ់ជា ៤ ចំណែកអំពីពាក្យបែបនេះ សេចក្តីនោះ នឹងមានសេចក្តីសំខាន់សម្រាប់*

បុរសដែលស្រឡាញ់នាង ដែលត្រូវកាគៈគ្របសង្កត់ តែឥឡូវនេះ ខ្ញុំប្រាស ចាកតម្រេកក្នុងនាង និងក្នុងកាមទាំងឡាយហើយ ព្រោះហេតុនោះខ្ញុំមិនព្រម ធ្វើតាមពាក្យរបស់នាង ។

នាងចាបា បំណងនឹងឲ្យឧបកៈនោះ ជាប់ចិត្តក្នុងខ្លួននាង ទើបពោលថា **កាឡង្គិនី** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កាឡ** ជាពាក្យហៅឧបកៈ នោះ ។ បទថា **អង្គិនី** បានដល់ ដល់ព្រមដោយសរីរៈនៅក្មេង ។ សព្ទថា **ឥវ** ត្រឹមតែជានិបាត ចុះក្នុងអត្ថឧបមា គឺប្រៀបធៀបសេចក្តី ។ បទថា **តក្ការី បុប្ផិតំ គិរិមុទ្ធនិ** បានដល់ ដូចទទឹមរីកលើកំពូលភ្នំ ។ ម្យ៉ាងទៀត អាចារ្យពួកខ្លះពោលថា **ឧក្កាគារី** ក៏មានសេចក្តីថា ដូចឈើថ្មៀបរងើកភ្លើង ឯពាក្យថា **គិរិមុទ្ធនិ** នេះ នាងចាបាពោលដើម្បីសម្តែងដល់លម្អដែលបុគ្គល ណាមួយប្រៀបធៀបមិនបាន អាចារ្យពួកខ្លះពោលបាឋៈថា **កាលិង្គិនី** ហើយ ប្រាប់សេចក្តីនៃពាក្យនោះថា ដូចវល្លិត្រឡាច ។ បទថា **ផុល្លំ ទាលិមលដ្ឋឹវ** បានដល់ ដូចក្រូចព្រៃដែលចេញផ្កា ។ បទថា **អន្តោទីបេវ ទាដលី** បាន ដល់ ដូចដើមប្រទៀងខាងក្នុងទ្វីប **ទីប** សព្ទក្នុងពាក្យនេះ នាងចាបា ពោល ដើម្បីសម្តែងនូវលម្អដែលគួរអស្ចារ្យ ។

បទថា **ហរិចន្ទនលិត្តង្គី** បានដល់ មានសរីរៈដែលលាបដោយចន្ទន៍ ក្រហម ។ បទថា **កាសិកុត្តមធារិនី** បានដល់ ទ្រទ្រង់នូវសំពត់ គឺស្បៀក ដណ្តប់សំពត់ដែនកាសីដ៏ប្រសើរ ។ បទថា **តំ មំ** ប្រែថា ខ្ញុំជាបុគ្គលបែបនោះ ។ បទថា **រូបវតី សន្តី** បានដល់ ជាអ្នកល្អព្រម ។ បទថា **កស្ស ឱហាយ**

**គច្ឆសិ** បានដល់ អ្នកលះបង់ គឺលោសចោល ព្រោះហេតុសត្វឈ្មោះណា ឬ ព្រោះហេតុអ្វី និងព្រោះអ្វី ។

ខាងមុខអំពីនេះ ជាគាថាដែលជនទាំងពីរ ឆ្លើយឆ្លងគ្នា វៀរលែងតែគាថា ៣ ខាងចុង ។ បណ្ដាបទទាំងនោះ បទថា **សាកុណិកោ វ** បានដល់ដូចព្រានបក្សី ។ បទថា **អាហារិមេន រូបេន** សេចក្ដីថា នាងបៀតបៀនខ្ញុំដោយការប្រោះព្រំរាងកាយ មានការចងសក់ជាដើម និងដោយគ្រឿងប្រដាប់មានសំពត់ជាដើម ដោយរូប ដោយពណ៌ ដោយកេរ្តិ៍ឈ្មោះ និងដោយភាពជំនាញ ។ បទថា **ន មំ ត្វំ ពាធយិស្សសិ** សេចក្ដីថា ឥឡូវនេះ នាងនឹងបៀតបៀនខ្ញុំមិនបានដូចក្នុងកាលមុនឡើយ ។ បទថា **បុត្តផលំ** បានដល់ផ្លែ ពោលគឺបុត្ត គឺសត្វចិញ្ចឹម គឺបុត្ត ។

បទថា **សប្បញ្ញា** បានដល់ ជាអ្នកមានបញ្ញា អធិប្បាយថា ដែលប្រកបដោយបញ្ញាដឹងច្បាស់នូវទោសក្នុងសង្សារ ពិតហើយ បុគ្គលអ្នកមានបញ្ញាទាំងនោះ រមែងលះបង់នូវញាតិសន្ដាន ឬគំនរទ្រព្យសម្បត្តិតូចធំ ចេញបួស ដោយហេតុនោះ ទើបឧបកៈពោលថា **បព្វជន្តិ មហាវីរា នាគោ ឆេត្វាវ ពន្ធនំ** ដូច្នោះ អធិប្បាយថា លោកអ្នកដែលមានសេចក្ដីព្យាយាមធំប៉ុណ្ណោះ ទើបលះនូវចំណង គឺគ្រហស្ថបួសបាន ដូចស្ដេចដំរីកាត់ចំណង គឺដែកចៀសចេញទៅ បុគ្គលមានសេចក្ដីព្យាយាមថោកថយ មិនអាចបួសបានឡើយ ។

បទថា **ឧណ្ណេន** បានដល់ កំណាត់ឈើណាមួយ ។ បទថា **ដុរិកាយ**

បានដល់ កាំបិតកោរ ។ បទថា **ភូមិយំវ និសុម្ភេយ្យំ** បានដល់ បៀតបៀន ដោយការវាយ និងចាក់ជាដើម ឲ្យដួលចុះលើផែនដី ។ បទថា **បុត្តសោកា ន គច្ឆសិ** បានដល់ នឹងមិនទៅ ព្រោះសោកដល់បុត្ត ។

បទថា **បធាហិសិ** បានដល់ សម្តែង ។ បទថា **បុត្តកាតេ្ត** ប្រែថា ព្រោះហេតុនៃបុត្ត ។ ពាក្យថា **ជម្មិ** ជាពាក្យហៅនាងចាបានោះ សេចក្តីថា នៃស្រីអាក្រក់ ។

ឥឡូវនេះ នាងចាបា កាលអនុញ្ញាតឲ្យឧបកៈនោះទៅ តែចង់ដឹងទីទៅ ទើបពោលគាថាថា **ហន្ទ ខោ** ជាដើម ។

ឧបកៈកាលសម្តែងថា កាលមុន ខ្ញុំរាប់អានសាសនា ដែលមិននាំសត្វចេញចាកទុក្ខ តែឥឡូវនេះ ខ្ញុំបំណងនឹងរាប់អានក្នុងសាសនារបស់ព្រះអានន្ត-ជិនៈ ដែលនាំសត្វចេញចាកទុក្ខ ព្រោះហេតុនោះ ទើបខ្ញុំចាំបាច់ទៅគាល់ព្រះអង្គ ទើបពោលគាថាថា **អហុម្ហា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **គណរិនោ** បានដល់ ជាអ្នកគ្រប់គ្រងគណៈ ។ បទថា **អសមណា** បានដល់ ជាអ្នកស្ងប់បាបមិនទាន់បាន ។ បទថា **សមណមានិនោ** បានដល់ មានការយល់ថា ស្ងប់បាបបានហើយ ។ ដោយបទថា **វិចរិម្ហា** ឧបកៈពោលដោយចាត់ខ្លួនឯងទុកក្នុងសាស្តាទាំងឡាយ មានបូរណកស្សបៈជាដើម ។

បទថា **នេរញ្ជរំ បតិ** បានដល់ ក្បែរស្ទឹងនេរញ្ជរា គឺមាត់ស្ទឹងនោះ ។ បទថា **ពុទ្ធោ** បានដល់ ត្រាស់ដឹងអភិសម្ពោធិ ឧបកៈពោលដោយយល់ថា ព្រះមានព្រះភាគកាលត្រាស់ដឹងអភិសម្ពោធិហើយ ក៏ទ្រង់សម្តែងធម៌ គង់

នៅក្នុងទីនោះឯងសព្វកាល ។

បទថា **វន្ទនំ ធាធិ មេ វជ្ជាសិ** សេចក្ដីថា សូមអ្នកក្រាបទូលដល់ការថ្វាយបង្គំរបស់ខ្ញុំ គឺទូលព្រះលោកនាថដ៏កំពូលតាមពាក្យរបស់ខ្ញុំ ។ បទថា **បទក្ខិណាញ្ច កត្វាន អាទិសេយ្យាសិ ទក្ខិណំ** បានដល់ កាលអ្នកធ្វើប្រទក្សិណាព្រះមានព្រះភាគ ៣ ជុំហើយ ថ្វាយបង្គំក្នុងទិសទាំង ៤ កាលឲ្យចំណែកបុណ្យដល់ខ្ញុំអំពីបុណ្យនោះ គប្បីតាំងចិត្តឧទ្ទិសចំណែកទក្ខិណាឲ្យផង ។ នាងចាបាពោលយ៉ាងនេះ ក៏ព្រោះធ្លាប់បានឮពុទ្ធគុណមកអំពីមុន និងព្រោះខ្លួនដល់ព្រមដោយហេតុ ។ បទថា **ឯតំ ខោ លព្ភំ អម្ហេហិ** អធិប្បាយថា បុណ្យ គឺការធ្វើប្រទក្សិណនេះ ខ្ញុំអាចឲ្យដល់នាងបាន តែខ្ញុំមិនអាចត្រឡប់ទៅបរិភោគកាមបានដូចអំពីកាលមុនឡើយ ។ បទថា **តេ វជ្ជំ** បានដល់ ប្រាប់ គឺទូលដល់ការថ្វាយបង្គំរបស់នាង ។ បទថា **សោ** បានដល់ លោកកាឡៈ ( ឧបកៈ ) ។ បទថា **អទ្ទសាសិ** ប្រែថា បានឃើញហើយ ។

ឧបកៈពោលពាក្យថា **ទុក្ខំ** ព្រោះការសម្ដែងសច្ចជាគោលនៃទេសនានៃព្រះសាស្ដា ព្រោះមិនសម្ដែងសច្ចមិនបាន ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា ចាបាថេរីគាថា ចប់

# សុន្ទរីថេរីគាថា

[ ៣៣៤ ] ( ព្រាហ្មណ៍ជាបិតាសួរថា ) នែនាងដ៏ចម្រើន ក្នុងកាលមុន នាងកាលស៊ីកូនទាំងឡាយដែលស្លាប់ហើយ នាងក្តៅក្រហាយក្រៃពេក ទាំងថ្ងៃទាំងយប់ ។ ម្នាលព្រាហ្មណី ជាវាសិដ្ឋគោត្ត ថ្ងៃនេះ នាងស៊ីកូនទាំងអស់ ៧ នាក់ ព្រោះហេតុអ្វី នាងមិនក្តៅក្រហាយខ្លាំង ។

( វាសិដ្ឋថេរីពោលថា ) ម្នាលព្រាហ្មណ៍ កូនទាំងរយ ពួកញាតិទាំងរយជាច្រើនរបស់ខ្ញុំ គឺខ្ញុំនឹងអ្នកស៊ីហើយ ក្នុងចំណែកកន្លងទៅហើយ ។ ខ្ញុំនោះដឹងនូវព្រះនិព្វាន ជាគ្រឿងរលាស់ជាតិនិងមរណៈ ទើបមិនសោក មិនយំ ទាំងមិនក្តៅក្រហាយ ។

ឱ នាងជាវាសិដ្ឋគោត្ត នាងនិយាយសម្តីបែបនេះ អស្ចារ្យណាស់ នាងដឹងច្បាស់នូវធម៌របស់អ្នកណា ទើបនិយាយសម្តីបែបនេះ ។

ម្នាលព្រាហ្មណ៍ ព្រះសម្ពុទ្ធអង្គនោះសំដែងធម៌ដល់សត្វទាំងឡាយដើម្បីលះបង់នូវទុក្ខទាំងពួង ជិតនគរមិថិលា ។ ម្នាលព្រាហ្មណ៍ ខ្ញុំបានស្តាប់ធម៌របស់ព្រះអរហន្តអង្គនោះ ដែលជាធម៌មិនមានឧបធិក្កិលេស បានដឹងច្បាស់នូវសច្ចធម៌ហើយក្នុងទីនោះ ទើបបន្ទោបង់នូវសេចក្តីសោកព្រោះកូនបាន ។

ខ្ញុំនោះនឹងទៅក្នុងទីជិតក្រុងមិថិលាដែរ ធ្វើដូចម្តេចហ្ន៎ ព្រះមានជោគអង្គនោះ គប្បីដោះខ្ញុំចាកទុក្ខទាំងពួងបាន ។

ព្រាហ្មណ៍បានចួបនឹងព្រះពុទ្ធ ព្រះអង្គផុតស្រឡះចាក ( កិលេស ) មិនមានឧបធិក្កិលេស ព្រះមុនីទ្រង់ដល់នូវត្រើយនៃទុក្ខ បានសំដែងប្រាប់ព្រាហ្មណ៍នោះនូវសច្ចធម៌ គឺទុក្ខ ១ ហេតុកើតឡើងនៃទុក្ខ ១ ការកន្លង

នូវទុក្ខ ១ មគ្គប្រកបដោយអង្គប្រាំបីដ៏ប្រសើរជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ សុជាតព្រាហ្មណ៍មានសច្ចធម៌ដ៏ផងច្បាស់ហើយ ក្នុងទីនោះ ពេញចិត្តនឹងបព្វជ្ជា បានសម្រេចវិជ្ជាបីដោយរាត្រីបី ។

ព្រាហ្មណ៍ពោលថា ម្នាលសារថី អ្នកចូរមក អ្នកចូរទៅ ចូរនាំរថនេះទៅវិញចុះ រួចចូរប្រាប់ព្រាហ្មណីកុំឲ្យមានមោះមៃថា ឥឡូវនេះសុជាតព្រាហ្មណ៍បួសហើយ បានសម្រេចវិជ្ជាបី ដោយរាត្រីបី ។

( លំដាប់នោះ សារថីនាំយករថផង កហាបណៈមួយពាន់ផង ហើយប្រាប់នាងព្រាហ្មណីមិនឲ្យមោះមៃថា ឥឡូវនេះ សុជាតព្រាហ្មណ៍បួសហើយ បានសម្រេចវិជ្ជាបីដោយរាត្រីបីហើយ ) ។

( ព្រាហ្មណីពោលថា ) ម្នាលសារថី ខ្ញុំសូមឲ្យរថដែលទឹមដោយសេះនេះ និងកហាបណៈមួយពាន់នេះ ជាអំណោយដល់អ្នក ព្រោះបានឮថា ព្រាហ្មណ៍បានត្រៃវិជ្ជា ។

( សារថីពោលថា ) ម្នាលព្រាហ្មណី រថដែលទឹមដោយសេះ និងកហាបណៈមួយពាន់នេះចូរនៅជារបស់នាងដដែលចុះ ខ្ញុំនឹងបួសក្នុងសំណាក់នៃព្រះសាស្តា ព្រះអង្គមានប្រាជ្ញាដ៏ប្រសើរដែរ ។

( ព្រាហ្មណីពោលនឹងនាងសុន្ទរីថា ) នែនាងសុន្ទរី បិតារបស់នាងលះបង់នូវដំរី គោ សេះ កែវមណី និងកុណ្ឌល ទ្រព្យសម្បត្តិ ដ៏ស្តុកស្តម្ភ នៅក្នុងផ្ទះនេះទៅបួសហើយ នាងចូរប្រើប្រាស់នូវភោគៈទាំងឡាយចុះ ( ព្រោះថា ) នាងជាទាយាទក្នុងត្រកូល ។

( នាងសុន្ទរីពោលថា ) បិតារបស់ខ្ញុំលះបង់នូវដំរី គោ សេះ កែវមណី កុណ្ឌល និងទ្រព្យសម្បត្តិដែលមានក្នុងផ្ទះនេះទៅបួសព្រោះត្រូវសេចក្តីសោកនឹងកូនគ្របសង្កត់ ចំណែកខាងខ្ញុំក៏នឹងបួសដែរ ព្រោះត្រូវសេចក្តីសោកនឹងបងគ្របសង្កត់ ។

( ព្រាហ្មណីពោលថា ) ហៃនាងសុន្ទរី នាងប្រាថ្នានូវតម្រិះណា សូមឲ្យនាងបានសម្រេចនូវតម្រិះនោះ ដុំបាយតាមលំដាប់ផ្ទះក្តី អាហារបំណាក្តី បំសុកូលចីវរក្តី ( ដែលនាងត្រូវស្វែងរក ) កាលបើនាងជម្រះនូវវត្ថុទាំងនេះ នឹងបានជាស្រីមិនមានអាសវៈក្នុងបរលោក ។

( នាងសុន្ទរីនិយាយនឹងឧបជ្ឈាយ៍ថា ) បពិត្រព្រះនាងជាម្ចាស់ ខ្ញុំនៅជាសិក្ខមានា បានជម្រះទិព្វចក្ខុហើយ កាលពីដើមខ្ញុំធ្លាប់នៅអាស្រ័យក្នុងទីណា ខ្ញុំដឹងនូវបុព្វេនិវាសក្នុងទីនោះ ។ បពិត្រព្រះនាងជាកល្យាណីដ៏ល្អរបស់ថេរីសង្ឃ វិជ្ជាបីខ្ញុំបានដល់ហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ព្រោះតែអាស្រ័យនូវព្រះនាង ។ បពិត្រព្រះនាងជាម្ចាស់ ខ្ញុំចង់ទៅកាន់ក្រុងសាវត្ថី សូមព្រះនាងអនុញ្ញាតដល់ខ្ញុំឲ្យទាន ខ្ញុំនឹងបន្លឺនូវសីហនាទ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ។

ម្នាលនាងសុន្ទរី នាងចូរមើលព្រះសាស្តា ព្រះអង្គមានសម្បុរដូចមាស មានព្រះតចៈពណ៌ដូចមាស ទូន្មានពួកសត្វដែលគេមិនទាន់ទូន្មាន ព្រះអង្គជាអ្នកត្រាស់ដឹងឯង ឥតមានភ័យអំពីណាឡើយ ។ សូមព្រះអង្គទតនាងសុន្ទរីដែលកំពុងដើរមក ជាស្ត្រីផុតស្រឡះ (ចាកកិលេស ) ឥតមានឧបធិ

ប្រាសចាកតម្រេក ប្រាសចាកគ្រឿងប្រកប មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ បពិត្រព្រះអង្គជាមហាវីរបុរស នាងសុន្ទរី ជាសាវិកា របស់ព្រះអង្គ ចេញអំពីក្រុងពារាណសី មកកាន់សំណាក់ព្រះអង្គ ថ្វាយបង្គំ នូវព្រះបាទទាំងឡាយ ។ បពិត្រព្រះមានព្រះភាគ ជាខីណាសវព្រាហ្មណ៍ព្រះ អង្គជាព្រះពុទ្ធ ព្រះអង្គជាគ្រូ ( របស់ខ្ញុំ ) ខ្ញុំព្រះអង្គជាធីតារបស់ព្រះអង្គ ជា ឱរសកើតអំពីព្រះឱស្ឋ មានកិច្ចធ្វើរួចហើយ ឥតមានអាសវៈ ។

ម្នាលនាងដ៏ចម្រើន ដំណើររបស់នាងមកល្អហើយ ដំណើររបស់នាង មកអំពីទីនោះ មិនឆ្ងាយទេ ព្រោះពួកអ្នកមានឥន្ទ្រិយទូន្មានហើយ ប្រាសចាក តម្រេក ប្រាសចាកគ្រឿងប្រកប មានកិច្ចធ្វើហើយ ឥតមានអាសវៈ រមែង មកថ្វាយបង្គំព្រះបាទាព្រះសាស្តាដូចនាងដែរ ។

**សុន្ទរីថេរី ។**

# អដ្ឋកថា

## សុន្ទរីថេរីគាថា

[ ៣៣៤ ] គាថារបស់ព្រះនាងសុន្ទរីថេរី មានពាក្យផ្ដើមថា **បេតានិ ភោតិ បុត្តានិ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ក្នុងកប្បទី ៣១ រាប់ថយក្រោយអំពីភទ្ទកប្បនេះ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាវេស្សភូ កុលធីតារូបនេះ កើតក្នុងផ្ទះមានត្រកូលដ៏ងក្ដីហើយ ថ្ងៃមួយ ឃើញព្រះសាស្ដា កំពុងនិមន្តបិណ្ឌបាត មានចិត្តជ្រះថ្លាប្រគេនភិក្ខា ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ ព្រះសាស្ដាទ្រង់ជ្រាបថា នាងមានចិត្តជ្រះថ្លា ទ្រង់ធ្វើអនុមោទនាហើយ ក៏យាងទៅ ។ ព្រោះបុណ្យនោះ នាងកើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស នៅក្នុងស្ថានសួគ៌នោះដរាបដល់អស់អាយុ សោយទិព្វសម្បត្តិហើយ ចុតិចាកស្ថានសួគ៌នោះ អន្ទោលទៅមកក្នុងសុគតិប៉ុណ្ណោះ មានញាណចាស់ក្លា ក្នុងពុទ្ធុប្បាទនេះ កើតជាធីតារបស់ព្រាហ្មណ៍ឈ្មោះសុជាត ក្នុងក្រុងពារាណសី ព្រោះនាងមានរូបសម្បត្តិស្អាត ទើបមានឈ្មោះថាសុន្ទរី កាលចម្រើនវ័យហើយ ប្អូនប្រុសរបស់នាងក៏ស្លាប់ បិតារបស់នាងសោយសោកព្រោះបុត្តនោះស្លាប់ក្រៃលែង ត្រាច់ទៅក្នុងទីផ្សេងៗ បានជួបជាមួយព្រះថេរី ឈ្មោះវាសិដ្ឋី កាលនឹងសាកសួរព្រះថេរីដល់ហេតុដើម្បីបន្ទោបង់សេចក្ដីសោក ទើបពោល ២ គាថាថា **បេតានិ**

**ភោគា ហិ បុត្តានិ** ជាដើម ព្រះថេរីដឹងថាព្រាហ្មណ៍មានសេចក្ដីសោកខ្លាំងបំណង នឹងជួយបន្ទោបង់នូវសេចក្ដីសោក ក៏ពោល ២ គាថាថា **ពហូនិ បុត្ត-សតានិ** ជាដើម ហើយប្រាប់ដល់រឿងដែលខ្លួនមិនសោក ព្រាហ្មណ៍ស្ដាប់រឿងនោះហើយ ក៏សួរព្រះថេរីថា បពិត្រព្រះនាងម្ចាស់ នាងមិនសោកយ៉ាងនេះបានដូចម្ដេចទើបព្រះថេរីពណ៌នាគុណព្រះរតនត្រ័យដល់ព្រាហ្មណ៍នោះ ។

ព្រាហ្មណ៍សួរថា ព្រះសាស្ដាគង់នៅឯណា ដឹងថាពេលនេះ គង់នៅក្នុងមិថិលា ។ ក្នុងវេលានោះឯង ក៏ទឹមរថបរទៅកាន់ក្រុងមិថិលា ចូលគាល់ព្រះសាស្ដា ថ្វាយបង្គំ ពោលសម្មោទនីយកថាតាមទំនៀម ហើយក៏អង្គុយសមគួរនាចំណែកម្ខាង ព្រះសាស្ដាក៏ទ្រង់សម្ដែងធម៌ដល់ព្រាហ្មណ៍ ព្រាហ្មណ៍ស្ដាប់ធម៌ហើយបាននូវសទ្ធាក៏បួស ផ្ដើមចម្រើនវិបស្សនា ព្យាយាម ក្នុងថ្ងៃទី ៣ ក៏សម្រេចអរហត្ត ។ កាលនោះសារថីបររថ ក៏នាំរថទៅកាន់ក្រុងពា-រាណសី ប្រាប់រឿងរ៉ាវដល់ព្រាហ្មណីជាភរិយា ។ ឯនាងសុន្ទរី ដឹងរឿងដែលឪពុកខ្លួនបួស ក៏លាមាតាថា បពិត្រអ្នកម៉ែ កូននឹងបួស មាតាពោលថា នែកូនភោគសម្បត្តិក្នុងផ្ទះនេះ ជារបស់កូន ចូរកូនជាទាយាទ ទទួលមត៌ករបស់ត្រកូលនេះ ចូរបរិភោគទ្រព្យសព្វយ៉ាង កុំបួសឡើយ ។ នាងសុន្ទរីពោលថា កូនមិនត្រូវការភោគទ្រព្យទេ កូននឹងបួស ។ នាងអង្វរ រហូតមាតាអនុញ្ញាត ហើយក៏លះបង់មហាភោគសម្បត្តិដូចដុំទឹកមាត់ ហើយបួស ។ កាលបួសជាសិក្ខមានាហើយ ចម្រើនវិបស្សនា ព្យាយាម ព្រោះញាណចាស់ក្លា ដល់ព្រមដោយហេតុសម្បទា ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ។

សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

ខ្ញុំកាន់បាយនិងវែក ប្រគេនដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ជាអ្នកស្វែងរកគុណធំព្រះនាមវេស្សភូដែលកំពុងត្រាច់បិណ្ឌបាត ។

ព្រះវេស្សភូសម្មាសម្ពុទ្ធជាសាស្តា ជាលោកនាយក ទ្រង់ទទួលហើយ ទ្រង់ឈរត្រង់ចំណែកនៃផ្លូវ ទ្រង់ធ្វើអនុមោទនាដល់ខ្ញុំថា បាយមួយវែក ( ដែលនាងឲ្យ ) នាងនឹងទៅកាន់ឋានតាវត្តិង្ស បានជាមហេសីរបស់សក្កទេវរាជ ៣៦ ដង នឹងបានជាមហេសីរបស់ស្តេចចក្រពត្តិ ៥០ ដង នាងមានចិត្តគិតយ៉ាងណានឹងបានសម្រេចសព្វយ៉ាង ។

កាលនាងសោយសម្បត្តិហើយ នឹងចេញបួស មិនមានកិលេសជាគ្រឿងកង្វល់ កំណត់ដឹងអាសវៈទាំងពួងហើយជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ព្រះវេស្សភូសម្មាសម្ពុទ្ធជាលោកនាយក មានព្រះតម្រាស់យ៉ាងនេះហើយ ទ្រង់យាងទៅតាមអាកាស ដូចស្តេចហង្សត្រាច់ទៅក្នុងលំហាមេឃ ។

ទានដ៏ប្រសើរខ្ញុំបានឲ្យហើយ យាគសម្បទាខ្ញុំក៏បូជាហើយ ខ្ញុំឲ្យបាយមួយវែក ហើយបានសម្រេចនូវអចលបទ គឺព្រះនិព្វាន ។

ក្នុងកប្បទី ៣១ អំពីកប្បនេះ ខ្ញុំបានថ្វាយភិក្ខុទាន ឯណា

ក្នុងកាលនោះ ខ្ញុំមិនស្គាល់ទុគ្គតិឡើយ នេះជាផលនៃកិច្ចទាន
កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំងសាសនា
របស់ព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ដូច្នេះ ។

សិក្ខមានាសុន្ទរី កាលសម្រេចអរហត្តហើយ នៅដោយសុខក្នុងផលនិង សុខក្នុងព្រះនិព្វាន តមកឧបសម្បទាហើយគិតថា អញនឹងបន្លឺសីហនាទចំពោះ ព្រះភក្ត្ររបស់ព្រះសាស្តា ទើបលាព្រះឧបជ្ឈាយ៍ ចេញអំពីក្រុងពារាណសី មួយអន្លើដោយភិក្ខុនីច្រើនរូប ដើរទៅដល់ក្រុងសាវត្ថីដោយលំដាប់ ហើយ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយឈរក្នុងទីសមគួរនាចំណែកម្ខាង ព្រះ សាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ នាងក៏ព្យាករអរហត្ត ដោយប្រកាសភាព ដែលខ្លួនជាធីតាកើតអំពីទ្រូងរបស់ព្រះសាស្តាជាដើម កាលនោះ ពួកញាតិ មានមាតារបស់នាងនិងមនុស្សជិតស្និទ្ធ ក៏នាំគ្នាចេញបួស ។ ក្នុងកាលតមក ព្រះនាងសុន្ទរីថេរីនោះ ពិចារណាដល់ការបដិបត្តិរបស់ខ្លួន ទើបពោលគាថា ទាំងនេះ ជាឧទាន តាំងអំពីគាថាដែលបិតាពោលមកហើយថា

( ព្រាហ្មណ៍ជាបិតាសួរថា ) នៃនាងដ៏ចម្រើន ក្នុងកាល
មុន នាងកាលស៊ីកូនទាំងឡាយ ដែលស្លាប់ហើយ នាងក្តៅ
ក្រហាយក្រៃពេក ទាំងថ្ងៃទាំងយប់ ។ ម្នាលព្រាហ្មណី ជា
វាសិដ្ឋគោត្ត ថ្ងៃនេះ នាងស៊ីកូនទាំងអស់ ៧ នាក់ ព្រោះ
ហេតុអ្វី នាងមិនក្តៅក្រហាយខ្លាំង ។

( វាសិដ្ឋថេរីពោលថា ) ម្នាលព្រាហ្មណ៍ កូនទាំងរយ

ពួកញាតិទាំងរយជាច្រើនរបស់ខ្ញុំ គឺខ្ញុំនឹងអ្នកស៊ីហើយ ក្នុងចំណែកកន្លងទៅហើយ ។ ខ្ញុំនោះដឹងនូវព្រះនិព្វាន ជាគ្រឿងរលាស់ជាតិនិងមរណៈ ទើបមិនសោក មិនយំ ទាំងមិនក្តៅក្រហាយ ។

ឱ នាងជាវាសិដ្ឋគោត្ត នាងនិយាយសម្តីបែបនេះ អស្ចារ្យណាស់ នាងដឹងច្បាស់នូវធម៌របស់អ្នកណា ទើបនិយាយសម្តីបែបនេះ ។

ម្នាលព្រាហ្មណ៍ ព្រះសម្ពុទ្ធអង្គនោះ សំដែងធម៌ដល់សត្វទាំងឡាយដើម្បីលះបង់នូវទុក្ខទាំងពួង ជិតនគរមិថិលា ។ ម្នាលព្រាហ្មណ៍ ខ្ញុំបានស្តាប់ធម៌របស់ព្រះអរហន្តអង្គនោះ ដែលជាធម៌មិនមានឧបធិក្កិលេស បានដឹងច្បាស់ នូវសច្ចធម៌ហើយក្នុងទីនោះ ទើបបន្ទោបង់នូវសេចក្តីសោកព្រោះកូនបាន ។

ខ្ញុំនោះនឹងទៅក្នុងទីជិតក្រុងមិថិលាដែរ ធ្វើដូចម្តេចហ្ន៎ ព្រះមានជោគអង្គនោះ គប្បីដោះខ្ញុំចាកទុក្ខទាំងពួងបាន ។

ព្រាហ្មណ៍បានចួបនឹងព្រះពុទ្ធ ព្រះអង្គផុតស្រឡះចាក ( កិលេស ) មិនមានឧបធិក្កិលេស ព្រះមុនីទ្រង់ដល់នូវត្រើយនៃទុក្ខ បានសំដែងប្រាប់ព្រាហ្មណ៍នោះនូវសច្ចធម៌ គឺទុក្ខ ១ ហេតុកើតឡើងនៃទុក្ខ ១ ការកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គប្រាំបីដ៏ប្រសើរជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ សុជាត

ព្រាហ្មណ៍មានសច្ចធម៌ដឹងច្បាស់ហើយក្នុងទីនោះ ពេញចិត្តនឹងបញ្ញា បានសម្រេចវិជ្ជាបីដោយរាត្រីបី ។

ព្រាហ្មណ៍ពោលថា ម្នាលសារថី អ្នកចូរមក អ្នកចូរទៅ ចូរនាំរថនេះទៅវិញចុះ រួចចូរប្រាប់ព្រាហ្មណីកុំឲ្យមានមោះមៃថាឥឡូវនេះ សុជាតព្រាហ្មណ៍បួសហើយ បានសម្រេចវិជ្ជាបីដោយរាត្រីបី ។

( លំដាប់នោះ សារថីនាំយករថផង កហាបណៈមួយពាន់ផង ហើយប្រាប់នាងព្រាហ្មណី មិនឲ្យមោះមៃថា ឥឡូវនេះ សុជាតព្រាហ្មណ៍បួសហើយ បានសម្រេចវិជ្ជាបីដោយរាត្រីបីហើយ ) ។

( ព្រាហ្មណីពោលថា ) ម្នាលសារថី ខ្ញុំសូមឲ្យរថដែលទឹមដោយសេះនេះ និងកហាបណៈមួយពាន់នេះ ជាអំណោយដល់អ្នក ព្រោះបានឮថា ព្រាហ្មណ៍បានត្រៃវិជ្ជា ។

( សារថីពោលថា ) ម្នាលព្រាហ្មណី រថដែលទឹមដោយសេះនិង កហាបណៈមួយពាន់នេះ ចូរនៅជារបស់នាងដដែលចុះ ខ្ញុំនឹងបួសក្នុងសំណាក់នៃព្រះសាស្តា ព្រះអង្គមានប្រាជ្ញាដ៏ប្រសើរដែរ ។

( ព្រាហ្មណីពោលនឹងនាងសុន្ទរីថា ) នែនាងសុន្ទរី បិតារបស់នាងលះបង់នូវដំរី គោ សេះ កែវមណី និងកុណ្ឌល

ទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ នៅក្នុងផ្ទះនេះទៅបួសហើយ នាងចូរប្រើប្រាស់នូវភោគៈទាំងឡាយចុះ ( ព្រោះថា ) នាងជាទាយាទក្នុងត្រកូល ។

( នាងសុន្ទរីពោលថា ) បិតារបស់ខ្ញុំលះបង់នូវដំរី គោ សេះ កែវមណី កុណ្ឌល និងទ្រព្យសម្បត្តិដែលមានក្នុងផ្ទះនេះទៅបួសព្រោះត្រូវសេចក្តីសោកនឹងកូនគ្របសង្កត់ចំណែកខាងខ្ញុំក៏នឹងបួសដែរព្រោះត្រូវសេចក្តីសោកនឹងបងគ្របសង្កត់ ។

( ព្រាហ្មណីពោលថា ) ហៃនាងសុន្ទរី នាងប្រាថ្នានូវតម្រិះណា សូមឲ្យនាងបានសម្រេចនូវតម្រិះនោះ ដុំបាយតាមលំដាប់ផ្ទះក្តី អាហារចំណីក្តី បំសុកូលចីវរក្តី ( ដែលនាងត្រូវស្វែងរក ) កាលបើនាងជម្រះនូវវត្ថុទាំងនេះ នឹងបានជាស្រីមិនមានអាសវៈក្នុងបរលោក ។

( នាងសុន្ទរីនិយាយនឹងឧបជ្ឈាយ៍ថា ) បពិត្រព្រះនាងជាម្ចាស់ ខ្ញុំនៅជាសិក្ខមានា បានជម្រះទិព្វចក្ខុហើយ កាលពីដើម ខ្ញុំធ្លាប់នៅអាស្រ័យក្នុងទីណា ខ្ញុំដឹងនូវបុព្វេនិវាសក្នុងទីនោះ ។ បពិត្រព្រះនាងជាកល្យាណីដ៏ល្អរបស់ថេរីសង្ឃ វិជ្ជាបីខ្ញុំបានដល់ហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ព្រោះតែអាស្រ័យនូវព្រះនាង ។ បពិត្រព្រះនាងជាម្ចាស់ ខ្ញុំចង់ទៅកាន់ក្រុងសាវត្ថី សូមព្រះនាងអនុញ្ញាតដល់ខ្ញុំឲ្យទាន ខ្ញុំនឹងបន្លឺនូវសីហនាទ

ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ។

ម្នាលនាងសុន្ទរី នាងចូរមើលព្រះសាស្តា ព្រះអង្គមានសម្បុរដូចមាស មានព្រះតចៈពណ៌ដូចមាស ទ្រង់ទូន្មានពួកសត្វដែលគេមិនទាន់ទូន្មាន ព្រះអង្គជាអ្នកត្រាស់ដឹងឯង ឥតមានភ័យអំពីណាឡើយ ។ សូមព្រះអង្គនិមន្តទតនាង សុន្ទរីដែលកំពុងដើរមក ជាស្ត្រីផុតស្រឡះ ( ចាកកិលេស ) ឥតមានឧបធិ ប្រាសចាកតម្រេក ប្រាសចាកគ្រឿងប្រកប មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ បពិត្រព្រះអង្គជាមហាវីរបុរស នាងសុន្ទរី ជាសាវិការបស់ព្រះអង្គ ចេញអំពីក្រុងពារាណសី មកកាន់សំណាក់ព្រះអង្គ ថ្វាយបង្គំនូវព្រះបាទទាំងឡាយ ។ បពិត្រព្រះមានព្រះភាគជាខីណាសវព្រាហ្មណ៍ ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាគ្រូ ( របស់ខ្ញុំ ) ខ្ញុំព្រះអង្គជាធីតារបស់ព្រះអង្គ ជាឱរសកើតអំពីព្រះឱស្ឋ មានកិច្ចធ្វើរួចហើយ ឥតមានអាសវៈ ។

ម្នាលនាងដ៏ចម្រើន ដំណើររបស់នាងមកល្អហើយ ដំណើររបស់នាងមកអំពីទីនោះ មិនឆ្ងាយទេ ព្រោះពួកអ្នកមានឥន្ទ្រិយទូន្មានហើយ ប្រាសចាកតម្រេក ប្រាសចាកគ្រឿងប្រកបមានកិច្ចធ្វើហើយ ឥតមានអាសវៈ រមែងមកថ្វាយបង្គំព្រះបាទាព្រះសាស្តាដូចនាងដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បេតានិ** បានដល់ ស្លាប់ហើយ ។ សុជាតព្រាហ្មណ៍ហៅវាសិដ្ឋីថេរីនោះថា **ភោតិ** បពិត្រព្រះនាងដ៏ចម្រើន ។ បទថា **បុត្តានិ** លោកប្រើជាលិង្គវិបល្លាស ( ព្រោះសព្ទថា **បុត្ត** ដោយប្រក្រតីជាបុំលិង្គ តែលោកធ្វើជានបុំសកលិង្គ ) សេចក្ដីដែលត្រូវគឺ **បេតេ បុត្តេ** ប្រែថា កូនប្រុសដែលស្លាប់ហើយ ។ សេចក្ដីពិត កូនប្រុសរបស់វាសិដ្ឋីថេរីនោះ ស្លាប់ទៅហើយ មានតែម្នាក់ប៉ុណ្ណោះ តែព្រាហ្មណ៍សម្គាល់យ៉ាងនេះថា វាសិដ្ឋីថេរីនេះ ត្រូវសេចក្ដីសោកបៀតបៀន ទើបត្រាច់ទៅអស់កាលយូរ ប្រហែលជាកូនប្រុសរបស់នាងស្លាប់ទៅហើយ មានច្រើននាក់ ទើបពោលពាក្យជាពហុវចនៈយ៉ាងនេះថា **សាជ្ជ សព្វានិ ខាទិត្វា សតបុត្តានិ**[១] ។ បទថា **ខាទមានា** នេះ ជាពាក្យតិះដៀលតាមលោកវោហារ ។ ពិតហើយ កូនប្រុសដែលកើតមកគ្រប់គ្នារបស់ស្រីណាក្នុងលោកស្លាប់ទៅទាំងអស់ មនុស្សទាំងឡាយកាលនឹងតិះដៀលស្រីនោះទើបពោលពាក្យថា ស្រីស៊ីកូនជាដើម ។ បទថា **អតីវ** ប្រែថា ហួសនឹងប្រៀប គឺធ្ងន់ ។ បទថា **បរិតប្បសិ** ប្រែថា ក្ដៅក្រហាយ ភ្ជាប់សេចក្ដីជាមួយពាក្យថា **បុរេ** ។ ក្នុងសេចក្ដីនេះ មានសេចក្ដីសង្ខេបដូចតទៅនេះថា បពិត្រព្រះនាងវាសិដ្ឋី អំពីមុន នាងសូម្បីកូនប្រុសស្លាប់ ហឫទ័យក្រៀមក្រំ ដោយសេចក្ដីសោកពន់ពេក ត្រាច់ទៅកាន់គាមនិគមនិងរាជធានីទាំងឡាយ ។

បទថា **សាជ្ជ** កាត់បទជា **សា អជ្ជ** សេចក្ដីថា ឥឡូវនេះ នាងក៏ស៊ីកូនប្រុសអស់រាប់រយនាក់ ។ម្យ៉ាងទៀត បាលីថា **សជ្ជ** ក៏មាន ។ បទថា

**កេន វណ្ណេន** ប្រែថា ព្រោះហេតុអ្វី ។

ដោយបទថា **ខាទិតានិ** ព្រះថេរីពោលអនុលោមតាមពាក្យដែលព្រាហ្មណ៍ពោល ម្យ៉ាងទៀត ព្រះថេរីពោលយ៉ាងនេះ សំដៅដល់ថា កូនត្រូវសត្វសាហាវ មានខ្លាធំ ខ្លាដំបង ឆ្មាព្រៃជាដើម ខាំស៊ីក៏បាន ។ បទថា **អតីតំសេ** ប្រែថា ចំណែកដែលជាអតីត សេចក្តីថា ក្នុងភពដែលកន្លងហើយ ។ បទថា **មម តុយ្ហញ្ច** ប្រែថា ខ្ញុំផង លោកផង ។ បទថា **និស្សរណំ ញត្វា** សេចក្តីថា ចាក់ធ្លុះនូវព្រះនិព្វានដែលជាគ្រឿងរលាស់ចេញនូវជាតិនិងមរណៈដោយមគ្គញ្ញាណ ។ បទថា **ន ចាហំ បរិតប្បាមិ** សេចក្តីថា ខ្ញុំមិនក្តៅក្រហាយ មិនដល់នូវការចង្អៀតចិត្តឡើយ ។

បទថា **អព្ភុតំ វត** ប្រែថា គួរអស្ចារ្យហ្ន៎ ។ ពិតហើយ ការអស្ចារ្យនោះមិនធ្លាប់មានមកអំពីមុន ទើបលោកហៅថា **អព្ភុតំ** ។ បទថា **ឯទិសំ** ប្រែថា បែបនេះ គឺវាចាដែលសម្តែងនូវការមិនមានសេចក្តីសោកជាដើម យ៉ាងនេះថា ទើបមិនសោក មិនយំ ទាំងមិនក្តៅក្រហាយ ព្រោះធម៌បែបនេះ មិនអាចបានមកដោយទំនើងចិត្តដូច្នោះ ដ្បិតពាក្យថា នាងដឹងច្បាស់នូវធម៌របស់អ្នកណា ទើបព្រាហ្មណ៍សួរដល់ព្រះសាស្តា និងពាក្យប្រៀនប្រដៅថា អ្នកនាងម្ចាស់ដឹងច្បាស់នូវធម៌របស់ព្រះសាស្តាអង្គណា ទើបពោលវាចាបែបនេះ ។

បទថា **និរូបធី** បានដល់ មិនមានទុក្ខ ។ បទថា **វិញ្ញាតសទ្ធម្មា** បានដល់ ចាក់ធ្លុះនូវធម៌ គឺអរិយសច្ច ។ បទថា **ព្យធានុធី** បានដល់ នាំចេញគឺលះ ។ បទថា **វិប្បមុត្តំ** បានដល់ រួចផុតដោយប្រការទាំងពួង គឺប្រាស

ចាកកិលេសគ្រប់យ៉ាង និងចាកភពទាំងអស់ ។ បទថា **សោស្ស** កាត់បទជា **សោ អស្ស** បទថា **សោ** គឺព្រះសម្មាសម្ពុទ្ធអង្គនោះ បទថា **អស្ស** គឺព្រាហ្មណ៍ ។ បទថា **តត្ថ** បានដល់ ក្នុងទេសនាពោលដោយសច្ចៈ ៤ នោះ ។ បទថា **រថំ និយ្យាទយាហិមំ** សេចក្តីថា ចូរប្រគល់រថនេះដល់ព្រាហ្មណី ។ បទថា **សហស្សញ្ចាបិ** ប្រកបសេចក្តីថា ចូរនាំរទេះសេះនិងទ្រព្យ ១ ពាន់ កហាបណៈដែលខ្ញុំនាំមកដើម្បីប្រើប្រាស់តាមផ្លូវ ទៅប្រគល់ឲ្យព្រាហ្មណីផង ។

បទថា **អស្សរថំ** បានដល់ រថដែលទឹមដោយសេះ ។ បទថា **បុណ្ណ-បត្តំ** បានដល់ រង្វាន់ដែលឲ្យដំណឹងគួរត្រេកអរ ។

កាលព្រាហ្មណីឲ្យរង្វាន់សម្រាប់ដំណឹងល្អយ៉ាងនេះ សារថីមិនព្រមទទួលរង្វាន់ ត្រឡប់ពោលគាថាថា **តុយ្ហេវ ហោតុ** ជាដើម ហើយទៅបួសក្នុងសម្នាក់ព្រះសាស្តាដូចគ្នា កាលសារថីបួសហើយ ព្រាហ្មណីក៏ហៅសុន្ទរីធីតារបស់ខ្លួនមកកាលដឹកនាំឲ្យនៅក្នុងឃរាវាសវិស័យទើបពោលគាថាថា **ហត្ថិ-គវស្សំ** ជាដើម ក្នុងគាថានោះ បទថា **ហត្ថិ** បានដល់ ដំរីជាច្រើន ។ បទថា **គវស្សំ** បានដល់ គោនិងសេះជាច្រើន ។ បទថា **មណិកុណ្ឌលញ្ច** បានដល់ កែវមណីនិងកុណ្ឌល ។ បទថា **ផីតញ្ចិមំ គេហវិតតំ បហាយ** សេចក្តីថា បិតារបស់កូនលះសម្បត្តិក្នុងផ្ទះ គឺទ្រព្យក្នុងផ្ទះជាដើម និងទ្រព្យដែលមិនបានពោល ដូចជាស្រែ ប្រាក់និងមាសជាដើម និងទ្រព្យគ្រប់យ៉ាង មានខ្ញុំប្រុស ខ្ញុំស្រីជាដើមនេះទៅបួស ។ បទថា **ភុញ្ជ ភោគានិ សុន្ទរិ** សេច

ក្តីថា នែសុន្ទរី ចូរកូនបរិភោគនូវភោគៈទាំងនេះ ។ បទថា **តុវំ ទាយាទិកា កុលេ** សេចក្តីថា ព្រោះកូនសមគួរជាទាយាទសម្រាប់ទទួលមតិកក្នុងត្រកូលនេះ ។

សុន្ទរីស្តាប់ពាក្យមាតានោះហើយ កាលនឹងប្រកាសអធ្យាស្រ័យ ដែលខ្លួនបង្អោនទៅក្នុងនេក្ខម្មៈ គឺការចេញបួស ទើបពោលគាថាថា **ហត្ថិគវស្សំ** ជាដើម ។

លំដាប់នោះ មាតាកាលនឹងដឹកនាំប្រកបកូន ក្នុងនេក្ខម្មៈនោះឯង ទើបពោលកន្លះគាថា ដោយន័យជាដើមថា **សោ តេ ឥជ្ឈតុ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យំ តុំ បត្ថេសិ សុន្ទរិ** សេចក្តីថា នែសុន្ទរីឥឡូវនេះ កូនប្រាថ្នានូវបំណងណា ការត្រិះរិះក្នុងបព្វជ្ជា ការពេញចិត្តក្នុងបព្វជ្ជាចូរសម្រេចដោយមិនមានអន្តរាយដល់កូន ។ បទថា **ឧត្តិដ្ឋបិណ្ឌោ** បានដល់ ដុំបាយដែលបានមកអំពីការឈរតាមផ្ទះផ្សេងៗ ។ បទថា **ឧញ្ឆោ** បានដល់ ការត្រាច់ទៅតាមលំដាប់ផ្ទះ និងឈរដើម្បីដុំបាយនោះ ។ បទថា **ឃតាទិ** បានដល់ កិច្ចកម្ម មានដុំបាយដែលឈរគ្រប់ផ្ទះ បានមកជាដើម ។ បទថា **អភិសម្ភោន្តិ** សេចក្តីថា ជាអ្នកមិននឿយណាយ អាស្រ័យកម្លាំងស្មូង បានមក គឺធ្វើឲ្យបរិសុទ្ធិ ។

កាលនោះសុន្ទរីទទួលពាក្យមាតាថា សាធុ ក៏ចេញទៅកាន់សម្នាក់ភិក្ខុនីបួសជាសិក្ខមានា ធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ តាំងចិត្តថា នឹងទៅគាល់ព្រះសាស្តា លាឧបជ្ឈាយ៍ហើយ ទៅកាន់នគរសាវត្ថី មួយអន្លើដោយភិក្ខុនីទាំង

ឡាយ ដោយហេតុនោះ ទើបលោកពោលថា **សិក្ខមានាយ មេ អយ្យេ** ជាដើមក្នុងពាក្យនោះ ។ បទថា **សិក្ខមានាយ មេ** សេចក្តីថា ខ្ញុំនៅជាសិក្ខមានា ។ នាងសុន្ទរីថេរីហៅឧបជ្ឈាយ៍របស់ខ្លួនដោយពាក្យថា **អយ្យេ** ។

បទថា **តុវំ និស្សាយ កល្យាណិ ថេរិសង្ឃស្ស សោភណេ** ប្រកបសេចក្តីថា បពិត្រព្រះនាងឈ្មោះថាថេរីនៃពួកសង្ឃ ព្រោះជាអ្នកចាស់ជាងភិក្ខុនីសង្ឃ និងព្រោះប្រកបដោយគុណដែលមាំទាំ ជាអ្នកស្អាត ជាអ្នកមានកល្យាណធម៌ ជាកល្យាណមិត្ត ព្រោះប្រកបដោយគុណ មានសីលជាដើមដ៏ស្អាត ខ្ញុំអាស្រ័យព្រះនាងម្ចាស់ ទើបខ្ញុំបាននូវវិជ្ជា ៣ ធ្វើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធឲ្យសម្រេច ។

បទថា **គច្ឆេ** ប្រែថា នឹងទៅ ។ បទថា **សាវត្ថឹ គន្តវេ** ប្រែថា ដើម្បីទៅក្រុងសាវត្ថី ។ ព្រះនាងសុន្ទរីថេរីពោលថា **សីហនាទំ នទិស្សាមិ** សំដៅដល់ការព្យាករអរហត្តផលប៉ុណ្ណោះ ។

កាលនោះ សុន្ទរីថេរីដល់សាវត្ថីដោយលំដាប់ ចូលទៅកាន់ព្រះវិហារឃើញព្រះសាស្តាគង់លើធម្មាសនៈ ក៏កើតបីតិនិងសោមនស្សដ៏ឧឡារ កាលពោលជាមួយខ្លួនឯង ទើបពោលថា **បស្ស សុន្ទរិ** ជាដើម ។ បទថា **ហេមវណ្ណំ** បានដល់ មានពណ៌សម្បុរដូចមាស ។ បទថា **ហរិត្តចំ** បានដល់ មានព្រះឆវីក្លីដូចមាស ពាក្យនេះខ្ញុំហៅព្រះមានព្រះភាគថា មានពណ៌ដូចមាស ព្រោះមានព្រះឆវីលឿង ។

គ្រានោះឯង សុន្ទរីថេរីពោលថា **ហេមវណ្ណំ** ប្រែថា មានពណ៌ដូច

*មាស ហើយពោលថា* **ហរិត្តចំ** *ប្រែថា មានព្រះឆវីដូចមាសទៀត ក៏ដើម្បីសម្តែងថា ព្រះមានព្រះភាគ មានព្រះឆវីវណ្ណចែងចាំងដូចមាសដែលគេខាត់ល្អហើយ លាបដោយជាតិហិង្គុ ហើយខាត់ឲ្យថ្លុះជាស្រមោល ។*

*បទថា* **បស្ស សុន្ទរិមាយន្តឹ** *សេចក្តីថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ទតខ្ញុំម្ចាស់ ឈ្មោះសុន្ទរីនោះ ដែលកំពុងគាល់ ។ ព្រះនាងសុន្ទរីថេរីខណៈព្យាករអរហត្ត ដោយពាក្យថា* **វិប្បមុត្តំ** *ជាដើម ក៏ពោលដោយការផ្សាយទៅនៃបីតិ តែដើម្បីដោះសេចក្តីសង្ស័យ របស់ពួកមនុស្សដែលងឿងឆ្ងល់ថា សុន្ទរីនេះមកអំពីណា មកធ្វើអ្វី និងជាមនុស្សប្រភេទណា ទើបពោលគាថាថា* **ពារាណសិតោ** *ជាដើម ដើម្បីធ្វើអត្ថតាមដែលពោលថា* **សាវិកា** *៥ ក្នុងគាថានោះឲ្យប្រាកដច្បាស់ ទើបពោលគាថាថា* **តុវំ ពុទ្ធោ** *ជាដើម អត្ថនៃពាក្យនោះមានដូច្នេះថា ព្រះអង្គប៉ុណ្ណោះ ជាព្រះសព្វញ្ញុពុទ្ធ ជាបុគ្គលឯកក្នុងលោក ព្រមទាំងទេវលោក ទ្រង់ជាព្រះសាស្តារបស់ខ្ញុំម្ចាស់ ព្រោះទ្រង់ទូន្មានដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍តាមសមគួរ បពិត្រព្រះមានព្រះភាគ ខ្ញុំម្ចាស់ជាខីណាសវព្រាហ្មណ៍ ឈ្មោះថា* **ឱរសា** *ព្រោះជាអភិជាតិដែល ទ្រង់ឲ្យកើតដោយសេចក្តីព្យាយាមក្នុងទ្រូងរបស់ព្រះអង្គ ឈ្មោះថា* **មុខតោ** *ព្រោះកើតដោយសំឡេងធម៌ដែលទ្រង់បន្លឺចេញអំពីព្រះឱស្ឋ និងដោយអរិយមគ្គដែលជាប្រធាននៃពាក្យប្រៀនប្រដៅ ឈ្មោះថា* **កតកិច្ចា** *ព្រោះករណីយកិច្ច មានបរិញ្ញាកិច្ច ជាដើមសម្រេចហើយ ឈ្មោះថា* **អនាសវា** *ព្រោះអាសវៈទាំងឡាយអស់ទៅដោយ*

ប្រការទាំងពួង ។

លំដាប់នោះ ព្រះសាស្តាកាលទ្រង់សរសើរការមករបស់នាងសុន្ទរីថេរី នោះទើបត្រាស់គាថាថា **តស្សា តេ ស្វាគតំ** ជាដើម អត្ថនៃព្រះគាថានោះ ដូច្នេះថា ម្នាលនាងសុន្ទរី នាងសម្រេចធម៌ដែលតថាគតសម្រេចហើយ តាមសេចក្តីពិត ការមករបស់នាងក្នុងសម្នាក់តថាគតនេះ ជាការមកល្អហ្ន៎ ព្រោះសេចក្តីនោះឯង ទើបជាការមកដែលមិនអាក្រក់ គឺមិនមែនការមកដែលថោកថយ ព្រោះហេតុអ្វី ព្រោះថា ពួកអ្នកមានឥន្រ្ទិយទូន្មានហើយរមែងមក ប្រកបសេចក្តីថា ម្នាលនាងសុន្ទរី ព្រោះថា មនុស្សទាំងឡាយ ឈ្មោះថា **ទន្តា** ព្រោះទូន្មានដោយអរិយមគ្គដ៏កំពូល ឈ្មោះថា **វីតរាគា** ព្រោះប្រាសចាករាគៈក្នុងទីទាំងពួង ព្រោះទូន្មានហើយនោះឯង ប្រាសចាកគ្រឿងប្រកប ធ្វើកិច្ចស្រេចហើយ ឥតមានអាសវៈ ព្រោះកាត់សំយោជនៈបានអស់ហើយតែងមកថ្វាយបង្គំ បាទាទាំងទ្វេរបស់ព្រះសាស្តា ដូចនាងមកនេះឯង ព្រោះហេតុនោះ ទើបការមករបស់នាងនោះជាការមកល្អ មិនមែនជាការមកមិនល្អទេ ។

## អដ្ឋកថាសុន្ទរីថេរីគាថា ចប់

# សុភាកម្មារធីតាថេរីគាថា

[ ៣៣៥ ] កាលពីដើម ខ្ញុំនៅក្រមុំ មានគ្រឿងស្លៀកពាក់ដ៏ស្អាត បាន ស្តាប់ធម៌ ការត្រាស់ដឹងសច្ចធម៌ ក៏កើតមានដល់ខ្ញុំនោះជាស្ត្រីមិនប្រហែស ធ្វេស ។ ហេតុនោះ ខ្ញុំមិនត្រេកអរក្រៃពេកក្នុងកាមារម្មណ៍ទាំងអស់ ឃើញ ភ័យក្នុងសក្កាយៈ ហើយពេញចិត្តនឹងការចេញសាងផ្នួសតែម្យ៉ាង ។ ខ្ញុំលះ បង់ពួកញាតិ ទាសកម្មករ ស្រុក ស្រែទាំងឡាយដ៏ស្តុកស្តម្ភ ( និងគំនរ នៃភោគៈទាំងឡាយ ) ដែលគួរត្រេកអរ គួររីករាយ ខ្ញុំលះបង់នូវសម្បត្តិ ដ៏ច្រើនហើយបួស ។ ខ្ញុំចេញ ( ចាកផ្ទះ ) ដោយសទ្ធា យ៉ាងនេះហើយ ( បួស ) ក្នុងព្រះសទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សំដែងហើយដោយ ប្រពៃ ខ្ញុំប្រាថ្នានូវសេចក្តីមិនកង្វល់ ព្រោះការត្រឡប់មករកកាមនោះមិនសម គួរដល់ខ្ញុំទេ អ្នកណាលះចោលមាសនិងប្រាក់ហើយ គប្បីត្រឡប់មកយកវិញ ។ ប្រាក់ក្តី មាសក្តី របស់បុគ្គលនុ៎ះ មិនមែនមានដើម្បីព្រះនិព្វានជាទីស្ងប់ទេ ការទទួលមាសនិងប្រាក់នុ៎ះ មិនសមគួរដល់សមណៈទេ ការទទួលនូវប្រាក់ និងមាសនុ៎ះ មិនមែនជាទ្រព្យប្រសើរទេ ។ ការទទួលនូវប្រាក់និងមាសនុ៎ះ សុទ្ធតែជាគ្រឿងឲ្យកើតលោភ ជាគ្រឿងស្រវឹង ជាគ្រឿងវង្វេង ជាគ្រឿងព័ន្ធ ព័ទ្ធដោយធូលី គឺកិលេស ប្រកបដោយសេចក្តីរង្កៀស មានសេចក្តីចង្អៀត ចង្អល់ច្រើន សេចក្តីទៀងទាត់ឋិតថេរក្នុងទ្រព្យនេះមិនមានទេ ។ ពួកនរជន ( ដែលត្រេកអរ ) ដោយទ្រព្យប៉ុណ្ណោះ ឈ្មោះថាជាអ្នកប្រហែសធ្វេស ជា អ្នកមានចិត្តសៅហ្មង ជាអ្នកអាក់អន់ រមែងធ្វើនូវជម្លោះជាច្រើនទៅវិញទៅ មក ។ សេចក្តីវិនាសច្រើនប្រការគឺការសម្លាប់ ការចង ការសៅហ្មង សេច

ក្ដីវិនាស សេចក្ដីសោក ខ្សឹកខ្សួល រមែងកើតប្រាកដ ដល់ពួកជនដែលជេក ត្រាំក្នុងកាមទាំងឡាយ ។ អ្នកទាំងឡាយជាញាតិមែន តែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី ( ព្រោះ ) អ្នកទាំងឡាយ ជ្រាបនូវខ្ញុំ ថាជាអ្នកបួស ជាស្ដ្រីឃើញនូវភ័យក្នុងកាមទាំងឡាយ ។ អាសវៈទាំងឡាយ មិនមែនអស់ទៅ ព្រោះប្រាក់និងមាស កាមទាំងឡាយមិនមែនជាមិត្ត ជា សភាវៈសម្លាប់ ( នូវប្រយោជន៍ ) ជាសត្រូវ ជាគ្រឿងចងទុកនូវសរ គឺ កិលេស ។ អ្នកទាំងឡាយ ជាញាតិមែន តែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះ ក្នុងកាមទាំងឡាយធ្វើអ្វី ( ព្រោះ ) អ្នកទាំងឡាយជ្រាបនូវខ្ញុំថា ជាអ្នកបួស មានក្បាលត្រងោល ដណ្ដប់នូវសង្ឃាដី ។ ដុំបាយតាមលំដាប់ផ្ទះក្ដី អាហារ ចំណីក្ដី បង្សុកូលចីវរក្ដី នេះឯងជាអំពើដ៏សមគួរដល់ខ្ញុំ ជាបរិក្ខារ ជាទីអា-ស្រ័យរបស់អ្នកបួស ។ លោកអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ខ្ជាក់ចោល នូវកាមទាំងឡាយដែលជាទិព្វនិងជារបស់មនុស្ស បុគ្គលអ្នកស្វែងរកនូវគុណ ធំទាំងនោះ មានចិត្តឱនទៅក្នុងព្រះនិព្វានជាទីដ៏ក្សេម បុគ្គលអ្នកស្វែងរកនូវ គុណធំទាំងនោះ បានដល់នូវសេចក្ដីសុខ ឥតកម្រើក ។ ទីជម្រករមែងមិន មានក្នុងកាមទាំងឡាយណា ខ្ញុំមិនសំគប់ ដោយកាមទាំងឡាយនោះទៀតទេ កាមទាំងឡាយមិនមែនជាមិត្ត ដូចជាអ្នកសម្លាប់ ឬដូចជាគំនរភ្លើង នាំមក នូវសេចក្ដីព្រួយ ។ កាមនោះមិនស្អាត ប្រកបដោយភ័យ ប្រកបដោយសេច ក្ដីចង្អៀតចង្អល់ ដូចជាបន្លា កាមនុ៎ះជាគ្រឿងញ៉ាម ជាគ្រឿងកន្ទល់ក្រៃលែង មានមុខឈមទៅរកសេចក្ដីវង្វេងដ៏ធំ ។ កាមគុណ ជាឧបសគ្គៈផង មាន

សភាពគួរខ្ពើមផង កាមារម្មណ៍ទាំងឡាយ មានឧបមាដូចក្បាលពស់ ពួកបុថុជ្ជនល្ងង់ខ្លៅ ដូចជាបុគ្គលខ្វាក់ តែងត្រេកត្រអាល ។ ព្រោះថា ពួកជនច្រើនរូបដែលចំពាក់ដោយគ្រឿងចំពាក់គឺកាមរមែងបាន ( សេចក្តីទុក្ខ ) ក្នុងលោក រមែងមិនដឹងច្បាស់នូវទីបំផុតនៃជាតិនិងមរណៈ ។ មនុស្សទាំងឡាយជាច្រើន តែងដើរទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិ មានកាមជាហេតុ ជាគ្រឿងនាំមកនូវរោគដល់ខ្លួន ។ កាមទាំងឡាយ ជាគ្រឿងញុំាងសត្វឲ្យកើតយ៉ាងនេះ ជាហេតុញុំាងសត្វឲ្យក្តៅក្រហាយ នាំមកនូវសេចក្តីសៅហ្មង ជានុយរបស់សត្វលោក ជាទីតាំងនៃគ្រឿងចង ជាចំណងនៃសេចក្តីស្លាប់ ។ កាមទាំងឡាយជាគ្រឿងញុំាងសត្វឲ្យឆ្កួត ឲ្យនិយាយប៉ប៉ាច់ប៉ប៉ោច ញុំាងចិត្តឲ្យក្តាំងក្តាត់ មារគឺកាមរបស់ពួកសត្វតែងរួបរឹតដោយសេចក្តីសៅហ្មងយ៉ាងឆាប់រហ័ស ។ កាមទាំងឡាយ មានទោសរកទីបំផុតគ្មាន មានទុក្ខច្រើនយ៉ាង មានពិសដ៏ខ្លាំងក្លា មានរសឆ្ងាញ់តិច ជាគ្រឿងធ្វើនូវចម្បាំង ញុំាងចំណែកនៃធម៌សឲ្យស្រាបសូន្យទៅ ។ ខ្ញុំនោះលះបង់នូវសេចក្តីវិនាសដែលមានកាមជាហេតុបែបនេះ ត្រេកអរចំពោះព្រះនិព្វានសព្វៗកាល មិនត្រឡប់មកកាន់កាមនោះវិញទេ ។ ខ្ញុំជាស្ត្រីប្រាថ្នានូវភាពដ៏ត្រជាក់ ( ព្រះអរហត្ត ) ធ្វើនូវចម្បាំងចំពោះកាមទាំងឡាយ ជាអ្នកមិនប្រមាទ ត្រេកអរចំពោះព្រះនិព្វានជាទីអស់ទៅនៃសំយោជនៈ ។ បុគ្គលអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ធ្លងហើយតាមផ្លូវណា ខ្ញុំនឹងដើរទៅតាមផ្លូវនោះ ជាផ្លូវឥតសោក មានធូលីទៅប្រាសហើយ ជាផ្លូវក្សេមដ៏ត្រង់ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

( ព្រះមានព្រះភាគត្រាស់ថា ) អ្នកទាំងឡាយ ចូរមើលនូវនាង សុភាកម្មារធីតានេះ ជាស្ត្រីឋិតនៅក្នុងធម៌ នាងបានចូលទៅកាន់ឈាន ឥតមានសេចក្តីញាប់ញ័រ ហើយស្ងប់ស្ងាត់ទៀបគល់ឈើ ។ នាងសុភាកម្មារធីតាបួសបាន ៨ ថ្ងៃនឹងថ្ងៃនេះហើយ ជាភិក្ខុនីមានសទ្ធាល្អក្នុងព្រះសទ្ធម្ម ដែលនាងឧប្បលវណ្ណាទូន្មានហើយ ជាស្ត្រីមានវិជ្ជា ៣ លះបង់នូវមច្ចុបាន ។ ភិក្ខុនីនេះ ជាអ្នកនៅឥតមានបំណុល មានឥន្ទ្រិយចម្រើនហើយ ប្រាសចាកកិលេសជាគ្រឿងប្រកបទាំងពួង មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ ទេវរាជឈ្មោះសក្កៈ ជាម្ចាស់នៃពួកសត្វ ព្រមទាំងពួកទេវតា ចូលទៅនមស្ការចំពោះភិក្ខុនីឈ្មោះសុភាកម្មារធីតានោះ ដោយឫទ្ធិ ( របស់ខ្លួន ) ។

**សុភាកម្មារធីតាថេរី ។**

**ចប់ វីសតិនិបាត ។**

# អដ្ឋកថា

## សុភាកម្មារធីតាថេរីគាថា

[ ៣៣៥ ] គាថារបស់ព្រះនាងសុភាកម្មារធីតាថេរី មានពាក្យផ្តើមថា **ទហរាហំ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុន ៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភព

នោះៗ អប់រំនូវកុសលមូល ចម្រើននូវធម្មសម្ភារៈដែលជាគ្រឿងតាក់តែង វិមោក្ខដោយលំដាប់ អន្ទោលទៅក្នុងចំណែកនៃសុគតិប៉ុណ្ណោះ កាលញាណចាស់ក្លា ក្នុងពុទ្ធុប្បាទនេះ កើតជាធីតារបស់ជាងមាសម្នាក់ ក្នុងក្រុងរាជគ្រឹះ ព្រោះការស្អាតនៃរូបសម្បត្តិ ទើបបានឈ្មោះថា សុភា ។ នាងដឹងក្តីមកដោយលំដាប់ កើតនូវការជ្រះថ្លា ក្នុងព្រះសាស្តា កាលព្រះសាស្តាយាងទៅកាន់ក្រុងរាជគ្រឹះ ថ្ងៃមួយ ទើបចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ព្រះសាស្តា ទ្រង់ឃើញនាងមានឥន្ទ្រិយចាស់ក្លា ទើបទ្រង់សម្តែងធម៌ គឺអរិយសច្ច ៤ ដែលសមគួរដល់អធ្យាស្រ័យ រំពេចនោះឯង ។ នាងក៏តាំងនៅក្នុងសោតាបត្តិផល ប្រដាប់ដោយន័យមួយពាន់ ។ តមកនាងឃើញទោសក្នុងឃរាវាសវិស័យ ក៏បួសក្នុងសម្នាក់របស់ព្រះនាងបជាបតិគោតមី តាំងនៅក្នុងសីលរបស់ភិក្ខុនី ប្រកបរឿយៗនូវភាវនា ដើម្បីមគ្គជាន់ខ្ពស់ ពួកញាតិនាំគ្នាចូលទៅរកនាងម្តងម្កាល អញ្ជើញនាងដោយកាម បង្ហាញទ្រព្យជាច្រើន មួយអន្លើដោយគំនរសម្បត្តិ លួងលោមដោយកាមទាំងឡាយ ។ ថ្ងៃមួយ កាលពួកញាតិចូលមករក កាលប្រកាសទោសក្នុងឃរាវាសវិស័យ និងក្នុងកាមទាំងឡាយ ទើបពោលធម៌ ២៤ គាថា មានពាក្យថា **ឧហាភាហំ** ជាដើម ធ្វើញាតិទាំងនោះឲ្យអស់សង្ឃឹម ចម្រើនវិបស្សនា ប្រកបឥន្ទ្រិយទាំងឡាយ ខ្នះខ្នែងក្នុងភាវនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ កាលសម្រេចអរហត្តហើយ ទើបពោលគាថាទាំងនេះថា

កាលពីដើម ខ្ញុំនៅក្រមុំ មានគ្រឿងស្លៀកពាក់ដ៏ស្អាត បាន ស្តាប់ធម៌ ការត្រាស់ដឹងសច្ចធម៌ ក៏កើតមានដល់ខ្ញុំនោះជាស្ត្រី មិនប្រហែសធ្វេស ។ ហេតុនោះ ខ្ញុំមិនត្រេកអរក្រៃពេកក្នុង កាមារម្មណ៍ទាំងអស់ ឃើញភ័យក្នុងសក្កាយៈ ហើយពេញ ចិត្តនឹងការចេញសាងផ្នួសតែម្យ៉ាង ។ ខ្ញុំលះបង់ពួកញាតិ ទាស កម្មករ ស្រុក ស្រែទាំងឡាយដ៏ស្តុកស្តម្ភ ( និងគំនរនៃភោគៈ ទាំងឡាយ ) ដែលគួរត្រេកអរ គួររីករាយ ខ្ញុំលះបង់នូវ សម្បត្តិដ៏ច្រើនហើយបួស ។ ខ្ញុំចេញ ( ចាកផ្ទះ ) ដោយ សទ្ធាយ៉ាងនេះហើយ ( បួស ) ក្នុងព្រះសទ្ធម្មដែលព្រះសម្មា សម្ពុទ្ធ ត្រាស់សំដែងហើយដោយប្រពៃ ខ្ញុំប្រាថ្នានូវសេចក្តីមិន កង្វល់ ព្រោះការត្រឡប់មករកកាមនោះ មិនសមគួរដល់ខ្ញុំទេ អ្នកណាលះចោលមាស និងប្រាក់ហើយ គប្បីត្រឡប់មកយក វិញ ។ ប្រាក់ក្តី មាសក្តី របស់បុគ្គលនុ៎ះ មិនមែនមានដើម្បី ព្រះនិព្វានជាទីស្ងប់ទេ ការទទួលមាសនិងប្រាក់នុ៎ះ មិនសម គួរដល់សមណៈទេ ការទទួលនូវប្រាក់និងមាសនុ៎ះ មិនមែន ជាទ្រព្យប្រសើរទេ ។ ការទទួលនូវប្រាក់និងមាសនុ៎ះ សុទ្ធតែ ជាគ្រឿងឲ្យកើតលោភ ជាគ្រឿងស្រវឹង ជាគ្រឿងវង្វេង ជា គ្រឿងព័ទ្ធព័ន្ធដោយធូលីគឺកិលេស ប្រកបដោយសេចក្តីរង្កៀស មានសេចក្តីចង្អៀតចង្អល់ច្រើន សេចក្តីទៀងទាត់ឋិតថេរក្នុង

ទ្រព្យនេះមិនមានទេ ។ ពួកនរជន ( ដែលត្រេកអរ ) ដោយទ្រព្យប៉ុណ្ណោះ ឈ្មោះថាជាអ្នកប្រហែសធ្វេស ជាអ្នកមានចិត្តសៅហ្មង ជាអ្នកអាក់អន់ រមែងធ្វើនូវជម្លោះជាច្រើនទៅវិញទៅមក ។ សេចក្ដីវិនាសច្រើនប្រការ គឺការសម្លាប់ ការចងការសៅហ្មង សេចក្ដីវិនាស សេចក្ដីសោកខ្សឹកខ្សួល រមែងកើតប្រាកដដល់ពួកជនដែលជេកត្រាំក្នុងកាមទាំងឡាយ ។ អ្នកទាំងឡាយជាញាតិមែន តែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី ( ព្រោះ ) អ្នកទាំងឡាយជ្រាបនូវខ្ញុំថាជាអ្នកបួស ជាស្ត្រីឃើញនូវភ័យក្នុងកាមទាំងឡាយ ។ អាសវៈទាំងឡាយ មិនមែនអស់ទៅព្រោះប្រាក់និងមាស កាមទាំងឡាយ មិនមែនជាមិត្ត ជាសត្រូវ ជាសការៈសម្លាប់ ( នូវប្រយោជន៍ ) ជាសត្រូវ ជាគ្រឿងចងទុកនូវសរ គឺកិលេស ។ អ្នកទាំងឡាយជាញាតិមែន តែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី ( ព្រោះ ) អ្នកទាំងឡាយជ្រាបនូវខ្ញុំថាជាអ្នកបួស មានក្បាលត្រងោល ដណ្ដប់នូវសង្ឃាដី ។ ដុំបាយ តាមលំដាប់ផ្ទះក្ដី អាហារចំណីក្ដី បង្សុកូលចីវរក្ដី នេះឯងជាអំពើដ៏សមគួរដល់ខ្ញុំ ជាបរិក្ខារ ជាទីអាស្រ័យរបស់អ្នកបួស ។ លោកអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ខ្ជាក់ចោលនូវកាមទាំងឡាយដែលជាទិព្វនិងជារបស់មនុស្ស បុគ្គលអ្នក

ស្វែងរកនូវគុណធំទាំងនោះ មានចិត្តឱនទៅក្នុងព្រះនិព្វាន ជាទីដ៏ក្សេម បុគ្គលអ្នកស្វែងរកនូវគុណធំទាំងនោះ បានដល់នូវសេចក្ដីសុខ ឥតកម្រើក ។ ទីជម្រករមែងមិនមាន ក្នុងកាមទាំងឡាយណា ខ្ញុំមិនសំគប់ ដោយកាមទាំងឡាយនោះទៀតទេ កាមទាំងឡាយមិនមែនជាមិត្ត ដូចជាអ្នកសម្លាប់ ឬដូចជាគំនរភ្លើង នាំមកនូវសេចក្ដីព្រួយ ។ កាមនោះមិនស្អាត ប្រកបដោយភ័យ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ដូចជាបន្លា កាមនុ៎ះជាគ្រឿងញាំម ជាគ្រឿងកន្សល់ក្រៃលែង មានមុខឈមទៅរកសេចក្ដីវង្វេងដ៏ធំ ។ កាមគុណជាឧបសគ្គៈផង មានសភាពគួរខ្លាចផង កាមារម្មណ៍ទាំងឡាយ មានឧបមាដូចក្បាលពស់ ពួកបុថុជ្ជនល្ងង់ខ្លៅ ដូចជាបុគ្គលខ្វាក់ តែងត្រេកត្រអាល ។ ព្រោះថា ពួកជនច្រើនរូបដែលចំពាក់ដោយគ្រឿងចំពាក់ គឺកាមរមែងបាន ( សេចក្ដីទុក្ខ ) ក្នុងលោក រមែងមិនដឹងច្បាស់នូវទីបំផុតនៃជាតិនិងមរណៈ ។ មនុស្សទាំងឡាយជាច្រើន តែងដើរទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិមានកាមជាហេតុ ជាគ្រឿងនាំមកនូវរោគដល់ខ្លួន ។ កាមទាំងឡាយជា គ្រឿងញុំាងសត្វឲ្យកើតយ៉ាងនេះ ជាហេតុញុំាងសត្វឲ្យក្ដៅក្រហាយ នាំមកនូវសេចក្ដីសៅហ្មង ជានុយរបស់សត្វលោក ជាទីតាំងនៃគ្រឿងចង ជាចំណងនៃសេចក្ដីស្លាប់ ។ កាមទាំងឡាយ ជាគ្រឿង

ញ៉ាំងសត្វឲ្យឆ្កួត ឲ្យនិយាយប៉ប៉ាច់ប៉ប៉ោច ញ៉ាំងចិត្តឲ្យភ្ញាំងភ្ញាត់ មារ គឺកាមរបស់ពួកសត្វតែងរួបរឹតដោយសេចក្តីសៅហ្មង យ៉ាងធាប់រហ័ស ។ កាមទាំងឡាយ មានទោសរកទីបំផុតគ្មាន មានទុក្ខច្រើនយ៉ាង មានពិសដ៏ខ្លាំងក្លា មានរសឆ្ងាញ់តិច ជាគ្រឿងធ្វើនូវចម្បាំង ញ៉ាំងចំណែកនៃធម៌សឲ្យសាបសូន្យទៅ ។ ខ្ញុំនោះលះបង់នូវសេចក្តីវិនាសដែលមានកាមជាហេតុបែបនេះ ត្រេកអរចំពោះព្រះនិព្វាន សព្វៗកាលមិនត្រឡប់មកកាន់កាមនោះវិញទេ ។ ខ្ញុំជាស្ត្រីប្រាថ្នានូវភាពដ៏ត្រជាក់ ( ព្រះអរហត្ត ) ធ្វើនូវចម្បាំងចំពោះកាមទាំងឡាយ ជាអ្នកមិនប្រមាទ ត្រេកអរចំពោះព្រះនិព្វាន ជាទីអស់ទៅនៃសំយោជនៈ ។ បុគ្គលអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ឆ្លងហើយតាមផ្លូវណា ខ្ញុំនឹងដើរទៅតាមផ្លូវនោះ ជាផ្លូវឥតសោកមានធូលីទៅប្រាសហើយ ជាផ្លូវក្សេមដ៏ត្រង់ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

( ព្រះមានព្រះភាគត្រាស់ថា ) អ្នកទាំងឡាយ ចូរមើលនូវនាងសុភាកម្មារធីតានេះ ជាស្ត្រីឋិតនៅក្នុងធម៌ នាងបានចូលទៅកាន់ឈាន ឥតមានសេចក្តីញាប់ញ័រ ហើយស្ងប់ស្ងាធិទៀបគល់ឈើ ។ នាងសុភាកម្មារធីតា បួសបាន ៨ ថ្ងៃនឹងថ្ងៃនេះហើយ ជាភិក្ខុនីមានសទ្ធាល្អ ក្នុងព្រះសទ្ធម្មដែល

នាងឧប្បលវណ្ណាទូន្មានហើយ ជាស្ត្រីមានវិជ្ជា ៣ លះបង់នូវមច្ចុបាន ។ ភិក្ខុនីនេះ ជាអ្នកនៅឥតមានបំណុល មានឥន្រ្ទិយចម្រើនហើយ ប្រាសចាកកិលេសជាគ្រឿងប្រកបទាំងពួង មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។

( ព្រះសង្គីតិកាចារ្យពោលថា )

ទេវរាជឈ្មោះសក្កៈ ជាម្ចាស់នៃពួកសត្វ ព្រមទាំងពួកទេវតា ចូលទៅនមស្ការចំពោះភិក្ខុនីឈ្មោះសុភាកម្មារធីតានោះ ដោយឫទ្ធិ ( របស់ខ្លួន ) ។

បណ្តាបទទាំងនោះ បទថា **ទហរាហំ សុទ្ធវសនា យំ បុរេ ធម្មមស្សុ-ណឹ** សេចក្តីថា ព្រោះហេតុពីមុន ខ្ញុំជាស្រីក្មេង មានសំពត់ស្អាត ស្លៀកដណ្តប់សំពត់ដែលបរិសុទ្ធ តាក់តែងកាយហើយ បានស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ។ បទថា **តស្សា មេ អប្បមត្តាយ សច្ចាភិសមយោ អហុ** សេចក្តីថា ព្រោះហេតុដែលខ្ញុំនោះពិចារណានូវធម៌តាមដែលខ្ញុំស្តាប់មកហើយ ជាអ្នកមិនប្រមាទ គឺមានសតិតាំងមាំហើយ អធិដ្ឋានសីល ប្រកបរឿយៗ នូវភាវនាដរាបដល់ត្រាស់ដឹង គឺចាក់ធ្លុះនូវអរិយសច្ចទាំង ៤ ដោយន័យថា នេះទុក្ខ ដូច្នេះជាដើម ។ បទថា **តតោហំ សព្វកាមេសុ ភុសំ អរតិមជ្ឈគំ** សេចក្តីថា ដូច្នោះ គឺព្រោះហេតុនោះ ទើបខ្ញុំមិនដល់នូវការត្រេកអរ គឺការអផ្សុកក្រៃលែង គឺពន់ពេក ក្នុងកាមទាំងឡាយសព្វយ៉ាង គឺជារបស់មនុស្សផង ជារបស់ទិព្វផង ព្រោះស្តាប់ធម៌មកក្នុងសម្នាក់ព្រះសាស្តាហើយ និង

ព្រោះត្រាស់ដឹងនូវអរិយសច្ចហើយ ខ្ញុំឃើញភ័យ គឺការមានភ័យចំពោះមុខ ក្នុងសក្កាយៈ គឺខន្ធបញ្ចកៈមានឧបាទាន ដោយចក្ខុ គឺញាណ ទើបត្រេកអរ ប្រាថ្នាតែនេក្ខម្មៈ គឺបព្វជ្ជាដើម្បីព្រះនិព្វានតែម៉្យាង ។

បទថា **ទាសកម្មករានិ ច** ប្រែថា ទាសៈនិងកម្មករ ពាក្យនេះលោកពោលជាលិង្គវិបល្លាស ។ បទថា **គាមខេត្តានិ** បានដល់ ស្រុកនិងចម្ការ ដែលដាំនូវបុព្វណ្ណជាតិនិងអបរន្នជាតិ និងផ្ទៃដីដែលទាក់ទងដោយស្រុក ។ បទថា **ជីតានិ** បានដល់ ភាពស្តុកស្តម្ភ ។ បទថា **រមណីយេ** បានដល់ វត្ថុដែលគួរបម្រើនចិត្ត ។ បទថា **បមោទិតេ** បានដល់ ដែលសត្វត្រេកអរហើយ ក្តាប់សេចក្តីថា លះនូវគំនរភោគសម្បត្តិ ។ បទថា **សាបតេយ្យំ** បានដល់ ទ្រព្យរបស់ខ្លួនឯង គឺរបស់ហួងហែងដែលធ្វើអំពីកែវមណី ធ្វើអំពីមាស ធ្វើអំពីប្រាក់ជាដើម ។ បទថា **អនប្បកំ** បានដល់ ច្រើន ប្រកបសេចក្តីថា លះនូវសម្បត្តិជាច្រើន ។ បទថា **ឯវំ សទ្ធាយ និក្ខម្ម** សេចក្តីថា ខ្ញុំលះនូវញាតិសន្តានជាច្រើន និងគំនរភោគសម្បត្តិធំ មានប្រការតាមដែលបានពោលដោយន័យថា **ហិត្វានហំ ញាតិគណំ** ជាដើម ជឿនូវវត្ថុដែលគួរជឿ គឺកម្ម ផលនៃកម្ម និងព្រះរតនត្រ័យដោយសទ្ធា ចេញចាកផ្ទះទៅបួសក្នុងព្រះសទ្ធម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសល្អហើយ គឺក្នុងអរិយវិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសដោយល្អហើយ ។

ឯការដែលខ្ញុំបួសយ៉ាងនេះហើយ ត្រឡប់មករកកាមទាំងឡាយ ដែលខ្ញុំបោះបង់ហើយមិនសមគួរដល់ខ្ញុំឡើយ ។ បទថា **អាកិញ្ចញ្ញំ ហិ បត្ថយេ**

សេចក្ដីថា ព្រោះថា ខ្ញុំប្រាថ្នាតែការមិនកន្ទ្វល់ គឺការមិនហួងហែងប៉ុណ្ណោះ ។ បទថា **យោ ជាតរូបរជតំ ឋបេត្វា បុនរាគមេ** សេចក្ដីថា បុគ្គលណាលះនូវប្រាក់ មាស ឬទ្រព្យណាមួយដទៃហើយ គប្បីត្រឡប់មកកាន់យកទ្រព្យនោះ បុគ្គលនោះគប្បីងើបក្បាលក្នុងកណ្ដាលពួកបណ្ឌិតបានដូចម្ដេច ។

ព្រោះថា ប្រាក់ មាស រមែងមិនមានដើម្បីសន្តិ គឺសេចក្ដីស្ងប់ អធិប្បាយថា មិនមានដើម្បីមគ្គញ្ញាណ មិនមានដើម្បីព្រះនិព្វាន សម្រាប់បុគ្គលនោះ ។ បទថា **ន ឯតំ សមណសារុប្បំ** សេចក្ដីថា ទ្រព្យសម្បត្តិនោះ គឺរបស់ហួងហែង មានប្រាក់មាសជាដើម ឬការហួងហែងប្រាក់មាសជាដើមនោះ មិនសមគួរដល់សមណៈ ។ ពិតហើយ លោកពោលក្នុង ( វិនយបិដកចុល្លវគ្គ ) ថា ព្រោះមាសនិងប្រាក់ មិនគួរដល់ពួកសមណៈជាសក្យបុត្តិយ៍ទេ ដូច្នេះ ជាដើម ។ បទថា **ន ឯតំ អរិយធនំ** សេចក្ដីថា របស់ហួងហែងតាមដែល ពោលហើយនោះ មិនមែនទ្រព្យដែលជាអរិយធម៌ ដូចអរិយទ្រព្យមានសទ្ធាជាដើមឡើយ ព្រោះមិននាំនូវភាពជាអរិយៈមកឲ្យឡើយ ដោយហេតុនោះទើបព្រះថេរពោលថា **លោភនំ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **លោភនំ** បានដល់ ដែលធ្វើឲ្យកើតសេចក្ដីលោភ ។ បទថា **មទនំ** បានដល់ នាំនូវការស្រវឹងមកឲ្យ ។ បទថា **សម្មោហនំ** បានដល់ ធ្វើឲ្យកើតសេចក្ដីវង្វេង ។ បទថា **រជពន្ធនំ** បានដល់ គ្រឿងចងលាម មានកិលេសដូចធូលីគឺរាគៈជាដើម ។ ទ្រព្យដែលឈ្មោះថា **សាសង្កំ** ព្រោះប្រព្រឹត្តទៅជាមួយភាពគួររង្កៀស ព្រោះទ្រព្យនេះ បុគ្គល

*ហួងហែងនាំមកនូវភាពគួររន្ធៀស អធិប្បាយថា នាំមកតែសេចក្ដីរន្ធៀសអំពីទ្រព្យដែលហួងហែង ។ បទថា* **ពហុ អាយាសំ** *បានដល់ លំបាកខ្លាំងដោយត្រូវចាត់ចែង ត្រូវរក្សាជាដើម ។ បទថា* **ឆត្តិ ចេត្ត ធុវំ ឋិតិ** *សេចក្ដីថា ការស្ថិតស្ថេរនិងការមាំទាំក្នុងទ្រព្យនោះមិនមានឡើយ មានតែប្រែប្រួល មិនមាំទាំប៉ុណ្ណោះ ។*

*បទថា* **ឃត្តាវតា បមត្តា ច សង្កិលិដ្ឋមណា ឆរា** *សេចក្ដីថា នរជនទាំងឡាយ ត្រេកអរហើយ គឺកើតនូវការត្រេកអរក្នុងទ្រព្យនោះ ឈ្មោះថា* **បមត្តា** *ព្រោះនៅប្រាសចាកសតិក្នុងកុសលធម៌ ១០ ជាអ្នកមានចិត្តសៅហ្មង គឺឈ្មោះថា ជាអ្នកមានចិត្តសៅហ្មង ព្រោះសៅហ្មងដោយកិលេស មានលោភៈ ជាដើម ។ ព្រោះហេតុនោះ បទថា* **អញ្ញមញ្ញេន ព្យារុទ្ធា បុថុ កុព្វន្តិ មេធគំ** *ទើបមានសេចក្ដីថា សត្វជាច្រើន គឺមាតានិងបុត្ត ចុងក្រោយក៏ជាសត្រូវដល់គ្នានឹងគ្នា យ៉ាងនេះគឺ មាតានិងបុត្តខ្លះ បុត្តនិងមាតាខ្លះ រមែងធ្វើនូវជម្លោះដល់គ្នានឹងគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល មានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំងឡាយ ។បេ។ មាតាទាស់ទែងនឹងបុត្តខ្លះ ដូច្នេះជាដើម ។*

*បទថា* **វធោ** *បានដល់ ការសម្លាប់ ។ បទថា* **ពន្ធោ** *បានដល់ ចំណងមានចំណងធ្វើដោយដែកជាដើម ។ បទថា* **បរិក្លេសោ** *បានដល់ ធ្វើឲ្យ*

វាងកាយពិការ មានកាត់ដៃជាដើម ។ បទថា **ជានិ** បានដល់ វិនាសទ្រព្យ និងវិនាសបរិវារ ។ បទថា **សោកបរិទ្ទវោ** បានដល់ សេចក្ដីសោកនិងការកន្ទក់កន្ទេញ ។ បទថា **អធិបដ្ឋានំ** បានដល់ ត្រូវគ្របសង្កត់ ។ បទថា **និស្សរេ ព្យសនំ ពហុំ** បានដល់ ការលំបាក ការវិនាសជាច្រើន គឺច្រើនយ៉ាង មានការសម្លាប់ ការចងជាដើម តាមដែលពោលមកហើយ និងទោមនស្ស ការចង្អៀតចង្អល់ចិត្តជាដើមដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅខាងមុខ ក្នុងកាមទាំងឡាយ ដែលឃើញជាក់ច្បាស់ ។

បទថា **តំ មំ ញាតី អមិត្តាវ កឹ វោ កាមេសុ យុញ្ជថ** សេចក្ដីថា អ្នកទាំងឡាយ ទោះជាញាតិនឹងគ្នា ក៏ដូចជាសត្រូវដែលមិនប្រាថ្នាល្អ ព្រោះហេតុអ្វី ទើបបបួលខ្ញុំដែលជាបុគ្គលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ មកក្នុងកាមទាំងឡាយ ។ បទថា **ជានាថ មំ បព្វជិតំ កាមេសុ ភយទស្សិនឹ** សេចក្ដីថា អ្នកទាំងឡាយចូរតាមទទួលដឹងថា ខ្ញុំជាអ្នកឃើញភ័យក្នុងកាមទាំងឡាយទើបបួស ។ អធិប្បាយថា ហេតុត្រឹមប៉ុណ្ណេះ ហេតុអ្វីទើបអ្នកទាំងឡាយមិនព្រមដឹង ។

បទថា **ន ហិរញ្ញសុវណ្ណេន បរិក្ខីយន្តិ អាសវា** សេចក្ដីថា អាសវៈទាំងឡាយ មានកាមាសវៈជាដើមមិនអស់ទៅដោយប្រាក់ ដោយមាស ដែលពិត បែរជាកម្រើកដោយមាសប្រាក់ទាំងនោះឯង ។ ដោយហេតុនោះ ទើបព្រះថេរីពោលថា កាមទាំងឡាយ មិនមែនជាមិត្ត ជាសភាវៈសម្លាប់ ( នូវប្រយោជន៍ ) ជាសត្រូវ ជាគ្រឿងចងទុកនូវសរគឺកិលេស ដូច្នេះ ។ អត្ថ

នៃពាក្យនោះ មានដូច្នេះថា សេចក្តីពិត កាមទាំងឡាយ ឈ្មោះថា **អមិត្តា** ព្រោះមិនមានមេត្រី នាំមកតែវត្ថុមិនជាប្រយោជន៍ ឈ្មោះថា **វធកា** ព្រោះដូចជាពេជ្ឈឃាតឆ្កាដាវជាដើម ហេតុដែលជាឫសគល់នៃការស្លាប់ ឈ្មោះថា **សបត្តា** ព្រោះដូចជាសត្រូវអ្នកចងពៀរ នាំមកតែសេចក្តីវិនាស ឈ្មោះថា **សល្លពន្ធនា** ព្រោះព្រួញទាំងឡាយមានរាគៈជាដើមមុត ។

បទថា **មុណ្ឌំ** បានដល់ កោរសក់ ឈ្មោះថា **សង្ឃាដិបារុតំ** ព្រោះរើសរេសសំពត់ទាំងឡាយក្នុងទីផ្សេងៗ មកដេរភ្ជាប់គ្នា ធ្វើចីវរដណ្តប់ ។ បទថា **ឧទ្ទិដ្ឋបិណ្ឌោ** បានដល់ ដុំបាយដែលទៅឈរក្បែរផ្ទះទាំងអស់ ដែលបើកទ្វារបានមក ។ បទថា **ឧញ្ឆោ** បានដល់ ការត្រាច់ទៅដើម្បីដុំបាយនោះ ។ បទថា **អនគារូបនិស្សយោ** បានដល់ បរិក្ខារអ្នកបួស ដែលជាទីអាស្រ័យ ព្រោះបួសមិនមានផ្ទះ ចាំបាច់ចូលទៅអាស្រ័យបរិក្ខានោះរស់នៅ ។ បទថា **វន្តា** បានដល់ លះបង់ហើយ ។ បទថា **មហេសីហិ** បានដល់ អ្នកស្វែងរកគុណធំ មានព្រះពុទ្ធជាដើម ។ បទថា **ខេមដ្ឋានេ** បានដល់ ក្នុងព្រះនិព្វានដែលជាទីមិនមានអន្តរាយ ចាកយោគៈទាំងឡាយ មានកាមយោគៈជាដើម ។ បទថា **តេ** សំដៅដល់ ជាអ្នកស្វែងរកគុណធំ ។ បទថា **អចលំ សុខំ** បានដល់ សម្រេចសុខក្នុងព្រះនិព្វាន អធិប្បាយថា ព្រោះហេតុដែលលោកជាអ្នកស្វែងរកគុណធំ មានព្រះពុទ្ធជាដើម ទ្រង់ខ្ពាក់នូវកាមហើយទើបសម្រេចនិព្វានសុខដូច្នោះ បុគ្គលប្រាថ្នានិព្វានសុខនោះ ទើបគួរលះនូវកាមទាំងឡាយ ។

*បទថា* **មាហំ កាមេហិ សង្គច្ឆំ** *សេចក្តីថា ខ្ញុំព្រះអង្គមិនគប្បីសមាគម ជាមួយកាមទាំងឡាយ មិនថាក្នុងកាលណាឡើយ បើសួរថា ព្រោះហេតុអ្វី ទើបព្រះថេរីពោលថា* **យេសុ តាណំ ន វិជ្ជតិ** *សេចក្តីថា បណ្តាបទទាំង នោះ បទថា* **យេសុ តាណំ ន វិជ្ជតិ** *សេចក្តីថា បណ្តាកាមពួកណា ដែល ចូលទៅវេទ្នង សូម្បីកាមត្រឹមតែមួយ ក៏ជួយការពារសេចក្តីវិនាសមិនបាន កាមទាំងឡាយ ឈ្មោះថា* **អគ្គិក្ខន្ធូបមា** *ព្រោះថា ដុតឲ្យក្តៅយ៉ាងខ្លាំង ឈ្មោះថា* **ទុខា** *ព្រោះអត្ថថា អត់ធន់បានលំបាក ។*

*សភាវៈដែលឈ្មោះថា* **អហិតា វធកា** **ឃស សកយោ** *ព្រោះវត្ថុដែលហៅ ថាកាម នាំមកតែសេចក្តីវិនាសយ៉ាងធំធេងដែលមិនដឹង ឈ្មោះថា* **សវិឃា-តោ** *ព្រោះបៀតបៀនចិត្ត ឈ្មោះថា* **សកណ្ដកោ** *ព្រោះចាក់ដោត ។ បទ ថា* **គេធោ សុវិសមោ ចេសោ** *សេចក្តីថា ឈ្មោះថា គេធៈ ព្រោះមានតម្រេក ជាហេតុ កាមនោះ មិនរាបស្មើ គឺការកន្លល់យ៉ាងខ្លាំង ។ ឈ្មោះថា* **មហន្តោ** *ព្រោះអត្ថថា ឈានកន្លងបានលំបាក ឈ្មោះថា* **មោហនាមុខោ** *ព្រោះជា ហេតុឲ្យដល់នូវការងប់ជ្រប់ ។ បទថា* **ឧបសគ្គោ ភីមរូបោ** *សេចក្តីថា ឈ្មោះ ថា* **ភីមរូបោ** *ព្រោះនាំទុក្ខ មានការវិនាស ជាដើមមកឲ្យ ដូចឧបសគ្គកើត មកអំពីទេវតា ។ កាមទាំងឡាយ ឈ្មោះថា ធំ ព្រោះនាំទុក្ខមានសេចក្តី វិនាសជាដើមមកឲ្យ កាមទាំងឡាយ ឈ្មោះថា* **សប្បសិរូបមា** *ព្រោះអត្ថថា ជាភ័យចំពោះមុខ ។*

*បទថា* **កាមសំសគ្គសត្តា** *បានដល់ ដែលជាប់ ដែលជំពាក់ដោយ*

ភក់ ពោលគឺកាម ។ បទថា **ទុគ្គតិគមនំ មគ្គំ** បានដល់ ផ្លូវដែលនាំទៅអបាយ មាននរកជាដើម ។ បទថា **កាមហេតុកំ** បានដល់ មានការបរិភោគកាមជាហេតុ ។ បទថា **ពហុំ** បានដល់ ច្រើនយ៉ាង ដោយប្រភេទនៃកម្ម មានបាណាតិបាតជាដើម ។ បទថា **រោគមាវហំ** បានដល់ នាំមកនូវទុក្ខ មានទុក្ខក្នុងបច្ចុប្បន្នជាដើម ដែលរាប់ថា រោគ ព្រោះអត្ថថាចាក់ដោត។

បទថា **ឯវំ** បានដល់ ដោយប្រការដែលពោលមកហើយថា **អមិត្តាវធកា** ជាដើម ។ បទថា **អមិត្តជននា** បានដល់ ឲ្យកើតជាអមិត្ត ។ បទថា **តាបនា** បានដល់ ឲ្យក្ដៅក្រហាយ អធិប្បាយថា ជាទីតាំងនៃការក្ដៅក្រហាយ ។ បទថា **សង្កិលេសិកា** បានដល់ នាំមកនូវកិលេសជាគ្រឿងសៅហ្មង ។ បទថា **លោកាមិសា** បានដល់ ជាអាមិស គឺនុយក្នុងលោក ។ បទថា **ពន្ធនីយា** បានដល់ ត្រូវចងដោយសំយោជនៈ ដែលជាគ្រឿងចង អធិប្បាយថា ដែលសំយោជនៈប្រកប ។ បទថា **មរណពន្ធនា** បានដល់ មរណៈចងទុក ព្រោះឲ្យកើតនិមិត្តដែលទៅកើតក្នុងភពជាដើម និងជាហេតុឲ្យស្លាប់ ។

បទថា **ឧម្មាទនា** បានដល់ កាមទាំងឡាយធ្វើឲ្យឆ្កួត ព្រោះសេចក្ដីសោកដោយការព្រាត់ប្រាសគ្នា ព្រោះកាមមានការប្រែប្រួលជាធម្មតា ឬនាំមកនូវការស្រវឹងក្រៃលែងឡើង ។ បទថា **ឧល្លបនា** បានដល់ បន្ទីវាចា ប៉ាច់ប៉ោចថា ឱសុខហ្ន៎ ឱសុខហ្ន៎ ។ បាលីថា **ឧល្លោលនា** ដូច្នេះក៏មានសេចក្ដីថា រវើរវាយដល់សត្វទាំងឡាយ ព្រោះអាមិសជាហេតុ ដូចខ្ទែបក់

កន្ទុយព្រោះជុំបាយ គឺធ្វើឲ្យមិនឲ្យដឹងថា ជាការវិនាស ។ បទថា **ចិត្តប្ប-មាថិនោ** បានដល់ មានប្រក្រតីញាំញីចិត្ត ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនា-គត ដោយការបង្កនូវការក្តៅក្រហាយជាដើម ។ បាលីថា **ចិត្តប្បមទ្ទិនោ** ក៏មាន សេចក្តីក៏យ៉ាងនោះដូចគ្នា ឯអាចារ្យពួកណាពោលថា **ចិត្តប្បមាថិនោ** អាចារ្យពួកនោះអធិប្បាយថា គឺនាំមកនូវសេចក្តីប្រមាទនៃចិត្ត ។ បទថា **សង្កិលេសាយ** បានដល់ ដើម្បីសេចក្តីវិនាស ដើម្បីសេចក្តីបៀតបៀន ឬក៏ដើម្បីកាត់ផ្តាច់ ។ បទថា **ខិប្បំ មារេន ឱឌ្ឌិតំ** សេចក្តីថា ឈ្មោះថា កាមទាំងនេះ បណ្ឌិតគប្បីឃើញថា ដូចលបដែលមារដាក់ ព្រោះនាំមកតែសេចក្តីវិនាសដល់សត្វទាំងឡាយ ។

បទថា **អនន្តាទីនវា** បានដល់ មានអាទីនវ គឺទោសមិនមានទីបំផុត គឺមានទោសច្រើន ដោយន័យដែលពោលក្នុងទីនេះថា **លោភជំ មជំ ឆញ្ចតំ** ប្រាក់នឹងមាសទ្ទុំះ សុទ្ធតែជាគ្រឿងឲ្យកើតលោភ ជាគ្រឿងស្រវឹង ដូច្នេះជាដើមនិងក្នុងសូត្រទាំងឡាយមានទុក្ខក្ខន្ធសូត្រជាដើមថា តែងមានត្រជាក់បៀតបៀន មានក្តៅបៀតបៀន ដូច្នេះជាដើម ។ បទថា **ពហុទុក្ខា** បានដល់ មានទុក្ខច្រើនយ៉ាង ដូចជាទុក្ខក្នុងអបាយជាដើម ជាប់តាមមក ។ បទថា **មហាវិសា** បានដល់ ដូចថ្នាំពិសដែលខ្លាំងក្លាជាដើម ព្រោះមានផលផ្សាក្តៅ ។ បទថា **អប្បស្សាទា** បានដល់ មានរសឆ្ងាញ់តិច ដូចតំណក់ទឹកឃ្មុំដែលជាប់ត្រង់មុខកាំបិតកោរ ។ បទថា **រណករា** បានដល់ បង្កើតនូវតម្រេកជាដើមក្រៃលែងឡើង ។ បទថា **សុក្កបក្ខវិសោសនា** បានដល់ ធ្វើ

ធម៌ដែលមិនមានទោសរបស់សត្វទាំងឡាយឲ្យវិនាស ។

បទថា **សាហំ** កាត់បទជា **សា អហំ** សេចក្ដីថា ខ្ញុំស្ដាប់ធម៌នៅក្នុងសម្នាក់ព្រះសាស្ដា ដោយន័យដែលពោលហើយអំពីខាងដើម បានទូវសទ្ធាហើយ លះនូវសម្បត្តិចេញបួស ។ បទថា **ឯតាទិសំ** បានដល់ បែបនោះគឺមានប្រការដូចពោលមកហើយ ។ បទថា **ហិត្វា** បានដល់ លះនូវសម្បត្តិនោះ អធិប្បាយថា ព្រោះហេតុតាមដែលពោលមកហើយ ។ បទថា **ន តំ បច្ចាគមិស្សាមិ** សេចក្ដីថា ខ្ញុំនឹងមិនត្រឡប់មកបរិភោគកាមទាំងឡាយដែលខ្ញុំខ្ពាក់មកអំពីមុនហើយ ។ បទថា **និព្វានាភិរតា សទា** ប្រកបសេចក្ដីថា ព្រោះខ្ញុំត្រេកអរក្រៃលែងហើយក្នុងព្រះនិព្វានមកសព្វកាល រាប់តាំងពីពេលដែលបួសហើយ ហេតុនោះ ខ្ញុំនឹងមិនត្រឡប់មករកកាមសម្បត្តិ នោះទៀតឡើយ ។ បទថា **រណំ តរិត្វា កាមានំ** សេចក្ដីថា ចុះកាន់លានចម្បាំងជាមួយកាមទាំងឡាយ ហើយធ្វើចម្បាំងដែលត្រូវធ្វើនោះ ឲ្យជាការប្រហារដោយអរិយមគ្គ ។ បទថា **សីតិភាវាភិកង្ខិនី** បានដល់ ទន្ទឹងព្រះអរហត្តដែលរាប់ថាជាភាវៈត្រជាក់ ព្រោះរម្ងាប់នូវការក្រវល់ក្រវាយ និងការក្ដៅក្រហាយរបស់កិលេសទាំងអស់បាន ។ បទថា **រតា សំយោជនក្ខយេ** បានដល់ ត្រេកអរក្រៃលែងក្នុងព្រះនិព្វានដែលជាធម៌អស់ទៅនៃសំយោជនៈសព្វយ៉ាង ។

បទថា **យេន តិណ្ណា មហេសិនោ** សេចក្ដីថា ពួកអ្នកស្វែងរកគុណដែលធំក្រៃលែង មានព្រះពុទ្ធជាដើម នាំគ្នាចូលមហាឱឃៈគឺសង្សារវដ្ដដោយ

អរិយមគ្គណា ខ្ញុំក៏នឹងដើរតាមមគ្គដែលដើរទៅហើយនោះ សម្រេចតាមដោយការបដិបត្តិសីលជាដើម ។

បទថា **ធម្មដ្ឋំ** បានដល់ តាំងនៅក្នុងធម៌ គឺអរិយផល ។ បទថា **អ-នេជំ** បានដល់ ផលដ៏ប្រសើរ ដែលបានឈ្មោះថា **អនេជំ** ព្រោះរម្ងាប់នូវការញាប់ញ័របានហើយ ។ បទថា **ឧបសម្បជ្ជ** បានដល់ សម្រេចផលហើយ គឺសម្រេចដោយការសម្រេចអរហត្តមគ្គ ។ បទថា **ឈាយតិ** បានដល់ ចូលទៅសម្ងំផលជ្ឈាននោះឯង ។

បទថា **អដ្ឋដ្ឋមី បព្វជិតា** សេចក្តីថា នាងបួសហើយ គឺរាប់តាំងអំពីថ្ងៃដែលនាងបួសហើយ ថ្ងៃនេះជាថ្ងៃទី ៨ ។ អធិប្បាយថា នាងបួសហើយបាន ៨ រាត្រី រាប់តាំងពីថ្ងៃដែលកន្ទងមកហើយនេះ ។ បទថា **សទ្ធា** បានដល់ ដល់ព្រមដោយសទ្ធា ។ បទថា **សទ្ធម្មសោភណា** បានដល់ ស្អាតព្រោះសម្រេចព្រះសទ្ធម្ម ។

បទថា **កុជិស្សា** បានដល់ ឈ្មោះថា **កុជិស្សា** ព្រោះលះកិលេសទាំងឡាយដែលដូចជាទាសៈ ឈ្មោះថា **អនណា** ព្រោះប្រាសចាកបំណុលមានកាមច្ឆន្ទៈជាដើម ។

បានឮថា ព្រះថេរីបួសហើយក្នុងថ្ងៃទី ៨ ក៏សម្រេចអរហត្ត អង្គុយចូលផលសមាបត្តិត្រង់គល់ឈើមួយដើម ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ភិក្ខុនីទាំងឡាយហើយ ទ្រង់សរសើរ ទើបត្រាស់គាថាទាំង ៣ នេះ ។

កាលនោះ សក្កទេវរាជទ្រង់ឃើញរឿងនោះដោយទិព្វចក្ខុហើយ ត្រិះរិះ

ថា ព្រោះព្រះថេរីរូបនេះ ព្រះសាស្តាទ្រង់សរសើរយ៉ាងនេះ ដូច្នោះ អាត្មាអញ មួយអន្លើដោយទេវតាទាំងឡាយ គួរចូលទៅរក ដូច្នេះហើយ រំពេចនោះឯង ទ្រង់ក៏យាងទៅរក មួយអន្លើដោយទេវតាជាន់តាវត្តិង្ស ទ្រង់អភិវាទហើយ ផ្គងអញ្ជលី ប្រថាប់ឈរ ។ សំដៅដល់រឿងនេះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

ទេវរាជឈ្មោះសក្កៈ ជាម្ចាស់នៃពួកសត្វ ព្រមទាំងពួកទេវតា
ចូលទៅនមស្ការចំពោះភិក្ខុនីឈ្មោះ សុភាកម្មារធីតានោះដោយ
ឫទ្ធិ ( របស់ខ្លួន ) ដូច្នេះ ។

ក្នុងគាថានោះ សេចក្តីថា សក្កទេវរាជទ្រង់បានព្រះនាមថា **ភូតបតិ** ព្រោះវិគ្គហៈថា ទ្រង់ជាធំជាងពួកសត្វ ដែលកើតក្នុងកាមភពទាំង ៣ ទ្រង់ចូលទៅរកព្រះនាងសុភាកម្មារធីតុថេរីរូបនោះ មួយអន្លើដោយពួកទេវតាដោយឫទ្ធិរបស់ព្រះអង្គ ទ្រង់នមស្ការ គឺទ្រង់ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។

**អដ្ឋកថា សុភាកម្មារធីតាថេរីគាថា ចប់**

**ថេរីគាថា វីសតិនិបាត ចប់**

# ថេរីគាថា តឹសនិបាត

## សុភាជីវកម្ពវនិកាថេរីគាថា

[ ៣៣៦ ] ( សុវណ្ណការបុត្ត ) ជាអ្នកលេង រារាំងភិក្ខុនីឈ្មោះសុភា កំពុងដើរទៅកាន់ជីវកម្ពវ័ន ជាទីរីករាយ ភិក្ខុនីឈ្មោះសុភា ក៏បានពោលនឹងសុវណ្ណការបុត្តនោះថា ។ កំហុសដូចម្តេច ដែលអាត្មាប្រទូស្តដល់អ្នក បានជាអ្នកឈររាំងអាត្មា នែអាវុសោ បុរសមិនគួរប៉ះពាល់នូវស្ត្រីជាបព្វជិតទេ ។ សិក្ខាទាំងឡាយក្នុងសាសនារបស់ព្រះសាស្តា ជាសិក្ខាគួរគោរព ព្រះសុគតបានសំដែងហើយដល់អាត្មា ហេតុដូចម្តេច ក៏អ្នកមកឈររាំងអាត្មា ដែលជាស្រីមានចំណែកនៃធម៌ដ៏បរិសុទ្ធ មិនមានទីទួលគឺកិលេស ។ អ្នកជាបុគ្គលមានចិត្តល្អក់ ប្រកបដោយធូលីគឺរាគៈ ហេតុដូចម្តេចក៏អ្នកមកឈររាំងអាត្មា ដែលជាស្រីមានចិត្តថ្លាស្អាត ប្រាសចាកធូលីគឺរាគៈ មិនមានទីទួលគឺកិលេស មានចិត្តផុតស្រឡះហើយ ( ចាកខន្ធបញ្ចកៈ ) ទាំងអស់ ។

( អ្នកលេងពោលថា ) នាងជាស្ត្រីនៅក្រមុំផង មិនអាក្រក់ផង បព្វជ្ជានឹងធ្វើប្រយោជន៍អ្វីដល់នាង ចូរនាងបោះចោលកាសាយចីវរចេញទៅ ហើយចូរមក យើងនឹងបានត្រេកត្រអាលក្នុងព្រៃដែលមានផ្ការីកល្អ ។ ដើមឈើទាំងឡាយហាក់ដូចជាតាំងឡើងដោយលម្អផ្កា បក់ផ្សព្វផ្សាយនូវក្លិនដ៏ក្រអូបសព្វទិស ( នេះ ) ជាវសន្តរដូវជាដំបូង ជារដូវនាំមកនូវសុខ នាងចូរមក យើងនឹងត្រេកត្រអាលក្នុងព្រៃដែលមានផ្ការីកល្អ ។ ដើមឈើទាំងឡាយ មានចុងស្គុសស្គាយដោយផ្កា លុះត្រូវខ្យល់បក់មក ក៏ហាក់ដូចជាបន្លឺ

សំឡេងឡើង ប្រសិនបើនាងនឹងចូលទៅក្នុងព្រៃម្នាក់ឯង នាងនឹងត្រេកត្រ-អាលដូចម្តេចកើត ។ នាងជាស្ត្រីឥតមិត្តសម្លាញ់ ចង់ទៅកាន់ព្រៃធំ ដែលប្រាសចាក ( មនុស្ស ) គួរឲ្យស្រប់ស្រែង ជាព្រៃដែលហ្វូងម្រឹគសាហាវនៅអាស្រ័យ ជាព្រៃដែលដំរីចុះប្រេងនិងមេដំរីបុកបែន ។ នាងប្រៀបដូចរូបតុក្កតាដែលសូនដោយមាសឆ្អិន ឬដូចជាស្ត្រីទេពអប្សរ ត្រាច់ទៅក្នុងឧទ្យានឈ្មោះចិត្តរថ ម្នាលនាងជាស្ត្រីល្អឥតឧបមា នាងល្អដោយសំពត់សម្រាប់ស្លៀកដណ្តប់ មានសាច់ដ៏ល្អិតសុខុម ដែលកើតក្នុងដែនកាសី ។ បើនាងនៅក្នុងចន្លោះព្រៃ ខ្ញុំនឹងលុះក្នុងអំណាចនៃនាង ម្នាលនាងជាស្ត្រីមានភ្នែកស្រទន់ដូចកិន្នរី ជីវិត ( របស់ខ្ញុំ ) ជាទីស្រឡាញ់ក្រៃលែងជាងនាង មិនមានទេ ។ បើនាងនឹងធ្វើតាមពាក្យខ្ញុំ នាងចូរមក ចូរនៅគ្រប់គ្រងផ្ទះជាសុខចុះ នាងនឹងនៅក្នុងប្រាសាទ មិនមានខ្យល់ ពួកនាងនារី ចូរធ្វើនូវការខ្វល់ខ្វាយបម្រើដល់នាង ។ ចូរនាងទ្រទ្រង់នូវសំពត់មានសាច់ម៉ដ្ឋ ដែលនាំមកអំពីដែនកាសី ចូរនាងតែងខ្លួនដោយផ្កាកម្រងនិងគ្រឿងលាបចុះ ខ្ញុំនឹងផ្គត់ផ្គង់គ្រឿងអាភរណៈផ្សេងៗច្រើនយ៉ាងដែលរចនាហើយដោយមាស កែវមណី និងកែវមុក្តាដល់នាង ។ ចូរនាងឡើងកាន់ដំណេកថ្មី ល្អ ដែលស្អាតគ្មានធូលី ព្រោះជម្រះលាងប្រពៃ ដែលក្រាលដោយកម្រាលរោមចៀម ញាត់ដោយសំឡីមានតម្លៃច្រើន ប្រដាប់ដោយខ្លឹមចន្ទន៍មានក្លិនក្រអូប ។ នាងជាស្ត្រីប្រព្រឹត្តព្រហ្មចារ្យ នាងនឹងដល់នូវការចាស់គ្រាំគ្រា ត្រង់អវយវៈទាំងឡាយរបស់ខ្លួន ដូចជាផ្កាឧប្បលលូតផុតទឹកដែលអមនុស្សហួងហែងរក្សា ( នឹងជាវត្ថុឥតមាន

អ្នកណាប្រើប្រាស់កើត ) ។

( នាងថេរីពោលថា ) ហេតុដូចម្តេច ក៏អ្នកមានគំនិតខុស សម្លឹងមើល ( អាត្មា ) ព្រោះឃើញនូវអារម្មណ៍ដែលសន្មតថាមានខ្លឹម ក្នុងរាងកាយនេះ ដ៏ពេញដោយសាកសព គ្រាន់តែការចម្រើនរបស់ព្រៃស្មសាន ជារាងកាយ បែកធ្លាយជាធម្មតា ។

( អ្នកលេងពោលថា ) ភ្នែកទាំងឡាយ ( របស់នាង ) ដូចជាភ្នែក កូនម្រឹគញី ឬដូចជាភ្នែកនៃកិន្នរីក្នុងចន្លោះនៃភ្នំ តម្រេកក្នុងកាមរបស់ខ្ញុំរមែង ចម្រើនក្រៃលែង ព្រោះឃើញនូវភ្នែករបស់នាង ។ កាមគុណរបស់ខ្ញុំរមែង ចម្រើនឡើងក្រៃលែង ព្រោះឃើញភ្នែករបស់នាង ដែលប្រៀបដោយត្របក នៃផ្កាឧប្បល ត្រង់មុខ ប្រាសចាកមន្ទិល ប្រាកដស្មើដោយមាស ។ នៃនាង មានរូបស្រស់ស្រោង មានភ្នែកថ្លាស្អាត បើទុកជាយើងទៅកាន់ទីឆ្ងាយ ក៏នៅ តែរឭកឃើញ ម្នាលនាងមានភ្នែកថ្លាដូចភ្នែកកិន្នរី ឥតមានអ្វីមួយជាទីស្រ-ឡាញ់នៃខ្ញុំជាងភ្នែករបស់នាងទេ ។

( នាងថេរីពោលថា ) អ្នកប្រាថ្នានូវធីតាជាឱរសរបស់ព្រះពុទ្ធ ( នេះ ) ឈ្មោះថាប្រាថ្នាដើម្បីដើរទៅតាមផ្លូវខុស ឈ្មោះថា ស្វែងរកព្រះចន្ទមកធ្វើ ជាល្បែង ឈ្មោះថាប្រាថ្នាដើម្បីលោតឡើងកាន់ភ្នំសិនេរុ ។ ឥឡូវនេះ ប្រសិន បើរាគៈគប្បីមានដល់អាត្មាក្នុងអារម្មណ៍ណា អារម្មណ៍នោះមិនមានក្នុងលោក ព្រមទាំងទេវលោក អាត្មាមិនដឹងនូវដំណើរនោះថា មានការៈអ្វីស្មើ ( ដោយ រាគៈ ) ទេ បានជា ( រាគៈនោះ ) អាត្មាដកចោលទាំងឫស ដោយអរិយ

មគ្គហើយ ។ ( រាគៈនោះ ) អាត្មាបានកម្ចាត់ចេញហើយ ដូចជាភាជនៈដាក់នូវថ្នាំពិស ដែលបុគ្គលបោះចោលក្នុងរងើកភ្លើងហើយ អាត្មាមិនឃើញនូវដំណើរនោះថា មានសភាវៈអ្វីស្មើ ( ដោយរាគៈ ) ទេ បានជា ( រាគៈនោះ ) អាត្មាដកចោលទាំងឫស ដោយអរិយមគ្គហើយ ។ ខន្ធបញ្ចកៈដែលស្ត្រីណាមិនបានពិចារណាឃើញ ឬថាស្ត្រីណា ដែលមិនបានចូលទៅអង្គុយជិតព្រះសាស្តា អ្នកចូរប្រលោមនូវស្ត្រី ប្រាកដដូច្នោះចុះ អ្នកនោះនឹងចង្អៀតចង្អល់ ( ព្រោះអាស្រ័យ ) ភិក្ខុនីនេះ ជាអ្នកដឹង ( អរិយសច្ច ) ។ ព្រោះថាស្មារតីរបស់អាត្មា បានតម្កល់ខ្ជាប់ហើយក្នុងបុគ្គលអ្នកជេរ និងអ្នកថ្វាយបង្គំក្នុងសុខ និងទុក្ខ ចិត្តរបស់អាត្មាមិនជាប់ក្នុងអារម្មណ៍ទាំងអស់នោះ ព្រោះដឹងច្បាស់ថា សង្ខតារម្មណ៍ ជារបស់មិនស្អាត ។ អាត្មាជាសាវិការបស់ព្រះសុគត ជាអ្នកដើរទៅដោយយានគឺអដ្ឋង្គិកមគ្គ មានសរ គឺកិលេស ដកចោលហើយ ឥតមានអាសវៈ ជាអ្នកត្រេកអរក្នុងផ្ទះស្ងាត់ ។ ព្រោះថា អាត្មាបានឃើញរូបយន្តឈើជាគ្រោងថ្មី ដែលគាត់តែងដ៏វិចិត្រ ចងរឹតដោយខ្សែសរសៃទាំងឡាយ និងឈើកន្លាស់ទាំងឡាយ ដូចជាគេរាំ ដោយអាការផ្សេង ៗ ។ កាលបើខ្សែសរសៃនិងឈើកន្លាស់នោះ ដាច់រដកចេញ រាត់រាយរលុងរង្គោះបាក់បែកខ្ចាត់ខ្ចាយ កាលបើរូបយន្តរង្គោះដាច់ខ្ចាត់ខ្ចាយហើយ បុគ្គលមិនគប្បីបាន ( រូបយន្តនោះ ) ទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរូបនោះដូចម្តេចកើត ។ រាងកាយទាំងឡាយរបស់ខ្ញុំដូចគ្នានឹងរូបយន្តដែរ បើវៀរចាករូបធម៌ មានចក្ខុជាដើមនោះហើយរមែងប្រព្រឹត្តទៅមិនបាន រាងកាយបើវៀរចាករូបធម៌ហើយ

ប្រព្រឹត្តទៅមិនបានទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរាងកាយនោះដូចម្ដេចកើត ។ បុគ្គលឃើញរូបស្រ្តីដែលគេគូរនឹងជញ្ជាំង លាបលនដោយថ្នាំដ៏ស្រស់យ៉ាងណាមិញ អ្នកមានការឃើញវិបរិតក្នុងរូបនោះ ក៏យ៉ាងនោះដែរ បញ្ញាជារបស់មនុស្សឥតប្រយោជន៍ទេឬ ។ នែបុគ្គលអន្ធពាល អ្នកស៊ុះចូលមកជិតនូវអត្តភាពដ៏ទទេ ដែលប្រៀបដូចជាថ្ងៃបណ្ដើរកូនតាំងនៅក្នុងខាងមុខ ឬដូចជាយល់សប្តិឃើញដើមឈើមាស ពុំនោះដូចជារូបយន្តគ្រាំគ្រាក្នុងកណ្ដាលនៃជន ។ ពពុះបាំងស្បែកកណ្ដាលភ្នែក ឬព្រៀកទឹកភ្នែក ឬក៏ពកបាយភ្នែក តែងកើតក្នុងមណ្ឌលនៃភ្នែកនោះ ដូចជាពពុះទឹកលក្ត ដែលបុគ្គលប្រោះលើកម្រាលចៀមស្ងួត ព្រោះថាសណ្ឋានរបស់ភ្នែក មានពណ៌ផ្សេងៗដែលសន្មារតាក់តែងហើយ ។

នាងសុភាភិក្ខុនី មានចិត្តឥតជាប់ចំពាក់ បានឆ្កៀលភ្នែកជាទីស្រឡាញ់ មិនជាប់ចំពាក់ ហើយក៏ឲ្យដល់បុរសនោះ ក្នុងពេលនោះ ដោយពាក្យថា ហ៊ឺ អាត្មាឲ្យភ្នែកដល់អ្នក ចូរអ្នកយកភ្នែកនោះទៅចុះ ។ រាគៈរបស់បុរសនោះក៏ប្រាសចេញក្នុងខណៈនោះផង បុរសនោះបានញ៉ាំងភិក្ខុនីនោះ ឲ្យអត់ទោសក្នុងទីនោះផង ដោយពាក្យថា ម្នាលនាងជាព្រហ្មចារិនី សួស្តីបូរមាន ( ដល់នាង ) ការប្រព្រឹត្តិអនាចារបែបនេះនឹងមិនមានដល់ខ្ញុំទេ ។ បើខ្ញុំបៀតបៀនជន ( ដែលគ្មានរាគៈ ) យ៉ាងនេះ ក៏ហាក់ដូចជាខ្ញុំឱបភ្លើងកំពុងឆេះសន្ធោសន្ធៅ ឬចាប់នូវអាសិរពិស បើដូច្នោះ សូមសួស្តីកើតមានដល់នាង សូមនាងអត់ទោសដល់ខ្ញុំ ។

ភិក្ខុនី លុះរួចអំពីបុរសជាអ្នកលេងនោះហើយ ក៏បានទៅកាន់សំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ចក្ខុក៏កើតឡើងដូចពីដើម ព្រោះបានឃើញនូវមហាបុរិសលក្ខណៈដែលកើតអំពីបុញ្ញសម្ភារដ៏ប្រសើរ ។

សុភាថេរី នៅក្នុងជីវកម្ពវ័ន ។

ចប់ តឹសនិបាត ។

# អដ្ឋកថា

# ថេរីគាថា តឹសនិបាត

## សុភាជីវកម្ពវនិកាថេរីគាថា

[ ៣៣៦ ] ក្នុងតឹសនិបាត គាថារបស់ព្រះនាងសុភាជីវកម្ពវនិកាថេរី មានពាក្យផ្តើមថា **ជីវកម្ពវនំ រម្មំ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ អប់រំនូវកុសលមូល សាងនូវបុញ្ញសម្ភារ ដែលជាគ្រឿងតាក់តែងវិមោក្ខដោយលំដាប់ មានញាណចាស់ក្លា លុះដល់ពុទ្ធុប្បាទនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងរាជគ្រឹះ មានឈ្មោះថាសុភា ។

បានឮថា នាងមានចំណែកសរីរៈ ប្រកបដោយពណ៌សម្បុរដូចមាស

ព្រោះហេតុនោះ ទើបមាននាមតាមនោះថាសុភា ប្រែថា ស្អាត ។ ខណៈព្រះសាស្តាយាងចូលទៅកាន់ក្រុងរាជគ្រឹះ នាងក៏បាននូវសទ្ធា ជាឧបាសិកា តមកកើតសេចក្តីសង្វេគក្នុងសង្សារវដ្ត ឃើញទោសក្នុងកាមទាំងឡាយ ឃើញនេក្ខម្មៈជាផ្លូវក្សេម បួសក្នុងសម្នាក់ព្រះនាងបជាបតិគោតមី បំពេញវិបស្សនា ២-៣ ថ្ងៃប៉ុណ្ណោះ តាំងនៅក្នុងអនាគាមិផល ។ តមក កំលោះអ្នកលេងម្នាក់ ជាអ្នកក្រុងរាជគ្រឹះ ឃើញព្រះថេរីកំពុងដើរទៅដើម្បីសម្រាកពេលថ្ងៃត្រង់ជីវកម្ពវនវិហារ កើតចិត្តប្រតិព័ទ្ធ ឈរពាំងផ្លូវ ពោលបបួលដោយកាមារម្មណ៍ ។ ព្រះថេរីកាលប្រកាសទោសរបស់កាមទាំងឡាយ និងអធ្យាស្រ័យក្នុងនេក្ខម្មៈ គឺការបួសរបស់ខ្លួនដោយប្រការផ្សេងៗ ទើបពោលធម៌ដល់បុរសនោះ ។ បុរសនោះ ស្តាប់ធម្មកថាហើយ ក៏មិនព្រមថយក្រោយនៅតែដើរតាមនោះឯង ។ ព្រះថេរីឃើញបុរសនោះមិនតាំងនៅក្នុងពាក្យរបស់ខ្លួន ហើយឈរសរសើរភ្នែក ក៏ពោលថា ណ្ហើយចុះ អ្នកប្រហែលជាស្រឡាញ់ភ្នែក ហើយខ្វេះភ្នែកម្ខាងរបស់ខ្លួនប្រគល់ឲ្យ ។ លំដាប់នោះ បុរសនោះកើតសេចក្តីសង្វេគ អស់សេចក្តីស្រឡាញ់ក្នុងព្រះថេរី សូមខមាទោសព្រះថេរីហើយ ក៏ចៀសចេញទៅ ។ ព្រះថេរីក៏ទៅកាន់សម្នាក់របស់ព្រះសាស្តា ដំណាលគ្នានឹងការជួបព្រះសាស្តានោះឯង ភ្នែករបស់នាងក៏មានដូចប្រក្រតី ។ លំដាប់នោះ ព្រះថេរីឈរ ត្រូវបីតិក្នុងព្រះពុទ្ធគុណប្រព្រឹត្តទៅ ពាល់ត្រូវមិនដាច់ ព្រះសាស្តាជ្រាបវារៈចិត្តរបស់ព្រះថេរី ទ្រង់សម្តែងធម៌ត្រាស់ប្រាប់កម្មដ្ឋានដើម្បីអរហត្តមគ្គ ព្រះថេរីសង្កត់នូវបីតិបានហើយ ចម្រើនវិបស្សនា

សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ក្នុងខណៈនោះឯង ។ កាល សម្រេចអរហត្តហើយ នៅដោយផលសុខនិងនិព្វានសុខ ពិចារណាបដិបទា របស់ខ្លួន ពោលគាថាដែលខ្លួននិងបុរសអ្នកលេងនោះពោលហើយ ជាឧទាន ថា

( សុវណ្ណការបុត្ត ) ជាអ្នកលេង រារាំងភិក្ខុនីឈ្មោះសុភា កំពុងដើរទៅកាន់ជីវកម្ពវ័ន ជាទីរីករាយ ភិក្ខុនីឈ្មោះសុភា ក៏ បានពោលនឹងសុវណ្ណការបុត្តនោះថា ។ កំហុសដូចម្តេចដែល អាត្មាប្រទូស្តដល់អ្នក បានជាអ្នកឈររាំងអាត្មា នែអាវុសោ បុរសមិនគួរប៉ះពាល់នូវស្ត្រីជាបព្វជិតទេ ។ សិក្ខាទាំងឡាយ ក្នុងសាសនារបស់ព្រះសាស្តា ជាសិក្ខាគួរគោរព ព្រះសុគត បានសំដែងហើយដល់អាត្មា ហេតុដូចម្តេច ក៏អ្នកមកឈររាំង អាត្មាដែលជា ស្រីមានចំណែកនៃធម៌ដ៏បរិសុទ្ធ មិនមានទីទួល គឺកិលេស ។ អ្នកជាបុគ្គលមានចិត្តល្អក់ ប្រកបដោយធូលី គឺរាគៈ ហេតុដូចម្តេច ក៏អ្នកមកឈររាំងអាត្មាដែលជាស្រីមាន ចិត្តថ្លាស្អាត ប្រាសចាកធូលីគឺរាគៈ មិនមានទីទួលគឺកិលេស មានចិត្តផុតស្រឡះហើយ ( ចាកខន្ធបញ្ចកៈ ) ទាំងអស់ ។

( អ្នកលេងពោលថា ) នាងជាស្ត្រីនៅក្រមុំផង មិនអា- ក្រក់ផង បព្វជ្ជានឹងធ្វើប្រយោជន៍អ្វីដល់នាង ចូរនាងបោះបោល កាសាយចីវរចេញទៅ ហើយចូរមក យើងនឹងបានត្រេកត្រ-

អាលក្នុងព្រៃដែលមានផ្ការីកល្អ ។ ដើមឈើទាំងឡាយហាក់ដូចជាតាំងឡើងដោយលម្អផ្កា បក់ផ្សព្វផ្សាយនូវក្លិនដ៏ក្រអូបសព្វទិស ( នេះ ) ជាវសន្តរដូវជាដំបូង ជារដូវនាំមកនូវសុខ នាងចូរមកយើងនឹងត្រេកត្រអាលក្នុងព្រៃដែលមានផ្ការីកល្អ។ ដើមឈើទាំងឡាយ មានចុងស្កុសស្កាយដោយផ្កា លុះត្រូវខ្យល់បក់មក ក៏ហាក់ដូចជាបន្ទឺសំឡេងឡើង ប្រសិនបើនាងនឹងចូលទៅក្នុងព្រៃម្នាក់ឯង នាងនឹងត្រេកត្រអាល ដូចម្ដេចកើត ។ នាងជាស្ត្រីឥតមិត្តសម្លាញ់ ចង់ទៅកាន់ព្រៃធំ ដែលប្រាសចាក ( មនុស្ស ) គួរឲ្យស្ញប់ស្ញែង ជាព្រៃដែលហ្វូងម្រឹគសាហាវនៅអាស្រ័យ ជាព្រៃដែលដំរីចុះប្រេង និងមេដំរីបុកបែន ។ នាងប្រៀបដូចរូបតុក្កតាដែលសូនដោយមាសឆ្អិន ឬដូចជាស្ត្រីទេពអប្សរត្រាច់ទៅក្នុងឱទ្យានឈ្មោះចិត្តរថ ម្នាលនាងជាស្ត្រីល្អឥតឧបមា នាងល្អដោយសំពត់សម្រាប់ស្លៀកដណ្ដប់ មានសាច់ដ៏ល្អិតសុខុម ដែលកើតក្នុងដែនកាសី ។ បើនាងនៅក្នុងចន្លោះព្រៃ ខ្ញុំនឹងលុះក្នុងអំណាចនៃនាង ម្នាលនាងជាស្ត្រីមានភ្នែកស្រទន់ដូចកិន្នរី ជីវិត ( របស់ខ្ញុំ ) ជាទីស្រឡាញ់ក្រៃលែងជាងនាងមិនមានទេ ។ បើនាងនឹងធ្វើតាមពាក្យខ្ញុំ នាងចូរមក ចូរនៅគ្រប់គ្រងផ្ទះជាសុខចុះ នាងនឹងនៅក្នុងប្រាសាទមិនមានខ្យល់ ពួកនាងនារីចូរធ្វើនូវការខ្វល់ខ្វាយ

បម្រើដល់នាង ។ ចូរនាងទ្រទ្រង់នូវសំពត់មានសាច់ម៉ដ្ឋ ដែលនាំមកអំពីដែនកាសី ចូរនាងតែងខ្លួន ដោយផ្កាកម្រងនិងគ្រឿងលាបចុះ ខ្ញុំនឹងផ្គត់ផ្គង់គ្រឿងអាភរណៈផ្សេងៗច្រើនយ៉ាងដែលរចនាហើយដោយមាស កែវមណី និងកែវមុក្តា ដល់នាង ។ ចូរនាងឡើងកាន់ដំណេកថ្មី ល្អ ដែលស្អាតគ្មានធូលី ព្រោះជម្រះលាងប្រពៃ ដែលក្រាលដោយកម្រាលរោមចៀម ញាត់ដោយសំឡីមានតម្លៃច្រើន ប្រដាប់ដោយខ្លឹមចន្ទន៍មានក្លិនក្រអូប ។ នាងជាស្ត្រីប្រព្រឹត្តព្រហ្មចារ្យ នាងនឹងដល់នូវការចាស់គ្រាំគ្រាត្រង់អវយវៈទាំងឡាយរបស់ខ្លួន ដូចជាផ្កាឧប្បលលូតផុតទឹកដែលអមនុស្សហួងហែងរក្សា ( នឹងជាវត្ថុឥតមានអ្នកណាប្រើប្រាស់កើត ) ។

( នាងថេរីពោលថា ) ហេតុដូចម្តេច ក៏អ្នកមានគំនិតខុសសម្លឹងមើល ( អាត្មា ) ព្រោះឃើញនូវអារម្មណ៍ដែលសន្មតថាមានខ្លឹមក្នុងរាងកាយនេះ ដ៏ពេញដោយសាកសព គ្រាន់តែការចម្រើនរបស់ព្រៃស្មសាន ជារាងកាយបែកធ្លាយជាធម្មតា ។

( អ្នកលេងពោលថា ) ភ្នែកទាំងឡាយ ( របស់នាង ) ដូចជាភ្នែកកូនម្រឹគញី ឬដូចជាភ្នែកនៃកិន្នរី ក្នុងចន្លោះនៃភ្នំតម្រេកក្នុងកាមរបស់ខ្ញុំ រមែងចម្រើនក្រៃលែង ព្រោះឃើញនូវភ្នែករបស់នាង ។ កាមគុណរបស់ខ្ញុំរមែងចម្រើនឡើងក្រៃ

លែង ព្រោះឃើញភ្នែករបស់នាងដែលប្រៀបដោយត្របកនៃផ្កាឧប្បលត្រង់មុខប្រាសចាកមន្ទិល ប្រាកដស្មើដោយមាស ។ នៃនាងមានរូបស្រស់ស្រោង មានភ្នែកថ្លាស្អាត បើទុកជាយើងទៅកាន់ទីឆ្ងាយ ក៏នៅតែរឭកឃើញ ម្នាលនាងមានភ្នែកថ្លាដូចភ្នែកកិន្នរី ឥតមានអ្វីមួយជាទីស្រឡាញ់នៃខ្ញុំជាងភ្នែករបស់នាងទេ ។

( នាងថេរីពោលថា ) អ្នកប្រាថ្នានូវធីតាជាឱរសរបស់ព្រះពុទ្ធ ( នេះ ) ឈ្មោះថាប្រាថ្នាដើម្បីដើរទៅតាមផ្លូវខុស ឈ្មោះថាស្វែងរកព្រះចន្ទមកធ្វើជាល្បែង ឈ្មោះថាប្រាថ្នាដើម្បីលោតឡើងកាន់ភ្នំសិនេរុ ។ ឥឡូវនេះ ប្រសិនបើរាគៈគប្បីមានដល់អាត្មាក្នុងអារម្មណ៍ណា អារម្មណ៍នោះមិនមានក្នុងលោកព្រមទាំងទេវលោក អាត្មាមិនដឹងនូវដំណើរនោះថា មានភាវៈអ្វីស្មើ ( ដោយរាគៈ ) ទេ បានជា ( រាគៈនោះ ) អាត្មាដកចោលទាំងឫស ដោយអរិយមគ្គហើយ ។ ( រាគៈនោះ ) អាត្មាបានកម្ចាត់ចេញហើយ ដូចជាភាជនៈដាក់នូវថ្នាំពិស ដែលបុគ្គលបោះចោលក្នុងរងើកភ្លើងហើយ អាត្មាមិនឃើញនូវដំណើរនោះថា មានសភាវៈអ្វីស្មើ ( ដោយរាគៈ ) ទេ បានជា ( រាគៈនោះ ) អាត្មាដកចោលទាំងឫស ដោយអរិយមគ្គហើយ ។ ខន្ធបញ្ចកៈដែលស្ត្រីណាមិនបានពិចារណាឃើញ ឬ

ថាស្ត្រីណាដែលមិនបានចូលទៅអង្គុយជិតព្រះសាស្តា អ្នកចូរ
ប្រលោមនូវស្ត្រី ប្រាកដដូច្នោះចុះ អ្នកនោះនឹងចង្អៀតចង្អល់
( ព្រោះអាស្រ័យ ) ភិក្ខុនីនេះ ជាអ្នកដឹង ( អរិយសច្ច ) ។
ព្រោះថា ស្មារតីរបស់អាត្មា បានតម្កល់ខ្ជាប់ហើយក្នុងបុគ្គល
អ្នកជេរនិងអ្នកថ្វាយបង្គំ ក្នុងសុខនិងទុក្ខ ចិត្តរបស់អាត្មាមិន
ជាប់ក្នុងអារម្មណ៍ទាំងអស់នោះ ព្រោះដឹងច្បាស់ថា សង្ខតា
រម្មណ៍ជារបស់មិនស្អាត ។ អាត្មាជាសាវិការបស់ព្រះសុគត
ជាអ្នកដើរទៅដោយយានគឺអដ្ឋង្គិកមគ្គ មានសរ គឺកិលេស ដក
ចោលហើយ ឥតមានអាសវៈ ជាអ្នកត្រេកអរក្នុងផ្ទះស្ងាត់ ។
ព្រោះថា អាត្មាបានឃើញរូបយន្តឈើជាគ្រោងថ្មី ដែលគាត់
តែងដ៏វិចិត្រ ចងរឹតដោយខ្សែសរសៃទាំងឡាយ និងឈើកន្លាស់
ទាំងឡាយ ដូចជាគេរាំដោយអាការផ្សេងៗ ។ កាលបើខ្សែ
សរសៃនិងឈើកន្លាស់នោះដាច់ដេកចេញ រាត់រាយរលុងរង្គោះ
បាក់បែកខ្ចាត់ខ្ចាយ កាលបើរូបយន្តរង្គោះដាច់ខ្ចាត់ខ្ចាយហើយ
បុគ្គលមិនគប្បីបាន ( រូបយន្តនោះ ) ទេ បុគ្គលគប្បីតម្កល់
ចិត្តក្នុងរូបនោះ ដូចម្តេចកើត ។ រាងកាយទាំងឡាយរបស់ខ្ញុំ
ដូចគ្នានឹងរូបយន្តដែរ បើវៀរចាករូបធម៌ មានចក្ខុជាដើមនោះ
ហើយ រមែងប្រព្រឹត្តទៅមិនបាន រាងកាយបើវៀរចាករូបធម៌
ហើយ ប្រព្រឹត្តទៅមិនបានទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរាង

កាយនោះដូចម្តេចកើត ។ បុគ្គលឃើញរូបស្រ្តីដែលគេគូរនឹងជញ្ជាំង លាបលនដោយថ្នាំដ៏ស្រស់ យ៉ាងណាមិញ អ្នកមានការឃើញវិបរិតក្នុងរូបនោះ ក៏យ៉ាងនោះដែរ បញ្ញារបស់មនុស្សឥតប្រយោជន៍ទេឬ ។ នៃបុគ្គលអន្ធពាល អ្នកស្ទុះចូលមកជិតនូវអត្តភាពដ៏ទទេ ដែលប្រៀបដូចជាថ្ងៃបណ្តើរកូនតាំងនៅក្នុងខាងមុខ ឬដូចជាយល់សប្តិឃើញដើមឈើមាសពុំនោះដូចជារូបយន្តគ្រាំគ្រា ក្នុងកណ្តាលនៃជន ។ ពពុះបាំងស្បែកកណ្តាលភ្នែក ឬព្រៀកទឹកភ្នែក ឬក៏ពកបាយភ្នែកតែងកើតក្នុងមណ្ឌលនៃភ្នែកនោះ ដូចជាពពុះទឹកល័ក្ត ដែលបុគ្គលប្រោះលើកម្រាលចៀមស្ងួត ព្រោះថាសណ្ឋានរបស់ភ្នែក មានពណ៌ផ្សេងៗដែលសង្ខារតាក់តែងហើយ ។

នាងសុភាភិក្ខុនី មានចិត្តឥតជាប់ចំពាក់ បានធ្មៀលភ្នែកជាទីស្រឡាញ់ មិនជាប់ចំពាក់ ហើយក៏ឲ្យដល់បុរសនោះ ក្នុងពេលនោះ ដោយពាក្យថា ហ៎ អាត្មាឲ្យភ្នែកដល់អ្នក ចូរអ្នកយកភ្នែកនោះទៅចុះ ។ រាគៈរបស់បុរសនោះ ក៏ប្រាសចេញក្នុងខណៈនោះផង បុរសនោះបានញុំាងភិក្ខុនីនោះឲ្យអត់ទោសក្នុងទីនោះផង ដោយពាក្យថា ម្នាលនាងជាព្រហ្មចារិនី សួស្តីចូរមាន ( ដល់នាង ) ការប្រព្រឹត្តិអនាចារបែបនេះនឹងមិនមានដល់ខ្ញុំទេ ។ បើខ្ញុំបៀតបៀនជន ( ដែលគ្មានរាគៈ ) យ៉ាង

នេះ ក៏ហាក់ដូចជាខ្ញុំឱបភ្លើងកំពុងឆេះសន្ធោសន្ធៅ ឬចាប់នូវអាសិរពិស បើដូច្នោះសូមសួស្តីកើតមានដល់នាង សូមនាងអត់ទោសដល់ខ្ញុំ ។

ភិក្ខុនី លុះរួចអំពីបុរសជាអ្នកលេងនោះហើយ ក៏បានទៅកាន់សំណាក់ នៃព្រះពុទ្ធដ៏ប្រសើរ ចក្ខុក៏កើតឡើងដូចពីដើម ព្រោះបានឃើញ នូវមហាបុរិសលក្ខណៈ ដែលកើតអំពីបុញ្ញសម្ភារដ៏ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជីវកម្ពវនំ** បានដល់ ចម្ការស្វាយរបស់ពេទ្យជីវកកោមារភច្ច ។ បទថា **រម្មំ** បានដល់ គួរជាទីត្រេកអរ ។ បានឮថា ចម្ការស្វាយនោះ គួរជាទីត្រេកអរ គួរជាទីរីករាយចិត្តក្រៃលែង ព្រោះដល់ព្រមដោយភូមិភាគនិងដល់ព្រមដោយម្លប់និងទឹក ដោយអាការដែលដាំទុក ។ បទថា **គច្ឆន្តី** បានដល់ និមន្តចូលទៅកាន់ចម្ការស្វាយ ដើម្បីសម្រាកពេលថ្ងៃ ។ បទថា **សុភំ** បានដល់ ព្រះថេរីដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ធុត្តកោ** បានដល់ បុគ្គលអ្នកលេង ។ បានឮថា បុរសកូនជាងមាសអ្នកមានសម្បត្តិច្រើនម្នាក់ក្នុងក្រុងរាជគ្រឹះ ជាកំលោះរូបស្អាត ជាបុរសអ្នកលេងស្រី ជាអ្នកស្រវឹងត្រាច់ទៅ ជួបព្រះថេរីនោះដែលដើរផ្លូវប្រាសគ្នា កើតចិត្តប្រតិព័ទ្ធ ក៏ឈរពាំងផ្លូវ ដោយហេតុនោះទើបលោកពោលថា **ធុត្តកោ សន្និវារេសិ** អធិប្បាយថា ឃាត់ខ្ញុំមិនឲ្យទៅ ។ បទថា **តមេនំ អព្រវី សុភា** សេចក្តីថា ព្រះនាងសុភាភិក្ខុនីពោលនឹងអ្នកលេងដែលពាំងផ្លូវនោះឯង ក្នុង

សេចក្តីនោះ ព្រះថេរីពោលដល់ខ្លួនឯងប៉ុណ្ណោះ ដូចជានិយាយនឹងអ្នកដទៃថា **គច្ឆន្តិ ភិក្ខុនី សុភំ តមេនំ អព្រវី សុភា** ដូច្នេះ គាថានេះ ព្រះសង្គីតិកាចារ្យពោលទុក ដោយសម្តែងការភ្ជាប់គាថាដែលព្រះថេរីពោលហើយ ។

កាលពោលថា **អព្រវី សុភា** ដូច្នេះហើយ ដើម្បីប្រាប់ថា អ្នកពោលអ្វី ទើបព្រះថេរីពោលថា **កឹ តេ អបរាធិតំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កឹ តេ អបរាធិតំ មយា** សេចក្តីថា ខ្ញុំធ្វើអ្វីខុសចំពោះអ្នក ។ បទថា **យំ មំ ឱវរិយានតិដ្ឋសិ** អធិប្បាយថា ដោយកំហុសឯណា ទើបអ្នករារាំងខ្ញុំដែលកំពុងដើរទៅ គឺហាមនូវការដើរទៅ ការខុសនោះមិនមានឡើយ ព្រះថេរីកាលសម្តែងថា បើអ្នកបដិបត្តិយ៉ាងនេះ ដោយសម្គាល់ថា ខ្ញុំជាស្រី ការបដិបត្តិយ៉ាងនេះ ក៏មិនសមគួរ ទើបពោលថា **ន ហិ បព្វជិតាយ អាវុសោ បុរិសោ សម្ផុសនាយ កប្បតិ** សេចក្តីថា នែកម្មារបុត្តទំនៀមរបស់លោកសន្និវាស បុរសមិនគួរប៉ះពាល់អ្នកបួស សូម្បីជាប្រុសឡើយ ឯស្រីអ្នកបួសមិនគួរប៉ះពាល់សូម្បីត្រឹមតែតិរច្ឆានឈ្មោល ការពាល់ត្រូវបុរសលើកទុកសិនចុះ ស្រីអ្នកបួសមិនគួរពាល់ត្រូវបុរសសូម្បីរបស់ដែលជាប់ដោយកាយដោយរបស់ដែលជាប់ដោយកាយ ដោយអំណាចរាគៈឡើយ ។

ដោយហេតុនោះ ព្រះថេរីក៏ពោលថា **គរុកេ មម សត្ថុសាសនេ** ជាដើម សេចក្តីថា សិក្ខាទាំងឡាយណា ដែលព្រះសុគតសម្ពុទ្ធ ទ្រង់សម្តែងបញ្ញត្តចំពោះភិក្ខុនីទាំងឡាយ ក្នុងសាសនារបស់ព្រះសាស្តានៃយើងដែលគួរគោរព គឺគប្បីធ្វើឲ្យធ្ងន់ដូចឆត្រថ្ម ហេតុអ្វីទើបអ្នកឈររារាំងខ្ញុំដែលមានបទដ៏បរិសុទ្ធ

គឺមានចំណែកនៃកុសល ដែលបរិសុទ្ធដោយសិក្ខាទាំងនោះ ដែលឈ្មោះថា **អនង្គណំ** ព្រោះមិនមានកិលេសដូចទីទួល មានរាគៈជាដើម ដោយប្រការទាំងពួង ដែលកំពុងដើរទៅយ៉ាងនេះ ។

បទថា **អាវិលចិត្តោ** សេចក្តីថា ព្រោះហេតុអ្វី អ្នកមានចិត្តល្អក់កករ ដោយអំណាចវិតក្កៈ មានកាមវិតក្កជាដើម ដែលធ្វើនូវការល្អក់នៃចិត្ត ទើបឈរភាំងខ្ញុំ ដែលជាអ្នកមានចិត្តមិនល្អក់ ព្រោះមិនមានការល្អក់នោះ អ្នកជាបុគ្គលមានកិលេសដូចធូលី ដោយអំណាចកិលេសដូចធូលី គឺរាគៈជាដើម អ្នកមានកិលេសដូចទីទួល ឈរភាំងខ្ញុំ ដែលឈ្មោះថា ប្រាសចាកកិលេសដូចធូលី ជាអ្នកមិនមានកិលេសដូចទីទួល ឈ្មោះថា ជាអ្នកមានចិត្តរួចផុតហើយ ព្រោះរួចផុតក្នុងទីទាំងពួង គឺក្នុងបញ្ចក្ខន្ធ ។

កាលព្រះថេរីពោលយ៉ាងនេះហើយ បុរសអ្នកលេង កាលប្រាប់បំណងរបស់ខ្លួន ទើបពោល ១០ គាថា ដោយន័យជាដើមថា **ទហរា ច** ជាដើម។

បណ្តាបទទាំងនោះ បទថា **ទហរា** បានដល់ វ័យក្មេង គឺនៅក្នុងបឋមវ័យ ។ បទថា **អបាបិកា ចសិ** បានដល់ មានរូបមិនអាក្រក់ អធិប្បាយថា មានរូបស្អាតក្រៃលែងផងដែរ ។ បទថា **កឹ តេ បព្វជ្ជា ករិស្សតិ** បុរសអ្នកលេងពោលដោយបំណងថា បព្វជ្ជានឹងធ្វើអ្វីដល់នាង ដែលនៅក្នុងបឋមវ័យ មានរូបស្អាតយ៉ាងនេះ ស្រីចាស់ ឬស្រីរូបអាក្រក់ទេតើ ទើបគួរបួស ។ បទថា **និក្ខិប** បានដល់ ចូរលះបង់ ។ បាលីថា **ឱក្ខិបា** ក៏មាន សេចក្តីថា ចូរដោះ ។

បទថា **មធុរំ** បានដល់ ស្អាត អធិប្បាយថា មានក្លិនក្រអូប ។ បទថា **បវន្តិ** ប្រែថា ជះក្លិន ។ បទថា **សព្វសោ** គឺដោយជុំវិញ ។ បទថា **កុសុមរជេន សមុដ្ឋិតា ទុមា** សេចក្តីថា ដើមឈើទាំងនេះដូចជាកើតឯង ដោយលម្អងផ្ការបស់ខ្លួនឯង ពោលគឺកេសរផ្កាកើតឡើងដោយខ្យល់បក់ផាត់តិចៗ ជះក្លិនក្រអូបទូទៅ ។ បទថា **បឋមវសន្តោ សុខោ ឧតុ** សេចក្តីថា ខែនេះជាខែដំបូងនៃវស្សានរដូវ មានសម្ផស្សស្រួលបាយ កំពុងប្រព្រឹត្តទៅ ។

បទថា **កុសុមិតសិខរា** បានដល់ មានត្រួយចេញផ្ការីកល្អហើយ ។ បទថា **អភិគជ្ជន្តិវ មាលុតេរិតា** បានដល់ ត្រូវខ្យល់បក់ផាត់ ហាក់ដូចបន្លឺនូវសំឡេង ។ បទថា **យទិ ឯកកោ វនមោគហិស្សសិ** បុរសអ្នកលេងពោលយ៉ាងនេះ ព្រោះឃើញដល់សេចក្តីសុខរបស់ខ្លួនថា បើនាងចូលទៅក្នុងព្រៃម្នាក់ឯង ហេតុអ្វីទើបនាងត្រេកអរក្នុងព្រៃនោះដែលទាក់ទងនឹងខ្លួនថា បើនាងចូលព្រៃម្នាក់ឯង នាងត្រេកអរក្នុងព្រៃនោះ ដូចម្តេចកើត ។

បទថា **វាឡមិគសង្ឃសេវិតំ** បានដល់ ដែលពពួកសត្វសាហាវ មានរាជសីហ៍និងខ្លាធំជាដើម ចូលទៅអាស្រ័យក្នុងទីនោះ ។ បទថា **កុញ្ជរមត្តករេណុលោឡិតំ** បានដល់ ទឹកដីដែលដេរដាសដោយដីអស្សុតរចុះប្រេង និងដីរញីរញៃបៀតបៀនធ្វើឲ្យម្រឹគភិតភ័យ ដោយការកាច់មែកឈើនិងជាន់បំបាក់គុម្ពឈើជាដើម ។ ទោះបីមិនមានហេតុបែបនេះ ក្នុងព្រៃនោះសព្វកាលក៏ពិតតែឈ្មោះថា ព្រៃក៏ត្រូវតែជាយ៉ាងនេះ ព្រោះហេតុនោះ បុរសអ្នកលេងបំណងឲ្យព្រះថេរីភ័យខ្លាច ទើបពោលយ៉ាងនេះ ។ បទថា **រហិតំ** បានដល់

វៀរចាកជន គឺប្រាសចាកពួកមនុស្ស ។ បទថា **ភីសនកំ** បានដល់ គួរកើតភ័យ ។

បទថា **តបនីយកតាវ ជីតិកា** សេចក្ដីថា នាងត្រាច់ទៅដូចតុក្កតាដែលជាងធ្វើអំពីមាស គឺដូចរូបបដិមាមាសដែលជាងយន្តអ្នកឈ្លាសតាក់តែងដោយការប្រកបយន្ត ដើរទៅដើរមក ពេលនេះនាងដើរទៅក្នុងទីផ្សេង ៗ ដូចគ្នា ។ បទថា **ចិត្តលតេវ អច្ឆរា** បានដល់ ដូចទេពអប្សរក្នុងសួនឈ្មោះថា ចិត្តលតា ។ បទថា **កាសិកសុមុខេហិ** បានដល់ សាច់ម៉ដ្ឋក្រៃលែង ដែលកើតក្នុងដែនកាសី ។ បទថា **វគ្គុភិ** បានដល់ ដែលរលោងល្អ ។ បទថា **សោភសី សុវសនេហិ នូបមេ** បានដល់ នាងជាស្រីស្អាត មិនមានគូប្រៀប គឺវៀរជនដែលប្រៀបបាន ដោយសំពត់ស្លៀក សំពត់ដណ្ដប់ ។ បុរសអ្នកលេងពោលនិងព្រះថេរី ហាក់ដូចជាប្រព្រឹត្តទៅបានពិតតាមដែលគេគិតថា បើនាងធ្វើតាមខ្ញុំ នាងនិងស្អាតក្រៃលែងឡើង ។

បទថា **អហំ តវ វសានុគោ សិយំ** សេចក្ដីថា ខ្ញុំរមែងនៅក្រោមអំណាចរបស់នាងនឹងធ្វើគ្រប់កិច្ចការ ។ បទថា **យទិ វិហរេមសេ កាននន្តរេ** សេចក្ដីថា បើយើងទាំង ២ ត្រេកត្រអាលនឹងគ្នាកណ្ដាលព្រៃ ។ បុរសអ្នកលេងប្រាប់ហេតុផល ក្នុងកាលដែលព្រះថេរីធ្វើតាមថា ព្រោះបុគ្គលដែលគួរស្រឡាញ់ជាងនាងសម្រាប់ខ្ញុំមិនមានឡើយ ។ បទថា **ចាណោ** បានដល់ សត្វ អធិប្បាយថា សត្វដទៃណាដែលគួរស្រឡាញ់ជាងនាង សម្រាប់ខ្ញុំមិនមានឡើយ ។ ន័យម្យ៉ាងទៀត បទថា **ចាណោ** បុរសអ្នកលេង ពោលសំដៅ

ដល់ជីវិតរបស់ខ្លួន អធិប្បាយថា ខ្ញុំមិនបានស្រឡាញ់ជីវិតខ្លួនឯង ក្រៃលែង ជាងនាងឡើយ ។ បទថា **កិន្នរិមន្ទលោចនេ** ប្រែថា មានភ្នែកដូចកិន្នរ ។ បទថា **យទិ មេ វចនំ ករិស្សសិ សុខិតា ឯហិ អគារមាវស** សេចក្តីថា បើនាងជឿខ្ញុំ ក៏ចូរលះបង់នូវការអង្គុយម្នាក់ឯង ការដេកម្នាក់ឯង ដែលជាទុក្ខ ក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មកយើងនឹងសេពសុខដោយកាមសម្បត្តិ នៅគ្រប់គ្រងផ្ទះរួមគ្នា ។ អាចារ្យពួកខ្លះពោលថា **សុខិតា ហោតិ អគារមាវសន្តិ** អត្ថរបស់អាចារ្យពួកនោះថា នាងនឹងជួបសុខ របស់មនុស្សទាំងឡាយដែល នៅគ្រប់គ្រងផ្ទះរួមគ្នា ។

បទថា **បាសាទនិវាតវាសិនី** បានដល់ នៅក្នុងប្រាសាទដែលប្រាស ចាកខ្យល់ ។ បាលីថា **បាសាទវិមានវាសិនី** ក៏មាន សេចក្តីថា នៅក្នុង ប្រាសាទដូចវិមាន ។ បទថា **បរិកម្មំ** បានដល់ ការខ្វល់ខ្វាយ ។ បទថា **ធារយ** បានដល់ ចូរគ្រប់គ្រង គឺចូរស្លៀក និងចូរដណ្តប់ ។ បទថា **អភិរោបេហិ** បានដល់ ឬចូរតាក់តែង អធិប្បាយថា ចូរប្រដាប់សរីរៈដោយ តាក់តែងគ្រឿងអលង្ការ ។ បទថា **មាលវណ្ណកំ** បានដល់ កម្រងផ្កា និង គ្រឿងក្រអូបគ្រឿងលាប ។ បទថា **កញ្ចនមណិមុត្តកំ** បានដល់ ប្រកប ដោយមាសនិងកែវមណី និងកែវមុក្តា អធិប្បាយថា តាក់តែងដោយកែវ មណីនិងកែវមុក្តា ដែលរំលេចដោយមាស ។ បទថា **ពហុំ** បានដល់ មាន ច្រើនប្រការ មានគ្រឿងប្រដាប់ដៃជាដើម ។ បទថា **វិវិធំ** បានដល់ ច្រើន យ៉ាង ដោយពណ៌សម្បុរច្រើនប្រភេទ ។

បទថា **សុធោតរជបច្ឆទំ** បានដល់ មានសំពត់បិទបាំងដែលប្រាសចាកធូលីហើយ ព្រោះបោកគក់ល្អហើយ ។ បទថា **សុភំ** បានដល់ ស្រស់ស្អាត ។ បទថា **គោនកត្ថលិកសន្ថតំ** បានដល់ ក្រាលដោយសំពត់កោជវៈពណ៌ខ្មៅមានរោមវែង និងសំពត់សំឡីដែលញាត់ដោយរោមហង្សជាដើម ។ បទថា **នវំ** បានដល់ ថ្មីស្អាត ។ បទថា **មហារហំ** បានដល់ មានតម្លៃច្រើន ។ បទថា **ចន្ទនមណ្ឌិតសារគន្ធិកំ** បានដល់ មានក្លិនក្រអូបឈ្ងុយ ព្រោះតាក់តែងដោយខ្លឹមចន្ទន៍ មានចន្ទន៍ក្រហមជាដើម អធិប្បាយថា ចូរនាងឡើងកាន់ដំណេកបែបនោះ ហើយចូរដេកនិងអង្គុយតាមសប្បាយ ។

ច សព្ទ ក្នុងបទថា **ឧប្បលំ ចុទកា សមុគ្គតំ** ត្រឹមតែជានិបាត សេចក្តីថា ផ្កាឧប្បលដែលផុសឡើងផុតទឹក តាំងនៅលើទឹក រីកហើយ ។ បទថា **យថា តំ អមនុស្សសេវិតំ** សេចក្តីថា ផ្កាឧប្បលនោះ មិនមានមនុស្សសេពគឺបុគ្គលណាមួយ មិនបានឃើញហើយ ព្រោះកើតក្នុងស្រះបោក្ខរណីដែលអារក្ខទឹកហួងហែងហើយ ។ បទថា **ឯវំ ត្វំ ព្រហ្មចារិនិ** បានដល់ នាងក៏ជាព្រហ្មចារី ដូចផ្កាឧប្បលរីកល្អនោះ ដូច្នោះដូចគ្នា ។ បទថា **សកេសំកេសុ** សេចក្តីថា កាលសរីរៈរបស់នាង គឺចំណែករាងកាយរបស់ខ្លួន ដែលបុគ្គលណាមួយមិនបានឃើញ នាងក៏នឹងដល់នូវជរា គឺការចាស់គ្រាំគ្រាទៅទទេៗ ។

កាលបុរសអ្នកលេង ប្រកាសបំណងរបស់ខ្លួនយ៉ាងនេះហើយ ព្រះថេរីកាលកាត់នូវបំណងនោះក្នុងរឿងនេះ ដោយការចង្អុលបង្ហាញដល់សភាវៈពិតនៃរាងកាយ ទើបពោលគាថាថា **កឹ តេ ៩៨** សេចក្តីថា គាថានោះ មានសេច

ក្តីថា នៃកូនជាងមាស ក្នុងសរីរៈដែលមិនស្អាតនេះ គឺដែលសន្មតថាកាយនេះ ពេញទៅដោយសាកសព មានសក់ជាដើម ត្រូវបែកធ្លាយដោយចំណែកមួយជាធម្មតា ចម្រើនតែព្រៃស្មសាន អ្នកយល់ដូចម្តេច បានជាពោលថាជាសារៈ ព្រោះឃើញវត្ថុណា អ្នកយល់ខុស គឺខ្វះនូវការគិត ក្នុងអារម្មណ៍ណាមួយ ឬខ្វះនូវការគិតដែលល្អ ឃើញថាជាសុខ ក្នុងរាងកាយដែលមិនស្អាតនេះ ចូរអ្នកប្រាប់វត្ថុនោះដល់ខ្ញុំ ។

បុរសអ្នកលេងស្តាប់ពាក្យយ៉ាងនោះហើយ ទោះបីដឹងថា រូបរបស់ព្រះថេរីស្អាតគ្រប់ចំណែក តែដើម្បីប្រាប់ដល់វត្ថុដែលធ្វើឲ្យខ្លួនវង្វេង មានចិត្តប្រតិព័ទ្ធ តាំងអំពីឃើញដំបូង ទើបពោលថា **អក្ខីនិ ច តុរិយារិវ** ជាដើម សេចក្តីពិត ព្រះថេរីនេះ ជាអ្នកមានឥន្ទ្រិយស្ងប់ ព្រោះជាអ្នកសង្រួមល្អហើយ តែព្រោះហេតុដែលអ្នកលេងនោះត្រូវកន្លងដោយអាកប្បកិរិយា មានការស្អាតនៃចរិតជាដើម ធ្វើឲ្យយល់ខុស ដែលកើតអំពីភ្នែករបស់ព្រះថេរីនោះ ដែលប្រកបដោយបសាទទាំង ៥ ដែលផូរផង់ដែលសម្រេចដោយអានុភាពនៃកម្មដែលប្រជុំចុះ ស្រស់ថ្លា ស្រទន់ និងស្ងប់ ព្រោះហេតុនោះ ទើបតម្រេកដោយការយល់ខុសរបស់អ្នកលេងនោះបន្ថែមក្រៃលែងឡើង ។ បទថា **អក្ខីនិ ច តុរិយារិវ** នោះ សត្វទ្រាយ លោកហៅថា **តុរិ** ។ **ច** សព្ទ ត្រឹមតែជានិបាត អធិប្បាយថា ភ្នែកទាំង ២ របស់នាង ហាក់បីដូចជាភ្នែករបស់កូនទ្រាយ ។ បាលីថា **កោរិយារិវ** ដូច្នេះ ក៏មាន លោកអធិប្បាយថា ហាក់ដូចកែវភ្នែករបស់មេមាន់ ដែលភ័យកិត ។ បទថា **កិន្នរិយារិវ បព្វតន្តរេ**

សេចក្តីថា កែវភ្នែករបស់នាង ដូចកែវភ្នែករបស់កិន្នរីដែលត្រាច់ទៅកាន់ភ្នំ ។ បទថា **តវ មេ ឧយនានិ ឧក្ខិយ** សេចក្តីថា ព្រោះឃើញនូវភ្នែករបស់នាងមានគុណវិសេសដែលពោលមកហើយ ទើបការត្រេកត្រអាលក្នុងកាមកម្រើកដល់ខ្ញុំក្រៃលែង គឺលិចលង់ ។

បទថា **ឧប្បលសិខរោបមានិ តេ** បានដល់ ភ្នែករបស់នាង ដូចចុងផ្កាឧប្បលក្រហម ។ បទថា **វិមលេ** បានដល់ មិនមានមន្ទិល ។ បទថា **ហាដកសន្និភេ** បានដល់ មុខរបស់នាង ដូចដុំបារមាស ប្រកបសេចក្តីថា ព្រោះឃើញភ្នែកទាំង ២ ។

បទថា **អបិ ទូរគតា** បានដល់ ទៅកាន់ទីឆ្ងាយ ។ បទថា **សរម្ហសេ** សេចក្តីថា ខ្ញុំមិនគិតដល់អ្វីដទៃឡើយ គិតដល់តែភ្នែកទាំងគូ របស់នាងប៉ុណ្ណោះ ។ បទថា **អាយតបម្ហេ** បានដល់ រោមភ្នែកវែង ។ បទថា **វិសុទ្ធទស្សនេ** បានដល់ កែវភ្នែកដែលមិនមានមន្ទិល ។ បទថា **ឧ ហិ មត្ថិ តយា បិយត្តរោ ឧយនា** សេចក្តីថា ខ្ញុំមិនមានអ្វីដទៃដែលជាទីស្រឡាញ់ជាជាងភ្នែករបស់នាង ព្រោះពាក្យថា **តយា** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ។

ព្រះថេរីកាលផ្លាស់ប្តូរសេចក្តីប្រាថ្នារបស់បុរសនោះ ដែលរវើរវាយដល់វត្ថុនោះៗដូចមនុស្សឆ្កួត ព្រោះលម្អរបស់ចក្ខុ ដូច្នេះ ទើបពោល ១២ គាថាដោយន័យថា **អបថេន** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អបថេន បយាតុមិច្ឆសិ** ប្រកបសេចក្តីថា អ្នកជាបុត្តជាងមាស កាលស្ត្រីដទៃមានហេតុអ្វី អ្នកត្រូវការ គឺប្រាថ្នាខ្ញុំដែលជាពុទ្ធបុត្ត គឺជាធីតាដែលកើតអំពីទ្រូង

របស់ព្រះពុទ្ធដ៏មានព្រះភាគ អ្នកកាលផ្លូវត្រង់ដ៏ក្សេមមាន ឈ្មោះថា ប្រាថ្នានឹងដើរ គឺបំណងនឹងដើរផ្លូវខុស គឺតាមផ្លូវខុស ដែលមានភ័យ រពាំងដោយបន្ទា ឈ្មោះថា ស្វែងរកព្រះចន្ទមកធ្វើជាល្បែង គឺបំណងនឹងធ្វើព្រះចន្ទឲ្យជារបស់លេង ។ ឈ្មោះថា ប្រាថ្នាដើម្បីលោតឡើងកាន់ភ្នំសិនេរុ គឺបំណងលោតឡើងលើភ្នំសិនេរុ ដែលមានកម្ពស់ ៨៤០០០ យោជន៍ ហើយឈរក្នុងកាលតមក អ្នកប្រាថ្នាខ្ញុំដែលជាពុទ្ធបុត្ត អ្នកនឹងមានសភាពដូចពោលមកហើយ ។

ឥឡូវនេះ ដើម្បីសម្តែងថា អ្នកមិននៅក្នុងវិស័យ និងដើម្បីសម្តែងថា ការប្រាថ្នារបស់អ្នក នាំមកត្រឹមតែការចង្អៀតចង្អល់ ទើបព្រះថេរីពោលថា **នត្ថិ** ជាដើម ។ បណ្តាបទទាំងនោះបទថា **រាគោ យត្ថបិ ទានិ មេ សិយា** សេចក្តីថា ឥឡូវនេះ រាគៈរបស់ខ្ញុំ គប្បីមាន គប្បីកើតក្នុងអារម្មណ៍ណា អារម្មណ៍នោះ មិនមានឡើយក្នុងលោកព្រមទាំងទេវលោក ។ បទថា **នបិ នំ ជានាមិ កីទិសោ** សេចក្តីថា ខ្ញុំមិនស្គាល់រាគៈនោះថាដូចម្តេច ។ ពាក្យថា **អថ** ក្នុងពាក្យថា **អថ មគ្គេន ហតោ សមូលកោ** ត្រឹមតែជានិបាត ។ រាគៈមួយអន្លើដោយឫសគល់ ដែលហៅថាអយោនិសោមនសិការ ខ្ញុំកម្ចាត់ គឺដកបានហើយដោយអរិយមគ្គ ។

បទថា **ឥង្គាលកុយា** បានដល់ ចាករណ្តៅរងើកភ្លើង ។ បទថា **ឧជ្ឈិ-តោ** បានដល់ ដូចត្រូវខ្យល់បក់ទៅ អធិប្បាយថា ដូចបុគ្គលណាមួយក្តិះនូវកំញមចេញអំពីជើងក្រាន ។ បទថា **វិសបត្តោរិវ** បានដល់ ដូចភាជនៈ

ដែលដាក់ថ្នាំពិស ។ បទថា **អគ្គិតោ ករតោ** សេចក្ដីថា ធ្វើឲ្យឆ្ងាយចាក ភ្លើង គឺរងើកភ្លើង អធិប្បាយថា នាំចេញ គឺទម្លាយបង់មិនឲ្យសេសសល់ ត្រឹមតែសេសនៃថ្នាំពិស ។

បទថា **យស្សា សិយា អបច្ចវេក្ខិតំ** សេចក្ដីថា ខន្ធបញ្ចកៈនេះ បើស្រី ណាមិនពិចារណា មិនកំណត់ដឹងហើយដោយញាណ ។ បទថា **សត្ថា វា អនុសាសិតោ សិយា** សេចក្ដីថា ស្រីណាដែលព្រះសាស្ដាទ្រង់មិនប្រៀន ប្រដៅ ព្រោះមិនឃើញធម៌ ។ បទថា **តំ កាមិសិកំ បលោភយ** សេចក្ដី ថា អ្នកចូរលួងលោមគឺចូរទៅរកស្រីបែបនោះ ដែលមិនពិចារណាសង្ខារមិន ពិចារណាលោកុត្តរធម៌ ដោយកាមទាំងឡាយចុះ ។ បទថា **ជានន្តី សោ ឥមំ វិហាញ្ញសិ** សេចក្ដីថា អ្នកកុំលំបាក គឺមកទទួលទុក្ខ ព្រោះសុភាភិក្ខុនី នេះ ជាអ្នកដឹងនូវបវត្តិ ( ទុក្ខ ) និងនិវត្តិ ( ការរំលត់ទុក្ខ ) តាមសេច ក្ដីពិត គឺអ្នកត្រាស់ដឹងនូវសច្ចៈទាំងក្នុងបច្ចុប្បន្ននិងក្នុងអនាគត ។

ឥឡូវនេះ ព្រះថេរីកាលសម្ដែងភាពដែលបុរសនោះ ដល់នូវការចង្អៀត ចង្អល់ ដោយការចង្អុលនូវហេតុផលឲ្យជ្រាប ទើបពោលថា **មយ្ហំ ហិ** ជា ដើម ។

បណ្ដាបទទាំងនោះ បទថា **ហិ** ត្រឹមតែជានិបាត ប្រើក្នុងអត្ថថា ហេតុ បទថា **អក្កុដ្ឋវន្ទិតេ** បានដល់ ក្នុងការជេរ និងការថ្វាយបង្គំ ។ បទថា **សុខ-ទុក្ខេ** បានដល់ ក្នុងសុខនិងទុក្ខ ឬព្រោះជួបនូវអារម្មណ៍ដែលគួរប្រាថ្នា និង មិនគួរប្រាថ្នា ។ បទថា **សតី ឧបដ្ឋិតា** បានដល់ សតិដែលប្រកបដោយ

ការពិចារណាមាំទាំសព្វកាល ។ បទថា **សង្ខតមសុភន្តិ ជានិយ** បានដល់ ដឹងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាសង្ខារ ថាមិនស្អាតព្រោះជាទីហូរចេញនៃកិលេសនិងរបស់មិនស្អាត ។ បទថា **សព្វត្ថេរ** សេចក្តីថា ចិត្តរបស់ខ្ញុំមិនជាប់នៅក្នុងភព ៣ និងភពទាំងអស់ ដោយកិលេសជាគ្រឿងបូកលាប គឺតណ្ហាជាដើម ។

បទថា **មគ្គដ្ឋង្គិកយានយាយិនី** បានដល់ ប្រព្រឹត្តទៅ គឺចូលទៅកាន់អមតបុរី ដោយយានដែលជាអរិយៈ ពោលគឺមគ្គប្រកបដោយអង្គ ៨ ។ បទថា **ឧទ្ធដសល្លា** បានដល់ មានកិលេសដូចព្រួញ គឺរាគៈជាដើម ដែលដកចេញហើយចាកសន្តានរបស់ខ្លួន ។

បទថា **សុចិត្តិតា** បានដល់ ដែលតាក់តែង គឺធ្វើឲ្យល្អដោយល្អ ដោយអាការ ដោយដៃជើង និងមុខជាដើម ។ បទថា **សោម្ភា** បានដល់ រូបតុក្កតា ។ បទថា **ទារុកបិល្លកានិ វា** បានដល់ រូបដែលធ្វើដោយកំណាត់ឈើជាដើម ។ បទថា **តន្តីហិ** បានដល់ សរសៃនិងអំបោះ ។ បទថា **ខីល–កេហិ** បានដល់ កំណាត់ឈើដែលគេតម្រៀបដើម្បីធ្វើជាដៃ ជើង ខ្នង និងត្រចៀកជាដើម ។ បទថា **វិនិពទ្ធា** បានដល់ ចងដោយអាការៈផ្សេងៗ ។ បទថា **វិវិធំ បនច្ចកា** បានដល់ ធ្វើអាកប្បកិរិយាតាមដែលគេរៀបចំទុកដោយការទាញ និងការបន្ធូរជាដើម ដោយអំបោះយន្តជាដើម ។ ប្រកបសេចក្តីថា ដែលគេឃើញហាក់ដូចជារាំ ។ បទថា **តម្ហុទ្ធដេ តន្តិខីលកេ** សេចក្តីថា អាស្រ័យវត្ថុដែលប្រកបឲ្យវិសេស ដោយការតាក់តែងយ៉ាងល្អ ដែល

មានឈ្មោះថារូប កាលអំបោះនិងឈើដែលគេដកចេញអំពីជំណាប់ ចេញអំពីគ្រឿងចង ធ្វើគ្នានឹងគ្នាឲ្យខ្វះខាត ព្រោះធ្វើឲ្យជាចំណែកៗ ក៏រាត់រាយខ្ចាត់ខ្ចាយ ព្រោះចោលក្នុងទីនោះៗ ។ បទថា **ន វិន្ទេយ្យ ខណ្ឌសោ ករោ** សេចក្តីថា កាលចំណែកនៃស្ពឹករឹតត្រូវធ្វើឲ្យជាចម្រៀកតូចធំ បុគ្គលក៏មិនជួប មិនបានស្ពឹករឹត កាលបើដូច្នោះ បុគ្គលគប្បីតាំងចិត្តក្នុងរូបនោះធ្វើអ្វី អធិប្បាយថា បុគ្គលគប្បីតាំងចិត្ត គឺយកចិត្តទុកដាក់ក្នុងចំណែកប្រកប របស់ស្ពឹករឹតនោះធ្វើអ្វី ឬក្នុងកំណាត់ឈើ ក្នុងដុំដីជាដើមធ្វើអ្វី សញ្ញានោះក៏កប់នៅក្នុងចំណែកដែលជាវិសង្ខារ ( មិនមានចិត្ត ) ម្តងម្កាលបាន ។

បទថា **តថូបមា** បានដល់ ដូចរូបនោះ គឺដូចស្ពឹករឹតនោះ ។ បើសួរថា បានដល់អ្វី ទើបព្រះថេរពោលថា **ទេហកានិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ទេហកានិ** បានដល់ អវយវៈនៃរាងកាយ មានដៃ ជើងមុខជាដើម ។ បទថា **មំ** សេចក្តីថា ប្រាកដទាក់ទងជាមួយខ្ញុំ ។ បទថា **តេហិ ធម្មេហិ** បានដល់ ចាកធម៌ទាំងនោះ មានបឋវីធាតុជាដើម និងចក្ខុជាដើម ។ បទថា **វិនា ន វត្តន្តិ** សេចក្តីថា ឈ្មោះថា រាងកាយដែលផុតអំពីធម៌ មានបឋវីធាតុជាដើមដែលតាំងនៅដោយប្រការនោះៗ ក៏មិនមាន ។ បទថា **ធម្មេហិ វិនា ន វត្តន្តិ** សេចក្តីថា រាងកាយវៀរចាកអវយវៈ គឺធម៌ចេញ ក៏មិនប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅមិនបាន ហេតុនោះ បុគ្គលគប្បីតាំងចិត្តក្នុងរាងកាយនោះធ្វើអ្វី អធិប្បាយថា បុគ្គលគប្បីតាំងចិត្ត គឺគប្បីយល់ក្នុងរាងកាយ ឬអវយវៈ មានដៃ ជើងជាដើមថា នៅក្នុងទីណា គឺក្នុងធាតុដី

ជាតុទឹកជាដើម ព្រោះក្នុងភាពជាធម៌ គឺធាតុ ៤ មានបឋវីធាតុជាដើម និង ភាពជាបសាទ ដែលសន្មតថា ជារាងកាយក្តី ដៃ ជើងជាដើមក្តី សត្វក្តី ស្រីក្តី ប្រុសក្តី ហេតុនោះ បុគ្គលណាក៏ដោយដែលដឹងទាន់ ក៏មិនប្រកាន់មាំ ក្នុងរាងកាយនោះ ។

បទថា **យថា ហរិតាលេន មក្ខិតំ អទ្ទស ចិត្តិកំ ភិត្តិយា កតំ** អធិប្បាយថា បុគ្គលគប្បីមើល គប្បីឃើញនូវរូបស្រីដែលវិចិត្រករអ្នកឈ្លាស គូរដោយហរតាល ត្រង់ជញ្ជាំង គឺផាត់ដោយហរតាលនោះឲ្យស្អាត ក្នុងសេចក្តីនេះ មានអធិប្បាយថា សញ្ញាណាដែលកើតឡើងថា ជញ្ជាំងនេះ មានមនុស្សឈរនៅ ឬទេ ព្រោះមានកិរិយា មានការស្ទាប ការគោះ ជាដើម សញ្ញានោះឥតប្រយោជន៍ ព្រោះប្រយោជន៍ពោលគឺភាពជាមនុស្ស មិនមាន ក្នុងរូបស្រីនោះ ។ បុរសនោះមានតែការយល់ខុសក្នុងរូបស្រីនោះ តែម្យ៉ាង ថា ជាមនុស្ស មិនពាល់ត្រូវតាមសេចក្តីពិតក្នុងវត្ថុដែលត្រឹមតែជាគំនូរនៃធម៌ ក៏គប្បីជ្រាបឧបមេយ្យដូចពោលមកនេះ ។

បទថា **មាយំ វិយ អគ្គតោ កតំ** បានដល់ ដូចថ្ងៃបណ្តើរកូនដែល ប្រាកដខាងមុខ ដោយអាការបោកបញ្ឆោត ។ បទថា **សុបិនន្តេវ សុវណ្ណ-ចានបំ** សេចក្តីថា ការយល់សប្តិនោះ ឈ្មោះថា **សុបិនន្ត** គឺហាក់បីដូចមាន ដើមឈើមាសដែលប្រាកដក្នុងការយល់សប្តិនោះ ។ បទថា **ឧបគច្ឆសិ អន្ធ រិត្តកំ** សេចក្តីថា នែអ្នកល្ងង់ខ្លៅ ដូចមនុស្សភ្នែកខ្វាក់ អ្នកនៅចូលទៅ ប្រកាន់មាំក្នុងអត្តភាពដែលទទេ មិនមានសារៈខាងក្នុង ថាដូចមានសារៈ ថា

ទុំះជារបស់អញ ។ បទថា **ជនមជ្ឈេរិវ រុប្បរូបកំ** សេចក្ដីថា ដូចគ្នានឹងអ្នកហិរញ្ញិកសម្ដែងកល ក្នុងកណ្ដាលមហាជន ឲ្យមើលដូចឃើញរបស់ពិត អធិប្បាយថា មិនមានសារៈ ។

បទថា **វដ្ដនិរិវ** ប្រែថា ដូចដុំល័ក្ត ។ បទថា **កោដរោហិតា** បានដល់ តាំងនៅក្នុងរន្ធ គឺក្នុងព្រង់ឈើ ។ បទថា **មជ្ឈេ បុព្ពុឡកា** បានដល់ ដូចពពុះទឹកដែលតាំងឡើងកណ្ដាលកែវភ្នែក ។ បទថា **សអស្សុកា** បានដល់ ប្រកបដោយទឹកភ្នែក ។ បទថា **បីឡកោឡិកា** បានដល់ ពពឹកភ្នែក ។ បទថា **ឃត្ត ជាយតិ** បានដល់ ជះនូវកិ្លនស្អុយ កើតឡើង ត្រង់ចុងសងខាងនៃកែវភ្នែកនោះ ។ ន័យម្យ៉ាងទៀត ពពុះដែលកើតក្នុងភ្នែក ហៅថា **បីឡ-កោឡិកា** ។ បទថា **វិវិធា** បានដល់ ច្រើនយ៉ាង ដោយវង្វង់មូលពណ៌ស និងខៀវ និងកា[illegible]ទាំង ៧ ជាន់ មានពណ៌ក្រហម និងពណ៌លឿងជាដើម ។ បទថា **ចក្កាវិធា** បានដល់ ចំណែកនៃចក្ខុ លក្ខណៈនៃចក្ខុ ព្រោះចក្ខុនោះ មានកលាបៈច្រើនកលាបៈ ។ បទថា **បិណ្ឌិតា** បានដល់ ប្រកបគ្នាឡើង ។

ព្រះថេរីចង្អុលបង្ហាញថា ភ្នែកជារបស់មិនស្អាត និងជារបស់មិនទៀង ព្រោះមិនតាំងមាំ មិនស្ថិតស្ថេរដល់បុរសអ្នកវង្វេងស្រឡាញ់ក្នុងភ្នែកយ៉ាងនេះ កាលចង្អុលបង្ហាញហើយ ព្រះថេរីត្រូវបុរសនោះ ដែលវង្វេងស្រឡាញ់ក្នុងភ្នែក ដើរតាមទៅ ទើបខ្វេះភ្នែករបស់ខ្លួនឲ្យបុរសនោះទៅ ដូចបុរសពួកខ្លះដែលនាំរបស់ជាទីគាប់ចិត្ត ដើរផ្លូវកន្ដារដែលមានចោរ ត្រូវពួកចោរចាប់ទើបឲ្យវត្ថុដែលគាប់ចិត្តនោះទៅ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោល

ថា **ឧប្បាដិយ ចារុទស្សនា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧប្បា-ដិយ** បានដល់ ខ្វេះ គឺទាញចេញអំពីប្រឡង់ភ្នែក ។ បទថា **ចារុទស្សនា** បានដល់ កែវភ្នែកដែលគួរស្រឡាញ់ កែវភ្នែកដែលគួរចាប់ចិត្ត ។ បទថា **ឥច បង្គិត្វា** បានដល់ មិនជាប់ជំពាក់ក្នុងចក្ខុនោះ ។ បទថា **អសង្គមានសា** សេចក្តីថា ព្រះថេរីមានចិត្តមិនជាប់ជំពាក់ក្នុងអារម្មណ៍ណាមួយ ។ បទថា **ហន្ទ តេ ចក្ខុំ** សេចក្តីថា ព្រះនាងសុភាថេរីពោលថា ព្រោះហេតុនោះ គឺព្រោះខ្ញុំឲ្យវត្ថុដែលអ្នកត្រូវការហើយ អញ្ជើញទទួលយកដុំសាច់ស្មោកគ្រោកដែលអ្នកយល់ថាជាភ្នែកទៅចុះ កាលទទួលហើយ ចូរយកចក្ខុដែលប្រកបដោយបសាទ ទៅកាន់ទីដែលអ្នកប្រាថ្នាចុះ ។

បទថា **តស្ស ច វិរមាសិ តាវទេ** សេចក្តីថា ក្នុងរំពេចនោះ គឺក្នុងខណៈដែលព្រះថេរីខ្វេះភ្នែកនោះឯង រាគៈរបស់បុរសអ្នកលេងនោះ ក៏វិនាសទៅ ។ បទថា **តត្ថ** បានដល់ ក្នុងកែវភ្នែក ឬក្នុងព្រះថេរីនោះ ន័យម្យ៉ាងទៀត បទថា **តត្ថ** បានដល់ ក្នុងទីនោះឯង ។ បទថា **ខមាបយិ** ប្រែថា ឲ្យព្រះថេរីអត់ទោសឲ្យហើយ ។ បទថា **សោត្ថិ សិយា ព្រហ្មចារិនិ** នេះ សេចក្តីថា បពិត្រព្រះនាងម្ចាស់ ជាព្រហ្មចារី ជាអ្នកស្វែងរកគុណធំ សូមការមិនមានរោគ មានដល់នាងចុះ ។ បទថា **ន បុនោ ឯទិសកំ ភវិស្សតិ** សេចក្តីថា ខាងមុខអំពីនោះ នឹងមិនមានការប្រព្រឹត្តអនាចារយ៉ាងនេះ អធិប្បាយថា ខ្ញុំនឹងមិនធ្វើឡើយ ។

បទថា **អាសាទិយ** បានដល់ ប៉ះខ្ទប់ ។ បទថា **ឯទិសំ** បានដល់

*ដែលប្រាសចាកកាគៈក្នុងអារម្មណ៍ទាំងពួងបែបនេះ ។ បទថា* **អគ្គី បជ្ជលិតំវ លិត្តិយ** *បានដល់ ដូចឱបទូវដុំភ្លើងដែលឆេះសន្ធោសន្ធៅ ។*

*បទថា* **តតោ** *ប្រែថា បុរសអ្នកលេងស្រីនោះ ។ បទថា* **សា ភិក្ខុនី** *បានដល់ ព្រះនាងសុភាភិក្ខុនីនោះ ។ បទថា* **អគមី ពុទ្ធវរស្ស សន្តិកំ** *បានដល់ ចូលទៅកាន់សម្នាក់ គឺចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ បទថា* **បស្សិយ វរបុញ្ញលក្ខណំ** *បានដល់ ឃើញព្រះមហាបុរិសលក្ខណៈដែលកើតដោយបុញ្ញសម្ភារដ៏ឧត្តម ។ បទថា* **យថា បុរាណកំ** *បានដល់ ភ្នែកបានត្រឡប់ជាប្រក្រតីដូចមុន គឺដូចកាលមុនខ្វះ ។ ពាក្យដែលមិនបានពោលក្នុងចន្លោះៗ ក្នុងរឿងនេះ ក៏ដឹងបានងាយដូចគ្នា ព្រោះមានន័យដូចពោលមកហើយ ។*

*អដ្ឋកថា សុភាជីវកម្ពវនិកាថេរីគាថា ចប់*

*ថេរីគាថា តឹសនិបាត ចប់*

# ថេរីគាថា ចត្តាឡីសនិបាត

## ឥសិទាសីថេរីគាថា

[ ៣៣៧ ] ភិក្ខុនីពីររូប ជាកុលធីតាក្នុងសាក្យត្រកូល ជាអ្នកមានគុណសម្បត្តិ ក្នុងនគរកុសុមបាដលិបុត្ត ដែលជាមណ្ឌលនៃដែនដី ។ បណ្ដាភិក្ខុនីទាំងពីររូបនោះ ភិក្ខុនី ១ រូប ឈ្មោះឥសិទាសី ភិក្ខុនីទី ២ ឈ្មោះពោធិ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកត្រេកអរដោយការរំពឹងក្នុងឈាន ជាពហូសូត មានកិលេសកម្ចាត់បង់ហើយ ។ ភិក្ខុនីទាំងពីររូបនោះ ត្រាច់ទៅបិណ្ឌបាត ហើយធ្វើនូវភត្តកិច្ច លុះលាងបាត្រហើយ អង្គុយជាសុខ ក្នុងទីស្ងាត់ ទើបផ្ដើមនិយាយសម្ដីទាំងឡាយនេះថា ។ ម្នាលនាងម្ចាស់ឈ្មោះ ឥសិទាសី នាងជាស្រីគួរជ្រះថ្លា ទាំងវ័យរបស់នាងក៏មិនទាន់សាបសូន្យ អើចុះនាងឃើញទោសដូចម្ដេច ទើបមកប្រកបខ្វនក្នុងបព្វជ្ជា ។ ឥសិទាសីភិក្ខុនីនោះ ជាអ្នកឈ្លាសវៃក្នុងធម្មទេសនា កាលបើពោធិភិក្ខុនីសាកសួរ ក្នុងហេតុជាប្រយោជន៍យ៉ាងនេះហើយ ក៏បានពោលនូវពាក្យនេះថា ម្នាលនាងពោធិ នាងចូរស្ដាប់តាមដំណើរដែលខ្ញុំបួសចុះ ។

លំដាប់អំពីនេះទៅ គឺជាពាក្យវិស្សជ្ជនា

សេដ្ឋីអ្នកសង្រួមក្នុងសីល ជាបិតារបស់ខ្ញុំ ក្នុងបុរីដ៏ប្រសើរឈ្មោះឧជ្ជេនី ( ក្នុងដែនអវន្តិ ) ខ្ញុំជាធីតាម្នាក់ ជាទីស្រឡាញ់ពេញចិត្ត ជាអ្នកគួរទទួលសេចក្ដីអនុគ្រោះរបស់បិតានោះ ។ លុះចំណេរមកខាងក្រោយ សេដ្ឋីមានត្រកូលដ៏ឧត្ដម មានទ្រព្យច្រើន មកអំពីនគរសាកេត ដណ្ដឹងខ្ញុំ បិតាក៏បាន

ឲ្យខ្ញុំជាកូនប្រសារបស់សេដ្ឋីនោះ ។ ខ្ញុំចូលទៅក្រាបក្បាលថ្វាយបង្គំ នូវជើងម្តាយក្មេកនិងឪពុកក្មេក រាល់ល្ងាចព្រឹក តាមដំណើរដែលមាតាបិតាប្រៀនប្រដៅ ។ ខ្ញុំឃើញនូវអ្នកដណ្តឹងសូម្បីម្នាក់ដែលជាបងប្អូនស្រី បងប្អូនប្រុស ឬជាបរិវាររបស់ស្វាមី ខ្ញុំក៏រលះរលាំងក្រាលអាសនៈ ។ ខ្ញុំអង្គាសផ្គត់ផ្គង់ឲ្យបាយ ទឹក និងបង្អែម ដែលមានក្នុងលំនៅនោះ តាមសមគួរ ដល់វត្ថុដែលគេត្រូវការ ។ ខ្ញុំក្រោកឡើងតាមកាលគួរ ហើយចូលទៅកាន់ផ្ទះរបស់ប្តី ជូតសម្អាតនូវធរណីទ្វារ ( ជាដើម ) និងដៃ ជើង ផ្គងអញ្ជលីចូលទៅរកប្តី ។ ខ្ញុំយកស្និតសក់ ម្សៅសម្រាប់លាបមុខ ថ្នាំសម្រាប់បន្តក់ភ្នែក និងកញ្ចក់ស្អិតស្អាងឲ្យប្តីដោយខ្លួនឯង ហាក់ដូចជា ( វណ្ណទាសី ) អ្នកធ្វើនូវការបម្រើ ។ ខ្ញុំដាំបាយខ្លួនឯង លាងភាជន៍ខ្លួនឯង បម្រើកស្តា ដូចជាមាតាថ្នមកូនខ្ចី ។ តែកស្តា តែងខឹងសម្បារនឹងខ្ញុំ ដែលជាស្ត្រីបម្រើបាយ គ្មានស្ត្រីណាលើសជាស្ត្រីធ្វើការ ( គ្រប់យ៉ាង ) ជាស្ត្រីមិនមានសេចក្តីប្រកាន់ មានសេចក្តីព្យាយាម មិនខ្ជិលប្រអូស មានមារយាទយ៉ាងនេះ ។ ស្វាមីនោះ និយាយនឹងមាតាបិតារបស់គេថា ខ្ញុំសូមលា ( អ្នកម្តាយលោកឪពុក ) ទៅ ( ក្នុងទីណាមួយ ) ( ព្រោះ ) ខ្ញុំមិនអាចនៅរួមគ្នាក្នុងផ្ទះមួយ ជាមួយនឹងនាងឥសិទាសីឡើយ ។

( មាតាបិតាពោលថា ) នែកូន កុំពោលយ៉ាងនេះឡើយ នាងឥសិទាសី ជាបណ្ឌិតឈ្លាសវៃ ជាស្ត្រីមានសេចក្តីព្យាយាម មិនខ្ជិលប្រអូសទេ ម្នាលកូន ហេតុអ្វី ក៏កូនឯងមិនពេញចិត្ត ។

( កូនពោលថា ) នាងឥសិទាសីមិនបៀតបៀនអ្វីៗដល់ខ្ញុំទេ ប៉ុន្តែខ្ញុំមិនអាចនៅជាមួយនឹងនាងឥសិទាសី ព្រោះថា នាងឥសិទាសី ជាស្រីសម្អប់របស់ខ្ញុំ ខ្ញុំមិនគួរនឹងនៅរួមទេ ខ្ញុំសូមលាទៅហើយ ។

ម្តាយក្មេកនិងឪពុកក្មេក បានស្តាប់ពាក្យកូននោះហើយ សួរខ្ញុំថា នាងធ្វើខុសអ្វីទេ នាងចូរប្រាប់កំហុសដែលនាងធ្វើហើយ នាងចូរដោះស្រាយតាមសេចក្តីពិតមកចុះ ។

( ខ្ញុំក៏ឆ្លើយថា ) ខ្ញុំមិនបានប្រទូស្តអ្វីៗទេ ខ្ញុំមិនបៀតបៀន មិនពោលពាក្យអាក្រក់ ( ដល់គាត់ទេ ) កស្តាស្អប់ខ្ញុំ ឲ្យខ្ញុំអាចធ្វើអ្វីកើត ។ ម្តាយក្មេកនិងឪពុកក្មេកទាំងឡាយនោះ ក៏អាក់អន់ចិត្ត ត្រូវសេចក្តីព្រួយគ្របសង្កត់ ក៏នាំខ្ញុំត្រឡប់ទៅកាន់ផ្ទះបិតាវិញ រក្សានូវកូន ( ដោយគិតថា ) យើងនឹងរកឲ្យបាននូវស្ត្រីមានរូបឆោមដ៏មានសិរី ។ គ្រាក្រោយមក បិតាបានឲ្យខ្ញុំក្នុងផ្ទះនៃត្រកូលទី ២ ជាអ្នកស្តុកស្តម្ភដោយជំនូនពាក់កណ្តាល អំពីជំនូនដែលសេដ្ឋីបានជូនមកខ្ញុំមុននោះ ។ ខ្ញុំបាននៅក្នុងផ្ទះនៃប្តីទី ២ នោះ អស់ ១ ខែ គ្រានោះ គាត់ក៏បណ្តេញខ្ញុំដែលជាស្ត្រីខ្នះខ្នែង បម្រើដូចជាទាសី ជាស្ត្រីមិនប្រទូស្ត មានមារយាទល្អ ។ បិតារបស់ខ្ញុំនិយាយនឹងបុរសអ្នកទូន្មាន ( ចិត្ត ) អ្នកទូន្មាន ( កាយនិងវាចា ) ដែលកំពុងត្រាច់ទៅដើម្បីភិក្ខាថា អ្នកចូរជាកូនប្រសារបស់ខ្ញុំ អ្នកចូរបោះបោលនូវកំណាត់សំពត់និងផ្តាំង ។ ស្វាមីទី ៣ នោះ បាននៅ ( ជាមួយនឹងខ្ញុំ ) អស់បក្ខ ១ ( កន្លះខែ ) ក៏និយាយនឹងបិតាខ្ញុំថា អ្នកចូរឲ្យកំណាត់សំពត់ ផ្តាំង និងអំបែង មកខ្ញុំវិញ ខ្ញុំនឹងត្រាច់

ទៅដើម្បីភិក្ខាទៀត ។ គ្រានោះ បិតាមាតានិងពពួកញាតិទាំងអស់របស់ខ្ញុំ និយាយនឹងបុរសនោះថា អ្នកណា មិនធ្វើតាមអ្នកក្នុងទីនេះឬ អ្នកចូរប្រាប់ហេតុដែលគេធ្វើដល់អ្នកឲ្យឆាប់ ។ បុរសនោះ កាលបើគេពោលយ៉ាងនេះហើយ ក៏ពោលតបថា បើខ្លួនរបស់ខ្ញុំអាចទៅបាន ( ក៏នាងឥសិទាសី ) មិនគួរដល់ខ្ញុំ ( ព្រោះហេតុនោះ ) ខ្ញុំមិននៅជាមួយនាងឥសិទាសីក្នុងផ្ទះមួយជាមួយគ្នាទេ បុរសនោះ កាលបើ ( បិតារបស់ខ្ញុំ ) លះបង់ហើយ ក៏ទៅបាត់ទៅ ចំណែកខាងខ្ញុំ ជាស្ត្រីនៅតែម្នាក់ឯង គិតថា អាត្មាអញនឹងលាមាតាបិតាទៅស្លាប់ឬទៅបួស ។ គ្រានោះ នាងថេរីជាម្ចាស់ឈ្មោះជិនទត្តា ជាអ្នកទ្រទ្រង់នូវវិន័យ ជាពហុស្សូត បរិបូណ៌ដោយសីល កាលត្រាច់ទៅដើម្បីភិក្ខាហារ ក៏បាននិមន្តមកកាន់ត្រកូលនៃបិតា ( ខ្ញុំ ) ។ ខ្ញុំឃើញនាងជិនទត្តាថេរីនោះ ក៏ក្រោកឡើងក្រាលអាសនៈរបស់យើង ប្រគេននាងថេរីនោះ លុះព្រះនាងគង់ហើយ ខ្ញុំក៏ថ្វាយបង្គំនូវព្រះបាទាហើយ ប្រគេនភោជន ។ ខ្ញុំញុំាងជិនទត្តាថេរីឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងបង្អែម ដែលមានក្នុងលំនៅនោះហើយពោលថា បពិត្រព្រះនាងជាម្ចាស់ ខ្ញុំចង់បួស ។ គ្រានោះ បិតាពោលនឹងខ្ញុំថា ម្នាលកូនស្រីតូច នាងចូរប្រព្រឹត្តធម៌នោះ ក្នុងផ្ទះនេះទៅចុះ ចូរញុំាងសមណៈទាំងឡាយផង ព្រាហ្មណ៍ទាំងឡាយផង ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកចុះ ។ លំដាប់នោះ ខ្ញុំក៏ប្រណម្យអញ្ជលី យំពោលនឹងបិតាថា បពិត្របិតា សូមលោកអនុញ្ញាតខ្ញុំ ខ្ញុំនឹងញុំាងបាបកម្មដែល ខ្ញុំធ្វើហើយនោះឲ្យវិនាស ។ គ្រានោះ បិតាពោលនឹងខ្ញុំថា ( ព្រះសម្មាសម្ពុទ្ធ )

ព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ណា នាងចូរបានលុះនូវពោធិញ្ញាណនិងអគ្គធម៌និងព្រះនិព្វាននោះចុះ ។ ខ្ញុំថ្វាយបង្គំលាបិតាមាតានិងពពួកនៃញាតិទាំងអស់ ហើយបួសបាន ៧ ថ្ងៃ ក៏សម្រេចវិជ្ជាបី ។ ខ្ញុំដឹងជាតិរបស់ខ្លួនបាន ៧ ជាតិ ផលវិបាកនេះរបស់កម្មណា ខ្ញុំនឹងប្រាប់នូវកម្មនោះដល់នាង នាងចូរមានចិត្តតែមួយ ចាំផ្ទៀងស្តាប់នូវកម្មនោះ ដូចតទៅនេះ ខ្ញុំជាជាងមាស មានទ្រព្យច្រើនក្នុងនគរឈ្មោះ ឯកកច្ឆៈ ខ្ញុំនោះជាមនុស្សស្រវឹង ព្រោះការស្រវឹងវ័យ បានប្រព្រឹត្តសេពសម្ភពនឹងប្រពន្ធបុគ្គលដទៃ ។ ខ្ញុំនោះ លុះឃ្លាតចាកអត្តភាពនោះហើយ ក៏ឆេះរោលរាលក្នុងនរកអស់កាលយូរ លុះរួចចាកនរកនោះហើយ មកចាប់បដិសន្ធិក្នុងផ្ទៃនៃមេស្វា ។ ស្វាឈ្មោលធំជាម្ចាស់នៃហ្វូង ខាំផ្តាច់នូវជាតកម្ម គឺអង្គជាត ( របស់ខ្ញុំ ) ដែលទើបនឹងកើតបាន ៧ ថ្ងៃ នុ៎ះជាផលនៃកម្មរបស់ខ្ញុំនោះ ដែលគប់រកនូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំនោះធ្វើមរណកាលច្យុតចាកកំណើតនៃស្វានោះហើយ ក៏ចាប់បដិសន្ធិក្នុងផ្ទៃនៃមេពពែខ្វាក់ផង ខ្ចកផង ក្នុងដែននៃស្តេចសិន្ធវៈ ។ ខ្ញុំត្រូវគេព្រនាក់កូនក្មេងអស់ ១២ ឆ្នាំ ត្រូវគេក្រៀវ ត្រូវដង្កូវបៀតបៀន ឈឺចាប់ ព្រោះតែអំពើដែលខ្ញុំសេពនូវប្រពន្ធរបស់បុគ្គលដទៃ ។ ខ្ញុំនោះ ច្យុតចាកកំណើតនៃពពែនោះហើយ ក៏កើតជាកូនគោ អំពីមេគោរបស់ឈ្មួញគោបាន ១២ ខែ មានរោមក្រហម ដូចជាជ្រលក់ល័ក្ត ហើយត្រូវគេក្រៀវ ។ ខ្ញុំតែងទាញនូវនង្គ័លនិងរទេះ ខ្វាក់ ខ្ចក ឈឺ ព្រោះតែខ្ញុំសេពនូវប្រពន្ធរបស់បុគ្គលដទៃ ។ ខ្ញុំនោះ ជាសត្វច្យុតចាកកំណើតនៃគោ

នោះហើយ ក៏កើតក្នុងផ្ទៃនៃទាសីក្នុងផ្ទះក្បែរថ្នល់មិនប្រាកដជាស្រី មិនប្រាកដជាប្រុស ( ឡើយ ) ព្រោះតែខ្ញុំសេពនូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំស្លាប់ក្នុងអាយុ ៣០ ឆ្នាំ ហើយក៏កើតជាទារិកាក្នុងត្រកូលនៃអ្នករទេះ ដែលជាត្រកូលកំព្រា គ្មានភោគសម្បត្តិ ត្រូវបុរសជាម្ចាស់ទ្រព្យរឹបជាន់ច្រើន ។ កាលការប្រាក់ចម្រើនច្រើនឡើងហើយ នាយឈ្មួញរទេះ ក៏អូសទាញខ្ញុំ អំពីផ្ទះនៃត្រកូលដែលកំពុងយំខ្សឹកខ្សួល ។ គ្រានោះ បុត្តរបស់ឈ្មួញរទេះនោះ ឈ្មោះគិរិទាសៈ បានឃើញខ្ញុំជាស្ត្រីនៅក្រមុំ មានវ័យចម្រើន ក្នុងឆ្នាំជាគម្រប់ ១៦ ក៏ហួងហែងទុក ( ក្នុងផ្ទះរបស់ខ្លួន ) ។ ប្រពន្ធដទៃរបស់គិរិទាសៈ ជាស្ត្រីមានសីលផង មានគុណផង ជាស្ត្រីប្រព្រឹត្តតាមភស្តា ខ្ញុំក៏បានធ្វើការស្អប់នូវប្រពន្ធរបស់គាត់ ។ ប្តីទាំងឡាយលះលែងខ្ញុំ ដែលជាអ្នកខ្នះខ្នែងបម្រើដូចជាទាសី ព្រោះផលនៃកម្មណា នុ៎ះជាផលកម្ម ( របស់ខ្ញុំ ) នោះ ទីបំផុតនៃបាបកម្មនោះឯង ខ្ញុំបានធ្វើហើយ ។

**ឥសិទាសីថេរី ។**

**ចប់ ចត្តាឡីសនិបាត ។**

# អដ្ឋកថា
# ថេរីគាថា ចត្តាឡីសនិបាត
## ឥសិទាសីថេរីគាថា

[ ៣៣៧ ] ក្នុងចត្តាឡីសនិបាត គាថារបស់ព្រះនាងឥសិទាសីថេរី មានពាក្យផ្តើមថា **នគរម្ហិ កុសុមនាមេ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ។ ក្នុងភពទី ៧ រាប់អំពីភពបច្ចុប្បន្ន បានធ្វើបរទារកកម្មជាមួយភរិយាអ្នកដទៃ ព្រោះសេពគប់មិត្តមិនល្អ ក្រោយអំពីស្លាប់ទៅបានកើតក្នុងនរក ឆេះក្នុងនរកនោះច្រើនឆ្នាំ ចុតិអំពីនរកនោះហើយ កើតក្នុងកំណើតតិរច្ឆាន ៣ ជាតិ ចុតិអំពីទីនោះហើយ កើតជាខ្ទើយក្នុងផ្ទៃរបស់ទាសី ចុតិអំពីនោះ កើតជាកូនស្រីអ្នកធ្វើរទេះក្រីក្រម្នាក់ ចម្រើនវ័យហើយ កូនប្រុសនាយរទេះម្នាក់ ឈ្មោះគិរិទាសៈ ក៏យកធ្វើជាភរិយា គិរិទាសៈនោះ មានភរិយាម្នាក់ជាអ្នកមានសីល មានកល្យាណធម៌ កូនស្រីជាងរទេះនោះ មានប្រក្រតីប្រណែននឹងភរិយាដើម ទើបឲ្យស្វាមីបណ្តេញនាងទៅ នាងនៅក្នុងផ្ទះនោះដរាបដល់អស់ជីវិត ក្រោយអំពីស្លាប់ ក្នុងពុទ្ធុប្បាទនេះ ក៏មកកើតជាធីតារបស់សេដ្ឋី ដែលដល់ព្រមដោយសម្បត្តិ បានទទួលនូវការលើកតម្កើងដោយគុណ មានត្រកូល ឋានៈ សីលនិងអាចារជាដើម ក្នុងនគរឧជ្ជេនី នាងមានឈ្មោះថាឥសិទាសី ។ លុះចម្រើនវ័យហើយ មាតាបិតា ក៏ឲ្យដល់សេដ្ឋី

បុត្តម្នាក់ ដែលមានត្រកូល រូប វ័យ និងសម្បត្តិជាដើម ដែលប្រហាក់ប្រហែលគ្នា ។ នាងឥសិទាសីនោះ បដិបត្តិស្វាមីដូចទេវតា ក្នុងផ្ទះរបស់ស្វាមីនោះ នៅបានត្រឹមតែមួយខែ ដោយផលនៃកម្មរបស់នាង ស្វាមីក៏កើតធុញទ្រាន់ បណ្តេញនាងចេញទៅអំពីផ្ទះ ។ រឿងទាំងអស់នោះ ជាក់ច្បាស់ហើយក្នុងបាលីនោះឯង ព្រោះហេតុដែលស្វាមីគ្រប់គ្នារង្កៀស ( ស្អប់ខ្ពើម ) នាងក៏មានចិត្តសង្វេគ ឲ្យបិតាអនុញ្ញាតហើយ បួសក្នុងសម្នាក់ព្រះនាងជិនទត្តាថេរី ចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ញុំាងកាលវេលាឲ្យកន្លងទៅដោយសុខក្នុង ផលនិងសុខក្នុងព្រះនិព្វាន ។ ថ្ងៃមួយ ត្រាច់បិណ្ឌបាតក្នុងក្រុងបាដលិបុត្ត បន្ទាប់អំពីឆាន់ស្រេចហើយ ត្រឡប់អំពីបិណ្ឌបាត អង្គុយលើឆ្នេរខ្សាច់ក្បែរស្ទឹងគង្គាមហានទី ត្រូវព្រះថេរីសម្លាញ់របស់ខ្លួន ឈ្មោះពោធិថេរីសួរដល់បុព្វបដិបត្តិ គឺប្រវត្តិមុនបួស ទើបវិសជ្ជនាសេចក្តីនោះដោយចងជាគាថាដោយន័យថា **នគរម្ហិ កុសុមនាមេ** ជាដើម ដើម្បីឲ្យពាក្យសួរនិងពាក្យឆ្លើយ របស់ព្រះថេរីទាំងពីររូបជាប់គ្នា ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថា ៣ ថា

> ភិក្ខុនីពីររូប ជាកុលធីតាក្នុងសាក្យត្រកូល ជាអ្នកមានគុណ
> សម្បត្តិក្នុងនគរកុសុមបាដលិបុត្ត ដែលជាមណ្ឌលនៃដែនដី ។
> បណ្តាភិក្ខុនីទាំងពីររូបនោះ ភិក្ខុនី ១ រូប ឈ្មោះឥសិទាសី
> ភិក្ខុនីទី ២ ឈ្មោះពោធិ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នក
> ត្រេកអរដោយការរំពឹងក្នុងឈាន ជាពហុស្សុត មានកិលេស

កម្ចាត់បង់ហើយ ។ ភិក្ខុនីទាំងពីររូបនោះ ត្រាច់ទៅបិណ្ឌបាត ហើយធ្វើនូវភត្តកិច្ច លុះលាងបាត្រហើយ អង្គុយជាសុខក្នុងទីស្ងាត់ ទើបផ្តើមនិយាយសម្តីទាំងឡាយនេះថា ។

( ព្រះនាងពោធិថេរីសួរថា )

ម្នាលនាងម្ចាស់ឈ្មោះឥសិទាសី នាងជាស្រីគួរជ្រះថ្លា ទាំងវ័យរបស់នាង ក៏មិនទាន់សាបសូន្យ អើចុះនាងឃើញទោសដូចម្តេច ទើបមកប្រកបខ្វល់ខ្វាយក្នុងបព្វជ្ជា ។ ឥសិទាសីភិក្ខុនីនោះជាអ្នកឈ្លាសវៃក្នុងធម្មទេសនា កាលបើពោធិភិក្ខុនីសាកសួរ ក្នុងហេតុជាប្រយោជន៍ យ៉ាងនេះហើយ ក៏បានពោលនូវពាក្យនេះថា ម្នាលនាងពោធិនាងចូរស្តាប់តាមដំណើរដែលខ្ញុំបួសចុះ ។

លំដាប់អំពីនេះទៅ គឺជាពាក្យវិស្សជ្ជនា

សេដ្ឋីអ្នកសង្រួមក្នុងសីល ជាបិតារបស់ខ្ញុំ ក្នុងបុរីដ៏ប្រសើរឈ្មោះឧជ្ជេនី ( ក្នុងដែនអវន្តិ ) ខ្ញុំជាធីតាម្នាក់ ជាទីស្រឡាញ់ពេញចិត្ត ជាអ្នកគួរទទួលសេចក្តីអនុគ្រោះរបស់បិតានោះ ។ លុះចំណេរមកខាងក្រោយ សេដ្ឋីមានត្រកូលដ៏ឧត្តម មានទ្រព្យច្រើន មកអំពីនគរសាកេត ដណ្តឹងខ្ញុំ បិតាក៏បានឲ្យខ្ញុំជាកូនប្រសាររបស់សេដ្ឋីនោះ ។ ខ្ញុំចូលទៅក្រាបក្បាលថ្វាយបង្គំនូវជើងម្តាយក្មេកនិងឪពុកក្មេក រាល់ល្ងាចព្រឹក តាមដំណើរដែលមាតាបិតាប្រៀនប្រដៅ ។ ខ្ញុំឃើញនូវអ្នកដណ្តឹង

សូម្បីម្នាក់ ដែលជាបងប្អូនស្រី បងប្អូនប្រុស ឬជាបរិវាររបស់ស្វាមី ខ្ញុំក៏រលះរលាំងក្រោលអាសនៈ ។ ខ្ញុំអង្គាសផ្គត់ផ្គង់ឲ្យបាយ ទឹក និងបង្អែម ដែលមានក្នុងលំនៅនោះ តាមសមគួរដល់វត្ថុដែលគេត្រូវការ ។ ខ្ញុំក្រោកឡើងតាមកាលគួរ ហើយចូលទៅកាន់ផ្ទះរបស់ប្តី ជូតសម្អាតនូវធរណីទ្វារ ( ជាដើម ) និងដៃ ជើង ផ្គងអញ្ជលីចូលទៅរកប្តី ។ ខ្ញុំយក ស្និតសក់ម្សៅសម្រាប់លាបមុខ ថ្នាំសម្រាប់បន្តក់ភ្នែក និងកញ្ចក់ ស្អិតស្អាងឲ្យប្តីដោយខ្លួនឯង ហាក់ដូចជា ( វណ្ណទាសី ) អ្នកធ្វើនូវការបម្រើ ។ ខ្ញុំដាំបាយខ្លួនឯង លាងភាជន៍ខ្លួនឯង បម្រើកស្តា ដូចជាមាតាថ្នមកូនខ្ចី ។ តែកស្តាតែងទឹងសម្បារនឹងខ្ញុំដែលជាស្ត្រីបម្រើបាយ គ្មានស្ត្រីណាលើស ជាស្ត្រីធ្វើការ ( គ្រប់យ៉ាង ) ជាស្ត្រីមិនមានសេចក្តីប្រកាន់ មានសេចក្តីព្យាយាម មិនខ្ជិលច្រអូស មានមារយាទយ៉ាងនេះ ។ ស្វាមីនោះនិយាយនឹងមាតាបិតារបស់គេថា ខ្ញុំសូមលា ( អ្នកម្តាយលោកឪពុក ) ទៅ ( ក្នុងទីណាមួយ ) ( ព្រោះ ) ខ្ញុំមិនអាចនៅរួមគ្នាក្នុងផ្ទះមួយ ជាមួយនឹងនាងឥសិទាសីឡើយ ។

( មាតាបិតាពោលថា ) នែកូន កុំពោលយ៉ាងនេះឡើយ នាងឥសិទាសី ជាបណ្ឌិតឈ្លាសវៃ ជាស្ត្រីមានសេចក្តីព្យាយាម មិនខ្ជិលច្រអូសទេ ម្នាលកូន ហេតុអ្វី ក៏កូនឯងមិន

ពេញចិត្ត ។

( កូនពោលថា ) នាងឥសិទាសីមិនបៀតបៀនអ្វីៗ ដល់ខ្ញុំទេ ប៉ុន្តែ ខ្ញុំមិនអាចនៅជាមួយនឹងនាងឥសិទាសី ព្រោះថា នាងឥសិទាសីជា ស្រីសម្អប់របស់ខ្ញុំ ខ្ញុំមិនគួរនឹងនៅរួមទេ ខ្ញុំសូមលាទៅហើយ ។

ម្តាយក្មេកនិងឪពុកក្មេក បានស្តាប់ពាក្យកូននោះហើយសួរខ្ញុំថា នាងធ្វើខុសអ្វីទេ នាងចូរប្រាប់កំហុសដែលនាងធ្វើហើយ នាងចូរដោះស្រាយតាមសេចក្តីពិតមកចុះ ។

( ខ្ញុំក៏ឆ្លើយថា ) ខ្ញុំមិនបានប្រទូស្តអ្វីៗទេ ខ្ញុំមិនបៀតបៀនមិនពោលពាក្យអាក្រក់ ( ដល់គាត់ទេ ) កស្តាស្អប់ខ្ញុំ ឲ្យខ្ញុំអាចធ្វើអ្វីកើត ។ ម្តាយក្មេក និងឪពុកក្មេកទាំងឡាយនោះក៏អាក់អន់ចិត្ត ត្រូវសេចក្តីព្រួយគ្របសង្កត់ ក៏នាំខ្ញុំត្រឡប់ទៅកាន់ផ្ទះបិតាវិញ រក្សានូវកូន ( ដោយគិតថា ) យើងនឹងរកឲ្យបាននូវស្រ្តីមានរូបឆោមដ៏មានសិរី ។ គ្រាក្រោយមក បិតាបានឲ្យខ្ញុំក្នុងផ្ទះនៃត្រកូលទី ២ ជាអ្នកស្តុកស្តម្ភ ដោយជំនូនពាក់កណ្តាលអំពីជំនូនដែលសេដ្ឋីបានជូនមកខ្ញុំមុននោះ ។ ខ្ញុំបាននៅក្នុងផ្ទះនៃប្តីទី ២ នោះ អស់ ១ ខែ គ្រានោះ គាត់ក៏បណ្តេញខ្ញុំ ដែលជាស្រ្តីខ្នះខ្នែងបម្រើដូចជាទាសី ជាស្រ្តីមិនប្រទូស្តមានមារយាទល្អ ។ បិតារបស់ខ្ញុំនិយាយនឹងបុរសអ្នក

ទូន្មាន ( ចិត្ត ) អ្នកទូន្មាន ( កាយនិងវាចា ) ដែលកំពុង ត្រាច់ទៅដើម្បីភិក្ខាថា អ្នកចូរជាកូនប្រសារបស់ខ្ញុំ អ្នកចូរបោះ បោលនូវកំណាត់សំពត់និងផ្ទាំង ។ ស្វាមីទី ៣ នោះ បានទៅ ( ជាមួយនឹងខ្ញុំ ) អស់បក្ខ ១ ( កន្លះខែ ) ក៏និយាយនឹង បិតាខ្ញុំថា អ្នកចូរឲ្យកំណាត់សំពត់ ផ្ទាំង និងអំបែង មកខ្ញុំវិញ ខ្ញុំនឹងត្រាច់ទៅដើម្បីភិក្ខាទៀត ។ គ្រានោះ បិតាមាតានិងពពួក ញាតិទាំងអស់របស់ខ្ញុំ និយាយនឹងបុរសនោះថា អ្នកណាមិន ធ្វើតាមអ្នកក្នុងទីនេះឬ អ្នកចូរប្រាប់ហេតុ ដែលគេធ្វើដល់អ្នក ឲ្យឆាប់ ។ បុរសនោះ កាលបើគេពោលយ៉ាងនេះហើយ ក៏ ពោលតបថា បើខ្លួនរបស់ខ្ញុំអាចនៅបាន ( ក៏នាងឥសិទាសី ) មិនគួរដល់ខ្ញុំ ( ព្រោះហេតុនោះ ) ខ្ញុំមិននៅជា មួយនាង ឥសិទាសីក្នុងផ្ទះមួយជាមួយគ្នាទេ បុរសនោះ កាលបើ ( បិតា របស់ខ្ញុំ ) លះបង់ហើយ ក៏ទៅបាត់ទៅ ចំណែកខាងខ្ញុំ ជា ស្ត្រីនៅតែម្នាក់ឯងគិតថា អាត្មាអញនឹងលាមាតាបិតាទៅស្លាប់ ឬទៅបួស ។ គ្រានោះ នាងថេរីជាម្ចាស់ឈ្មោះជិនទត្តា ជា អ្នកទ្រទ្រង់នូវវិន័យ ជាពហុស្សូត បរិបូណ៌ដោយសីលកាល ត្រាច់ទៅដើម្បី ភិក្ខាហារ ក៏បាននិមន្តមកកាន់ត្រកូលនៃបិតា ( ខ្ញុំ ) ។ ខ្ញុំឃើញ នាងជិនទត្តាថេរីនោះ ក៏ក្រោកឡើងក្រាល អាសនៈរបស់យើងប្រគេននាងថេរីនោះ លុះព្រះនាងគង់ហើយ

ខ្ញុំក៏ថ្វាយបង្គំនូវព្រះបាទាហើយ ប្រគេនភោជន ។ ខ្ញុំញុំាងជិនទត្តាថេរី ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងបង្អែម ដែលមានក្នុងលំនៅនោះ ហើយពោលថា បពិត្រព្រះនាងជាម្ចាស់ ខ្ញុំចង់បួស ។ គ្រានោះ បិតាពោលនឹងខ្ញុំថា ម្នាលកូនស្រីតូច នាងចូរប្រព្រឹត្តធម៌នោះ ក្នុងផ្ទះនេះទៅចុះ ចូរញុំាងសមណៈទាំងឡាយផង ព្រាហ្មណ៍ទាំងឡាយផង ឲ្យឆ្អែតស្កប់ស្កល់ដោយ បាយនិងទឹកចុះ ។ លំដាប់នោះ ខ្ញុំក៏ប្រណម្យអញ្ជលីយំពោលនឹងបិតាថា បពិត្របិតា សូមលោកអនុញ្ញាតខ្ញុំ ខ្ញុំនឹងញុំាងបាបកម្មដែលខ្ញុំធ្វើហើយនោះឲ្យវិនាស ។ គ្រានោះបិតាពោលនឹងខ្ញុំថា ( ព្រះសម្មាសម្ពុទ្ធ ) ព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ណា នាងចូរបានលុះនូវពោធិញ្ញាណនិងអគ្គធម៌និងព្រះនិព្វាននោះចុះ ។ ខ្ញុំថ្វាយបង្គំលាបិតាមាតានិងពពួកនៃញាតិទាំងអស់ ហើយបួសបាន ៧ ថ្ងៃ ក៏សម្រេចវិជ្ជា ៣ ។ ខ្ញុំដឹងជាតិរបស់ខ្លួនបាន ៧ ជាតិ ផលវិបាកនេះរបស់កម្មណា ខ្ញុំនឹងប្រាប់នូវកម្មនោះដល់នាង នាងចូរមានចិត្តតែមួយ ចាំផ្ទៀងស្តាប់នូវកម្មនោះ ដូចតទៅនេះ ខ្ញុំជាជាងមាស មានទ្រព្យច្រើន ក្នុងនគរឈ្មោះឯកកច្ឆៈ ខ្ញុំនោះជាមនុស្សស្រវឹង ព្រោះការស្រវឹងវ័យ បានប្រព្រឹត្តសេពសម្ភពនឹងប្រពន្ធបុគ្គលដទៃ ។ ខ្ញុំនោះ លុះឃ្លាត

ចាកអត្តភាពនោះហើយ ក៏ឆេះរោលរាលក្នុងនរក អស់កាលយូរ លុះរួចចាកនរកនោះហើយ មកចាប់បដិសន្ធិក្នុងផ្ទៃនៃមេស្វា ។ ស្វាឈ្មោលធំ ជាម្ចាស់នៃហ្វូង ខាំផ្ដាច់នូវជាតកម្ម គឺអណ្ឌជាត ( របស់ខ្ញុំ ) ដែលទើបនឹងកើតបាន ៧ ថ្ងៃ នុ៎ះជាផលនៃកម្មរបស់ខ្ញុំនោះ ដែលគប់រកនូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំនោះ ធ្វើមរណកាល ច្យុតចាកកំណើតនៃស្វានោះហើយ ក៏ចាប់បដិសន្ធិក្នុងផ្ទៃនៃមេពពែខ្វាក់ផង ខ្វកផង ក្នុងដែននៃស្ដេចសិន្ធវៈ ។ ខ្ញុំត្រូវគេព្រនាក់កូនក្មេងអស់ ១២ ឆ្នាំ ត្រូវគេក្រៀវ ត្រូវដង្កូវបៀតបៀន ឈឺចាប់ ព្រោះតែអំពើដែលខ្ញុំសេពនូវប្រពន្ធរបស់បុគ្គលដទៃ ។ ខ្ញុំនោះ ច្យុតចាកកំណើតនៃពពែនោះហើយ ក៏កើតជាកូនគោ អំពីមេគោរបស់ឈ្មួញគោ បាន ១២ ខែ មានរោមក្រហម ដូចជាជ្រលក់ល័ក្ត ហើយត្រូវគេក្រៀវ ។ ខ្ញុំតែងទាញនូវនង្គ័លនិងរទេះ ខ្វាក់ ខ្វក ឈឺ ព្រោះតែខ្ញុំសេពនូវប្រពន្ធរបស់បុគ្គលដទៃ ។ ខ្ញុំនោះជាសត្វច្យុតចាកកំណើតនៃគោនោះហើយ ក៏កើតក្នុងផ្ទៃនៃទាសីក្នុងផ្ទះក្បែរថ្នល់ មិនប្រាកដជាស្រី មិនប្រាកដជាប្រុស ( ខ្ទើយ ) ព្រោះតែខ្ញុំសេពនូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំស្លាប់ក្នុងអាយុ ៣០ ឆ្នាំ ហើយក៏កើតជាទារិកាក្នុងត្រកូលនៃអ្នករទេះដែលជា ត្រកូលកំព្រា គ្មានភោគសម្បត្តិ ត្រូវបុរសជាម្ចាស់ទ្រព្យរើបជាន់ច្រើន ។

កាលការប្រាក់ចម្រើនច្រើនឡើងហើយ នាយឈ្មួញរទេះ ក៏អូសទាញខ្ញុំអំពីផ្ទះនៃត្រកូលដែលកំពុងយំ ខ្សឹកខ្សួល ។ គ្រានោះបុត្តរបស់ឈ្មួញរទេះនោះ ឈ្មោះគិរិទាសៈ បានឃើញខ្ញុំជាស្ត្រីនៅក្រមុំ មានវ័យចម្រើនក្នុងឆ្នាំជាគម្រប់ ១៦ ក៏ហួងហែងទុក ( ក្នុងផ្ទះរបស់ខ្លួន ) ។ ប្រពន្ធដទៃរបស់គិរិទាសៈ ជាស្ត្រីមានសីលផង មានគុណផង ជាស្ត្រីប្រព្រឹត្តតាមកស្តា ខ្ញុំក៏បានធ្វើការស្អប់នូវប្រពន្ធរបស់គាត់ ។ ប្តីទាំងឡាយ លះលែងខ្ញុំ ដែលជាអ្នកខ្នះខ្នែងបម្រើដូចជាទាសី ព្រោះផលនៃកម្មណា នុ៎ះជាផលកម្ម ( របស់ខ្ញុំ ) នោះ ទីបំផុតនៃបាបកម្មនោះឯង ខ្ញុំបានធ្វើហើយ ។

បណ្តាបទទាំងនោះ បទថា **នគរម្ហិ កុសុមនាមេ** បានដល់ ក្នុងនគរដែលជាក់ឈ្មោះតាមឈ្មោះផ្កាថាកុសុមនគរ គឺជានគរផ្កា ឥឡូវនេះ នគរនោះមានឈ្មោះថាបាដលិបុត្ត ។ បទថា **បឋវិយា មណ្ឌេ** បានដល់ ជានគរវិសេសផង់ទាំងអស់ ។ បទថា **សក្យកុលកុលីនាយោ** បានដល់ ជាធីតាក្នុងសក្យត្រកូល លោកពោលយ៉ាងនេះ ក៏ព្រោះជាអ្នកបួស ក្នុងសាសនារបស់ព្រះមានព្រះភាគដែលជាសក្យបុត្ត ។

បទថា **តត្ថ** បានដល់ ក្នុងភិក្ខុនី ២ រូបនោះ ។ បទថា **ពោធិ** បានដល់ ព្រះថេរីមានឈ្មោះយ៉ាងនេះ ។ បទថា **ឈានជ្ឈាយនរតាយោ** បានដល់ ជាអ្នកត្រេកអរក្រៃលែងក្នុងការសម្ពឹងឈានដែលជាលោកិយនិងលោ-

កុត្តរ ។ បទថា **ពហុស្សុតាយោ** បានដល់ ជាពហូសូតដោយពាហុសច្ចៈខាងបរិយត្តិ ។ បទថា **ធុតកិលេសាយោ** បានដល់ ជាអ្នកជកនូវកិលេសបានដោយប្រការទាំងពួង ដោយអរហត្តមគ្គ ។ បទថា **កតត្តំ ការិយ** បានដល់ ធ្វើកត្តកិច្ចស្រេចហើយ ។ បទថា **រហិតម្ហិ** បានដល់ ក្នុងទីដែលប្រាសចាកមនុស្ស គឺក្នុងទីស្ងាត់ ។ បទថា **សុខនិសិន្នា** បានដល់ អង្គុយជាសុខដោយសុខក្នុងបព្វជ្ជា និងដោយសុខក្នុងវិវេក ។ បទថា **ឥមា គិរា** បានដល់ ការសន្ទនាជាសុខដែលនឹងពោលក្នុងឥឡូវនេះ ។ បទថា **អត្ថុតីរេសុំ** បានដល់ ពោលជាការសួរការឆ្លើយ ។

គាថាថា **បាសាទិកាសិ** ជាដើម ព្រះនាងពោធិថេរីពោលជាពាក្យសួរ ។ គាថាថា **ឯវមនុយុញ្ជិយមានា** ជាដើម ព្រះសង្គីតិកាចារ្យទាំងឡាយ ជាអ្នកពោល ។ គាថាទាំងអស់ចាប់អំពីពាក្យថា **ឧជ្ជនិយា** ជាដើម ព្រះនាងឥសិទាសីថេរីជាអ្នកពោល ។ បណ្តាបទទាំងនោះ បទថា **បាសាទិកាសិ** បានដល់ ជាអ្នកនាំមកនូវសេចក្តីជ្រះថ្លាដល់អ្នកដែលជួបដែលឃើញ ព្រោះមានរូបស្អាត ។ បទថា **វយោបិ តេ អបរិហីនោ** សេចក្តីថា សូម្បីវ័យរបស់នាង ក៏មិនទាន់ទ្រុឌទ្រោម គឺនៅក្នុងបឋមវ័យ ។ បទថា **កឹ ទិស្វាន ព្យាលិកំ** សេចក្តីថា ឃើញទុក្ខភ័យ គឺទោសក្នុងឃរាវាសដូចម្តេច ។ សព្ទថា **អថ** ក្នុងបទថា **អថាសិ នេក្ខម្មមនុយុត្តា** ត្រឹមតែជានិបាត សេចក្តីថា ទើបជាអ្នកខ្វល់ខ្វាយក្នុងនេក្ខម្មៈ គឺបព្វជ្ជា ។

បទថា **អនុយុញ្ជិយមានា** បានដល់ ត្រូវសួរ ប្រកបសេចក្តីថា ព្រះ

នាងឥសិទាសីនោះ ត្រូវព្រះនាងពោធិថេរីនោះសាកសួរ ។ បទថា **រហិតេ** បានដល់ ក្នុងទីដែលស្ងាត់មនុស្ស ។ បទថា **សុណា ពោធិ យថាម្ហិ បព្វជិតា** សេចក្តីថា ព្រះនាងពោធិថេរី សូមនាងស្តាប់រឿងចាស់ដែលធ្វើឲ្យខ្ញុំបួស ។

បទថា **ឧជ្ជេនិយា បុរវរេ** បានដល់ ក្នុងនគរដ៏ឧត្តម ដែលមាន ឈ្មោះថាឧជ្ជេនីក្នុងដែនអវន្តី ។ បទថា **បិយា** បានដល់ ដែលមាតាបិតាគប្បីស្រឡាញ់ ព្រោះជាកូនតែម្នាក់ ។ បទថា **មនាបា** បានដល់ ជាទីចម្រើនចិត្តដោយគុណ គឺសីលាចារវត្ត ។ បទថា **ទយិតា** បានដល់ ដែលមាតាបិតាគប្បីករុណា ។ បទថា **អថ** បានដល់ ក្នុងកាលខាងក្រោយ គឺក្នុងកាលដែលខ្ញុំចម្រើនវ័យ ។ បទថា **មេ សាកេតតោ វរកា** សេចក្តីថា បុគ្គលស្និទ្ធស្នាលរបស់ខ្ញុំមកអំពីនគរសាកេត ជ្រើសរើសខ្ញុំ ។ បទថា **ឧត្តមកុលីនា** បានដល់ ជាអ្នកមានត្រកូលខ្ពស់ក្នុងនគរនោះ បុគ្គលដែលបញ្ជូនមនុស្សទាំងនោះទៅ គឺសេដ្ឋីដែលមានរតនៈច្រើន ។ បទថា **តស្ស មមំ សុណ្ហមទាសិ តាតោ** សេចក្តីថា បិតារបស់ខ្ញុំលើកខ្ញុំឲ្យជាកូនប្រសាររបស់សេដ្ឋីនគរសាកេត ជាភរិយារបស់កូនប្រុស ។

បទថា **សាយំ បាតំ** បានដល់ ពេលល្ងាច និងពេលព្រឹក ។ បទថា **បណាមមុបគម្ម សិរសា ករោមិ** សេចក្តីថា ខ្ញុំចូលទៅរកម៉ែក្មេកនិងពុកក្មេក ធ្វើការថ្វាយបង្គំដោយសិរសាគឺត្បូង ក្រាបទៀបបាទារបស់លោក ។ បទថា **យថាម្ហិ អនុសិដ្ឋា** សេចក្តីថា ខ្ញុំធ្វើតាមដែលលោកប្រៀនប្រដៅ មិន

កន្ទងពាក្យប្រៀនប្រដៅរបស់លោក ។

បទថា **តមេកវរកម្បិ** បានដល់ សូម្បីតែមនុស្សស្និទ្ធស្នាលម្នាក់ ។ បទថា **ឧតិ្តក្តា** បានដល់ កោតក្រែង ។ បទថា **អាសនំ ទេមិ** សេចក្តីថា វត្ថុណាសមគួរដល់បុគ្គលណា ខ្ញុំឲ្យវត្ថុនោះដល់បុគ្គលនោះ ។

បទថា **តត្ថ** បានដល់ ក្នុងលំនៅ ។ បទថា **សន្និហិតំ** បានដល់ ដែលមាន តាមដែលរៀបចំទុក ។ បទថា **ធាទេមិ** សេចក្តីថា ទទួល កាលទទួលហើយ ក៏នាំចូលទៅ កាលនាំចូលទៅហើយ ក៏ឲ្យ កាលឲ្យ ក៏ឲ្យតែវត្ថុសមគួរប៉ុណ្ណោះ ។

បទថា **ឧម្មារេ** បានដល់ ទ្វារ ។ បទថា **ធោវន្តី ហត្ថបាទេ** ប្រកបសេចក្តីថា ខ្ញុំត្រូវលាងដៃ ជើង កាលលាងហើយ ទើបចូលទៅក្នុងផ្ទះ ។

បទថា **កោច្ឆំ** បានដល់ ស្និតសម្រាប់សិតពុកមាត់ និងសក់ ។ បទថា **ចាសាធំ** បានដល់ គ្រឿងលាបមុខ មានលម្អិតក្រអូបជាដើម ។ បាលីថា **បសាធនំ** ក៏មាន បានដល់ គ្រឿងប្រដាប់ ។ បទថា **អញ្ជនី** បានដល់ ក្លាក់ថ្នាំបន្តក់ភ្នែក ។ បទថា **បរិកម្មការិកា វិយ** សេចក្តីថា ខ្ញុំជាមនុស្សត្រកូលខ្ពស់ សម្បូរដោយសម្បត្តិ ក៏ដូចជាអ្នកបម្រើរបស់ប្តី ។

បទថា **សាធយាមិ** បានដល់ ស្ងោរ ។ បទថា **ភាជនំ** បានដល់ ភាជនៈធ្វើដោយលោហៈ ប្រកបសេចក្តីថា ខ្ញុំត្រូវលាងនូវភាជនៈផ្សេងៗប្រណិប័តន៍ស្វាមីដោយខ្លួនឯង ។

បទថា **ភត្តិកតំ** បានដល់ ជាអ្នកធ្វើនូវស្វាមីភក្តិ ។ បទថា **អនុរត្តំ**

បានដល់ ជាអ្នកស្រឡាញ់ ។ បទថា **កតាវិកំ** បានដល់ ដែលធ្វើក្នុងទីដែលគួរធ្វើនោះៗ ដូចពោលមក ។ បទថា **និហតមានំ** បានដល់ ជាអ្នកនាំមានះចេញហើយ ។ បទថា **ឧដ្ឋាយិកំ** បានដល់ ជាអ្នកដល់ព្រមដោយសេចក្តីព្យាយាម ។ បទថា **អនលសំ** បានដល់ ជាអ្នកដល់ព្រមដោយការខ្ជិលច្រអូស ។ បទថា **សីលវតី** បានដល់ ជាអ្នកដល់ព្រមដោយសីលាចារវត្ត ។ បទថា **ទុស្សតេ** ប្រែថា ប្រទូសរ៉ាយ គឺពោលព្រោះក្រោធ ។ បទថា **ភណាតិ អាបុច្ឆហំ គមិស្សា-មិ** សេចក្តីថា ប្តីរបស់ខ្ញុំនោះ ពោលនឹងមាតាបិតារបស់ខ្លួនថា ខ្ញុំនឹងលាលោកឪពុកអ្នកម្តាយទៅកាន់ទីដទៃ ។ បើសួរថា បុគ្គលនោះនិយាយដូចម្តេច ក៏ឆ្លើយបានថា បុគ្គលនោះ ពោលថា ខ្ញុំមិនអាចនៅរួមគ្នាក្នុងផ្ទះមួយ ជាមួយនឹងនាងឥសិទាសីឡើយ ។ បណ្តាបទទាំងនោះ បទថា **វច្ឆំ** ប្រែថា នៅ ។

បទថា **ទេស្សា** បានដល់ មិនជាទីស្រឡាញ់ គឺស្អប់ ។ បទថា **អលំ មេ** សេចក្តីថា ខ្ញុំមិនត្រូវការនាងឥសិទាសីនោះ ។ បទថា **អាបុច្ឆាហំ គមិស្សាមិ** សេចក្តីថា បើលោកឪពុកអ្នកម្តាយបំណាន់ឲ្យខ្ញុំនៅរួមជាមួយនាងឥសិទាសីនោះ ខ្ញុំក៏សូមលាលោកឪពុកអ្នកម្តាយទៅរស់នៅតំបន់ដទៃ ។

បទថា **តស្ស** ប្រែថា ស្វាមីរបស់ខ្ញុំ ។ បទថា **កិស្ស** កាត់បទជា **កឹ អស្ស** សំដៅដល់ ស្វាមីរបស់នាង ។ បទថា **តយា អបរទ្ធំ** សេចក្តីថា នាងធ្វើខុសអ្វីចំពោះស្វាមី ។

បទថា **នបិហំ អបរជ្ឈំ** សេចក្តីថា ខ្ញុំមិនបានធ្វើខុសអ្វីចំពោះស្វាមី

នោះ ។ម្យ៉ាងទៀត បាលីថា **អបរជ្ឈឹ** ក៏មាន ។ បទថា **ឆបិ ហីសេមិ** បានដល់ ទាំងមិនបានបៀតបៀន ។ បទថា **ឧត្វចនំ** បានដល់ ពាក្យសម្តីដែលគ្រោតគ្រាត ។ បទថា **កឹ សក្កា កាតុយ្យេ** សេចក្តីថា បពិត្រអ្នកម៉ែខ្ញុំនឹងធ្វើអ្វីបាន ។ បទថា **យំ មំ វិទេស្សតេ ភត្តា** សេចក្តីថា ព្រោះស្វាមីរបស់ខ្ញុំ ស្អប់ខ្ញុំ គឺធ្វើនូវការស្អប់ ធ្វើនូវការអាក់អន់ ។

បទថា **វិមនា** បានដល់ ទោមនស្ស ។ បទថា **បុត្តមនុរក្ខមានា** បានដល់ លើកស្ទួយបុត្តរបស់ខ្លួនដែលជាប្តីរបស់ខ្ញុំដោយការរក្សាទឹកចិត្ត ។ បទថា **ជិតាម្ហសេ រូបិនឹ លក្ខឹ** សេចក្តីថា ពួកយើងឈ្នះ ពួកយើងឈ្នះតែវិនាសនាងដែលជាមនុស្សស្អាត មានសិរី គឺវិនាសនូវទេវតានៃសិរីដែលកាឡាខ្លួនជារាងកាយមនុស្ស ។

បទថា **អឌ្ឍស្ស យរម្ហិ ទុតិយកុលិកស្ស** សេចក្តីថា បិតាបានឲ្យខ្ញុំក្នុងផ្ទះត្រកូលទី ២ បើធៀបនឹងប្តីទី ១ ក៏មានស្តុកស្តម្ភតិចជាងគ្នាពាក់កណ្តាល តែកាលឲ្យ ក៏ឲ្យដោយបណ្ណាការពាក់កណ្តាលនៃបណ្ណាការស្វាមីទី ១ នោះ ។ បទថា **យេន មំ វិន្ទថ សេដ្ឋិ** ប្រកបសេចក្តីថា សេដ្ឋីបានខ្ញុំជាដំបូងដោយបណ្ណាការឯណា បិតារបស់ខ្ញុំក៏លើកឲ្យដោយបណ្ណាការពាក់កណ្តាលអំពីបណ្ណាការស្វាមីដំបូងនោះ ។

បទថា **សោបិ** បានដល់ សូម្បីស្វាមីទី ២ ។ បទថា **មំ បដិច្ឆរយិ** បានដល់ បណ្តេញខ្ញុំ គឺបណ្តេញខ្ញុំចេញអំពីផ្ទះ ។ បទថា **ឧបដ្ឋហាន្តឹ** បានដល់ ជាអ្នកទំនុកបម្រុង គឺធ្វើការប្រណិប័តន៍ដូចទាសី ។ បទថា **អទូសិកំ**

ប្រែថា ជាអ្នកមិនប្រទូស្ត ។

បទថា **ឧមកំ** បានដល់ ជាអ្នកទូន្មានចិត្តរបស់អ្នកដទៃ ព្រោះជាអ្នកអធិដ្ឋានទូវសេចក្តីករុណា គឺអ្នកត្រាច់សូមអាហារដែលអ្នកដទៃគប្បីឲ្យ ធ្វើកាយវាចាមនុស្សឲ្យស្ងប់រម្ងាប់ ដោយអាការៈដែលជនពួកដទៃឲ្យរបស់ខ្លះៗ ។ បទថា **ជាមាតា** បានដល់ ប្តីរបស់ធីតា គឺកូនប្រសា ។ បទថា **និក្ខិប ថោដ្ឋិញ្ច យដិកញ្ច** សេចក្តីថា ចូរអ្នកលះបង់សំពត់ចាស់ ដែលអ្នកស្លៀកដណ្តប់ និងភាជនៈសូមទានរបស់អ្នក ។

បទថា **សោបិ វសិត្វា បក្ខំ** សេចក្តីថា បុរសសុំទានម្នាក់នោះ នៅជាមួយខ្ញុំ បានត្រឹមកន្លះខែ ក៏ចៀសចេញទៅ ។

បទថា **អថ ធំ ភណាតី តាតោ** សេចក្តីថា មាតាបិតា និងពួកញាតិគ្រប់គ្នារបស់ខ្ញុំ រួមគ្នាជាក្រុម នាំគ្នានិយាយនឹងអ្នកសុំទាននោះ ។ ពោលថាដូចម្តេច ពោលថា អ្នកណាមិនធ្វើតាមអ្នកក្នុងទីនេះឬ សេចក្តីថា វត្តណាដែលអ្នកមិនធ្វើ ឬធ្វើមិនសម្រេច ។ បទថា **តំ តេ ករិហិតិ** បានដល់ ខ្ញុំនឹងធ្វើកិច្ចនោះជំនួសអ្នក ។

បទថា **យទិ មេ អត្តា សក្កោតិ** ប្រកបសេចក្តីថា បើខ្លួនខ្ញុំពឹងខ្លួនឯង បានជាអ្នកជាដល់ខ្លួន ខ្ញុំក៏គ្រប់គ្រាន់ គឺនាងឥសិទាសីនោះ ក៏មិនមានប្រយោជន៍សម្រាប់ខ្ញុំ ព្រោះហេតុនោះ ខ្ញុំមិននៅរួមផង មិននៅរួមក្នុងផ្ទះជាមួយនាងឥសិទាសីនោះផង ។

បទថា **វិសជ្ជិតោ គតោ សោ** សេចក្តីថា អ្នកសូមទាននោះ បិតាដោះ

លែងហើយ ក៏ទៅតាមគាប់ចិត្ត ។ បទថា **ឯកាកិនី** បានដល់ តែម្នាក់ឯង ។ បទថា **អាបុច្ឆិត្វាន គច្ឆំ** សេចក្តីថា ខ្ញុំលះបង់បិតារបស់ខ្ញុំទៅ ។ បទថា **មារិតុយេ** ប្រែថា ដើម្បីសម្លាប់ខ្លួនឲ្យស្លាប់ ។ **វាា** សព្ទ ត្រឹមតែជានិបាត ចុះក្នុងអត្ថត្រឹមតែដើម្បីហៅ ។ បទថា **គោចរាយ** បានដល់ ដើម្បីអាហារ ប្រកបសេចក្តីថា មកកាន់ត្រកូល របស់បិតាដើម្បីរកអាហារ ។

បទថា **តំ** បានដល់ ព្រះនាងជិនទត្តាថេរីនោះ ។ បទថា **ឧដ្ឋាយាសនំ តស្សា បញ្ញាបយឹ** សេចក្តីថា ក្រោកឡើង ទៅក្រាលអាសនៈប្រគេនព្រះថេរីនោះ ។

បទថា **ឥធេវ** បានដល់ នៅក្នុងផ្ទះនេះឯង ។ បិតាកាលករុណា ក៏ហៅកូនស្រីដោយវោហារសាមញ្ញថា **បុត្តក** ។ បទថា **ចរាហិ តុំ ធម្មំ** សេចក្តីថា ចូរកូនប្រព្រឹត្តធម៌ មានព្រហ្មចរិយៈជាដើម ដែលមនុស្សគេបួសហើយប្រព្រឹត្ត ។ បទថា **ទ្វិជាតី** បានដល់ ជាតិព្រាហ្មណ៍ ។

បទថា **និជ្ជរេស្សាមិ** បានដល់ នឹងធ្វើឲ្យអស់ទៅ នឹងធ្វើឲ្យវិនាសទៅ ។ បទថា **ពោធិ** បានដល់ ការត្រាស់ដឹងសច្ចៈ អធិប្បាយថា មគ្គញ្ញាណ ។ បទថា **អគ្គធម្មំ** បានដល់ ផលធម៌ គឺអរហត្ត ។ បទថា **យំ សច្ឆិការី ទ្វិ-បទសេដ្ឋោ** ប្រកបសេចក្តីថា ព្រះសម្មាសម្ពុទ្ធជាបុគ្គលប្រសើរបំផុតជាងទេវតានិងមនុស្សទាំងឡាយ ទ្រង់បានធ្វើលោកុត្តរធម៌ឯណា ដែលគេស្គាល់ថា មគ្គ ផល និព្វាន ឲ្យជាក់ច្បាស់ ចូរកូនបានលោកុត្តរធម៌នោះ ។

បទថា **សត្តាហំ បព្វជិតា** សេចក្តីថា បួសបានមួយសប្តាហ៍ ។ បទ

ថា **អជស្សយិ** បានដល់ ពាល់ត្រូវ គឺធ្វើឲ្យជាក់ច្បាស់ ។

បទថា **យស្សយំ ផលវិបាកោ** សេចក្តីថា វិបាកដែលឲ្យផល គឺការដែលស្វាមីរង្កៀសនេះ ជាផលរបស់បាបកម្មឯណា ។ បទថា **តំ តវ អាចិក្ខិស្សំ** សេចក្តីថា ខ្ញុំនឹងពោលបាបកម្មនោះដល់ព្រះនាង ។ បទថា **តំ** បានដល់កម្មនោះឯង ឬពាក្យដែលខ្ញុំនោះនឹងពោលតទៅ ។ បទថា **ឯកមនា** បានដល់ ជាអ្នកមានអារម្មណ៍មួយ ម្យ៉ាងទៀត បាលីជា **ឯកគ្គមនា** ក៏មាន ។

បទថា **នគរម្ហិ ឯរកច្ឆេ** បានដល់ នគរដែលមានឈ្មោះយ៉ាងនេះ ។ បទថា **សោ បរទារំ អសេវិហំ** ប្រែថា ខ្ញុំនោះបានសេពកិរិយារបស់អ្នកដទៃ ។

បទថា **ចិរំ បក្កោ** បានដល់ ត្រូវភ្លើងនរកដុតច្រើនសែនឆ្នាំ ។ បទថា **តតោ ច ឧដ្ឋហិត្វា** បានដល់ ចេញ គឺចុតិអំពីនរកនោះហើយ ។ បទថា **មក្កដិយា កុច្ឆិមោក្កមឹ** បានដល់ បដិសន្ធិក្នុងផ្ទៃមេស្វា ។

បទថា **យូថបោ** ប្រែថា មេហ្វូង ។ បទថា **ឆិល្លេច្ឆេសិ** បានដល់ ខាំ គឺផ្តាច់នូវពូជ គឺអវយវៈសម្រាប់បន្តពូជដែលជាគ្រឿងសម្គាល់នូវភេទឈ្មោល ចេញ ។ បទថា **តស្សេតំ កម្មផលំ** បានដល់ នុ៎ះជាផលរបស់កម្មដែលធ្វើហើយក្នុងអតីតរបស់ខ្ញុំនោះ ។ បទថា **យថាបិ គន្ត្វាន បរទារំ** បានដល់ដូចដែលខ្ញុំកន្លងល្មើសក្នុងកិរិយារបស់អ្នកដទៃ ។

បទថា **តតោ** បានដល់ ចាកកំណើតពានរ ។ បទថា **សិន្ធវារញ្ញេ** បានដល់ ក្នុងទីដែលជាព្រៃធំ ក្នុងដែនសិន្ធព ។ បទថា **ឯឡកិយា** ប្រែថា មេពពែ ។ បទថា **ទារកេ បរិវហិត្វា** បានដល់ នាំពួកក្មេងដែលជិះលើ

ខ្លួនទៅ ។ បទថា **កិមិឆាវេដ្ឋោ** បានដល់ កើតរោគ ត្រូវជន្លូវរូងជញ្ជក់ត្រង់អវយវៈបន្ទាប់ជ រងទុក្ខទារុណ ។ បទថា **អក្កោស្មោ** ប្រែថា ឈឺ ឲ្យបន្ថែមនូវពាក្យថា **អហោសិ** ( កើត ) ចូលមក ។ បទថា **គោឃាតកាជិកស្ស** បានដល់ អ្នកលក់គោចិញ្ចឹមជីវិត ។ បទថា **លោហិតមក្ខោ** បានដល់ ប្រកបដោយរោមពណ៌ក្រហម ដូចជ្រលក់ដោយ ទឹកល័ខ ។

បទថា **ឋោរក្ខន**[១] បានដល់ ត្រូវប្រើឲ្យអូស ។ បទថា **នង្គលំ** ប្រែថា នង្គ័ល អធិប្បាយថា អូសនង្គ័លនិងអូសរទេះ ។ បទថា **អន្ធោវេដ្ឋោ** បានដល់ កើតរោគខ្វាក់ភ្នែកដ៏ទារុណបៀតបៀន ។ បទថា **វិជិយោ** បានដល់ ដងផ្លូវក្នុងនគរ ។ បទថា **ទាសិយា ឃរេ ជាតោ** បានដល់ កើតក្នុងផ្ទះទាសីក្នុងផ្ទះ អាចារ្យពួកខ្លះពោលថា ស្រីវណ្ណទាសី ក៏មាន ។ បទថា **នេវ មហិលា ន បុរិសោ** សេចក្តីថា ខ្ញុំជាស្រី ឬជាបុរស ក៏មិនមែន គឺមិនមានភេទ ។ បទថា **តិំសតិវស្សម្ហិ មតោ** បានដល់ ជាមនុស្សមិនមានភេទ ស្លាប់ហើយ ក្នុងកាលអាយុ ៣០ ឆ្នាំ ។ បទថា **សាកដិកកុលម្ហិ** បានដល់ ត្រកូលជាងធ្វើរទេះ។ បទថា **ធនិកបុរិស ធាតពហុលម្ហិ** បានដល់ ត្រូវបុរសម្ចាស់បំណុល គឺម្ចាស់បំណុលជាច្រើន មកតឹងទារ ។

បទថា **ឧស្សន្នាយ** បានដល់ សន្សំ ។ បទថា **វិបុលាយ** បានដល់ ច្រើន ។ បទថា **វឌ្ឍិយា** បានដល់ កាលបំណុលចម្រើន ។ បទថា **ឱកឌ្ឍិតិ** បានដល់ អូសទាញ ។ បទថា **កុលឃរស្មា** បានដល់ ចេញអំពីផ្ទះត្រកូល

១-បិដកខ្មែរជា ឋេ បុន ។

ដែលខ្ញុំកើត ។

បទថា **ឱរុទ្ធកស្ស បុត្តោ** សេចក្តីថា កូនរបស់ទាយរទេះនោះ ឈ្មោះថា គិរិទាសៈ កើតចិត្តប្រតិព័ទ្ធក្នុងខ្ញុំ ក៏ហួងហែងខ្ញុំ គឺធ្វើឲ្យខ្ញុំនៅក្នុងផ្ទះ ដោយប្រកាន់ថាជាសម្បត្តិរបស់ខ្លួន ។

បទថា **អនុរត្តា ភត្តារំ** បានដល់ អនុលោមតាមប្តី ។ បទថា **តស្សាហំ វិទ្ទេសនមកាសឹ** បានដល់ គឺធ្វើឧបាយឲ្យបុរសនោះស្អប់កិរិយា ញុះញង់កិរិយា គឺស្រើរមប្តីឲ្យបែកអំពីស្វាមី ។

បទថា **យំ មំ អបកិរិតូន គច្ឆន្តិ** បានដល់ ការដែលប្តីទាំងឡាយក្នុងផ្ទះនោះៗ លះបង់ខ្ញុំដែលប្រណិប័តន៍ដោយគោរព ដូចទាសី មិនអាល័យអារម្មណ៍ លះបង់ទៅ នេះជាផលកម្ម គឺការសេពគប់កិរិយាអ្នកដទៃ និងកម្ម គឺការធ្វើស្រើរមប្តីឲ្យបែកចាកស្វាមី ដែលខ្ញុំធ្វើទុកក្នុងកាលនោះ ។ បទថា **តស្សបិ អន្តោ កតោ មយា** សេចក្តីថា ទីបំផុតនៃកម្មដែលជាប់តាមមកដ៏ទារុណយ៉ាងនោះ ឥឡូវនេះ ខ្ញុំជាអ្នកសម្រេចអរហត្តមគ្គ ធ្វើស្រេចហើយ ទុក្ខអ្វីក្រៅអំពីនេះ មិនមានឡើយ ។ មួយ៉ាងទៀត ពាក្យត្រង់ចន្លោះៗ ដែលមិនបានពោលទុកក្នុងរឿងនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលមកហើយ ។

អដ្ឋកថា ឥសិទាសីថេរីគាថា ចប់

ថេរីគាថា ចត្តាឡីសនិបាត ចប់

# ថេរីគាថា មហានិបាត

## សុមេធាថេរីគាថា

[ ៣៣៨ ] នាងសុមេធា ជាធីតានៃអគ្គមហេសីរបស់ព្រះរាជាទ្រង់ព្រះនាមកោញ្ចៈ ក្នុងនគរឈ្មោះមន្តាវតី ជាស្ត្រីដែលព្រះអរិយៈអ្នកធ្វើសាសនាឲ្យជ្រះថ្លាហើយ ។ នាងសុមេធា ជាស្រីមានសីល ជាធម្មកថិកាដ៏វិចិត្រ ជាពហុស្សូត ជាស្រីបានបទក្នុងព្រះពុទ្ធសាសនា ចូលទៅជិតព្រះមាតាបិតាហើយទូលថា សូមទ្រង់ទាំងពីរស្តាប់ ( ពាក្យខ្ញុំម្ចាស់ ) ។ ខ្ញុំម្ចាស់ជាអ្នកត្រេកអរចំពោះព្រះនិព្វាន ភពសូម្បីជាទិព្វ ក៏ជារបស់មិនទៀងទាត់ នឹងចាំបាច់ពោលទៅថ្វីដល់កាមទាំងឡាយដែលជារបស់សោះសូន្យ មានការត្រេកអរតិច មានសេចក្តីចង្អៀតចង្អល់ច្រើន ។ ពួកជនពាល ឈ្ពក់ក្នុងកាមទាំងឡាយណា កាមទាំងឡាយនោះ ជាសភាវៈខ្វាចផ្សា ឧបមាដូចជាអាសិរពិស ពួកជនពាលទាំងនោះ សឹងពេញណែនត្រៀបត្រាក្នុងនរក រងទុក្ខលំបាកអស់កាលដ៏អង្វែង ពួកជនពាល មានកម្មដ៏លាមក មានគំនិតអាក្រក់ មិនសង្រួមកាយ វាចា ចិត្ត រមែងសាេ្រងសង្រែ ក្នុងវិនិបាត ( អបាយ ) សព្វៗកាល ។ ជនពាលទាំងនោះ ជាអ្នកឥតប្រាជ្ញា ឥតចេតនា ត្រូវតណ្ហាជាហេតុនៃទុក្ខរួបរឹត មិនដឹង ( នូវចតុសច្ចធម៌ ) ដែលព្រះសម្ពុទ្ធទ្រង់សំដែង រមែងមិនត្រាស់ដឹងនូវអរិយសច្ចទាំងឡាយ ។ បពិត្រព្រះមាតា ជនទាំងឡាយជាច្រើននាក់ណាស់ ដែលមិនដឹងនូវសច្ចធម៌ដ៏ជាធម៌ គឺព្រះពុទ្ធដ៏ប្រសើរទ្រង់សំដែងហើយត្រេកអរតែនឹងភព ពេញចិត្តតែនឹងការកើត ក្នុងពួកទេវតា ។

សូម្បីការកើតក្នុងពួកទេវតា ក៏មិនទៀង កាលបើកពមិនទៀង ពួកជនពាល ក៏នៅតែមិនតក់ស្លុតនឹងភពដែលសត្វត្រូវកើតញយៗ ។ វិនិបាត ៤ និងគតិ ២ បុគ្គលគប្បីបានដូចម្តេចកើត បព្វជ្ជារបស់ពួកសត្វវិនិបាតក្នុងនរក មិនមានឡើយ ។ សូមទ្រង់ទាំងពីរ អនុញ្ញាតឲ្យខ្ញុំម្ចាស់ទៅបួស ក្នុងសាសនានៃព្រះទសពល ខ្ញុំម្ចាស់នឹងជាស្ត្រីមានសេចក្តីខ្វល់ខ្វាយតិច ប្រឹងប្រែងដើម្បីលះបង់នូវជាតិនិងមរណៈ ។ ប្រយោជន៍អ្វីដោយកព ដែលអ្នកផងត្រេកត្រអាល ប្រយោជន៍អ្វីដោយកាយជាទោស ឥតខ្លឹមសារ សូមទ្រង់អនុញ្ញាត ខ្ញុំម្ចាស់នឹងបួសដើម្បីរំលត់នូវភវតណ្ហា ។ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ( ខ្ញុំម្ចាស់បានចួបប្រទះហើយ ) កាលមិនមែនជាខណៈ ខ្ញុំម្ចាស់វៀរស្រឡះហើយ ខណៈខ្ញុំម្ចាស់បានហើយ ខ្ញុំម្ចាស់មិនប្រទូស្តនូវសីលនិងព្រហ្មចរិយៈ រហូតអស់មួយជីវិត ។

លុះនាងសុមេធា ក្រាបទូលយ៉ាងនេះ គ្រានោះ ព្រះមាតាបិតា បានមានបន្ទូលនឹងនាងថា យើងទាំងឡាយជាគ្រហស្ថ សុទ្ធតែលុះក្នុងអំណាចនៃសេចក្តីស្លាប់ នឹងលះបង់មិនបានទេ ។ មាតាជាទុក្ខ ស្រែកយំ បិតាក៏ជាទុក្ខ ត្រូវសេចក្តីសោកស្តាយគ្របសង្កត់ដូចគ្នា ប្រឹងប្រែងសង្រួបសង្រួមធីតានោះដែលដួលចុះលើផែនដី នាផ្ទៃប្រាសាទថា ។

ម្នាលកូនស្រី ចូរនាងក្រោកឡើង ប្រយោជន៍អ្វីដោយការសោក ( ដើម្បីចង់បួស ) យើងបានថ្វាយនាងដល់ស្តេចទ្រង់ព្រះនាមអនិករត្តៈ ជាស្តេចមានរូបល្អ ក្នុងនគរឈ្មោះវារណវតីហើយ ។ នាងនឹងបានជាអគ្គមហេសី នឹង

បានជាកិរិយារបស់ស្តេចអនិករត្ត: នៃកូនស្រី សីល ព្រហ្មចរិយធម៌និងបព្វជ្ជា គេធ្វើបានកម្រណាស់ ។ អាណាចក្រក្នុងរាជ្យ ( នៃស្តេចអនិករត្ត: ) ទ្រព្យ និងឥស្សរិយយស ( ក៏មានច្រើន ) ភោគសម្បត្តិទាំងឡាយ នាំមកនូវសេចក្តីសុខ ទាំងខ្លួននាងក៏នៅក្រមុំ ព្រោះហេតុនោះ នាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ ម្នាលកូនស្រី កិច្ចដែលគេត្រូវដណ្តឹង ចូរមានដល់នាង ។

គ្រានោះ នាងសុមេធាក្រាបទូលមាតាបិតានោះថា ទ្រព្យទាំងឡាយប្រាកដដូច្នេះ ចូរកុំមាន ( ដល់ខ្ញុំម្ចាស់ ) ភពជារបស់គ្មានខ្លឹមសារ បព្វជ្ជាឬមរណៈចូរមានដល់ខ្ញុំម្ចាស់ ព្រោះហេតុនោះ កិច្ចដែលគេត្រូវដណ្តឹង ( ចូរកុំមានដល់ខ្ញុំម្ចាស់ឡើយ ) ។ ( សរីរៈនេះ ) ដូចជាដង្កូវ ជាកាយស្អុយមិនស្អាត មានក្លិនផ្សាយទៅ គួរឲ្យខ្លាច ដូចជាការុងជាវិការនៃស្បែក ពេញដោយសាកសព ពេញដោយរបស់មិនស្អាតដែលហូរចេញក្នុងកាលម្តងៗ ។ ខ្ញុំម្ចាស់ដឹងនូវសរីរៈនោះថា ដូចជាអ្វីមួយដែលបូកលាបដោយសាច់និងឈាម ជារបស់គួរខ្ពើមក្រៃពេក ជាលំនៅនៃហ្វូងដង្កូវ ជាចំណីនៃសត្វស្លាប ជាសាកសព ( គេ ) នឹងឲ្យដល់អ្នកណាម្តេចបាន ។ កាយដែលមានវិញ្ញាណប្រាសចេញហើយ មិនយូរប៉ុន្មាន គេតែងដុតក្នុងព្រៃស្មសាន ពួកញាតិដែលខ្ពើមរអើម ក៏បោះបង់ចោល ដូចជាអង្កត់ឧស ។ មាតាបិតារបស់ខ្លួន បោលសាកសពនោះឲ្យជាចំណីសត្វដទៃក្នុងព្រៃស្មសាន ខ្ពើមរអើម ផ្លូតលាង ( ខ្លួនដើរចេញទៅ ) ចំណង់បើសាធារណជន ( នឹងមិនខ្ពើម ) ដូចម្តេចកើតសត្វទាំងឡាយ តែងជ្រុលជ្រប់ក្នុងគ្រោងកាយ ជាសាកសពឥតខ្លឹមសារ ដែល

សង្ខារផ្សំផ្គុំដោយឆ្អឹងនិងសរសៃ ជាកាយស្អុយ ពេញដោយទឹកមាត់ទឹកភ្នែក ទឹកសម្បោរនិងទឹករងៃ ។ បើបុគ្គលពន្លាត់រាងកាយនោះ ធ្វើអាការខាងក្នុងនៃវាឲ្យត្រឡប់មកខាងក្រៅវិញ សូម្បីមាតារបស់ខ្លួនក៏ខ្ពើមរអើម អត់ទ្រាំនឹងក្លិនពុំបាន ។ ខ្ញុំម្ចាស់និយាយដោយឧបាយនៃប្រាជ្ញានូវខន្ធ ធាតុ អាយតនៈ ដែលសង្ខារតាក់តែងថា មានជាតិជាឫសគល់ នាំមកនូវទុក្ខ មិនជាទីពេញចិត្ត នឹងប្រាថ្នានូវកិច្ចដែលគេត្រូវដណ្តឹងដើម្បីអ្វី ។ លំពែង ៣ រយ ដែលសំលៀងថ្មីៗ គប្បីធ្លាក់ចុះលើកាយរាល់ៗថ្ងៃ ប្រសិនបើការអស់ទៅនៃទុក្ខ សូម្បីមានការលំបាក ( យ៉ាងនេះ ) អស់រយឆ្នាំ ជាការប្រសើរ ។ បុគ្គលណាដឹងព្រះពុទ្ធដីកា របស់ព្រះសាស្តាយ៉ាងនេះ ហើយបានទទួលនូវសេចក្តីលំបាក ( ការអស់ទៅនៃទុក្ខតែងមានដល់បុគ្គលនោះ ) សង្សារ ( ការអន្ទោលទៅ ) របស់បុគ្គលពាលទាំងឡាយ ដែលលំបាករឿយៗ ជាសង្សារវែងឆ្ងាយ ។ ការលំបាកគានតឹងមិនមានប្រមាណ រមែងប្រាកដក្នុងពួកទេវតា ពួកមនុស្ស ក្នុងកំណើតតិរច្ឆាន ក្នុងពួកអសុរកាយក្នុងពួកប្រេតនិងក្នុងពួកនរក ។ ក្នុងនរកមានសេចក្តីលំបាកច្រើន សត្វដែលកើតក្នុងវិនិបាត ក៏លំបាក សូម្បីក្នុងពួកទេវតាក៏មិនមានទីពឹង សេចក្តីសុខដទៃក្រៃលែងជាងសេចក្តីសុខក្នុងព្រះនិព្វានមិនមានទេ ។ បុគ្គលពួកណា ខំប្រឹងប្រែងក្នុងសាសនារបស់ព្រះទសពល ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ខំព្យាយាមលះបង់ជាតិនិងមរណៈ បុគ្គលពួកនោះ ឈ្មោះថា បានព្រះនិព្វាន បពិត្រព្រះបិតា ខ្ញុំម្ចាស់នឹងចេញបួសក្នុងថ្ងៃនេះ ប្រយោជន៍អ្វីដោយភោគៈទាំងឡាយដែលឥតខ្លឹមសារ

កាមទាំងឡាយទុកស្មើវត្ថុដែលគេខ្ជាក់ចោល ខ្ញុំម្ចាស់នឿយណាយហើយ ធ្វើឲ្យដូចដើមត្នោត មិនមានទីកើត ( ដែលបុគ្គលដកចោលហើយ ) ។

នាងសុមេធានោះ កំពុងនិយាយនឹងបិតាយ៉ាងនេះ ស្រាប់តែព្រះបាទអនិករត្តៈដែលបិតាបានថ្វាយនាងដល់ទ្រង់ ស្តេចព្រះរាជដំណើរចូលទៅដល់ដោយមានពួកកំលោះហែហម ( ព្រោះ ) ការត្រូវជណ្តឹង មានក្នុងកាលប្រាកដហើយ ។ ក្នុងកាលនោះ នាងសុមេធា កាត់នូវសក់ទាំងឡាយដែលមានពណ៌ខ្មៅរលើបស្លូតទន់ ដោយព្រះខាន់ហើយបិទទ្វារប្រាសាទរួចចូលបឋមជ្ឈាន ។ នាងសុមេធា កំពុងតែចូលសមាបត្តិ ចម្រើននូវអនិច្ចសញ្ញាលើប្រាសាទ គាប់ចួនស្តេចអនិករត្តៈ ក៏យាងមកដល់នគរ ។ នាងសុមេធានោះកំពុងតែធ្វើទុកក្នុងចិត្ត ( នូវអនិច្ចសញ្ញា ) ស្តេចអនិករត្តៈដែលស្អិតស្អាងព្រះអង្គ ដោយគ្រឿងអលង្ការជាវិការៈកែវមណីនិងមាស ក៏ឡើងមកដោយរួសរាន់ ហើយធ្វើអញ្ជលីអង្វរនាងសុមេធាថា ។ អាជ្ញាក្នុងរាជ្យរបស់យើង ទ្រព្យនិងឥស្សរិយយស ( ក៏មានច្រើន ) ភោគសម្បត្តិទាំងឡាយ នាំមកនូវសេចក្តីសុខទាំងខ្លួននាង សោត ក៏នៅក្រមុំ នាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ ( ព្រោះថា ) កាមសុខក្នុងលោក គេរកបានដោយកម្រណាស់ ។ រាជសម្បត្តិយើងប្រគល់ផ្តាច់ឲ្យនាង នាងចូរប្រើប្រាស់នូវភោគសម្បត្តិទាំងឡាយ ចូរឲ្យនូវទានចុះ នាងកុំតូចចិត្តឡើយ មាតាបិតារបស់នាងជាទុក្ខ ។

នាងសុមេធាជាស្ត្រីមិនត្រូវការដោយកាម មានមោហៈទៅប្រាសហើយ ក៏ទូលតបស្តេចអនិករត្តៈនោះថា ព្រះអង្គកុំត្រេកត្រអាលចំពោះកាមទាំងឡាយ

ព្រះអង្គចូរឃើញទោសក្នុងកាមទាំងឡាយវិញ ។ ព្រះរាជាទ្រង់ព្រះនាមមន្ធាតុ ជាធំលើទ្វីបទាំងបួន ជាបុគ្គលប្រសើរផុតជាងពួកជនអ្នកបរិភោគកាម ទ្រង់មិនឆ្អែតឆ្អន់ ( ដោយកាមទាំងឡាយ ) ទ្រង់ទិវង្គតទៅ សេចក្តីប្រាថ្នារបស់ស្តេចនោះនៅតែមិនពេញគ្រប់គ្រាន់នៅឡើយ ។ ភ្លៀងគប្បីបង្អុរចុះនូវរតនៈទាំងឡាយ ៧ ប្រការជុំវិញគ្រប់ទិសទាំង ១០ សេចក្តីឆ្អែតចំពោះកាមទាំងឡាយក៏នៅតែមិនល្មម ពួកនរជនរមែងស្លាប់ទៅទាំងមិនឆ្អែត ។ កាមទាំងឡាយប្រៀបដូចជាដាវនិងឈើស្រួច កាមទាំងឡាយប្រៀបដូចជាក្បាលនៃពស់ ឬប្រៀបដូចជាគប់ភ្លើង គ្រៀមក្រោះដូចជាពងឆ្អឹង តែងដុតកម្តៅរឿយៗ ។ កាមទាំងឡាយមិនទៀងទាត់ មិនឋិតថេរ មានទុក្ខច្រើន មានពិសខ្លាំង មានសេចក្តីតានតឹងជាឫសគល់ មានសេចក្តីទុក្ខជាផល ដូចជាដុំដែកដែលកំពុងឆេះ ។ កាមទាំងឡាយប្រៀបដូចជាផ្លែឈើ ឬប្រៀបដូចដុំសាច់ នាំមកនូវទុក្ខ កាមទាំងឡាយដូចការយល់សប្តិ ជាគ្រឿងបញ្ឆោត ដូចជារបស់ខ្ចីគេ ។ កាមទាំងឡាយដូចជាលំពែងនិងដែកស្រួច ដូចជារោគ ឬដូចជាបូស ជាគ្រឿងតានតឹង ចង្អៀតចង្អល់ កាមទាំងឡាយប្រាកដស្មើដោយរណ្តៅនៃរងើកភ្លើង មានសេចក្តីតានតឹងជាឫស ជាភ័យ ជាខ្មាំង ។ កាមទាំងឡាយ មានសេចក្តីទុក្ខច្រើនយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសភាវៈធ្វើនូវសេចក្តីអន្តរាយ សូមព្រះអង្គយាងទៅវិញចុះ សេចក្តីស្និទ្ធស្នាលក្នុងភព របស់ខ្ញុំម្ចាស់មិនមានទេ ។ បុគ្គលដទៃនឹងធ្វើនូវប្រយោជន៍ដូចម្តេចដល់ខ្ញុំម្ចាស់កើត កាលបើក្បាលរបស់ខ្លួនត្រូវភ្លើងឆេះ កាលបើជរាមរណៈកំពុងជាប់តាម ខ្ញុំ

ម្ចាស់ត្រូវប្រឹងប្រែងដើម្បីកម្ចាត់បង់នូវជរាមរណៈនោះ ។

នាងសុមេធានេះ លុះឃើញមាតាបិតា និងស្តេចអនិករត្តៈដែលមកមិនទាន់ដល់ទ្វារ កំពុងគង់យំលើផែនដី ក៏ទូលនូវពាក្យនេះថា សង្សាររបស់បុគ្គលអន្ធពាលដែលយំទួញញយៗ ចំពោះសេចក្តីស្លាប់របស់បិតា សេចក្តីស្លាប់របស់បងប្អូន និងសេចក្តីស្លាប់របស់ខ្លួនក្នុងសង្សារវដ្ត ដែលគេមិនអាចដឹងទីបំផុតបាន ជាសង្សារវែងឆ្ងាយ ។ សូមទ្រង់ទាំងឡាយ រឭកនូវទឹកភ្នែក ទឹកដោះ និងឈាម កាលទ្រង់អន្ទោលទៅព្រោះសង្សារដែលគេមិនអាចដឹងទីបំផុតបាន សូមទ្រង់រឭកនូវគំនរឆ្អឹងទាំងឡាយរបស់ពួកសត្វដែលអន្ទោលទៅមកៗ ។ សូមទ្រង់រឭកដល់ទឹកភ្នែក ទឹកដោះ និងឈាម ដែលប្រៀបធៀបនឹងសមុទ្រធំទាំង ៤ សូមទ្រង់រឭកនូវគំនរនៃឆ្អឹងទាំងឡាយ ក្នុងកប្បមួយៗ ដែលស្មើនឹងភ្នំវេបុល្លៈ ។ ដុំដីប៉ុនគ្រាប់ក្រពៅ ដែលបុគ្គលលញ់ដីអស់ទាំងជម្ពូទ្វីប ក៏មិនល្មម គឺតិចជាងមាតាបិតាទាំងឡាយរបស់សត្វ កាលអន្ទោលទៅក្នុងសង្សារដែលគេមិនអាចដឹងទីបំផុតបាន សូមទ្រង់រឭកនូវស្មៅកំណាត់ឈើ មែកឈើនិងស្លឹកឈើដែលគេនាំមកប្រៀបធៀបខ្ទាច់ទាំងឡាយ ( របស់ស្មៅជាដើមនោះ ) ប្រមាណបួនធ្នាប់ៗ ក៏មិនល្មមស្មើនឹងបិតានិងជីតាទាំងឡាយ ព្រោះសង្សារ មានទីបំផុត គេមិនអាចដឹងបាន ។ សូមទ្រង់នឹកមើលនូវអណ្តើកខ្វាក់និងប្រហោងនឹម ( ដែលខ្យល់បក់បន្ទិល ) ទៅក្នុងសមុទ្រ អំពីត្រើយខាងកើតទៅត្រើយដទៃទៀត និងក្បាលអណ្តើកនោះដែលចូលទៅ ( ក្នុងប្រហោងនឹម ) នេះជាសេចក្តីឧបមាក្នុងការបានអត្តភាពជា

មនុស្ស ។ សូមទ្រង់ពិចារណានូវរូបរបស់គ្រោងកាយជាទោសឥតខ្លឹមសារ មាន ឧបមាដូចដុំនៃពពុះទឹក សូមទ្រង់ឃើញនូវខន្ធទាំងឡាយថាជាសភាវៈមិនទៀង ទាត់ សូមទ្រង់រឭកនូវនរកទាំងឡាយដែលមានសេចក្តីទុក្ខក្តៅជាច្រើន ។ សូមទ្រង់រឭកនូវសត្វទាំងឡាយ ដែលញ៉ាំងទីស្មសានឲ្យចម្រើនរឿយៗ ក្នុង ជាតិទាំងឡាយនោះៗ សូមរឭកនូវភ័យក្នុងការចិញ្ចឹមពោះផង សូមរឭកនូវ អរិយសច្ចទាំង ៤ ផង ។ កាលបើអមតធម៌មាន ប្រយោជន៍អ្វីដោយហេតុ ក្តៅផ្សា ៥ យ៉ាង ដែលទ្រង់សោយហើយ ដ្បិតតម្រេកក្នុងកាមទាំងអស់ ក្តៅផ្សាក្រៃពេក ព្រោះហេតុក្តៅផ្សា ៥ យ៉ាង ។

កាលបើអមតធម៌មាន ទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយដែល ជារបស់ក្តៅក្រហាយ ត្បិតតម្រេកក្នុងកាមទាំងអស់ ( ត្រូវភ្លើង ១១ កង ) ឆេះពុះឡើង ញាប់ញ័រ ក្តៅ សព្វ ។ កាលបើធម៌ដែលឥតសត្រូវ ( នេក្ខម្មៈ ) មាន ទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយដែលមានសត្រូវច្រើន កាម ទាំងឡាយជាសាធារណៈ មានសត្រូវច្រើន គឺសត្រូវអំពីស្តេច ភ្លើង ចោរ ទឹកនិងបុគ្គលមិនជាទីស្រឡាញ់ ។

កាលបើព្រះនិព្វានមាន ទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយដែល ជាគ្រឿងសម្លាប់ ជាគ្រឿងចង ព្រោះថាកាមទាំងឡាយតែងមានគ្រឿងសម្លាប់ និងគ្រឿងចង ពួកសត្វនេះតែងទទួលសេចក្តីទុក្ខទាំងឡាយ ព្រោះតែការប្រាថ្នា កាម ។ គប់ស្មៅដែលភ្លើងកំពុងឆេះ តែងឆេះនូវបុគ្គលអ្នកកាន់មិនលែងចេញ ព្រោះថាកាមទាំងឡាយ ប្រៀបដូចជាគប់ភ្លើងតែងឆេះនូវពួកសត្វ ដែលមិន

លែងចេញ ។ សូមទ្រង់កុំលះបង់នូវសេចក្ដីសុខដ៏ធំទូលាយ ព្រោះហេតុតែសុខក្នុងកាមបន្តិចបន្តួចឡើយ សូមទ្រង់កុំក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ដូចជាត្រីលេបនូវសន្ទូច ។ សូមទ្រង់កុំប្រាស់ប្រាល់ ព្រោះតែកាមទាំងឡាយ ដូចសុនខដែលគេចងភ្ជាប់នឹងបង្គោល ឱ សត្វទាំងឡាយជាអ្នកស្រេកឃ្លាន តែងធ្វើតាមសេចក្ដីប្រាថ្នា ដូចជាពួកចណ្ឌាល ( ព្រានបណ្ដើរគោ្ក ដល់នូវសេចក្ដីវិនាសព្រោះបាន ) នូវគោ្ក ។ បើទ្រង់ប្រកបខ្លួនក្នុងកាម នឹងរងទុក្ខមិនមានប្រមាណផង រងទោមនស្សក្នុងចិត្តដ៏ច្រើនផង សូមទ្រង់លះបង់កាមទាំងឡាយ ជារបស់មិនទៀងចេញ ។ កាលបើព្រះនិព្វានជាធម្មជាតមិនចេះចាស់មាន ទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយជារបស់ចាស់កំណើតទាំងអស់ក្នុងភពទាំងពួង ( សុទ្ធតែ ) ត្រូវមរណៈនិងព្យាធិរឹបជាន់ ។ ព្រះនិព្វាននេះ មិនចាស់ មិនស្លាប់ ព្រះនិព្វាននេះ ទាំងមិនចាស់ មិនស្លាប់ មិនមានសោក មិនមានសត្រូវ មិនចង្អៀត មិនភ្លាំងភ្លាត់ មិនមានភ័យ មិនក្ដៅរោលរាល ។ អមតនិព្វាននេះ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ច្រើនរូបបានហើយ មិនតែប៉ុណ្ណោះទេ ព្រះនិព្វាននេះ គេគប្បីបានក្នុងកាលសព្វថ្ងៃនេះ បុគ្គលណាព្យាយាមដោយឧបាយប្រាជ្ញា ( បុគ្គលនោះរមែងបាននូវព្រះនិព្វាន ) តែបុគ្គលដែលមិនមានសេចក្ដីប្រឹងប្រែង មិនអាចបាននូវព្រះនិព្វានឡើយ ។ នាងសុមេធាមិនបាននូវសេចក្ដីត្រេកអរក្នុងសង្ខារ ពោលយ៉ាងនេះ នាងសុមេធាកាលពន្យល់ស្ដេចអនិករត្តៈ ហើយក៏បោះសក់ទាំងឡាយចោលលើផែនដី ។ ស្ដេចអនិករត្តៈនោះ ក្រោកឡើងផ្គងអញ្ជលី អង្វរ

បិតារបស់នាងសុមេធានោះថា សូមព្រះអង្គអនុញ្ញាតបើករាជបុត្រីឈ្មោះនាងសុមេធាឲ្យបួសចុះ ដើម្បីឲ្យនាងឃើញនូវព្រះនិព្វានដែលជាគុណជាតទៀងទាត់ ។

នាងសុមេធានោះ ដែលជាស្ត្រីតក់ស្លុតចំពោះសោកនិងភ័យ លុះមាតាបិតាបើកឲ្យ ក៏បួស ហើយសិក្សានូវអគ្គផល បានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ ។ ព្រះនិព្វាននោះជាគុណជាតអស្ចារ្យចម្លែក បានកើតមានដល់រាជកញ្ញា លុះក្នុងកាលជាទីបំផុត ( ទៀបនឹងបរិនិព្វាន ) នាងបានសំដែងនូវបុព្វេនិវាសចរិតថា ។ កាលព្រះមានព្រះភាគ ទ្រង់ព្រះនាម កោនាគមនៈ ( ត្រាស់ឡើងក្នុងលោក ) យើងជាសម្លាញ់នឹងគ្នាទាំងបីនាក់ ( គឺនាងធនញ្ជានី ១ នាងខេមា ១ ខ្ញុំ ១ ) បានថ្វាយវិហារទានក្នុងអារាមនៃសង្ឃ ជានិវេសន៍ដ៏ថ្មី ។ ( ដោយអានិសង្សនៃវិហារទាននេះ ) យើងទាំងឡាយ បានទៅកើតក្នុងពួកទេវតា ១០ ដង ១០០ ដង ១.០០០ ដង ១០.០០០ ដង នឹងបាច់និយាយទៅថ្វីក្នុងពួកមនុស្ស ។ យើងជាអ្នកមានឫទ្ធិច្រើនក្នុងពួកទេវតានឹងបាច់និយាយទៅថ្វីក្នុងពួកមនុស្ស ខ្ញុំបានកើតជាស្ត្រីកែវ ជាអគ្គមហេសីនៃស្តេចដែលមានរតនៈទាំង ៧ ប្រការ អានិសង្សនៃវិហារទាននោះជាហេតុ អានិសង្សនោះជាប្រភព ( ដែនកើត ) អំណោយទាននោះ ជាឫសគល់ដ៏ពេញចិត្តក្នុងសាសនា អំណោយទាននោះ ជាការជួបជុំមុនដំបូង អំណោយទាននោះ ជាហេតុឲ្យរលត់កិលេស ( ព្រះនិព្វាន ) របស់ខ្ញុំដែលជាអ្នកត្រេកអរក្នុងធម៌ ។ ពួកជនណា ជឿនូវព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះ

អង្គមានប្រាជ្ញាមិនថោកថយ ពួកជននោះ រមែងពោលយ៉ាងនេះថា ពួកជននៀយណាយក្នុងភពតីសង្សារវដ្ដ លុះនៀយណាយហើយប្រាសចាកតម្រេក ។

សុមេធាថេរី ។

ចប់មហានិបាត ។

ថេរីគាថានេះ មានគាថា ៤៨០ និង ១៤ គាថាទៀត ថេរីៗ ទាំងអស់នោះ ៧១ អង្គ ជាភិក្ខុនីអស់អាសវៈ ។

ចប់ ថេរីគាថា ។

# អដ្ឋកថា

# ថេរីគាថា មហានិបាត

## សុមេធាថេរីគាថា

[ ៣៣៨ ] ក្នុងមហានិបាត គាថារបស់ព្រះនាងសុមេធាថេរី មានពាក្យផ្ដើមថា **មន្តាវតិយា នគរេ** ដូច្នេះជាដើម ។

បានឮថា កុលធីតារូបនេះ ក៏ជាអ្នកមានបុញ្ញាធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ បម្រើនទូវធម្មសម្ភារ ដែលជាគ្រឿងតាក់តែងវិមោក្ខដោយគោរព ។ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកោនាគមនៈ កើតក្នុងផ្ទះមានត្រកូល

ដល់នូវកាលជាអ្នកដឹងក្តីហើយ មានអធ្យាស្រ័យជាមួយពួកកុលធីតាដែលជាសម្លាញ់របស់ខ្លួន រួមគ្នាសាងអារាមធំ វេរថ្វាយសង្ឃដែលមានព្រះពុទ្ធជាប្រធាន ព្រោះបុញ្ញកម្មនោះ កាលបែកធ្លាយទម្លាយខន្ធ នាងក៏ទៅកើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស សោយទិព្វសម្បត្តិដរាបដល់អស់អាយុក្នុងឋានសួគ៌នោះ ចុតិអំពីនោះហើយ កើតក្នុងស្ថានសួគ៌ជាន់យាមា ចុតិអំពីនោះហើយទៅកើតស្ថានសួគ៌ជាន់តុសិត ចុតិអំពីតុសិត ក៏ទៅកើតក្នុងស្ថានសួគ៌ជាន់និម្មានរតី ចុតិចាកស្ថានសួគ៌ជាន់និម្មានរតី ក៏ទៅកើតក្នុងស្ថាន សួគ៌ជាន់បរនិម្មិតវសវត្តី នាងកើតក្នុងស្ថានសួគ៌កាមាវចរទាំង ៥ ជាន់ តាមលំដាប់ ដូចពោលមកដូច្នេះ បានជាមហេសីរបស់ទេវរាជក្នុងស្ថានសួគ៌ជាន់នោះៗ ចុតិអំពីនោះហើយ ក្នុងសាសនាព្រះមានព្រះភាគព្រះនាមថាកស្សបៈ កើតជាធីតារបស់សេដ្ឋីអ្នកមានសម្បត្តិច្រើន ដឹងក្តីតាមលំដាប់ ហើយក៏ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា បានធ្វើបុញ្ញកម្មដ៏ឧឡារចំពោះព្រះរតនត្រ័យ ។

ក្នុងកាលនោះ នាងចិញ្ចឹមជីវិតប្រកបដោយធម៌ ត្រេកអរក្នុងកុសលធម៌ដរាបដល់អស់ជីវិតចុតិអំពីនោះហើយកើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្សអន្ទោលទៅមកក្នុងសុគតិប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទនេះ កើតជាបុត្រីរបស់ព្រះបាទកោញ្ចៈក្នុងនគរមន្តាវតី ព្រះជនកព្រះជននីបានថ្វាយព្រះនាមថា សុមេធា ។ លុះព្រះនាងចម្រើនព្រះជន្មវស្សា ព្រះជននីក៏ប្រឹក្សាគ្នាថា នឹងថ្វាយព្រះនាងដល់ព្រះបាទអនិករត្តៈ ក្នុងនគរវារណាវតី តាំងអំពីព្រះនាងនៅជាទារិកា ព្រះនាងនិងរាជធីតាដទៃដែលមានវ័យស្របាលគ្នា មួយអន្លើដោយពួកទាសី នាំគ្នាទៅ

កាន់សម្នាក់ភិក្ខុនី ស្តាប់ធម៌ក្នុងសម្នាក់ភិក្ខុនីហើយ ក៏កើតសេចក្តីសង្វេគក្នុងសង្សារវដ្ត ព្រោះបំពេញបារមីមកអស់កាលយូរ ព្រះនាងជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា កាលចម្រើនព្រះជន្មវស្សា ក៏មានព្រះទ័យបែរចេញអំពីកាមទាំងឡាយ ដោយហេតុនោះ ព្រះនាងបានស្តាប់ការប្រឹក្សា របស់ព្រះជនកព្រះជននី និងព្រះញាតិ ទើបមានព្រះសវនីយ៍ថា ខ្ញុំមិនបំណងកិច្ចក្នុងឃរាវាស ខ្ញុំនឹងបួស ព្រះជនកព្រះជននីប្រកបព្រះនាងទុកក្នុងឃរាវាសកិច្ច សូម្បីអង្វរដោយប្រការផ្សេងៗ ក៏មិនអាចធ្វើព្រះនាងឲ្យយល់ព្រមបាន ។ ព្រះនាងត្រិះរិះថា អញនឹងបានការបួសដោយវិធីនេះ ហើយទាញព្រះខ័នកាត់ព្រះកេសាដោយខ្លួនឯង ព្រះនាងប្រារព្ធកេសាទាំងនោះ ផ្តើមមនសិការដាក់ចិត្តជារបស់បដិកូល ធ្វើអសុភនិមិត្តឲ្យកើតឡើង ក៏សម្រេចបឋមជ្ឈានក្នុងទីនោះឯងព្រោះព្រះនាងបំពេញបារមីមកហើយក្នុងជាតិនោះៗនិងព្រោះធ្លាប់ស្តាប់វិធីមនសិការក្នុងសម្នាក់ភិក្ខុនី ។ ព្រះនាងលុះសម្រេចបឋមជ្ឈានហើយ ក៏ធ្វើរាជត្រកូលទាំងអស់ មួយអន្លើដោយជនជាបរិវារតាំងអំពីព្រះជនកព្រះជននី ដែលមកដោយព្រះអង្គឯង ដើម្បីដឹកនាំឲ្យនាងនៅគ្រប់គ្រងផ្ទះឲ្យជ្រះថ្លាក្រៃលែងឡើងក្នុងសាសនា ហើយចេញអំពីព្រះរាជមន្ទីរ ទៅកាន់សម្នាក់ភិក្ខុនី សូមបួស កាលបួសហើយ ក៏ផ្តើមវិបស្សនា មានព្រះញាណចាស់ក្លាដោយប្រពៃពិតមិនយូរប៉ុន្មាន ក៏សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ៤ ព្រោះធម៌ទាំងឡាយដែលជួយអប់រំបន្ទុំវិមុត្តិ ធ្វើឲ្យសម្រេចនូវគុណវិសេស ។ សមដូចគាថាព័ន្ធដែលលោកពោលទុកក្នុងអបទានថា

កាលព្រះមានព្រះភាគព្រះនាមកោនាគមនៈ គង់នៅក្នុងសង្ឃារាមយើងជាស្ត្រី ៣ នាក់ ជាសំឡាញ់នឹងគ្នា បានថ្វាយនូវវិហារទាន ។ ពួកយើងបានទៅកើតក្នុងពួកទេវតាអស់ ១០ ជាតិផង ១០០ ជាតិផង ១ ម៉ឺនជាតិផង ចាំបាច់និយាយថ្វីក្នុងការកើតជារបស់មនុស្ស ។ ខ្ញុំជាស្រីមានឫទ្ធិច្រើនក្នុងពួកទេវតាទាំងឡាយ ចាំបាច់និយាយថ្វីក្នុងការកើតជារបស់មនុស្ស ខ្ញុំកើតជាស្រីកែវ ធ្វើជាមហេសីរបស់ស្តេចមានរតនៈ ៧ ។ ជន ៣ នាក់នោះ គឺនាងធនញ្ជានី ១ នាងខេមា ១ នឹងខ្ញុំ ១ បានកើតក្នុងត្រកូលដែលសម្រេចល្អដោយកុសល ដែលយើងបានសន្សំហើយក្នុងភពនោះ ។ ខ្ញុំបានកសាងអារាមល្អ ដ៏ប្រដាប់ដោយអវយវៈ ( គ្រឿងតាក់តែង ) គ្រប់យ៉ាង ហើយមានចិត្តរីករាយ វេរថ្វាយដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ ដោយផលនៃកុសលកម្មនោះ ខ្ញុំចូលទៅកើតក្នុងភពណាៗតែងដល់នូវភាពដ៏ប្រសើរក្នុងទេវលោកក្នុងមនុស្សលោកក៏ដូចគ្នា។ ក្នុងកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយទ្រង់កើតឡើង។ កាលនោះ ស្តេចក្នុងដែនកាសីទ្រង់ព្រះនាមកិកី ជាឥស្សរៈរបស់ជនក្នុងពារាណសីបុរីដ៏ឧត្តម ជាឧបដ្ឋាកនៃព្រះកស្សបៈព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ព្រះរាជាអង្គនោះ មានរាជ

កញ្ញាជាធីតា ៧ អង្គ ជាស្រីឋិតនៅក្នុងសេចក្ដីសុខ ត្រេកអរក្នុងការបម្រើព្រះពុទ្ធ ធីតាទាំងនោះ ប្រព្រឹត្តព្រហ្មចរិយធម៌ ។ ខ្ញុំជាសំឡាញ់នៃធីតាទាំងនោះ មានចិត្តតម្កល់មាំក្នុងសីល ឲ្យនូវទានទាំងឡាយដោយគោរព ប្រព្រឹត្តនូវវត្តក្នុងផ្ទះ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវសេចក្ដីប្រាថ្នានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំច្យុតអំពីឋាននោះមក ក៏បានទៅកើតក្នុងឋានយាមៈ លុះច្យុតអំពីឋានយាមៈនោះ បានទៅកើតក្នុងឋានតុសិត លុះច្យុតអំពីតុសិតនោះ បានទៅកើតក្នុងឋាននិម្មានរតី លុះច្យុតអំពីនិម្មានរតីនោះ បានទៅកើតក្នុងវសវត្តីបុរី ។ ខ្ញុំជាស្រីប្រកបដោយបុញ្ញកម្មនោះ ទៅកើតក្នុងឋានណាៗ តែងបាននូវភាពជាមហេសី របស់ស្ដេចទាំងឡាយក្នុងឋាននោះៗ ។ លុះខ្ញុំច្យុតអំពីអត្តភាពនោះហើយ បានមកកើតជាមនុស្ស ក៏បាននូវភាពជាមហេសីនៃស្ដេចចក្រពត្តិទាំងឡាយផងនៃស្ដេចដែលមានមណ្ឌលទាំងឡាយផង ។ ខ្ញុំទទួលនូវសម្បត្តិក្នុងទេវតាទាំងឡាយផង ក្នុងមនុស្សទាំងឡាយផង ជាស្ត្រីមានសេចក្ដីសុខ ក្នុងទីទាំងពួង អន្ទោលទៅអស់ច្រើនជាតិ ។ ហេតុនោះក្ដី ដើមកំណើតនោះក្ដី ឫសគល់នោះក្ដី សេចក្ដីគាប់ចិត្តក្នុងសាសនានោះក្ដី ការប្រជុំចុះ ជាដំបូងនោះ

ក្តី ធម្មជាតទាំងនោះបានរលត់ហើយ ដោយសេចក្តីត្រេកអរ ក្នុងធម៌ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ។បេ។ ទាំង សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ដូច្នេះ ។

កាលសម្រេចអរហត្តហើយ ព្រះនាងសុមេធាថេរី ពិចារណាបដិបទា របស់ខ្លួនហើយ ទើបពោលគាថាជាឧទានថា

នាងសុមេធា ជាធីតានៃអគ្គមហេសីរបស់ព្រះរាជា ទ្រង់ព្រះ នាមកោញ្ចៈ ក្នុងនគរឈ្មោះមន្តាវតី ជាស្ត្រីដែលព្រះអរិយៈ អ្នកធ្វើសាសនា ឲ្យជ្រះថ្លាហើយ ។ នាងសុមេធាជាស្រីមាន សីល ជាធម្មកថិកាដ៏វិចិត្រ ជាពហុស្សូត ជាស្រីបានបទ ក្នុង ព្រះពុទ្ធសាសនា ចូលទៅជិតព្រះមាតាបិតា ហើយទូលថា សូមទ្រង់ទាំងពីរស្តាប់ ( ពាក្យខ្ញុំម្ចាស់ ) ។ ខ្ញុំម្ចាស់ជាអ្នក ត្រេកអរចំពោះព្រះនិព្វាន ភពសូម្បីជាទិព្វ ក៏ជារបស់មិនទៀង ទាត់ នឹងចាំបាច់ពោលទៅថ្វីដល់កាមទាំងឡាយដែលជារបស់ សោះសូន្យ មានការត្រេកអរតិច មានសេចក្តីចង្អៀតចង្អល់ ច្រើន ។ ពួកជនពាលឈ្លក់ក្នុងកាមទាំងឡាយណា កាមទាំង ឡាយនោះជាសភាវៈខ្លោចផ្សា ឧបមាដូចជាអាសិរពិស ពួក ជនពាលទាំងនោះ សឹងពេញណែនត្រៀបត្រាក្នុងនរក រងទុក្ខ លំបាកអស់កាលដ៏អង្វែង ពួកជនពាលមានកម្មដ៏លាមក មាន គំនិតអាក្រក់ មិនសង្រួមកាយវាចាចិត្ត រមែងសង្រេងសង្រែ

ក្នុងវិនិបាត ( អបាយ ) សព្វៗកាល ។ ជនពាលទាំងនោះ ជាអ្នកឥតប្រាជ្ញា ឥតចេតនា ត្រូវតណ្ហាជាហេតុនៃទុក្ខរួបរឹត មិនដឹង ( នូវចតុសច្ចធម៌ ) ដែលព្រះសម្ពុទ្ធទ្រង់សំដែងរមែង មិនត្រាស់ដឹងនូវអរិយសច្ចទាំងឡាយ ។ បពិត្រព្រះមាតាជន ទាំងឡាយជាច្រើននាក់ណាស់ ដែលមិនដឹងនូវសច្ចធម៌ ដ៏ជា ធម៌ គឺព្រះពុទ្ធដ៏ប្រសើរ ទ្រង់សំដែងហើយត្រេកអរតែនឹងភព ពេញចិត្តតែនឹងការកើតក្នុងពួកទេវតា ។ សូម្បីការកើតក្នុងពួក ទេវតាក៏មិនទៀង កាលបើភពមិនទៀង ពួកជនពាលក៏នៅតែ មិនតក់ស្លុតនឹងភពដែលសត្វត្រូវកើតញយៗ ។ វិនិបាត ៤ និង គតិ ២ បុគ្គលគប្បីបានដូចម្ដេចកើត បព្វជ្ជារបស់ពួកសត្វ វិនិបាតក្នុងនរក មិនមានឡើយ ។ សូមទ្រង់ទាំងពីរអនុញ្ញាត ឲ្យខ្ញុំម្ចាស់ទៅបួស ក្នុងសាសនានៃព្រះទសពល ខ្ញុំម្ចាស់នឹងជា ស្ត្រីមានសេចក្ដីខ្វល់ខ្វាយតិច ប្រឹងប្រែងដើម្បីលះបង់នូវជាតិ និងមរណៈ ។ ប្រយោជន៍អ្វីដោយភពដែលអ្នកផងត្រេកត្រ- អាល ប្រយោជន៍អ្វីដោយកាយជាទោស ឥតខ្លឹមសារ សូម ទ្រង់អនុញ្ញាត ខ្ញុំម្ចាស់នឹងបួសដើម្បីរំលត់នូវភវតណ្ហា ។ ការ កើតឡើងនៃព្រះពុទ្ធទាំងឡាយ ( ខ្ញុំម្ចាស់បានចួបប្រទះហើយ ) កាលមិនមែនជាខណៈ ខ្ញុំម្ចាស់វៀរស្រឡះហើយ ខណៈខ្ញុំម្ចាស់ បានហើយ ខ្ញុំម្ចាស់មិនប្រទូស្តនូវសីលនិងព្រហ្មចរិយៈ រហូត

អស់មួយជីវិត ។

លុះនាងសុមេធា ក្រាបទូលយ៉ាងនេះ គ្រានោះព្រះមាតាបិតា បានមានបន្ទូលនឹងនាងថា យើងទាំងឡាយជាគ្រហស្ថ សុទ្ធតែលុះក្នុងអំណាចនៃសេចក្ដីស្លាប់នឹងលះបង់មិនបានទេ។ មាតាជាទុក្ខស្រែកយំ បិតាក៏ជាទុក្ខ ត្រូវសេចក្ដីសោកស្ដាយគ្របសង្កត់ដូចគ្នា ប្រឹងប្រែងសន្រួបសន្រួមធីតានោះដែលដួលចុះលើផែនដីនាផ្ទៃប្រាសាទថា ។

ម្នាលកូនស្រី ចូរនាងក្រោកឡើង ប្រយោជន៍អ្វីដោយការសោក ( ដើម្បីចង់បួស ) យើងបានថ្វាយនាងដល់ស្ដេចទ្រង់ព្រះនាមអនិករត្តៈ ជាស្ដេចមានរូបល្អ ក្នុងនគរឈ្មោះវារណវតីហើយ ។ នាងនឹងបានជាអគ្គមហេសី នឹងបានជាភរិយារបស់ស្ដេចអនិករត្តៈ នៃកូនស្រី សីល ព្រហ្មចរិយធម៌និងបព្វជ្ជាគេធ្វើបានកម្រណាស់ ។ អាណាចក្រក្នុងរាជ្យ ( នៃស្ដេចអនិករត្តៈ ) ទ្រព្យនិងឥស្សរិយយស ( ក៏មានច្រើន ) ភោគសម្បត្តិទាំងឡាយនាំមកនូវសេចក្ដីសុខ ទាំងខ្លួននាងក៏នៅក្រមុំ ព្រោះហេតុនោះ នាងចូរប្រើប្រាស់ភោគសម្បត្តិ តាមប្រាថ្នាចុះ ម្នាលកូនស្រី កិច្ចដែលគេត្រូវដណ្ដឹង ចូរមានដល់នាង ។

គ្រានោះ នាងសុមេធាក្រាបទូលមាតាបិតានោះថា ទ្រព្យទាំងឡាយប្រាកដដូច្នេះ ចូរកុំមាន ( ដល់ខ្ញុំម្ចាស់ ) ភពជា

របស់គ្មានខ្លឹមសារ បព្វជ្ជាឬមរណៈចូរមានដល់ខ្ញុំម្ចាស់ ព្រោះហេតុនោះ កិច្ចដែលគេត្រូវដណ្តឹង ( ចូរកុំមានដល់ខ្ញុំម្ចាស់ឡើយ ) ។ ( សរីរៈនេះ ) ដូចជាដង្កូវ ជាកាយស្អុយ មិនស្អាត មានក្លិនផ្សាយទៅគួរឲ្យខ្ពើម ដូចជាការុង ជាវិការនៃស្បែកពេញដោយសាកសពពេញដោយរបស់មិនស្អាត ដែលហូរចេញក្នុងកាលម្តងៗ ។ ខ្ញុំម្ចាស់ដឹងនូវសរីរៈនោះថា ដូចជាអ្វីមួយ ដែលបូកលាបដោយសាច់និងឈាម ជារបស់គួរខ្ពើមក្រែពេក ជាលំនៅនៃហ្វូងដង្កូវ ជាចំណីនៃសត្វស្លាប ជាសាកសព ( គេ ) នឹងឲ្យដល់អ្នកណាម្តេចបាន ។ កាយដែលមានវិញ្ញាណប្រាសចេញហើយ មិនយូរប៉ុន្មាន គេតែងដុតក្នុងព្រៃស្មសាន ពួកញាតិដែលខ្ពើមរអើម ក៏បោះបង់ចោល ដូចជាអង្កត់ឧស ។ មាតាបិតារបស់ខ្លួន ចោលសាកសពនោះឲ្យជាចំណីសត្វដទៃក្នុងព្រៃស្មសាន ខ្ពើមរអើម ងូតលាង ( ខ្លួនដើរចេញទៅ ) ចំណាំបើសាធារណជន ( នឹងមិនខ្ពើម ) ដូចម្តេចកើត សត្វទាំងឡាយតែងជ្រុលជ្រប់ក្នុងគ្រោងកាយជាសាកសពឥតខ្លឹមសារដែលសង្ខារផ្សំផ្គុំដោយឆ្អឹងនិងសរសៃ ជាកាយស្អុយ ពេញដោយទឹកមាត់ ទឹកភ្នែក ទឹកសម្បោរ និងទឹករងៃ ។ បើបុគ្គលពន្លាត់រាងកាយនោះធ្វើអាការខាងក្នុងនៃវាឲ្យត្រឡប់មកខាងក្រៅវិញ សូម្បីមាតារបស់ខ្លួន ក៏ខ្ពើមរអើមអត់

ទ្រាំនឹងក្លិនពុំបាន ។ ខ្ញុំម្ចាស់និយាយដោយឧបាយនៃប្រាជ្ញានូវខន្ធ ធាតុ អាយតនៈ ដែលសង្ខារតាក់តែងថា មានជាតិជាឫសគល់ នាំមកនូវទុក្ខ មិនជាទីពេញចិត្ត នឹងប្រាថ្នានូវ កិច្ចដែលគេត្រូវដណ្តឹងដើម្បីអ្វី ។ លំពែង ៣ រយដែលសំលៀងថ្មីៗ គប្បីធ្លាក់ចុះលើកាយរាល់ៗថ្ងៃ ប្រសិនបើការអស់ទៅនៃទុក្ខ សូម្បីមានការលំបាក ( យ៉ាងនេះ ) អស់រយឆ្នាំ ជាការប្រសើរ ។ បុគ្គលណាដឹងព្រះពុទ្ធដីការបស់ព្រះសាស្តាយ៉ាងនេះហើយ បានទទួលនូវសេចក្តីលំបាក ( ការអស់ទៅនៃទុក្ខតែងមានដល់បុគ្គលនោះ ) សង្សារ ( ការអន្ទោលទៅ ) របស់បុគ្គលពាលទាំងឡាយ ដែលលំបាករឿយៗ ជាសង្សារវែងឆ្ងាយ ។ ការលំបាកតានតឹងមិនមានប្រមាណរមែងប្រាកដក្នុងពួកទេវតា ពួកមនុស្ស ក្នុងកំណើតតិរច្ឆាន ក្នុងពួកអសុរកាយ ក្នុងពួកប្រេតនិងក្នុងពួកនរក ។ ក្នុងនរកមានសេចក្តីលំបាកច្រើន សត្វដែលកើតក្នុងវិនិបាតក៏លំបាក សូម្បីក្នុងពួកទេវតា ក៏មិនមានទីពឹង សេចក្តីសុខដទៃក្រៃលែងជាងសេចក្តីសុខក្នុងព្រះនិព្វានមិនមានទេ ។ បុគ្គលពួកណា ខំប្រឹងប្រែងក្នុងសាសនារបស់ព្រះទសពល ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ខំព្យាយាមលះបង់ជាតិនិងមរណៈ បុគ្គលពួកនោះឈ្មោះថាបានព្រះនិព្វាន បពិត្រព្រះបិតា ខ្ញុំម្ចាស់នឹងចេញបួសក្នុងថ្ងៃ

នេះ ប្រយោជន៍អ្វីដោយភោគៈទាំងឡាយ ដែលឥតខ្លឹមសារ កាមទាំងឡាយ ទុកស្មើវត្ថុដែលគេខ្ជាក់ចោល ខ្ញុំម្ចាស់នឿយណាយហើយ ធ្វើឲ្យដូចដើមត្នោតមិនមានទីកើត ( ដែលបុគ្គលដកចោលហើយ ) ។

នាងសុមេធានោះ កំពុងនិយាយនឹងបិតាយ៉ាងនេះ ស្រាប់តែព្រះបាទអនិករត្តៈដែលបិតាបានថ្វាយនាងដល់ទ្រង់ ស្តេចព្រះរាជដំណើរចូលទៅដល់ដោយមានពួកកំលោះហែហម ( ព្រោះ ) ការត្រូវដណ្តឹងមានក្នុងកាលប្រាកដហើយ ។ ក្នុងកាលនោះ នាងសុមេធាកាត់នូវសក់ទាំងឡាយ ដែលមានពណ៌ខ្មៅរលើបស្លូតទន់ ដោយព្រះខាន់ ហើយបិទទ្វារប្រាសាទ រួចចូលបឋមជ្ឈាន ។ នាងសុមេធា កំពុងតែចូលសមាបត្តិ ចម្រើននូវអនិច្ចសញ្ញាលើប្រាសាទ គាប់ចួនស្តេចអនិករត្តៈ ក៏យាងមកដល់នគរ ។ នាងសុមេធានោះកំពុងតែធ្វើទុកក្នុងចិត្ត ( នូវអនិច្ចសញ្ញា ) ស្តេចអនិករត្តៈដែលស្អិតស្អាងព្រះអង្គ ដោយគ្រឿងអលង្ការជាវិការៈកែវមណីនិងមាស ក៏ឡើងមក ដោយរួសរាន់ ហើយធ្វើអញ្ជលីអង្វរនាងសុមេធាថា ។ អាជ្ញាក្នុងរាជ្យរបស់យើង ទ្រព្យនិងឥស្សរិយយស ( ក៏មានច្រើន ) ភោគសម្បត្តិទាំងឡាយនាំមកនូវសេចក្តីសុខ ទាំងខ្ទននាងសោតក៏នៅក្រមុំនាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ ( ព្រោះ

ថា ) កាមសុខក្នុងលោក គេរកបានដោយកម្រណាស់ ។ រាជសម្បត្តិ យើងប្រគល់ផ្តាច់ឲ្យនាង នាងចូរប្រើប្រាស់នូវភោគសម្បត្តិទាំងឡាយ ចូរឲ្យនូវទានចុះនាងកុំតូចចិត្តឡើយ មាតាបិតា របស់នាងជាទុក្ខ ។

នាងសុមេធាជាស្ត្រីមិនត្រូវការដោយកាម មានមោហៈទៅប្រាសហើយ ក៏ទូលតបស្តេចអនិករត្តៈនោះថា ព្រះអង្គកុំត្រេកត្រអាល ចំពោះកាមទាំងឡាយ ព្រះអង្គចូរឃើញទោសក្នុងកាមទាំងឡាយវិញ ។ ព្រះរាជាទ្រង់ព្រះនាមមន្ធាតុ ជាធំលើទ្វីបទាំងបួន ជាបុគ្គលប្រសើរផុត ជាងពួកជនអ្នកបរិភោគកាម ទ្រង់មិនឆ្អែតឆ្អន់ ( ដោយកាមទាំងឡាយ ) ទ្រង់ទិវង្គតទៅ សេចក្តីប្រាថ្នារបស់ស្តេចនោះ នៅតែមិនពេញគ្រប់គ្រាន់នៅឡើយ ។ ភ្លៀងគប្បីបង្អុរចុះនូវរតនៈទាំងឡាយ ៧ ប្រការ ជុំវិញគ្រប់ទិសទាំង ១០ សេចក្តីឆ្អែតចំពោះកាមទាំងឡាយ ក៏នៅតែមិនល្មម ពួកនរជនរមែងស្លាប់ទៅទាំងមិនឆ្អែត ។ កាមទាំងឡាយ ប្រៀបដូចជាដាវនិងឈើស្រួច កាមទាំងឡាយប្រៀបដូចជាក្បាលនៃពស់ ឬប្រៀបដូចជាគប់ភ្លើង គ្រៀមក្រោះដូចជារាងឆ្អឹង តែងដុតកម្តៅរឿយៗ ។ កាមទាំងឡាយមិនទៀងទាត់ មិនឋិតថេរ មានទុក្ខច្រើន មានពិសខ្លាំង មានសេចក្តីតានតឹងជាឫសគល់ មានសេចក្តីទុក្ខជាផល ដូចជាដុំ

ដែកដែលកំពុងឆេះ ។ កាមទាំងឡាយ ប្រៀបដូចជាផ្លែឈើ ឬប្រៀបដូចដុំសាច់ នាំមកនូវទុក្ខ កាមទាំងឡាយ ដូចការយល់សប្តិ ជាគ្រឿងបញ្ឆោត ដូចជារបស់ខ្ចីគេ ។ កាមទាំងឡាយដូចជាលំពែងនិងដែកស្រួច ដូចជារោគ ឬដូចជាបូសជាគ្រឿងតានតឹង ចង្អៀតចង្អល់ កាមទាំងឡាយប្រាកដស្មើដោយរណ្ដៅនៃរងើកភ្លើង មានសេចក្ដីតានតឹងជាឫស ជាភ័យជាខ្មាំង ។ កាមទាំងឡាយ មានសេចក្ដីទុក្ខច្រើនយ៉ាងនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាសភាវៈធ្វើនូវសេចក្ដីអន្តរាយ សូមព្រះអង្គយាងទៅវិញចុះ សេចក្ដីស្និទ្ធស្នាលក្នុងភពរបស់ខ្ញុំម្ចាស់មិនមានទេ ។ បុគ្គលដទៃនឹងធ្វើនូវប្រយោជន៍ដូចម្ដេចដល់ខ្ញុំម្ចាស់កើត កាលបើក្បាលរបស់ខ្លួនត្រូវភ្លើងឆេះ កាលបើជរាមរណៈកំពុងជាប់តាមខ្ញុំម្ចាស់ត្រូវប្រឹងប្រែងដើម្បីកម្ចាត់បង់នូវជរាមរណៈនោះ ។

នាងសុមេធានេះ លុះឃើញមាតាបិតា និងស្ដេចអនិករត្តៈដែលមកមិនទាន់ដល់ទ្វារ កំពុងគង់យំលើផែនដី ក៏ទូលនូវពាក្យនេះថា សង្សាររបស់បុគ្គលអន្ធពាលដែលយំទួញញយៗចំពោះសេចក្ដីស្លាប់របស់បិតា សេចក្ដីស្លាប់របស់បងប្អូន និងសេចក្ដីស្លាប់របស់ខ្លួន ក្នុងសង្សារវដ្ដ ដែលគេមិនអាចដឹងទីបំផុតបាន ជាសង្សារវែងឆ្ងាយ ។ សូមទ្រង់ទាំងឡាយរឭក

នូវទឹកភ្នែក ទឹកដោះនិងឈាម កាលទ្រង់អន្ទោលទៅព្រោះសង្សារដែលគេមិនអាចដឹងទីបំផុតបាន សូមទ្រង់រឭកនូវគំនរឆ្អឹងទាំងឡាយ របស់ពួកសត្វដែលអន្ទោលទៅមកៗ ។ សូមទ្រង់រឭកដល់ទឹកភ្នែក ទឹកដោះនិងឈាមដែលប្រៀបធៀបនឹងសមុទ្ទធំទាំង ៤ សូមទ្រង់រឭកនូវគំនរនៃឆ្អឹងទាំងឡាយ ក្នុងកប្បមួយៗដែលស្មើនឹងភ្នំវេបុល្លៈ ។ ដុំដីប៉ុនគ្រាប់ក្រពៅ ដែលបុគ្គលលញ់ដី អស់ទាំងជម្ពូទ្វីប ក៏មិនល្មម គឺតិចជាងមាតាបិតាទាំងឡាយរបស់សត្វកាលអន្ទោលទៅក្នុងសង្សារ ដែលគេមិនអាចដឹងទីបំផុតបាន សូមទ្រង់រឭកនូវស្មៅ កំណាត់ឈើ មែកឈើនិងស្លឹកឈើ ដែលគេនាំមកប្រៀបធៀបខ្នាច់ទាំងឡាយ ( របស់ស្មៅជាដើមនោះ ) ប្រមាណបួនធ្នាប់ៗ ក៏មិនល្មមស្មើនឹងបិតានិងជីតាទាំងឡាយ ព្រោះសង្សារ មានទីបំផុតគេមិនអាចដឹងបាន ។ សូមទ្រង់នឹកមើលនូវអណ្តើកខ្វាក់និងប្រហោងនឹម ( ដែលខ្យល់បក់បង្វិល ) ទៅក្នុងសមុទ្ទអំពីត្រើយខាងកើតទៅត្រើយដទៃទៀត និងក្បាលអណ្តើកនោះដែលចូលទៅ ( ក្នុងប្រហោងនឹម ) នេះជាសេចក្តីឧបមាក្នុងការបានអត្តភាពជាមនុស្ស ។ សូមទ្រង់រឭកនូវរូបរបស់គ្រោងកាយ ជាទោសឥតខ្លឹមសារ មានឧបមាដូចដុំនៃពពុះទឹក សូមទ្រង់ឃើញនូវខន្ធទាំងឡាយថា ជាសភាវៈមិនទៀងទាត់ សូម

ទ្រង់រឭកនូវនរកទាំងឡាយ ដែលមានសេចក្ដីទុក្ខ ក្ដួលក្ដៅជាច្រើន ។ សូមទ្រង់រឭកនូវសត្វទាំងឡាយដែលញុំាងទីស្មសានឲ្យចម្រើនរឿយៗ ក្នុងជាតិទាំងឡាយនោះៗ សូមរឭកនូវភ័យក្នុងការចិញ្ចឹមពោះផង សូមរឭកនូវអរិយសច្ចទាំង ៤ ផង ។ កាលបើអមតធម៌មាន ប្រយោជន៍អ្វី ដោយហេតុក្ដៅផ្សា ៥ យ៉ាង ដែលទ្រង់សោយហើយ ដ្បិតតម្រេកក្នុងកាមទាំងអស់ក្ដៅផ្សាក្រៃពេក ព្រោះហេតុក្ដៅផ្សា ៥ យ៉ាង ។

កាលបើអមតធម៌មាន ទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយដែលជារបស់ក្ដៅក្រហាយ ត្បិតតម្រេកក្នុងកាមទាំងអស់ ( ត្រូវភ្លើង ១១ កង ) ឆេះពុះឡើង ញាប់ញ័រ ក្ដៅសព្វ ។ កាលបើធម៌ដែលឥតសត្រូវ ( នេក្ខម្មៈ ) មាន ទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយដែលមានសត្រូវច្រើន កាមទាំងឡាយជាសាធារណៈ មានសត្រូវច្រើន គឺសត្រូវអំពីស្ដេច ភ្លើង ចោរ ទឹក និងបុគ្គលមិនជាទីស្រឡាញ់ ។

កាលបើព្រះនិព្វានមាន ទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយដែលជាគ្រឿងសម្លាប់ ជាគ្រឿងចង ព្រោះថាកាមទាំងឡាយតែងមានគ្រឿងសម្លាប់ និងគ្រឿងចង ពួកសត្វនេះតែងទទួលសេចក្ដីទុក្ខទាំងឡាយ ព្រោះតែការប្រាថ្នាកាម ។ គប់ស្មៅ ដែលភ្លើងកំពុងឆេះ តែងឆេះនូវបុគ្គលអ្នកកាន់មិន

លែងចេញ ព្រោះថា កាមទាំងឡាយប្រៀបដូចជាគប់ភ្លើងតែង ឆេះនូវពួកសត្វដែលមិនលែងចេញ ។ សូមទ្រង់កុំលះបង់នូវសេចក្តីសុខដ៏ធំទូលាយ ព្រោះហេតុតែសុខក្នុងកាមបន្តិចបន្តួចឡើយ សូមទ្រង់កុំក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដូចជាត្រីលេបនូវសន្ទូច ។ សូមទ្រង់កុំប្រាស់ប្រាល់ ព្រោះតែកាមទាំងឡាយ ដូចសុនខដែលគេចងភ្ជាប់នឹងបង្គោល ឱ សត្វទាំងឡាយ ជាអ្នកស្រេកឃ្លាន តែងធ្វើតាមសេចក្តីប្រាថ្នា ដូចជាពួកចណ្ឌាល ( ព្រានបណ្តើរឆ្កែដល់នូវសេចក្តីវិនាសព្រោះបាន ) នូវឆ្កែ ។ បើទ្រង់ប្រកបខ្វនក្នុងកាម នឹងរងទុក្ខមិនមានប្រមាណផង រងទោមនស្សក្នុងចិត្តដ៏ច្រើនផង សូមទ្រង់លះបង់កាមទាំងឡាយជារបស់មិនទៀងចេញ ។ កាលបើព្រះនិព្វាន ជាធម្មជាតមិនចេះចាស់មាន ទ្រង់មានប្រយោជន៍អ្វីដោយកាមទាំងឡាយជារបស់ចាស់ កំណើតទាំងអស់ក្នុងភពទាំងពួង ( សុទ្ធតែ ) ត្រូវមរណៈនិងព្យាធិរឹបជាន់ ។ ព្រះនិព្វាននេះ មិនចាស់ មិនស្លាប់ ព្រះនិព្វាននេះ ទាំងមិនចាស់ មិនស្លាប់ មិនមានសោក មិនមានសត្រូវ មិនចង្អៀត មិនភ្ញាំងភ្ញាត់ មិនមានភ័យ មិនក្តៅរោលរាល ។ អមតនិព្វាននេះ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ច្រើនរូបបានហើយ មិនតែប៉ុណ្ណោះទេ ព្រះនិព្វាននេះ គេគប្បីបានក្នុងកាល

សព្វថ្ងៃនេះ បុគ្គលណាព្យាយាមដោយឧបាយប្រាជ្ញា ( បុគ្គលនោះរមែងបាននូវព្រះនិព្វាន ) តែបុគ្គលដែលមិនមានសេចក្តីប្រឹងប្រែង មិនអាចបាននូវព្រះនិព្វានឡើយ ។ នាងសុមេធាមិនបាននូវសេចក្តីត្រេកអរក្នុងសង្ខារ ពោលយ៉ាងនេះ នាងសុមេធា កាលពន្យល់ស្តេចអនិករត្តៈហើយ ក៏បោះសក់ទាំងឡាយចោលលើផែនដី ។ ស្តេចអនិករត្តៈនោះ ក្រោកឡើងផ្គងអញ្ជលី អង្វរបិតារបស់នាងសុមេធានោះថា សូមព្រះអង្គអនុញ្ញាតបើករាជបុត្រីឈ្មោះនាងសុមេធាឲ្យបួសចុះ ដើម្បីឲ្យនាងឃើញនូវព្រះនិព្វាន ដែលជាគុណជាតទៀងទាត់ ។

នាងសុមេធានោះ ដែលជាស្រ្តីតក់ស្លុត ចំពោះសោកនិងភ័យ លុះមាតាបិតាបើកឲ្យ ក៏បួស ហើយសិក្សានូវអគ្គផលបានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ ។ ព្រះនិព្វាននោះជាគុណជាតអស្ចារ្យចម្លែកបានកើតមានដល់រាជកញ្ញា លុះក្នុងកាលជាទីបំផុត ( ទៀបនឹងបរិនិព្វាន ) នាងបានសំដែងនូវបុព្វេនិវាសចរិតថា ។ កាលព្រះមានព្រះភាគ ទ្រង់ព្រះនាមកោនាគមនៈ ( ត្រាស់ឡើងក្នុងលោក ) យើងជាសម្លាញ់នឹងគ្នាទាំងបីនាក់ ( គឺនាងធនញ្ជានី ១ នាងខេមា ១ ខ្ញុំ ១ ) បានថ្វាយវិហារទានក្នុងអារាមនៃសង្ឃជានិវេសន៍ដ៏ថ្មី ។ ( ដោយអានិសង្សនៃវិហារទាននេះ ) យើងទាំងឡាយ បានទៅកើត

ក្នុងពួកទេវតា ១០ ដង ១០០ ដង ១.០០០ ដង ១០.០០០ ដង នឹងបាច់និយាយទៅថ្វីក្នុងពួកមនុស្ស ។ យើងជាអ្នកមានឫទ្ធិច្រើនក្នុងពួកទេវតា នឹងបាច់និយាយទៅថ្វី ក្នុងពួកមនុស្ស ខ្ញុំបានកើតជាស្ត្រីកែវ ជាអគ្គមហេសីនៃស្តេចដែលមានរតនៈទាំង ៧ ប្រការ អានិសង្សនៃវិហារទាននោះជាហេតុ អានិសង្សនោះជាប្រភព ( ដែនកើត ) អំណោយទាននោះជាឫសគល់ដ៏ពេញចិត្តក្នុងសាសនា អំណោយទាននោះ ជាការជួបជុំមុនដំបូង អំណោយទាននោះ ជាហេតុឲ្យរលត់កិលេស ( ព្រះនិព្វាន ) របស់ខ្ញុំដែលជាអ្នកត្រេកអរក្នុងធម៌ ។ ពួកជនណាជឿនូវព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានប្រាជ្ញាមិនថោកថយ ពួកជននោះរមែងពោលយ៉ាងនេះថា ពួកជននឿយណាយក្នុងភព គឺសង្សារវដ្ត លុះនឿយណាយហើយប្រាសចាកតម្រេក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មន្តាវតិយា នគរេ** បានដល់ នគរមានឈ្មោះយ៉ាងនេះថាមន្តវតី ។ បទថា **រញ្ញោ កោញ្ចស្ស** សេចក្តីថា បានជាព្រះរាជធីតាកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះរាជាព្រះនាមថា កោញ្ចៈ ។ បទថា **សុមេធា** បានដល់ មានព្រះនាមថាសុមេធា ។ បទថា **បសាទិតា សាសនករេហិ** សេចក្តីថា ដែលព្រះអរិយៈទាំងឡាយ ធ្វើតាមពាក្យប្រៀនប្រដៅព្រះសាស្តា ធ្វើឲ្យជ្រះថ្លាក្នុងពាក្យប្រៀនប្រដៅ ដោយព្រះធម្មទេសនា

គឺធ្វើឲ្យកើតសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ ។ បទថា **សីលវតី** បានដល់ ដល់ព្រមដោយអាចារ មារយាទ និងសីល ។ បទថា **ចិត្តកថា** បានដល់ ពោលធម៌បានពីរោះ ។ បទថា **ពហុស្សុតា** បានដល់ ជាអ្នកប្រកបដោយការស្ដាប់ព្រះបរិយត្តិធម៌ក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ។ បទថា **ពុទ្ធសាសនេ វិនីតា** បានដល់ ត្រូវទូន្មាន គឺមានកាយវាចាចិត្តសង្រួមហើយ ក្នុងពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ព្រោះសង្កត់កិលេសទាំងឡាយទុកដោយតទង្គប្បហាន ដោយយោនិសោមនសិការ តាមព្រះសូត្រថា យ៉ាងនេះ បវត្តិ ( ទុក្ខ ) យ៉ាងនេះ និវត្តិ ( ការរំលត់ទុក្ខ ) យ៉ាងនេះ សមាធិ យ៉ាងនេះបញ្ញា ។ បទថា **ឧភយោ និសាមេថ** សេចក្ដីថា សូមព្រះជនក ព្រះជននីទាំង ២ តាំងព្រះទ័យស្ដាប់វាចារបស់កូន ប្រកបសេចក្ដីថា ព្រះនាងសុមេធាចូលទៅគាល់ព្រះជនកព្រះជននី ហើយមានព្រះសវនីយ៍ ។

បទថា **យទិបិ ទិព្វំ** សេចក្ដីថា ឈ្មោះថា ភព សូម្បីទាក់ទងដោយទេវលោកទាំងអស់ ក៏មិនស្ថិតស្ថេរ មិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតា ។ បទថា **កិមង្គ បន តុច្ឆា កាមា** សេចក្ដីថា នឹងពោលទៅថ្វីដល់កាមទាំងឡាយដែលជារបស់មនុស្ស កាមទាំងនោះសព្វយ៉ាង ឈ្មោះថាទទេ ព្រោះមិនជាខ្លឹម ឈ្មោះថា មានសេចក្ដីត្រេកអរតិច ដូចទឹកឃ្មុំត្រង់មុខកាំបិត ឈ្មោះថា មានការចង្អៀតចង្អល់ច្រើន ព្រោះមានទុក្ខដ៏ធំ ទាំងបច្ចុប្បន្ន ទាំងអនាគត ។

បទថា **កដុកា** បានដល់ មិនគួរប្រាថ្នា កាមទាំងឡាយប្រៀបដូចអា-

សិរពិស ព្រោះអត្ថថា មានភ័យចំពោះមុខ ។ បទថា **មុច្ឆិតា** បានដល់ វង្វេងហើយ ។ បទថា **សមប្បិតា** បានដល់ កកកុញ គឺត្រូវបោះទៅ អធិប្បាយថា កើតឡើងហើយ ដោយប្រការទាំងពួង ដោយកម្មរបស់ខ្លួន ។ បទថា **ហញ្ញន្តេ** បានដល់ ត្រូវបៀតបៀន ។ បទថា **វិនិបាតេ** បានដល់ ក្នុងអបាយ ។

បទថា **អចេតនា** បានដល់ ឈ្មោះថា **អចេតនា** ព្រោះមិនគិតដល់ប្រយោជន៍របស់ខ្លួន ។ បទថា **ឧក្ខេសមុទយោរុទ្ធា** បានដល់ ត្រូវបិទហើយ ក្នុងសង្សារវដ្តដែលមានតណ្ហាជាហេតុ ។ បទថា **ទេសេន្តេ** បានដល់ ធម៌ គឺអរិយសច្ច ៤ ដែលលោកសម្តែង ។ បទថា **អជានន្តា** បានដល់ មិនដឹងអត្ថ ។ បទថា **ន ពុជ្ឈរេ អរិយសច្ចានិ** បានដល់ មិនត្រាស់ដឹងអរិយសច្ច មានទុក្ខជាដើម ។

ដោយបទថា **អម្ម** ព្រះនាងសុមេធាត្រាស់ហៅព្រះជននីជាសំខាន់ ។ បទថា **តេ ពហុតរា អជានន្តា** ប្រកបសេចក្តីថា ជនពួកណា កាលមិនដឹងសច្ចៈ ដែលព្រះពុទ្ធដ៏ប្រសើរទ្រង់សម្តែងហើយ រមែងសរសើរនូវភព ត្រេកអរក្នុងការកើតក្នុងកំណើតទេវតាទាំងឡាយ ជនទាំងនោះឯងមានចំនួនច្រើនជាងក្នុងលោកនេះ ។

បទថា **ភវគតេ អនិច្ចម្ហិ** សេចក្តីថា កាលភពទាំងអស់មិនទៀត ការកើតក្នុងទេវលោកទាំងឡាយ ក៏មិនទៀង កាលបើដូច្នោះ ពួកជនពាលក៏នៅតែមិនតក់ស្លុត ។ បទថា **បុនប្បុនំ ជាយិតព្វស្ស** បានដល់ ដែលកើតក្នុង

ភពតៗទៅ ។

បទថា **ចត្តារោ វិនិបាតា** បានដល់ គតិដែលប្រាសចាកសេចក្តីសុខ មាន ៤ យ៉ាងគឺ នរក តិរច្ឆាន បិត្តិវិស័យ និងកំណើតអសុរ ។ ចំណែកគតិ ២ គឺកំណើតមនុស្សនិងទេវតា សត្វបានដោយលំបាកគឺបានដោយក្រ ព្រោះបុញ្ញកម្មសត្វធ្វើបានដោយក្រ ។ បទថា **និរយេសុ** បានដល់ អបាយដែលប្រាសចាកសុខ ។

បទថា **អប្បោស្សុក្កា** បានដល់ មិនមានការខ្វល់ខ្វាយក្នុងកិច្ចដទៃ ។ បទថា **ឃដិស្សំ** ប្រកបសេចក្តីថា ប្រយោជន៍អ្វីដោយកាយដែលមានទោស មិនមានខ្លឹមសារ ក្នុងភពដែលសត្វសរសើរយ៉ាងខ្លាំង កូននឹងព្យាយាម នឹងប្រកបរឿយៗនូវការនា ។

បទថា **ភវតណ្ហាយ និរោធា** បានដល់ ដើម្បីជាហេតុឲ្យរលត់ គឺដើម្បីរលត់ភវតណ្ហា ។

ប្រកបសេចក្តីថា ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ត្រូវបានហើយ អខណៈ ៨ យ៉ាង មានការកើតក្នុងនរកជាដើម ក៏វៀរហើយ ខណៈទី ៩ ឈ្មោះថា ខណៈដែលកូនបានហើយ ។ បទថា **សីលានិ** បានដល់ ចតុប្បារិសុទ្ធិសីល ។ បទថា **ព្រហ្មចរិយំ** បានដល់ សាសនព្រហ្មចរិយៈ ។ បទថា **ន ទូសេយ្យំ** បានដល់ មិនធ្វើឲ្យវិនាសទៅ ។

បទថា **ន តាវ អាហារំ អាហារិស្សំ គហដ្ឋា** ប្រកបសេចក្តីថា ព្រះនាងសុមេធាក្រាបទូលព្រះជនកព្រះជននីយ៉ាងនេះថា ជាបឋមកូនជាគ្រហស្ថ

នឹងមិនពាល់ត្រូវអាហារ បើកូនមិនបានបួស ក៏នឹងស្លាប់តែម្យ៉ាង ។

បទថា **អស្សា** បានដល់ ព្រះនាងសុមេធា ។ បទថា **សព្វសោ សមភិហតោ** ប្រែថា ព្រះភក្ត្រជោកដោយព្រះអស្សុជល ។ បទថា **ឃដេន្តិ សញ្ញាបេតុំ** សេចក្តីថា មាតាបិតាទ្រង់ព្យាយាមឲ្យព្រះនាងសុមេធា ដែលដួលចុះត្រង់ផែនដី លើផ្ទៃប្រាសាទយល់ព្រមជាគ្រហស្ថ ។ បាលីថា **ឃដេន្តិ វាយមន្តិ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។

បទថា **កឹ សោចិតេន** បានដល់ ប្រយោជន៍អ្វី ដោយការសោយសោកថា អញមិនបានបួស ។ បទថា **ទិន្នាសិ វារណវតិម្ហិ** ប្រែថា នែកូន បិតាបានថ្វាយដល់ព្រះបាទអនិករត្ត ឯវារណវតីនគរហើយ ។ ព្រះបាទកោញ្ចៈត្រាស់ថា បិតាបានថ្វាយហើយ ហើយត្រាស់ទៀតថា ម្នាលកូនស្រី យើងបានថ្វាយនាងដល់ស្តេចទ្រង់ព្រះនាមអនិករត្តៈ ដើម្បីបញ្ជាក់ថាលើកឲ្យហើយពិតប្រាកដ ។

បទថា **រជ្ជេ អាណា** សេចក្តីថា កូនក៏រមែងប្រើអំណាចក្នុងរាជសម្បត្តិរបស់ព្រះបាទអនិករត្តៈបាន ។ បទថា **ធនមិស្សរិយំ** បានដល់ ព្រះរាជទ្រព្យនិងភាពជាធំក្នុងរាជត្រកូលនេះ និងក្នុងរាជត្រកូលព្រះស្វាមី ។ សេចក្តីថា ភោគៈសុខ ជាសម្បត្តិដែលគួរប្រាថ្នាក្រៃលែង វត្ថុទាំងអស់ដូចពោលមកនេះឃើញច្បាស់ហើយ គឺធ្លាក់ក្នុងដៃរបស់កូនហើយ ។ បទថា **ធហរិកាសិ** បានដល់ បុត្រីក៏នៅក្មេង ព្រោះហេតុនោះ ចូរកូនបរិភោគកាមសម្បត្តិចុះ ។ ប្រកបសេចក្តីថា នែកូន ដោយហេតុនោះ ចូរកូនរៀបការចុះ ។

បទថា **នេ** បានដល់ ( ក្រាបទូល ) មាតាបិតា ។ បទថា **មា ឯ–និសិកានិ** សេចក្ដីថា អំណាចជាដើម ក្នុងរាជសម្បត្តិបែបនេះ កុំមានមកឡើយ បើសួរថា ព្រោះហេតុអ្វី ទើបព្រះនាងសុមេធាត្រាស់ថា ភពជារបស់គ្មានខ្លឹមសារ ជាដើម ។

បទថា **កិមិវ** ប្រែថា ដូចដង្កូវ ។ បទថា **បូតិកាយំ** បានដល់ សាកសពដែលស្អុយនេះ ។ បទថា **សវនគន្ធំ** បានដល់ ក្លិនដែលស្អុយផ្សាយទៅ ។ បទថា **ភយានកំ** បានដល់ នាំមកនូវភ័យសម្រាប់បុគ្គលល្ងង់ខ្លៅដែលមិនប្រាសចាករាគៈ ។ បទថា **កុណបំ អភិសំវិសេយ្យំ ភស្តំ** បានដល់ ថង់ស្បែកដែលពេញដោយសាកសព ពេញដោយរបស់មិនស្អាត ហូរចេញមិនមែនតែម្ដង គឺពេញដោយរបស់មិនស្អាត មានប្រការផ្សេងៗ ហូរចេញអស់កាលជានិច្ច ដែលបុគ្គលប្រកាន់ថា នេះរបស់អញ ។ កូនស្គាល់សាកសពនោះថា ដូចជាដង្កូវ ។ បទថា **វិក្កូលកំ** បានដល់ បដិកូលពន់ពេកមានដុំសាច់ដែលមិនស្អាតនិងឈាមបូកលាប ជាលំនៅរបស់ពួកដង្កូវច្រើនក្រុម ជាចំណីរបស់ក្អែកត្មាត ។ បាលីថា **កិមិកុលាលសកុណភត្តំ** ដូច្នេះក៏មាន សេចក្ដីថា ជាចំណីរបស់ពួកដង្កូវ និងពួកបក្សីដទៃៗ ក្រៅអំពីនោះ ព្រះនាងសុមេធាសម្ដែងថា កូនដឹងថារាងកាយនោះគឺសាកសព ឥឡូវនេះ ទ្រង់ព្រះរាជទានខ្ញុំម្ចាស់ឲ្យរៀបការធ្វើអ្វី គឺដោយហេតុអ្វី ប្រកបសេចក្ដីថា ការព្រះរាជទានខ្ញុំម្ចាស់ដល់ស្ដេចអនិករត្តៈនោះ នឹងមានប្រយោជន៍អ្វី ។

បទថា **និព្ពុយ្ហតិ សុសានំ អចិរំ កាយោ អបេតវិញ្ញាណោ** សេចក្ដី

ថា មិនយូរប៉ុន្មាន កាយនេះប្រាសចាកវិញ្ញាណ ក៏នឹងត្រូវនាំទៅ គឺយកទៅកាន់ព្រៃខ្មោច ។ បទថា **ឆុឌ្ឌោ** បានដល់ ត្រូវបោលទៅ ។ បទថា **កលិង្គរំ វិយ** បានដល់ ដូចកំណាត់ឈើដែលឥតប្រយោជន៍ ។ បទថា **ជិគុច្ឆមានេហិ ញាតីហិ** ប្រែថា សូម្បីបុគ្គលដែលជាញាតិ ក៏ខ្ពើមរអើម ។

បទថា **ឆុឌ្ឌេន ធំ សុសានេ** បានដល់ បោលនូវសាកសពនោះក្នុងព្រៃ។ បទថា **បរភត្តំ** បានដល់ ជាអាហាររបស់សត្វដទៃ មានឆ្កែស្រុក និងឆ្កែចចក ជាដើម ។ បទថា **ន្ហាយន្តិ ជិគុច្ឆន្តា** សេចក្ដីថា មាតាបិតាខ្ពើមរអើម ព្រោះគ្រាន់តែមកតាមក្រោយសាកសពនោះ ហើយក៏ត្រឡប់ទៅផ្ទះ ក៏ត្រូវចុះងូតទឹក កក់សក់ មិនចាំពោលដល់បុគ្គល ដែលពាល់ត្រូវសាកសពនោះឡើយ ។ បទថា **និយកា មាតាបិតរោ** បានដល់ សូម្បីមាតាបិតារបស់ខ្លួនឯង ។ បទថា **កឹ បន សាធារណា ជនតា** បានដល់ នឹងត្រូវពោលទៅថ្វីថា ជនក្រៅអំពីនេះ មិនខ្ពើមរអើម ។

បទថា **អជ្ឈោសិតា** បានដល់ ប្រកាន់មាំដោយអំណាចតណ្ហា ។ បទថា **អសារេ** បានដល់ ដែលវៀរចាកសារៈ មាននិច្ចសារៈជាដើម ។

បទថា **វិនិព្ភុជិត្វា** បានដល់ ធ្វើនូវការញែកវិញ្ញាណចេញទៅ ។ បទថា **គន្ធស្ស អសហមានា** បានដល់ អត់ធន់នឹងក្លិននៃកាយនេះមិនបាន ។ បទថា **សកាបិ មាតា** បានដល់ សូម្បីតែមាតារបស់ខ្លួនក៏ខ្ពើមព្រោះឃើញច្បាស់ដោយបដិកូលភាវនា ។

បទថា **ខន្ធធាតុអាយតនំ** សេចក្ដីថា ខន្ធ ធាតុ និងអាយតនៈ យ៉ាង

នេះ គឺបញ្ចក្ខន្ធទាំងនេះ មានរូបក្ខន្ធជាដើម ធាតុទាំង ១៨ នេះ មានចក្ខុធាតុជាដើម អាយតនៈ ១២ នេះ មានចក្ខាយតនៈ ជាដើម រួមសេចក្តីថា ធម្មជាតិដែលជារូបនិងមិនមែនរូបដូចពោលមកទាំងអស់នេះ ឈ្មោះថា សង្ខតៈ ព្រោះបច្ច័យទាំងឡាយប្រជុំរួមគ្នាសាងឡើង ធម្មជាតិនោះ ប្រព្រឹត្តទៅក្នុងភពនោះ ទើបជាទុក្ខ ឈ្មោះថា **ជាតិមូលកំ** ព្រោះមានជាតិជាបច្ច័យ កូនពិចារណាគិតដោយឧបាយប្រាជ្ញាយ៉ាងនេះហើយ ព្រោះហេតុអ្វី ទើបចង់រៀបការនោះ ។

ដើម្បីជំទាស់ពាក្យដែលព្រះជនកព្រះជននីត្រាស់ថា សីល ព្រហ្មចរិយធម៌និងបព្វជ្ជា គេធ្វើបានកម្រណាស់ ទើបព្រះនាងសុមេធាពោលថា លំពែង ៣ រយ ដែលសំលៀងថ្មីៗ ជាដើម ។ បណ្តាបទទាំងនោះ បទថា **ទិវសេ ទិវសេ តិសត្តិសតានិ នវនវា បតេយ្យុំ កាយម្ហិ** សេចក្តីថា លំពែង ៣ រយដែលសំលៀងថ្មីៗ ព្រោះលាបដោយប្រេង គប្បីធ្លាក់ចុះ ត្រង់រាងកាយរាល់ៗថ្ងៃ ។ បទថា **វស្សសតម្បិ ច ឃាតោ សេយ្យោ** សេចក្តីថា ការចាក់ដោយលំពែងដូចពោលហើយ ចាក់អស់ ១០០ ឆ្នាំ គ្មានឈប់ឈរគង់ប្រសើរជាង ។ បទថា **ទុក្ខស្ស ចេវំ ខយោ** សេចក្តីថា បើធ្វើយ៉ាងនេះអស់នូវទុក្ខក្នុងវដ្តៈ ក៏គួរអត់សង្កត់នូវសេចក្តីទុក្ខដែលប្រព្រឹត្តទៅ ក្រៃលែងយ៉ាងនេះ ហើយធ្វើនូវឧស្សាហៈដើម្បីដល់នូវព្រះនិព្វាន ។

បទថា **អជ្ឈុបគច្ឆេ** ប្រែថា គប្បីទទួល ។ បទថា **ឯវំ** ប្រែថា ដោយន័យដែលពោលមកហើយ លោកអធិប្បាយដូច្នេះថា បុគ្គលណាដឹងនូវព្រះ

*តម្រាស់របស់ព្រះសាស្តាដែលសម្តែងដល់សង្សារវដ្ត ដែលមិនមានខាងដើម និងទីបំផុត និងទុក្ខក្នុងវដ្តៈដែលរាប់មិនបាន គប្បីព្រមទទួលទុក្ខ ព្រោះការចាក់ដោយលំពែងតាមដែលពោលហើយ ព្រោះការដឹងនោះឯង បើទុក្ខក្នុងវដ្តៈគប្បីអស់ទៅបាននោះ ។ ដោយហេតុនោះ ទើបព្រះនាងសុមេធាពោលថា* **ទីឃោ តេសំ សំសារោ បុនប្បុនំ ហញ្ញមានានំ** *សេចក្តីថា ត្រូវជរា ព្យាធិ មរណៈ បៀតបៀនរឿយៗអស់កាលយូរ អធិប្បាយថា ត្រូវជាតិ ជរា ព្យាធិ មរណៈជាដើម បៀតបៀនហើយបៀតបៀនទៀត ។ បទថា* **អសុរកាយេ** *បានដល់ ពួកប្រេតនិងអសុរ មានកាឡកញ្ជិកាសុរៈជាដើម ។ បទថា* **ឃាតា** *បានដល់ ការប្រទូស្ត ការបៀតបៀនកាយ និងចិត្ត ។*

*បទថា* **ពហូ** *បានដល់ ប្រទូស្តច្រើន មានការដាក់ទោស មានចំណង ៥ ប្រការជាដើម ។ បទថា* **វិនិបាតគតស្ស** *បានដល់ ជាអ្នកចូលដល់វិនិបាត ពោលគឺអបាយដ៏សេស ដែលពោលហើយ ។ បទថា* **បីឡិយមានស្ស** *បានដល់ ត្រូវបៀតបៀនដោយការសម្លាប់ជាដើម ក្នុងអត្តភាពដែលជាសត្វតិរច្ឆានជាដើម ។ បទថា* **ទេវេសុបិ អត្តាណំ** *សេចក្តីថា ក្នុងអត្តភាពដែលជាទេវតា ក៏ជួយមិនបាន ព្រោះមានទុក្ខ មានការបង្អៀតបង្អល់ដោយការក្តៅក្រហាយដោយរាគៈជាដើម ។ បទថា* **និព្វានសុខា បរំ នត្ថិ** *សេចក្តីថា ធម្មតាសុខដទៃក្រៅអំពីសេចក្តីសុខគឺព្រះនិព្វាន កាន់យកជាសេចក្តីសុខដ៏កំពូលមិនបាន ព្រោះលោកិយសុខ មានទុក្ខកើតអំពីសង្ខារប្រែប្រួលជាលក្ខណៈ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកក្នុង ( ធម្ម*

បទ ) ថា **និព្វានំ បរមំ សុខំ** ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ដូច្នេះ ។

បទថា **បត្តា តេ និព្វានំ** សេចក្តីថា ជនទាំងនោះឈ្មោះថា សម្រេចព្រះនិព្វាននោះឯង ។ ន័យម្យ៉ាងទៀត ជនទាំងនោះប៉ុណ្ណោះ ដែលសម្រេចព្រះនិព្វាន ។ បទថា **យេ យុត្តា ទសពលស្ស សាសនេ** សេចក្តីថា ជនឯណា ខ្វល់ខ្វាយក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។

បទថា **និព្ពិន្នា** ប្រែថា នឿយណាយ ។ បទថា **មេ ស្មើគ្នានឹង មយា** ប្រែថា ដែលកូន ។ បទថា **វណ្ណសមា** បានដល់ ដូចកម្ពួតក្អែ ។ បទថា **តាលវណ្តកតា** ប្រែថា ធ្វើឲ្យដូចទីតាំងនៃដើមត្នោត ។

បទថា **អថ** ប្រែថា ខាងក្រោយ គឺក្រោយអំពីព្រះនាងទូលអំពីអធ្យាស្រ័យរបស់នាងឲ្យព្រះជនកនិងព្រះជននីជ្រាប ព្រះនាងក៏ឮថា ព្រះបាទអនិករត្តៈ យាងមកដល់ហើយ ។ បទថា **អសិតនិចិតមុទុកេ** បានដល់ ឈ្មោះថា **អសិត** ព្រោះមានពណ៌ដូចត្នូនិល និងស្លាបកំភេម ឈ្មោះថា **និចិត** ព្រោះធ្វើឲ្យជាសំណុំ ឈ្មោះថា **មុទុកេ** ព្រោះមានសម្ផស្សទន់ដូចប៉ុយរកា ។ បទថា **កេសេ ខគ្គេន ឆិន្ទិយ** បានដល់ ព្រះនាងយកកាំបិតដែលគេសំលៀងមុតល្អហើយកាត់ព្រះកេសារបស់ព្រះនាង ។ បទថា **ចាសាទំ បិទហិត្វា** បានដល់ ព្រះនាងបិទបន្ទប់ដ៏មានសិរីលើប្រាសាទដែលប្រថាប់នៅរបស់ព្រះនាង អធិប្បាយថា ព្រះនាងបិទទ្វារបន្ទប់នោះ ។ បទថា **បឋមជ្ឈានំ សមាបជ្ជិ** សេចក្តីថា ព្រះនាងដាក់នូវព្រះកេសារបស់ព្រះនាងដែលព្រះនាងយកព្រះខ័នកាត់ទុកអំពីខាងមុខ ព្រះនាងចាប់ផ្តើមមនសិការនូវភាពជារបស់បដិកូលក្នុង

ព្រះកេសានោះ ព្រះនាងចូលបឋមជ្ឈាន ដែលកើតឡើងក្នុងនិមិត្តតាមដែលប្រាកដឲ្យដល់នូវការជំនាញ អធិប្បាយថា ព្រះនាងសុមេធានោះចូលឈានក្នុងប្រាសាទនោះ ។ បទថា **អនិច្ចសញ្ញំ សុភាវេតិ** សេចក្តីថា ព្រះនាងចេញអំពីឈានហើយផ្តើមវិបស្សនា ធ្វើឈានឲ្យជាបាទ ចម្រើនដោយល្អនូវអនិច្ចានុបស្សនាដោយន័យជាដើមថា **យំកិញ្ចិ រូបំ** រូបឯណានីមួយ ... ។ ដោយ **អនិច្ចសញ្ញា** សព្ទ ក្នុងពាក្យថា **អនិច្ចសញ្ញំ ភាវេតិ** នេះ គប្បីជ្រាបថា សង្គ្រោះយកទុក្ខសញ្ញាជាដើមទុកផងដែរ ។

បទថា **មណិកនកភូសិតង្គោ** បានដល់ ប្រដាប់ព្រះកាយដោយគ្រឿងអលង្ការ គឺកម្រងផ្កាមាសដែលវិចិត្រដោយកែវមណី ។

ពាក្យថា **រជ្ជេ អាណា** ជាដើម ជាពាក្យសម្តែងអាការដែល ( ព្រះបាទអនិករត្តៈ ) ទ្រង់អង្វរ បណ្តាបទទាំងនោះ បទថា **អាណា** បានដល់ភាពជាធំ ។ បទថា **ឥស្សរិយំ** បានដល់ យស គឺសម្បត្តិ ។ បទថា **ភោគា សុខា** បានដល់ គ្រឿងឧបភោគដែលជាកាមគួរប្រាថ្នា គួរពេញចិត្ត ។ បទថា **ទហរិកាសិ** បានដល់ ព្រះនាងក៏នៅក្មេង ។

បទថា **និស្សដ្ឋំ តេ រជ្ជំ** សេចក្តីថា អាណាចក្រទំហំ ៣ យោជន៍របស់ខ្ញុំលះថ្វាយព្រះនាងហើយ សូមព្រះនាងទទួលអាណាចក្រនោះ ហើយបរិភោគភោគៈទាំងឡាយចុះ សូមព្រះនាង កុំទោមនស្សថា ព្រះរាជាអង្គនេះអញ្ជើញអញដោយកាមទាំងឡាយតែម្យ៉ាងឡើយ ។ បទថា **ទេហិ ទានានិ** គប្បីជ្រាបពាក្យអធិប្បាយថា សូមព្រះនាងធ្វើនូវការថ្វាយទានជាច្រើន ក្នុង

សមណព្រាហ្មណ៍ទាំងឡាយ តាមគាប់ព្រះទ័យចុះ ព្រះជនកព្រះជននីរបស់ព្រះនាង ទ្រង់កើតទុក្ខ ទ្រង់ទោមនស្ស ព្រោះដឹងថាព្រះនាងបំណងនឹងបួស ព្រោះហេតុនោះ សូមព្រះនាងបរិភោគកាម បម្រើព្រះជនកព្រះជននី ដោះព្រះអង្គទាំងពីរឲ្យផុតចាកទុក្ខចុះ ។

បទថា **មា កាមេ អភិនន្ទិ** បានដល់ ទ្រង់កុំត្រេកអរដោយវត្ថុកាមនិងកិលេសកាម សូមទ្រង់ឃើញនូវអាទីនវៈក្នុងកាមទាំងនោះ សូមពិចារណាដោយញាណចក្ខុ តាមគន្លងនៃពាក្យរបស់ខ្ញុំម្ចាស់ផងចុះ ។

បទថា **ចាតុទ្ទីបោ** បានដល់ ជាម្ចាស់នៃទ្វីបទាំង ៤ មានជម្ពូទ្វីបជាដើម ។ បទថា **មន្ធាតា** បានដល់ ព្រះរាជាមានឈ្មោះយ៉ាងនេះ ទ្រង់ជាបុគ្គលក្រៃលែង គឺជាកំពូលនៃអ្នកបរិភោគកាមទាំងឡាយ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា រាហុធំលើសពួកសត្វ ដែលមានអត្តភាព ស្តេចមន្ធាតុប្រសើរជាងបុគ្គលអ្នកបរិ-ភោគកាមទាំងឡាយ ដូច្នេះ ។ បទថា **អតិត្តោ កាលង្កតោ** សេចក្តីថា ទ្រង់នៅជាកុមារ ៨៤០០០ ឆ្នាំ ទ្រង់នៅជាឧបរាជ ៨៤០០០ ឆ្នាំ ទ្រង់ជាស្តេចចក្រពត្តិ ៨៤០០០ ឆ្នាំ សោយភោគសម្បត្តិដូចភោគសម្បត្តិ ក្នុងទេវលោក ទាំងសោយសគ្គសម្បត្តិក្នុងភពតាវត្តិង្ស អស់កាលស្មើនឹងអាយុរបស់ព្រះឥន្ទ្រ ៣៦ អង្គ ទ្រង់មិនទាន់ឆ្អែតដោយកាមទាំងឡាយក៏សោយទិវង្គតទាំងដែលការប្រាថ្នារបស់ព្រះអង្គ នៅមិនទាន់ពេញ គឺចំណង់ក្នុងកាមទាំងឡាយរបស់ព្រះបាទមន្ធាតុរាជមិនទាន់បរិបូណ៌ ។

បទថា **សត្ត រតនានិ វស្សេយ្យ** សេចក្តីថា បើទេវតាភ្លៀងគប្បីបង្អុរ រតនៈទាំង ៧ ប្រការឲ្យធ្លាក់ចុះមកតាមការពេញចិត្តរបស់មនុស្ស គ្រប់ទាំង ១០ ទិស ដោយជុំវិញ បុរសកាលបើដូច្នោះ ក៏មិនឆ្អែតដោយកាមទាំងឡាយ ដូចព្រះបាទមន្ធាតុរាជ នរជនទាំងឡាយ ស្លាប់ទៅទាំងមិនឆ្អែតក្នុងកាម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងធម្មបទ ) ថា **ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ** ប្រែថា ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមានព្រោះកហាបណៈ( ដែលធ្លាក់ចុះ ) ដូចទឹកភ្លៀងទេ ដូច្នេះ ។

កាមទាំងឡាយ ប្រៀបដូចដាវនិងឈើស្រួច ព្រោះអត្ថថា រង់ចាំកាត់ ប្រៀបដូចក្បាលនៃពស់ ព្រោះអត្ថថា មានភ័យចំពោះមុខ ប្រៀបដូចជាគប់ភ្លើងគឺគប់ភ្លើងស្មៅ ព្រោះអត្ថថា ដុត ដោយហេតុនោះទើបព្រះនាងសុមេធាថេរីពោលថា **អនុទហន្តិ** ដូច្នេះ ប្រៀបដូចរាងឆ្អឹង ព្រោះអត្ថថា មានរស់ឆ្ងាញ់តិច ។

បទថា **មហាវិសា** បានដល់ ដូចថ្នាំពិសដែលមានពិសដ៏ខ្លាំងក្លាជាដើម ។ បទថា **អឃមូលា** បានដល់ ជាមូល គឺជាហេតុនៃទុក្ខ ដោយហេតុនោះ ទើបព្រះនាងសុមេធាថេរីពោលថា **ទុក្ខមូលា** ដូច្នេះ ។ កាមទាំងឡាយប្រៀបដូចជាផ្លែឈើ ព្រោះអត្ថថា កាច់បំបាក់នូវការចម្រើន នៃមែកធាងតូចធំរបស់ដើមឈើ ប្រៀបដូចដុំសាច់ ព្រោះអត្ថថា ជារបស់សាធារណៈដល់មនុស្សទូទៅ កាមទាំងឡាយដូចការយល់សប្តិ ព្រោះអត្ថថា ប្រាកដបន្តិចបន្តួចព្រោះបោកបញ្ឆោតដូចមាយា ដោយហេតុនោះ ទើបព្រះនាងសុមេធាថេរីពោលថា

**វញ្ចនីយា** អធិប្បាយថា បោកបញ្ឆោត ។ បទថា **យាចិតក្កូបមា** បានដល់ដូចទ្រព្យដែលខ្ចីគេមក ព្រោះអត្ថថា ជារបស់ម្ចាស់ម្ចាល ។

ប្រៀបដូចលំពែងនិងដែកស្រួច ព្រោះអត្ថថា មុត ឈ្មោះថា **រោគោ** ព្រោះអត្ថថា ដាក់ដោត ព្រោះជាទុក្ខបានងាយ ឈ្មោះថា **គណ្ឌោ** ព្រោះជាទីហូរចេញនៃរបស់មិនស្អាត គឺកិលេស ឈ្មោះថា **អឃំ** ព្រោះអត្ថថា ឲ្យកើតទុក្ខ ឈ្មោះថា **និឃំ** ព្រោះឲ្យដល់នូវការស្លាប់បាន ឈ្មោះថា **អង្គារ-កាសុសទិសា** ព្រោះអត្ថថា ធ្វើឲ្យក្តៅដ៏ខ្លាំង ។ ភ័យ ឈ្មោះថា វធៈ ប្រ-កបសេចក្តីថា កាមទាំងឡាយ ឈ្មោះថាជាភ័យ និងព្រោះច្រើនដោយអ្នកសម្លាប់ ។

បទថា **អក្ខាតា អន្តរាយិកា** បានដល់ ដែលបណ្ឌិត មានព្រះពុទ្ធជាដើមដែលមានចក្ខុត្រាស់ទុកថា ធ្វើអន្តរាយដល់ផ្លូវទៅកាន់ស្ថានសួគ៌ និងផ្លូវទៅកាន់ព្រះនិព្វាន ។ ព្រះនាងសុមេធាសូមឲ្យព្រះបាទអនិករត្តៈ មួយអន្លើដោយបរិស័ទត្រឡប់ទៅ ដោយព្រះសវនីយ៍ថា **គច្ឆថ** សូមព្រះអង្គយាងទៅវិញចុះ ។

បទថា **កឹ មម បរោ ករិស្សតិ** សេចក្តីថា កាលសីសៈរបស់ខ្លួនឯងត្រូវភ្លើង ១១ កងឆេះ អ្នកដទៃណានឹងធ្វើប្រយោជន៍អ្វីដល់ខ្ញុំបាន ដោយហេតុនោះ ទើបព្រះនាងសុមេធាថេរីពោលថា កាលបើជរានិងមរណៈកំពុងជាប់តាម ដូច្នេះ ។ បុគ្គលគួរព្យាយាមកម្ចាត់ គឺដកនូវជរានិងមរណៈនោះ ដែលដូចជាភ្លើងឆេះលើក្បាល ។

បទថា **ឆមំ** ប្រែថា លើផែនដី បទថា **ឥឆមព្រាចំ** ព្រះនាងសុមេធា បានពោលពាក្យនេះ គឺពាក្យដែលប្រព្រឹត្តទៅដើម្បីឲ្យកើតសង្វេគថា **ឪឃោ ពាលានំ សំសារោ** ដូច្នេះ ។

បទថា **ឪឃោ ពាលានំ សំសារោ** សេចក្តីថា សង្សារ ពោលគឺការប្រព្រឹត្តទៅតាមលំដាប់នៃខន្ធ អាយតនៈ ជាដើម ដែលជាវដ្តៈ គឺកិលេស កម្មនិងវិបាកវែងឆ្ងាយ សូម្បីតែពុទ្ធញ្ញាណក៏កំណត់មិនបាន សម្រាប់បុគ្គលល្ងង់ខ្លៅ ដូចបុគ្គលខ្វាក់ជាអ្នកមិនកំណត់ដឹងវត្ថុ គឺអវិជ្ជា ៨ ពិតហើយ ទីបំផុតខាងដើមនៃគ្រឿងចង គឺភពវមែងមិនប្រាកដ ព្រោះកំណត់ព្រំដែនអវិជ្ជា តណ្ហាមិនបាន ព្រោះកាត់មិនទាន់ដាច់ យ៉ាងណា សូម្បីចំណុចខាងចុង ក៏មិនប្រាកដ យ៉ាងនោះ ។ បទថា **បុនប្បុនញ្ច រោទតំ** សេចក្តីថា បុគ្គលយំហើយយំទៀតដោយសេចក្តីសោក ។ ព្រះនាងសុមេធាចង្អុលបង្ហាញនូវភាពដែលអវិជ្ជានិងតណ្ហាមិនទាន់កាត់ផ្តាច់ដោយបទនេះ ។

បទថា **អស្សុ ថញ្ញំ រុធិរំ** សេចក្តីថា ទឹកភ្នែកឯណារបស់សត្វដែលការវិនាសញាតិជាដើមពាល់ត្រូវហើយយំ ទឹកដោះឯណា ដែលពួកសត្វបៅអំពីដោះរបស់មាតាក្នុងកាលជាទារក ឈាមឯណា របស់សត្វដែលត្រូវបច្ចាមិត្តប្រទូស្ត សូមទ្រង់រឭកដល់សង្សារដែលមិនដឹងខាងដើមនិងខាងចុង គឺការវិលវល់ទៅមករបស់សត្វ ដែលអន្ទោលទៅដោយកាលដ៏វែងឆ្ងាយនេះ ព្រោះសង្សារមានចំណុចខាងដើមនិងខាងចុងមិនប្រាកដ គឺព្រោះសង្សារមានទីបំ-ផុតដែលតាមដឹងមិនបាន ក៏ដឹងច្បាស់មិនបានដោយញាណ សូមទ្រង់រឭក

ដល់ទឹកភ្នែកទឹកដោះ និងឈាមនោះថា ច្រើនប៉ុនណា សូមទ្រង់ព្រួកដល់អធិប្បាយថា ពិចារណាដល់ការសន្សំនៃឆ្អឹងទាំងឡាយ ។

ឥឡូវនេះ ដើម្បីសម្តែងដល់អាទីនវៈដែលមានច្រើន ដោយឧបមា ទើបព្រះនាងសុមេធាថេរីពោលគាថាថា **សរ ចតុរោទធី ឧបនីតេ អស្សុថញ្ញ-រុធិរម្ហិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សរ ចតុរោទធី** សេចក្តីថា សូមទ្រង់ព្រួកដល់សមុទ្រទាំង ៤ គឺមហាសមុទ្រទាំង ៤ ដែលល្មមប្រៀបធៀបជាប្រមាណជាមួយទឹកភ្នែក ទឹកដោះនិងឈាមរបស់បណ្តាពួកសត្វដែលអន្ទោលទៅក្នុងសង្សារ ដែលមានទីបំផុតខាងដើមនិងខាងចុងដឹងមិនបាននេះ ដែលព្រះពុទ្ធទាំងឡាយ ប្រៀបធៀបដោយឧបមា ។ បទថា **ឯកកប្បមដ្ឋីនំ សញ្ចយំ វិបុលេន សមំ** សេចក្តីថា សូមទ្រង់ព្រួកដល់គំនរនៃឆ្អឹងទាំងឡាយក្នុងកប្បមួយ របស់បុគ្គលម្នាក់ដែលព្រះពុទ្ធទាំងឡាយ បង្អោននាំមកប្រៀបធៀបទុក ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា

> គំនរនៃឆ្អឹងរបស់បុគ្គលម្នាក់ ចំនួនមួយកប្ប គំនរនោះប្រហែល
> គ្នានឹងភ្នំ ព្រះពុទ្ធជាមហេសី បានត្រាស់ហើយ ដូច្នេះ ភ្នំវេ-
> បុល្លៈនេះ លោកពោលហើយថា ធំលើសលុបជាងភ្នំគិជ្ឈកូដ
> ទៀបក្រុងគិរិព្វជៈ ( រាជគ្រឹះ ) របស់អ្នកមគធៈទាំងឡាយ
> ដូច្នេះ ។

សូមទ្រង់ព្រួកដល់ផែនដី និងជម្ពូទ្វីបដែលព្រះពុទ្ធទ្រង់នាំមកប្រៀបធៀប ។ បទថា **កោលដ្ឋិមត្តគុឡិកា មាតាមតុស្សេវ នប្បហោន្តិ** សេចក្តី ថាកាល

ធ្វើផែនដីធំដែលហៅថាជម្ពូទ្វីបឲ្យជាដុំប៉ុនគ្រាប់កោលៈ គឺគ្រាប់ក្រពៅ ពូតដុំដីមួយដុំៗក្នុងជម្ពូទ្វីបនោះយ៉ាងនេះថា នេះមាតារបស់អញ នេះយាយរបស់អញ ដុំដីទាំងនោះក៏មិនល្មមនឹងរាប់ចំនួនមាតានិងជីដូន កាលមាតានិងជីដូនមិនទាន់អស់ទៅ ដុំដីទាំងនោះ ដុំចុងក្រោយនឹងអស់ទៅមុន មាតានិងជីដូនរបស់សត្វដែលអន្ទោលទៅក្នុងសង្សារវដ្តដែលមានទីបំផុតខាងដើម និងខាងចុងដឹងមិនបាន ក៏មិនទាន់អស់ទៅឡើយ សូមទ្រង់ធ្វើផែនដីក្នុងជម្ពូទ្វីបទុកក្នុងចិត្តបង្អោននាំមកប្រៀបធៀបថា សង្សារវដ្តវែងឆ្ងាយដូចពោលមកនេះ ដូច្នេះ ។

បទថា **តិណកដ្ឋសាខាបលាសំ** បានដល់ ស្មៅ ដើមឈើ និងស្លឹកឈើ ។ បទថា **ឧបនីតំ** ប្រែថា នាំចូលមកប្រៀបធៀប ។ បទថា **អនមតគ្គតោ** បានដល់ ព្រោះសង្សារវដ្តមានទីបំផុតខាងដើមនិងខាងចុងដឹងមិនបាន ។ បទថា **ចតុរង្គុលិកា ឃដិកា** បានដល់ ដុំឈើដែលកាច់ប៉ុនៗ ៤ ធ្នាប់ ។ បទថា **បិតុបិតុស្វេវ នប្បហោន្តិ** សេចក្តីថា កំណាត់ឈើទាំងនោះរមែងមិនគ្រប់គ្រាន់ដល់ចំនួនបិតា និងជីតាទាំងឡាយ លោកអធិប្បាយទុកដូច្នេះថា កាលកាត់ស្មៅ ឈើ និងមែកឈើទាំងអស់ក្នុងលោកនេះ ទំហំប៉ុន ៤ ធ្នាប់ ហើយចែកមួយចម្រៀកៗ បណ្តាស្មៅ ឈើនិងមែកឈើនោះយ៉ាងនេះថា នេះបិតា នេះជីតារបស់អញ ឈើទាំងនោះនឹងអស់ទៅមុន បិតានិងជីតារបស់សត្វដែលអន្ទោលទៅក្នុងសង្សារវដ្ត ដែលមានទីបំផុតខាងដើមនិងខាងចុងដឹងមិនបាន នឹងមិនអស់ទៅ សូមទ្រង់រឭកដល់ស្មៅ ឈើ និងស្លឹកឈើ បង្អោននាំមកប្រៀបធៀបដោយការវែងឆ្ងាយនៃសង្សារវដ្ត ដោយប្រ-

ការដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតគេមិនអាចដឹងបាន គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយដែលមានអវិជ្ជា ជារនាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះ ថាដូចម្តេច គឺត្រង់ដែលអ្នកទាំងឡាយអន្ទោលទៅ ត្រាច់រង្គាត់ទៅ កន្ទក់កន្ទេញ ទួញយំ ព្រោះជួបប្រទះ នឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលអង្វែងនេះ ទឹកភ្នែកដែលហូរស្រក់ហើយ នឹងទឹកក្នុងមហាសមុទ្ទទាំង ៤ តើបណ្តាទឹកទាំងពីរនោះ ទឹកណាច្រើនជាង ដូច្នេះ ។

បទថា **សរ កាណាកច្ឆបំ** សេចក្តីថា សូមទ្រង់រឭកដល់អណ្តើកខ្វាក់ទាំងសងខាង ។ បទថា **បុព្វេ សមុទ្ទេ អបរតោ ច យុគច្ឆិទ្ទំ** បានដល់ប្រហោងមួយនៃច្បោះដែលវិលវល់ទៅមក ព្រោះកម្លាំងរបស់ខ្យល់ នៅក្នុងសមុទ្ទទិសខាងកើត និងទិសដទៃៗ គឺក្នុងសមុទ្ទទិសបច្ឆិម ទិសឧត្តរ និងទិសទក្សិណ ។ បទថា **សិរំ តស្ស ច បដិមុក្កំ** សេចក្តីថា សូមទ្រង់រឭកដល់ក្បាលរបស់អណ្តើកខ្វាក់និងការកន្ទងទៅរាប់រយឆ្នាំ ក្បាលរបស់អណ្តើកនោះដែលអើតកផុសមកចូលទៅក្នុងច្បោះ ។ បទថា **មនុស្សលាភម្ហិ ឱបម្មំ** សេចក្តីថា សូមទ្រង់ធ្វើនូវវត្ថុទាំងអស់នេះ ជាគ្រឿងប្រៀបធៀបក្នុងការបាន

អត្តភាពជាមនុស្ស ដូចគ្នានឹងការកើតឡើងនៃព្រះពុទ្ធនិងការសម្តែងធម៌ហើយ ប្រើបញ្ញាវពូកមើលថា ការបានអត្តភាពជាមនុស្សនោះ ជាសភាវៈដែលបាន ដោយកម្រក្រៃពេកព្រោះភ័យនៃតម្រេកជាសភាវៈដែលកន្លងទៅហើយ សម ដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងពាលបណ្ឌិតសូត្រ ) ថា ម្នាលភិក្ខុទាំង ឡាយ ដូចបុរសដាក់នឹមដែលមានចន្លោះតែមួយទៅក្នុងមហាសមុទ្ទ ដូច្នេះជា ដើម ។

បទថា **សរ រូបំ ជេណាបិណ្ឌោបមស្ស** សេចក្តីថា សូមទ្រង់រឭកដល់ ការបែកធ្លាយនៃកាយដែលហៅថាទីប្រជុំ ព្រោះជាទីប្រជុំចុះនូវវត្ថុ ដែលឥត ប្រយោជន៍ ឥតសារៈ ព្រោះមិនមានខ្លឹម មាននិច្ចសារៈជាដើម ជាទីមិន ស្អាត មានក្លិនស្អុយ មានភាវៈជារបស់គួរខ្ពើម ដូចដុំពពុះទឹក ព្រោះមិនអត់ ធន់ចំពោះការបៀតបៀន ។ បទថា **ខន្ធេ បស្ស អនិច្ចេ** សេចក្តីថា សូមទ្រង់ រឭក គឺពិចារណាដោយញាណចក្ខុថា ឧបាទានក្ខន្ធទាំង ៥ មិនទៀង ព្រោះ អត្ថថា មានហើយបែរជាមិនមាន ។ បទថា **សរាហិ និរយេ ពហុវិឃាតេ** សេចក្តីថា សូមទ្រង់រឭកដល់មហានរក ៨ រណ្តៅ ឧស្សទនរក ១៦ រណ្តៅ ដែលមានការចង្អៀតចង្អល់ច្រើន មានទុក្ខច្រើន និងមានទុក្ខធំក្រៃលែង ។

បទថា **សរ កដសឹ វឌ្ឍេន្តេ** សេចក្តីថា សូមទ្រង់រឭកដល់ពួកសត្វដែល នៅត្រង់ស្មសាន គឺព្រៃខ្មោច បានដល់ ទីកប់សពនោះឯង ព្រោះកាលមាន ការកើតរឿយៗ ទៅមកៗ ក្នុងជាតិនោះៗ ។ បាលីថា **វឌ្ឍេន្តោ** ក៏មាន ។ ប្រកបសេចក្តីថា ទ្រង់បន្ថែមព្រៃខ្មោច គឺធ្វើព្រៃខ្មោច ឲ្យចម្រើន ។ បទថា

**កុម្ភីលភយានិ** បានដល់ ភ័យ គឺការឃើញដល់ផ្ទៃ ដោយភាពជាអ្នកធ្វើកិច្ចដែលមិនគួរដើម្បីចិញ្ចឹមផ្ទៃ សមដូចព្រះមានព្រះភាគ ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថាភ័យអំពីក្រពើនេះឯង ជាឈ្មោះនៃសេចក្តីប្រាថ្នាអាហារចម្អែតពោះ ដូច្នេះ ។ បទថា **សាហិ ចត្តារិ សច្ចានិ** សេចក្តីថា សូមទ្រង់ញែកគឺពិចារណាតាមសេចក្តីពិត នូវអរិយសច្ច ៤ ថា នេះទុក្ខអរិយសច្ច នេះសមុទយអរិយសច្ច នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

ព្រះរាជបុត្រីកាលប្រកាសទោសក្នុងកាម និងសង្សារដោយញែកដល់អាការ និងខន្ធយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីប្រកាសនូវទោសនោះ ទើបត្រាស់គាថាថា **អមតម្ហិ វិជ្ជមានេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អមតម្ហិ វិជ្ជមានេ** បានដល់ ដែលបានឈ្មោះថា អមតសទ្ធម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់នាំមកប្រៀបធៀប ដោយព្រះមហាករុណា ។ បទថា **កឹ តវ បញ្ចកដុកេន បីតេន** សេចក្តីថា ប្រយោជន៍អ្វីរបស់ព្រះអង្គដោយរសក្នុងកាមគុណ ៥ ដែលជារសផ្សាក្តៅ ៥ យ៉ាង ដែលទ្រង់សោយហើយ ព្រោះមានទុក្ខ មានការចង្អៀតចង្អល់ ព្រោះជាប់តាមមកដោយទុក្ខដ៏ខ្លាំងក្លា ជាងក្នុងឋានៈទាំង ៥ គឺការស្វែងរក ១ ការហួងហែង ១ ការរក្សា ១ ការបរិភោគ ១ វិបាក ១ ឥឡូវនេះ កាលព្រះនាងពង្រីកសេចក្តីដែលពោលហើយឲ្យប្រាកដច្បាស់ ទើបត្រាស់ថា **សព្វា ហិ កាមរតិយោ កដុកតរា បញ្ចកដុកេន** ដូច្នេះ អធិប្បាយថា ក្តៅក្រហាយក្រៃលែងជាង ។

បទថា **យេ បរិឡាហា** សេចក្តីថា កាមពួកណា ឈ្មោះថា មានការក្តៅក្រហាយ មានការបង្អៀតបង្អល់ច្រើន ដោយការក្តៅក្រហាយដោយកិលេសក្នុងបច្ចុប្បន្ន និងក្តៅក្រហាយ ដោយវិបាកក្នុងអនាគត ។ បទថា **ជលិតា កុថិតា កម្បិតា សន្តាបិតា** សេចក្តីថា ដែលភ្លើង ១១ កង ធ្វើឲ្យឆេះសន្ធោសន្ធៅហើយ ដុតពោលនូវបុគ្គលដែលស្រវឹងក្នុងកាមនោះ ។

បទថា **អសបត្តម្ហិ** បានដល់ កាលនេក្ខម្មៈដែលប្រាសចាកសត្រូវ ។ បទថា **សមានេ** ប្រែថា មាន ឬកើត ។ ព្រះនាងត្រាស់ថា **ពហុសបត្តា** រួបត្រាស់ថា **រាជគ្គិ** ជាដើម ដើម្បីសម្តែងភ័យដែលឲ្យមានសត្រូវច្រើន ព្រះនាងត្រាស់ឧបមាឲ្យឃើញថា កាមទាំងនោះមានភ័យដោយទូទៅអំពីព្រះរាជា ភ្លើង ចោរ ទឹក អ្នកទទួលមត៌ក ជាដើម ដែលមិនត្រូវគ្នា ។ បទថា **យេសុ វធពន្ធា** សេចក្តីថា ដាក់ទោស មានការធ្វើឲ្យស្លាប់ វាយដំច្រំបាក់ជាដើម និងការចងដោយច្រវាក់ជាដើមមានកាមជាហេតុមានក្នុងកាមពួកណា ។ បទថា **កាមេសុ** ជាពាក្យជួយធ្វើពាក្យដែលពោលទុកខាងមុខឲ្យជាក់ច្បាស់ ។ បណ្តាបទទាំងនោះ បទថា **ហិ** ត្រឹមតែជា និបាត ចុះក្នុងអត្ថថា ហេតុ ។ ព្រោះហេតុដែលសត្វទាំងនោះ រមែងសោយ គឺជួបនូវទុក្ខក្នុងការសម្លាប់ និងការចង ដូច្នោះ ទើបព្រះនាងសុមេធា ត្រាស់ថា **អសកាមា** អធិប្បាយថា ឈ្មោះថា កាមទាំងនេះ ជារបស់មិនល្អ អាក្រក់ ថោកថយ ម្យ៉ាងទៀត បាលីថា **អឃកាមា** ក៏មាន សេចក្តីក៏យ៉ាងនោះដូចគ្នា សេចក្តីពិត សព្ទថា **អឃ** ប្រែថា ថោកទាប ដូច **អឃ** សព្ទ ក្នុងប្រយោគថា **អឃលោ-**

**កិត្តិយោ** ឈ្មោះថា ស្ត្រីក្នុងលោកថោកទាប ។

បទថា **អាទីបិតា** ប្រែថា រុងរឿងហើយ ។ បទថា **តិណុក្កា** បាន ដល់ គប់ភ្លើងដែលធ្វើដោយស្មៅ ។ បទថា **ឌហន្តិ យេ តេ ឆ មុញ្ចន្តិ** សេចក្តីថា សត្វពួកណាមិនព្រមលែងកាមទាំងនោះ គឺប្រកាន់យ៉ាងមាំ គប់ ភ្លើងរមែងឆេះសត្វទាំងនោះ គឺដុតក្នុងបច្ចុប្បន្នផង ក្នុងអនាគតផង ។

បទថា **មា អប្បកស្ស ហេតុ** សេចក្តីថា សូមទ្រង់កុំលះបង់នូវលោ-កុត្តរសុខដ៏បរិបូណ៌ ឧឡារ និងប្រណីត ព្រោះហេតុនៃកាមសុខបន្តិចបន្តួច ដែលដូចជាទឹកដមរបស់ផ្កា ។ បទថា **មា បុថុលោមោវ ពលិសំ គិលិត្វា** សេចក្តីថា ទ្រង់មិនលះកាមទាំងឡាយហើយ ក៏នឹងក្តៅក្រហាយក្នុងកាលជា ខាងក្រោយ គឺចង្អៀតចង្អល់ក្នុងកាលជាខាងក្រោយ ដូចត្រីសាមញ្ញ លេប នូវផ្លែសន្ទូច ព្រោះចំណង់ក្នុងនុយ ដល់នូវការវិនាសដូច្នោះ ។

បទថា **សុនខោវ សង្ខលាពទ្ធោ** សេចក្តីថា ដូចឆ្កែដែលគេលាមខ្សែ គេយកខ្សែចងទុកត្រង់បង្គោល ក៏ទៅក្នុងទីដទៃមិនបាន វិលនៅក្នុងទីនោះឯង យ៉ាងណា ព្រះអង្គក៏ត្រូវកាមតណ្ហាចងទុកក៏យ៉ាងនោះ ឥឡូវនេះ សូមទ្រង់ បន្ទោបង់នូវចំណង់ក្នុងកាមទាំងឡាយ គឺសូមទ្រង់ទូន្មាននូវឥន្ទ្រិយឲ្យបាន ។ បទថា **កាហន្តិ ខុ តំ កាមា ឆាតា សុនខំវ ចណ្ឌាលា** សព្ទថា **ខុ** ត្រឹម តែជានិបាត សេចក្តីថា កាមទាំងនោះ នឹងធ្វើបុគ្គលនោះ ឲ្យដូចជាមនុស្ស ចណ្ឌាល ដែលហេវហត់ខ្លាំង បានសុនខមក ក៏ធ្វើឲ្យ ( សុនខ ) វិនាស បានដូច្នោះ ។

បទថា **អបរិមិតញ្ច ទុក្ខំ** បានដល់ ទុក្ខផ្លូវកាយក្នុងនរកជាដើម ដែលមិនមានប្រមាណ គឺមិនអាចកំណត់បានថា ប៉ុណ្ណេះ ឬប៉ុណ្ណោះ ។ បទថា **ពហូនិ ច ចិត្តទោមនស្សានិ** បានដល់ ទោមនស្សជាច្រើនមិនមែនតិចដែលបុគ្គលនោះបានទទួលក្នុងចិត្ត គឺទុក្ខផ្លូវចិត្ត ។ បទថា **អនុភោហិសិ** ប្រែថា នឹងសោយ ។ បទថា **កាមយុត្តោ** ប្រែថា ដែលប្រកបដោយកាមទាំងឡាយ គឺដែលមិនព្រមលះបង់កាមទាំងនោះ ។ បទថា **បដិនិស្សជ អទ្ធុវេ កាមេ** សេចក្ដីថា សូមទ្រង់ប្រាសចេញ គឺចៀសចាកកាមទាំងឡាយ ដែលមិនស្ថិតស្ថេរ មិនទៀងចុះ ។

បទថា **ជរាមរណព្យាធិគហិតា សព្វា សព្វត្ថ ជាតិយោ** ប្រកបសេចក្ដីថា ព្រោះហេតុដែលជាតិទាំងឡាយក្នុងភពជាដើមទាំងអស់មានជាតិថោកទាបជាដើម ត្រូវជរាមរណៈ និងព្យាធិចាប់ទុក មិនផុតអំពីជរាមរណៈ និងព្យាធិនោះ ព្រោះហេតុនោះ កាលព្រះនិព្វានដែលមិនមានជរាមាន កាមដែលមិនផុតអំពីការចាស់ជាដើមនឹងមានប្រយោជន៍អ្វីដល់ទ្រង់ ។

ព្រះនាងសុមេធា កាលប្រកាសទោសក្នុងកាម និងភពទាំងឡាយដោយបំណងសម្ដែងគុណរបស់ព្រះនិព្វានយ៉ាងនេះហើយ ឥឡូវនេះ កាលប្រកាសគុណរបស់ព្រះនិព្វានដែលកើតបានក្នុងទីនោះ ទើបពោលគាថា ២ ដោយន័យថា **ឥទមជរំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឥទមជរំ** សេចក្ដីថា ព្រះនិព្វាននេះប៉ុណ្ណោះ ឈ្មោះថាមិនជរា ព្រោះនិព្វានមិនមានការចាស់ និងព្រោះជាហេតុឲ្យបុគ្គលអ្នកដល់ព្រះនិព្វានមិនមានការចាស់ ។ ក្នុងបទថា

**ឥធមមរំ** នេះ ក៏មានន័យដូចគ្នា ។ ព្រះនាងសុមេធារួមបទទាំងពីរចូលគ្នា គឺមិនចាស់មិនស្លាប់ ដើម្បីសរសើរនូវព្រះនិព្វាន ។ បទថា **បធំ**[១] ឈ្មោះថា **បធំ** ព្រោះជាប្រការដែលអ្នកបំណងផុតចាកទុក្ខក្នុងវដ្តៈ គប្បីរៀរ ( បួស ) គប្បីដើរតាម ឈ្មោះថា **អសោកំ** ព្រោះមិនមានហេតុនៃសេចក្ដីសោក និង មិនមានសេចក្ដីសោក ឈ្មោះថា **អសបត្តំ** ព្រោះមិនមានធម៌ ដែលធ្វើឲ្យជាសត្រូវ ឈ្មោះថា **អសម្ពាធំ** ព្រោះមិនមានការចង្អៀតចង្អល់ដោយកិលេស ឈ្មោះថា **អខលិតំ** ព្រោះមិនមានធម៌ដែលរាប់បានថាខុសភាំងភាត់ ឈ្មោះ ថា **អភយំ** ព្រោះមិនមានភ័យ មានការតិះដៀលខ្លួនឯងជាដើម និងភ័យក្នុង វដ្តទុក្ខគ្រប់ប្រការ ឈ្មោះថា **និរុបតាបំ** ព្រោះមិនមានការក្ដៅក្រហាយដោយ ទុក្ខ ។ ពាក្យទាំងអស់នេះ ព្រះនាងសំដៅដល់អមតមហានិព្វាននោះឯង ។ សេចក្ដីពិត ព្រះនាងសុមេធានោះ ត្រាស់ពាក្យថា **ឥធំ** សម្ដែងព្រះនិព្វាននោះ តាមបែបដែលបានមកអំពីការស្ដាប់ជាដើម ដល់មនុស្សទាំងនោះ យ៉ាងជាក់ ច្បាស់ ហាក់ដូចព្រះនិព្វានកើតឡើងដល់នាង ។

បទថា **អធិគតមិធំ ពហូហិ អមតំ** សេចក្ដីថា អមតនិព្វាននេះដែល ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ដ៏ច្រើនអនេក រាប់មិនអស់បាន សម្រេច គឺត្រាស់ដឹង ធ្វើឲ្យប្រចក្សដល់ខ្លួនមកហើយ ។ ព្រះនាងមិនមែន ត្រាស់សំដៅដល់អមតនិព្វាន ដែលព្រះអរិយៈទាំងនោះសម្រេចហើយតែម្យ៉ាង ប៉ុណ្ណោះទេដោយពិតត្រាស់ដល់អមតនិព្វានដែលគួរបានក្នុងថ្ងៃនេះ គឺសម្រេច

---

១-បាលីក្នុងអដ្ឋកថាជា បទមសោកំ ទើបមានសព្ទថា បទំ នេះ ឯបិដកខ្មែរជា មិទមសោកំ ។

បាន ចូលដល់បាន ក្នុងឥឡូវនេះផងដែរ បើសួរថា អ្នកណាគួរបាន ទើបព្រះនាងត្រាស់ថា **យោ យោនិសោ បយុញ្ជតិ** ប្រកបសេចក្តីថា បុគ្គលណា តាំងនៅក្នុងឱវាទ ដែលព្រះសាស្តាប្រទាន ហើយព្យាយាមធ្វើនូវការព្យាយាមប្រពៃដោយឧបាយ អមតនិព្វានដែលបុគ្គលនោះគួរបាន ។ បទថា **ន ច សក្កា អយុជមានេន** សេចក្តីថា ឯបុគ្គលណា មិនព្យាយាមដោយឧបាយ បុគ្គលដែលមិនព្យាយាមនោះ ក៏មិនអាចបាន គឺមិនអាចបាន ទោះក្នុងកាលណាក៏ដោយ ។

បទថា **ឯវំ ភណតិ សុមេធា** សេចក្តីថា ព្រះនាងសុមេធារាជធីតាត្រាស់ធម្មកថាដែលសម្តែងនូវសេចក្តីសង្វេគ របស់ព្រះនាងក្នុងសង្សារវដ្ត ដែលជាចំណែកឲ្យកើតការនឿយណាយយ៉ាងនេះ គឺដូចពោលមកនេះឯង ។ បទថា **សង្ខារគតេ រតឹ អលភមានា** បានដល់ កាលទ្រង់មិនបាននូវសេចក្តីត្រេកអរក្រៃលែងក្នុងសង្ខារដែលប្រព្រឹត្តទៅត្រឹមបន្តិចបន្តួច ។ បទថា **អនុនេន្តី អនិករត្តំ** បានដល់ ដើម្បីលួងលោមព្រះបាទអនិករត្តៈ ។ បទថា **កេសេ ច ឆមំ ខិបិ** បានដល់ ព្រះនាងបោះនូវព្រះកេសា ដែលកាត់ដោយព្រះខ័នទៅលើផែនដី ។

បទថា **យាចតស្សា បិតរំ សោ** សេចក្តីថា ព្រះបាទអនិករត្តៈនោះទូលអង្វរព្រះបាទកោញ្ចៈ ព្រះជនករបស់ព្រះនាងសុមេធានោះ ។ បើសួរថា ទ្រង់ទូលអង្វរដូចម្តេច គឺព្រះបាទអនិករត្តៈត្រាស់ថា សូមព្រះអង្គអនុញ្ញាតបើកព្រះរាជបុត្រី ឈ្មោះនាងសុមេធាឲ្យបួសចុះ ដើម្បីឲ្យនាងឃើញនូវព្រះ

និព្វានដែលជាគុណជាតទៀងទាត់ អធិប្បាយថា សូមទ្រង់លែងព្រះនាងសុ-មេធារាជបុត្រីឲ្យបួសចុះ ដ្បិតថា ព្រះនាងបួសហើយ គង់នឹងឃើញវិមោក្ខនិងសច្ចៈ គឺឃើញព្រះនិព្វាន ដែលជាធម៌មិនវិបរិត ។

បទថា **សោកភយភីតា** បានដល់ ព្រះនាងខ្លាចភ័យក្នុងសង្សារវដ្តគ្រប់យ៉ាង ដែលជាហេតុឲ្យព្រាត់ប្រាសចាកញាតិជាដើម ព្រោះមានញាណខ្ពង់-ខ្ពស់ ។ បទថា **សិក្ខមានាយ** សេចក្តីថា ព្រះនាងកំពុងសិក្សា គឺនៅជាសិក្ខមានាក៏ធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ ព្រះនាងក៏ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តដែលជាផលដ៏ប្រសើរ ។

បទថា **អច្ឆរិយមព្ភុតំ តំ និព្វានំ អាសិ រាជកញ្ញាយ** សេចក្តីថា ការរំលត់ដោយឥតសេសសល់ចាកកិលេសទាំងឡាយដែលអស្ចារ្យ មិនធ្លាប់មានក៏មានដល់ព្រះនាង សុមេធា រាជបុត្រី ។ បើសួរថា ដឹងបានដូចម្តេចថាព្រះនាងសម្រេចអភិញ្ញា ៦ ឆ្លើយថា លុះកាលជាទីបំផុត ( ទៀបនឹងបរិនិព្វាន ) នាងបានសម្តែងនូវបុព្វេនិវាសចរិត ដូច្នេះ គឺគប្បីជ្រាបតាមពាក្យដែលព្រះនាងព្យាករចរិយាដែលទាក់ទងក្នុងជាតិមុនរបស់ព្រះនាង ក្នុងពេលចុងក្រោយ គឺក្នុងវេលាទៀបរំលត់ខន្ធបរិនិព្វាន ។

ដើម្បីសម្តែងបុព្វេនិវាសញ្ញាណ តាមដែលព្រះនាងព្យាករទុក ទើបព្រះនាងពោលថា កាលព្រះមានព្រះភាគទ្រង់ព្រះនាមកោនាគមនៈ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ភគវតិ កោណាគមនេ** សេចក្តីថា កាលព្រះសម្មាសម្ពុទ្ធព្រះនាមថា កោនាគមនៈទ្រង់កើតឡើងក្នុងលោក ។ បទថា

**សង្ឃារាមម្ហិ នវនិវេសម្ហិ** សេចក្តីថា កាលអារាមដែលខ្ញុំសាងឧទ្ទិសព្រះសង្ឃ សម្រេចថ្មីៗ ។ បទថា **សខិយោ តិស្សោ ជនិយោ វិហារទានំ អទាសិម្ហា** សេចក្តីថា យើង ៣ រូប គឺធនញ្ជានី ១ ខេមា ១ ខ្ញុំ ១ ជាសម្លាញ់នឹងគ្នា បានទាំគ្នាថ្វាយវិហារជាអារាមដល់សង្ឃ ។

បទថា **ទសក្ខត្តុំ សតក្ខត្តុំ** សេចក្តីថា ដោយអានុភាពរបស់វិហារទាន នោះ ខ្ញុំកើតក្នុងទេវតា ១០ ដង បន្ទាប់អំពីនោះ ក៏កើតក្នុងមនុស្ស ហើយ កើតក្នុងទេវតាទៀត ១០០ ដង ។ បន្ទាប់អំពីនោះ ក៏កើតក្នុងមនុស្ស រួច កើតក្នុងទេវតាទៀត អស់ ១ រយជាតិ ១០ ដង គឺ ១ ពាន់ បន្ទាប់ អំពីនោះ ក៏កើតក្នុងមនុស្សហើយកើតក្នុងទេវតាទៀត ១ រយ ១ រយ ដង គឺ ១ ម៉ឺនដង នឹងបាច់និយាយទៅថ្វីក្នុងពួកមនុស្ស គឺមិនមានគន្លងរបស់ ពាក្យដែលពោលក្នុងកាលកើតជាមនុស្សទាំងឡាយយ៉ាងនោះ អធិប្បាយថា ខ្ញុំកើតច្រើនពាន់ដង ។

បទថា **ទេវេសុ មហិទ្ធិកា អហុម្ហា** សេចក្តីថា ខ្ញុំមានឫទ្ធិច្រើន មាន អានុភាពច្រើន ក្នុងទេវតាទាំងឡាយ ពេលកើតក្នុងពួកទេវតានោះៗ ។ បទ ថា **មានុសកម្ហិ កោ បន វាទោ** បានដល់ មិនមានពាក្យដែលពោលដល់ ការដែលខ្ញុំមានឫទ្ធិច្រើន ក្នុងកាលបានអត្តភាពជាមនុស្ស ។ ឥឡូវនេះ ព្រះ នាងកាលសម្តែងភាពឧក្រិដ្ឋ នៃការមានឫទ្ធិច្រើន ក្នុងពេលបានអត្តភាពជា មនុស្សនោះឯង ទើបត្រាស់ថា **សត្តរតនស្ស មហេសី ឥត្ថិរតនំ អហំ អាសឹ** ជាដើម ក្នុងពាក្យនោះ រតនៈ ៧ ប្រការ មានចក្ករតនៈជាដើម មាន

ដល់ព្រះរាជានោះ ហេតុនោះ ព្រះរាជានោះមានឈ្មោះថា សត្តរតនៈ គឺមានរតនៈ ៧ ប្រការ បានដល់ ស្តេចចក្រពត្តិ ។ របស់ស្តេចចក្រពត្តិដែលមានរតនៈ ៧ ប្រការនោះ ។ ខ្ញុំបានជាឥត្ថីរតនៈទាំងឡាយ ព្រោះប្រកបដោយគុណយ៉ាងនេះ គឺវៀរចាកទោស ៦ ប្រកបដោយលម្អ ៥[១] មានព្រះឆវីវណ្ណជាងពណ៌សម្បុរមនុស្ស តែមិនដល់ពណ៌សម្បុរទិព្វជាដើម ។

បទថា **សោ ហេតុ** សេចក្តីថា កុសល គឺវិហារទានដែលខ្ញុំធ្វើដល់សង្ឃកាលព្រះមានព្រះភាគព្រះនាមថា កោនាគមនៈ ជាហេតុនៃទិព្វសម្បត្តិ តាមដែលពោលហើយ ។ បទថា **សោ បភវោ តំ មូលំ** ជាពាក្យពោលដល់ហេតុដោយអម ។ បទថា **សាវ សាសនេ ខន្តិ** សេចក្តីថា វត្ថុនោះឯងជាការអត់ធន់ ក្នុងការសម្លឹងធម៌ក្នុងសាសនារបស់ព្រះសាស្តានេះ ។ បទថា **តំ បឋមសមោធានំ** បានដល់ វត្ថុនោះឯងជាហេតុតាំងមាំគ្រាដំបូង គឺហេតុឲ្យបានមកជួបនឹងសាសនធម៌របស់ព្រះសាស្តា ។ ព្រោះព្រះនាងសុមេធាថេរីត្រេកអរក្នុងសាសនធម៌របស់ព្រះសាស្តា ទើបអាងយកវិហារធម៌នោះឯងថាជាហេតុឲ្យចូលជិតផលគឺព្រះនិព្វាន ។ ម្យ៉ាងទៀត ៤ គាថានេះ ( ចាប់ពី **ភគវតិ កោណាគមនេ** រហូតដល់ **តំ ធម្មតាយ និព្វានំ** ) ព្រះសង្គីតិ

---

១-ទោស ៦ ប្រការគឺ មិនខ្ពស់ពេក ១ មិនទាបពេក ១ មិនស្គមពេក ១ មិនធាត់ពេក ១ មិនខ្មៅពេក ១ មិនសពេក ១ ។ លម្អ ៥ គឺ កេសកល្យាណំ លម្អសក់ ១ មំសកល្យាណំ លម្អបបូរមាត់ ១ អដ្ឋិកល្យាណំ លម្អធ្មេញ ១ ឆវិកល្យាណំ លម្អសម្បុរថ្ងៃ ១ វយកល្យាណំ លម្អវ័យ ១ ។ ក្នុងអដ្ឋកថាសំយុត្តនិកាយ លោកដកលម្អសក់ចេញហើយបញ្ចូល នហារុកល្យាណំ គឺលម្អក្រចកជំនួសវិញ ។

កាចារ្យលើកឡើងកាន់សង្គាយនា ទុកក្នុងបាលីអបទានផងដែរ ទាំងនេះដើម្បីពន្លឺកសេចក្តីអបទានរបស់ព្រះថេរីឲ្យជាក់ច្បាស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាចុងក្រោយ ដូចតទៅនេះថា ។ បទថា **ឃរំ ករោន្តិ** សេចក្តីថា ក្នុងអត្តភាពមុនៗ និងក្នុងអត្តភាពនេះ ខ្ញុំធ្វើ គឺបដិបត្តិយ៉ាងណា សូម្បីជនដទៃក៏ធ្វើគឺបដិបត្តិយ៉ាងនោះ ។ សួរថា ជនពួកណាធ្វើយ៉ាងនេះ ទើបព្រះថេរីពោលថា **យេ សទ្ទហន្តិ វចនំ អនោមបញ្ញស្ស** សេចក្តីថា បុគ្គលពួកណាជឿនូវព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធដែលមានបញ្ញាពេញប្រៀប ព្រោះទ្រង់មានញេយ្យបរិយន្តិកញ្ញាណ ( គឺញាណដឹងវត្ថុដែលគួរដឹងដោយជុំវិញ ) ជឿមាំថា នេះយ៉ាងនេះ បុគ្គលទាំងនោះ រមែងធ្វើគឺបដិបត្តិយ៉ាងនេះ ឥឡូវនេះ ព្រះថេរីដើម្បីសម្តែងថា ព្រះតម្រាស់នោះ ត្រូវបដិបត្តិយ៉ាងឧក្រិដ្ឋ ទើបពោលថា **និព្ពិន្ទន្តិ ភវគតេ និព្ពិន្ទិត្វា វិរជ្ជន្តិ** បទនោះ មានសេចក្តីថា បុគ្គលពួកណា ជឿនូវព្រះតម្រាស់របស់ព្រះមានព្រះភាគតាមសេចក្តីពិត បុគ្គលទាំងនោះ កាលបដិបត្តិវិសុទ្ធិប្បដិបទារមែងនឿយណាយដោយវិបស្សនាបញ្ញា ក្នុងភពទាំងអស់ គឺសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ កាលនឿយណាយហើយតែងប្រាសចាកតម្រេក ដោយប្រការទាំងពួងដោយអរិយមគ្គ រមែងរួចផុតចាកភពទាំងអស់ អធិប្បាយថា កាលអរិយមគ្គដែលជាវិរាគធម៌ ដែលបុគ្គលសម្រេចហើយ បុគ្គលដែលសម្រេចនោះរមែងជាអ្នករួចផុតដោយពិតនោះឯង ។

# សរុបព្រះថេរី

ព្រះថេរីទាំងឡាយដូចពោលមកនេះ មានព្រះនាងថេរិកា ជាអង្គទី ១ មានព្រះនាងសុមេធាថេរីជាអង្គចុងក្រោយ ព្រះសង្គីតិកាចារ្យលើកឡើងកាន់សង្គាយនាទុកជាមួយគ្នា ក្នុងថេរីគាថានេះ ព្រោះជាគាថាបែបតែមួយ មានចំនួន ៧៣ រូប តែបើពោលដោយភាណវារៈ ថេរីគាថា មានចំនួន ៦០២ គាថា ព្រះថេរីទាំងឡាយនោះ ពោលដោយប្រភេទ ១ ជាសាវិការបស់ព្រះសម្មាសម្ពុទ្ធដូចគ្នា ជាព្រះអសេក្ខៈដូចគ្នា ជាអ្នកដកនូវកិលេសដូចរនុកបានហើយ ឆ្លងនូវកិលេសដែលដូចជាបន្ទាបានហើយ ដោយដកនូវសសរខឿនបានហើយ ដកនូវរនុកទ្វារបានហើយ ដាក់ចុះនូវទង់ហើយ ដាក់ចុះនូវភារៈបានហើយ ជាអ្នកប្រាសចាកកិលេសនិងសង្សារ ព្រោះតាំងនៅប្រចាំក្នុងអរិយវាស ១០[1]។ ពិតហើយ ព្រះថេរីទាំងនោះ ឈ្មោះថាមាន ១ ប្រភេទ ដោយន័យជាដើមយ៉ាងនេះ គឺជាអ្នកលះនូវអង្គ ៥ ប្រកបដោយអង្គ ៦ ជាអ្នកមានគ្រឿងរក្សា ១ ជាអ្នកមានអបស្សេនធម៌ ៤ ជាអ្នកបន្ទោបង់នូវសច្ចៈដោយចំពោះ ជាអ្នកស្វែងរកសមគួរ ជាអ្នកមានតម្រិះមិនល្អក់ ជាអ្នកមានកាយសង្ខារស្ងប់រម្ងាប់ហើយ ជាអ្នកមានចិត្តរួចផុតដោយល្អ ជាអ្នកមានបញ្ញារួចផុតដោយល្អ ។

ឈ្មោះថា មាន ២ ប្រភេទ មានភាពជាសាវិកាចំពោះមុខ ១ ជាសាវិកាកំបាំងមុខ ១ ពិតហើយ ព្រះថេរីពួកណា ដូចជាព្រះនាងមហាបជាបតិ-

---

១-អរិយវាស ១០ ប្រការនេះ មានក្នុងទសុត្តរសូត្រ ទីឃនិកាយបាដិកវគ្គ ឯណោះ បណ្ឌិតគប្បីជ្រាប ។

គោតមីជាដើមកើតក្នុងអរិយជាតិក្នុងកាលព្រះសាស្ដាគង់ព្រះជន្មាយុនៅឡើយ នេះឈ្មោះថា សាវិកាចំពោះមុខ ចំណែកព្រះថេរីពួកណា បានសម្រេចគុណវិសេសខាងក្រោយអំពីព្រះមានព្រះភាគទ្រង់រំលត់ខន្ធបរិនិព្វាន ព្រះថេរីទាំងនោះ ឈ្មោះថា សាវិកាកំបាំងមុខ ព្រោះកាលព្រះធម្មសរីរៈ ( គឺធម៌ ) របស់ព្រះសាស្ដានៅប្រចក្ស តែលោកមិនបានឃើញព្រះសរីរៈ ( រូបកាយ ) របស់ព្រះសាស្ដា ។

ម្យ៉ាងទៀត ព្រះថេរីមាន ២ ពួក គឺឧភតោភាគវិមុត្តិ ១ បញ្ញាវិមុត្តិ ១ តែព្រះថេរីដែលមកក្នុងបាលីនេះ ជាឧភតោភាគវិមុត្តិទាំងអស់ ។

ម្យ៉ាងទៀត មាន ២ ពួក គឺព្រះថេរីដែលមានអបទាន ១ មិនមានអបទាន ១ ។ ព្រះថេរីពួកណា មានអបទាន ពោលគឺការសន្សំបារមីដោយការធ្វើបុណ្យមក ក្នុងព្រះសម្មាសម្ពុទ្ធ ក្នុងព្រះបច្ចេកពុទ្ធ និងក្នុងសាវកពុទ្ធ ក្នុងជាតិមុន ព្រះថេរីទាំងនោះ ឈ្មោះថា ជាអ្នកមានអបទាន ព្រះថេរីពួកណា មិនមានអបទាននោះ ព្រះថេរីទាំងនោះ ឈ្មោះថា មិនមានអបទាន ។

ម្យ៉ាងទៀត មាន ២ ពួក គឺ បានឧបសម្បទាពីព្រះសាស្ដា ១ បានឧបសម្បទាអំពីសង្ឃ ១ ។ ពិតហើយ ព្រះនាងមហាបជាបតិគោតមី ជាអ្នកបានឧបសម្បទា ព្រោះទទួលនូវគរុធម៌ ឈ្មោះថា បាននូវឧបសម្បទា អំពីព្រះសាស្ដា ព្រោះបានឧបសម្បទាពីសម្នាក់ព្រះសាស្ដាដោយផ្ទាល់ ព្រះថេរីក្រៅអំពីនោះ ឈ្មោះថា បានឧបសម្បទាអំពីសង្ឃ ព្រះថេរីដែលបានឧបសម្បទាអំពីសង្ឃទាំងនោះ ក៏មាន ២ ពួក គឺ អ្នកបានឧបសម្បទាអំពីឯក-

គោសង្ឃ ១ បានឧបសម្បទាអំពីឧភតោសង្ឃ ១ បណ្ដាព្រះថេរីទាំងនោះ វៀរតែព្រះនាង មហាបជាបតិគោតមី ព្រះថេរីដែលជាម្ចាស់ក្សត្រិយសក្យៈ ៥០០ ចេញបួសជាមួយព្រះនាងមហាបជាបតិគោតមី ឈ្មោះថា បានឧប-សម្បទាអំពីឯកតោសង្ឃ ព្រោះបានឧបសម្បទាអំពីភិក្ខុសង្ឃតែមួយចំណែក ក្រៅអំពីនេះ ឈ្មោះថា បានឧបសម្បទាអំពីឧភតោសង្ឃ ព្រោះបានឧប-សម្បទាក្នុងសង្ឃទាំងពីរចំណែក ។

ក្នុងទីនេះ មិនបានពួក ២ សម្រាប់ឯហិភិក្ខុនី ដូចពួក ២ របស់ឯហិ-ភិក្ខុ ព្រោះហេតុអ្វី ព្រោះការឧបសម្បទាយ៉ាងនេះ ( ឯហិភិក្ខុនី ) របស់ភិក្ខុនីទាំងឡាយមិនមាន កាលបើយ៉ាងនោះ ពាក្យណាដែលព្រះនាងភទ្ទា-កុណ្ឌលកេសាថេរីពោលទុកថា

ក៏លុតជង្គង់ថ្វាយបង្គំ ប្រណម្យអញ្ជលី ក្នុងទីចំពោះព្រះភក្ត្រ ព្រះមានព្រះភាគបានត្រាស់ថា ម្នាលនាង នាងចូរមកចុះ ឧប-សម្បទានោះក៏សម្រេចដល់ខ្ញុំ ដូច្នេះ ។

( និងគាថាក្នុងអបទានាថា )

កាលនោះ ព្រះពុទ្ធជានាយក ដែលខ្ញុំសូមហើយ ទើបទ្រង់ត្រាស់ថា ម្នាលនាងដ៏ចម្រើន នាងចូរមកចុះ កាលនោះ ខ្ញុំក៏បានឧបសម្បទា ហើយបានឃើញទឹកបន្តិច ដូច្នេះ ។

ពាក្យនោះ ព្រះនាងភទ្ទាកុណ្ឌលកេសាថេរីពោលធ្វើអ្វី ឆ្លើយថា ពាក្យនេះ ព្រះថេរីមិនបានពោលសំដៅដល់ការឧបសម្បទាដោយជាឯហិភិក្ខុនីឧប-

សម្បទា តែពោលសំដៅដល់ថា ព្រះតម្រាស់របស់ព្រះសាស្ដាជាឧបសម្បទា របស់ខ្ញុំ ព្រោះព្រះតម្រាស់ជាហេតុឲ្យមានការឧបសម្បទា ។

ពិតយ៉ាងនោះ លោកពោលក្នុងអដ្ឋកថាថា ព្រះនាងភទ្ទាកុណ្ឌលកេសា-ថេរីពោលថា ព្រះមានព្រះភាគត្រាស់នឹងខ្ញុំថា ម្នាលនាងភទ្ទា ចូរនាងទៅកាន់គណៈភិក្ខុនី បព្វជ្ជាឧបសម្បទាក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ព្រះតម្រាស់របស់ព្រះសាស្ដានោះ បានជាឧបសម្បទារបស់ខ្ញុំ ព្រោះជាហេតុនៃការបួសរបស់ខ្ញុំតាមព្រះវាចានោះ បណ្ឌិតគប្បីជ្រាបថា លោកពណ៌នាអត្ថនៃអបទានគាថាដោយន័យយ៉ាងនេះឯង ។

កាលបើដូច្នោះពាក្យក្នុងភិក្ខុនីវិភង្គដែលថា ហៅថាភិក្ខុនី ព្រោះសម្រេចជាឯហិភិក្ខុនី សំដៅសេចក្ដីដូចម្ដេច ឆ្លើយថា ពាក្យនេះជាពាក្យប្រាប់ឲ្យដឹងថា កាលឧបសម្បទារបស់ភិក្ខុនីមិនមានបែបជាឯហិភិក្ខុនី ព្រោះភិក្ខុនីមិនមានឧបសម្បទាបែបនោះ ។ សួរថា បើដូច្នោះ ហេតុអ្វីទើបក្នុងវិភង្គចែកពាក្យថាឯហិភិក្ខុទុកដែរ ឆ្លើយថា ព្រោះអនុលោម តាមក្រសែរបស់ទេសនាន័យ ព្រោះអនុលោមតាមក្រសែនេះត្រូវមិនលះបង់នូវការដែលអាចមានក្នុងទីខ្លះ ។

ក្នុងអភិធម្មបិដក អង្គឈានមានក្នុងមនោធាតុនិទ្ទេស លោកមិនបានលើកឡើង ដោយអនុលោមតាមក្រសែនៃបញ្ចវិញ្ញាណ ព្រោះមិនមានសម្ដែងទុកក្នុងទីណាមួយឡើយ យ៉ាងណា ហទយវត្ថុក្នុងវត្ថុនិទ្ទេស ក្នុងអភិធម្មបិដកដូចគ្នា លោកមិនបានលើកឡើង ព្រោះកាន់យកសេចក្ដីដែលមិនមានក្នុងទីណាមួយ យ៉ាងណា ក្នុងបិតកប្បនិទ្ទេសក៏ដូចគ្នា ដូចលោកពោលទុក ( ក្នុង

អភិធម្មបុគ្គលបញ្ញត្តិ ) ថា

បុគ្គលនេះជាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតបត្តិផល ទុកជាវេលាភ្លើងឆេះកប្បនឹងមាន បើបុគ្គលនេះមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរ នេះហៅថាបុគ្គលជាឋិតកប្បី ដូច្នេះ ។

ក្នុងទីនេះ ក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា ឯហិភិក្ខុនីនេះ ជាពាក្យបម្រុងទុក ព្រោះលោកនាំពាក្យដែលមិនមាន មកទុកផងដែរ[១]។ សួរថា បើព្រះមានព្រះភាគ ត្រាស់ជាមួយស្រីណាម្នាក់ក៏បានដែលល្មមជាភិក្ខុនីថា នាងចូរជាភិក្ខុនីចុះ ត្រឹមតែប៉ុណ្ណេះ ក៏សម្រេចជាភិក្ខុនី ហេតុអ្វីទើបទ្រង់មិនត្រាស់ឆ្លើយថា ព្រោះស្រីទាំងនោះ មិនបានធ្វើអធិការទុក ដើម្បីជាភិក្ខុនី ចំណែកអាចារ្យពួកណាប្រាប់ហេតុផលថា ព្រោះមិនបានសន្សំនូវការជិតស្និទ្ធ ហើយអធិប្បាយថា ព្រោះភិក្ខុទាំងឡាយប៉ុណ្ណោះនៅជិតព្រះសាស្តាបាន ចូលគាល់បានសព្វកាល ព្រោះហេតុនោះ ទើបភិក្ខុទាំងនោះ សមគួរនឹងត្រាស់ហៅថាឯហិភិក្ខុ ចំណែកភិក្ខុនីទាំងឡាយមិនដូច្នោះឡើយ គប្បីយល់ថា នោះត្រឹមតែជាការយល់ឃើញរបស់អាចារ្យទាំងនោះ ទើបសរុបសេចក្តីបានថាកើត ( ជាឯហិភិក្ខុ ) ព្រោះនៅជិតឬនៅឆ្ងាយព្រះសាស្តា ឬព្រោះសមនិងមិនសម ។

---

១-ពាក្យថា ហៅថា ភិក្ខុនី ព្រោះសម្រេចជាឯហិភិក្ខុនី នេះ លោកគ្រាន់តែលើកមកពោលទុកដូចពាក្យ ក្នុងបុគ្គលបញ្ញត្តិ ទោះបីមិនមាន បុគ្គលសម្រេចសោតាក្នុងវេលាភ្លើងប្រល័យកប្បក៏លោកនៅតែលើកមកពោលទុកដូចគ្នា ។

សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងឥតិវុត្តក ) ថា

ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុចាប់ជាយសង្ឃាដិ( នៃតថាគត ) ហើយដើរតាមអំពីខាងក្រោយៗដាក់ជើង ( ខ្លួន ) ត្រង់កន្លែងជើង ( នៃតថាគត ) តែថាភិក្ខុនោះជាអ្នកច្រើនដោយអភិជ្ឈា មានតម្រេកដ៏ក្លៀវក្លាក្នុងកាម មានចិត្តព្យាបាទ មានសេចក្តីត្រិះរិះក្នុងចិត្តដ៏អាក្រក់ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនមាំមួន មានចិត្តភ្ញាក់ផ្អើល មានឥន្ទ្រិយជាប្រក្រតី ភិក្ខុនោះឈ្មោះថា នៅឆ្ងាយអំពីតថាគតដោយពិត ឯតថាគតក៏ឈ្មោះថានៅឆ្ងាយអំពីភិក្ខុនោះដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះមិនឃើញធម៌ កាលបើមិនឃើញធម៌ហើយ ឈ្មោះថា មិនឃើញតថាគត ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះ នៅក្នុងទីមួយចំនួនរយយោជន៍ តែភិក្ខុនោះ មិនជាអ្នកច្រើនដោយអភិជ្ឈា មិនមានតម្រេកដ៏ក្លៀវក្លាក្នុងកាម មិនមានចិត្តព្យាបាទ មិនមានសេចក្តីត្រិះរិះក្នុងចិត្តដ៏អាក្រក់ ប្រុងស្មារតី ដឹងខ្លួន មានចិត្តមាំមួនមានចិត្តមូលនឹងធឹងក្នុងអារម្មណ៍តែមួយ សង្រួមឥន្ទ្រិយ ភិក្ខុនោះឈ្មោះថា នៅជិតតថាគតដោយពិត ទាំងតថាគតក៏ឈ្មោះថា នៅជិតភិក្ខុនោះដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។

ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះឃើញធម៌ កាលបើឃើញធម៌ហើយ ឈ្មោះថា ឃើញតថាគត ដូច្នេះ ។

ព្រោះហេតុនោះ ភាពដែលបុគ្គលនៅជិត និងនៅឆ្ងាយព្រះសាស្តាដោយទីកន្លែង មិនមែនជារឿងសំខាន់ឡើយ ឯភិក្ខុនីទាំងឡាយ មិនគួរបួសបែបឯហិភិក្ខុនីនោះ ។ ព្រោះភិក្ខុនីទាំងនោះ មិនបានសន្សំបារមីទុក ដោយហេតុនោះ ទើបខ្ញុំពោលថា ក្នុងទីនេះមិនបានពួក ២ សម្រាប់ឯហិភិក្ខុនី ។ ព្រះថេរីមាន ២ ពួក ដូចពោលមកនេះ ។

ព្រះថេរីមាន ៣ ពួក គឺអគ្គសាវិកា ១ មហាសាវិកា ១ បកតិសាវិកា ១ ។ ក្នុង ៣ ពួកនោះ ព្រះថេរី ២ រូប គឺខេមា ១ ឧប្បលវណ្ណា ១ ឈ្មោះថា អគ្គសាវិកា ព្រះថេរីជាព្រះខីណាស្រពគ្រប់រូបធ្វើសីលវិសុទ្ធិជាដើម ឲ្យដល់ព្រម មានចិត្តតាំងមាំក្នុងសតិប្បដ្ឋាន ៤ ចម្រើនពោជ្ឈង្គ ៧ តាមសេចក្តីពិត ធ្វើកិលេសឲ្យអស់ទៅមិនសេសសល់តាមលំដាប់មគ្គ តាំងនៅក្នុងអគ្គផលក៏ពិត តែព្រះថេរីទាំងឡាយឈ្មោះថា ជាសាវិកា ក៏ព្រោះជាសាវិកា ជាអ្នកធំក្រៃលែងដោយគុណទាំងឡាយ មានសីលជាដើម ព្រោះមានគុណក្នុងសន្តានផ្សេងគ្នាដោយភាពជាអ្នកធំដោយអភិនីហារនិងភាពជាធំដោយបុព្វប្បយោគ ( សេចក្តីព្យាយាមខាងដើម ) ដូចគ្នា នឹងចែកសាវិកជា ២ ពួក តាមការផ្សេងគ្នានៃការនាំដែលជាចំណែកខាងដើម គឺជាទិដ្ឋិប្បត្តបុគ្គលព្រោះរួចផុតដោយសទ្ធា ១ ជាឧភតោភាគវិមុត្តព្រោះរួចផុតដោយបញ្ញា ១ ដូច្នោះ ព្រះខីណាសវថេរីទាំង ២ រូបនោះ ឈ្មោះថា អគ្គសាវិកា ក៏ព្រោះជាបុគ្គល

តាំងនៅក្នុងភាពដ៏លើស ដោយគុណសព្វយ៉ាង ដោយវិសេស ដោយការសម្រេចបារមីដ៏ឧក្រិដ្ឋ ក្នុងបញ្ញានិងសមាធិតាមលំដាប់ ដោយសម្មាបដិបត្តិដែលកើតមកអស់កាលយូរមិនលះបង់ដោយគោរព ព្រោះជាអ្នកមានអភិនីហារកើតអំពីសម្មាទិដ្ឋិនិងសម្មាសមាធិនោះ ដែលហេតុអំពីអានុភាពនៃការធ្វើដែលល្អក្រៃលែងរបស់សម្មាទិដ្ឋិនិងសម្មាសមាធិដែលជាធុរៈដោយជាប្រធានក្នុងពោធិបក្ខិយធម៌ទាំងនោះឯង ។ ឯថេរី មានព្រះមហាបជាបតិគោតមីថេរីជាដើម ឈ្មោះថា មហាសាវិកា ព្រោះជាសាវិកាធំដោយគុណវិសេសដែលបានអំពីភាពជាអ្នកធំក្រៃលែងដោយអភិនីហារនិងអំពីជាអ្នកធំក្រៃលែងដោយបុព្វប្បយោគ ព្រះថេរីក្រៅអំពីនេះ មានព្រះនាងថេរិកា ព្រះនាងតិស្សា ព្រះនាងវីរា ព្រះនាងធីរា ជាដើម ឈ្មោះថាជាបកតិសាវិកា ព្រោះមិនមានភាពជាធំដោយអភិនីហារជាដើម ។

បកតិសាវិកាទាំងនោះ មិនមានចំនួនស្មើនឹងអគ្គសាវិកា និងមហាសាវិកាដែលពិតគប្បីជ្រាបថា បកតិសាវិកាទាំងនោះមានចំនួនច្រើនរយច្រើនពាន់ ។

ព្រះថេរីមាន ៣ ពួក បានចែកជាអគ្គសាវិកាជាដើម ដូចពោលមកដូច្នេះ ។

មាន ៣ ពួក ដោយចាត់តាមវិមោក្ខដូចជាសុញ្ញតវិមោក្ខជាដើម ។ មាន ៤ ពួក ដោយចែកតាមបដិបទាជាដើម ។ មាន ៥ ពួក ដោយចែកតាមការក្រៃលែងដោយឥន្ទ្រិយជាដើម ។ម្យ៉ាងទៀត មាន ៥ ពួក ដោយចែកតាមបដិបទាជាដើម ។

មាន ៦ ពួក មានអនិមិត្តវិមុត្តិជាដើម ។ មាន ៧ ពួក ដោយចែកតាម

អធិមុត្តិជាដើម ។ មាន ៨ ពួក ដោយចែកតាមធុរបដិបទាជាដើម ។ មាន ៩ ពួក និង ១០ ពួក ដោយចែកតាមវិមុត្តិ ។ ព្រះថេរីទាំងនោះ ចែកដោយប្រភេទធុរៈ តាមដែលពោលហើយក៏មាន ២០ ពួក ។ ចែកដោយបដិបទាក៏មាន ៤០ ពួក ចែកតាមប្រភេទនៃបដិបទា តាមប្រភេទនៃធុរៈ ក៏មាន ៨០ ពួក ចែកតាមចំណែកបន្តិចបន្តួចនៃសុញ្ញតវិមុត្តិជាដើម ក៏មាន ២៤០ ពួក ចែកដោយចំណែកបន្តិចបន្តួចនៃបុគ្គលដែលក្រៃលែងដោយវីរិយៈជាដើម ក៏មាន ១២០០ ពួក បណ្ឌិតគប្បីជ្រាបថា ព្រះថេរីទាំងនោះផ្សេងគ្នា ច្រើនប្រភេទដោយគុណរបស់ខ្លួននោះឯង ដោយប្រការដូច្នេះ សេចក្តីសង្ខេបក្នុងថេរីគាថានេះ មានដូចពោលមកនេះ ។ ឯសេចក្តីពិស្តារ គប្បីកាន់យកតាមន័យដូចពោលហើយក្នុងអដ្ឋកថាថេរគាថាខាងដើមនោះឯង ។

**អដ្ឋកថាសុមេធាថេរីគាថា ចប់**

**ថេរីគាថា មហានិបាត ចប់**

ក្នុងថេរីគាថានេះ រួមជាគាថា ៤៩៤ ព្រះថេរី ៧១ រូប សុទ្ធតែជាអ្នកអស់អាសវៈពោលហើយ ។

# និគមគាថា

សាវកទាំងឡាយណា មានព្រះសទ្ធម្មដល់ព្រមជាបុត្តកើតអំពីទ្រូង កើតអំពីព្រះឱស្ឋ ជាធម្មទាយាទ ដែលធម្មនិម្មិតរបស់ព្រះសាស្តា ដែលជាធម្មរាជា ជាអ្នកបរិបូណ៌ដោយគុណ មានសីលជាដើម ជាអ្នកសម្រេចកិច្ចហើយ មិនមានអាសវៈ ជាព្រះថេរៈក៏មាន ដូចជា ព្រះសុភូតិជាដើម ជាព្រះថេរីក៏មាន ដូចជា ព្រះនាងថេរិកាជាដើម សាវកទាំងនោះ ពោលគាថាណាទុកដោយវិធីព្យាករព្រះអរហត្តជាដើម ព្រះមហាថេរៈទាំងឡាយដែលជាអ្នកនឹងធឹង ប្រមូលចងក្រងគាថាទាំងនោះទុកជាមួយគ្នា លើកឡើងជាពួក ហៅថា ថេរគាថា ថេរីគាថា ។ ដើម្បីប្រកាសសេចក្តីរបស់ថេរគាថា និងថេរីគាថាទាំងនោះ ខ្ញុំអាស្រ័យន័យ ដែលមកក្នុងអដ្ឋកថាដើម ទើបផ្តើមរចនាពាក្យអធិប្បាយឯណា ពាក្យអធិប្បាយនោះ ប្រកាសអត្ថដ៏កំពូលក្នុងថេរគាថា និងថេរីគាថានោះតាមការសមគួរក្នុងទីនោះ ដោយឈ្មោះឈ្មោះថា បរមត្ថទីបនី មានវិនិច្ឆ័យមិនខ្វះកន្ទះ ដល់នូវការចប់ដោយបាលីប្រមាណ ៩២ ភាណវារ ។ ហេតុនោះ បុណ្យនោះ ដែលខ្ញុំរចនាគម្ពីរ បរមត្ថទីបនីនេះ បានជួបហើយ ដោយអានុភាពនៃបុណ្យនោះ សូមសត្វទាំងពួង ឈមចុះក្នុងសាសនារបស់ព្រះលោកនាថ ដោយបដិបទា មានសីលជាដើមដ៏បរិសុទ្ធ រហូតបានជាភាគីគឺចំណែកនៃវិមុត្តិរស ។

សូមសាសនារបស់ព្រះសម្មាសម្ពុទ្ធ តាំងនៅស្ថិតស្ថេរក្នុងលោក សូមសព្វសត្វមានសេចក្តីគោរពក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធជានិច្ចនិរន្តរ៍ ។

សូមភ្លៀងធ្លាក់តាមរដូវកាល សូមស្តេចផែនដីជាអ្នកត្រេកអរជានិច្ច ក្នុង

ព្រះសទ្ធម្ម សូមទ្រង់គ្រប់គ្រងសត្វលោកដោយធម៌ហោង ។

គាថាពណ៌នានៃថេរីគាថា ខ្ញុំធម្មបាលត្ថេរ ជាអាចារ្យក្នុងពទរតិត្ថវិហារ គឺវត្តកំពង់ពុទ្ធរចនា ចប់ដោយប្រការដូច្នេះ ។៚

## បរមត្ថទីបនី អដ្ឋកថាថេរីគាថា ចប់បរិបូណ៌

# ក្បាលទី ៤៤

# សុត្តន្តបិដក បាលីប្រែ -៥៧

## សន្ទឹកបង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| អញ្ញតរាថេរីគាថា | ២ |
| អដ្ឋកថា អញ្ញតរាថេរីគាថា | ៣ |
| មុត្តាថេរីគាថា | ១៧ |
| អដ្ឋកថា មុត្តាថេរីគាថា | ១៧ |
| បុណ្ណាថេរីគាថា | ២១ |
| អដ្ឋកថា បុណ្ណាថេរីគាថា | ២១ |
| តិស្សាថេរីគាថា | ២៤ |
| អដ្ឋកថា តិស្សាថេរីគាថា | ២៤ |
| អញ្ញតរាតិស្សាថេរីគាថា | ២៦ |
| ធីរាថេរីគាថា | ២៦ |
| អញ្ញតរាធីរាថេរីគាថា | ២៦ |
| មិត្តាថេរីគាថា | ២៧ |
| ភទ្រាថេរីគាថា | ២៧ |
| ឧបសមាថេរីគាថា | ២៧ |
| អដ្ឋកថា អញ្ញតរាតិស្សាថេរីគាថាជាដើម | ២៨ |
| មុត្តាថេរីគាថា | ៣៣ |
| អដ្ឋកថា មុត្តាថេរីគាថា | ៣៣ |
| ធម្មទិន្នាថេរីគាថា | ៣៧ |
| អដ្ឋកថា ធម្មទិន្នាថេរីគាថា | ៣៧ |

វិសាខាថេរីគាថា .......... .......... .......... .......... ...... ៤៦

អដ្ឋកថា វិសាខាថេរីគាថា .......... .......... .......... .......... ..... ៤៦

សុមនាថេរីគាថា .......... .......... .......... .......... .... ៤៨

អដ្ឋកថា សុមនាថេរីគាថា .......... .......... .......... .......... .... ៤៨

ឧត្តរាថេរីគាថា .......... .......... .......... .......... .... ៥០

អដ្ឋកថា ឧត្តរាថេរីគាថា .......... .......... .......... .......... ..... ៥០

សុមនាវុឌ្ឍបព្វជិតាថេរីគាថា .......... .......... .......... .......... ...... ៥៣

អដ្ឋកថា សុមនាវុឌ្ឍបព្វជិតាថេរីគាថា ........ .......... .......... .......... ..... ៥៣

ធម្មាថេរីគាថា .......... .......... .......... .......... ...... ៥៥

អដ្ឋកថា ធម្មាថេរីគាថា .......... .......... .......... .......... ...... ៥៥

សង្ឃាថេរីគាថា .......... .......... .......... .......... ...... ៥៧

អដ្ឋកថា សង្ឃាថេរីគាថា .......... .......... .......... .......... ...... ៥៧

## ទុកនិបាត ថេរីគាថា

នន្ទាថេរីគាថា .......... .......... .......... .......... ...... ៥៩

អដ្ឋកថា នន្ទាថេរីគាថា .......... .......... .......... .......... ...... ៥៩

ជន្តាថេរីគាថា .......... .......... .......... .......... ...... ៦៥

អដ្ឋកថា ជន្តាថេរីគាថា .......... .......... .......... .......... ...... ៦៥

អញ្ញតរាថេរីភិក្ខុនីអបរិញ្ញាតាគាថា .......... .......... .......... .......... .... ៦៨

អដ្ឋកថា សុមង្គលមាតុថេរីគាថា .......... .......... .......... .......... ...... ៦៨

អឌ្ឍកាសីថេរីគាថា .......... .......... .......... .......... ....... ៧២

អដ្ឋកថា អឌ្ឍកាសីថេរីគាថា .......... .......... .......... .......... ....... ៧២

ចិត្តាថេរីគាថា .......... .......... .......... .......... ........ ៧៨

អដ្ឋកថា ចិត្តាថេរីគាថា .......... .......... .......... .......... ........ ៧៨

មេត្តិកាថេរីគាថា .......... .......... .......... .......... ...... ៨២
អដ្ឋកថា មេត្តិកាថេរីគាថា .......... .......... .......... .......... ..... ៨២
មិត្តាថេរីគាថា .......... .......... .......... .......... ....... ៨៥
អដ្ឋកថា មិត្តាថេរីគាថា .......... .......... .......... .......... ....... ៨៥
អភយមាតាថេរីគាថា .......... .......... .......... .......... ...... ៩១
អដ្ឋកថា អភយមាតាថេរីគាថា .......... .......... .......... .......... ....... ៩១
អភយាថេរីគាថា .......... .......... .......... .......... ....... ៩៦
អដ្ឋកថា អភយាថេរីគាថា .......... .......... .......... .......... ....... ៩៦
សាមាថេរីគាថា .......... .......... .......... .......... ....... ១០២
អដ្ឋកថា សាមាថេរីគាថា .......... .......... .......... .......... ....... ១០២

## ថេរីគាថា តិកនិបាត

អញ្ញតរាសាមាថេរីគាថា .......... .......... .......... .......... ....... ១០៥
អដ្ឋកថា អញ្ញតរាសាមាថេរីគាថា .......... .......... .......... .......... ....... ១០៥
ឧត្តមាថេរីគាថា .......... .......... .......... .......... ......... ១០៩
អដ្ឋកថា ឧត្តមាថេរីគាថា .......... .......... .......... .......... ......... ១០៩
អញ្ញតរាឧត្តមាថេរីគាថា .......... .......... .......... .......... ........ ១១៥
អដ្ឋកថា អញ្ញតរាឧត្តមាថេរីគាថា .......... .......... .......... .......... ......... ១១៥
ទន្តិកាថេរីគាថា .......... .......... .......... .......... .......... ១១៩
អដ្ឋកថា ទន្តិកាថេរីគាថា .......... .......... .......... .......... .......... ១១៩
ឧព្វិរីថេរីគាថា .......... .......... .......... .......... .......... .. ១២៤
អដ្ឋកថា ឧព្វិរីថេរីគាថា .......... .......... .......... .......... .......... .. ១២៤
សុក្កាថេរីគាថា .......... .......... .......... .......... .......... ១៣២
អដ្ឋកថា សុក្កាថេរីគាថា .......... .......... .......... .......... .......... ១៣២

សេលាថេរីគាថា .......... .......... .......... .......... .......... ១៥១
អដ្ឋកថា សេលាថេរីគាថា .......... .......... .......... .......... .......... ១៥១
សោមាថេរីគាថា .......... .......... .......... .......... .......... ១៥៩
អដ្ឋកថា សោមាថេរីគាថា .......... .......... .......... .......... .......... ១៥៩

## ថេរីគាថា ចតុក្កនិបាត

ភទ្ទាកាបិលានីថេរីគាថា .......... .......... .......... .......... .......... ១៥៣
អដ្ឋកថា ភទ្ទាកាបិលានីថេរីគាថា .......... .......... .......... .......... .......... ១៥៣

## ថេរីគាថា បញ្ចកនិបាត

អញ្ញតរាភិក្ខុនីអប្បញ្ញាតាថេរីគាថា ...... .......... .......... .......... .......... . ១៦៧
អដ្ឋកថា អញ្ញតរាថេរីគាថា .......... .......... .......... .......... .......... ១៦៨
វិមលាបុរាណគណិកាថេរីគាថា .......... .......... .......... .......... .......... ១៧១
អដ្ឋកថា វិមលាថេរីគាថា .......... .......... .......... .......... .......... ១៧១
សីហាថេរីគាថា .......... .......... .......... .......... .......... .. ១៧៦
អដ្ឋកថា សីហាថេរីគាថា .......... .......... .......... .......... .......... . ១៧៦
នន្ទាថេរីគាថា .......... .......... .......... .......... .......... ១៨១
អដ្ឋកថា សុន្ទរីនន្ទាថេរីគាថា .......... .......... .......... .......... .......... ១៨១
នន្ទុត្តរាថេរីគាថា .......... .......... .......... .......... .......... ១៩៤
អដ្ឋកថា នន្ទុត្តរាថេរីគាថា .......... .......... .......... .......... .......... ១៩៤
មិត្តកាលីថេរីគាថា .......... .......... .......... .......... . ១៩៩
អដ្ឋកថា មិត្តកាលីថេរីគាថា .......... .......... .......... .......... .. ១៩៩
សកុលាថេរីគាថា .......... .......... .......... .......... .. ២០៤
អដ្ឋកថា សកុលាថេរីគាថា .......... .......... .......... .......... .. ២០៤
សោណាថេរីគាថា .......... .......... .......... .......... . ២១៣

អដ្ឋកថា សោណាថេរីគាថា .......... .......... .......... .......... . ២១៣

អត្ថរបស់ រូប សព្ទ .......... .......... .......... .......... . ២១៨

អត្ថរបស់ សមុស្សយ សព្ទ .......... .......... .......... .......... ... ២១៩

កុណ្ឌលាថេរីគាថា .......... .......... .......... .......... ... ២២២

អដ្ឋកថា កុណ្ឌលកេសាថេរីគាថា .......... .......... .......... .......... .. ២២២

បដាចារាថេរីគាថា .......... .......... .......... .......... ... ២៣៩

អដ្ឋកថា បដាចារាថេរីគាថា .......... .......... .......... .......... .. ២៣៩

តឹសមត្តាថេរីគាថា .......... .......... .......... .......... ... ២៥៦

អដ្ឋកថា តឹសមត្តាថេរីគាថា .......... .......... .......... .......... ... ២៥៧

ចន្ទាថេរីគាថា .......... .......... .......... .......... .... ២៦១

អដ្ឋកថា ចន្ទាថេរីគាថា .......... .......... .......... .......... ... ២៦១

## ថេរីគាថា ឆក្កនិបាត

បញ្ចសតមត្តាថេរីគាថា .......... .......... .......... .......... ... ២៦៥

អដ្ឋកថា បញ្ចសតមត្តាថេរីគាថា .......... .......... .......... .......... .. ២៦៦

វាសិដ្ឋីថេរីគាថា .......... .......... .......... .......... .. ២៧១

អដ្ឋកថា វាសិដ្ឋីថេរីគាថា .......... .......... .......... .......... .. ២៧២

ខេមាថេរីគាថា .......... .......... .......... .......... ... ២៧៦

អដ្ឋកថា ខេមាថេរីគាថា .......... .......... .......... .......... ... ២៧៧

សុជាតាថេរីគាថា .......... .......... .......... .......... .. ២៩៥

អដ្ឋកថា សុជាតាថេរីគាថា .......... .......... .......... .......... .. ២៩៥

អនោបមាថេរីគាថា .......... .......... .......... .......... . ២៩៩

អដ្ឋកថា អនោបមាថេរីគាថា .......... .......... .......... .......... . ២៩៩

មហាបជាបតិគោតមីថេរីគាថា .......... .......... .......... .......... . ៣០៣

អដ្ឋកថា មហាបជាបតិគោតមីថេរីគាថា .......... .......... .......... .......... ៣០៤
គុត្តាថេរីគាថា .......... .......... .......... .......... ៣៣៨
អដ្ឋកថា គុត្តាថេរីគាថា .......... .......... .......... .......... . ៣៣៨
វិជយាថេរីគាថា .......... .......... .......... .......... .. ៣៤៣
អដ្ឋកថា វិជយាថេរីគាថា .......... .......... .......... .......... . ៣៤៣

## ថេរីគាថា សត្តកនិបាត

ឧត្តរាថេរីគាថា .......... .......... .......... .......... . ៣៤៦
អដ្ឋកថា ឧត្តរាថេរីគាថា .......... .......... .......... .......... .. ៣៤៧
ចាលាថេរីគាថា .......... .......... .......... .......... . ៣៥០
អដ្ឋកថា ចាលាថេរីគាថា .......... .......... .......... .......... . ៣៥១
ឧបចាលាថេរីគាថា .......... .......... .......... .......... ... ៣៥៦
អដ្ឋកថា ឧបចាលាថេរីគាថា .......... .......... .......... .......... .. ៣៥៧

## ថេរីគាថា អដ្ឋកនិបាត

សីសូបចាលាថេរីគាថា .......... .......... .......... .......... . ៣៦២
អដ្ឋកថា សីសូបចាលាថេរីគាថា .......... .......... .......... .......... . ៣៦៣

## ថេរីគាថា នវកនិបាត

វឌ្ឍមាតាថេរីគាថា .......... .......... .......... .......... . ៣៦៩
អដ្ឋកថា វឌ្ឍមាតុថេរីគាថា .......... .......... .......... .......... .......... ៣៧០

## ថេរីគាថា ឯកាទសកនិបាត

កីសាគោតមីថេរីគាថា .......... .......... .......... .......... .......... ៣៧៧
អដ្ឋកថា កីសាគោតមីថេរីគាថា .......... .......... .......... .......... .......... ៣៧៨

## ថេរីគាថា ទ្វាទសកនិបាត

ឧប្បលវណ្ណាថេរីគាថា .......... .......... .......... .......... .......... ៣៩៥

អដ្ឋកថា ឧប្បលវណ្ណាថេរីគាថា .......... .......... .......... .......... .......... ៣៩៧

## ថេរីគាថា សោឡសកនិបាត

បុណ្ណិកាថេរីគាថា .......... .......... .......... .......... .......... ៤២៩

អដ្ឋកថា បុណ្ណាថេរីគាថា .......... .......... .......... .......... ......... ៤៣១

## ថេរីគាថា វីសតិនិបាត

អម្ពបាលីថេរីគាថា .......... .......... .......... .......... ............ ៤៤៣

អដ្ឋកថា អម្ពបាលីថេរីគាថា .......... .......... .......... .......... ........... ៤៤៦

រោហិណីថេរីគាថា .......... .......... .......... .......... .......... ៤៦១

អដ្ឋកថា រោហិណីថេរីគាថា .......... .......... .......... .......... ........... ៤៦៤

ចាបាថេរីគាថា .......... .......... .......... .......... ......... ៤៧៦

អដ្ឋកថា ចាបាថេរីគាថា .......... .......... .......... .......... ........... ៤៧៩

សុន្ទរីថេរីគាថា .......... .......... .......... .......... ........... ៤៩៤

អដ្ឋកថា សុន្ទរីថេរីគាថា .......... .......... .......... .......... ........... ៤៩៨

សុភាកម្មារធីតាថេរីគាថា .......... .......... .......... .......... ........... ៥១៣

អដ្ឋកថា សុភាកម្មារធីតាថេរីគាថា ........ .......... .......... .......... .......... ៥១៦

## ថេរីគាថា តឹសនិបាត

សុភាជីវកម្ពវនិកាថេរីគាថា .......... .......... .......... .......... ........ ៥៣៤

អដ្ឋកថា សុភាជីវកម្ពវនិកាថេរីគាថា .......... .......... .......... .......... ..... ៥៣៩

## ថេរីគាថា ចត្តាឡីសនិបាត

ឥសិទាសីថេរីគាថា .......... .......... .......... .......... .... ៥៦៤

អដ្ឋកថា ឥសិទាសីថេរីគាថា .......... .......... .......... .......... ..... ៥៧០

## ថេរីគាថា មហានិបាត

*សុមេធាថេរីគាថា* .......... .......... .......... .......... .... ៥៨៩

*អដ្ឋកថា សុមេធាថេរីគាថា* .......... .......... .......... .......... .... ៥៩៩